# អដ្ឋកថា ព្រះសុត្តន្តបិដក

## អង្គុត្តរនិកាយ

ឈ្មោះ

## មនោរថបូរណី

## ភាគ ៤០

## បឋមភាគ

ពុទ្ធសករាជ ២៥៥៧

អធិប្បាយ

ក្នុងឯកនិបាត-ទុកនិបាត មាន ១៣ វគ្គ

និងឯតទគ្គបុគ្គល ៤១ អង្គ

ព្រះអដ្ឋកថាកែសេចក្តី ៧២៦ សូត្រ

# អដ្ឋកថា ព្រះសុត្តន្តបិដក

## អង្គុត្តរនិកាយ

ឈ្មោះ

## មនោរថបូរណី

## ភាគ ៤០

## បឋមភាគ

ពុទ្ធសករាជ ២៥៥៧

អធិប្បាយ

ក្នុងឯកនិបាត–ទុកនិបាត មាន ១៣ វគ្គ

និងឯតទគ្គបុគ្គល ៤១ អង្គ

ព្រះអដ្ឋកថាកែសេចក្តី ១២៦ សូត្រ

# អង្គុត្តរនិកាយបឋមភាគ

## រួមមាន

## ឯកធម្មាទិបាលិ មាន ១៣ វគ្គ

## ព្រះអដ្ឋកថាកែសេចក្តី ៨៥ សូត្រ

## និង

## ឯតទគ្គបាលិ មាន ៤ វគ្គ ៤១ អង្គ

១ ប្រវត្តិព្រះអញ្ញាកោណ្ឌញ្ញៈ
២ ប្រវត្តិព្រះសារីបុត្ត និង
ប្រវត្តិព្រះមហាមោគ្គល្លាន
៣ ប្រវត្តិព្រះមហាកស្សបៈ
៤ ប្រវត្តិព្រះអនុរុទ្ធ
៥ ប្រវត្តិព្រះភទ្ទិយកាឡិគោធាបុត្ត
៦ ប្រវត្តិព្រះលកុណ្ឌកភទ្ទិយៈ
៧ ប្រវត្តិព្រះបិណ្ឌោលភារទ្វាជៈ
៨ ប្រវត្តិព្រះបុណ្ណមន្តានីបុត្ត
៩ ប្រវត្តិព្រះមហាកច្ចាយនៈ
១០ ប្រវត្តិព្រះចុល្លបន្ថកៈ
១១ ប្រវត្តិព្រះមហាបន្ថកៈ
១២ ប្រវត្តិព្រះសុភូតិ
១៣ ប្រវត្តិព្រះសុភូតិ
១៤ ប្រវត្តិព្រះរេវតៈ
១៥ ប្រវត្តិព្រះកង្ខារេវតៈ
១៦ ប្រវត្តិព្រះសោណកោឡិវិសៈ
១៧ ប្រវត្តិព្រះសោណកុដិកណ្ណ
១៨ ប្រវត្តិព្រះសីវលី
១៩ ប្រវត្តិព្រះវក្កលិ
២០ ប្រវត្តិព្រះរាហុល
២១ ប្រវត្តិព្រះរដ្ឋបាល
២២ ប្រវត្តិព្រះកោណ្ឌធានៈ
២៣ ប្រវត្តិព្រះវង្គីសៈ
២៤ ប្រវត្តិព្រះឧបសេនវង្គន្តបុត្ត
២៥ ប្រវត្តិព្រះទព្វមល្លបុត្ត

២៦ ប្រវត្តិព្រះបិលិន្ទវច្ឆ
២៧ ប្រវត្តិព្រះពាហិយទារុចិរិយ
២៨ ប្រវត្តិព្រះកុមារកស្សបៈ
២៩ ប្រវត្តិព្រះមហាកោដ្ឋិតៈ
៣០ ប្រវត្តិព្រះអានន្ទ
៣១ ប្រវត្តិព្រះឧរុវេលកស្សបៈ
៣២ ប្រវត្តិព្រះកាឡុទាយី
៣៤ ប្រវត្តិព្រះពក្កុលៈ
៣៤ ប្រវត្តិព្រះសោភិតៈ
៣៥ ប្រវត្តិព្រះឧបាលី
៣៦ ប្រវត្តិព្រះនន្ទកៈ
៣៧ ប្រវត្តិព្រះនន្ទៈ
៣៨ ប្រវត្តិព្រះមហាកប្បិនៈ
៣៩ ប្រវត្តិព្រះសាគតៈ
៤០ ប្រវត្តិព្រះរាធៈ
៤១ ប្រវត្តិព្រះមោឃរាជ

# ស្រៈនិសស្យ៍យ

# *Signes et accents:*



# ស្រះពេញតួ

## Voyelles.

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| រ៉ូម Romain | a | ā | i | ī | u | ū | e | o |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | ອະ | ອາ | ອິ | ອີ | ອຸ | ອູ | ເອ | ໂອ |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ

# Consonnes:

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| រូម Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ກ | ຂ | ຄ | ຆ | ງ |
| សិង្ហ Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| [illegible] Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຊ | ຍ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| ឡូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្រ | ឆ្ន | ជ្ជ | ឈ្យ | ញ្ញ |
| ឡាទ Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຊ | ຍ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| ឡូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຍ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

# ពាក្យផ្ដើម

*ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖*

***សុត្ត*** *បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។*

***គេយ្យ*** *បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។*

***វេយ្យាករណ*** *គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។*

***គាថា*** *គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។*

***ឧទាន*** *គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។*

***ឥតិវុត្តក*** *គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។*

***ជាតក*** *គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។*

***អព្ភូតធម៌*** *គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។*

***វេទល្ល*** *គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស ព្រមទាំងបាននូវសេចក្ដី*

វែកញែក និងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្ដែងថា ៖

ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្ដីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្ដែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគមាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្ដែងធម៌មានហេតុផល ដែលអ្នកស្ដាប់អាចពិចារណាឃើញតាមសេចក្ដីពិតបាន ។

៣ ទ្រង់សម្ដែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្ដែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្ដាប់នូវពុទ្ធោវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្ដែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្ដាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្ដីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្ដីដែលលំបាកយល់ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្ដីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ សុត្តានុលោម គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្តីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង បុព្វាចារ្យជំនាន់ក្រោយ ៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្តែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាម អាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយ ច្រើន ទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមក ហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះ ខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹង ក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះនឹងមានឱកាសដែលយល់ខុស និយាយ ខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ

របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្ដីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្ដីសង្ខេបថា ក្នុងទីបំផុតនៃការសម្ដែងយមកប្បាដិហារ្យ ព្រះមានព្រះ-ភាគជាម្ចាស់ ស្ដេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិច្ឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្ម-កថាដល់ទេវបរិស័ទ លុះទ្រង់សម្ដែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្ដែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណាប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បី ខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្តាប់ វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរស របស់ ព្រះចៅសុសុនាគៈធ្វើជាសម្លាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គ ក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយ គ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែល ជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហា សង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះ ម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយ- វាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈ នោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យ ទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការ ដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជា

ប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិ-សាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្ដាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូល អាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថាសង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និ-កាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទ យ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយ-វាទ ១១ និកាយនេះ រួមទីងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្ដី ត្រកូលអាចារ្យ ១៨ ក្ដី ជាឈ្មោះ របស់និកាយដែលពោលមកហើយទាំងនោះឯង ។ ម្យ៉ាងទៀត បណ្ដានិកាយទាំង ១៨ នោះបណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្តែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្តេញចេញហើយ បានពួកដទៃទៀត ទើបផ្តើមតាំងជាគណាចារ្យថ្មី ។

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

---

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បាន ប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាន នាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរ អដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យ នោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការ កសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធាឃោសាចារ្យជាអ្នកស្រុក ជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ ពុទ្ធគយាដែនមគធៈ ជិត ស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍- សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅ កាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បាន ឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នមានសតិបញ្ញា ច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហា ព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែល សមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះ បោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធ-គយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិ-សម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កា-ទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចអគ្គសាវ័ក)

ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះ ហើយព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់ កំពង់ផែក្រុងលង្កាសម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្វះ ( សិរិកុថៈ ) ខ្វះ ( សិរិកូដ្ឋៈ ) ខ្វះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្តាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថា ជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃ ដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនា

សិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបាន រចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្តីយ៉ាងល្អប្រសើរ រហូតដល់ ព្រះសង្ឃលង្កាទទួលស្តាប់នូវសេចក្តីជំនាញរបស់លោក តាមប្រវត្តិបាននិយាយ ថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតា បានបណ្តាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បាន រចនាជាថ្មីម្តងទៀត ទេវតាក៏បណ្តាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្តង ទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរ ទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ ប្រៀបធៀបគ្នាហើយមិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬ ដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណាទីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បី សម្តែងសេចក្តីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្តីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គ នេះ ជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡៈមកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្តាប់កិត្តិគុណរបស់ លោក ស្តេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ

ហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធានឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ ជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរិយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា

ព្រះមហិន្ទត្ថេរៈនាំមកពីជម្ពូទីប ហើយរចនាទុកជាភាសាសីហឡៈឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរិយៈ ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋកថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តបាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលបញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលទៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្តីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុផាត

លោកគ្រូវិនិយាចារ្យ គាំ អ៊ីវ

ឧបាសក ក្អាត ហ៊ិន

ឧបាសក ទុំ ទូន

ឧបាសក ជឹម ជំនិត

ឧបាសក សន ម៉ារឌី

ឧបាសក អ៊ុំ រ៉ៃយ៉ា

ឧបាសក សោម រតនៈ

ឧបាសក ម៉ៅ ផុន

ឧបាសិកា ថាប់ លឿម

ឧបាសិកា ប៊ុត សុម៉ាលី

ឧបាសិកា ពូ ហ៊ាង

ឧបាសិកា ប៉ែន រមណី

ឧបាសក នាក់ ម៉ៅ

ឧបាសក ហុក សឹងហួត

ឧបាសក កើត ទិត្យ

ឧបាសក ហាយ ចំរើន

ឧបាសក សុក្រ ហ៊ត

ឧបាសក សំ ឆាយ

ឧបាសក ជា ស៊ីបាន

ឧបាសិកា ហាយ សារ៉ាត់

ឧបាសិកា យស សម្បត្តិ

ឧបាសិកា ប៊ុត សេដាដួង

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

| | | |
|---|---|---|
| ព្រះភិក្ខុអគ្គទិន្នោ | នូវ ប៉ូវ៉ា | ប្រធានអាស្រម |
| ព្រះភិក្ខុចិត្តរក្ខិតោ | សំ សម្បត្តិ | ធម្មាចារ្យ |
| ព្រះភិក្ខុធម្មប្បញ្ញោ | ឆុំ សារឿន | ធម្មាចារ្យ |
| ព្រះភិក្ខុវរធម្មោ | ផុត តៅ | ធម្មាចារ្យ |

សាមណេរ កោវិនោ ឡោះ សូវៀត សមណសិស្ស សាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

ឧបាសក ហាយ ចំរើន

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.000 ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ ៖-

**ឧទ្ទិសថ្វាយ និងគោរពជូន:**

-ព្រះមហាវីរក្សត្រ និងមហាវីរក្សត្រិយានី

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុផាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា !.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌

ឈ្មោះធម៌ | ទំព័រ


**រូបាទិវគ្គទី ១**

| | |
|---|---|
| អារម្ភកថា | ០១ |
| អដ្ឋកថាសូត្រទី ១ | ០៥ |
| អដ្ឋកថាសូត្រទី ២ | ៤៣ |
| អដ្ឋកថាសូត្រទី ៣ | ៤៨ |
| អដ្ឋកថាសូត្រទី ៤ | ៤៩ |
| អដ្ឋកថាសូត្រទី ៥ | ៥០ |

**នីវរណប្បហានវគ្គទី ២**

| | |
|---|---|
| អដ្ឋកថាសូត្រទី ១ | ៥៦ |
| អដ្ឋកថាសូត្រទី ២ | ៦៣ |
| អដ្ឋកថាសូត្រទី ៣ | ៦៤ |
| អដ្ឋកថាសូត្រទី ៤ | ៦៦ |
| អដ្ឋកថាសូត្រទី ៥ | ៦៧ |
| អដ្ឋកថាសូត្រទី ៦ | ៦៨ |
| អដ្ឋកថាសូត្រទី ៧ | ៩០ |
| អដ្ឋកថាសូត្រទី ៨ | ៩៣ |
| អដ្ឋកថាសូត្រទី ៩ | ៩៧ |
| អដ្ឋកថាសូត្រទី ១០ | ៩៩ |

**អកម្មនិយវគ្គទី ៣**

| | |
|---|---|
| អដ្ឋកថាសូត្រទី ១ | ១០១ |
| អដ្ឋកថាសូត្រទី ២ | ១០២ |
| អដ្ឋកថាសូត្រទី ៣ | ១០៣ |
| អដ្ឋកថាសូត្រទី ៤ | ១០៤ |

អដ្ឋកថាសូត្រទី ៥-៦ ១០៥
អដ្ឋកថាសូត្រទី ៧-៨ ១០៦
អដ្ឋកថាសូត្រទី ៩ ១០៧
អដ្ឋកថាសូត្រទី ១០ ១០៨

**អនន្តវគ្គទី ៤**

អដ្ឋកថាសូត្រទី ១ ១០៩
អដ្ឋកថាសូត្រទី ២ ១១០
អដ្ឋកថាសូត្រទី ៣ ១១១
អដ្ឋកថាសូត្រទី ៤ ១១២
អដ្ឋកថាសូត្រទី ៥-៦ ១១៣
អដ្ឋកថាសូត្រទី ៧-៨ ១១៤
អដ្ឋកថាសូត្រទី ៩-១០ ១១៥

**បណិហិតអច្ឆវគ្គទី ៥**

អដ្ឋកថាសូត្រទី ១ ១១៦
អដ្ឋកថាសូត្រទី ២ ១១៨
អដ្ឋកថាសូត្រទី ៣ ១២០
អដ្ឋកថាសូត្រទី ៤ ១២១
អដ្ឋកថាសូត្រទី ៥ ១២២
អដ្ឋកថាសូត្រទី ៦ ១២៥
អដ្ឋកថាសូត្រទី ៧ ១២៦
អដ្ឋកថាសូត្រទី ៨ ១២៧
អដ្ឋកថាសូត្រទី ៩ ១២៩
អដ្ឋកថាសូត្រទី ១០ ១៣១

**អច្ឆរាសង្ឃាតវគ្គទី ៦**

អដ្ឋកថាសូត្រទី ១ ១៣២
អដ្ឋកថាសូត្រទី ២ ១៣៦
អដ្ឋកថាសូត្រទី ៣ ១៣៨

អដ្ឋកថាសូត្រទី ៤ ១៥៣
អដ្ឋកថាសូត្រទី ៥ ១៥៤
អដ្ឋកថាសូត្រទី ៦ ១៥៥
អដ្ឋកថាសូត្រទី ៧ ១៥៧
អដ្ឋកថាសូត្រទី ៨ ១៥៨
អដ្ឋកថាសូត្រទី ៩ ១៥៩
អដ្ឋកថាសូត្រទី ១០ ១៦០

**វីរិយារម្ភាទិវគ្គទី ៧**

អដ្ឋកថាសូត្រទី ១ ១៦១
អដ្ឋកថាសូត្រទី ២ ១៦២
អដ្ឋកថាសូត្រទី ៣ ១៦៣
អដ្ឋកថាសូត្រទី ៤ ១៦៩
អដ្ឋកថាសូត្រទី ៥ ១៧០
អដ្ឋកថាសូត្រទី ៦-៧ ១៧៥
អដ្ឋកថាសូត្រទី ៨ ១៧៦
អដ្ឋកថាសូត្រទី ៩ ១៧៧
អដ្ឋកថាសូត្រទី ១០ ១៧៨

**កល្យាណមិត្តតាទិវគ្គទី ៨**

អដ្ឋកថាសូត្រទី ១ ១៧៩
អដ្ឋកថាសូត្រទី ២ ១៨០
អដ្ឋកថាសូត្រទី ៣ ១៨១
អដ្ឋកថាសូត្រទី ៤ ១៨២
អដ្ឋកថាសូត្រទី ៥ ១៨៣
អដ្ឋកថាសូត្រទី ៦ ១៨៤
អដ្ឋកថាសូត្រទី ៧ ១៨៦
អដ្ឋកថាសូត្រទី ៨ ១៨៨
អដ្ឋកថាសូត្រទី ៩ ១៨៩

អដ្ឋកថាសូត្រទី ១០ ១៩០

**បមាទាទិវគ្គទី ៩**

អដ្ឋកថាសូត្រទី ១ ១៩១

អដ្ឋកថាសូត្រទី ២ ១៩២

**អដ្ឋកថាវគ្គទី ១០** ១៩៣

**អដ្ឋកថាអធម្មវគ្គទី ១១** ២០៩

**អដ្ឋកថាអនាបត្តិវគ្គទី ១២** ២១០

**អដ្ឋកថាឯកបុគ្គលវគ្គទី ១៣**

អដ្ឋកថាសូត្រទី ១ ២១២

អដ្ឋកថាសូត្រទី ២ ២៤៦

អដ្ឋកថាសូត្រទី ៣ ២៤៧

អដ្ឋកថាសូត្រទី ៤ ២៥១

អដ្ឋកថាសូត្រទី ៥ ២៥២

អដ្ឋកថាសូត្រទី ៦ ជាដើម ២៥៦

**អដ្ឋកថាឯតទគ្គវគ្គ**

**អដ្ឋកថាឯតទគ្គវគ្គទី ១**

អដ្ឋកថា កថាដើម ២៦៩

ប្រវត្តិព្រះអញ្ញាកោណ្ឌញ្ញៈ ២៨៨

ប្រវត្តិព្រះសារីបុត្ត និងព្រះមហាមោគ្គល្លាន ៣១១

ប្រវត្តិព្រះមហាកស្សបៈ ៣៣៤

ប្រវត្តិព្រះអនុរុទ្ធ ៣៧២

ប្រវត្តិព្រះភទ្ទិយកាឡិគោធាបុត្ត ៣៨៧

ប្រវត្តិព្រះលកុណ្ឌកភទ្ទិយ ៣៩១

ប្រវត្តិព្រះបិណ្ឌោលភារទ្វាជៈ ៣៩៥

ប្រវត្តិព្រះបុណ្ណមន្តានីបុត្ត ៤០០

ប្រវត្តិព្រះមហាកច្ចាយនៈ ៤០៩

## អដ្ឋកថាឯតទគ្គវគ្គទី ២

ប្រវត្តិព្រះចុល្លបន្ថកៈ និងព្រះមហាបន្ថកៈ ៤១៧
ប្រវត្តិព្រះសុភូតិ ៤៣៥
ប្រវត្តិព្រះសុភូតិ ៤៣៧
ប្រវត្តិព្រះរេវតៈ ៤៤២
ប្រវត្តិព្រះកង្ខារេវតៈ ៤៥៣
ប្រវត្តិព្រះសោណកោឡិវិសៈ ៤៥៦
ប្រវត្តិព្រះសោណកុដិកណ្ណ ៤៦៤
ប្រវត្តិព្រះសីវលី ៤៧៤
ប្រវត្តិព្រះវក្កលិ ៤៨៤

## អដ្ឋកថាឯតទគ្គវគ្គទី ៣

ប្រវត្តិព្រះរាហុល ៤៨៩
ប្រវត្តិព្រះរដ្ឋបាល ៤៩០
ប្រវត្តិព្រះកុណ្ឌធានៈ ៥០៥
ប្រវត្តិព្រះវង្គីសៈ ៥១៥
ប្រវត្តិព្រះឧបសេនវង្គន្តបុត្ត ៥២២
ប្រវត្តិព្រះទព្វមល្លបុត្ត ៥២៦
ប្រវត្តិព្រះបិលិន្ទវច្ឆៈ ៥៣២
ប្រវត្តិព្រះពាហិយទារុចិរិយៈ ៥៣៧
ប្រវត្តិព្រះកុមារកស្សបៈ ៥៤៤
ប្រវត្តិព្រះមហាកោដ្ឋិតៈ ៥៤៨

## អដ្ឋកថាឯតទគ្គវគ្គទី ៤

ប្រវត្តិព្រះអានន្ទ ៥៥០
ប្រវត្តិព្រះឧរុវេលកស្សបៈ ៥៦៨
ប្រវត្តិព្រះកាឡុទាយី ៥៧៤
ប្រវត្តិព្រះពាកុលៈ ៥៨០

| | |
|---|---|
| ប្រវត្តិព្រះសោភិតៈ | ៥៨៩ |
| ប្រវត្តិព្រះឧបាលិ | ៥៩១ |
| ប្រវត្តិព្រះនន្ទកៈ | ៥៩៣ |
| ប្រវត្តិព្រះនន្ទៈ | ៥៩៧ |
| ប្រវត្តិព្រះមហាកប្បិន | ៦០៣ |
| ប្រវត្តិព្រះសាគតៈ | ៦១៤ |
| ប្រវត្តិព្រះរាធៈ | ៦១៩ |
| ប្រវត្តិព្រះមោឃរាជ | ៦២៥ |

# ព្រះសុត្តន្តបិដក
# អង្គុត្តរនិកាយ ឯកនិបាត-ទុកនិបាត
# ឈ្មោះ
# មនោរថបូរណី
# បឋមភាគ
# ភាគ ៤០

## អដ្ឋកថា ឯកនិបាត
### អារម្ភកថា

*ខ្ញុំ (ព្រះពុទ្ធឃោសាចារ្យ) សូមនមស្ការព្រះសុគត ទ្រង់រួចផុតចាកគតិ ទ្រង់មានព្រះទ័យត្រជាក់ដោយព្រះករុណា ទ្រង់មានផនឹត គឺ មោហៈ ដែលពន្លឺនៃបញ្ញាកម្ចាត់ហើយ ជាគ្រូរបស់លោក ព្រមទាំងមនុស្ស និងទេវតា ។*

*ព្រះពុទ្ធទ្រង់ចម្រើន និងធ្វើឲ្យច្បាស់នូវគុណដែលជាព្រះពុទ្ធ ចូលដល់ធម៌ណាដែលប្រាសចាកមន្ទិល ខ្ញុំសូមនមស្ការធម៌ដ៏កំពូលនោះ ។*

*ខ្ញុំម្ចាស់សូមនមស្ការ ដោយសិរសាដល់ព្រះអរិយសង្ឃ*

*ទាំង ៨ ដែលជាឱរសរបស់ព្រះតថាគត ជាអ្នកញាំញីនូវកងទ័ព*

*មារ ។*

*បុណ្យណាសម្រេចដោយការនមស្ការព្រះរតនត្រ័យរបស់ខ្ញុំ អ្នកមានចិត្តជ្រះថ្លាដូចពោលមកដូច្នេះ ខ្ញុំជាអ្នកដែលអានុភាពនៃបុណ្យនោះ ជួយកម្ចាត់អន្តរាយហើយ នឹងប្រែភាសាសីហឡចេញពីគម្ពីរអដ្ឋកថា ដែលព្រះអរហន្តអ្នកស្ទាត់ជំនាញ ៥០០ អង្គ សង្គាយនាមកពីដើម និងសង្គាយនាតៗ មក សូម្បីខាងក្រោយ ព្រះមហិន្ទត្ថេរនាំមកកាន់កោះសីហឡ: ចាត់ចែងធ្វើទុកជាភាសាសីហឡ: ដើម្បីឲ្យជាប្រយោជន៍ដល់អ្នកកោះ ហើយលើកឡើងកាន់ភាសាដែលគួររីករាយគួរដល់ន័យនៃព្រះបាលី គឺ ធ្វើជាភាសាមគធ: មិនជំទាស់លទ្ធិសម័យ ដែលប្រាសចាកទោសរបស់ពួកព្រះថេរៈប្រទីបនៃថេរវង្ស អ្នកនៅក្នុងមហាវិហារ ដែលមានវិនិច្ឆ័យល្អិតល្អន់ល្អ លះបង់សេចក្ដីដដែលៗ ចេញហើយ ប្រកាសសេចក្ដីនៃគម្ពីរអង្គុត្តរនិកាយដ៏ប្រសើរ ដែលប្រដាប់ដោយ ឯកនិបាត ទុកនិបាត តិកនិបាត ជាដើម ដើម្បីឲ្យអត្ថជាក់ច្បាស់ សម្រាប់ឲ្យកើតបដិភាណដ៏វិចិត្រ ដល់ពួកព្រះធម្មកថិកដែលល្អ ដែលខ្ញុំកាលពោលខ្លឹមសារនៃគម្ពីរទីឃនិកាយ និងគម្ពីរមជ្ឈិមនិកាយ ជាខាងក្រោយ ទើបពណ៌នារឿងរ៉ាវរបស់ព្រះនគរទាំងឡាយ មាន*

ក្រុងសាវត្ថីជាដើម ឲ្យសាធុជនត្រេកអរ និងដើម្បីឲ្យព្រះធម៌តាំងនៅយូរអង្វែងបានឮថា រឿងពួកណា ដែលពោលទុកក្នុងគម្ពីរទាំងពីរនោះ (ទីឃ , មជ្ឈិម) ក៏ពិស្តារក្នុងគម្ពីរអង្គុត្តរនិកាយនេះ ខ្ញុំនឹងមិនពោលរឿងទាំងនោះឲ្យពិស្តារក្រៃលែងឡើងទៀតទេ តែសម្រាប់សូត្រទាំងឡាយ សេចក្តីពួកណា វៀរចាករឿងរ៉ាវចេញនឹងមិនជាក់ច្បាស់ ខ្ញុំនឹងពោលរឿងរ៉ាវទាំងឡាយទុក ដើម្បីសេចក្តីជាក់ច្បាស់នៃខ្លឹមសារទាំងនោះ ។

ព្រះពុទ្ធវចនៈនេះ គឺ សីលកថា ធុតង្គធម៌ កម្មដ្ឋានទាំងអស់ សេចក្តីពិស្តាររបស់ឈាន និងសមាបត្តិ ដែលប្រកបដោយវិធីបដិបត្តិ អភិញ្ញាទាំងអស់ ពាក្យវិនិច្ឆ័យទាំងអស់ដែលជាប់ដោយបញ្ញា ខន្ធ ធាតុ អាយតនៈ ឥន្ទ្រិយ អរិយសច្ច ៤ បច្ចយាការទេសនា មាននយ័ដែលបរិសុទ្ធល្អិតល្អន់ ដែលមិនផុតចាកលំនាំព្រះបាលី និងវិបស្សនាភាវនា តែព្រោះហេតុដែលព្រះពុទ្ធវចនៈដែលពោលមកហើយទាំងអស់ ខ្ញុំពោលហើយក្នុងវិសុទ្ធិមគ្គយ៉ាងហ្មត់ចត់ល្អ ដូច្នោះ ក្នុងទីនេះខ្ញុំនឹងមិនពិចារណារឿងទាំងអស់នេះឲ្យក្រៃលែងឡើយ ព្រោះបករណ៍ពិសេសឈ្មោះថា វិសុទ្ធិមគ្គនេះ ដែលខ្ញុំរចនាទុកហើយនោះ តាំងនៅកណ្តាលនៃនិកាយទាំង ៤ នឹងប្រកាសសេចក្តីតាមដែលបានពោលទុកក្នុងនិកាយទាំង ៤ នោះ ដូច្នោះសូមសាធុជនទាំងឡាយ ចូរកាន់យកបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គនោះ ព្រម

*ដោយអដ្ឋកថានេះ ហើយនឹងជ្រាបសេចក្ដីតាមដែលអាស្រ័យគម្ពីរអង្គុត្តរនិកាយនេះឯង ។*

# រូបាទិវគ្គទី ១

## អដ្ឋកថាសូត្រទី ១

[១] ក្នុងគម្ពីរទាំងនោះ គម្ពីរឈ្មោះថា អង្គុត្តរនិកាយ មាន ១១ និបាត គឺ ឯកនិបាត ទុកនិបាត តិកនិបាត ចតុក្កនិបាត បញ្ចកនិបាត ឆក្កនិបាត សត្តកនិបាត អដ្ឋកនិបាត នវកនិបាត ទសកនិបាត ឯកាទសកនិបាត ។

*ពោលដោយសូត្រ អង្គុត្តរនិកាយ មាន ៩,៥៥៧ សូត្រ បណ្ដានិបាតនៃអង្គុត្តរនិកាយនោះ ឯកនិបាត ជានិបាតដើម ។ បណ្ដាសូត្រ ចិត្តបរិយាយសូត្រ ជាសូត្រដើម ។ ពាក្យនិទានសូម្បីនៃសូត្រនោះមានបទថា* ***ឯវំមេ សុតំ*** *ជាដើម ព្រះអានន្ទពោលទុកក្នុងកាលមហាសង្គីតិគ្រាដំបូងជាដើម ក៏មហាសង្គីតិគ្រាដំបូងនោះ ពោលទុកពិស្ដារហើយក្នុងខាងដើមនៃអដ្ឋកថាទីឃនិកាយ ឈ្មោះថា សុមង្គលវិលាសិនី ព្រោះដូច្នោះ មហាសង្គីតិគ្រាដំបូងនោះ គប្បីជ្រាបដោយពិស្ដារក្នុងអដ្ឋកថាទីឃនិកាយនោះឯង ។*

*ក៏បទថា* ***ឯវំ*** *ក្នុងពាក្យនិទានវចនៈថា* ***ឯវំមេ សុតំ*** *ជាដើម ជាបទនិបាត បទថា* ***មេ*** *ជាបទនាម បទថា* ***វិ*** *ក្នុងបទថា* ***សាវត្ថិយំ វិហរតិ*** *នេះ ជាបទឧបសគ្គ ។ បទថា* ***ហរតិ*** *ជាបទអាខ្យាត ។ គប្បីជ្រាបការចែកបទដោយន័យនេះមុន ។*

តែកាលពោលអំពីអត្ថ មុនដំបូង ឯវំ ស័ព្ទ មានអត្ថច្រើនប្រភេទ មានជាដើម ដូចជា **ឧបមា** ប្រៀបធៀប, **ឧបទេស** ណែនាំ, **សម្បហំសនៈ** លើកតម្កើង, **គរហណៈ** តិះដៀល, **វចនសម្បដិគ្គហណៈ** ទទួលពាក្យ, **អាការ** អាការ, **និទស្សនៈ** គួយ៉ាង និង **អវធារណៈ** សេចក្ដីជាក់, ពិតយ៉ាងនោះ ឯវំ ស័ព្ទនោះ មកក្នុង **ឧបមា** ប្រៀបធៀប ក្នុងពាក្យជាដើមយ៉ាងនេះថា **ឯវំ ជាតេន មច្ចេន កត្តព្វំ កុសលំ ពហុំ** សត្វដែលកើតមកហើយ គួរធ្វើកុសលឲ្យច្រើន ដូច្នោះ ។ មកក្នុង **ឧបទេសៈ** ណែនាំ ក្នុងពាក្យជាដើមថា **ឯវន្តេ អភិក្កមិតព្វំ ឯវំ បដិក្កមិតព្វំ** លោកគប្បីឈានទៅយ៉ាងនេះ គប្បីថយត្រឡប់យ៉ាងនេះ ។ មកក្នុង **សម្បហំសនៈ** លើកតម្កើង ក្នុងពាក្យជាដើមថា **ឯវមេតំ ភគវា ឯវមេតំ សុគត** បពិត្រព្រះដ៏មានព្រះភាគ ប្រការនោះជាយ៉ាងនោះ បពិត្រព្រះសុគត ប្រការនោះជាយ៉ាងនោះ ។ មកក្នុង **គរហណៈ** តិះដៀល ក្នុងពាក្យជាដើមយ៉ាងនេះថា **ឯវមេវ បនាយំ វសលី យស្មឹ វា តស្មឹ វា តស្ស មុណ្ឌកស្ស វណ្ណំ ភាសតិ** (ក៏ស្ត្រីថោកទាបនេះ រមែងពោលគុណរបស់សមណៈត្រងោល មិនថាក្នុងទីណាៗ យ៉ាងនេះឯង) ។ មកក្នុង **វចនសម្បដិគ្គហណៈ** ទទួលពាក្យ ក្នុងពាក្យជាដើមថា **ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ** ភិក្ខុទាំងនោះទទួលព្រះតម្រាស់របស់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។

មកក្នុង អាការ អាការ ក្នុងពាក្យជាដើមថា ឯវំ ព្យា ខោ អហំ ភន្តេ ភគវតា ធម្មំ ទេសិតំ អាជានាមិ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គដឹងទូទៅនូវធម៌ដែលព្រះដ៏មានព្រះភាគសម្តែងហើយដោយអាការយ៉ាងនេះ ។

មកក្នុង និទស្សនៈ គួយ៉ាង ក្នុងពាក្យជាដើមថា ឯហិ ត្វំ មាណវក ។បេ។ ឯវញ្ច វទេហិ សាធុ កិរ ភវំ អានន្ទោ យេន សុភស្ស មាណវស្ស តោទេយ្យបុត្តស្ស និវេសនំ តេនុបសង្កមតុ អនុកម្បំ ឧបាទាយ មកចុះមាណព អ្នកចូរចូលទៅរកព្រះអានន្ទដល់កន្លែងនៅ ហើយ ចូរសួរសេចក្តីមានអាពាធតិច សេចក្តីមានរោគតិច សេចក្តីរហ័សរហួន កម្លាំងពលំ ការនៅជាសុខ ចំពោះព្រះអានន្ទ តាមពាក្យរបស់យើងថា សុភមាណពតោទេយ្យបុត្រ សួរដល់សេចក្តីមានអាពាធតិច សេចក្តីមានរោគតិច សេចក្តីរហ័សរហួន កម្លាំងពលំ ការនៅជាសុខ ចំពោះព្រះអានន្ទ និងចូរពោលយ៉ាងនេះថា ករុណា សូមលោកម្ចាស់អានន្ទមេត្តាអនុគ្រោះ ចូលទៅកាន់និវេសន៍របស់សុភមាណពតោទេយ្យបុត្រផងចុះ ។

មកក្នុង អវធារណៈ សេចក្តីដទៃ ក្នុងពាក្យជាដើមថា តំ កឹ មញ្ញថ កាលាមា ។បេ។ ឯវំ នោ ឯត្ថ ហោតិ ម្នាលកាលាមៈទាំងឡាយ អ្នកសម្គាល់សេចក្តីនោះដូចម្តេច ធម៌ទាំងនេះជាកុសល ឬអកុសល ? ជាអកុសល ព្រះអង្គ មានទោស ឬមិនមានទោស? មានទោសព្រះអង្គ វិញ្ញូជនតិះដៀល ឬសរសើរ?

វិញ្ញូជនតិះដៀល ព្រះអង្គ ។ បុគ្គលសមាទានឲ្យបរិបូរណ៍ហើយ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខ ឬមិនប្រព្រឹត្តទៅ ឬក្នុងសេចក្តីនោះ ដូចម្តេច? ព្រះអង្គ ដែលបុគ្គលសមាទានឲ្យបរិបូណ៌ហើយ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខ , ក្នុងសេចក្តីនេះ ពួកខ្ញុំព្រះអង្គឃើញយ៉ាងនេះ ។

**ឯវំ** ស័ព្ទនេះ ក្នុងទីនេះគប្បីឃើញថា ប្រើក្នុងអត្ថថា អាការ និទស្សនៈ និង អវធារណៈ ។

បណ្តាអត្ថ ៣ យ៉ាងនោះ ដោយ **ឯវំ** ស័ព្ទ មានអាការជាអត្ថ ព្រះថេរៈសម្តែងដល់អត្ថនេះថា ព្រះតម្រាស់របស់ព្រះដ៏មានព្រះភាគ ល្អិតដោយន័យផ្សេងៗ មានអធ្យាស្រ័យដ៏ច្រើនជាសមុដ្ឋាន សម្បូរដោយអត្ថ និងព្យញ្ជនៈ មានបាដិ-ហារ្យផ្សេងៗ ជ្រៅដោយធម៌ , អត្ថ , ទេសនា និងបដិវេធ មកប្រាកដផ្លូវសោតទ្វារនៃសព្វសត្វ តាមសមគួរដល់ភាសារៀងៗ ខ្លួន នរណាហ្ន៎ នឹងអាចជ្រាបបានដោយអាការទាំងពួង តែខ្ញុំធ្វើសេចក្តីលំបាកស្តាប់ឲ្យកើតឡើងហើយ ដោយខ្លាំងក្លាគ្រប់យ៉ាង បានស្តាប់មកហើយដោយអាការយ៉ាងនេះ គឺ ខ្ញុំម្ចាស់ខ្លួនឯងបានស្តាប់មកហើយដោយអាការតែម្យ៉ាង ។

ដោយ **ឯវំ** ស័ព្ទ មាននិទស្សនៈជាអត្ថ ព្រះថេរៈកាលនឹងដោះខ្លួនថា ខ្ញុំមិនមែនព្រះសយម្ភូ ព្រះសូត្រនេះ ខ្ញុំមិនបានធ្វើឲ្យច្បាស់ ទើបសម្តែងសូត្រទាំង

អស់ ដែលនឹងគួរពោលក្នុងឥឡូវនេះថា ឯវម្មេ សុតំ ប្រែថា សូម្បីខ្ញុំក៏បានស្តាប់ហើយយ៉ាងនេះ ។

ដោយ ឯវំ ស័ព្ទ ដែលមានអវធារណៈជាអត្ថ ព្រះថេរៈកាលនឹងសម្តែងកម្លាំងនៃការចងចាំរបស់ខ្លួន ដែលសមគួរដល់ព្រះដ៏មានព្រះភាគសរសើរហើយយ៉ាងនេះថា ភិក្ខុទាំងឡាយ បណ្តាភិក្ខុសាវកអ្នកពហុស្សូតរបស់តថាគត អានន្ទប្រសើរបំផុត បណ្តាភិក្ខុសាវករបស់តថាគត អ្នកមានសតិ អ្នកមានគតិ អ្នកមានធិតិ អ្នកឧបដ្ឋាក អានន្ទប្រសើរបំផុត និងជាអ្នកដែលព្រះធម្មសេនាបតីសារីបុត្រសរសើរថា ព្រះអានន្ទ ជាអ្នកឆ្លាតក្នុងអត្ថ ឆ្លាតក្នុងធម៌ ឆ្លាតក្នុងព្យញ្ជនៈ ឆ្លាតក្នុងនិរុត្តិ ឆ្លាតក្នុងអនុសន្ធិខាងដើម និងខាងចុង ទើបញ៉ាំងភាពជាអ្នកប្រាថ្នាដើម្បីនឹងស្តាប់របស់សត្វទាំងឡាយឲ្យកើតថា យើងបានស្តាប់មកហើយយ៉ាងនេះក៏សូត្រនោះឯង មិនខ្វះមិនលើស ដោយអត្ថ ឬដោយព្យញ្ជនៈ គប្បីឃើញយ៉ាងនេះឯង មិនគប្បីឃើញដោយប្រការដទៃ ។

មេ ស័ព្ទ ប្រាកដក្នុងអត្ថ ៣ យ៉ាង ពិតយ៉ាងនោះ មេ ស័ព្ទនោះ មានអត្ថថា មយា (ដែលយើង) ក្នុងពាក្យជាដើមថា គាថាភិគីតំ មេ អភោជនីយំ ភោជនដែលបានមកព្រោះចម្រៀង យើងមិនគួរបរិភោគ ។ មេ ស័ព្ទ មានអត្ថថា មយ្ហំ (ដល់យើង) ក្នុងពាក្យជាដើមថា សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ

**ទេសេតុ** បពិត្រព្រះអង្គដ៏ចម្រើន សាធុ ! សូមព្រះដ៏មានព្រះភាគ ទ្រង់មេត្តាសម្តែងធម៌ដោយសង្ខេបដល់ខ្ញុំព្រះអង្គចុះ ។ **មេ** ស័ព្ទ មានអត្ថថា **មម** (របស់យើង) ក្នុងពាក្យជាដើមថា **ធម្មទាយាទា មេ ភិក្ខវេ ភវថ** ម្នាលភិក្ខុទាំងឡាយពួកអ្នកចូរជាធម្មទាយាទ **របស់តថាគត** ។ តែក្នុងទីនេះ ប្រើក្នុងអត្ថទាំង ២ គឺ **មយា សុតំ** ដែលខ្ញុំស្តាប់មកហើយ និងថា **មម សុតំ** ការស្តាប់របស់ខ្ញុំ ។

ស័ព្ទថា **សុត** ក្នុងបទថា **សុតំ** នេះ ទាំងមានឧបសគ្គ និងទាំងមិនមានឧបសគ្គ មានប្រភេទនៃអត្ថជាច្រើន ដូចជា **គមនៈ** ទៅ, **វិសុតៈ** ប្រាកដ, **កិលិន្នៈ** សើម, **ឧបចិត្តៈ** សន្សំ, **អនុយុត្តៈ** ខ្វល់ខ្វាយ, **សោតវិញ្ញេយ្យៈ** សំឡេងដែលដឹងដោយសោតៈ, និងសោតទ្វារានុសារវិញ្ញាត ដឹងតាមសោតទ្វារជាដើម ។

ពិតហើយ **សុតំ** ស័ព្ទនោះ មានអត្ថថា ទៅ ក្នុងពាក្យជាដើមថា **សេនាយ បសុតោ** ទៅក្នុងកងទ័ព ។ កាលបើអត្ថថា ជាធម៌ប្រាកដហើយ ក្នុងពាក្យជាដើមថា **សុតធម្មស្ស បស្សតោ** អ្នកមានធម៌ប្រាកដហើយ ឃើញហើយ ។ អត្ថថា ភិក្ខុនីដែលទទឹកជោកដោយរាគៈចំពោះបុរសដែលទទឹកជោកដោយរាគៈ ក្នុងពាក្យជាដើមថា **អវស្សុតា អវស្សុតស្ស** ភិក្ខុនីដែលប្រាថ្នាដោយរាគៈ ចំពោះដែលបុរសប្រាថ្នាដោយរាគៈ ។ អត្ថថា សន្សំ ក្នុងពាក្យជាដើមថា **តុម្ហេហិ បុញ្ញំ បសុតំ អនប្បកំ** អ្នកសន្សំបុណ្យទុកមិនមែនតិច ។ អត្ថថា ខ្វល់ខ្វាយក្នុងឈាន ក្នុងពាក្យ

ជាដើមថា **យេ ឈានបសុតា ធីរា** អ្នកប្រាជ្ញពួកណា ដែលខ្វល់ខ្វាយក្នុងឈាន អត្ថថា សំឡេងដែលដឹងដោយសោតៈ ក្នុងពាក្យជាដើមថា **ទិដ្ឋំ សុតំ មុតំ** រូបដែលឃើញ សំឡេងដែលបានឮ អារម្មណ៍ដែលដឹង, អត្ថថា ចងចាំដឹងតាមក្រសែសោតទ្វារ ក្នុងពាក្យជាដើមថា **សុតធរោ សុតសន្និចយោ** អ្នកចងចាំការដឹង សន្សំការដឹង ។ តែក្នុងទីនេះ **សុត** ស័ព្ទ មានអត្ថថា **ឧបធារិតំ** ចងចាំទុកតាមផ្លូវសោតទ្វារ ឬថា **ឧបធារណំ** ការចងចាំ ។ ពិតហើយ កាលបើ **មេ** ស័ព្ទ មានអត្ថថា **មយា** សេចក្តីថា ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ គឺ ចូលទៅចាំទុកតាមក្រសែនៃសោតទ្វារក៏បាន ។ កាលបើមានអត្ថថា **មម** សេចក្តីថា ការស្តាប់របស់ខ្ញុំយ៉ាងនេះ គឺ ការចាំទុកតាមក្រសែនៃសោតទ្វារក៏បាន ។

បណ្តាបទទាំង ៣ នោះ ដូចពោលមកនេះ បទថា **ឯវំ** ជាបទសម្តែងកិច្ច គឺ នាទីរបស់វិញ្ញាណ មានសោតវិញ្ញាណជាដើម ។ បទថា **មេ** ជាបទសម្តែងបុគ្គលដែលព្រមព្រៀងដោយវិញ្ញាណដូចពោលហើយ បទថា **សុតំ** ជាបទសម្តែងដល់ការកាន់យកមិនខ្វះ មិនលើស មិនវិបរិត្ត ព្រោះបដិសេធភាវៈដែលមិនបានឮមួយទៀត បទថា **ឯវំ** ជាបទប្រកាសថា វិញ្ញាណវីថិដែលប្រព្រឹត្តទៅហើយតាមក្រសែនៃសោតទ្វារនោះ ប្រព្រឹត្តទៅក្នុងអារម្មណ៍ដោយប្រការផ្សេងៗ ។ បទថា **មេ** ជាបទប្រកាសខ្លួន ។ បទថា **សុតំ** ជាបទប្រកាសធម៌ ។ ក៏ក្នុងទីនេះ មាន

សេចក្តីសង្ខេបដូច្នេះថា ខ្ញុំមិនធ្វើកិច្ចយ៉ាងដទៃ តែកិច្ចនេះខ្ញុំធ្វើហើយ ធម៌នេះ ខ្ញុំស្តាប់មកហើយ ដោយវិញ្ញាណវីថិ ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ ដោយប្រការផ្សេងៗ ។

មួយទៀត បទថា **ឯវំ** ជាបទប្រកាសអត្ថដែលនឹងគប្បីចង្អុលបង្ហាញ ។ បទថា **មេ** ជាបទប្រកាសបុគ្គល ។ បទថា **សុតំ** ជាបទប្រកាសកិច្ចរបស់បុគ្គល លោកអធិប្បាយទុកថា ខ្ញុំបង្ហាញព្រះសូត្រណា ព្រះសូត្រនោះ ខ្ញុំស្តាប់មកហើយយ៉ាងនេះ ។

មួយទៀត ស័ព្ទថា **ឯវំ** សម្តែងអាការផ្សេងៗ របស់ចិត្តសន្តាន ដែលកាន់យកអត្ថ និងព្យញ្ជនៈផ្សេងៗ ព្រោះចិត្តសន្តានប្រព្រឹត្តទៅផ្សេងៗ គ្នា ពិតហើយ ស័ព្ទថា **ឯវំ** នេះ សម្តែងដល់បញ្ញត្តិ គឺ ការដឹងដោយអាការ ។ ស័ព្ទថា **មេ** សម្តែងដល់អ្នកធ្វើ ។ ស័ព្ទថា **សុតំ** សម្តែងអារម្មណ៍ ។ ដោយពាក្យត្រឹមតែប៉ុណ្ណេះ ការព្រមព្រៀងដោយកាន់យកអ្នកធ្វើអារម្មណ៍ របស់លោកអ្នកព្រមព្រៀងដោយចិត្តសន្តាននោះ ជាការធ្វើហើយដោយចិត្តសន្តាន ដែលប្រព្រឹត្តទៅដោយប្រការផ្សេងៗ ។

មយ៉ាងទៀត **ឯវំ** ស័ព្ទ សម្តែងកិច្ចរបស់បុគ្គល ។ **សុតំ** ស័ព្ទ សម្តែងកិច្ចរបស់វិញ្ញាណ ។ **មេ** ស័ព្ទ សម្តែងបុគ្គលដែលប្រកបកិច្ចទាំង ២ ក៏ក្នុងទីនេះ

មានសេចក្ដីសន្និដ្ឋានដូច្នេះថា ខ្ញុំជាបុគ្គលដែលព្រមព្រៀងដោយវិញ្ញាណ ដែលមានកិច្ច គឺ ការស្ដាប់ បានស្ដាប់មកហើយ ដោយវោហារថា កិច្ច គឺ ការស្ដាប់ ដែលបានមកជាប់ដោយវិញ្ញាណ ។

បណ្ដាបទទាំងនោះ បទថា **ឯវំ** និងបទថា **មេ** ជាអវិជ្ជមានបញ្ញត្តិ បញ្ញត្តិវត្ថុដែលមិនមាន ដោយអំណាចនៃសច្ចិកត្ថៈ និងបរមត្ថៈ ពិតណាស់ ក្នុងទីនេះ ពាក្យដែលនឹងគប្បីបាននិទ្ទេសថា **ឯវំ** ឬថា **មេ** បើពោលដោយបរមត្ថនឹងមានហើយឬ ។ បទថា **សុតំ** ជាវិជ្ជមានបញ្ញត្តិ បញ្ញត្តិវត្ថុដែលមានហើយ គឺក្នុងទីនេះវត្ថុដែលមកដោយសោតវិញ្ញាណនោះ មានហើយដោយបរមត្ថ ។ បទថា **ឯវំ** និង **មេ** ជាឧបាទាយបញ្ញត្តិ ព្រោះអាស្រ័យវត្ថុដែលបានមកដោយសោតៈនោះៗ ពោលដោយប្រការនោះ ។ បទថា **សុតំ** ជាឧបនិធាយបញ្ញត្តិ (បញ្ញត្តិក្នុងការតាំងទុក) ព្រោះរក្សាយកវត្ថុដែលឃើញហើយជាដើមមកពោល មួយទៀតបណ្ដាពាក្យទាំង ២ នោះ ដោយពាក្យថា **ឯវំ** ព្រះអានន្ទសម្ដែងដល់សេចក្ដីមិនវង្វេង ។ ពិតណាស់ អ្នកវង្វេង រមែងមិនអាចយល់បានដោយប្រការផ្សេងៗ ។ ដោយពាក្យថា **សុតំ** ព្រះអានន្ទសម្ដែងសេចក្ដីមិនភ្លេចធម៌ដែលស្ដាប់មកហើយ ។ ពិតហើយ អ្នកណាស្ដាប់ហើយតែភ្លេចវិញ តមកអ្នកនោះក៏មិនអាចទទួលបានថា ខ្ញុំស្ដាប់មកហើយដូច្នោះ ព្រះអានន្ទនោះ ឈ្មោះថា សម្រេចដោយបញ្ញា ព្រោះការ

មិនវង្វេង ឈ្មោះថា សម្រេចដោយសតិ ព្រោះការមិនភ្លេច ។ បណ្តាបញ្ញា និង សតិនោះ សតិដែលមានបញ្ញាជាតួនាំ អាចនឹងចាំព្យញ្ជនៈបាន បញ្ញាដែលមាន សតិជាតួនាំ អាចយល់អត្ថបាន ឈ្មោះថា សម្រេចដោយភាពជាធម្មភណ្ឌាគារិកៈ ព្រោះអាចថែរក្សាឃ្លាំងធម៌ ដែលបរិបូរណ៍ដោយអត្ថ និងព្យញ្ជនៈ ព្រោះប្រកប ដោយសមត្ថភាពទាំង ២ យ៉ាងនោះ ។

ន័យមួយទៀត ក៏ដោយពាក្យថា **ឯវំ** ព្រះអានន្ទសម្តែងការធ្វើទុកក្នុង ចិត្តដោយឧបាយ ព្រោះការធ្វើទុកក្នុងចិត្តមិនដោយឧបាយ ក៏មិនយល់ដោយប្រការ ផ្សេងៗ បាន ក៏ដោយពាក្យថា **សុតំ** ព្រះអានន្ទសម្តែងដល់សេចក្តីមិនរាយមាយ សូម្បីគេនិយាយដោយត្រឹមត្រូវគ្រប់យ៉ាង ក៏ពោលថា ខ្ញុំមិនបានឮ លោកចូរពោល ម្តងទៀត ក៏ព្រោះការធ្វើទុកក្នុងចិត្តដោយឧបាយក្នុងសេចក្តីនេះ រមែងឲ្យសម្រេច **អត្តសម្មាបណិធិ** ការតាំងខ្លួនទុកប្រពៃ និង **បុព្វេកតបុញ្ញតា** ភាពជាអ្នកមាន បុណ្យដែលបានធ្វើទុកក្នុងកាលមុន ព្រោះអ្នកដែលមិនតាំងខ្លួនទុកប្រពៃ និងមិន បានធ្វើបុណ្យទុកក្នុងកាលមុន ក៏ជាយ៉ាងដទៃ គឺ មិនមានយោនិសោមនសិការ ដោយការមិនរាយមាយ ក៏ឲ្យសម្រេចសទ្ធម្មស្សវនៈ ការស្តាប់ព្រះសទ្ធម្ម និង សប្បុរិសូបសំសេវៈ ការចូលទៅសេពគប់សប្បុរស ។ ព្រោះអ្នកដែលមានចិត្ត រាយមាយ មិនអាចស្តាប់ និងកាលមិនចូលទៅរកសប្បុរស ការស្តាប់ក៏មិនមាន ។

ន័យមួយទៀត ព្រោះហេតុដែលពោលមកហើយថា ស័ព្ទថា **ឯវំ** សម្តែងអាការផ្សេងៗ របស់ចិត្តសន្តាន ដែលកាន់យកអត្ថ និងព្យញ្ជនៈផ្សេងៗ ព្រោះចិត្តសន្តានប្រព្រឹត្តទៅផ្សេងៗ គ្នា និងចិត្តសន្តាននោះ ក៏គឺ អាការដែលល្អយ៉ាងនេះ រមែងមិនមានដល់អ្នកមិនតាំងខ្លួនទុកប្រពៃ ឬដល់អ្នកមិនបានធ្វើបុណ្យទុកក្នុងកាលមុន ដូច្នោះ ដោយពាក្យថា **ឯវំ** នេះ ព្រះអានន្ទសម្តែងសម្បត្តិ គឺ ចក្កធម៌ ២ ប្រការក្រោយរបស់ខ្លួន ដោយអាការដែលល្អ សម្តែងសម្បត្តិ គឺ ចក្កធម៌ ២ ប្រការដំបូងដោយប្រកបការស្តាប់ ដោយបទថា **សុតំ** ។ ព្រោះបុគ្គលនៅក្នុងប្រទេសដែលមិនសមគួរ និងអ្នកវៀរចាកការចូលទៅសេពគប់រកសប្បុរស ការស្តាប់ក៏មិនមាន ដូច្នោះ ព្រះអានន្ទនោះ ទើបសម្រេចអាសយសុទ្ធិ សេចក្តីបរិសុទ្ធនៃអាសយៈ ព្រោះការសម្រេចនៃចក្កធម៌ ២ ប្រការក្រោយ សម្រេចបយោគ-សុទ្ធិ សេចក្តីបរិសុទ្ធនៃការប្រកប ព្រោះសេចក្តីសម្រេចនៃចក្កធម៌ ២ ប្រការខាងដើម និងព្រះអានន្ទ សម្រេចភាពស្ទាត់ជំនាញក្នុងអាគម (និកាយទាំង ៥ ) ក៏ព្រោះអាសយសុទ្ធិ សេចក្តីបរិសុទ្ធនៃអាសយៈនោះ ។ សម្រេចភាពស្ទាត់ជំនាញក្នុងអធិគម (មគ្គផល) ក៏ព្រោះបយោគសុទ្ធិ សេចក្តីបរិសុទ្ធនៃប្រយោគ ដូច្នោះពាក្យរបស់ព្រះអានន្ទ ដែលបរិសុទ្ធដោយប្រយោគ ការប្រកប និង អាសយៈអធ្យាស្រ័យ អ្នកដល់ព្រមដោយអាគម និងអធិគម ទើបគួរនឹងជាខាងដើម (អ្នកនាំ)

នៃព្រះតម្រាស់របស់ព្រះដ៏មានព្រះភាគ ដូចអរុណរះជាខាងដើមរបស់ព្រះអាទិត្យឧទ័យ និងដូចយោនិសោមនសិការ ជាខាងដើមនៃកុសលកម្ម ដូច្នោះ ព្រោះដូច្នោះ ព្រះអានន្ទកាលតាំងនិទានវចនៈ ពាក្យចាប់ផ្ដើមក្នុងឋានៈដែលគួរ ទើបពោលពាក្យជាដើមថា **ឯវម្មេ សុតំ** ដូច្នេះ ។

ន័យមួយទៀត ព្រះអានន្ទសម្ដែងសភាវៈនៃសម្បត្តិ គឺ អត្ថប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទារបស់ខ្លួន ដោយពាក្យដែលសម្ដែងដល់សេចក្ដីដឹងច្បាស់ដោយប្រការផ្សេងៗ ដោយពាក្យថា **ឯវំ** នេះ ។ សម្ដែងសភាវៈនៃសម្បត្តិ គឺ ធម្មប្បដិសម្ភិទា និងនិរុត្តិប្បដិសម្ភិទា ដោយពាក្យដែលសម្ដែងដល់សេចក្ដីដឹងច្បាស់ប្រភេទនៃធម៌ដែលគួរស្ដាប់ ដោយពាក្យថា **សុតំ** នេះ ។ ព្រះថេរៈកាលពោលដល់ពាក្យដែលសម្ដែងយោនិសោមនសិការនេះថា **ឯវំ** រមែងសម្ដែងថា ធម៌ទាំងនេះ យើងពិចារណាហើយដោយចិត្ត គិតល្អហើយដោយទិដ្ឋិ ព្រះថេរៈកាលពោលដល់ពាក្យដែលសម្ដែងការប្រកបរឿយៗ ដល់ការស្ដាប់នេះថា **សុតំ** រមែងសម្ដែងថា ធម៌ជាច្រើន យើងស្ដាប់ហើយ ចាំទុកហើយ ស្ទាត់មាត់ហើយ សូម្បីដោយពាក្យទាំង ២ នោះ ព្រះថេរៈកាលសម្ដែងសេចក្ដីបរិបូរណ៍ នៃអត្ថនិងព្យញ្ជនៈ ទើបធ្វើឲ្យកើតសេចក្ដីអើពើក្នុងការស្ដាប់ ។ ពិតណាស់ បុគ្គលកាលមិនស្ដាប់ធម៌ដែលបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ដោយសេចក្ដីអើពើ រមែង

ឆ្ងាយចាកប្រយោជន៍ជាច្រើន ព្រោះដូច្នោះ គួរធ្វើសេចក្តីអើពើឲ្យកើតហើយ ស្តាប់ធម៌ដោយគោរពចុះ ។

មួយទៀត ដោយពាក្យទាំងអស់ថា **ឯវំមេ សុតំ** នេះ ព្រះអានន្ទ កាលមិនតាំងធម៌ដែលព្រះតថាគតប្រកាសហើយទុកនឹងខ្លួន ឈ្មោះថា ឈានកន្លងភូមិអសប្បុរស[១] កាលប្តេជ្ញាភាពជាព្រះសាវក ឈ្មោះថា ធ្លាក់ចុះកាន់ភូមិសប្បុរស ។ មួយទៀត ធ្វើចិត្តឲ្យចេញចាកអសទ្ធម្ម ឈ្មោះថា តាំងចិត្តទុកក្នុងព្រះសទ្ធម្ម ។ កាលសម្តែងថា អាស្រ័យព្រះតម្រាស់របស់ព្រះជិនស្រី ឈ្មោះថា តាំងធម្មនេត្តិទុក (នេត្តិ គឺ ដឹកនាំសត្វក្នុងប្រយោជន៍លោកនេះ ប្រយោជន៍លោកខាងមុខ និងបរមត្ថប្រយោជន៍ តាមសមគួរ) ។

ន័យមួយទៀត ព្រះអានន្ទកាលមិនប្តេជ្ញាថា ធម៌នោះខ្លួនធ្វើឲ្យកើតឡើង ទើបអធិប្បាយពាក្យខាងដើមថា **ឯវំមេ សុតំ** កម្ចាត់ការមិនមានសទ្ធា ធ្វើសទ្ធាសម្បត្តិឲ្យកើតឡើងក្នុងធម៌នេះ ដល់ទេវតា និងមនុស្សគ្រប់ជំពូកថា ព្រះតម្រាស់នេះ យើងទទួលហើយក្នុងទីចំពោះព្រះភ័ក្ត្ររបស់ព្រះដ៏មានព្រះភាគព្រះអង្គនោះ ដែលទ្រង់ក្លៀវក្លាដោយវេសារជ្ជញ្ញាណ ៤ ព្រះអង្គទ្រទ្រង់ទុកនូវពលញ្ញាណ ទ្រង់តាំងនៅក្នុងឋានៈដ៏ប្រសើរ ជាអ្នកបន្លឺសីហនាទ ទ្រង់ឧត្តមជាងសត្វទាំងពួង ទ្រង់

(១) សេចក្តីនោះគួរតែ "កាលមិនតាំងធម៌......ឈ្មោះថា ឈានកន្លងភូមិសប្បុរស ? "។

ជាធំក្នុងធម៌ ព្រះអង្គជាព្រះធម្មរាជា ជាធម្មាធិបតី ទ្រង់មានធម៌ជាប្រទីប ជាអ្នកមានធម៌ជាទីពឹង ទ្រង់ជាអ្នកបន្ទិលចក្ក គឺ ព្រះសទ្ធម្មដ៏ប្រសើរ ព្រះអង្គត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គឯង ទើបមិនគួរធ្វើសេចក្ដីសង្ស័យ ឬសេចក្ដីងឿងឆ្ងល់ក្នុងអត្ថ ធម៌ បទ ឬព្យញ្ជនៈ ក្នុងពាក្យនេះ ព្រោះហេតុនោះ លោកទើបពោលពាក្យនេះទុកថា ៖

*វិនាសយតិ អស្សទ្ធំ សទ្ធំ វឌ្ឍេតិ សាសនេ*

*ឯវម្មេ សុតមិច្ចេវំ វទំ គោតមសាវកោ*

សាវ័ករបស់ព្រះគោតម កាលពោលយ៉ាងនេះថា **ឯវម្មេ សុតំ** ឈ្មោះថា ធ្វើសេចក្ដីមិនមានសទ្ធាឲ្យវិនាស ធ្វើសទ្ធាក្នុងព្រះ-សាសនាឲ្យចម្រើន ។

ស័ព្ទថា **ឯកំ** សម្ដែងការកំណត់ចំនួន ស័ព្ទថា **សមយំ** សម្ដែងកាលដែលកំណត់ទុកហើយ ពាក្យថា **ឯកំ សមយំ** ជាពាក្យសម្ដែងវេលាមិនពិតប្រាកដ **សមយ** ស័ព្ទ ក្នុងពាក្យថា **ឯកំ សមយំ** នោះ ប្រើក្នុងសមវាយៈ ព្រមព្រៀង ១ ខណៈ ១ កាល ១ សមុហៈ ជំនុំ ១ ហេតុ ១ ទិដ្ឋិ សេចក្ដីឃើញ ១ បដិលាភៈ ការបាន ១ បហានៈ ការលះ ១ បដិវេធ ការចាក់ធ្លុះ ១ ។

ពិតយ៉ាងនោះ **សមយ** ស័ព្ទ មានអត្ថថា សមវាយៈ ព្រមព្រៀង ក្នុង

ពាក្យមានជាដើម យ៉ាងនេះថា **អប្បេវ នាម ស្វេបិ ឧបសង្កមេយ្យាម កាលញ្ច សមយញ្ច ឧបាទាយ** បើយ៉ាងណា សូម្បីស្អែកនេះ យើងទាំងឡាយគប្បីអាស្រ័យកាលៈ និងសេចក្តីព្រមព្រៀងគ្នាចូលទៅ ។

មានអត្ថថា **ខណៈ** ក្នុងពាក្យមានជាដើមយ៉ាងនេះថា **ឯកោ ច ខោ ភិក្ខវេ ខណោ ច សមយោ ច ព្រហ្មចូរិយវាសាយ** ម្នាលភិក្ខុទាំងឡាយ ខណៈ និងសម័យមួយមាន ដើម្បីប្រព្រឹត្តព្រហ្មចរិយៈនោះឯង ។

មានអត្ថថា **កាល** ក្នុងពាក្យមានជាដើមយ៉ាងនេះថា **ឧណ្ហសមយោ បរិឡាហសមយោ** គ្រាក្តៅ គ្រាខ្វល់ខ្វាយ ។

មានអត្ថថា **សមុហៈ** ប្រជុំ ក្នុងពាក្យមានជាដើមយ៉ាងនេះថា **មហាសមយោ បវនស្មឹ** ប្រជុំធំក្នុងព្រៃធំ ។ មានអត្ថថា **ហេតុ** ក្នុងពាក្យមានជាដើមយ៉ាងនេះថា **សមយោ បិ ខោ តេ ។បេ។ អប្បដិវិទ្ធោ អហោសិ** សូម្បីហេតុផល បានជាហេតុដែលអ្នកមិនដឹងច្បាស់ថា សូម្បីព្រះដ៏មានព្រះភាគ ស្តេចប្រថាប់ក្នុងក្រុងសាវត្ថី ។ សូម្បីព្រះអង្គនឹងទ្រង់ជ្រាបយើងថា ភិក្ខុឈ្មោះភទ្ទាលិ មិនមែនជាអ្នកមានប្រក្រតីធ្វើឲ្យបរិបូណ៌ក្នុងសិក្ខានៃសាសនារបស់ព្រះសាស្តា ម្នាលភទ្ទាលិ **ហេតុ** សូម្បីនេះឯង ទើបជាហេតុដែលអ្នកមិនដឹងច្បាស់នោះឯង ។

មានអត្ថថា **លទ្ធិ** ក្នុងពាក្យមានជាដើមយ៉ាងនេះថា **តេន ខោ បន**

សមយេន ។បេ។ សមយប្បវាទកេ តិណ្ឌុកាចិរេ ឯកសាលកេ មល្លិកាយ អារាមេ បដិវសតិ ក៏សម័យនោះឯង បរិព្វាជក ឈ្មោះឧគ្គាហមានះ បុត្ររបស់សមណមុណ្ឌិកា អាស្រ័យនៅក្នុងអារាមរបស់ព្រះនាងមល្លិកា មានសាលាមួយខ្នង មានដើមទន្លាប់ដុះរៀងគ្នា ដែលជាទីប្រជុំ លទ្ធិ ។

មានអត្ថថា បានចំពោះ ក្នុងពាក្យមានជាដើមយ៉ាងនេះថា

ទិដ្ឋេ ធម្មេ ច យោ អត្ថោ យោ ចត្ថោ សម្បរាយិកោ
អត្ថាភិសមយា ធីរោ បណ្ឌិតោតិ បវុច្ចតិ ។

អ្នកមានបញ្ញាជាគ្រឿងទ្រទ្រង់ តថាគតហៅថា បណ្ឌិត ព្រោះការបានចំពោះនូវប្រយោជន៍ទាំងភពនេះ និងភពមុខ ។

មានអត្ថថា បហានៈ លះបង់ ក្នុងពាក្យជាដើមយ៉ាងនេះថា សម្មាមានាភិសមយា អន្តមកាសិ ទុក្ខស្ស ភិក្ខុនេះបានធ្វើទីបំផុតទុក្ខ ព្រោះលះមានះដោយប្រពៃ ។

មានអត្ថថា បដិវេធ ចាក់ធ្លុះ ក្នុងពាក្យជាដើមយ៉ាងនេះថា ទុក្ខស្ស បីឡនដ្ឋោ ។ល។ វិបរិណាមដ្ឋោ អភិសមយដ្ឋោ ទុក្ខ មានអត្ថថា បៀតបៀន តាក់តែង ដុតរោល ប្រែប្រួល ចាក់ធ្លុះ ។

តែក្នុងទីនេះ សមយ ស័ព្ទនោះ មានអត្ថថា កាល ។

ដោយពាក្យនោះ ព្រះថេរៈសម្តែងថា សម័យមួយ ក្នុងបណ្តាសម័យទាំងឡាយ ដែលជាប្រភេទនៃកាលជាដើមថា ឆ្នាំ រដូវ ខែ កន្លះខែ ពេលយប់ ពេលថ្ងៃ ព្រឹក ថ្ងៃត្រង់ ល្ងាច បឋមយាម មជ្ឈិមយាម បច្ឆិមយាម និងមួយស្របក់ ។

ក្នុងពាក្យថា **ឯកំ សមយំ** នោះ បណ្តាសម័យ មានឆ្នាំជាដើមទាំងនោះ ព្រះសូត្រណាៗ ព្រះដ៏មានព្រះភាគត្រាស់ទុកក្នុងឆ្នាំ រដូវ ខែ បក្ខ ចំណែកនៃរាត្រី ចំណែកនៃថ្ងៃណាៗ ទាំងអស់នោះ ព្រះថេរៈដឹងល្អហើយ កំណត់ល្អហើយ ដោយបញ្ញាសូម្បីដោយពិត សូម្បីយ៉ាងនោះ កាលព្រះថេរៈពោលទុកយ៉ាងនេះថា ខ្ញុំបានស្តាប់មកហើយយ៉ាងនេះថា ក្នុងឆ្នាំឯណោះ រដូវឯណោះ ខែឯណោះ បក្ខឯណោះ កាលដែលជាចំណែកនៃរាត្រីឯណោះ ចំណែកនៃថ្ងៃឯណោះ នរណាៗ ក៏មិនអាចនឹងចាំបាន ឬសម្តែងបាន ឬឲ្យអ្នកដទៃសម្តែងបានដោយងាយ និងជារឿងដែលត្រូវពោលច្រើន ដូច្នោះ លោកទើបប្រមូលសេចក្តីនោះទុកដោយបទតែមួយប៉ុណ្ណោះ ហើយពោលថា **ឯកំ សមយំ** ដូច្នេះ ។

ម្យ៉ាងទៀត ព្រះអានន្ទ រមែងសម្តែងថា សម័យរបស់ព្រះដ៏មានព្រះភាគជាប្រភេទនៃកាលមិនមែនតិច ដែលប្រាកដច្រើនណាស់ក្នុងពួកទេវតា និងមនុស្សទាំងឡាយ មានជាដើមយ៉ាងនេះ គឺ សម័យស្តេចយាងចុះកាន់ព្រះគភ៌ សម័យប្រសូតិ សម័យទ្រង់ស្តុតព្រះទ័យ សម័យស្តេចចេញព្រះផ្នួស សម័យទ្រង់បំពេញ

ទុក្ករកិរិយា សម័យទ្រង់ឈ្នះមារ សម័យត្រាស់ដឹង សម័យប្រថាប់ជាសុខក្នុងទិដ្ឋធម៌ សម័យត្រាស់ទេសនា សម័យស្ដេចបរិនិព្វាន ទាំងនេះណា ក្នុងបណ្ដាសម័យទាំងនោះ **សម័យមួយ** គឺ សម័យត្រាស់ទេសនា ។

ម្យ៉ាងទៀត ក្នុងបណ្ដាសម័យនៃញាណកិច្ច និងករុណាកិច្ច សម័យនៃករុណាកិច្ចនេះណា ក្នុងបណ្ដាសម័យទ្រង់បំពេញប្រយោជន៍ព្រះអង្គ និងទ្រង់បំពេញប្រយោជន៍អ្នកដទៃ សម័យទ្រង់បំពេញប្រយោជន៍អ្នកដទៃ នេះណា ក្នុងបណ្ដាសម័យនៃករណីទាំងឡាយដល់អ្នកប្រជុំគ្នា សម័យត្រាស់ធម្មីកថានេះណា ក្នុងបណ្ដាសម័យនៃទេសនា និងបដិបត្តិ សម័យនៃទេសនានេះណា ព្រះអានន្ទពោលថា **សម័យមួយ** ដូច្នេះ សំដៅដល់ សម័យណាមួយ ក្នុងបណ្ដាសម័យទាំងឡាយសូម្បីទាំងនោះ ។

សួរថា ក៏ហេតុអ្វី ក្នុងព្រះសូត្រនេះ លោកទើបធ្វើនិទ្ទេសដោយទុតិយាវិភត្តិថា **ឯកំ សមយំ** មិនធ្វើដូចក្នុងព្រះអភិធម្ម ដែលលោកបានធ្វើនិទ្ទេសដោយសត្តមីវិភត្តិថា **យស្មឹ សមយេ កាមាវចរំ** និងក្នុងសុត្តបទដទៃៗ អំពីព្រះអភិធម្មនេះ ក៏ធ្វើនិទ្ទេសដោយសត្តមីវិភត្តិថា **យស្មឹ សមយេ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ** ចំណែកក្នុងព្រះវិន័យ លោកធ្វើនិទ្ទេសដោយតតិយាវិភត្តិថា **តេន សមយេន ពុទ្ធោ ភគវា** ?

ឆ្លើយថា ព្រោះក្នុងព្រះអភិធម្ម និងព្រះវិន័យនោះ មានអត្ថយ៉ាងនោះ ចំណែកក្នុងព្រះសូត្រនេះ មានអត្ថយ៉ាងដទៃ ។ ពិតហើយ បណ្ដាបិដកទាំង ៣ នោះ ក្នុងព្រះអភិធម្ម និងក្នុងសុត្តបទដទៃក្រៅពីព្រះអភិធម្មនេះ រមែងសម្រេចអត្ថនៃអធិករណៈ និងអត្ថនៃការកំណត់ភាវៈដោយភាវៈ ។ ក៏អធិករណៈ គឺសម័យដែលមានកាលជាអត្ថ និងមានការប្រជុំជាអត្ថ និងភាវៈនៃធម៌មានផស្សៈជាដើម លោកកំណត់ដោយភាវៈនៃសម័យ ពោលគឺ ខណៈការព្រមព្រៀង និងហេតុនៃធម៌មានផស្សៈជាដើម ដែលត្រាស់ទុកក្នុងព្រះអភិធម្ម និងសុត្តបទដទៃនោះៗ ព្រោះដូច្នោះ ដើម្បីបំភ្លឺអត្ថនោះ លោកទើបធ្វើនិទ្ទេសដោយសត្តមីវិភត្តិក្នុងព្រះអភិធម្ម និងក្នុងសុត្តបទដទៃនោះ ។ ចំណែកក្នុងព្រះវិន័យ រមែងសម្រេចអត្ថនៃហេតុ និងអត្ថនៃករណៈ ។ ពិតណាស់ សម័យនៃការទ្រង់បញ្ញត្តិសិក្ខាបទនោះណា សូម្បីសាវក មានព្រះសារីបុត្រជាដើម ក៏ដឹងលំបាក ដោយសម័យនោះដែលជាហេតុ និងជាករណៈ ព្រះដ៏មានព្រះភាគ កាលទ្រង់បញ្ញត្តិសិក្ខាបទទាំងឡាយ និងទ្រង់ពិចារណាដល់ហេតុនៃការទ្រង់បញ្ញត្តិសិក្ខាបទ បានប្រថាប់នៅក្នុងទីនោះៗ ព្រោះដូច្នោះ ដើម្បីបំភ្លឺសេចក្ដីនោះ លោកទើបធ្វើនិទ្ទេសដោយតតិយាវិភត្តិក្នុងព្រះវិន័យនោះ ។ ចំណែកក្នុងព្រះសូត្រនេះ និងព្រះសូត្រដទៃដែលមានកំណើតយ៉ាងនេះ រមែងសម្រេចអត្ថនៃអច្ចន្តសំយោគៈ ពិតហើយ

ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងព្រះសូត្រនេះ ឬព្រះសូត្រដទៃ រហូតដល់អស់សម័យណា ស្តេចប្រថាប់នៅដោយធម៌ជាគ្រឿងនៅ គឺ ករុណា រហូតដល់អស់សម័យនោះឯង ។ ព្រោះដូច្នោះ ដើម្បីបំភ្លឺសេចក្តីនោះ លោកទើបធ្វើនិទ្ទេសដោយទុតិយាវិភត្តិក្នុងព្រះសូត្រនេះ ។ ព្រោះហេតុនោះ លោកទើបពោលគាថា-ព័ន្ធទុកដូច្នេះថា

លោកពិចារណាអត្ថនោះៗ ពោល **សម័យ** ស័ព្ទ
ក្នុងបិដកដទៃដោយសត្តមីវិភត្តិ និងតតិយាវិភត្តិ
តែក្នុងព្រះសុត្តន្តបិដកនេះ ពោល**សម័យ** ស័ព្ទនោះ
ដោយទុតិយាវិភត្តិ ។

ក៏ព្រះបុរាណាចារ្យទាំងឡាយ ពណ៌នាទុកថា នេះផ្សេងគ្នាត្រឹមតែវោហារថា **តស្មឹ សមយេ** ខ្ញុះ **តេន សមយេន** ខ្ញុះ **តំ សមយំ** ខ្ញុះ ក្នុងទីគ្រប់កន្លែងមានអត្ថជាសត្តមីវិភត្តិទាំងនោះ ព្រោះដូច្នោះ សូម្បីលោកពោលថា **ឯកំ សមយំ** ក៏គប្បីជ្រាបសេចក្តីថា **ឯកស្មឹ សមយេ** (ក្នុងសម័យមួយ) ។

បទថា **ភគវា** ជាពាក្យពោលដោយសេចក្តីគោរព ។ ពិតណាស់ បុគ្គលទាំងឡាយហៅគ្រូក្នុងលោកថា **ភគវា** ។ ក៏ព្រះដ៏មានព្រះភាគនេះ ជាគ្រូរបស់សត្វទាំងពួង ព្រោះទ្រង់ជាបុគ្គលប្រសើរវិសេសដោយគុណទាំងពួង ព្រោះដូច្នោះ

គប្បីជ្រាបព្រះអង្គថា **ភគវា** ។ សូម្បីព្រះបុរាណាចារ្យទាំងឡាយ ក៏ពោលទុកថា

ពាក្យថា **ភគវា** ជាពាក្យប្រសើរ ពាក្យថា **ភគវា**

ជាពាក្យខ្ពស់បំផុត ព្រះដ៏មានព្រះភាគអង្គនោះ គួរ

ដល់សេចក្ដីគោរពដោយឋានៈជាគ្រូ ព្រោះហេតុនោះ

បណ្ឌិតទើបថ្វាយព្រះនាមថា **ភគវា** ។

ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបសេចក្ដីនៃបទនោះ ដោយពិស្ដារ ដោយ

អំណាចនៃគាថានេះថា ៖

ព្រះដ៏មានព្រះភាគ ទ្រង់ជាអ្នកមានជោគ ទ្រង់កាច់

បំបាក់កិលេស ទ្រង់ប្រកបដោយភគធម៌ ទ្រង់ចែក

ធម៌ ទ្រង់គួរសេពគប់ និងទ្រង់ខ្ជាក់ចោលនូវកិលេស

ជាគ្រឿងទៅក្នុងភពទាំងឡាយចេញបាន ព្រោះហេតុ

នោះ ទ្រង់ព្រះនាមថា **ភគវា** ។

សេចក្ដីនោះ ពោលទុកហើយ ដោយពិស្ដារក្នុងពុទ្ធានុស្សតិនិទ្ទេស ក្នុង

គម្ពីរវិសុទ្ធិមគ្គនោះឯង ។

ក៏ដោយពាក្យមានប្រមាណប៉ុណ្ណេះ ព្រះថេរៈកាលសម្ដែងធម៌តាមដែល

ស្ដាប់មក ទើបធ្វើព្រះសរីរៈ គឺ ព្រះធម៌របស់ព្រះដ៏មានព្រះភាគ ឲ្យជាក់ច្បាស់

ដោយពាក្យថា **ឯវម្មេ សុតំ** ក្នុងសូត្រនេះ ។ ដោយពាក្យនោះ ព្រះថេរៈឈ្មោះថា លុងលោមបុគ្គលជាអ្នកកំសត់ ព្រោះមិនបានឃើញព្រះសាស្តាថា បាវចនៈ (ធម៌ និងវិន័យ) នេះ ឈ្មោះថា មានសាស្តាកន្លងទៅហើយមិនមែន ព្រះធម៌វិន័យនេះ ជាសាស្តារបស់លោកទាំងឡាយ ។ ដោយពាក្យថា **ឯកំ សមយំ ភគវា** ព្រះថេរៈ កាលនឹងសម្តែងថា ព្រះដ៏មានព្រះភាគ មិនមាននៅក្នុងសម័យនោះ ឈ្មោះថា លើកការបរិនិព្វានខាងព្រះរូបកាយឲ្យឃើញ ដោយពាក្យនោះ ព្រះថេរៈទើបធ្វើ ឲ្យអ្នកវង្វេង ព្រោះសេចក្តីស្រវឹងក្នុងជីវិត ឲ្យកើតសេចក្តីសង្វេគ និងធ្វើឲ្យបុគ្គល នោះកើតសេចក្តីឧស្សាហ៍ក្នុងព្រះសទ្ធម្មថា ព្រះដ៏មានព្រះភាគនោះ ដែលទ្រទ្រង់ ទុកដោយទសពលញ្ញាណ មានព្រះវរកាយស្មើដោយពេជ្រ ព្រះអង្គទ្រង់សម្តែង អរិយធម៌ ឈ្មោះយ៉ាងនេះ គង់បរិនិព្វាន អ្នកដទៃណាហ្ន៎ នឹងគប្បីឲ្យកើតសេចក្តី សង្ឃឹមក្នុងជីវិត និងព្រះថេរៈកាលពោលថា **ឯវំ** ឈ្មោះថា បង្ហាញទេសនា- សម្បត្តិ (សម្បត្តិ គឺ ការសម្តែង) ។ ពោលថា **មេ សុតំ** ឈ្មោះថា បង្ហាញ ដល់សាវកសម្បត្តិ (សម្បត្តិរបស់សាវក) ។ ពោលថា **ឯកំ សមយំ** ឈ្មោះថា បង្ហាញដល់កាលសម្បត្តិ (សម្បត្តិ គឺ វេលា) ពោលថា **ភគវា** ឈ្មោះថា បង្ហាញ ដល់ទេសកសម្បត្តិ (សម្បត្តិ គឺ អ្នកសម្តែង) ។

បទថា **សាវត្ថិយំ** បានដល់ ជិតនគរឈ្មោះយ៉ាងនេះ ។ ក៏ពាក្យថា

**សាវត្ថិយំ** នេះ ជាសត្តមីវិភត្តិប្រើក្នុងអត្ថថា ជិត ។ បទថា **វិហរតិ** នេះ ជាបទសម្តែងសេចក្តីព្រមព្រៀងនៃការនៅណាមួយ ក្នុងបណ្តាឥរិយាបថវិហារ ទិព្វវិហារ ព្រហ្មវិហារ និងអរិយវិហារ ដោយមិនប្លែកគ្នា ។ តែក្នុងទីនេះ សម្តែងការប្រកបព្រម ដោយឥរិយាបថយ៉ាងណាមួយ ក្នុងបណ្តាឥរិយាបថ មានឈរ ដើរ អង្គុយ និងដេក ដោយបទថា **វិហរតិ** នោះ ព្រះដ៏មានព្រះភាគ ប្រថាប់ឈរក្តី ដើរក្តី អង្គុយក្តី ផ្ទំក្តី បណ្ឌិតគប្បីជ្រាបថា ប្រថាប់ទាំងនោះឯង ។ ពិតណាស់ ព្រះ-ដ៏មានព្រះភាគនោះ ទ្រង់កាត់ផ្តាច់សេចក្តីលំបាកនៃឥរិយាបថមួយ ដោយឥរិ-យាបថមួយ ទ្រង់នាំទៅ គឺ ធ្វើអត្តភាពឲ្យប្រព្រឹត្តទៅ មិនឲ្យទ្រុឌទ្រោម ព្រោះហេតុនោះ ព្រះអានន្ទទើបពោលថា **វិហរតិ** (ប្រថាប់នៅ) ។

បទថា **ជេតវនេ** បានដល់ ក្នុងសួនរបស់ព្រះរាជកុមារព្រះនាមថា **ជេត** សួននោះ ព្រះរាជកុមារព្រះនាមថា **ជេត** នោះ បានដាំដើមឈើឲ្យដុះដាលល្អ រក្សាទុកយ៉ាងល្អ និងព្រះអង្គបានជាម្ចាស់របស់សួននោះ ព្រោះដូច្នោះ សួននោះទើបរាប់ថា **ជេតវ័ន** ។ ក្នុងព្រះជេតវ័ននោះ ។

បទថា **អនាថបិណ្ឌិកស្ស អារាមេ** សេចក្តីថា អារាមដែលរាប់ថា របស់អនាថបិណ្ឌិកៈ ព្រោះជាអារាមដែលគហបតីនាមថា អនាថបិណ្ឌិកៈ ប្រគល់ថ្វាយចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយបរិច្ចាគទ្រព្យជាប្រាក់ ៥៤ កោដិ

ក៏ក្នុងទីនេះ សេចក្តីសង្ខេបមានត្រឹមតែប៉ុណ្ណេះ ។

ចំណែកសេចក្តីពិស្តារ ពោលទុកហើយក្នុងអដ្ឋកថា សព្វាសវសូត្រ អដ្ឋកថាមជ្ឈិមនិកាយ ឈ្មោះបបញ្ចសូទនី ក្នុងសេចក្តីនោះ បើមានពាក្យសួរជំទាស់ចូលមកថា បើព្រះដ៏មានព្រះភាគ ប្រថាប់នៅក្រុងសាវត្ថីមុន ព្រះថេរៈក៏មិនគួរពោលថា ព្រះវិហារឈ្មោះថា ជេតវន បើព្រះអង្គប្រថាប់នៅក្នុងព្រះជេតវននោះក៏មិនគួរពោលថា ជិតក្រុងសាវត្ថី ។ សេចក្តីពិត នរណាៗ មិនអាចនឹងនៅបានក្នុងទី ២ កន្លែង ព្រមគ្នាតែមួយ ឆ្លើយថា ប្រការនោះ មិនគប្បីឃើញយ៉ាងនោះខ្ញុំទាំងឡាយ បានពោលទុកហើយមិនមែនឬថា ពាក្យថា **សាវត្ថិយំ** ជាសត្តមីវិភត្តិ ប្រើក្នុងអត្ថថា ជិត ព្រោះដូច្នោះ សូម្បីក្នុងទីនេះ ព្រះដ៏មានព្រះភាគប្រថាប់នៅក្នុងព្រះវិហារឈ្មោះថា ជេតវន ដែលនៅជិតក្រុងសាវត្ថី ព្រះអានន្ទពោលថា ប្រថាប់នៅក្នុងព្រះវិហារឈ្មោះថា ជេតវន ជិតក្រុងសាវត្ថី ដូចហ្វូងគោដើររកស៊ីជិតទន្លេគង្គា និងទន្លេយមុនាជាដើម គេហៅថា ដើររកស៊ីជិតទន្លេគង្គា ជិតទន្លេយមុនា ដូច្នោះ ។ ពិតហើយ ការពោលដល់ក្រុងសាវត្ថីរបស់ព្រះអានន្ទនោះ ក៏ដើម្បីសម្តែងគោចរគ្រាម ការពោលដល់ស្ថានទីដ៏សេស ក៏ដើម្បីសម្តែងស្ថានទីជាទីអាស្រ័យ ដែលសមគួរដល់បព្វជិត ក្នុងពាក្យទាំងនោះ ដោយពាក្យថា **សាវត្ថិយំ** ព្រះអានន្ទសម្តែងការដែលព្រះដ៏មានព្រះភាគ ទ្រង់ធ្វើការអនុ-

គ្រោះដល់គ្រហស្ថ ។ សម្តែងការធ្វើអនុគ្រោះដល់បព្វជិត ដោយការរួមយកព្រះជេតវ័ន ។ មួយទៀត ព្រះថេរៈសម្តែងការវៀរអត្តកិលមថានុយោគ ព្រោះការទទួលបច្ច័យដោយពាក្យដើម សម្តែងឧបាយជាគ្រឿងវៀរកាមសុខល្លិកានុយោគ ព្រោះវត្ថុកាម ដោយពាក្យក្រោយ ។ មួយទៀត សម្តែងការប្រកបព្រះធម៌-ទេសនា ដោយពាក្យដើម សម្តែងការបង្អោនទៅដើម្បីវិវេក ដោយពាក្យក្រោយ ។ សម្តែងការមានព្រះករុណាដោយពាក្យដើម សម្តែងការមានព្រះបញ្ញា ដោយពាក្យក្រោយ សម្តែងថា ទ្រង់បង្អោនទៅក្នុងការឲ្យសម្រេចនូវសុខដល់ពួកសត្វ ដោយពាក្យដើម សម្តែងថា ទ្រង់មិនជាប់ក្នុងការធ្វើឲ្យសម្រេចនូវសុខដល់បុគ្គលដទៃ ដោយពាក្យក្រោយ ។ សម្តែងការដែលទ្រង់នៅជាសុខ ដោយការលះបង់នូវសុខដែលប្រកបដោយធម៌ជានិមិត្ត ដោយពាក្យដើម , សម្តែងការទ្រង់ប្រកបរឿយៗនូវធម៌ដ៏ក្រៃលែងរបស់មនុស្សជានិមិត្ត ដោយពាក្យក្រោយ , សម្តែងការដែលទ្រង់ជាអ្នកមានឧបការៈច្រើនដល់មនុស្សទាំងឡាយ ដោយពាក្យដើម សម្តែងការដែលទ្រង់ជាអ្នកមានឧបការៈច្រើនដល់ទេវតាទាំងឡាយ ដោយពាក្យក្រោយ , សម្តែងការដែលស្តេចកើតឡើងក្នុងលោកហើយ សេចក្តីចម្រើនក៏មានព្រមក្នុងលោក ដោយពាក្យដើម សម្តែងការដែលទ្រង់មិនជាប់ជំពាក់ក្នុងលោក ដោយពាក្យក្រោយ ។ សម្តែងទ្រង់ធ្វើប្រយោជន៍ដែលស្តេចឧប្បត្តិ ឲ្យសម្រេចរៀបរយ

ដោយពាក្យដើម ដោយព្រះបាលីថា "ម្នាលភិក្ខុទាំងឡាយ បុគ្គលឯក កាលកើតឡើងក្នុងលោក រមែងកើតឡើងដើម្បីសេចក្ដីចម្រើនដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះសត្វលោក ដើម្បីប្រយោជន៍ធំទូលាយ ដើម្បីសេចក្ដីសុខដល់ទេវតា និងមនុស្សទាំងឡាយ បុគ្គលឯក គឺ បុគ្គលណា គឺ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ" ។ សម្ដែងការដែលទ្រង់នៅសមគួរដល់ស្ថានទីជាទីប្រសូតិ ដោយពាក្យក្រោយ ។ ពិតណាស់ ព្រះដ៏មានព្រះភាគស្ដេចប្រសូតិក្នុងព្រៃទាំងនោះ ព្រោះឧប្បត្តិទាំងជាលោកិយៈ និងលោកុត្តរៈ គឺ លើកដំបូងក្នុងលុម្ពិនីវ័ន លើកទី ២ ត្រង់ពោធិមណ្ឌលស្ថាន ព្រោះហេតុនោះ ព្រះថេរៈទើបសម្ដែងទីប្រថាប់របស់ព្រះអង្គក្នុងព្រៃនោះឯង ។ ក្នុងសូត្រនេះ គប្បីជ្រាបការប្រកបសេចក្ដី ដោយន័យដូចពោលមកហើយជាដើម ដូច្នេះ ។

បទថា **តត្រ** សម្ដែងទេសៈ និងកាលៈ ។ ក៏បទថា **តត្រ** នោះ ព្រះថេរៈសម្ដែងថា ក្នុងសម័យដែលព្រះដ៏មានព្រះភាគប្រថាប់នៅ និងក្នុងអារាមដែលបានប្រថាប់ ឬសម្ដែងទេសៈ និងកាលៈ ដែលគួរនឹងពោលដល់ ។ ពិតណាស់ ព្រះដ៏មានព្រះភាគ មិនត្រាស់ធម៌ក្នុងប្រទេស ឬក្នុងកាលដែលមិនសមគួរ ។

ក៏ពាក្យថា "ម្នាលពាហិយៈ នេះជាកាលមិនសមគួរឡើយ" ជាសាធកៈក្នុងរឿងនេះ ។ ស័ព្ទថា **ខោ** ជាអវធារណៈ ប្រើក្នុងអត្ថ ត្រឹមតែធ្វើបទឲ្យពេញ

ឬជានិបាត ប្រើក្នុងអត្ថថា កាលខាងដើម ។ បទថា **ភគវា** សម្តែងសភាពដែលទ្រង់ជាគ្រូនៃលោក ។

បទថា **ភិក្ខុ** ជាពាក្យសម្តែងដល់បុគ្គលដែលស្តាប់ព្រះតម្រាស់ ។ ម្យ៉ាងទៀត ក្នុងបទថា **ភិក្ខុ** នេះ គប្បីជ្រាបអត្ថនៃពាក្យមានជាដើមថា ឈ្មោះថា ភិក្ខុ ព្រោះជាអ្នកសូម ឬឈ្មោះថា ភិក្ខុ ព្រោះចូលដល់ការដើរសូម ។

បទថា **អាមន្តេសិ** ប្រែថា ហៅ គឺ ពោល បានដល់ ដាស់ឲ្យភ្ញាក់ ។ ក្នុងបទថា **អាមន្តេសិ** នេះ មានសេចក្តីដូច្នេះ ។ តែក្នុងទីដទៃ ប្រើក្នុងអត្ថថា ឲ្យដឹងក៏មាន ។ ដូចដែលត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ តថាគតសូមប្រាប់អ្នកទាំងឡាយឲ្យជ្រាប សូមដាស់តឿនអ្នកទាំងឡាយ ។ ប្រើក្នុងអត្ថថា **ហៅ** ក៏មានដូចដែលត្រាស់ទុកមកនេះថា មកនេះភិក្ខុ អ្នកចូរហៅសារីបុត្រមក តាមពាក្យរបស់តថាគត ។

បទថា **ភិក្ខវោ** សម្តែងអាការហៅ ។ ក៏បទនោះ ត្រាស់ព្រោះសម្រេចដោយការប្រកបដោយគុណ គឺ ភាពជាអ្នកសូមដោយប្រក្រតី ។ អ្នកប្រាជ្ញសទ្ទ-សាស្ត្រ រមែងសម្គាល់ថា ក៏ភិក្ខុដែលប្រកបដោយគុណ គឺ ភាពជាអ្នកសូមជាប្រក្រតីក៏មាន ប្រកបដោយគុណ គឺ ភាពជាអ្នកសូមជាធម្មតាក៏មាន ប្រកបដោយគុណ គឺ ភាពជាអ្នកមានប្រក្រតីធ្វើល្អក្នុងការសូមក៏មាន ។ ព្រះដ៏មានព្រះភាគ

នឹងទ្រង់ប្រកាសការប្រព្រឹត្ត ដែលបុគ្គលអាក្រក់ និងបុគ្គលល្អសេពហើយ ទើបទ្រង់ធ្វើការគ្របសង្កត់សេចក្តីលំបាកមិនដែលលើកឡើង ដោយព្រះតម្រាស់នោះដែលសម្រេចដោយការប្រកបដោយគុណ មានការសូមជាប្រក្រតីជាដើម របស់ភិក្ខុទាំងនោះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើភិក្ខុទាំងនោះ ឲ្យបែរមុខចំពោះព្រះភក្ត្ររបស់ព្រះអង្គ ដោយព្រះតម្រាស់ដែលទ្រង់ទតព្រះនេត្រចុះ ដោយព្រះហឫទ័យដ៏ស្រស់ថ្លា ផ្សាយទៅដោយព្រះករុណាជាខាងមុខថា **ភិក្ខវោ** នេះ ទ្រង់ធ្វើឲ្យភិក្ខុទាំងនោះកើតសេចក្តីប្រាថ្នានឹងស្តាប់ ដោយព្រះតម្រាស់ដែលពុទ្ធបំណងនឹងត្រាស់សម្តែងនោះឯង និងទ្រង់ជាស់តឿនភិក្ខុទាំងនោះទុក សូម្បីក្នុងការតាំងចិត្តស្តាប់ដោយល្អ ដោយព្រះតម្រាស់នោះ ដែលមានអត្ថថា ធ្វើឲ្យភ្ញាក់នោះឯង ។ ពិតហើយ ព្រះសាសនានឹងបរិបូរណ៍បាន ក៏ព្រោះការតាំងចិត្តស្តាប់ដោយល្អ ។

បើមានពាក្យសួរថា កាលទេវតា និងមនុស្សសូម្បីពួកដទៃក៏មានហើយ ព្រោះហេតុអ្វី ព្រះដ៏មានព្រះភាគ ទើបត្រាស់ហៅចំពោះភិក្ខុទាំងនោះ ។

ឆ្លើយថា ព្រោះភិក្ខុទាំងនោះជាអ្នកចម្រើនបំផុត ប្រសើរបំផុត នៅជិត និងជាអ្នកនៅប្រចាំ ។ ពិតណាស់ ព្រះធម៌ទេសនារបស់ព្រះដ៏មានព្រះភាគ រមែងមានដល់សត្វទាំងពួង ។ តែភិក្ខុទាំងឡាយ ឈ្មោះថា ជាអ្នកចម្រើនបំផុត របស់បរិស័ទ ក៏ព្រោះជាអ្នកកើតមុន ។ និងឈ្មោះថា ជាអ្នកប្រសើរបំផុត ក៏ព្រោះជា

អ្នកដើរតាមព្រះចរិយារបស់ព្រះសាស្តា ផ្តើមតាំងពីអ្នកដែលមិនគ្រប់គ្រងផ្ទះ និង ព្រោះជាអ្នកទទួលព្រះសាសនាទាំងអស់ ។ ឈ្មោះថា ជាអ្នកជិត ព្រោះកាលលោកអង្គុយក្នុងទីនោះៗ ក៏ជិតព្រះសាស្តាទាំងនោះ ។ ឈ្មោះថា នៅជាប្រចាំ ក៏ព្រោះប្រគល់កាយថ្វាយខ្លួនតែក្នុងសំណាក់ព្រះសាស្តា ។ម្យ៉ាងទៀត ភិក្ខុទាំងនោះ ឈ្មោះថា ជាភាជនៈទ្រទទួលព្រះធម្មទេសនា ព្រោះកើតដោយការបដិបត្តិតាមដែលទ្រង់ទូន្មាន សូម្បីព្រោះហេតុនោះ ព្រះអង្គទើបត្រាស់ហៅភិក្ខុទាំងនោះដោយប្រការដូច្នេះ ។

សួរថា ក៏ដើម្បីប្រយោជន៍អ្វី ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងធម៌ ទើបត្រាស់ហៅភិក្ខុជាមុន ទ្រង់មិនសម្តែងធម៌តែម្តងទៅ ។

ឆ្លើយថា ដើម្បីឲ្យកើតសតិ ។ សេចក្តីពិត ភិក្ខុទាំងឡាយ គិតរឿងដទៃក៏មាន មានចិត្តរវើរវាយក៏មាន ពិចារណាធម៌ក៏មាន អង្គុយមនសិការកម្មដ្ឋានក៏មាន ភិក្ខុទាំងនោះ កាលមិនត្រាស់ហៅឲ្យដឹង (ខ្លួន) ទ្រង់សម្តែងធម៌ទៅ ក៏មិនអាចនឹងកំណត់បានថា ទេសនានេះ មានអ្វីជាហេតុ មានអ្វីជាបច្ច័យ ព្រះអង្គទ្រង់សម្តែង ព្រោះអត្ថុប្បត្តិ (ហេតុកើតរឿង) ដូចម្តេច? នឹងគប្បីទទួលយកបានលំបាក ឬមិនគប្បីទទួលយកឡើយ ។ ដើម្បីឲ្យភិក្ខុទាំងនោះកើតសតិដោយព្រះតម្រាស់នោះ ព្រះដ៏មានព្រះភាគ ទើបត្រាស់ហៅជាមុន ហើយទើបទ្រង់សម្តែង

ធម៌ជាខាងក្រោយ ។

បទថា **ភទន្តេ** នេះ ជាពាក្យសម្តែងសេចក្តីគោរព ឬជាការថ្វាយពាក្យឆ្លើយតប (គឺទទួលតប) ចំពោះព្រះសាស្តា ។ ម្យ៉ាងទៀត ក្នុងទីនេះ ព្រះដ៏មាន-ព្រះភាគកាលត្រាស់ថា **ភិក្ខវោ** ឈ្មោះថា ហៅភិក្ខុទាំងនោះ ។ ភិក្ខុទាំងឡាយកាលទូលថា **ភទន្តេ** ឈ្មោះថា ទទួលតបព្រះដ៏មានព្រះភាគជាខាងក្រោយ ។ មួយទៀត ព្រះដ៏មានព្រះភាគ ត្រាស់ហៅថា **ភិក្ខវោ** ។ ភិក្ខុទាំងឡាយ ក្រាបទូលជាខាងក្រោយថា **ភទន្តេ** ។ ព្រះដ៏មានព្រះភាគ បង្គាប់ឲ្យភិក្ខុឆ្លើយតបព្រះតម្រាស់ដែលថា **ភិក្ខវោ** ។ ភិក្ខុថ្វាយពាក្យឆ្លើយថា **ភទន្តេ** ។

បទថា **តេ ភិក្ខូ** បានដល់ ពួកភិក្ខុដែលព្រះដ៏មានព្រះភាគត្រាស់ហៅ ។ បទថា **ភគវតោ បច្ចស្សោសុំ** សេចក្តីថា ភិក្ខុទាំងឡាយបានស្តាប់ចំពោះព្រះតម្រាស់ត្រាស់ហៅរបស់ព្រះដ៏មានព្រះភាគ ។ អធិប្បាយថា បែរមុខមកស្តាប់ គឺ ទទួល បានដល់ ផ្គង (ចិត្ត) ទទួល ។ បទថា **ភគវា ឯតទវោច** សេចក្តីថា ព្រះដ៏មានព្រះភាគ បានត្រាស់ពាក្យនោះ គឺ ព្រះសូត្រទាំងអស់ដែលនឹងគប្បីពោលក្នុងឥឡូវនេះ ។

ក៏ដោយពាក្យត្រឹមតែប៉ុណ្ណេះ ពាក្យចាប់ផ្តើមណា ដែលប្រកបដោយកាល , អ្នកសម្តែង , ទេសៈ , បរិស័ទ និងប្រទេស ព្រះអានន្ទពោលហើយ

ដើម្បីកំណត់យកព្រះសូត្រនេះបានដោយងាយ ។ ការពណ៌នាខ្លឹមសារនៃពាក្យចាប់ផ្តើមនោះ ចប់បរិបូណ៌ហើយ ដូច្នេះឯង ។

ឥឡូវនេះ មកដល់ឱកាសពណ៌នាព្រះសូត្រ ដែលព្រះដ៏មានព្រះភាគទ្រង់តាំងទុក ដោយន័យជាដើមថា **នាហំ ភិក្ខវេ អញ្ញំ ឯករូបំបិ សមនុបស្សាមិ** ដូច្នេះហើយ ។

ក៏ការពណ៌នាសេចក្តីនោះ ព្រោះហេតុដែលកំពុងពោលពិចារណាហេតុតាំងឲ្យព្រះសូត្រប្រាកដ ដូច្នោះ បណ្ឌិតគប្បីជ្រាបការពិចារណាហេតុតាំងឲ្យព្រះសូត្រមុន ។

ពិតណាស់ ហេតុតាំងនៃព្រះសូត្រ មាន ៤ យ៉ាង គឺ កើតព្រោះអជ្ឈាស្រ័យរបស់ខ្លួន ១ កើតព្រោះអជ្ឈាស្រ័យរបស់អ្នកដទៃ ១ កើតដោយអំណាចពាក្យសួរ ១ កើតព្រោះហេតុកើតរឿង ១ ។ ក្នុងហេតុទាំង ៤ យ៉ាងនោះ ព្រះសូត្រពួកណា ព្រះដ៏មានព្រះភាគ ដែលអ្នកដទៃមិនបានអារាធនា ត្រាស់ដោយព្រះអជ្ឈាស្រ័យរបស់ព្រះអង្គតែម្យ៉ាង ដូចជាអាកង្ខេយ្យសូត្រ , វត្ថសូត្រ ជាដើម សូត្រទាំងនោះ ឈ្មោះថា **មានហេតុកើតពីអជ្ឈាស្រ័យរបស់ព្រះអង្គ** ។

មួយទៀត សូត្រពួកណាដែលព្រះអង្គទ្រង់ពិចារណាមើល អជ្ឈាស្រ័យសេចក្តីពេញចិត្ត បុណ្យចាស់ និងសេចក្តីត្រាស់ដឹង ហើយត្រាស់ដោយអជ្ឈា-

ស្រ័យរបស់អ្នកដទៃយ៉ាងនេះថា ធម៌ជាគ្រឿងបន្ទុំវិមុត្តិរបស់ព្រះរាហុលឲ្យចាស់ក្លាហើយ យ៉ាងណា តថាគតគប្បីណែនាំក្នុងធម៌ជាទីអស់អាសវៈឲ្យក្រៃលែង ៗ ឡើងដល់ព្រះរាហុល ដូចជា រាហុលោវាទសូត្រ ធម្មចក្កប្បវត្តនសូត្រជាដើម សូត្រទាំងនោះ ឈ្មោះថា **មានហេតុកើតព្រោះអធ្យាស្រ័យរបស់អ្នកដទៃ** ។

ក៏ទេវតា និងមនុស្សទាំងនោះ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ហើយសួរបញ្ហាដោយប្រការផ្សេងៗ ព្រះដ៏មានព្រះភាគ ត្រូវទេវតា និងមនុស្សទាំងនោះ ទូលសួរហើយ ត្រាស់សូត្រណា មានទេវតាសំយុត្ត និងពោជ្ឈង្គសំយុត្តជាដើម ។ សូត្រទាំងនោះ ឈ្មោះថា **មានហេតុកើតដោយអំណាចពាក្យសួរ** ។

មួយទៀត សូត្រពួកណា ព្រះដ៏មានព្រះភាគត្រាស់ព្រោះអាស្រ័យហេតុកើតឡើង ដូចជាធម្មទាយាទសូត្រ និងបុត្តមំសូបមសូត្រជាដើម សូត្រទាំងនោះឈ្មោះថា **មានហេតុដោយហេតុកើតរឿងឡើង** ។

ក្នុងហេតុឲ្យកើតព្រះសូត្រទាំង ៤ នេះ សូត្រនេះឈ្មោះថា មានហេតុឲ្យកើតពីអធ្យាស្រ័យរបស់អ្នកដទៃ ។ ពិតហើយ សូត្រនេះ កើតឡើងដោយអំណាចអធ្យាស្រ័យរបស់អ្នកដទៃ ។ សួរថា ដោយអធ្យាស្រ័យរបស់អ្នកណា? ឆ្លើយថា របស់បុរសអ្នកជូន់ក្នុងរូប ។

ក្នុងបទទាំងនោះ ន អក្សរ ក្នុងពាក្យថា **នាហំ ភិក្ខវេ** ជាដើម មាន

បដិសេធជាអត្ត ។ ដោយបទថា **អហំ** សម្ដែងអាងដល់ព្រះអង្គ ។ ព្រះដ៏មាន-ព្រះភាគ ត្រាស់ហៅភិក្ខុទាំងនោះថា **ភិក្ខវេ** ។ បទថា **អញ្ញំ** សេចក្ដីថា ដល់រូបដទៃ ក្រៅពីរូបស្ត្រីដែលគប្បីពោលក្នុងកាលឥឡូវនេះ ។ បទថា **ឯករូបំបិ** ប្រែថា រូបសូម្បីតែម្យ៉ាង ។ បទថា **សមនុបស្សាមិ** សេចក្ដីថា សមនុបស្សនា ២ យ៉ាង គឺ ញាណសមនុបស្សនា ១ ទិដ្ឋិសមនុបស្សនា ១ ។ ក្នុងពីរយ៉ាងនោះ អនុបស្សនាថា ភិក្ខុឃើញថាជារបស់មិនទៀង មិនមែនឃើញថាជារបស់ទៀង នេះឈ្មោះថា **ញាណសមនុបស្សនា** ។ ចំណែកអនុបស្សនា មានជាដើមថា ភិក្ខុពិចារណាឃើញរូបជាអត្តា ឈ្មោះថា **ទិដ្ឋិសមនុបស្សនា** ។ ក្នុងពីរយ៉ាង នោះ ក្នុងទីនេះ លោកបំណងយក ញាណសមនុបស្សនា ។ តែគប្បីជ្រាបការ ភ្ជាប់បទនេះដោយ ន អក្សរ ។ លោកពោលអធិប្បាយទុកដូច្នេះថា ភិក្ខុទាំងឡាយ តថាគតសូម្បីកាលត្រួតមើលដោយសព្វញ្ញុតញ្ញាណ ក៏មើលមិនឃើញ សូម្បីរូបដទៃត្រឹមតែមួយ ។

បទថា **យំ ឯវំ បុរិសស្ស ចិត្តំ បរិយាទាយ តិដ្ឋតិ** សេចក្ដីថា រូបណាធ្វើកុសលចិត្តឲ្យប្រព្រឹត្តទៅក្នុងភូមិ ៤ របស់បុរសអ្នកជួនក្នុងរូប ឲ្យអស់ទៅ តាំងបានហើយ ។ ពិតហើយ ការប្រកាន់ ឈ្មោះថា ការប្រកាន់មាំ បានក្នុងពាក្យថា ប្រកាន់មាំក្នុងកាយស្ត្រីទាំងអស់ ជាដើម ។ ឈ្មោះថា ឲ្យអស់ទៅ

បានក្នុងពាក្យជាដើមថា ម្នាលភិក្ខុទាំងឡាយ អនិច្ចសញ្ញា ដែលភិក្ខុអប់រំហើយ ធ្វើឲ្យច្រើនហើយ ធ្វើកាមរាគៈទាំងពួងឲ្យអស់ទៅ ។ ក្នុងទីនេះ ក៏ត្រូវទាំងពីរយ៉ាង ។ ក្នុងការប្រកាន់ និងការឲ្យអស់ទៅ ទាំងពីរយ៉ាងនោះ រូបនេះ កាលកាន់យកកុសលចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ឈ្មោះថា កាន់យក ដូចបុរសយកដៃកាន់ទងផ្កាឧប្បល ផ្កាឈូកស ក៏មិនមែន កាលធ្វើឲ្យអស់ទៅ ឈ្មោះថា ធ្វើឲ្យអស់ទៅ ដូចភ្លើងដែលធ្វើទឹកលើចង្ក្រានឲ្យក្តៅ ហើយឲ្យអស់ទៅ ក៏មិនមែន ។ មួយទៀត ១ រូបដែលហាមការកើតឡើងនៃកុសលចិត្តនោះ នុ៎ះឯងគប្បីជ្រាបថា ឈ្មោះថា ប្រកាន់ និងធ្វើកុសលចិត្តសូម្បីដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ឲ្យអស់ទៅ ។ ដោយហេតុនោះទើបត្រាស់ថា **បុរិសស្ស ចិត្តំ បរិយាទាយ តិដ្ឋតិ** (គ្របសង្កត់ចិត្តរបស់បុរសហើយស្ថិតនៅ) ។

បទថា **យថយិទំ** កាត់ជា **យថា ឥទំ** ។ បទថា **ឥត្ថីរូបំ** ប្រែថា រូបរបស់ស្ត្រី ។ ក្នុងពាក្យថា **រូប** នោះ គប្បីជ្រាបអត្ថនៃពាក្យ និងសាមញ្ញលក្ខណៈនៃរូប តាមសេចក្តីនៃសូត្រថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកពោលរូបដូចម្តេច? ម្នាលភិក្ខុទាំងឡាយ ធម្មជាតិណារមែងបែកធ្លាយ ព្រោះហេតុនោះ ធម្មជាតិនោះទើបហៅថា រូប ។ រូប រមែងបែកធ្លាយទៅព្រោះហេតុអ្វី ? រមែងបែកធ្លាយទៅព្រោះត្រជាក់ខ្លះ រមែងបែកធ្លាយទៅព្រោះក្តៅខ្លះ ។

ក៏សព្ទថា **រូប** នេះ រមែងបានក្នុងអត្ថច្រើនយ៉ាង ដូចជា ខន្ធ , ភព , និមិត្ត , បច្ច័យ , សរីរៈ , វណ្ណៈ , សណ្ឋាន ជាដើម ។ ពិតណាស់ សព្ទថា **រូប** នេះ ប្រើក្នុងអត្ថថា **រូបក្ខន្ធ** ក្នុងប្រយោគនេះថា រូបក្ខន្ធយ៉ាងណាមួយ ដែលជាអតីត អនាគត និងបច្ចុប្បន្ន ។ ប្រើក្នុងអត្ថថា **រូបភព** ក្នុងប្រយោគ នេះថា ចម្រើនមគ្គដើម្បីឧប្បត្តិក្នុងរូបភព ។ ប្រើក្នុងអត្ថថា **កសិណនិមិត្ត** ក្នុង ប្រយោគនេះថា កំណត់រូបខាងក្នុង ឃើញរូបកសិណខាងក្រៅ ។ ប្រើក្នុង អត្ថថា **បច្ច័យ** ក្នុងប្រយោគនេះថា អកុសលធម៌ដ៏លាមកទាំងដែលមានរូប និង មិនមានរូប រមែងកើតឡើង ។

ប្រើក្នុងអត្ថថា **សរីរៈ** ក្នុងប្រយោគនេះថា អាកាសដែលហោមព័ទ្ធ ជុំវិញខ្ទង់ក៏ហៅថា សរីររូប ដូចគ្នា ។ ប្រើក្នុងអត្ថថា **វណ្ណៈ** ក្នុងប្រយោគនេះ ថា អាស្រ័យចក្ខុ និងវណ្ណរូប ក៏កើតចក្ខុវិញ្ញាណ ។ ប្រើក្នុងអត្ថថា **សណ្ឋាន** ក្នុងប្រយោគនេះថា អ្នកកាន់យកសណ្ឋាននៃរូបជាប្រមាណ ជ្រះថ្លាក្នុងសណ្ឋាន នៃរូប ។ គប្បីសង្គ្រោះរូប មានជាដើមថា **បិយរូបំ សាតរូបំ អរសរូបោ** (រូបគួរស្រឡាញ់ រូបគួរីករាយ អ្នកមានរូបមិនគួរត្រេកអរ) ដោយ **អាទិ** សព្ទ ។ តែក្នុងទីនេះ រូប សព្ទនោះ ប្រើក្នុងអត្ថថា វណ្ណៈ ពោលគឺ រូបាយតនៈ ដែល មានសមុដ្ឋាន ៤ របស់ស្ត្រី ។ មុ្យាងទៀត **វណ្ណៈ** (ពណ៌) យ៉ាងណាមួយ

ដែលទាក់ទងដោយកាយរបស់ស្ត្រី មិនថា សំពត់ដែលស្លៀកដណ្ដប់ គ្រឿងប្រដាប់ក្លិនក្រអូប និងពណ៌សម្បុរជាដើម ឬគ្រឿងប្រដាប់ និងរបៀបផ្កាឈើ រមែងសម្រេចជាអារម្មណ៍នៃចក្ខុវិញ្ញាណរបស់បុរស ។ ទាំងអស់នោះ គប្បីជ្រាបថា ជារូបនៃស្ត្រី ដូចគ្នា ។

បទថា **ឥត្ថីរូបំ ភិក្ខវេ បុរិសស្ស ចិត្តំ បរិយាទាយ តិដ្ឋតិ** នេះ ត្រាស់ទុក ដើម្បីធ្វើពាក្យដែលត្រាស់មកមុនទុំះឯងឲ្យធ្ងន់ ។ ឬពាក្យមុន ត្រាស់ទុកដោយអំណាចឧបមាយ៉ាងនេះថា **យថយិទំ ភិក្ខវេ ឥត្ថីរូបំ** (ដូចជារូបស្ត្រីនេះ ម្នាលភិក្ខុទាំងឡាយ) ។ តែពាក្យនេះ ត្រាស់ដោយអំណាចការចង្អុលការៈនៃសេចក្ដីប្រកាន់ ។

ក្នុងរូបស្ត្រីគ្របសង្កត់នោះ មានរឿងសាធកៈដូចតទៅនេះ ៖

បានឮថា ព្រះរាជាទ្រង់ព្រះនាមថា មហាទាឋិកនាគ ឲ្យសាងព្រះសថូបធំ ត្រង់ល្អាងអម្ពដ្ឋៈ ជិតចេតិយគិរីវិហារ ធ្វើគិរិកណ្ឌវាហនបូជា (បូជាដោយនាំរបស់ដែលកើតក្នុងភ្នំមក) មានពួកនាងស្នំហែហមស្ដេចទៅកាន់ចេតិយគិរីវិហារ ថ្វាយមហាទានដល់ភិក្ខុសង្ឃ តាមកាលដែលសមគួរ ។ ធម្មតាថា ស្ថានទីដែលជនដ៏ច្រើនប្រជុំគ្នា ជនទាំងអស់មិនមានសតិដែលនឹងតាំងមាំបាន ។ ព្រះអគ្គមហេសីរបស់ព្រះរាជា ទ្រង់ព្រះនាមថា ទមិឡទេវី ទ្រង់តាំងនៅក្នុងវ័យក្រមុំ

គួរពិករាយ គួរពិសម័យ ។ គ្រានោះព្រះថេរៈមួយរូប ឈ្មោះចិត្តៈ អ្នកបួសចាស់ កាលក្រឡេកមើលដោយទំនងដែលមិនសង្រួម ក៏កាន់យកនិមិត្តក្នុងរូបារម្មណ៍ របស់ព្រះអគ្គមហេសីនោះ ដូចជាមនុស្សឆ្កួត ។ ដើរនិយាយក្នុងកន្លែងដែល ខ្ទួនឈរ និងអង្គុយថា ឱព្រះនាងទមិឡទេវីអើយ ឱព្រះនាងទមិឡទេវីអើយ ។ តាំងពីនោះមក ភិក្ខុកម្លោះ និងសាមណេរ ហៅលោកថា ព្រះឧម្មត្តិកចិត្តត្ថេរៈ (ភិក្ខុឆ្កួត) ។ មិនយូរប៉ុន្មាន ព្រះទេវីនោះក៏ទិវង្គតទៅ ។ កាលភិក្ខុសង្ឃទៅ ក្នុងព្រៃជាទីចោលសាកសពហើយត្រឡប់មក ភិក្ខុកម្លោះ និងសាមណេរ បាន ទៅកាន់សម្នាក់របស់លោក ពោលយ៉ាងនេះថា លោកម្ចាស់ចិត្តត្ថេរៈ លោក រំពឹងដល់ព្រះទេវីអង្គណា ពួកខ្ញុំករុណាទៅព្រៃស្មសាន ជួបព្រះទេវីអង្គនោះ ត្រឡប់មកហើយ សូម្បីភិក្ខុកម្លោះ និងសាមណេរទាំងឡាយនិយាយយ៉ាងនោះ លោកក៏មិនជឿ បានតែនិយាយដូចមនុស្សឆ្កួតថា ពួកលោកទៅឃើញនរណាៗ ក៏បានក្នុងព្រៃជាទីចោលសាកសព មុខរបស់ពួកលោកទើបមានពណ៌ដូចផ្សែង ភ្លើង ។ រូបនៃស្ត្រីនេះ បានគ្របសង្កត់ចិត្តរបស់ព្រះចិត្តត្ថេរៈ ហើយក៏ឆ្កួត តាំង នៅដោយប្រការដូច្នេះ ។

រឿងមួយទៀត បានឮមកថា ថ្ងៃមួយព្រះមហារាជា ទ្រង់ព្រះនាមថា សទ្ធាតិស្សៈ មានពួកស្រីស្នំហែហមស្ដេចមកកាន់វិហារ ។ ភិក្ខុកំលោះមួយរូប

ឈរត្រង់ស៊ុមទ្វារនៃលោហប្រសាទ តាំងនៅក្នុងសេចក្តីមិនសង្រួមក្រឡេកមើលស្ត្រីម្នាក់ ។ ចំណែកស្ត្រីនោះ ក៏ឈប់ក្រឡេកមើលភិក្ខុកម្លោះរូបនោះដែរ ។ ទាំងពីរនាក់ ត្រូវភ្លើង គឺ រាគៈ ដែលតាំងឡើងក្នុងទ្រូង ដុតពោល បានស្លាប់ទៅជាមួយគ្នា ។ រូបនៃស្ត្រី បានគ្របសង្កត់ចិត្តរបស់ភិក្ខុកម្លោះ ហើយតាំងនៅដោយប្រការយ៉ាងនេះ ។

រឿងមួយទៀត ដំណាលមកថា ភិក្ខុកម្លោះមួយរូប ចេញពីកល្យាណិ-មហាវិហារ ទៅកាន់ស្រុកកាឡទីឃវាបិគ្រាម ដើម្បីសម្តែងព្រះបាតិមោក្ខ សម្រេចការសម្តែងព្រះបាតិមោក្ខហើយ កាលមិនជឿកាន់ពាក្យនិយាយរបស់អ្នកប្រាជ្ញាល្អ គិតថា ក្នុងទីដែលទៅហើយ យើងត្រូវភិក្ខុកម្លោះ និងសាមណេរសួរហើយ គួរនឹងប្រាប់អាការដែលយើងអាស្រ័យក្នុងស្រុក ដូច្នេះហើយ ទើបត្រាច់ទៅបិណ្ឌបាតក្នុងស្រុក កាន់យកនិមិត្តក្នុងវិសភាគារម្មណ៍ (អារម្មណ៍ដែលជាសត្រូវ) ហើយទៅកាន់ទីនៅរបស់ខ្លួន ចាំសំពត់ដែលនាងស្លៀកដណ្តប់បាន សួរថា លោកម្ចាស់ លោកបានសំពត់នេះមកយ៉ាងណា? ដឹងថា នាងស្លាប់ហើយ គិតថា ស្ត្រីឈ្មោះនេះស្លាប់ព្រោះយើង ដូច្នេះ ត្រូវភ្លើង គឺ រាគៈដែលតាំងឡើង ដុតពោល ក៏អស់ជីវិតទៅ ។ បណ្ឌិតគប្បីជ្រាបថា រូបរបស់ស្ត្រី គ្របសង្កត់ចិត្តរបស់បុរសហើយតាំងនៅ សូម្បីដោយអាការយ៉ាងនេះ ។

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

[៣] *សូត្រទី ២ ជាដើម លោកពោលហើយ ដោយអំណាចនៃបុគ្គលដែលធ្ងន់ក្នុងសំឡេងជាដើម ។ បណ្តាទាំងនោះ បទថា* **ឥត្ថិសទ្ទោ** *បានដល់សំឡេងនិយាយ ច្រៀង និងប្រគំ ដែលមានចិត្តជាសមុដ្ឋានរបស់ស្ត្រី ។ម្យ៉ាងទៀត សំឡេងពិណ , ខ្លុយ , ស័ង្ខ , ស្គរជាដើម ដែលសម្រេចដោយការប្រកបរបស់ស្ត្រី ដែលមានគ្រឿងស្លៀកដណ្តប់ខ្វះ ដែលមានគ្រឿងប្រដាប់ខ្វះ គប្បីជ្រាបថា សំឡេងរបស់ស្ត្រីនោះឯង ។ ពិតហើយ សំឡេងស្ត្រីទាំងអស់នោះរមែងគ្របសង្កត់ចិត្តរបស់បុរស ដូច្នេះឯង ។ ក្នុងសូត្រនោះ គប្បីជ្រាបរឿងក្តាមមាស សត្វក្ងោកមាស និងកិន្នរកម្លោះជាដើម ។*

*ដូចបានស្តាប់មក ហ្វូងស្តេចដំរីធំ អាស្រ័យនៅញកភ្នំ ។ ក្នុងទីមិនឆ្ងាយញកភ្នំនោះ មានស្រះដ៏ធំសម្រាប់ប្រើប្រាស់ ។ ក្នុងស្រះនោះ មានក្តាមមាសខ្លួនវែង ក្តាមមាសនោះ យកតង្កៀបចាប់ជើងសត្វដែលនាំគ្នាមកចុះស្រះនោះ ដូចចាប់ដោយតង្កៀប ហើយឲ្យនៅក្នុងអំណាចរបស់ខ្លួន ហើយធ្វើឲ្យស្លាប់ ។ ស្តេចដំរីសូមឱកាសក្តាមមាសនោះ ប្រើដំរីធំមួយឲ្យជាប្រធានត្រាច់ទៅ ។ ថ្ងៃមួយក្តាមនោះ ចាប់ស្តេចដំរីនោះបាន ។ ស្តេចដំរីដែលសម្បូរណ៍ដោយកម្លាំង និងសតិ គិតថា បើយើងនឹងស្រែកព្រោះខ្លាច ដំរីទាំងអស់នឹងលេងតាមសេចក្តីពេញ*

ចិត្ត នឹងគេចចេញទៅ ទើបបានឈរស្ងៀមទ្រឹងឯង លុះដឹងថា ហ្វូងដំរីឡើងអស់ហើយ ទើបស្រែកដើម្បីឲ្យកិរិយារបស់ខ្លួនដឹងថា ខ្លួនត្រូវក្ដាមមាសកៀប ទើបពោលយ៉ាងនេះថា ៖

ក៏ក្ដាមពណ៌ដូចមាស មានភ្នែកលៀន មានធ្អឹងជំនួស
ស្បែកអាស្រ័យនៅក្នុងទឹក មិនមានរោម យើងត្រូវវា
កៀប ស្រែកយំសូមសេចក្ដីអាណិត នាងកុំលះបង់
ចោលខ្ញុំ នាងដូចជាជីវិតខ្ញុំ

កិរិយាបានស្ដាប់ដូចនោះ ដឹងថា ស្វាមីត្រូវក្ដាមកៀប ទើបចចារជាមួយដំរីខ្លះ ជាមួយក្ដាមខ្លះ ដើម្បីឲ្យស្វាមីផុតពីភ័យនោះ ទើបបានពោលយ៉ាងនេះថា ៖

បាអើយ ខ្ញុំនឹងមិនលះបង់អ្នក ដែលមានជាតិជាដំរី
មានអាយុ ៦០ ឆ្នាំ អ្នកជាទីស្រឡាញ់ ក្រៃលែងរបស់ខ្ញុំ
លើផែនដីដែលមានទ្វីបទាំង ៤ ជាព្រំដែន ក្ដាមពួក
ណានៅក្នុងសមុទ្រ ក្នុងទន្លេគង្គា និងក្នុងទន្លេយមុនា
លោកជាសត្វកើតក្នុងទឹកដ៏ប្រសើរបំផុតនៃក្ដាម ទាំង
នោះ មេត្តាដោះលែងស្វាមីរបស់នាងខ្ញុំ ដែលស្រែកយំ ។

ក្ដាមក៏លែងតង្កៀបចេញពីជើងទៅ ព្រមគ្នានឹងបានឮសំឡេងរបស់ស្ត្រី ។ លំដាប់នោះស្ដេចដំរីគិតថា នេះឯង ជាឱកាសចន្លោះរបស់វា ទើបយកជើងម្ខាងជាន់ ដោយអាការរហ័សរហួន ហើយលើកជើងទី ២ ឡើង ជាន់ឆ្អឹងខ្នងក្ដាមនោះ ធ្វើឲ្យបែកល្អិត បោះឆ្អឹងក្ដាមនោះឡើងលើគោក ។ លំដាប់នោះដំរីទាំងអស់ប្រជុំគ្នាជាន់ក្ដាមនោះឲ្យបែកល្អិត ដោយគិតថា ក្ដាមនោះជាសត្រូវរបស់ពួកយើង ។ សំឡេងរបស់ស្ត្រីគ្របសង្កត់ចិត្តរបស់ក្ដាមមាស ដោយប្រការដូច្នេះឯង ។

ចំណែកបក្សីក្ងោកមាស ចូលទៅកាន់ព្រៃហិមពាន្ត អាស្រ័យជួរនៃភ្នំធំក្រឡេកមើលព្រះអាទិត្យ ក្នុងវេលាដែលព្រះអាទិត្យរះឡើង អស់កាលជានិច្ចកាលនឹងធ្វើការរក្សាខ្លួន ទើបពោលយ៉ាងនេះថា ៖

ព្រះអាទិត្យ ជាកែវភ្នែកលោក ជាភជាឯក មានពណ៌
លឿងដូចមាស ធ្វើផ្ទៃផែនដីឲ្យស្វាងស្វៃ ឧទ័យឡើង
មក ដោយហេតុនោះ ខ្ញុំសូមនមស្ការព្រះអាទិត្យនោះ
ដែលមានពណ៌លឿងដូចមាស ធ្វើផ្ទៃផែនដីឲ្យស្វាងស្វៃ
ខ្ញុំទាំងឡាយជាអ្នកដែលលោកឃុំគ្រងហើយ ក្នុងថ្ងៃ
នេះ គប្បីនៅជាសុខរហូតអស់មួយថ្ងៃ ព្រាហ្មណ៍ទាំង

ទ្បាយពួកណា អ្នកចប់នូវវេទក្នុងធម៌ទាំងពួង ខ្ញុំសូម
នមស្ការព្រាហ្មណ៍ទាំងនោះ និងព្រាហ្មណ៍ទាំងឡាយទាំង
នោះ មេត្តារក្សាខ្ញុំដោយ ការនមស្ការរបស់ខ្ញុំ ចូរមាន
ដល់ព្រះពុទ្ធទាំងឡាយ សេចក្តីនមស្ការរបស់ខ្ញុំ ចូរមាន
ចំពោះព្រះពោធិញ្ញាណ សេចក្តីនមស្ការរបស់ខ្ញុំ ចូរមាន
ចំពោះលោកអ្នករួចផុតហើយ សេចក្តីនមស្ការរបស់ខ្ញុំ
ចូរមានចំពោះវិមុត្តិ (ធម៌ជាគ្រឿងរួចផុត) ។

សត្វក្ងោកនោះ បានធ្វើបរិត្តយ៉ាងនេះហើយ ទើបត្រាច់ស្វែងរកអាហារ ។ សត្វក្ងោកមាសនោះ ត្រាច់រកស៊ីរហូតអស់មួយថ្ងៃ ក្នុងវេលាល្ងាចទើបចូលទៅទីនៅ សម្លឹងមើលព្រះអាទិត្យដែលអស្តង្គត បានពោលសរសើរយ៉ាងនេះថា ៖

ព្រះអាទិត្យជាកែវភ្នែកលោក ជារាជាឯក មានពណ៌លឿង
ដូចមាស ធ្វើផ្ទៃផែនដីឲ្យស្វាងស្វៃ រមែងអស្តង្គតទៅ ដោយ
ហេតុនោះ ខ្ញុំសូមនមស្ការព្រះអាទិត្យនោះ ដែលមានពណ៌
លឿងដូចពណ៌មាស ធ្វើផ្ទៃផែនដីឲ្យស្វាងស្វៃ ខ្ញុំទាំងឡាយ
ជាអ្នកដែលលោកឃុំគ្រងហើយ ក្នុងថ្ងៃនេះ គប្បីនៅជាសុខ
រហូតអស់មួយយប់ ព្រាហ្មណ៍ពួកណា អ្នកចប់វេទក្នុងធម៌

ទាំងពួង ខ្ញុំសូមនមស្ការ ព្រាហ្មណ៍ទាំងនោះ និងព្រាហ្មណ៍ទាំងនោះ មេត្តារក្សាខ្ញុំ ដោយសេចក្តីនមស្ការរបស់ខ្ញុំ ចូរមានចំពោះព្រះពុទ្ធទាំងឡាយ ការនមស្ការរបស់ខ្ញុំ ចូរមានចំពោះព្រះពោធិញ្ញាណ ការនមស្ការរបស់ខ្ញុំ ចូរមានចំពោះលោកអ្នករួចផុតហើយទាំងឡាយ ការនមស្ការរបស់ខ្ញុំ ចូរមានចំពោះវិមុត្តិ (ធម៌ជាគ្រឿងរួចផុត) ។

សត្វក្ងោកនោះ បានធ្វើបរិត្តនេះហើយ ទើបសម្រេចការនៅនោះឯង ។

សត្វក្ងោកនោះ រស់នៅបានរហូតដល់អស់ ៧០០ ឆ្នាំ ដោយទំនងនេះឯង ថ្ងៃមួយបានឮសំឡេងនាងសត្វក្ងោក មុនការធ្វើបរិត្ត មិនបានរឭកការធ្វើបរិត្ត ទើបជាប់អន្ទាក់របស់នាយព្រាន ដែលព្រះរាជាបញ្ជូនទៅ សំឡេងរបស់ស្ត្រី គ្របសង្កត់ចិត្តរបស់សត្វក្ងោកមាស ដោយប្រការដូច្នេះឯង ។ បានឮថា ភិក្ខុកម្លោះដែលនៅចាតកបព្វត និងភិក្ខុកម្លោះដែលនៅសុធាមុណ្ឌកាវិហារ បានឮសំឡេងរបស់ស្ត្រី រមែងអផ្សុកហើយ ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ២

# អដ្ឋកថាសូត្រទី ៣

ក្នុងសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៤] បទថា *ឥត្ថិគន្ធោ* បានដល់ គន្ធាយតនៈរបស់ស្ត្រី មានសមុដ្ឋាន ៤ ។ ក្លិនកាយរបស់ស្ត្រីនោះ រមែងផ្សាយចេញពីក្លិនគ្រឿងចម្រើនសម្បុរជាដើមខាងក្រៅ ដែលលាបខ្លួន លោកបំណងយកក្នុងទីនេះ ។ ពិតហើយ ស្ត្រីខ្លះមានក្លិនដូចក្លិនសេះ ស្ត្រីខ្លះមានក្លិនដូចក្លិនពពែ ស្ត្រីខ្លះមានក្លិនញើសក្អែល ស្ត្រីខ្លះមានក្លិនដូចក្លិនឈាម ជនល្ងង់ខ្លៅខ្លះ ស្រឡាញ់ក្នុងស្ត្រីបែបនោះឯង ។

ចំណែកក្លិនចន្ទន៍ផ្សាយចេញពីកាយ និងក្លិនផ្កាឧប្បលផ្សាយចេញពីមាត់របស់ស្ត្រីកែវរបស់ស្តេចចក្រពត្តិ ក្លិននេះមិនមានដល់ស្ត្រីគ្រប់ជំពូក ចំពោះក្លិនគ្រឿងចម្រើនសម្បុរជាដើមខាងក្រៅ លោកបំណងយកក្នុងទីនេះ ចំណែកសត្តិរច្ឆាន មានដំរី សេះ និងគោជាដើម រមែងដើរទៅបានអស់ផ្លូវ ១ យោជន៍ ២ យោជន៍ ៣ យោជន៍ និង ៤ យោជន៍ តាមក្លិនរដូវរបស់សត្វតិរច្ឆានញី ។ មិនថា ក្លិនកាយស្ត្រី ឬក្លិនគ្រឿងស្លៀកដណ្តប់ដែលស្ត្រីស្លៀកដណ្តប់ គ្រឿងចម្រើនសម្បុរដែលស្ត្រីលាបលាប គ្រឿងប្រដាប់ និងស្មៅតផ្កាឈើជាដើមរបស់ស្ត្រីក៏ដោយ ទាំងអស់គប្បីជ្រាបថា ក្លិនស្ត្រីទាំងនោះ ។

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថាសូត្រទី ៤

ក្នុងសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៥] បទថា *ឥត្ថិរសោ* បានដល់ រសាយតនៈរបស់ស្ត្រី មានសមុដ្ឋាន ៤ ក៏ព្រះបូឡាកយត្ថេរៈ អ្នកទ្រទ្រង់ព្រះត្រៃបិដក ពោលថា រសនេះ ជារសនៃការស្ដាប់ ឬរសនៃការបរិភោគ ដោយអំណាចការបម្រើជាដើមរបស់ស្ត្រី រសនេះឈ្មោះថា រសរបស់ស្ត្រី ។

ក៏រសទឹកមាត់ ដែលប្រឡាក់សាច់បបូរមាត់ជាដើមរបស់ស្ត្រី សូម្បីតែរសនៃបបរ និងបាយជាដើម ដែលនាងឲ្យដល់ស្វាមី ទាំងអស់នេះគប្បីជ្រាបថារសនៃស្ត្រីដូចគ្នា ។ ពិតណាស់ សត្វជាច្រើនកាន់យករបស់ណាមួយ ដែលស្ត្រីមេផ្ទះឲ្យដោយដៃរបស់ខ្លួនប៉ុណ្ណោះ ថាជារបស់ឆ្ងាញ់ សូម្បីសេចក្ដីវិនាសទៅហើយ ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី៤

# អដ្ឋកថាសូត្រទី ៥

*ក្នុងសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៦] *បទថា* ***ឥត្ថិផោដ្ឋព្វំ*** *សេចក្តីថា សម្ផស្សកាយរបស់ស្ត្រី សម្ផស្ស សូម្បីរបស់សំពត់ គ្រឿងប្រដាប់ និងស្នៀតផ្កាឈើជាដើម ដែលនៅនឹងខ្លួនស្ត្រី គប្បីជ្រាបថា ផោដ្ឋព្វៈស្ត្រីទាំងនោះ ។ ក៏ផស្សៈទាំងអស់នោះ រមែងគ្របសង្កត់ចិត្តរបស់បុរសហើយស្ថិតនៅ ដូចផស្សៈដែលជាវិសភាគារម្មណ៍ (អារម្មណ៍ដែលជាសត្រូវ) របស់ភិក្ខុកម្លោះដែលកំពុងស្វាធ្យាយជាគណៈ នៅត្រង់លានវិមហាចេតិយ ។*

*ដូច្នោះ ព្រះសាស្តាទើបកាន់យកអារម្មណ៍ មានរូបារម្មណ៍ជាដើមណាមួយ ដោយអំណាចនៃអាសយៈ (អជ្ឈាស្រ័យ) និងអនុស័យ (កិលេសដែលដេកត្រាំក្នុងសន្តាន) របស់សត្វទាំងឡាយ ទើបត្រាស់ថា តថាគតមើលមិនឃើញអារម្មណ៍ដទៃ ដូច្នេះ ។ ដូចជា រូបស្ត្រី រមែងចូលដល់ចិត្តុប្បាទរបស់បុរសអ្នកធ្ងន់ក្នុងរូប រមែងរួបរឹត ឲ្យពុល ឲ្យស្រវឹង ឲ្យវង្វេង ឲ្យភ្លេចភ្លាំង យ៉ាងណា សំឡេងជាដើមដ៏សេស មិនដូច្នោះឡើយ ។ មួយទៀត សំឡេងជាដើម រមែងចូលដល់ចិត្តុប្បាទរបស់បុរសអ្នកធ្ងន់ក្នុងសំឡេងជាដើម យ៉ាងណា អារម្មណ៍*

មានរូបជាដើម ក៏មិនជាដូច្នោះ ព្រោះបណ្តាអារម្មណ៍ មានរូបារម្មណ៍ជាដើម អារម្មណ៍តែមួយ រមែងគ្របសង្កត់ចិត្តរបស់បុរសពួកខ្លះ ។ សម្រាប់បុរសពួកខ្លះ អារម្មណ៍ខ្លះ ២ អារម្មណ៍ខ្លះ ៣ អារម្មណ៍ខ្លះ ៤ អារម្មណ៍ខ្លះ ៥ គ្របសង្កត់ចិត្ត ។ ដូច្នោះ សូត្រទាំង ៥ សូត្រនេះ ព្រះអង្គត្រាស់ហើយ ដោយអំណាចបុគ្គលដែលធ្ងន់ក្នុងអារម្មណ៍ ៥ យ៉ាង មិនត្រាស់ដោយអំណាចបញ្ចគរុកជាតក ។ ចំណែកបញ្ចគរុកជាតក ក៏គួរនាំមកពោលដើម្បីជាសាក្សី ។ ពិតណាស់ ក្នុងជាតកនោះ កាលពួកអមនុស្សនាំគ្នាចាត់ចែងរានផ្សារកណ្តាលផ្លូវកន្តារ បណ្តាសម្លាញ់ ៥ នាក់ របស់មហាបុរសសម្លាញ់ អ្នកធ្ងន់ក្នុងរូប ជាប់នៅក្នុងអារម្មណ៍ ដល់សេចក្តីវិនាស ។ អ្នកធ្ងន់ក្នុងសំឡេងជាដើម ជាប់នៅក្នុងសទ្ទារម្មណ៍ជាដើម ក៏ដល់សេចក្តីវិនាស ។ រឿងដែលជាអតីត គួរនាំមកពោលដើម្បីជាសាក្សី ។

ក៏ព្រះសូត្រទាំង ៥ នេះ ព្រះអង្គត្រាស់ដោយអំណាចបុគ្គល ដែលធ្ងន់ក្នុងអារម្មណ៍ ៥ យ៉ាងប៉ុណ្ណោះ ក៏ព្រោះហេតុដែលមិនមែនត្រឹមតែបុរសតែម្យ៉ាងប៉ុណ្ណោះ ជាអ្នកធ្ងន់ក្នុងអារម្មណ៍ទាំង ៥ សូម្បីស្រ្តីក៏ជាអ្នកធ្ងន់ដូចគ្នា ដូច្នោះ ព្រះអង្គទើបត្រាស់ព្រះសូត្រ ៥ ទៀត ដោយអំណាចស្រ្តីធ្ងន់ក្នុងអារម្មណ៍ សូម្បីទាំងនោះ ។ សេចក្តីនៃព្រះសូត្រនោះ គប្បីជ្រាបដោយន័យដែលពោលហើយ

ទុះឯង ។

សូម្បីបណ្ដារឿងទាំងឡាយ ក្នុងសូត្រទី ១ គប្បីជ្រាបរឿងរបស់ស្ទំរបស់មហាពជា ដែលសម្លឹងមើលភិក្ខុកម្លោះ ដែលឈរត្រង់ទ្វារនៃលោហប្រាសាទ ហើយក៏ស្លាប់ទៅ រឿងនោះពោលទុកពិស្ដារហើយក្នុងខាងដើមទុះឯង ។

ក្នុងសូត្រទី ២ គប្បីជ្រាបរឿងស្ត្រីអ្នកអាស្រ័យរូបចិញ្ចឹមជីវិត ក្នុងក្រុងសាវត្ថី ។ ដំណាលមកថា អ្នកដេញពិណ ឈ្មោះថា គុត្តិលៈ បានបញ្ជូនទ្រព្យ ១,០០០ ទៅឲ្យស្ត្រីម្នាក់ នាងត្រឡប់ចំអកឡកឡឺយ មិនប្រាថ្នានឹងទទួល គេគិតថា យើងនឹងធ្វើវត្ថុដែលគួរធ្វើក្នុងរឿងនេះ ដល់វេលាល្ងាច ទើបតែងខ្លួនអង្គុយជិតទ្វារមួយកន្លែងត្រង់មុខផ្ទះរបស់នាង តម្លើងខ្សែពិណសមគួរហើយ ទើបច្រៀងជាមួយនឹងសំឡេងពិណ ។ ស្ត្រីនោះបានឮសំឡេងភ្លេងប្រគំរបស់គេគិតថា យើងនឹងទៅរកគេ តាមបង្អួចដែលបើកទុក ដោយការសម្គាល់ថាទ្វារ ក៏ភ្លាត់ធ្លាក់ចុះទៅរហូតអស់ជីវិត ។

ក្នុងសូត្រទី ៣ គប្បីជ្រាប ក្លិនចន្ទផ្សាយចេញពីព្រះកាយ និងក្លិនឧប្បលផ្សាយចេញពីព្រះឱស្ឋរបស់ស្ដេចចក្រពត្តិ រឿងនេះគួរនាំមកសម្ដែង ក៏ក្នុងសេចក្ដីនេះ គប្បីជ្រាបរឿងដូចតទៅនេះ ៖

បានឮមកថា ស្វាមីរបស់ធីតានៃកុដុម្ពិកៈម្នាក់ ក្នុងក្រុងសាវត្ថី ស្លាប់

ព្រះធម៌ទេសនារបស់ព្រះសាស្តា គិតថា យើងជាគ្រហស្ថ មិនអាចនឹងបំពេញធម៌នេះបាន ទើបបួសក្នុងសំណាក់របស់ព្រះបិណ្ឌបាតិកត្ថេរៈ (ព្រះថេរៈអ្នកត្រាច់បិណ្ឌបាតជាវត្ត) មួយរូប ។ គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់ជ្រាបកិរិយារបស់គេថា ស្ត្រីអ្នកនេះមិនមានស្វាមី ទើបបង្គាប់ឲ្យរាជបុរសនាំមកនៅក្នុងព្រះរាជវាំង ថ្ងៃមួយ ទ្រង់កាន់យកបាច់ផ្កាឈូកសមួយក្តាប់ ស្តេចចូលទៅក្នុងព្រះរាជវាំង ទ្រង់ប្រទានផ្កាឧប្បលដល់ស្ត្រីអ្នកអត់ផ្កា ។ កាលបែងចែកគ្នា នៅសល់ផ្កាឧប្បល ២ ផ្កា បានដល់ដៃរបស់ស្ត្រីនោះ ។ ស្ត្រីនោះសម្តែងអាការរីករាយ ហិតហើយក៏យំ ។ ព្រះរាជាទ្រង់ឃើញអាការទាំង ២ របស់នាង ទើបបង្គាប់ឲ្យហៅនាងមកត្រាស់សួរ ។ ចំណែកនាងក្រាបទូលហេតុដែលខ្លួនត្រេកអរ និងយំឲ្យទ្រង់ជ្រាប ។ សូម្បីកាលនាងក្រាបទូលលើកទី ៣ ព្រះរាជាទ្រង់មិនជឿ ថ្ងៃស្អែកឡើង ទើបបង្គាប់ឲ្យមនុស្សយករបស់ក្រអូបដែលមានក្លិនយ៉ាងល្អ មានកម្រងផ្កាឈើ និងគ្រឿងលាបជាដើមគ្រប់យ៉ាង ក្នុងព្រះរាជនិវេសន៍ចេញ ឲ្យក្រាលអាសនៈសម្រាប់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានថ្វាយមហាទានចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ក្នុងវេលាសម្រេចភត្តកិច្ច ត្រាស់សួរស្ត្រីនោះថា ព្រះថេរៈរូបណា កាលនាងក្រាបទូលថា អង្គនេះទ្រង់ជ្រាបហើយ ថ្វាយបង្គំព្រះសាស្តា ហើយទូលថា បពិត្រព្រះអង្គដ៏ចម្រើន

សូមភិក្ខុសង្ឃចូរត្រឡប់ទៅជាមួយព្រះអង្គ ព្រះថេររូបឯណោះ របស់ខ្ញុំព្រះអង្គនឹងធ្វើអនុមោទនា ។ ព្រះសាស្តាវៀរភិក្ខុអង្គនោះទុក ហើយស្តេចទៅកាន់ព្រះវិហារ ។ ពេលព្រះថេរៈផ្តើមពោលអនុមោទនា ទូទៅព្រះរាជនិវេសន៍ដូចជាពេញទៅដោយក្លិនក្រអូប ។ ព្រះរាជាទ្រង់ជ្រះថ្លាថា នាងនិយាយពិតមែនថ្ងៃស្អែក ទើបសួរដល់ហេតុនោះចំពោះព្រះសាស្តា ។ ព្រះសាស្តាត្រាស់ប្រាប់ថា ក្នុងអតីតកាល ភិក្ខុរូបនេះស្តាប់ធម្មកថា បានសាធុការថា សាធុ សាធុ មិនដាច់ បានស្តាប់ដោយគោរព មហាបពិត្រ ភិក្ខុនោះបានអានិសង្សនេះ មានការសាធុការនោះជាមូល

> ក្នុងវេលាស្តាប់ព្រះសទ្ធម្ម កាលភិក្ខុនោះពោលថា សាធុ
> សាធុ ក្លិនក្រអូបកើតចេញពីមាត់ ផ្សាយចេញទៅដូចក្លិន
> ផ្កាឧប្បល ដូច្នោះ ។

ពាក្យដ៏សេសក្នុងបទទាំងពួង ងាយទាំងនោះឯង ក្នុងវគ្គនេះលោកពោលដល់រឿងទាំងនោះ ។ បាលីពោលអំពីរូបចប់ ។

ចប់អដ្ឋកថា សូត្រទី៩

## ចប់វគ្គនិវគ្គទី ១

### រួមអដ្ឋកថាក្នុងវគ្គនេះមាន


អដ្ឋកថា សូត្រទី ១ កែស័ត្ត... អដ្ឋកថា សូត្រទី ២ សំឡេងស្ត្រី
អដ្ឋកថា សូត្រទី ៣ ក្លិនស្ត្រី អដ្ឋកថា សូត្រទី ៤ រសស្ត្រី
អដ្ឋកថា សូត្រទី ៥ សម្ផស្សស្ត្រី

# នីវរណប្បហានវគ្គទី ២[1]

## អដ្ឋកថាសូត្រទី ១

វគ្គទី ២ សូត្រ ១ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[១២] បទថា **ឯកធម្មំបិ** នេះ គប្បីជ្រាបធម៌ ដោយអត្ថថា មិនមែនសត្វ ដូចក្នុងពាក្យមានជាដើមថា ក៏ក្នុងសម័យនោះឯង ធម៌ទាំងឡាយរមែងមាន ។ ព្រោះដូច្នោះ ក្នុងបទថា **ឯកធម្មំបិ** នេះ មានសេចក្ដីដូច្នេះថា សូម្បីសភាវៈតែមួយមិនមែនសត្វ ។ ក៏ **វា** សព្ទ ក្នុងបទថា **អនុប្បន្នោ វា** នេះ មានសមុច្ចយជាអត្ថ មិនមែនមានវិកប្បជាអត្ថ ដូចជា **វា** សព្ទ ក្នុងប្រយោគយ៉ាងនេះថា **ភូតានំសត្តានំ ឋិតិយា សម្ភវេសីនំ វា អនុគ្គហាយ យាវតា ភិក្ខវេ សត្តា អបទា វា ទ្វិបទា វា** ដើម្បីតាំងនៅនៃសត្វដែលកើតហើយផង ដើម្បីអនុគ្រោះពួកសម្ភវេសីសត្វផង ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វមិនមានជើង និងសត្វជើង ២ មានប្រមាណត្រឹមណា ដូច្នេះ ។ ក៏ក្នុងប្រការនេះ មានសេចក្ដីដូច្នេះថា កាមច្ឆន្ទៈ ដែលមិនទាន់កើត រមែងកើតឡើង និងកើតឡើងហើយ រមែងប្រព្រឹត្ត

---

១ វគ្គទី ២ នេះ បាលីមិនបានបែងចែកជាសូត្រៗ តែអដ្ឋកថាបែងចែកទុក ១០ សូត្រ) ។

ទៅ ដើម្បីសេចក្តីចម្រើនជាកិយ្យាភាពព្រោះធម៌ណា តថាគតរំពឹងរកមើលមិន

ឃើញធម៌នោះ យ៉ាងដទៃ ដូចជាសុភនិមិត្តឡើយ ។

បណ្តាបទទាំងនោះ បទថា **អនុប្បន្នោ** សេចក្តីថា មិនកើត មិនកើត

ព្រម មិនប្រាកដ មិនប្រព្រឹត្តទៅ ។ បទថា **កាមច្ឆន្ទោ** បានដល់ កាមច្ឆន្ទ-

នីវរណៈ ដែលពោលទុកពិស្តារហើយ ដោយន័យមានជាដើមថា សេចក្តីពេញ

ចិត្តក្នុងកាម សេចក្តីតម្រេកក្នុងកាម សេចក្តីភ្លើតភ្លើនក្នុងកាម សេចក្តីចំណង់

ក្នុងកាមណា ។

បទថា **ឧប្បជ្ជតិ** បានដល់ កើត ប្រាកដ ។ ក៏កាមច្ឆន្ទៈនោះ គប្បីជ្រាប

ថា ដែលនៅមិនទាន់កើតរមែងកើតឡើង ដោយអំណាចការផ្សាយឡើង ឬដោយ

អារម្មណ៍ដែលមិនទាន់បានសោយ ។ ពិតណាស់ កាលពោលដោយប្រការដទៃ

កាមច្ឆន្ទៈ ឈ្មោះថា មិនកើតឡើងក្នុងសង្សារដែលមិនប្រាកដខាងដើម និងខាង

ចុង រមែងមិនមាន ។ ក្នុងប្រការនោះ កិលេស រមែងមិនផ្សាយឡើង ដល់ភិក្ខុ

រូបខ្លះ ដោយអំណាចវត្ត រមែងមិនផ្សាយឡើងដល់ភិក្ខុរូបខ្លះ ដោយអំណាច

គន្ថៈ , ធុតង្គ , សមាធិ , វិបស្សនា , និងនវកម្ម ដែលលោកធ្វើហើយ យ៉ាង

ណាមួយ ។ ពិតហើយ ភិក្ខុរូបខ្លះ ជាអ្នកសម្បូរណ៍ដោយវត្ត កាលភិក្ខុនោះ

ធ្វើខុទ្ទកវត្ត (វត្តតូច) ៨២ ប្រការ មហាវត្ត (វត្តធំ) ១២ ប្រការ ចេតិយង្គណវត្ត

ពោធិយង្គណវត្ត បានីយមាឡកវត្ត ឧបោសថាគារវត្ត អាគន្តុកវត្ត និងគមិកវត្ត កិលេស រមែងមិនបានឱកាស ។ តែគ្រាតមក កាលលោកលះបង់វត្ត បែកធ្លាយវត្តហើយត្រាច់ទៅ អាស្រ័យការធ្វើទុកក្នុងចិត្តមិនដោយឧបាយនៃប្រាជ្ញា និងការលះបង់សតិ កិលេសរមែងកើតឡើង ដូច្នោះ កិលេសមិនទាន់កើតឡើង ព្រោះមិនទាន់ផ្សាយឡើង ក៏ឈ្មោះថា រមែងកើតឡើង ។ អង្គខ្លះជាអ្នកប្រកបដោយគន្ថៈ រៀន ១ និកាយខ្លះ ២ និកាយខ្លះ ៣ និកាយខ្លះ ៤ និកាយខ្លះ ៥ និកាយខ្លះ កាលលោករៀន ស្វាធ្យាយ ប្រាប់ សម្តែង ប្រកាសពុទ្ធវចនៈ គឺ បិដក ៣ ដោយអំណាចអត្ថ ដោយអំណាចបាលី ដោយអំណាចអនុសន្ធិ ដោយអំណាចអក្សរជាខាងដើម ខាងចុង កិលេសរមែងមិនបានឱកាស ។ តមក កាលលះបង់ការរៀនសូត្រ ខ្ជិលច្រអូស ត្រាច់ទៅអាស្រ័យអយោនិសោមនសិការ និងការលះបង់សតិ កិលេសរមែងកើតឡើង ។ សូម្បីយ៉ាងនេះ កិលេសដែលនៅមិនទាន់កើតឡើង ព្រោះមិនទាន់ផ្សាយឡើង ក៏ឈ្មោះថា រមែងកើតឡើង ។

តែអង្គខ្លះជាអ្នកទ្រទ្រង់ធុតង្គ សមាទានប្រព្រឹត្តធុតង្គគុណ ១៣ ហើយ ។ ក៏កាលលោកបរិហារ គឺ រក្សាធុតង្គគុណ កិលេសរមែងមិនបានឱកាស ។ តែតមក កាលលោកលះបង់ធុតង្គ វិលមកដើម្បីប្រព្រឹត្តសេចក្តីប្រាថ្នាច្រើន អាស្រ័យ

អយោនិសោមនសិការ លះបង់សតិ កិលេសរមែងកើតឡើង ។ ព្រោះហេតុនេះ កិលេសដែលនៅមិនទាន់កើតឡើង ព្រោះមិនទាន់ផ្សាយឡើង ក៏ឈ្មោះថា រមែងកើតឡើង ។ អង្គខ្លះ មានភាពជំនាញដែលសន្សំទុកក្នុងសមាបត្តិ ៨ ។ កាលលោកប្រកបរឿយៗ ក្នុងបឋមឈានជាដើម ដោយអំណាចវសី មានអាវជ្ជវសីជំនាញចូលសមាបត្តិជាដើម កិលេសរមែងមិនបានឱកាស តែតមកកាលលោកសាបសូន្យឈាន ឬលះបង់ឈានចេញហើយ ប្រកបរឿយៗ ក្នុងកិច្ចមានកាចូលចិត្តជជែកគ្នាជាដើម អាស្រ័យអយោនិសោមនសិការ លះបង់សតិ កិលេសរមែងកើតឡើង ព្រោះហេតុនោះ កិលេសដែលនៅមិនទាន់កើត ព្រោះមិនទាន់ផ្សាយឡើង ឈ្មោះថា រមែងកើតឡើង ។

មួយទៀត អង្គខ្លះ ជាអ្នកចម្រើនវិបស្សនា ធ្វើកិច្ចក្នុងអនុបស្សនា ៧ និងមហាវិបស្សនា ១៨ ។ កាលលោករស់នៅយ៉ាងនេះ កិលេស រមែងមិនបានឱកាស តែតមក កាលលោកលះបង់កិច្ចក្នុងវិបស្សនា ប្រាថ្នាទៅក្នុងការធ្វើរាងកាយឲ្យរឹងមាំ អាស្រ័យអយោនិសោមនសិការ និងការលះបង់សតិ កិលេសរមែងកើតឡើង ព្រោះហេតុនេះ កិលេសដែលនៅមិនកើតឡើង ព្រោះមិនទាន់ផ្សាយឡើង ក៏ឈ្មោះថា រមែងកើតឡើង ។

អង្គខ្លះជាអ្នកប្រកបការងារនវកម្ម ឲ្យសាងរោងឧបោសថ និងរោងឆាន់

ជាដើម កាលលោកកំពុងគិតដល់គ្រឿងឧបករណ៍ របស់ពេងខបោសថជាដើម វេលានោះ កិលេសរមែងមិនបានឱកាស លុះតមក កាលការងារនវកម្មរបស់លោករួចរាល់ហើយ ឬលះបង់ចោល អាស្រ័យអយោនិសោមនសិការ និងការលះបង់សតិ កិលេសក៏កើតឡើង ព្រោះហេតុនេះ កិលេសដែលនៅមិនទាន់កើតឡើង ព្រោះមិនទាន់ផ្សាយឡើង ឈ្មោះថា រមែងកើតឡើង ។

អង្គខ្លះទៀត មកពីព្រហ្មលោក ជាសត្វបរិសុទ្ធ , ព្រោះខ្លួនមិនមានការសេពមកពីមុន កិលេសទើបមិនបានឱកាស តែលុះតមក បានការសេព អាស្រ័យអយោនិសោមនសិការ និងការលះបង់សតិ កិលេសរមែងកើតឡើង ព្រោះហេតុនេះ កិលេសដែលនៅមិនទាន់កើតឡើង ព្រោះមិនទាន់ផ្សាយឡើង ក៏ឈ្មោះថា រមែងកើតឡើង ។ គប្បីជ្រាបការកើតឡើងនៃកិលេស ដែលនៅមិនទាន់កើតឡើង ព្រោះមិនទាន់ផ្សាយឡើង ដោយប្រការយ៉ាងនេះចុះ ។

កិលេសដែលកើតឡើង ព្រោះអារម្មណ៍ដែលនៅមិនធ្លាប់សោយ ដូចម្តេច? ភិក្ខុរូបខ្លះ រមែងបានអារម្មណ៍ មានរូបារម្មណ៍ ដែលគួរពេញចិត្ត និងមិនគួរពេញចិត្តជាដើម ដែលខ្លួនធ្លាប់បានសោយ អាស្រ័យអយោនិសោមនសិការ និងការលះបង់សតិទៅក្នុងអារម្មណ៍នោះ រាគៈ រមែងកើតឡើងដល់ភិក្ខុនោះ ព្រោះហេតុនេះ កិលេសដែលនៅមិនទាន់កើត ព្រោះអារម្មណ៍ដែលនៅ

មិនធ្លាប់សោយ ឈ្មោះថា រមែងកើតឡើង ។

បទថា **ឧប្បន្នោ** បានដល់ កើតហើយ កើតព្រមហើយ បង្កើតហើយ បង្កើតក្រៃលែងហើយ ប្រាកដហើយ ។ បទថា **ភិយ្យោភាវាយ** បានដល់ ដើម្បីកើតមានរឿយៗ ។ បទថា **វេបុល្លាយ** បានដល់ ដើម្បីភិយ្យោភាព គឺដើម្បីសេចក្តីកពូន ។ ក្នុងប្រការនោះ ប្រការដែលពោលថា កាមច្ឆន្ទៈកើតឡើងតែមួយគ្រានឹងមិនរលត់ ឬរលត់ទៅតែមួយគ្រា នឹងមិនកើតឡើងទៀតនោះ មិនមែនជាឋានៈ ។ ក៏កាលកាមច្ឆន្ទៈមួយរលត់ទៅហើយ កាមច្ឆន្ទៈកាលកើតបន្តៗ ទៅ ក្នុងអារម្មណ៍នោះ ឬអារម្មណ៍ណាមួយ ឈ្មោះថា រមែងប្រព្រឹត្តទៅ ដើម្បីមានដ៏ក្រៃលែងឡើង ដើម្បីភិយ្យោភាពឡើង ។

បទថា **សុភនិមិត្តំ** បានដល់ អារម្មណ៍ដែលជាទីតាំងនៃរាគៈ ពិតហើយ បទថា **និមិត្តំ** ជាឈ្មោះនៃបច្ច័យ បានក្នុងពាក្យនេះថា ម្នាលភិក្ខុទាំងឡាយ អកុសល បាបធម៌ ដែលមានបច្ច័យរមែងកើតឡើង ដែលមិនមានបច្ច័យមិនកើតឡើង ។ បទថា **និមិត្តំ** ជាឈ្មោះនៃហេតុ បានក្នុងពាក្យនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបរឿយៗ នូវអធិចិត្ត គប្បីមនសិការដល់ហេតុទាំង ៥ តាមកាលដែលគួរ ។ បទថា **និមិត្តំ** ជាឈ្មោះរបស់សមាធិ បានក្នុងពាក្យនេះថា **សោ តំ និមិត្តំ អាសេវតិ ភាវេតិ** សេចក្តីថា ភិក្ខុនោះ រមែងសេព រមែងចម្រើន

សមាធិនោះ ។ បទថា **និមិត្តំ** ជាឈ្មោះនៃវិបស្សនា បានក្នុងពាក្យនេះថា កាលភិក្ខុអាស្រ័យវិបស្សនាណា មនសិការវិបស្សនាណា អាសវៈទាំងឡាយ រមែងអស់ទៅរឿយៗ ។ តែក្នុងទីនេះ ធម៌ដែលជាឥដ្ឋារម្មណ៍ ដែលជាទីតាំងនៃរាគៈ លោកបំណងយកសុភនិមិត្ត ។

បទថា **អយោនិសោ មនសិករោតោ** សេចក្ដីថា កាលភិក្ខុធ្វើទុកក្នុងចិត្តដោយមិនមែនឧបាយ ដោយអំណាចការធ្វើទុកក្នុងចិត្តយ៉ាងនេះថា បណ្ដាការធ្វើទុកក្នុងចិត្តទាំងនោះ ការធ្វើទុកក្នុងចិត្តដោយមិនជាឧបាយដូចម្ដេច? ការធ្វើទុកក្នុងចិត្តដោយមិនឧបាយ គឺ ការធ្វើទុកក្នុងចិត្តក្រៅផ្លូវ ក្នុងវត្ថុដែលមិនទៀង ថាទៀង ក្នុងវត្ថុដែលជាទុក្ខ ថាជាសុខ ក្នុងវត្ថុដែលមិនមែនជាអត្តា ថាជាអត្តា ក្នុងវត្ថុដែលមិនស្អាត ថាស្អាត ឬការរំពឹងដល់ ការនឹកដល់រឿយៗ ការចងចិត្ត ការប្រមូលចិត្ត ដោយវត្ថុដែលជាបដិកូល ដែលប្រាសចាកសេចក្ដីពិត ទាំងនេះហៅថា ការធ្វើទុកក្នុងចិត្តដោយមិនឧបាយ ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

*ក្នុងសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[១៣] បទថា* ***ព្យាបាទោ*** *បានដល់ សេចក្ដីវិបត្តិ ការលះប្រក្រតីនៃចិត្ត ដូចសេចក្ដីវិបត្តិនៃអាហារ (អាហារផ្អូម) ។ បទថា* ***ព្យាបាទោ*** *នេះ ជាឈ្មោះនៃព្យាបាទនីវរណៈ ដែលពោលទុកពិស្ដារហើយ យ៉ាងនេះថា ក្នុងនីវរណៈទាំងនោះ ព្យាបាទនីវរណៈដូចម្ដេច? គឺ សេចក្ដីអាឃាតកើតឡើងថា បុគ្គលនេះបានធ្វើសេចក្ដីវិនាសដល់យើង ។*

*បទថា* ***បដិឃនិមិត្តំ*** *បានដល់ និមិត្តដែលមិនគួរប្រាថ្នា ពាក្យថា* ***បដិឃនិមិត្តំ*** *នេះ ជាឈ្មោះរបស់បដិឃចិត្ត គំនុំគុំកួនក៏មាន ជាឈ្មោះនៃអារម្មណ៍ដែលធ្វើឲ្យគុំកួនក៏មាន សមពិតដូចពាក្យដែលព្រះអដ្ឋកថាចារ្យ ពោលទុកក្នុងអដ្ឋកថាថា សូម្បីបដិឃចិត្ត ក៏ឈ្មោះថា បដិឃនិមិត្ត សូម្បីធម៌ដែលជាអារម្មណ៍របស់បដិឃចិត្ត ក៏ឈ្មោះថា បដិឃនិមិត្ត ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបដោយន័យដែលពោលក្នុងកាមច្ឆន្ទៈនុ៎ះឯង ។ ក្នុងបដិឃនីវរណៈនេះ យ៉ាងណា សូម្បីក្នុងនីវរណៈដទៃអំពីនេះ ក៏ដូច្នោះ ។ ក៏ក្នុងសូត្រនោះៗ ខ្ញុំនឹងពោលត្រឹមតែប្រការប្លែកគ្នាប៉ុណ្ណោះឯង ។*

ចប់អដ្ឋកថា សូត្រទី ២

# អដ្ឋកថាសូត្រទី ៣

ក្នុងសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖

[១៤] បទថា **ថីនមិទ្ធំ** បានដល់ ថីនៈ និងមិទ្ធៈ ក្នុង ២ យ៉ាងនោះ ភាវៈដែលចិត្តមិនគួរដល់ការងារ ឈ្មោះថា ថីនៈ ពាក្យថា ថីនៈនេះ ជាឈ្មោះនៃសេចក្តីខ្ជិលច្រអូស ។ ភាវៈនៃខន្ធទាំង ៣ មិនគួរដល់ការងារ ឈ្មោះថា មិទ្ធៈ ។ ពាក្យថា មិទ្ធៈ នេះ ជាឈ្មោះរបស់សេចក្តីងោកងុយ ដូចការងោកងុយរបស់ស្វា ជាធម្មជាតិប្រែប្រួល ។ គប្បីជ្រាបសេចក្តីពិស្តារនៃថីនៈ និងមិទ្ធៈទាំង ២ នោះ ដោយន័យជាដើមថា ក្នុងថីនៈ និងមិទ្ធៈទាំង ២ នោះ ថីនៈ ដូចម្តេច? ភាវៈនៃចិត្តមិនគួរដល់ការងារ មិនរឹងមាំ ស្ពឹកស្ពើរ ឈ្មោះថា ថីនៈ ក្នុងថីនៈ និងមិទ្ធៈទាំង ២ នោះ មិទ្ធៈ ដូចម្តេច? ភាវៈនៃកាយមិនសមគួរ មិនគួរដល់ការងារ ងោកងុយ ឈ្មោះថា មិទ្ធៈ ។

បទថា **អរតិ** ជាដើម គប្បីជ្រាបដោយន័យដែលចែកទុកហើយក្នុងវិភង្គនុ៎ះឯង សមពិតដូចពាក្យដែលលោកពោលទុកថា បណ្តាធម៌ទាំងនោះ **អរតិ** ដូចម្តេច? ការមិនត្រេកអរ ភាវៈដែលមិនត្រេកអរ ការមិនត្រេកអរខ្លាំង ការមិនអភិរម្យ សេចក្តីខ្វាចរអា ភាពញាញើតញាញើម ក្នុងសេនាសនៈដែលស្ងាត់

ឬក្នុងអធិកុសលធម៌ដទៃៗ នេះហៅថា **អរតិ** ។ បណ្ដាធម៌ទាំងនោះ **តន្ទិ** សេចក្ដីខ្ជិលច្រអូសដូចម្ដេច? ការខ្ជិល ការច្រអូស ការធ្វើទុកក្នុងចិត្តក្នុងសេចក្ដីខ្ជិលច្រអូស សេចក្ដីខ្ជិលច្រអូស កិរិយាដែលខ្ជិលច្រអូស ភាវៈនៃអ្នកខ្ជិលច្រអូស នេះលោកហៅថា **តន្ទិ** ។ បណ្ដាធម៌ទាំងនោះ **ការមិតពត់កាយ** ដូចម្ដេច? ការពត់ ការពត់ពេន ការបង្អោនទៅ សេចក្ដីអែនអន ការមិតពត់ នេះហៅថា **វិជម្ភិកា** ។ បណ្ដាធម៌ទាំងនោះ **ការស្រវឹងក្នុងអាហារ** ដូចម្ដេច? អ្នកពេញចិត្តបរិភោគ ស្រវឹងក្នុងអាហារ លំបាកក្នុងអាហារ ទោរទន់ក្នុងកាល នេះហៅថា ការស្រវឹងក្នុងអាហារ ។ បណ្ដាធម៌ទាំងនោះ **សភាពនៃចិត្តរួញរា** ដូចម្ដេច? ភាវៈដែលចិត្តមិនសមគួរ មិនគួរដល់ការងារ សេចក្ដីធូរថយ ការរួញរា សេចក្ដីស្ទាក់ស្ទើរ សេចក្ដីអន់ថយ ភាវៈអន់ថយនៃចិត្តនេះ ហៅថា ការរួញរានៃចិត្ត ។ ក៏បណ្ដាធម៌ទាំងនេះ ធម៌ ៤ ខាងដើម ជាបច្ច័យដល់ថីនមិទ្ធនីវរណៈ ទាំងដោយសហជាតបច្ច័យ ទាំងដោយឧបនិស្សយប្បច្ច័យ ។ មួយទៀត ភាវៈដែលធូរថយ រមែងមិនជាសហជាតប្បច្ច័យដល់ខ្លួនឯង តែជាសហជាតប្បច្ច័យក្នុងទីបំផុតនៃឧបនិស្សយប្បច្ច័យ ។

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថាសូត្រទី ៤

ក្នុងសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖

[១៥] បទថា **ឧទ្ធច្ចកុក្កុច្ចំ** បានដល់ ឧទ្ធច្ចៈ និងកុក្កុច្ចៈ ។ ក្នុង ២ យ៉ាងនោះ អាការដែលចិត្តរាយមាយ ឈ្មោះថា **ឧទ្ធច្ចៈ** សេចក្តីក្តៅក្រហាយរបស់បុគ្គលដែលមិនបានធ្វើគុណ គឺ សេចក្តីល្អ ធ្វើតែសេចក្តីអាក្រក់ ព្រោះប្រការនោះជាបច្ច័យ ឈ្មោះថា **កុក្កុច្ចៈ** ។ បទថា **ចេតសោ អវូបសមោ** នេះជាឈ្មោះរបស់ឧទ្ធច្ចៈ និងកុក្កុច្ចៈ នុ៎ះឯង ។ បទថា **អវូបសន្តចិត្តស្ស** បានដល់ អ្នកមានចិត្តមិនស្ងប់ដោយឈាន និងវិបស្សនា ក៏សេចក្តីមិនស្ងប់នេះ ជាបច្ច័យដល់ឧទ្ធច្ចៈ និងកុក្កុច្ចៈ ក្នុងទីបំផុតនៃឧបនិស្សយប្បច្ច័យ ។

ចប់អដ្ឋកថា សូត្រទី៤

# អដ្ឋកថាសូត្រទី ៥

*ក្នុងសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[១៦] *បទថា* ***វិចិកិច្ឆា*** *បានដល់ វិចិកិច្ឆានីវរណៈ ដែលពោលទុកពិស្តារហើយ ដោយន័យមានជាដើមថា រមែងសង្ស័យក្នុងព្រះសាស្តា ការមិនធ្វើទុកក្នុងចិត្តដោយឧបាយ មានលក្ខណៈដូចពោលហើយនោះឯង ។*

ចប់អដ្ឋកថា សូត្រទី ៥

# អដ្ឋកថាសូត្រទី ៦

ក្នុងសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ ៖

[១៧] បទថា *អនុប្បន្នោ វា កាមច្ឆន្ទោ នុប្បជ្ជតិ* សេចក្តីថា កាមច្ឆន្ទៈដែលបានកើតឡើងដោយហេតុ ២ យ៉ាងប៉ុណ្ណោះ គឺ ដោយការមិនផុសផុលឡើង ឬដោយអារម្មណ៍ដែលមិនធ្លាប់សោយ ក៏មិនកើតឡើង ។ កាមច្ឆន្ទៈនោះ ភិក្ខុគ្រប់សង្កត់បានហើយយ៉ាងនោះ រមែងមិនបានហេតុ ឬបច្ច័យទៀត ។ សូម្បីក្នុងទីនេះ បណ្ឌិតគប្បីជ្រាប ការមិនផុសផុលឡើង ដោយអំណាចវត្តជាដើម ។ ពិតហើយ កាលភិក្ខុរូបខ្វះប្រកបក្នុងវត្ត ធ្វើនៅវត្តទាំងឯង ដោយន័យដូចពោលហើយ កិលេសរមែងមិនបានឱកាស ព្រោះដូច្នោះ កាមច្ឆន្ទៈនោះ ឈ្មោះថា ភិក្ខុគ្រប់សង្កត់ទុកបានដោយអំណាចវត្ត ភិក្ខុនោះ ធ្វើកាមច្ឆន្ទៈនោះ ដែលខ្លួនគ្រប់សង្កត់ទុកបានយ៉ាងនោះ និងវៀរដាច់ខាត រមែងប្រកាន់យកព្រះអរហត្តបាន ដូចព្រះមាលកតិស្សត្ថេរៈដូច្នោះ ។

បានឮថា ព្រះមាលកតិស្សៈ កើតក្នុងត្រកូលព្រាន ក្នុងទីភិក្ខាចារនៃគមេណ្ឌវាសីវិហារ ក្នុងរោហណជនបទ ចម្រើនវ័យហើយ ក៏គ្រប់គ្រងផ្ទះ គិតថា នឹងចិញ្ចឹមបុត្រ និងភរិយា ដាក់អន្ទាក់ទុក ១០០ ដាក់អន្ទាក់ ១០០ ចម្រូង ១០០

កន្ទែង សន្សំបាបទុកយ៉ាងច្រើន ថ្ងៃមួយកាន់យកភ្លើង និងអំបិលពីផ្ទះទៅព្រៃ សម្លាប់សត្វដែលជាប់អន្ទាក់ បរិភោគសាច់ដែលចំអិនដោយរងើកភ្លើង ស្រេកទឹក ក៏ចូលទៅគមេណ្ឌវាសីវិហារ មិនបានផឹកទឹកសូម្បីត្រឹមតែបន្ទោបង់សេចក្ដីស្រេក ក្នុងថ្នាំងទឹកប្រមាណ ១០ ថ្នាំង ក្នុងរោងទឹក ក៏ផ្ដើមពោលទោសថា ដូចម្ដេច ក្នុងទីនៅភិក្ខុមានប្រមាណប៉ុណ្ណេះ មិនមានទឹកផឹក ត្រឹមតែបន្ទោបង់សេចក្ដីស្រេក សម្រាប់អ្នកមកដើម្បីប្រាថ្នានឹងផឹក ព្រះចូឡបិណ្ឌបាតិកតិស្ស-ត្ថេរៈ ស្ដាប់ពាក្យរបស់គេហើយ ទើបទៅរកគេ ឃើញថ្នាំងទឹកផឹក ប្រមាណ ១០ ថ្នាំង ពេញដោយទឹក គិតថា សត្វនេះប្រហែលជាជីវមានប្រេត ទើបពោលថា ឧបាសក បើលោកស្រេកទឹក ក៏ចូរផឹកចុះ ដូច្នេះហើយ លើកថ្នាំងឡើង ចាក់លើដៃរបស់គេ ព្រោះអាស្រ័យកម្មរបស់គេ ទឹកផឹកដែលផឹកហើយ ក៏ស្ងួតអស់ទៅដូចដាក់ចុះក្នុងអំបែងក្ដៅ កាលគេផឹកទឹកក្នុងថ្នាំងទាំងអស់ ក៏មិនបាត់សេចក្ដីស្រេក លំដាប់នោះ ព្រះថេរៈទើបពោលនឹងគេថា ម្នាលឧបាសក ក៏លោកធ្វើកម្មអាក្រក់បែបណា លោកទើបកើតជាប្រេតក្នុងបច្ចុប្បន្ន វិបាកនឹងដូចម្ដេច?

គេស្ដាប់ពាក្យរបស់ព្រះថេរៈហើយ មានសេចក្ដីសង្វេគ ថ្វាយបង្គំព្រះថេរៈហើយ រុះរើគ្រឿងប្រហារមានអន្ទប់ជាដើមទាំងនោះចេញ ប្រញាប់ទៅផ្ទះ

មើលបុត្រ និងភរិយា ហើយទម្លាយចម្រូង លះបង់ ប្រទីប ម្រឹគ និងបក្សីក្នុងព្រៃនោះ ត្រឡប់ទៅរកព្រះថេរៈសូមបព្វជ្ជា ព្រះថេរៈពោលថា អ្នកមានអាយុ បព្វជ្ជាជាកិច្ចដែលធ្វើបានលំបាក លោកនឹងបួសបានយ៉ាងណា? គេពោលថា លោកម្ចាស់ដ៏ចម្រើន ខ្ញុំឃើញហេតុប្រាកដច្បាស់យ៉ាងនេះ នឹងមិនបួសដូចម្តេច ព្រះថេរៈឲ្យតចបញ្ចកម្មដ្ឋានហើយឲ្យគេបួស លោកធ្វើវត្តបដិបត្តិ ត្រេកអររៀនយកពុទ្ធវចនៈ ថ្ងៃមួយ បានស្តាប់ក្នុងទេវទូតសូត្រថា ភិក្ខុទាំងឡាយ ពួកនាយនិរយបាល រមែងដាក់សត្វដែលសោយទុក្ខ មានប្រមាណប៉ុណ្ណេះ ចូលក្នុងមហានរកទៀត ទើបពោលថា នាយនិរយបាល ដាក់សត្វដែលសោយទុក្ខ មានប្រមាណប៉ុណ្ណេះហើយ ចុះទៅក្នុងមហានរកទៀត ឱ! មហានរកធ្ងន់ណាស់ហ្ន៎ លោកម្ចាស់ ព្រះថេរៈឆ្លើយថា អើ! អ្នកមានអាយុ ធ្ងន់ លោកសួរថា ផលអាចនឹងមើលឃើញទេលោកម្ចាស់ ព្រះថេរៈពោលថា លោកមិនអាចមើលឃើញ (តែ) យើងនឹងសម្តែងហេតុ ធ្វើឲ្យដូចគ្នាដែលនឹងអាចមើលឃើញបាន ទើបពោលថា លោកចូរបបួលពួកសាមណេរធ្វើគំនរឈើស្រស់ លើខ្នងថ្មាំងថ្មចុះ លោកបានធ្វើដូចយ៉ាងនោះ ព្រះថេរៈអង្គុយនៅដូចដើម សំដែងឫទ្ធិ នាំកំទេចភ្លើងប្រមាណប៉ុនអំពិលអំពែកពីមហានរក ដាក់ចុះត្រង់គំនរឧសរបស់ព្រះថេរៈនោះ ដែលកំពុងមើលនៅទុំះឯង ការដែលកំទេចភ្លើងនរក ធ្លាក់ចុះទៅក្នុង

គំនរឧសនោះ គំនរឧសនេះជាផេះ ប្រាកដមិនមុនមិនក្រោយគ្នាឡើយ ។

លោកឃើញហេតុនោះហើយ សួរថា លោកម្ចាស់ដ៏ចម្រើន ឈ្មោះថា ធុរៈក្នុងព្រះសាសនានេះមានប៉ុន្មាន? ព្រះថេរៈឆ្លើយថា អ្នកមានអាយុ មាន ២ គឺ វាសធុរៈ (វិបស្សនាធុរៈ) និងគន្ថធុរៈ លោកពោលថា លោកដ៏ចម្រើន ឈ្មោះថា គន្ថៈ ជាភារៈរបស់អ្នកអាច តែសទ្ធារបស់ខ្ញុំអាស្រ័យទុក្ខជាហេតុ ខ្ញុំនឹងបំពេញវាសធុរៈ សូមលោកចូរឲ្យកម្មដ្ឋានដល់ខ្ញុំចុះ ថ្វាយបង្គំហើយ ក៏អង្គុយ ព្រះថេរៈតាំងនៅក្នុងវត្តបដិបត្តិ ដោយគិតថា ភិក្ខុត្រូវជាអ្នកសម្បូរណ៍នៅដោយវត្ត ហើយទើបប្រាប់កម្មដ្ឋានដល់លោក លោកទទួលកម្មដ្ឋានហើយ ធ្វើកម្មក្នុងវិបស្សនា និងបំពេញវត្ត ធ្វើវត្តត្រង់ចិត្តលបពិតមហាវិហារមួយថ្ងៃ , ធ្វើត្រង់គាមេណ្ឌវាសីមហាវិហារមួយថ្ងៃ , ធ្វើត្រង់គោចរគ្រាមមហាវិហារមួយថ្ងៃ ពេលដែលថីនមិទ្ធៈគ្របសង្កត់ ក៏យកស្មឹកឈើជ្រលក់ទឹកមកដាក់លើសីសៈ អង្គុយយកជើងត្រាំទឹក ព្រោះខ្លាចវត្តសាបសូន្យ ថ្ងៃមួយ ធ្វើវត្តរហូតអស់ ២ យាម ត្រង់ចិត្តលបពិតវិហារ កាលផ្ដើមនឹងដេកលក់ ក្នុងវេលាជិតភ្លឺ ទើបអង្គុយដាក់ស្មឹកឈើស្រស់ទុកលើសីសៈ កាលសាមណេរ កំពុងស្វាធ្យាយក្នុងអរុណវតិសូត្រនៅម្ខាងភ្នំទិសខាងកើត បានឮយ៉ាងនេះថា ៖

អារភថ និក្ខមថ យុញ្ជថ ពុទ្ធសាសនេ

ធុនាថ មច្ចុនោ សេនំ  នឡាគារំវ  កុញ្ជរោ
យោ ឥមស្មឹ ធម្មវិនយេ  អប្បមត្តោ វិហរិស្សតិ
បហាយ ជាតិសំសារំ  ទុក្ខស្សន្តំ ករិស្សតិ ។

ចូរប្រារព្ធព្យាយាម ព្យាយាម ឧស្សាហ៍ក្នុងព្រះពុទ្ធសាសនា កម្ចាត់កងទ័ពរបស់មច្ចុ ដូចដំរីកម្ចាត់ផ្ទះបបុសដូច្នោះ អ្នកណាមិនប្រមាទក្នុងព្រះធម៌វិន័យនេះនៅ នឹងលះជាតិសង្សារ ធ្វើទីបំផុតទុក្ខបាន ។

ទើបកើតបីតិឡើងថា ពាក្យនេះ ប្រាកដជាពាក្យដែលព្រះសម្មាសម្ពុទ្ធ ត្រាស់ជួយភិក្ខុដែលប្រារព្ធសេចក្តីព្យាយាមដូចជាយើង ដូច្នេះ ហើយធ្វើឈាន ឲ្យកើត ធ្វើឈាននោះឯងឲ្យជាបាទហើយ តាំងនៅក្នុងអនាគាមិផល ព្យាយាម បន្តៗ ទៅ ក៏សម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទា សូម្បីក្នុងវេលាបរិនិព្វាន កាលសម្តែងហេតុនោះឯង ទើបពោលគាថាយ៉ាងនេះថា

អល្លបលាសបុញ្ជាហំ  សិរេនាទាយ  ចង្កមិ
បត្តោស្មិ តតិយដ្ឋានំ  នត្ថិ មេ ឯត្ថ សំសយោ

យើងយកបាច់ស្លឹកឈើស្រស់ដាក់លើសិរសៈ ដើរចង្ក្រម យើងជាអ្នកដល់ឋានទី ៣ (អនាគាមិផល) យើងមិនមាន

សេចក្តីសង្ស័យក្នុងរឿងនេះ ។

កិលេសដែលគ្របសង្កត់ដោយអំណាចនៃវត្តរបស់ភិក្ខុបែបនេះ ឈ្មោះថា រមែងជាការគ្របសង្កត់នោះឯង កាលភិក្ខុរូបខ្លះខ្វល់ខ្វាយក្នុងគន្ថៈ (គម្ពីរ-ពុទ្ធវចនៈ) រៀន សម្តែង និងប្រកាស គន្ថៈដោយន័យដែលពោលហើយនុ៎ះឯង កិលេស រមែងមិនបានឱកាស ជាការគ្របសង្កត់បានដោយអំណាចគន្ថៈនុ៎ះឯង លោកធ្វើកិលេសនោះដែលគ្របសង្កត់បាន យ៉ាងនោះឯង ប្រាសចាកតម្រេកបានហើយ ក៏កាន់យកព្រះអរហត្តបាន ដូចព្រះមាលិយទេវត្ថេរៈ ដូច្នោះ ។

បានឮថា ព្រះមាលិយទេវត្ថេរៈដ៏មានអាយុនោះ រៀនឧទ្ទេស និងធ្វើវិបស្សនាកម្មដ្ឋាន ត្រង់មណ្ឌលារាមវិហារ ក្នុងកល្លគ្រាម ក្នុងវេលាជាភិក្ខុបាន ៣ វស្សា ថ្ងៃមួយ កាលលោកទៅបិណ្ឌបាត្រក្នុងកល្លគាម ឧបាសិកាម្នាក់ថ្វាយយាគូមួយវែក ក៏កើតសេចក្តីស្រលាញ់ដូចជាបុត្រ ឲ្យព្រះថេរៈអង្គុយខាងក្នុងនិវេសន៍ ថ្វាយភោជនដែលប្រណីត ហើយសួរថា លោកជាអ្នកស្រុកណា? លោកឆ្លើយថា ឧបាសិកា អាត្មាធ្វើកិច្ចកម្ម គឺ ការរៀនគន្ថៈ ក្នុងមណ្ឌលារាមវិហារ ឧបាសិកាពោលថា បើដូច្នោះ លោកកូនចូរទទួលភិក្ខាជាប្រចាំក្នុងទីនេះចុះ ដរាបដែលរៀនគន្ថៈ លោកទទួលពាក្យនោះហើយ ទទួលភិក្ខាក្នុងទីនោះជាប្រចាំ ក្នុងវេលាសម្រេចភត្តកិច្ច កាលនឹងធ្វើអនុមោទនា ទើបពោលចំពោះ ២ បទថា **សុខំ**

*ហោតុ ទុក្ខា មុច្ចតុ (សូមលោកចូរជាសុខ ចូរផុតចាកទុក្ខ) ហើយក៏ទៅធ្វើការ សង្គ្រោះដល់នាងនោះឯង រហូតអស់ ៣ ខែ ខាងក្នុងវស្សា ធ្វើសេចក្តីកោត- ក្រែងចំពោះបិណ្ឌបាត ក្នុងថ្ងៃមហាបវារណា ក៏សម្រេចព្រះអរហត្ត ព្រមដោយ បដិសម្ភិទា ។ ព្រះមហាថេរៈអ្នកជាម្ចាស់ទឹកទន្លេង ពោលថា ព្រះមហាទេវៈ ថ្ងៃនេះ មហាជននឹងប្រជុំគ្នាក្នុងវិហារ លោកចូរឲ្យធម្មទានដល់មហាជននោះ ព្រះថេរៈ ក៏ទទួល ភិក្ខុកម្លោះ និងសាមណេរបានឲ្យសញ្ញាដល់ឧបាសិកាថា ថ្ងៃនេះ បុត្រ របស់អ្នកនឹងសម្តែងធម៌ អ្នកគប្បីទៅវិហារស្តាប់ធម៌ ឧបាសិកាពោលថា លោក ម្ចាស់ ជនទាំងឡាយមិនដឹងធម្មកថាបុត្ររបស់ខ្ញុំម្ចាស់ សម្តែងដល់ខ្ញុំម្ចាស់រហូត អស់កាលមានប្រមាណប៉ុណ្ណេះ សម្តែងតែ ២ បទ ប៉ុណ្ណោះថា សូមឧបាសិកា ចូរមានសេចក្តីសុខ សូមឧបាសិកាចូរផុតពីទុក្ខ លោកម្ចាស់កុំបញ្ឆោតខ្ញុំ ភិក្ខុកម្លោះ និងសាមណេ ពោលថា ឧបាសិកា អ្នកដឹង ឬមិនដឹង ក៏ចូរទៅវិហារ ស្តាប់ធម៌ប៉ុណ្ណោះ ឧបាសិកាកាន់យកសក្ការៈ មានរបស់ក្រអូប និងផ្កាឈើជា ដើមទៅបូជា ហើយអង្គុយស្តាប់ធម៌នៅខាងក្រោយបរិស័ទ ព្រះធម្មកថិក និង ភិក្ខុដែលសូត្រសរភញ្ញៈពេលថ្ងៃ ដឹងកាលគួររបស់ខ្លួន ក៏ក្រោកចេញទៅ លំដាប់ នោះ ព្រះមាលិយទេវត្ថេរៈ អង្គុយលើធម្មាសនៈ ចាប់ផ្ចិតវិជនីពោលបុព្វកថា ហើយគិតថា យើងធ្វើអនុមោទនាដល់មហាឧបាសិកា ដោយ ២ បទ មករហូត*

អស់ ៣ ខែ ថ្ងៃនេះយើងនឹងចាប់យក (សេចក្តី) ពីព្រះត្រៃបិដក ហើយពោល អត្ថនៃបទទាំង ២ នោះ រហូតអស់នៃយប់ ទើបផ្តើមសម្តែងធម៌ទេសនា រហូតអស់មួយយប់ដល់ភ្លឺ ក្នុងវេលាចប់ទេសនា អរុណរះឡើង មហាឧបាសិកា បានតាំងនៅក្នុងសោតាបត្តិផល ។

ព្រះថេរៈមួយរូបទៀត នាមថា តិស្សភូតត្ថេរៈ ក្នុងវិហារនោះឯង រៀនព្រះវិន័យ ចូលទៅខាងក្នុងស្រុកក្នុងវេលាភិក្ខាចារ បានក្រឡេកឃើញវិសភាគារម្មណ៍ លោកកើតសេចក្តីលោភឡើង លោកធ្វើជើងដែលឈរនោះ មិនឲ្យឃ្លាតទៅណា ថ្វាយយាគូក្នុងបាត្ររបស់ខ្លួនទៅក្នុងបាត្ររបស់ភិក្ខុកម្លោះ ដែលជាឧបដ្ឋាក គិតថា វិតក្កៈនេះ កាលបន្ថែមច្រើនឡើងៗ នឹងធ្វើយើងឲ្យលិចចុះក្នុងអបាយ ៤ ទើបត្រឡប់ចាកពីទីនោះ ទៅកាន់សំណាក់របស់ព្រះអាចារ្យ ថ្វាយបង្គំហើយ ឈរក្នុងទីដ៏សមគួរមួយ ពោលថា ព្យាធិមួយយ៉ាងកើតឡើងដល់ខ្ញុំហើយ ខ្ញុំមិនអាចនឹងព្យាបាលបាន ទើបមករក មិនមែនមកដោយរឿងដទៃឡើយ សូមលោកម្ចាស់មេត្តាជួយខ្ញុំ ឲ្យឧទ្ទេសពេលថ្ងៃ និងឧទ្ទេសពេលល្ងាច តែកុំឲ្យឧទ្ទេសក្នុងវេលាជិតភ្លឺឡើយ លុះពោលយ៉ាងនេះហើយ ក៏បានទៅកាន់សម្នាក់របស់ព្រះមល្លយវាលិមហារក្ខិតត្ថេរៈ ព្រះថេរៈកំពុងធ្វើការតុបតែងបណ្ណសាលារបស់ខ្លួន មិនក្រឡេកមើលលោក ពោលថា លោកដ៏មានអាយុ ចូររក្សា

បាត្រ និងចីវររបស់លោកចុះ ភិក្ខុនោះពោលថា លោកម្ចាស់ដ៏ចម្រើន ខ្ញុំមានព្យាធិមួយយ៉ាង បើលោកអាចព្យាបាលបាន ខ្ញុំទើបនឹងរក្សា ព្រះថេរះពោលថា អ្នកមានអាយុ មកកាន់សម្នាក់របស់លោក អ្នកអាចព្យាបាលរោគដែលកើតឡើងហើយ លោកចូររក្សាទុកចុះ ភិក្ខុជាអ្នកប្រដៅងាយ គិតថា អាចារ្យរបស់ពួកយើង មិនដឹង គង់មិនពោលយ៉ាងនោះ ហើយដាក់បាត្រ និងចីវរ សម្ដែងវត្តដល់ព្រះថេរៈ ថ្វាយបង្គំហើយ អង្គុយក្នុងទីដ៏សមគួរម្ខាង ។ ព្រះថេរៈដឹងថា លោកនេះជារាគចរិត ទើបបានប្រាប់អសុភកម្មដ្ឋាន លោកក្រោកឡើងស្ពាយបាត្រ និងចីវរគ្រងស្នា ថ្វាយបង្គំព្រះថេរៈហើយ ថ្វាយបង្គំទៀត ព្រះថេរៈសួរថា មហាភូតិ ហេតុដូចម្ដេច លោកទើបសម្ដែងអាការគោរពដ៏លើសលុបយ៉ាងនេះ លោកពោលថា លោកម្ចាស់ដ៏ចម្រើន បើខ្ញុំនឹងធ្វើកិច្ចរបស់ខ្លួនបានដែរ ប្រការនោះជាការល្អ បើមិនបានដូច្នោះ ការឃើញគ្រានេះ នឹងជាការឃើញគ្រាចុងក្រោយរបស់ខ្ញុំ ព្រះថេរៈពោលថា មហាភូតិទៅចុះ ឈានក្ដី វិបស្សនាក្ដី មគ្គក្ដី ផលក្ដី កុលបុត្រអ្នកប្រកបសេចក្ដីព្យាយាមដូច្នោះ បានមិនលំបាកទេ ភិក្ខុនោះស្ដាប់ពាក្យរបស់ព្រះថេរៈហើយ បានសម្ដែងអាការនមស្ការ ហើយទៅកាន់ដើមចំបក់ គ្រង់ម្ហូបដែលខ្លួនកំណត់ដោយភ្នែកទុកក្នុងពេលមក អង្គុយពត់ភ្នែន ធ្វើអសុភកម្មដ្ឋានឲ្យជាបាទផ្ដើមតាំងវិបស្សនា តាំងនៅក្នុងព្រះអរហត្ត ទាន់ពេល

សម្តែងបាតិមោក្ខក្នុងវេលាជិតភ្លឺ ភិក្ខុបែបនេះ គ្របសង្កត់កិលេសបានដោយអំណាចគន្ថៈ ឈ្មោះថា គ្របសង្កត់បានដោយប្រការនោះដូចគ្នា ។

ភិក្ខុរូបខ្លះ រក្សាធុតង្គ ដោយន័យដូចពោលហើយនុ៎ះឯង កិលេសរមែងមិនបានឱកាស កិលេសនោះ លោកគ្របសង្កត់បានដោយអំណាចធុតង្គ លោកធ្វើកិលេសនោះ ឲ្យជាការគ្របសង្កត់បានហើយនុ៎ះឯង ប្រាសចាកតម្រេកបានហើយ កាន់យកព្រះអរហត្តទុកបាន ដូចព្រះមហាសិវត្ថេរៈ ដែលនៅត្រង់ញកភ្នំជិតស្រុក ។

បានឮថា ព្រះមហាសិវត្ថេរៈ នៅក្នុងតិស្សមហាវិហារ ជិតមហាគាម បង្រៀនព្រះត្រៃបិដក ដល់ភិក្ខុគណៈធំ ១៨ គណៈ ទាំងដោយអត្ថ ទាំងដោយបាលី ភិក្ខុ ៦០.០០០ រូប តាំងនៅក្នុងឱវាទរបស់ព្រះថេរៈ សម្រេចព្រះអរហត្តហើយ បណ្តាភិក្ខុទាំងនោះ ភិក្ខុមួយរូប ប្រារព្ធធម៌ដែលខ្លួនបានត្រាស់ដឹងហើយកើតសោមនស្សឡើង គិតថា សេចក្តីសុខនេះ មានដល់អាចារ្យរបស់យើងខ្លះទេហ្ន៎ ភិក្ខុនោះកាលរពឹងហើយ ក៏ដឹងថា ព្រះថេរៈនៅជាបុថុជ្ជន គិតថា យើងនឹងធ្វើឲ្យសេចក្តីសង្វេគកើតឡើងដល់ព្រះថេរៈដោយឧបាយនេះ ទើបចេញពីទីនៅរបស់ខ្លួនទៅកាន់សម្នាក់របស់ព្រះថេរៈ ថ្វាយបង្គំសម្តែងវត្តហើយអង្គុយ ។ លំដាប់នោះ ព្រះថេរៈពោលនឹងភិក្ខុនោះថា បិណ្ឌបាតិកៈ លោកមកធ្វើអ្វី ភិក្ខុ

នោះពោលថា លោកម្ចាស់ ខ្ញុំមកដោយបំណងថា បើលោកម្ចាស់នឹងឲ្យឱកាសដល់ខ្ញុំ ខ្ញុំក៏នឹងរៀនធម្មបទ ព្រះថេរៈពោលថា អ្នកមានអាយុ ភិក្ខុច្រើនគ្នារៀនលោកនឹងមិនមានឱកាស , ភិក្ខុនោះកាលមិនបានឱកាស ក្នុងចំណែកពេលយប់និងពេលថ្ងៃ ទើបពោលថា បើឱកាសមិនមានយ៉ាងនោះ លោកនឹងបានឱកាសនៃមរណៈដូចម្តេច? វេលានោះព្រះថេរៈគិតថា ភិក្ខុនេះមិនមកដើម្បីរៀនឧទ្ទេសតែគេមកដើម្បីធ្វើសេចក្តីសង្វេគឲ្យកើតដល់យើង សូម្បីភិក្ខុនោះ ពោលថា លោកម្ចាស់ដ៏ចម្រើន ធម្មតាថា ភិក្ខុ គប្បីជាអ្នកដូចយើង ដូច្នេះ ហើយថ្វាយបង្គំព្រះថេរៈ ហោះទៅក្នុងអាកាសដែលមានពណ៌ដូចកែវមណី ។

ព្រះថេរៈកើតសេចក្តីសង្វេគ តាំងពីវេលាដែលភិក្ខុនោះចេញទៅហើយប្រាប់ឧទ្ទេសកណ្តាលពេលថ្ងៃ និងក្នុងពេលល្ងាច រៀបចំបាត្រ និងចីវរទុកជិតហត្ថបាស ក្នុងវេលាជិតភ្លឺទើបរៀនឧទ្ទេស កាន់បាត្រ និងចីវរចុះទៅជាមួយភិក្ខុដែលកំពុងចុះទៅ អធិដ្ឋានធុតង្គគុណ ១៣ ឲ្យបរិបូណ៌ហើយ ទៅកាន់សេនាសនៈត្រង់ញកភ្នំជិតស្រុក បោសសំអាតញកភ្នំហើយ ឲ្យលើកគ្រែ និងតាំងឡើងតាំងចិត្តថា បើយើងមិនទាន់សម្រេចព្រះអរហត្ត នឹងមិនទំរេតខ្នងលើគ្រែ ទើបចុះកាន់ទីចង្ក្រម កាលលោកព្យាយាមដោយសង្ឃឹមថា យើងនឹងសម្រេចព្រះ-អរហត្តក្នុងថ្ងៃនេះ យើងនឹងសម្រេចព្រះអរហត្តក្នុងថ្ងៃនេះ ថ្ងៃបវារណាក៏មកដល់

កាលជិតដល់ថ្ងៃបវារណា លោកគិតថា យើងនឹងលះបង់ភាពជាបុថុជ្ជន បវា-រណាជាវិសុទ្ធិបវារណា ក៏លំបាកក្រៃលែង លោកកាលមិនអាចនឹងធ្វើមគ្គ ឬផលឲ្យកើតក្នុងថ្ងៃបវារណានោះបាន ទើបពោលថា អ្នកប្រារព្ធវិបស្សនាសូម្បីដូចយើង ក៏មិនទាន់បាន ព្រះអរហត្តនេះ ជាគុណដែលបានលំបាកពិតហ្ន៎ ទើបជាអ្នកច្រើនទៅដោយការឈរ និងការដើរ ដោយទំនងនេះឯង ធ្វើសមណធម៌រហូតអស់ ៣០ ឆ្នាំ ឃើញព្រះច័ន្ទពេញវង់អណ្តែតនៅត្រង់កណ្តាលតិថី ថ្ងៃមហាបវារណា គិតថា ព្រះចន្ទបរិសុទ្ធ ឬសីលរបស់យើងបរិសុទ្ធ ក៏រំពឹងថា ក្នុងព្រះចន្ទនៅប្រាកដមានលក្ខណៈជារូបទន្សាយ តែស្នាមខ្មៅ ឬភាពពព្រុសក្នុងសីលរបស់យើង តាំងពីយើងឧបសម្បទជាបដល់សព្វថ្ងៃនេះមិនមាន បានកើតសោមនស្ស លោកគ្របសង្កត់បីតិព្រោះមានញាណចាស់ក្លា សម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទា ភិក្ខុបែបនេះ គ្របសង្កត់កិលេសបានដោយអំណាចធុតង្គឈ្មោះថា គ្របសង្កត់កិលេសបានហើយ ដោយប្រការនោះឯង ។

ព្រោះភិក្ខុរូបខ្លះ ច្រើនទៅដោយការចូលបឋមឈានជាដើម ដោយន័យដូចពោលហើយនុ៎ះឯង កិលេស រមែងមិនបានឱកាស ជាការគ្របសង្កត់បានដោយអំណាចសមាបត្តិ លោកធ្វើកិលេសដែលគ្របសង្កត់បាន ដោយប្រការនោះឯង ប្រាសចាកតម្រេក រមែងកាន់យកព្រះអរហត្តទុកបាន ដូចព្រះមហាតិ-

សង្ឃត្ថេរៈ ដូច្នេះ ។

បានឮថា ព្រះមហាតិស្សត្ថេរៈបានសមាបត្តិ ៨ តាំងពីវេលាដែលមានវស្សា ៨ លោកពោលធម៌បានជិតអរិយមគ្គ ដោយអំណាចការរៀន និងការសាកសួរ ព្រោះកិលេសដែលត្រូវគ្របសង្កត់ដោយសមាបត្តិមិនកើតឡើង សូម្បីក្នុងវេលាដែលលោកមានវស្សា ៦០ ក៏មិនដឹងខ្លួនថា នៅជាបុថុជ្ជន ថ្ងៃមួយភិក្ខុសង្ឃចេញចាកពីតិស្សមហាវិហារ ក្នុងស្រុកមហាគាម បានបញ្ជូនដំណឹងដល់ព្រះធម្មទិន្នត្ថេរៈ ដែលរស់នៅជិតឆ្នេរខ្សាច់ថា សូមព្រះថេរៈចូរមកពោលធម្មកថាដល់ពួកខ្ញុំ ព្រះថេរៈទទួលពាក្យហើយ គិតថា ភិក្ខុដែលចាស់ជាង មិនមានក្នុងសម្នាក់របស់យើង តែព្រះមហាតិស្សត្ថេរៈ ក៏ជាអាចារ្យអ្នកប្រាប់កម្មដ្ឋានដល់យើង យើងនឹងតាំងលោកឲ្យជាព្រះសង្ឃត្ថេរៈហើយ ទើបទៅ លោកដែលភិក្ខុសង្ឃហែហមហើយ ទៅកាន់វិហាររបស់ព្រះថេរៈ សម្តែងវត្តដល់ព្រះថេរៈក្នុងទីសម្រាកពេលថ្ងៃ អង្គុយក្នុងទីដ៏សមគួរមួយ ព្រះថេរៈពោលថា ធម្មទិន្នៈមកយូរហើយឬ? ព្រះធម្មទិន្នត្ថេរៈពោលថា ករុណា លោកម្ចាស់ ភិក្ខុសង្ឃបញ្ជូនដំណឹងពីតិស្សមហាវិហារមកដល់ខ្ញុំ ខ្លួនខ្ញុំម្នាក់ឯងក៏នឹងមិនមក តែខ្ញុំប្រាថ្នានឹងទៅជាមួយលោកម្ចាស់ ទើបបានមក លោកពោលសារាណិយកថា ពន្យាពេលឲ្យយូរ ហើយសួរថា លោកម្ចាស់ដ៏ចម្រើន លោកសម្រេចធម៌នេះកាលណា?

ព្រះថេរៈពោលថា ធម្មទិន្នៈប្រមាណ ៦០ ឆ្នាំ ព្រះធម្មទិន្នត្ថេរៈពោលថា លោកម្ចាស់ដ៏ចម្រើន លោកប្រើសមាធិឬ ព្រះថេរៈពោលថា ករុណា ព្រះធម្មទិន្នត្ថេរៈពោលថា លោកម្ចាស់ដ៏ចម្រើន លោកនិម្មិតស្រះបោក្ខរណីមួយបានទេ ព្រះថេរៈពោលថា លោក ប្រការនោះមិនធ្ងន់ឡើយ ហើយនិម្មិតស្រះបោក្ខរណីឡើងក្នុងទីចំពោះមុខ និងលោកពោលបន្តថា សូមលោកចូរនិម្មិតគុម្ពផ្កាបទុមមួយគុម្ពក្នុងស្រះនេះ ក៏និម្មិតគុម្ពផ្កាបទុមសូម្បីនោះ ព្រះធម្មទិន្នត្ថេរៈពោលថា ឥឡូវនេះ លោកចូរសាងផ្កាឈើធំក្នុងគុម្ពផ្កាបទុមនេះ ព្រះថេរៈក៏សម្តែងផ្កាឈើនោះ ហើយពោលថា លោកចូរសម្តែងរូបស្ត្រីមានអាយុប្រមាណ ១៦ ឆ្នាំក្នុងផ្កាឈើនោះ ក៏សម្តែងរូបស្ត្រីសូម្បីនោះ លំដាប់នោះ ព្រះធម្មទិន្នៈពោលនឹងព្រះថេរៈនោះថា លោកដ៏ចម្រើន លោកចូរដាក់ចិត្តដល់រូបស្ត្រីនោះរឿយៗដោយសេចក្តីស្អាត ព្រះថេរៈក្រឡេកមើលរូបស្ត្រីដែលខ្លួននិម្មិតឡើង ក៏កើតតម្រេកឡើងក្នុងវេលានោះ ទើបដឹងខ្លួនថា នៅជាបុថុជ្ជន ទើបពោលថាលោកសប្បុរស សូមលោកចូរជាទីពឹងរបស់ខ្ញុំ ហើយអង្គុយប្រហោងក្នុងសម្នាក់របស់អន្តេវាសិក ។ ព្រះធម្មទិន្នពោលថា លោកម្ចាស់ ខ្ញុំមកដើម្បីប្រយោជន៍នេះឯង ហើយប្រាប់កម្មដ្ឋានស្រាលៗ ទាក់ទងជាមួយអសុភដល់ព្រះថេរៈ ហើយចេញទៅខាងក្រៅដើម្បីឲ្យឱកាសដល់ព្រះថេរៈ ព្រះថេរៈដែលមានសន្ធារដែលបរិកម្ម

ទុកល្អហើយ លុះមពេលព្រះធម្មទិន្នៈនោះ ចេញអំពីទីសម្រាកពេលថ្ងៃប៉ុណ្ណោះ ក៏បានសម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទា លំដាប់នោះ ព្រះធម្មទិន្នត្ថេរៈ ធ្វើលោកឲ្យជាព្រះសង្ឃត្ថេរៈ ហើយទើបទៅកាន់មហាតិស្សវិហារ សម្តែងធម្មកថាដល់សង្ឃ កិលេសដែលព្រះថេរៈបែបនោះគ្របសង្កត់ហើយ ក៏ជាការគ្របសង្កត់ហើយដោយប្រការនោះឯង ។

តែសម្រាប់ភិក្ខុរូបខ្លះ ធ្វើវិបស្សនាកម្មដ្ឋាន ដោយន័យដូចពោលហើយនុ៎ះឯង កិលេស រមែងមិនបានឱកាស ព្រោះគ្របសង្កត់កិលេសបានដោយអំណាចវិបស្សនានុ៎ះឯង ភិក្ខុនោះគ្របសង្កត់កិលេសបាន ដោយប្រការនោះ ប្រាសចាកតម្រេកហើយ រមែងសម្រេចព្រះអរហត្តបាន ដូចភិក្ខុចម្រើនវិបស្សនាប្រមាណ ៦០ រូប ក្នុងសម័យពុទ្ធកាល ។

បានឮថា ភិក្ខុទាំងនោះ ទទួលព្រះកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តាហើយ ចូលទៅព្រៃដែលស្ងាត់ ធ្វើកម្មក្នុងវិបស្សនា (តែ) មិនធ្វើសេចក្តីព្យាយាមដើម្បីប្រយោជន៍ដល់មគ្គផល ដោយសម្គាល់ថា យើងសម្រេចមគ្គផលហើយ ព្រោះកិលេសមិនផុសផុលឡើង គិតថា យើងនឹងក្រាបទូលដល់ធម៌ដែលយើងត្រាស់ដឹងហើយចំពោះព្រះទសពល ទើបមកគាល់ព្រះសាស្តា តែមុនពេលដែលភិក្ខុទាំងនោះនឹងមកដល់ ព្រះសាស្តាបានត្រាស់ចំពោះព្រះអានន្ទត្ថេរៈថា អានន្ទ ភិក្ខុ

ដែលបំពេញព្យាយាម នឹងមកជួបតថាគតក្នុងថ្ងៃនេះ អ្នកកុំឲ្យឱកាសដល់ភិក្ខុទាំងនោះដើម្បីនឹងជួបតថាគត គប្បីបញ្ជូនទៅថា ពួកលោកចូរទៅកាន់ព្រៃជាទីចោលសាកសពស្រស់ ធ្វើការនាអសុភស្រស់ ព្រះថេរៈបានប្រាប់ដំណឹងដែលព្រះសាស្តាត្រាស់បង្គាប់ដល់ភិក្ខុដែលមកហើយទាំងនោះ ភិក្ខុទាំងនោះ គិតថាព្រះតថាគតទ្រង់មិនជ្រាបហើយគង់មិនត្រាស់ ប្រហែលជានឹងមានហេតុក្នុងសេចក្តីនេះដោយពិត ដូច្នេះ ទើបទៅកាន់ព្រៃជាទីចោលសាកសពស្រស់ ពិចារណាមើលអសុភស្រស់ ក៏កើតតម្រេកឡើង កើតសេចក្តីសង្វេគឡើងថា ប្រការនេះព្រះសម្មាសម្ពុទ្ធគង់នឹងទ្រង់ឃើញហើយដោយពិត ទើបផ្តើមកម្មដ្ឋានដែលខ្លួនបានតាំងពីដើម ព្រះសាស្តាទ្រង់ជ្រាបថា ភិក្ខុទាំងនោះផ្តើមវិបស្សនា ប្រថាប់គង់ក្នុងព្រះគន្ធកុដិនុ៎ះឯង បានត្រាស់ឱភាសគាថាថា

យានីមានិ អបត្ថានិ អលាពូនេវ សារទេ
កាបោតកានិ អដ្ឋីនិ តានិ ទិស្វាន កា រតិ

នឹងត្រេកអរដូចម្តេច ព្រោះបានឃើញឆ្អឹងដែលមានពណ៌ដូចសត្វព្រាបដែលនរណាៗ មិនប្រាថ្នា ដូចទឹកឃ្លោកក្នុងសារទ-កាល ដូច្នោះ ។

ក្នុងវេលាចប់គាថា ភិក្ខុទាំងនោះ ក៏តាំងនៅក្នុងព្រះអរហត្តផល ភិក្ខុ

បែបនេះ គ្របសង្កត់កិលេសបានហើយ ដោយអំណាចនៃវិបស្សនា ឈ្មោះថា គ្របសង្កត់បានហើយ ដោយប្រការនោះឯង ។

ភិក្ខុរូបខ្លះ ធ្វើនវកម្ម ដោយន័យដូចពោលហើយនុ៎ះឯង កិលេស រមែងមិនបានឱកាស ឈ្មោះថា លោកគ្របសង្កត់កិលេសបាន ដោយអំណាចនវកម្ម លោកធ្វើកិលេសនោះឲ្យជាការគ្របសង្កត់ហើយយ៉ាងនោះ ប្រាសចាកតម្រេកបានហើយ រមែងកាន់យកព្រះអរហត្តបាន ដូចព្រះតិស្សត្ថេរៈ ក្នុងចិត្តលបពិតដូច្នោះ ។

បានឮថា ក្នុងវេលាដែលព្រះតិស្សត្ថេរៈនោះបាន ៨ វស្សា កើតសេចក្តីចង់សឹក លោកមិនអាចបន្ទោបង់សេចក្តីចង់សឹកនោះបាន គក់ចីវរ កោរសក់ហើយ ថ្វាយបង្គំព្រះឧបជ្ឈាយ៍ ឈរក្នុងទីមួយ លំដាប់នោះ ព្រះថេរៈពោលនឹងលោកថា មហាតិស្សៈ អាការរបស់លោក ដូចមិនត្រេកអរឬ? ភិក្ខុនោះឆ្លើយថា ករុណាលោកម្ចាស់ ខ្ញុំចង់សឹក ខ្ញុំបន្ទោបង់វាមិនបាន ព្រះថេរៈពិចារណាអជ្ឈាស្រ័យរបស់លោក ឃើញឧបនិស្ស័យព្រះអរហត្ត ទើបពោលដោយសេចក្តីមេត្តាថា អ្នកមានអាយុ ពួកយើងជាមនុស្សចាស់ លោកចូរសាងទីកន្លែងនៅសម្រាប់ពួកយើងមួយខ្នង ភិក្ខុដែលមិនធ្លាប់ត្រូវអ្នកណានិយាយដោយពាក្យទី ២ ទើបទទួលថា ករុណាលោកម្ចាស់ លំដាប់នោះ ព្រះថេរៈពោលនឹងភិក្ខុទាំងឡាយ

ថា អ្នកមានអាយុ កាលលោកកំពុងធ្វើនវកម្ម ក៏សូមកុំលះបង់សូម្បីតែឧទ្ទេស ចូរមនសិការព្រះកម្មដ្ឋាន និងចូរធ្វើបរិកម្មកសិណតាមកាលដែលសមគួរ ភិក្ខុនោះពោលថា ខ្ញុំនឹងធ្វើយ៉ាងនោះលោកម្ចាស់ ថ្វាយបង្គំព្រះថេរៈហើយ ពិចារណាមើលកន្ទ្រៃនដែលជាញកក្នុំ ឃើញហើយ គិតថា ត្រង់នេះធ្វើបាន ទើបនាំឧសមកដុតជម្រះ (ទី) ឲ្យស្អាត ហើយយកឥដ្ឋ ប្រកបទ្វារ និងបង្អួច ធ្វើទីពួនសម្ងំស្រេចហើយ ព្រមទាំងកឥដ្ឋលើទីចង្ក្រមជាដើម ហើយតាំងគ្រែ និងតាំងទុកទៅកាន់សម្នាក់ព្រះថេរៈ ថ្វាយបង្គំហើយពោលថា លោកម្ចាស់ ទីពួនសម្ងំសម្រេចហើយ សូមមេត្តានៅចុះ ព្រះថេរៈពោលថា អ្នកមានអាយុ លោកធ្វើការងារនេះបានដោយលំបាក ថ្ងៃនេះលោកនៅក្នុងទីនេះមួយថ្ងៃសិន ភិក្ខុនោះពោលថា ករុណាលោកម្ចាស់ ហើយលាងជើង ចូលទៅកាន់ទីពួនសម្ងំអង្គុយពត់ភ្នែនរំឭកដល់កម្មដែលខ្លួនធ្វើ កាលលោកគិតថា ការធ្វើសេចក្ដីខ្វល់ខ្វាយដោយកាយដែលជាទីពេញចិត្ត យើងធ្វើដល់ព្រះឧបជ្ឈាយ៍ហើយ បីតិកើតឡើងក្នុងខាងក្នុង លោកគ្របសង្កត់បីតិនោះបានហើយ ចម្រើនវិបស្សនា ក៏សម្រេចព្រះអរហត្តដែលជាផលដ៏កំពូល ភិក្ខុបែបនេះ គ្របសង្កត់កិលេសបានដោយអំណាចនវកម្ម ឈ្មោះថា លោកគ្របសង្កត់បានហើយដោយប្រការនោះដូចគ្នា ។

ចំណែកភិក្ខុរូបខ្លះ មកពីព្រហ្មលោក ជាសត្វបរិសុទ្ធ កិលេសមិនផុស-

ផុលឡើង ព្រោះលោកមិនមានអាសវៈ (គឺទំលាប់) ឈ្មោះថា លោកគ្រប-សង្កត់បានដោយអំណាចកត លោកវៀរកិលេសនោះ ដែលគ្របសង្កត់បានហើយដោយប្រការនោះ កាន់យកព្រះអរហត្តបាន ដូចព្រះមហាកស្សបៈ ដូច្នោះ ។

ពិតណាស់ ព្រះមហាកស្សបៈនោះ មិនបរិភោគកាមទាំងដែលនៅគ្រប់-គ្រងផ្ទះ លះបង់សម្បត្តិដ៏ច្រើន ចេញបួស ឃើញព្រះសាស្តាស្តេចមកទទួលក្នុងរវាងផ្លូវ ថ្វាយបង្គំហើយ បានឧបសម្បទាដោយឱវាទ ៣ ប្រការ សម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទា ក្នុងអរុណទី ៨ ភិក្ខុបែបនេះ គ្របសង្កត់កិលេសបានដោយអំណាចកត ឈ្មោះថា គ្របសង្កត់កិលេសបានយ៉ាងនោះដូចគ្នា ។

មួយទៀត ភិក្ខុណាបានអារម្មណ៍ មានរូបារម្មណ៍ជាដើម ដែលមិនធ្លាប់បានសោយ ផ្តើមតាំងវិបស្សនាក្នុងអារម្មណ៍នោះឯង ប្រាសចាកតម្រេកបានរមែងកាន់យកព្រះអរហត្តបាន កាមច្ឆន្ទៈ ដែលមិនទាន់កើតឡើង ដោយអំណាចអារម្មណ៍ដែលមិនធ្លាប់សោយ ក៏ឈ្មោះថា មិនកើតឡើងដល់ភិក្ខុបែបនេះ ។

បទថា **ឧប្បន្នោ** ក្នុងពាក្យថា **ឧប្បន្នោ វា កាមច្ឆន្ទោ បហីយតិ** នេះបានដល់ កើតហើយ មានហើយ ផុសផុលឡើងហើយ ។

បទថា **បហីយតិ** សេចក្តីថា លោកលះបានដោយបហានៈទាំង ៥ នេះ

គឺ តទង្គប្បហាន វិក្ខម្ភនប្បហាន សមុច្ឆេទប្បហាន បដិប្បស្សទ្ធិប្បហាន និស្សរណប្បហាន អធិប្បាយថា មិនកើតឡើងទៀត ក្នុងបហាន ៥ យ៉ាងនោះ ៗ កិលេសដែលលោកលះបានដោយវិបស្សនា ដោយអំណាចតទង្គប្បហាន ព្រោះហេតុនោះ វិបស្សនា គប្បីជ្រាបថាជា តទង្គប្បហាន ៗ ចំណែកសមាបត្តិរមែងគ្របសង្កត់កិលេសបាន ព្រោះដូច្នោះ សមាបត្តិនោះ គប្បីជ្រាបថា ជាវិក្ខម្ភនប្បហាន លះបង់ដោយការគ្របសង្កត់ ៗ មគ្គ កាត់កិលេសបានដាច់ខាតក៏កើតឡើង ផលស្ងប់រម្ងាប់កើតឡើង ព្រះនិព្វានរលាស់ចេញចាកកិលេសទាំងពួង ៗ មគ្គ ផល និព្វាន ទាំង ៣ ដូចពោលមកនេះ លោកហៅថា សមុច្ឆេទប្បហាន បដិប្បស្សទ្ធិប្បហាន និងនិស្សរណប្បហាន អធិប្បាយថា កិលេសលោកលះដោយបហាន ៥ ដែលជាលោកិយៈ និងលោកុត្តរៈនេះឯង ៗ

បទថា **អសុភនិមិត្តំ** បានដល់ បឋមឈានព្រមទាំងអារម្មណ៍កើតឡើងក្នុងអសុភ ១០ ព្រោះហេតុនោះ ព្រះបុរាណាចារ្យទាំងឡាយទើបបានពោលថា អសុភនិមិត្តមានក្នុងអសុភ ធម៌ទាំងឡាយដែលមានអសុភជាអារម្មណ៍ ឈ្មោះថា អសុភនិមិត្ត ៗ បទថា **យោនិសោ មនសិករោតោ** សេចក្តីថា អ្នកធ្វើទុកក្នុងចិត្តដោយអំណាចមនសិការដោយឧបាយ ដូចពោលហើយ ដោយន័យមានជាដើមដូច្នេះថា ក្នុងធម៌ទាំងនោះ យោនិសោមនសិការដូចម្តេច? គឺ មន-

សិការក្នុងវត្ថុដែលមិនទៀង ថាមិនទៀង ។ បទថា **អនុប្បន្នោ ចេវ កាមច្ឆន្ទោ នុប្បជ្ជតិ** បានដល់ កាមច្ឆន្ទៈ ដែលនៅមិនទាន់ផុសផុល ក៏មិនផុសផុលឡើង បទថា **ឧប្បន្នោ កាមច្ឆន្ទោ បហីយតិ** សេចក្ដីថា កាមច្ឆន្ទៈ ផុសផុលឡើង លោកលះបានដោយបហានទាំង ៥ ។

ម្យ៉ាងទៀត ធម៌ទាំង ៦ ប្រព្រឹត្តទៅដើម្បីលះកាមច្ឆន្ទៈ គឺ ការរៀនអសុភនិមិត្ត , ការប្រកបរឿយៗ ក្នុងអសុភភាវនា , ភាពជាអ្នកឃុំគ្រងទ្វារក្នុងឥន្ទ្រិយ , ភាពជាអ្នកដឹងប្រមាណក្នុងភោជន , ការដែលមានកល្យាណមិត្ត , ការពោលពាក្យតែដែលជាសប្បាយ ។ ពិតណាស់ កាលភិក្ខុរៀនយកអសុភនិមិត្តទាំង ១០ ក្ដី ចម្រើនអសុភភាវនាក្ដី ឃុំគ្រងក្នុងដែលឥន្ទ្រីយ៍ក្ដី ស្គាល់ប្រមាណក្នុងភោជន ព្រោះកាលមានឱកាសបរិភោគបាន ៤-៥ ដុំក៏ផឹកទឹក ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅជាប្រក្រតីក្ដី លោករមែងលះកាមច្ឆន្ទនីវរណៈបាន ព្រោះហេតុនោះ លោកទើបពោលថា

*ចត្តារោ បញ្ចអាលោបេ　　អភុត្វា ឧទកំ បិវេ*

*អលំ ផាសុវិហារាយ　　បហិតត្តស្ស ភិក្ខុនោ*

*ភិក្ខុនោះ គប្បីវៀរដុំបាយ ៤-៥ ដុំ ហើយផឹកទឹក (ជំនួស)*

*ក៏ល្មមនៅជាសុខ សម្រាប់ភិក្ខុដែលមានចិត្តស្ងប់ ។*

ភិក្ខុ គប់រកកល្យាណមិត្តដែលត្រេកអរក្នុងអសុភភាវនា ដូចជា ព្រះ-តិស្សត្ថេរៈអ្នកបំពេញអសុភកម្មដ្ឋាន រមែងលះបង់កាមច្ឆន្ទៈបាន ដោយសប្បា-យកថា ដែលអាស្រ័យអសុភ ១០ ក្នុងការឈរ និងអង្គុយជាដើម ក៏លះកាម-ច្ឆន្ទៈបាន ។ ព្រោះហេតុនោះ លោកទើបពោលថា ធម៌ ៦ រមែងប្រព្រឹត្តទៅដើម្បីលះបង់កាមច្ឆន្ទ ។

ចប់អដ្ឋកថា សូត្រទី ៦

# អដ្ឋកថាសូត្រទី ៧

ក្នុងសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ ៖

[១៨] បទថា **មេត្តា ចេតោវិមុត្តិ** បានដល់ មេត្តាដែលផ្សាយប្រយោជន៍ដ៏ធំទៅក្នុងសត្វគ្រប់ជំពូក ក៏ព្រោះចិត្តប្រកបដោយមេត្តានោះ រមែងរួចផុតចាកធម៌ដែលជាសត្រូវ មាននីវរណៈជាដើម ដូច្នោះ មេត្តានោះ លោកទើបហៅថា **ចេតោវិមុត្តិ** ។ ម្យ៉ាងទៀត ពោលដោយពិសេស មេត្តានោះ គប្បីជ្រាបថា ឈ្មោះថា ចេតោវិមុត្តិ ព្រោះរួចផុតចាកកិលេសជាគ្រឿងរួបរឹត គឺ ព្យាបាទទាំងអស់ ។ ដោយពាក្យត្រឹមតែប៉ុណ្ណេះថា មេត្តា ក្នុងពាក្យថា មេត្តាចេតោវិមុត្តិនោះ សូម្បីបដិបទាជាចំណែកខាងដើម ក៏ប្រើបាន ។ តែព្រោះលោកពោលថា ចេតោវិមុត្តិ ក្នុងទីនេះ លោកបំណងយកមេត្តាដែលជាអប្បនា ដោយអំណាចតិកឈាន និងចតុក្កឈានប៉ុណ្ណោះ ។ បទថា **យោនិសោ មនសិការោ** សេចក្តីថា មនសិការនូវមេត្តាចេតោវិមុត្តិនោះ ព្រោះមនសិការដោយឧបាយ ដែលមានលក្ខណៈដូចពោលហើយ ។

ម្យ៉ាងទៀត ធម៌ ៦ ប្រការ ប្រព្រឹត្តទៅដើម្បីលះព្យាបាទ គឺ ការរៀនយកមេត្តានិមិត្ត , ការប្រកបរឿយៗ ក្នុងមេត្តាភាវនា , ការពិចារណាដល់សត្វ

មានកម្មជារបស់ខ្លួន , ភាពជាអ្នកច្រើនដោយការពិចារណា , ជាអ្នកមានកល្យាណមិត្ត , ការពោលពាក្យដែលជាសប្បាយ ។ ពិតណាស់ កាលភិក្ខុកាន់យកមេត្តាដោយការផ្សាយទៅ ដោយចំពោះ និងមិនចំពោះ ក៏រមែងលះបង់ព្យាបាទបាន ។ កាលពិចារណាដល់ភាពដែលខ្លួន និងបុគ្គលដទៃ ជាអ្នកមានកម្មជារបស់ខ្លួន យ៉ាងនេះ កំពុងក្រោធនឹងគេហើយ នឹងធ្វើអ្វីគេបាន នឹងធ្វើសីលជាដើមរបស់គេឲ្យវិនាសបានឬ លោកមកដោយកម្មរបស់ខ្លួន ហើយក៏ទៅដោយកម្មរបស់ខ្លួនប៉ុណ្ណោះមិនមែនឬ ឈ្មោះថា ការក្រោធនឹងអ្នកដទៃ រមែងដូចជាចាប់រងើកភ្លើងដែលប្រាសចាកអណ្តាត ប្រវាក់ដែកដែលក្តៅ និងលាមកជាដើម ហើយបំណងប្រហារអ្នកដទៃ អ្នកដែលក្រោធចំពោះលោកនេះ នឹងធ្វើអ្វីបាន នឹងអាចធ្វើសីលជាដើម របស់លោកឲ្យវិនាសឬ គេមកដោយកម្មរបស់ខ្លួនហើយ និងទៅដោយកម្មរបស់ខ្លួនប៉ុណ្ណោះ សេចក្តីក្រោធនោះ នឹងធ្លាក់លើខ្លួនរបស់អ្នកនោះប៉ុណ្ណោះ ប្រៀបដូចអន្ទង់ទឹកធំ ដែលមិនមានអ្វីបិទបាំងទុក និងដូចក្តាប់ល្អងធូលីបាចបញ្ច្រាសខ្យល់ដូច្នោះ ដូច្នេះក្តី ។ អ្នកពិចារណានូវភាពដែលគេទាំង ២ ជាអ្នកមានកម្មជារបស់ខ្លួន ហើយតាំងនៅក្នុងការពិចារណាក្តី សេពគប់រកកល្យាណមិត្ត អ្នកត្រេកអរក្នុងការចម្រើនភាវនា ដូចគ្នានឹងព្រះអស្សគុត្តត្ថេរៈក្តី រមែងលះព្យាបាទបាន ។ រមែងលះព្យាបាទបាន សូម្បី

ដោយការពោលពាក្យដែលជាសប្បាយ ដែលអាស្រ័យមេត្តា ទាំងក្នុងការឈរ និងអង្គុយជាដើម ។ ដោយហេតុនោះ លោកទើបពោលថា ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះព្យាបាទ ។ ពាក្យដ៏សេសគប្បីជ្រាបដោយន័យដែលពោលហើយក្នុងទីនេះ និងក្នុងទីដទៃពីទីនុ៎ះឯង ។ តែខ្ញុំនឹងពោលត្រឹមតែសេចក្តីដែលប្លែកគ្នាប៉ុណ្ណោះឯង ។

ចប់អដ្ឋកថា សូត្រទី៧

# អដ្ឋកថាសូត្រទី ៨

ក្នុងសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ ៖

[១៩] សេចក្តីព្យាយាមគ្រាដំបូង ឈ្មោះថា **អារម្ភធាតុ** ក្នុងពាក្យមានជាដើមថា **អារម្ភធាតុ** ។ សេចក្តីព្យាយាមមានកម្លាំងជាងនោះ ព្រោះចេញចាកសេចក្តីខ្ជិលច្រអូសបាន ឈ្មោះថា **និក្កមធាតុ** ។ សេចក្តីព្យាយាមដែលខ្លាំងជាងនោះ ព្រោះឈានទៅកាន់ឋានៈខាងមុខៗ ឈ្មោះថា **បរក្កមធាតុ** ។ តែក្នុងអដ្ឋកថា លោកពោលទុកថា សេចក្តីព្យាយាមផ្តើមដំបូង ដើម្បីបន្ទោបង់កាម ១ ការឈានចេញដើម្បីកម្ចាត់កិលេសដូចជាស្នៀត ១ សេចក្តីព្យាយាម ដើម្បីកាត់កិលេសដូចជាគ្រឿងចង ១ ហើយពោលថា យើងពោលថា សេចក្តីព្យាយាមមានប្រមាណក្រៃលែងជាងទាំង ៣ យ៉ាងសូម្បីនោះ ។

បទថា **អារទ្ធវីរិយស្ស** បានដល់ អ្នកមានសេចក្តីព្យាយាមបរិបូណ៌ និងមានសេចក្តីព្យាយាមដែលផ្គងទុក ក្នុងពីរយ៉ាងនោះ សេចក្តីព្យាយាមដែលប្រាសចាកទោស ៤ យ៉ាង គប្បីជ្រាបថា សេចក្តីព្យាយាមដែលផ្តើមហើយ តែមិនមែនធូរថយពេក មិនមែនដែលផ្គងពេកទេ តែក៏មិនមែនសេចក្តីព្យាយាមដែលរួញរាក្នុងខាងក្នុង និងមិនមែនសេចក្តីព្យាយាមដែលរវើរវាយទៅខាងក្រៅ

សេចក្តីព្យាយាមនេះ មាន ២ យ៉ាងគឺ សេចក្តីព្យាយាមផ្លូវកាយ ១ សេចក្តីព្យាយាមផ្លូវចិត្ត ១ ។

ក្នុងពីរយ៉ាងនោះ គប្បីជ្រាប សេចក្តីព្យាយាមផ្លូវកាយរបស់ភិក្ខុអ្នកប្រារព្ធព្យាយាមផ្លូវកាយ ៥ ចំណែក ទាំងពេលយប់ និងពេលថ្ងៃយ៉ាងនេះថា ភិក្ខុក្នុងធម្មវិន័យនេះ រមែងជម្រះចិត្តចេញពីធម៌ដែលគប្បីរាំងចិត្ត ដោយការដើរ ការអង្គុយ រហូតអស់មួយថ្ងៃ ។ គប្បីជ្រាបសេចក្តីត្រឹមតែផ្លូវចិត្តរបស់ភិក្ខុដែលប្រារព្ធព្យាយាមចងចិត្ត ដោយការកំណត់ឱកាសយ៉ាងនេះថា យើងនឹងមិនចេញទៅពីទីពួនសម្ងំនេះ ដរាបដែលចិត្តរបស់យើងមិនទាន់រួចផុតចាកអាសវៈព្រោះមិនប្រកាន់មាំ ឬដោយការកំណត់ឥរិយាបថ មានការអង្គុយជាដើម យ៉ាងនេះថា យើងនឹងមិនលើកនូវភ្នែននេះចេញ ដរាបដែលចិត្តរបស់យើងមិនទាន់រួចផុតចាកអាសវៈ ព្រោះមិនប្រកាន់មាំ ។ សេចក្តីព្យាយាមសូម្បីទាំង ២ នោះរមែងសមគួរក្នុងទីនេះ ។ ក៏សម្រាប់ភិក្ខុដែលប្រារព្ធសេចក្តីព្យាយាម ដោយសេចក្តីព្យាយាមសូម្បីទាំង ២ យ៉ាងនេះ ថីនមិទ្ធៈដែលនៅមិនកើត ក៏មិនកើតឡើង និងដែលកើតឡើងហើយក៏រមែងលះបាន ដូចព្រះតិស្សត្ថេរៈ វង្សមិលក្ខៈ ដូចព្រះមហាសិវត្ថេរៈ អ្នកនៅញកភ្នំជិតលង្វែកស្រុក ដូចព្រះបីតិមល្លកត្ថេរៈ និងដូចព្រះតិស្សត្ថេរៈ បុត្រកុដុម្ពិកៈ ដូច្នោះ ក៏បណ្តាព្រះថេរៈទាំងនោះ ព្រះថេរៈ

៣ រូបខាងដើម និងព្រះថេរៈដទៃ ជាអ្នកផ្តើមបំពេញសេចក្តីព្យាយាម ដោយសេចក្តីព្យាយាមផ្លូវកាយ ព្រះតិស្សត្ថេរៈបុត្រកុដុម្ពិកៈ និងព្រះថេរៈដទៃទៀត ជាអ្នកប្រារព្ធសេចក្តីព្យាយាម ដោយសេចក្តីព្យាយាមផ្លូវចិត្ត ចំណែកព្រះមហា-នាគត្ថេរៈ អ្នកនៅឧច្ចវាលុកវិហារ ជាអ្នកប្រារព្ធសេចក្តីព្យាយាមទាំង ២ យ៉ាង ។

បានឮថា ព្រះថេរៈ ដើរចង្ក្រម ១ សប្តាហ៍ , ឈរ ១ សប្តាហ៍ , អង្គុយ ១ សប្តាហ៍ , ដេក ១ សប្តាហ៍ ព្រះមហាថេរៈមិនមានសូម្បីត្រឹមតែឥរិយាបថមួយ ដែលនឹងបានឈ្មោះថាមិនជាសប្បាយ ក្នុងសប្តាហ៍ទី ៤ លោកចម្រើនវិបស្សនាក៏តាំងនៅក្នុងព្រះអរហត្ត ។

មួយវិញទៀត ធម៌ ៦ ប្រការ ប្រព្រឹត្តទៅដើម្បីលះថីនមិទ្ធៈ គឺ ការកាន់យកនិមិត្តក្នុងការបរិភោគច្រើន ១ , ការផ្លាស់ឥរិយាបថដោយស្មើ ១ , មនសិការដល់អាលោកសញ្ញា ១ , ការនៅក្នុងទីវាល ១ , ការមានកល្យាណមិត្ត ១ , ការពោលពាក្យដែលជាសប្បាយ ១ ។ ពិតហើយ កាលភិក្ខុបរិភោគភោជន ដូចដែលព្រាហ្មណ៍ឈ្មោះថា អាហរហត្ថកៈ ព្រាហ្មណ៍ដែលឈ្មោះថា កុត្ថវម្មិតកៈ ព្រាហ្មណ៍ដែលឈ្មោះថា តត្ថវដ្តកៈ ព្រាហ្មណ៍ដែលឈ្មោះថា អ-លង្សាដកៈ និងព្រាហ្មណ៍ដែលឈ្មោះថា កាកមាសកៈជាដើម អង្គុយក្នុងទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ ធ្វើសមណធម៌ ថីនមិទ្ធៈ រមែងគ្របសង្កត់

ដូចដំរីធំដូច្នោះ តែកាលភិក្ខុបញ្ឈប់ដុំបាយ ៤-៥ ដុំ ហើយផឹកទឹក លុះមញ្ញាំង អត្តភាពឲ្យប្រព្រឹត្តទៅជាប្រក្រតី ថីនមិទ្ធៈនោះ ក៏មិនមាន ។ សូម្បីកាលភិក្ខុ កាន់យកនិមិត្តក្នុងការបរិភោគច្រើន ដូចពោលហើយនេះ រមែងលះថីនមិទ្ធៈ បាន ។ ថីនមិទ្ធៈ ឈានចុះក្នុងឥរិយាបថណា កាលលោកផ្លាស់ប្តូរឥរិយាបថ ជាយ៉ាងដទៃ ចេញពីឥរិយាបថនោះក្តី មនសិការដល់ពន្លឺនៃព្រះចន្ទ ពន្លឺនៃ ប្រទីប ពន្លឺនៃគប់ភ្លើង ក្នុងពេលយប់ និងពន្លឺនៃព្រះអាទិត្យក្នុងពេលថ្ងៃក្តី នៅ ទីវាលក្តី សេពគប់កល្យាណមិត្ត រមែងលះថីនមិទ្ធៈបាន ដូចព្រះមហាកស្សប- ត្ថេរៈក្តី រមែងលះថីនមិទ្ធៈបាន សូម្បីការពោលសប្បាយកថា ដែលអាស្រ័យ ធុតង្គគុណ ក្នុងឥរិយាបថ មានការឈរ និងការអង្គុយជាដើម ក៏រមែងលះបាន ដោយហេតុនោះ លោកទើបពោលថា ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បី លះថីនមិទ្ធៈនោះឯង ។

ចប់អដ្ឋកថា សូត្រទី ៨

# អដ្ឋកថាសូត្រទី ៩

ក្នុងសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ ៖

[២០] បទថា *វូបសន្តចិត្តស្ស* បានដល់ អ្នកមានចិត្តស្ងប់ហើយដោយឈាន ឬវិបស្សនា ។

ម្យ៉ាងទៀត ធម៌ ៦ ប្រការ ប្រព្រឹត្តទៅដើម្បីលះឧទ្ធច្ចៈកុក្កុច្ចៈ គឺ ភាពជាពហុស្សូត , ភាពជាអ្នកសាកសួរ , ភាពជាអ្នកជំនាញក្នុងវិន័យ , ការចូលទៅរកបុគ្គលជាធំ , ការមានកល្យាណមិត្ត , ការពោលពាក្យដែលសប្បាយ ។ ពិតហើយ កាលភិក្ខុរៀនសូម្បីបាន ១ និកាយ ២ និកាយ ៣ និកាយ ៤ និកាយ ឬ ៥ និកាយ ដោយអំណាចបាលី និងដោយអំណាចអត្ថនៃបាលី រមែងលះឧទ្ធច្ចកុក្កុច្ចៈបាន ។ សូម្បីភាពជាពហុស្សូត កាលភិក្ខុច្រើនដោយការសាកសួរក្នុងវត្ថុដែលគួរ និងមិនគួរ ក្នុងឥរិយាបថឈរ និងដេកជាដើមក្តី ជាអ្នកជំនាញ ព្រោះមានភាពជំនាញក្នុងវិន័យប្បញ្ញត្តិក្តី អ្នកចូលទៅរកព្រះថេរៈជាអ្នកធំ ដែលជាមនុស្សចំណាស់ក្តី សេពគប់កល្យាណមិត្តអ្នកទ្រទ្រង់ព្រះវិន័យដូចជាព្រះឧបាលិត្ថេរៈក្តី រមែងលះឧទ្ធច្ចកុក្កុច្ចៈបាន រមែងលះបានសូម្បីដោយពាក្យដែលជាទីសប្បាយ ដែលអាស្រ័យវត្ថុដែលគួរ និងមិនគួរ ក្នុងឥរិយាបថ

*ឈរ និងអង្គុយជាដើម ក៏រមែងលះបាន ដោយហេតុនោះ លោកទើបពោលថា ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះឧទ្ធច្ចកុក្កុច្ចៈ ។*

ចប់អដ្ឋកថា សូត្រទី ៩

# អដ្ឋកថាសូត្រទី ១០

ក្នុងសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ៖

[២១] បទថា **យោនិសោ មនសិការោ** សេចក្តីថា មនសិការហើយដោយឧបាយ តាមន័យដែលពោលហើយនុ៎ះឯង ។

មយ៉ាងទៀត ធម៌ ៦ ប្រការ ប្រព្រឹត្តទៅដើម្បីលះវិចិកិច្ឆា គឺ ភាពជាពហុស្សូត , ការសាកសួរ , ជាអ្នកជំនាញក្នុងវិន័យ , ជាអ្នកច្រើនដោយការបង្អោនចិត្តជឿ , ការមានកល្យាណមិត្ត , ការពោលពាក្យជាទីសប្បាយ ។ កាលភិក្ខុរៀន ១ និកាយ ២ និកាយ ៣ និកាយ ៤ និកាយ ឬ ៥ និកាយ ដោយអំណាចបាលី និងដោយអំណាចអត្ថ រមែងលះវិចិកិច្ឆាបាន សូម្បីភាពជាពហុស្សូត ។ កាលភិក្ខុច្រើនដោយការសាកសួរ ជាប់ទាក់ទងនឹងព្រះរតនត្រ័យក្តី អ្នកមានសេចក្តីជំនាញក្នុងព្រះវិន័យក្តី អ្នកច្រើនទៅដោយអធិមោក្ខពោលគឺ សទ្ធាបង្អោនចិត្តជឿក្នុងឋានៈ ៣ ក្តី សេពគប់កល្យាណមិត្ត ដូចជាព្រះវក្កលិត្ថេរៈដែលបង្អោនទៅក្នុងសទ្ធាក្តី រមែងលះវិចិកិច្ឆាបាន ។ រមែងលះបាន សូម្បីដោយការពោលពាក្យដែលជាទីសប្បាយ អាស្រ័យគុណព្រះរតនត្រ័យ ក្នុងឥរិយាបថឈរ និងអង្គុយជាដើម ដោយហេតុនោះ លោកទើបពោល

*ថា ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះវិចិកិច្ឆា ។*

ចប់អដ្ឋកថា សូត្រទី ១០

## ចប់នីវរណប្បហានវគ្គទី ២

រួមអដ្ឋកថាក្នុងវគ្គនេះមាន ១០ អដ្ឋកថា

ក្នុងនីវរណប្បហានវគ្គនេះ លោកពោលទុកទាំងវដ្ដៈ និងវិវដ្ដៈនោះឯង ។

ចប់អដ្ឋកថា នីវរណប្បហានវគ្គទី ២

# អកម្មនិយវគ្គទី ៣

## អដ្ឋកថាសូត្រទី ១

*សូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២២] *បទថា **អភាវិតំ** សេចក្ដីថា មិនចម្រើន គឺ មិនប្រព្រឹត្តទៅដោយអំណាចភាវនា បទថា **អកម្មនិយំ ហោតិ** បានដល់ រមែងមិនគួរដល់ការងារ គឺ មិនគួរដល់ការងារ ។*

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

[២៣] *ក្នុងសូត្រទី ២ គប្បីជ្រាបសេចក្ដីដោយបរិយាយដូចពោលហើយ ក៏បទថា* **ចិត្តំ** *ក្នុងសូត្រទី ១ នោះ បានដល់ ចិត្តដែលកើតឡើងដោយអំណាចវដ្ដៈ (ក្នុងសូត្រទី ២ បានដល់ ចិត្តដែលកើតដោយអំណាចវដ្ដៈ) ក៏ក្នុងពីរយ៉ាងនោះ គប្បីជ្រាបសេចក្ដីផ្សេងគ្នាដូច្នេះ គឺ វដ្ដៈ វដ្ដបាទ , វិវដ្ដៈ វិវដ្ដបាទ កម្មដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា វដ្ដៈ កម្ម គឺ ការធ្វើដើម្បីបានវដ្ដៈ ឈ្មោះថា វដ្ដបាទ ។ លោកុត្តរធម៌ ៩ ឈ្មោះថា វិវដ្ដៈ កម្ម គឺ ការបដិបត្តិដើម្បីបាន វិវដ្ដៈ ឈ្មោះថា វិវដ្ដបាទ ។ លោកពោលវដ្ដៈ និងវិវដ្ដៈ ទុកក្នុងសូត្រទាំងនេះ ដោយប្រការដូច្នេះ ។*

ចប់អដ្ឋកថា សូត្រទី ២

# អដ្ឋកថាសូត្រទី ៣

[២៤] ក្នុងសូត្រទី ៣ គប្បីជ្រាប ចិត្តដែលកើតឡើងដោយអំណាចវដ្តៈទាំងឯង ។ បទថា **មហតោ អនត្ថាយ សំវត្តតិ** សេចក្តីថា ចិត្តសូម្បីឲ្យទេវសម្បត្តិ មនុស្សសម្បត្តិ និងភាពជាធំក្នុងមារ និងព្រហ្ម ក៏នៅញុំាងឲ្យជាតិជរា ព្យាធិ មរណៈ សោកៈ បរិទេវៈ ទុក្ខ ទោមនស្ស និងឧបាយាសរឿយៗ និងឲ្យវដ្តៈ គឺ ខន្ធ ធាតុ អាយតនៈ និងបដិច្ចសមុប្បាទ រមែងឲ្យតែកងទុក្ខតែម្យ៉ាងប៉ុណ្ណោះ ព្រោះហេតុនោះ ឈ្មោះថា រមែងប្រព្រឹត្តទៅដើម្បីមិនមែនជាប្រយោជន៍យ៉ាងធំ ។

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថាសូត្រទី ៤

[២៥] *បទថា* **ចិត្តំ** *ក្នុងសូត្រទី ៤ បានដល់ ចិត្តដែលកើតឡើងដោយអំណាចវិវដ្តៈ ។*

ចប់អដ្ឋកថា សូត្រទី ៤

# អដ្ឋកថាសូត្រទី ៥-៦

[២៦] ក្នុងសូត្រទី ៥-៦ មានសេចក្ដីប្លែកគ្នាត្រឹមតែប៉ុណ្ណេះថា **អភាវិតំ អបាតុភូតំ** មិនអប់រំហើយ មិនប្រាកដហើយ ដូច្នេះ ក្នុងប្រការនោះ មានការអធិប្បាយដូចតទៅនេះថា ចិត្តសូម្បីកើតដោយអំណាចវដ្ដៈ ក៏ឈ្មោះថា មិនអប់រំ មិនប្រាកដ ព្រោះហេតុអ្វី? ព្រោះមិនអាចនឹងស្ទុះទៅក្នុងវិបស្សនា ដែលមានឈានជាបាទ មគ្គ ផល និងនិព្វាន ដែលជាលោកុត្តរៈ ។ ចំណែកចិត្តដែលកើតដោយអំណាចវិវដ្ដៈ ឈ្មោះថា ជាចិត្តអប់រំហើយ ប្រាកដហើយ ព្រោះហេតុអ្វី? ព្រោះអាចស្ទុះទៅក្នុងធម៌ទាំងនោះបាន ។ ចំណែកព្រះបុស្សមិត្តត្ថេរៈ អ្នកនៅកុរុន្ទកវិហារ ពោលថា អ្នកមានអាយុ មគ្គចិត្តប៉ុណ្ណោះ ឈ្មោះថា ជាចិត្តអប់រំហើយ ប្រាកដហើយ ។

ចប់អដ្ឋកថា សូត្រទី៥-៦

# អដ្ឋកថាសូត្រទី ៧-៨

*ក្នុងសូត្រទី ៧-៨ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២៨] *បទថា* ***អពហុលីកតំ*** *បានដល់ មិនធ្វើរឿយៗ គប្បីជ្រាបចំពោះចិត្ត ដែលកើតឡើងដោយអំណាចវដ្ដៈ និងវិវដ្ដៈ ទាំង ២ ដូង នេះឯង ។*

ចប់អដ្ឋកថា សូត្រទី ៧-៨

# អដ្ឋកថាសូត្រទី ៩

*ក្នុងសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣០] *(ចិត្ត) ឈ្មោះថា នាំទុក្ខមកឲ្យ ព្រោះនាំមក គឺ នាំមកនូវវដ្ដទុក្ខ ដែលត្រាស់ទុកដោយន័យមានជាដើមថា* ***ជាតិបិ ទុក្ខា*** *(សូម្បីការកើតក៏ជាទុក្ខ) បាលីថា* ***ទុក្ខាធិវាហំ*** *ដូច្នេះក៏មាន សេចក្ដីនៃបាលីនោះ គប្បីជ្រាបដូចតទៅនេះ ថា ចិត្ត ឈ្មោះថា* ***ទុក្ខាធិវាហៈ*** *ព្រោះលំបាកដែលនឹងត្រូវនាំឆ្ពោះកាន់អរិយធម៌ ដែលមានឈានជាបាទរបស់លោកុត្តរៈជាដើម សូម្បីចិត្តនេះ ក៏គឺ ចិត្តដែលកើតឡើងដោយអំណាចវដ្ដទុក្ខទុំះឯង ។ ពិតណាស់ ចិត្តនោះ សូម្បីនឹងឲ្យទេវ-សម្បត្តិ និងមនុស្សសម្បត្តិ មានប្រការដូចពោលហើយ ក៏ឈ្មោះថា នាំទុក្ខមកឲ្យ ព្រោះនាំជាតិទុក្ខជាដើមមកឲ្យ និងឈ្មោះថា លំបាកដែលនឹងនាំទៅ ព្រោះឆ្ពោះទៅដើម្បីសម្រេចអរិយធម៌បានដោយលំបាក ។*

ចប់អដ្ឋកថា សូត្រទី ៩

# អដ្ឋកថាសូត្រទី ១០

*ក្នុងសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣១] *ចិត្ត ក៏គឺ ចិត្តដែលកើតឡើងដោយអំណាចវិវដ្ដៈនុ៎ះឯង ពិតហើយ ចិត្ត ឈ្មោះថា* ***សុខាធិវហៈ*** *ឬ* ***សុខាធិវាហៈ*** *ព្រោះអត្ថថា នាំមក គឺ នាំមកដែលទិព្វសុខដ៏ល្អិត ប្រណីតជាងសុខរបស់មនុស្ស , នូវឈានសុខដ៏ល្អិត ប្រណីតជាងទិព្វសុខ , នូវវិបស្សនាសុខដ៏ល្អិត ប្រណីតជាងឈានសុខ , នូវមគ្គសុខដ៏ល្អិត ប្រណីតជាងវិបស្សនាសុខ , នូវផលសុខដ៏ល្អិត ប្រណីតជាងមគ្គសុខ , នូវនិព្វានសុខដ៏ល្អិត ប្រណីតជាងផលសុខ ។*

*ពិតណាស់ ចិត្តនោះ ជាចិត្តងាយដែលនឹងបញ្ជូនត្រង់ចំពោះអរិយធម៌ដែលមានឈានជាបាទរបស់លោកុត្តរៈជាដើម ដូចវជិរាវុធរបស់ព្រះឥន្ទ្រដែលព្រលែងទៅ ដូច្នោះ ហេតុនោះ ទើបហៅថា សុខាធិវាហៈ ។ ក្នុងវគ្គនេះ លោកពោលវដ្ដៈ និងវិវដ្ដៈប៉ុណ្ណោះឯង ។*

ចប់អដ្ឋកថា សូត្រទី ១០

## ចប់អកម្មនិយវគ្គទី ៣

រួមអដ្ឋកថាក្នុងវគ្គនេះមាន ១០ អដ្ឋកថា

# អនន្តវគ្គទី ៤

## អដ្ឋកថាសូត្រទី ១

*សូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣២] *បទថា* ***អទន្តំ*** *សេចក្តីថា មានការសេពខុស (គឺ មានអស្មិមានះ) ដូចដំរី និងសេះជាដើម ដែលមិនបានទូន្មាន បទថា* ***ចិត្តំ*** *បានដល់ចិត្តដែលកើតឡើងដោយអំណាចវដ្តៈ ។*

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

*សូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៣] *បទថា* ***ទន្តំ*** *បានដល់ អស់អស្មិមានះ គឺ ដូចជាដំរី និងសេះជាដើម ដែលទូន្មានហើយ ក្នុងសូត្រទាំង ២ នេះ លោកពោលចំពោះចិត្ត ដែលកើតឡើងដោយអំណាចវដ្ដៈ និងវិវដ្ដៈ ក៏ក្នុងសូត្រនេះយ៉ាងណា សូម្បីក្នុងសូត្រដទៃៗ ក្រៅពីសូត្រនេះ ក៏ដូច្នោះ ។*

ចប់អដ្ឋកថា សូត្រទី ២

# អដ្ឋកថាសូត្រទី ៣

*សូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៤] *បទថា* ***អគុត្តំ*** *បានដល់ មិនគ្រប់គ្រង គឺ វៀរចាកសតិសំវរៈ ដូចជាដំរី និងសេះដែលមិនបានគ្រប់គ្រង (គឺ មិនមានអ្នករក្សា) ដូច្នោះ ។*

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថាសូត្រទី ៤

*សូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣៥] បទថា* **គុត្តំ** *បានដល់ គ្រប់គ្រងហើយ គឺ មិនលះបង់សតិសំវរៈ ដូចជាដំរី និងសេះជាដើម ដែលបានរក្សាហើយ ។*

ចប់អដ្ឋកថា សូត្រទី ៤

# អដ្ឋកថាសូត្រទី ៥-៦

*សូត្រទី ៥-៦ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៦] *លោកពោលតាមអធ្យាស្រ័យរបស់សត្វដែលនឹងត្រាស់ដឹងដោយអំណាចបទថា* ***អរក្ខិតំ*** *ក៏អត្ថក្នុងបទនេះ ដូចបទមុនន៉ុះឯង ។*

ចប់អដ្ឋកថា សូត្រទី ៥-៦

# អដ្ឋកថាសូត្រទី ៧-៨

*សូត្រទី ៧-៨ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៨-៣៩] *សូម្បីក្នុងសូត្រទី ៧-៨ ក៏ន័យនេះដូចគ្នា តែក្នុងសេចក្តីនេះ គប្បីជ្រាបឧបមាដោយទ្វារផ្ទះជាដើម ដែលមិនប្រុងប្រយ័ត្ន ។*

ចប់អដ្ឋកថា សូត្រទី ៧-៨

# អដ្ឋកថាសូត្រទី ៩-១០

*សូត្រទី ៩-១០ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៤០-៤១] ក្នុងសូត្រទី ៩-១០ លោកយកបទ ៤ បទមកប្រកប ហើយពោលក្នុងវគ្គនេះ លោកពោលចំពោះវដ្ដៈ និងវិវដ្ដៈ ប៉ុណ្ណោះឯង ។*

ចប់អដ្ឋកថា សូត្រទី ៩-១០

## ចប់អនន្តវគ្គទី ៤

រួមអដ្ឋកថាក្នុងវគ្គនេះមាន ១០ អដ្ឋកថា

# បណិហិតអច្ឆវគ្គទី ៥

## អដ្ឋកថាសូត្រទី ១

"ពោលអំពីផលនៃចិត្តដែលតាំងទុកខុសជាដើម"

*សូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៤២] *ស័ព្ទថា **សេយ្យថាបិ** ជានិបាត ប្រើក្នុងអត្ថថា ឧបមា ។ ក្នុងអត្ថដែលពោលដោយឧបមានោះ កន្លែងខ្លះ ព្រះដ៏មានព្រះភាគទ្រង់សម្ដែងយកការប្រកបឧបមាដូចក្នុងវត្ថសូត្រ និងក្នុងបរិឆត្តកោបមសូត្រ និងអគ្គិខន្ធោបមសូត្រ និងដូចក្នុងសុវណ្ណការសូត្រ និងសុរិយោបមសូត្រជាដើម តែក្នុងសាលិសូកោបមសូត្រនេះ ព្រះដ៏មានព្រះភាគ កាលទ្រង់យកឧបមាប្រកបសេចក្ដី ទើបត្រាស់ពាក្យមានជាដើមថា **សេយ្យថាបិ ភិក្ខវេ** ដូច្នេះ បណ្ដាបទទាំងនោះ បទថា **សាលិសូកំ**[១] ប្រែថា ចុងគ្រាប់ស្រូវខ្សាយ សូម្បីក្នុងចុងគ្រាប់ស្រូវដំណើប ក៏ន័យនេះដូចគ្នា **វា** ស័ព្ទ មានអត្ថថា **វិកប្ប** មិនពិតប្រាកដ ។ បទថា **មិច្ឆាបណិហិតំ** ប្រែថា តាំងទុកខុស អធិប្បាយថា មិនតាំងឲ្យចុងឡើងលើ ដោយប្រការដែលអាចនឹងមុតបាន ។ បទថា **ភិជ្ជិស្សតិ** សេចក្ដីថា នឹង*

---

*១ សាលិសូកំ អដ្ឋកថា ប្រែថា ស្រូវសាលី , បិដក ស្រូវខ្សាយ យកតាមបិដក ។*

ទម្លាយ គឺ នឹងធ្វើឲ្យឈាមផុលឡើង ។

បទថា **មិច្ឆាបណិហិតេន ចិត្តេន** ប្រែថា ព្រោះចិត្តដែលតាំងទុកខុស ពាក្យនេះ លោកពោលសំដៅយកចិត្តដែលកើតឡើងដោយអំណាចវដ្ដៈ បទថា **អវិជ្ជំ** បានដល់ សេចក្ដីមិនដឹងដ៏ធំ ក្រាស់ដោយសេចក្ដីងងឹត ជាសេចក្ដីមិនដឹងក្នុងឋានៈ ៨ ។ បទថា **វិជ្ជំ** ក្នុងពាក្យថា **វិជ្ជំ ឧប្បាទេស្សតិ** នេះ បានដល់ ញាណដែលសម្បយុត្តដោយអរហត្តមគ្គ ។ បទថា **និព្វានំ** បានដល់ អមតៈ គុណជាតិដែលមិនស្លាប់ ដែលលោកពោលទុកយ៉ាងនោះ ក៏ព្រោះជាគុណជាតចេញចាកកិលេសជាគ្រឿងរួបរឹត គឺ តណ្ហា ។ បទថា **សច្ឆិករិស្សតិ** បានដល់ ធ្វើឲ្យប្រាកដ ។

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

ក្នុងសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៤៣] បទថា *សម្មាបណិហិតំ* សេចក្ដីថា តាំងទុកល្អ ព្រោះធ្វើឲ្យចុងឡើងលើ ព្រោះអាចនឹងមុតបាន ។ ក្នុងបទថា *អក្កន្តំ* (ជាន់) នេះ រមែងឈ្មោះថា ជាន់ដោយជើងប៉ុណ្ណោះ (បើជាដៃក៏បាន) យកដៃច្របាច់ ។ តែដែលពោលថា "ជាន់" ក៏ជាប់ដោយជាស័ព្ទដែលធ្លាប់ប្រើជាប់គ្នាមក ។ ក៏ក្នុងសូត្រនេះ មានអរិយវោហារត្រឹមតែប៉ុណ្ណោះ ។

សួរថា ក៏ព្រោះហេតុណា លោកទើបមិនកាន់យកវត្ថុដទៃៗ ដែលធំមានបន្លាដើមចំបក់ជាដើម កាន់យកតែចុងស្រូវខ្សាយ ចុងស្រូវជំណើបប៉ុណ្ណោះ ដែលជារបស់ទន់ មិនរឹង ។ ឆ្លើយថា ដើម្បីសម្ដែងថា អកុសលកម្ម សូម្បីមានចំនួនតិច ក៏អាចសម្លាប់កុសលកម្មបាន ។ ដូចជា ចុងស្រូវខ្សាយ ឬចុងស្រូវជំណើប ដែលទន់មិនរឹង ឬបន្លារបស់ដើមចំបក់ និងបន្លានៃដើមឈើមានបន្លាជាដើម ដែលធំៗ ក៏ព្រោះក្នុងបណ្ដាបន្លាទាំងនោះ បន្លាប្រភេទណាមួយ ដែលតាំងទុកខុស មិនអាចនឹងមុតដៃ ឬជើង ឬធ្វើឲ្យចេញឈាម តែដែលតាំងទុកត្រូវ រមែងអាច យ៉ាងណា កុសលមានចំនួនតិច មិនថានឹងឲ្យស្លឹកឈើប្រមាណមួយក្ដាប់ ឬកុសលធំៗ ដូចការឲ្យរបស់វេលាមព្រាហ្មណ៍ជាដើមក៏ដោយ

ចុះ បើប្រាថ្នាវដ្ដសម្បត្តិ ចិត្ត ឈ្មោះថា តម្កល់ទុកខុស ដោយអំណាចពីងវដ្ដៈ អាចនាំវដ្ដៈប៉ុណ្ណោះមកឲ្យ មិនអាចនាំវិវដ្ដៈមកឲ្យ ក៏ដូច្នោះដែរ ។ តែកាល បុគ្គលប្រាថ្នាវិវដ្ដៈ យ៉ាងនេះថា សូមទានរបស់យើងនេះ ចូរនាំមកនូវការអស់ អាសវៈ ឈ្មោះថា តម្កល់ទុកដោយប្រពៃ ដោយអំណាចវិវដ្ដៈ រមែងអាចឲ្យ ទាំងព្រះអរហត្ត ទាំងបច្ចេកពោធិញ្ញាណនោះឯង ។

សមដូចពាក្យដែលលោកពោលទុកថា

**បដិសម្ភិទា វិមោក្ខា ច យា ច សាវកបារមី**

**បច្ចេកពោធិ ពុទ្ធភូមិ សព្វមេតេន លព្ភតិ ។**

បដិសម្ភិទា ១ វិមោក្ខ ១ សាវកបារមី ១ បច្ចេកពោធិ ១ ពុទ្ធភូមិ ១ ទាំងអស់នោះ បុគ្គលរមែងបានដោយចិត្តដែល តម្កល់ទុកដោយប្រពៃ ។

ក៏ក្នុងសូត្រទាំងពីរនេះ លោកពោលទាំងវដ្ដៈ និងវិវដ្ដៈ ។

ចប់អដ្ឋកថា សូត្រទី ២

# អដ្ឋកថាសូត្រទី ៣

ក្នុងសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៤៤] បទថា **បទុដ្ឋចិត្តំ** បានដល់ ចិត្តដែលទោសប្រទូសរ៉ាយហើយ ។ បទថា **ចេតសា ចេតោ បរិច្ច** សេចក្តីថា កំណត់ចិត្តរបស់គេ ដោយចិត្តរបស់ខ្លួន ។ បទថា **យថាភតំ និក្ខិត្តោ** សេចក្តីថា គប្បីឃើញថា តាំងនៅក្នុងនរកទុះឯង ដូចត្រូវនាំមកចោល គឺ ទម្លាក់ ។ បទថា **អបាយំ** ជាដើមទាំងអស់ ជាពាក្យវេវចនៈរបស់នរក ។ ពិតហើយ នរកប្រាសចាកសេចក្តីសុខ គឺ សេចក្តីចម្រើន ទើបឈ្មោះថា អបាយ ។ ភូមិជាទីទៅ គឺ ជាទីត្រាច់ទៅនៃទុក្ខ ព្រោះដូច្នោះ ទើបឈ្មោះថា **ទុគ្គតិ** ។ ឈ្មោះថា **វិនិបាត** ព្រោះជាទីដែលបុគ្គលអ្នកធ្វើអាក្រក់ធ្លាក់ទៅ មិនមានអំណាច ។ ឈ្មោះថា **នរក** ព្រោះអត្ថថា មិនមានគុណដែលគួរត្រេកអរ ។

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថាសូត្រទី ៤

ក្នុងសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៤៥] បទថា **បសន្នំ** បានដល់ ថ្លៃថ្លា ដោយសេចក្តីថ្លៃថ្លាព្រោះសទ្ធា ។ បទថា **សុគតឹ** បានដល់ ភូមិជាទីទៅនៃសុខ ។ បទថា **សគ្គំ លោកំ** បានដល់ លោកដែលលើសដោយសម្បត្តិ មានរូបសម្បត្តិជាដើម ។

ចប់អដ្ឋកថា សូត្រទី ៤

## អដ្ឋកថាសូត្រទី ៥

*ក្នុងសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៤៦] បទថា* ***ឧទករហទោ*** *ប្រែថា អន្លង់ទឹក ។ បទថា* ***អាវិលោ*** *បានដល់ មិនថ្លា ។ បទថា* ***លុឡិតោ*** *បានដល់ មិនស្អាត ។ បទថា* ***កលលីភូតោ*** *ប្រែថា មានភក់ល្បាប់ ។ គប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យថា* ***សិប្បិសម្ពុកំ*** *ជាដើម ដូចតទៅនេះ ៖ ខ្យង លៀស និងសំបកខ្យង ឈ្មោះថា សិប្បិសម្ពុកៈ ជុំគ្រួស និងក្បឿង ឈ្មោះថា សក្ខរកឋលៈ ។ ហ្វូង គឺ ក្រុមនៃត្រីទាំងឡាយ ហេតុនោះ ទើបឈ្មោះថា មច្ឆគុម្ពៈ ហ្វូងត្រី ។ បទថា* ***ចរន្តម្បិ តិដ្ឋន្តម្បិ*** *នេះ មានអធិប្បាយថា ជុំគ្រួស និងក្បឿងនៅស្ងៀមតែម្យ៉ាង ក្រៅពីនេះ ស្ងៀមក៏មាន ហែលទៅក៏មាន ដូចជា រវាងមេគោ ដែលឈរក្ដី ឈប់ក្ដី ដេកក្ដី គោក្រៅពីនោះ ក៏ហៅថា ត្រាច់ទៅ ព្រោះអាស្រ័យគោដែលកំពុងត្រាច់ទៅថា គោទាំងនេះត្រាច់ទៅហើយ យ៉ាងណា ជុំគ្រួស និងក្បឿងទាំងពីរ សូម្បីក្រៅពីនេះ គេហៅថា ឈប់ ព្រោះអាស្រ័យជុំគ្រួស និងក្បឿងដែលនៅស្ងៀម សូម្បីជុំគ្រួស និងក្បឿង ដែលគេហៅថា ហែលទៅ ក៏ព្រោះអាស្រ័យហ្វូងត្រីដែលកំពុងហែលទៅ ដូច្នោះ ។ បទថា* ***អាវិលេន*** *បានដល់ ត្រូវនីវរណៈ ៥ គ្របសង្កត់ទុក ។ ប្រយោជន៍របស់ខ្លួនដែលលាយគ្នាទាំងដែលជាលោកិយៈ និងលោកុត្តរៈ ដែល*

ប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន ឈ្មោះថា ប្រយោជន៍របស់ខ្លួន ក្នុងពាក្យមានជាដើមថា **អត្តត្ថំ វា** ប្រយោជន៍របស់ខ្លួន ដែលលាយគ្នាទាំងជាលោកិយៈ និងលោកុត្តរៈ ក្នុងសម្បរាយភព ឈ្មោះថា ប្រយោជន៍ខាងមុខ សូម្បីប្រយោជន៍ខាងមុខ ឈ្មោះថា **បរត្ថៈ** ព្រោះប្រកបដោយប្រយោជន៍របស់បុគ្គលដទៃ ។ ប្រយោជន៍ទាំង ២ នោះ ឈ្មោះថា **ឧភយត្ថៈ** ប្រយោជន៍ទាំង ២ ។ ម្យ៉ាងទៀត ប្រយោជន៍ជាលោកិយៈ និងលោកុត្តរៈ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងសម្បរាយភពរបស់ខ្លួន ឈ្មោះថា ប្រយោជន៍ខ្លួន ។ ប្រយោជន៍នុ៎ះឯង របស់អ្នកដទៃ ឈ្មោះថា ប្រយោជន៍របស់អ្នកដទៃ ។ សូម្បីប្រយោជន៍ទាំង ២ នោះ ក៏ឈ្មោះថា ឧភយត្ថៈ ប្រយោជន៍ទី ២ ។

បទថា **ឧត្តរឹ វា មនុស្សធម្មា** បានដល់ ដែលក្រៃលែងជាង ធម៌របស់មនុស្ស ពោលគឺ កុសលកម្មបថ ១០ ប្រការ ។ ពិតណាស់ ធម៌ ១០ ប្រការនេះ សូម្បីមិនមានអ្នកដទៃបបួល លោកក៏ហៅថា មនុស្សធម៌ ព្រោះជាធម៌ដែលមនុស្សអ្នកកើតសេចក្តីសង្វេគ សមាទានដោយខ្លួនឯង ក្នុងខាងចុងនៃសត្ថន្តរកប្ប (កប្បដែលសម្លាប់គ្នាដោយសស្ត្រាវុធ) ។ តែឈាន និងវិបស្សនា មគ្គ និងផល គប្បីជ្រាបថា ក្រៃលែងទៅជាងមនុស្សធម៌នោះ ។

បទថា **អលមរិយញ្ញាណទស្សនវិសេសំ** សេចក្តីថា គុណវិសេស ពោល

គឺ ញាណទស្សនៈ ដែលគួរដល់ព្រះអរិយៈទាំងឡាយ ឬដែលអាចធ្វើឲ្យបានជាអរិយៈ ។ ពិតណាស់ ញាណនុ៎ះឯង គប្បីជ្រាបថា ញាណ ព្រោះអត្ថថា ដឹងថា ទស្សនៈ ព្រោះអត្ថថា ឃើញ ។ ពាក្យថា **អលមរិយញ្ញាណទស្សនវិសេសំ** នេះ ជាឈ្មោះរបស់ទិព្វចក្ខុញ្ញាណ វិបស្សនាញាណ មគ្គញ្ញាណ ផលញ្ញាណ និងបច្ចវេក្ខណញ្ញាណ ។

ចប់អដ្ឋកថា សូត្រទី ៥

# អដ្ឋកថាសូត្រទី ៦

ក្នុងសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៤៧] បទថា **អច្ឆោ** ប្រែថា មិនមានមន្ទិល ។ បាលីថា **បសន្នោ** (ថ្លា) ដូច្នេះក៏គួរ ។ បទថា **វិប្បសន្នោ** ប្រែថា ថ្លាល្អ ។ បទថា **អនាវិលោ** ប្រែថា មិនល្អក់ អធិប្បាយថា បរិសុទ្ធ ។ លោកអធិប្បាយទុកថា វៀរចាកពពុះទឹក សារាយ និងចកតូច ។ បទថា **អនាវិលេន** បានដល់ ប្រាសចាកនីវរណៈ ៥ ។ ពាក្យដ៏សេស មានន័យដូចពោលហើយក្នុងសូត្រទី ៤ នុ៎ះឯង ។ ក្នុងសូត្រទាំង ២ នេះ លោកពោលទាំងវដ្ដៈ ទាំងវិវដ្ដៈនុ៎ះឯង ។

ចប់អដ្ឋកថា សូត្រទី ៦

# អដ្ឋកថាសូត្រទី ៧

ក្នុងសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៤៨] បទថា **រុក្ខជាតានំ** ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថបឋមាវិភត្តិ ។ អធិប្បាយថា **រុក្ខជាតានិ** ដើមឈើទាំងឡាយ ។ បទថា **រុក្ខជាតានិ** នេះ ជាឈ្មោះរបស់ដើមឈើទាំងឡាយ ។ បទថា **យទិទំ** ត្រឹមតែនិបាត ។ បទថា **មុទុតាយ** បានដល់ ព្រោះជាឈើទៅខ្ចី ។ ទ្រង់សម្តែងថា ដើមឈើប្រភេទខ្លះ ប្រសើរបំផុត សម្បីដោយពណ៌ខ្លះ ប្រភេទខ្លះប្រសើរដោយក្លិន ប្រភេទខ្លះប្រសើរដោយរស ប្រភេទខ្លះប្រសើរដោយជារបស់រឹង ។ ចំណែកឈើចន្ទន៍ ប្រសើរបំផុត គឺ ប្រសើរ ព្រោះជាឈើទន់ និងសមគួរដល់ការងារ ។

ក្នុងពាក្យថា **ចិត្តំ ភិក្ខវេ ភាវិតំ ពហុលីកតំ** នេះ លោកបំណងយកចិត្តដែលអប់រំ និងធ្វើរឿយៗ ដោយអំណាចសមថៈ និងវិបស្សនា ។ ចំណែកព្រះកុរុន្ទកវសីបុស្សមិត្តត្ថេរៈពោលថា លោកដ៏មានអាយុ ចិត្តក្នុងចតុត្ថជ្ឈានដែលជាបាទរបស់អភិញ្ញាប៉ុណ្ណោះ ឈ្មោះថា ជាចិត្តទន់ និងសមគួរដល់ការងារតែម្យ៉ាង ។

ចប់អដ្ឋកថា សូត្រទី ៧

# អដ្ឋកថាសូត្រទី ៨

ក្នុងសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៤៩] បទថា **ឯវំ លហុបរិវត្តំ** សេចក្តីថា កើតរហ័ស រលត់រហ័ស ដោយអាការយ៉ាងនេះ ។ ស័ព្ទថា **យាវញ្ច** ជានិបាតប្រើក្នុងអត្ថស្មើនឹងអធិមត្តៈ មានប្រមាណក្រៃលែង ។ អធិប្បាយថា មិនមែនធ្វើបានដោយងាយ ។ បទថា **ឥទំ** ត្រឹមតែនិបាត ។ ក្នុងបទថា **ចិត្តំ** មុន អាចារ្យពួកខ្លះពោលថា ជាកវគ្គ-ចិត្ត ។ តែលោកបដិសេធពាក្យនោះ ហើយពោលថា ចិត្តដួងណាមួយ ដោយទីបំផុតសូម្បីចក្ខុវិញ្ញាណ ក៏បំណងយកថា ចិត្តក្នុងទីនេះ ។

តែក្នុងទីនេះ ស្តេចក្រុងមិលិន្ទ ត្រាស់សួរព្រះនាគសេនត្ថេរៈ ដែលជាព្រះធម្មកថិកថា ព្រះនាគសេន ចិត្តសន្ទារដែលប្រព្រឹត្តទៅសូម្បីមួយផ្ទាត់ម្រាមដៃ បើមានរូបរាងនឹងជាគំនរធំប៉ុនណា? ព្រះនាគសេនឆ្លើយថា មហាបពិត្រ ស្រូវមួយរយរទេះ ខ្វះកន្លះរទេះ ៧ អម្ពនៈ និង ២ តុម្ពៈ រមែងមិនដល់សូម្បីការរាប់ រមែងមិនដល់សូម្បីការពណ៌នា រមែងមិនដល់សូម្បីការចែក នៃការរាប់ចំនួនរបស់ចិត្តដែលប្រព្រឹត្តទៅត្រឹមមួយផ្ទាត់ម្រាមដៃ ។

សួរថា បើដូច្នោះ ព្រោះហេតុអ្វី ព្រះសម្មាសម្ពុទ្ធទើបត្រាស់ថា សូម្បីការឧបមា ក៏ធ្វើបានលំបាក ។ ឆ្លើយថា សូម្បីលោកបដិសេធឧបមាដោយស្រូវ

ក៏បានធ្វើឧបមាអាយុរបស់កប្ប ដោយប្រៀបធៀបនឹងភ្នំមួយយោជន៍ ឬព្រះនគរពេញទៅដោយគ្រាប់ស្ពៃទំហំមួយយោជន៍ ប្រៀបធៀបទុក្ខរបស់សត្វនរកដោយការចាក់ ១០០ លំពែង ប្រៀបធៀបសេចក្ដីសុខក្នុងសួគ៌ ដោយប្រៀបធៀបនឹងសម្បត្តិស្ដេចចក្រពត្តិ យ៉ាងណា សូម្បីក្នុងទីនេះ ក៏គប្បីធ្វើឧបមាដូច្នោះ ។ ក្នុងមិលិន្ទបញ្ហានោះ លោកធ្វើឧបមា ដោយអំណាចនៃពាក្យសួរយ៉ាងនេះថា លោកម្ចាស់ធ្វើឧបមាបានទេ? ក្នុងសូត្រនេះ លោកមិនធ្វើឧបមាទុក ព្រោះមិនមានការសាកសួរ ។ ពិតហើយ ព្រះសូត្រនេះ លោកពោលទុកក្នុងផ្នែកបញ្ចប់ព្រះធម៌ទេសនា ។ ក្នុងព្រះសូត្រនេះ លោកហៅឈ្មោះថា **ចិត្តរាសី** (គំនរចិត្ត) ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា សូត្រទី ៨

# អដ្ឋកថាអនន្តរវគ្គទី ៩

ក្នុងសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៥០] បទថា **បភស្សរំ** បានដល់ ស គឺ បរិសុទ្ធ ។ បទថា **ចិត្តំ** បានដល់ ភវង្គចិត្ត ។ សួរថា ក៏ឈ្មោះថា ពណ៌របស់ចិត្តមានឬ? ឆ្លើយថា មិនមាន ។ ពិតណាស់ ចិត្តនឹងមានពណ៌ណាមួយ មានពណ៌ខៀវជាដើម ឬនឹងជាពណ៌មាសក៏ដោយ សូម្បីយ៉ាងណាមួយ លោកក៏ហៅថា **បភស្សរ** ព្រោះជាចិត្តបរិសុទ្ធ ។ សូម្បីចិត្តនេះ ឈ្មោះថា បរិសុទ្ធ ព្រោះប្រាសចាកឧបក្កិលេស ហេតុនោះ ទើបឈ្មោះថា **បភស្សរ** ។

បទថា **តញ្ច ខោ** បានដល់ ភវង្គចិត្តនោះ ។ បទថា **អាគន្តុកេហិ** បានដល់ ឧបក្កិលេសដែលមិនកើតរួមគ្នា នឹងកើតក្នុងខណៈនៃជវនចិត្តក្នុងចំណែកខាងក្រោយ ។ បទថា **ឧបក្កិលេសេហិ** សេចក្តីថា ភវង្គចិត្តនោះ លោកហៅថា ឈ្មោះថា សៅហ្មងហើយ ព្រោះសៅហ្មងហើយដោយកិលេសមានរាគៈជាដើម ។ សៅហ្មងយ៉ាងណា? ដូចជា បិតាមាតា ឬឧបជ្ឈាយ៍អាចារ្យ មានសីលសម្បូរដោយការប្រព្រឹត្ត មិនបន្ទោស មិនឲ្យសិក្សា មិនទូន្មាន មិនបង្រៀនបុត្រ ឬអន្តេវាសិក និងសទ្ធិវិហារិករបស់ខ្លួន ព្រោះហេតុដែលបុត្រ និងសទ្ធិវិហារិក អន្តេវាសិក ជាអ្នកទ្រុស្តសីល មានការប្រព្រឹត្តមិនល្អ មិនសម្បូរណ៍ដោយវត្ត-

បដិបត្តិ រមែងបានទទួលការតិះដៀល វិនាសកេរ្តិ៍ឈ្មោះ យ៉ាងណា គប្បីជ្រាប ប្រការឧបមេយ្យនេះ ដូច្នោះ ។ គប្បីឃើញភវង្គចិត្ត ដូចបិតាមាតា និងឧបជ្ឈាយ៍ អាចារ្យ អ្នកបរិបូរណ៍ដោយការប្រព្រឹត្ត ។ ភវង្គចិត្ត សូម្បីនឹងបរិសុទ្ធតាម ប្រក្រតី ក៏ឈ្មោះថា សៅហ្មង ព្រោះឧបក្កិលេសដែលចូរមក ដែលកើតឡើង ដោយអំណាចការកើតព្រមដោយលោភៈ ទោសៈ និងមោហៈ ដែលមានសេចក្តី ពេញចិត្ត ទាស់ចិត្ត និងសេចក្តីវង្វេងជាសភាវៈ ក្នុងខណៈនៃជវនចិត្ត ដូចជា បិតាមាតាជាដើមទាំងនោះ បានការវិនាសកេរ្តិ៍ឈ្មោះ ហេតុព្រោះបុត្រជាដើម ដូច្នោះឯង ។

ចប់អដ្ឋកថា សូត្រទី ៩

# អដ្ឋកថាសូត្រទី ១០

*សូម្បីក្នុងសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៥១] **ចិត្ត** ក៏គឺ ភវង្គចិត្តនុ៎ះឯង ។ បទថា **វិប្បមុត្តំ** សេចក្តីថា ភវង្គចិត្តនោះ មិនត្រេកអរ មិនទាស់ចិត្ត មិនវង្វេង តែក្នុងខណៈនៃជវនចិត្តកើតឡើង ដោយអំណាចកុសលចិត្តដែលជាញាណសម្បយុត្ត ប្រកបដោយត្រៃហេតុជាដើម រមែងឈ្មោះថា រួចផុតចាកឧបក្កិលេសទាំងឡាយដែលចរមក ។ សូម្បីក្នុងទីនេះ ភវង្គចិត្តនេះ លោកហៅថា រួចផុតហើយចាកឧបក្កិលេសទាំងឡាយដែលចរមក ដោយអំណាចកុសលចិត្ត ដែលកើតឡើងក្នុងខណៈនៃជវនចិត្ត ដូចមាតាជាដើម បានទទួលសេចក្តីសរសើរ និងមានឈ្មោះបោះសំឡេងថា ពួកគេប្រសើរពិត ញ៉ាំងបុត្រជាដើមឲ្យសិក្សា ឱវាទ អនុសាសន៍ ហើយដូច្នេះ ហេតុព្រោះបុត្រជាដើម ជាអ្នកមានសីល សម្បូរណ៍ដោយការប្រព្រឹត្តដូច្នោះ ។*

ចប់អដ្ឋកថា សូត្រទី ១០

## ចប់បណិហិតអច្ឆវគ្គទី ៥

រួមអដ្ឋកថាក្នុងវគ្គនេះមាន ១០ អដ្ឋកថា

# អច្ឆរាសង្ឃាតវគ្គទី ៦

## អដ្ឋកថាសូត្រទី ១

*សូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៥២] *បទថា* **តំ អស្សុតវា បុថុជ្ជនោ** *សេចក្ដីថា បុថុជ្ជន វៀរចាកពីការសិក្សាភវង្គចិត្តនោះ ។ ក្នុងបទថា* **តំ អស្សុតវា បុថុជ្ជនោ** *នោះ ឈ្មោះថា មិនបានសិក្សាញេយ្យធម៌ ព្រោះមិនមានអាគមនិកាយដែលបានរៀន និងអធិគមមគ្គផលដែលនឹងសម្រេច ។ ពិតហើយ បុគ្គលណាដេញដោលសួរព្រះសូត្រនេះ ដោយអត្ថតាំងពីដើម មិនទាន់ដឹងដោយអំណាចនិកាយ គឺ គម្ពីរ ដែលមានមករបស់សូត្រនេះ ដោយអត្ថតាំងពីដើម មិនទាន់ដឹងដោយអំណាចនិកាយ គឺ គម្ពីរដែលមានមករបស់សូត្រនេះ និងដោយអំណាចមគ្គផល ដែលអ្នកបដិបត្តិគប្បីសម្រេចថា ឈ្មោះថា ភវង្គចិត្តនេះ សូម្បីបរិសុទ្ធតាមប្រក្រតី ក៏សៅហ្មងព្រោះឧបក្កិលេស មានលោភៈជាដើម ដែលកើតឡើងហើយ ក្នុងខណៈនៃជវនចិត្ត ។ មួយទៀត បុគ្គលណាមិនមាននិកាយជាទីមក ដែលនឹងបកស្រាយធម៌ឲ្យយល់តាមសេចក្ដីពិត ព្រោះវៀរចាកការរៀន និងការសាកសួរក្នុងខន្ធ ធាតុ អាយតនៈ បច្ចយាការ និងសតិប្បដ្ឋានជាដើម និងមិនមានអធិគម ព្រោះមិនបាន*

សម្រេចមគ្គផល ដែលនឹងគប្បីសម្រេចដោយការបដិបត្តិ បុគ្គលនោះឈ្មោះថា មិនសិក្សាញេយ្យធម៌ ព្រោះមិនមានអាគម និងអធិគម ។

**បុថូនំ ជននាទីហិ ការណេហិ បុថុជ្ជនោ**
**បុថុជ្ជនន្តោគធត្តា បុថុ វាយំ ជនោ ឥតិ ។**

ជននេះ ឈ្មោះថា បុថុជ្ជន ព្រោះហេតុទាំងឡាយ មាន ធ្វើកិលេសជាច្រើនឲ្យកើតឡើងជាដើម ឬថា ឈ្មោះថា បុថុជ្ជន ព្រោះធ្លាក់ចុះចំណែកខាងក្នុងនៃជនអ្នកដែលមាន កិលេសក្រាស់ ។

ពិតណាស់ ជននោះ ឈ្មោះថា **បុថុជ្ជន** ព្រោះហេតុទាំងឡាយ មានការធ្វើឲ្យកើតកិលេសមានប្រការផ្សេងៗ ជាច្រើន ដូចដែលលោកពោលទុកថា ឈ្មោះថា **បុថុជ្ជន** ព្រោះធ្វើឲ្យកើតកិលេសជាច្រើន ។ ឈ្មោះថា **បុថុជ្ជន** ព្រោះមានសក្កាយទិដ្ឋិដែលមិនទាន់លះបង់បាន ។ ឬថា **បុថុជ្ជន** ព្រោះតាក់តែងដោយអភិសង្ខារផ្សេងៗ ដ៏ច្រើន ។ ឈ្មោះថា **បុថុជ្ជន** ព្រោះត្រូវឱឃៈកិលេស ដូចអន្លង់ទឹកផ្សេងៗ ដ៏ច្រើនបន្សាត់នាំទៅ ។ ឈ្មោះថា **បុថុជ្ជន** ព្រោះក្តៅក្រហាយដោយគ្រឿងក្តៅក្រហាយជាច្រើន ។ ឈ្មោះថា **បុថុជ្ជន** ព្រោះរីករាយ ត្រេកអរ ល្មោភ ស្ងប់ ងប់ ជាប់ ជំពាក់ ព័ន្ធព័ទ្ធ ក្នុងកាមគុណទាំង ៥ ច្រើន ។ ឈ្មោះ

ថា **បុថុជ្ជន** ព្រោះត្រូវនីវរណៈ ៥ រួបរឹត បិទបាំង រាំង កំបាំងទុកច្រើន ។ ម្យ៉ាងទៀត ឈ្មោះថា **បុថុជ្ជន** ព្រោះធ្លាក់ចុះក្នុងចំណែកនៃជនអ្នកមានកិលេសក្រាស់ ប្រព្រឹត្តទៅកន្លងការរាប់ អ្នកបែរខ្នងចំពោះអរិយធម៌ អ្នកប្រព្រឹត្តធម៌ដែលថោកទាប ដូច្នេះក៏មាន ។ ក៏បុថុជ្ជននេះ រាប់ថា ជាអ្នកលះបង់គ្នានោះឯង ។ ឈ្មោះថា **បុថុជ្ជន** ព្រោះជាអ្នកមិនទាក់ទងជាមួយព្រះអរិយៈ ដែលប្រកបដោយគុណ មានសីល និងសុតៈជាដើម ។ ពីរបទថា **អស្សុតវា បុថុជ្ជនោ** ដូចបានពណ៌នាមកយ៉ាងនេះ លោកពោលបុថុជ្ជនទុក ២ ពួកថា ៖

**ទុវេ បុថុជ្ជនា វុត្តា ពុទ្ធេនាទិច្ចពន្ធុនា**

**អន្ធោ បុថុជ្ជនោ ឯកោ កល្យាណោ បុថុជ្ជនោ ។**

ព្រះពុទ្ធជាផៅពង្សនៃព្រះអាទិត្យ ត្រាស់បុថុជ្ជនទុក ២ ពួក

គឺ អន្ធបុថុជ្ជន ១ កល្យាណបុថុជ្ជន ១ ។

បណ្តាបុថុជ្ជន ដែលពោលទុកហើយទាំង ២ នោះ អន្ធបុថុជ្ជន គប្បីជ្រាបថា ជាការពោលទុកហើយ ។ បទថា **យថាភូតំ នប្បជានាតិ** សេចក្តីថា បុថុជ្ជនដែលមិនបានស្តាប់ រមែងមិនដឹងតាមសេចក្តីពិត កវង្គចិត្តនេះ ឈ្មោះថា សៅហ្មង ព្រោះឧបក្កិលេសទាំងឡាយដែលចរមកយ៉ាងនេះ ឈ្មោះថា រួចផុតហើយយ៉ាងនេះ ។ បទថា **តស្មា** សេចក្តីថា ព្រោះហេតុដែលមិនដឹង ។ បទថា

*ចិត្តភាវនា នត្ថិ បានដល់ សេចក្ដីតាំងមាំនៃចិត្ត ការកំណត់ចិត្តមិនមាន ។ ដោយការៈដែលមិនមានទុំះឯង ទ្រង់សម្ដែងថា តថាគតពោលថា មិនមានដូច្នេះ ។*

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

ក្នុងសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៥៣] បទថា *សុតវា* បានដល់ ដល់ព្រមដោយការសិក្សា ។ ក៏ក្នុងបទថា *សុតវា* នេះ បើពោលដោយពិស្តារ គប្បីជ្រាបសេចក្តីដោយផ្ទុយគ្នានឹងបទថា *អស្សុតវា* ។

បទថា *អរិយសាវកោ* បានដល់ ព្រះអរិយៈដែលមិនមែនជាព្រះសាវកក៏មាន ដូចជា ព្រះពុទ្ធ និងព្រះបច្ចេកពុទ្ធ ។ ព្រះសាវក ដែលមិនមែនជាព្រះអរិយៈក៏មាន ដូចគ្រហស្ថអ្នកមិនទាន់បានសម្រេចផល ។ ទាំងមិនជាព្រះអរិយៈទាំងមិនជាព្រះសាវកក៏មាន ដូចជាពួកតិរ្ថិយដ៏ច្រើន ។ ទាំងជាព្រះអរិយៈ ទាំងជាព្រះសាវកក៏មាន ដូចជាព្រះសមណសក្យបុត្រ អ្នកសម្រេចផល ដឹងច្បាស់ពាក្យប្រៀនប្រដៅហើយ ។ តែក្នុងទីនេះ នឹងជាគ្រហស្ថ ឬបព្វជិតក៏ដោយ បុគ្គលណាមួយ ដែលសម្បូរណ៍ដោយការសិក្សា ដោយអំណាចនៃអត្ថដែលពោលទុកហើយ គប្បីជ្រាបថា បុគ្គលនេះជាព្រះអរិយសាវក ក្នុងបទថា *សុតវា* នេះ ។

បទថា *យថាភូតំ បជានាតិ* ព្រះអរិយសាវកអ្នកបានស្តាប់ហើយ រមែង

ដឹងច្បាស់តាមសេចក្តីពិតករង្គចិត្តនេះ ផុតហើយចាកឧបក្កិលេសទាំងឡាយ ដែលចរមកដោយអាការយ៉ាងនេះ សៅហ្មងហើយដោយអាការយ៉ាងនេះ ។ បទថា **ចិត្តភាវនា អត្ថិ** សេចក្តីថា ការតាំងមាំនៃចិត្ត ការកំណត់ចិត្តមានហើយ ដោយការៈដែលចិត្តមានហើយនុ៎ះឯង ទ្រង់សម្តែងថា មានហើយ ។ ក្នុងសូត្រនេះ លោកពោលដល់វិបស្សនាដែលចាស់ក្លា ។ អាចារ្យពួកខ្លះពោលថា ជាវិបស្សនាដែលនៅទន់ខ្ចី ។

ចប់អដ្ឋកថា សូត្រទី ២

# អដ្ឋកថាសូត្រទី ៣

[៥៤] *សូត្រទី ៣ ពោលទុកហើយក្នុងហេតុកើតរឿង ។ ពោលទុកក្នុងហេតុកើតនូវរឿងអ្វី? ក្នុងហេតុកើតរឿង អគ្គិក្ខន្ធោបមសូត្រ ។*

*បានឮថា សម័យមួយព្រះដ៏មានព្រះភាគ ប្រថាប់នៅក្នុងជេតវនមហាវិហារជិតក្រុងសាវត្ថី ។ ពិតហើយ ព្រះពុទ្ធទាំងឡាយ ទ្រង់អាស្រ័យនៅក្នុងទីកន្លែងណាមួយ ក៏ទ្រង់មិនបានលះបង់កិច្ច ៥ យ៉ាងឡើយ ។*

*ឈ្មោះថា ពុទ្ធកិច្ច ៥ យ៉ាង គឺ បុរេភត្តកិច្ច ១ បច្ឆាភត្តកិច្ច ១ បុរិមយាមកិច្ច ១ មជ្ឈិមយាមកិច្ច ១ បច្ឆិមយាមកិច្ច ១ ។*

*ក្នុងពុទ្ធកិច្ច ៥ នោះ បុរេភត្តកិច្ច កិច្ចមុនសោយអាហារ មានដូចតទៅនេះ ។ ពិតហើយ ព្រះដ៏មានព្រះភាគ ស្តេចតើនឡើងពីព្រឹក ទ្រង់ធ្វើបរិកម្មព្រះសរីរៈ មានការលុបលាងព្រះភក្ត្រជាដើម ដើម្បីអនុគ្រោះឧបដ្ឋាក និងដើម្បីសេចក្តីសុខនៃព្រះសរីរៈ ទ្រង់សម្ងំនៅលើអាសនៈដែលស្ងាត់ ដរាបដល់វេលាភិក្ខាចារ លុះបានវេលាភិក្ខាចារ ទ្រង់ស្លៀកអន្តរវាសកៈ ទ្រង់វត្តពន្ធចង្កេះ ដណ្តប់ចីវរ យកបាត្រ គ្រាខ្លះក៏ព្រះអង្គតែមួយអង្គ គ្រាខ្លះក៏ហែហមទៅដោយភិក្ខុសង្ឃ ស្តេចចូលទៅកាន់ស្រុក ឬនិគមបិណ្ឌបាត ។ ពេលខ្លះស្តេចចូលទៅ*

តាមប្រក្រតី ពេលខ្លះស្តេចទៅដោយបាដិហារ្យដ៏ច្រើន ។ គឺ កាលព្រះលោកនាថ ស្តេចយាងបិណ្ឌបាត ខ្យល់រំភើយៗ ក៏បក់ទៅខាងមុខ បោសផែនដីឲ្យស្អាត ពពកបង្អុរគ្រាប់ភ្លៀងបំបាត់ល្អងធូលីលើផ្លូវ បាំងជាពិតានទៅខាងលើ ។ ខ្យល់មួយពួកទៀត ក៏នាំផ្កាឈើចូលទៅរោយចុះលើផ្លូវ ភូមិប្រទេសដែលជាទីទួល ក៏ស្រុតចុះ ។ ភូមិប្រទេសដែលជារណ្តៅ ក៏ទួលពេញឡើង វេលាដែលទ្រង់ឈានព្រះបាទ ភូមិភាគរមែងមានផ្ទៃរាបស្មើ ឬផ្កាបទុមមានសម្ផស្សដ៏ទន់ល្មើយ ចាំទ្រព្រះបាទ ។ ពេលទ្រង់ដាក់ព្រះបាទខាងស្តាំ មានចំណែកដូចសសរខឿន ធព្វណ្ណរង្សី ព្រះរស្មីមានពណ៌ ៦ ប្រការ ផ្សាយចេញពីព្រះសរីរាវយវៈ បាញ់ទៅដោយជុំវិញ ធ្វើប្រាសាទ និងផ្ទះកំពូលជាដើម ឲ្យមានពណ៌លឿងដូចមាស និងឲ្យដូចជារុំព័ទ្ធដោយសំពត់ដ៏វិចិត្រ ។ សត្វទាំងឡាយ មានដំរី សេះ និងបក្សីជាដើម ដែលនៅក្នុងកន្លែងរៀងៗ ខ្លួន ក៏បន្លឺសំឡេងដ៏ពីរោះ ។ តន្ត្រីមានស្គរ និងស្គរធំជាដើម និងគ្រឿងអាភរណៈ ដែលជាប់នឹងកាយរបស់ពួកមនុស្ស ក៏ដូចគ្នា គឺ បន្លឺសំឡេងដ៏ពីរោះ ដោយសញ្ញាណនោះ ពួកមនុស្សរមែងដឹងថា ថ្ងៃនេះ ព្រះដ៏មានព្រះភាគ ស្តេចយាងទៅបិណ្ឌបាតក្នុងទីនេះ ។ មនុស្សទាំងនោះស្លៀកដណ្តប់រៀបរយ កាន់គ្រឿងសក្ការៈ មានគ្រឿងក្រអូប និងផ្កាឈើជាដើម ចេញពីផ្ទះ ធ្វើដំណើរទៅតាមថ្នល់ បូជាព្រះដ៏មានព្រះភាគ

ដោយគ្រឿងក្រអូប និងផ្កាឈើជាដើមដោយគោរព ថ្វាយបង្គំហើយ ទូលសូមថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គមេត្តាប្រទានភិក្ខុដល់ពួកខ្ញុំព្រះអង្គ ១០ រូប ដល់ពួកខ្ញុំព្រះអង្គ ២០ រូប ដល់ពួកខ្ញុំព្រះអង្គ ១០០ រូប ហើយទទួលបាត្រពីព្រះដ៏មានព្រះភាគ ក្រាលអាសនៈ បង្អោនថ្វាយបិណ្ឌបាតដោយគោរព ។ ព្រះដ៏មានព្រះភាគសោយព្រះក្រយាហារស្រេចហើយ ទ្រង់ពិចារណាមើលសន្ដានរបស់មនុស្សទាំងនោះហើយ ទ្រង់សម្ដែងធម៌ ។ ពួកខ្លះក៏តាំងនៅក្នុងសរណគមន៍ ពួកខ្លះក៏តាំងនៅក្នុងសីល ៥ ពួកខ្លះក៏តាំងនៅក្នុងសោតាបត្តិផល សកទាគាមិផល និងអនាគាមិផលណាមួយ ពួកខ្លះក៏បួសហើយ តាំងនៅក្នុងព្រះអរហត្តដែលជាផលដ៏ប្រសើរបំផុត ដោយប្រការណា ក៏ទ្រង់អនុគ្រោះមហាជនដោយប្រការនោះ ស្ដេចក្រោកចាកអាសនៈ ស្ដេចត្រឡប់ទៅព្រះវិហារ ។ ស្ដេចទៅកាន់ព្រះវិហារនោះហើយ ប្រថាប់គង់លើបវរពុទ្ធាសនៈ ដែលគេតាក់តែងទុកក្នុងសាលាមូលប្រកបដោយរបស់ក្រអូប ។ ក្នុងវេលាស្រេចភត្តកិច្ចរបស់ភិក្ខុទាំងឡាយ ឧបដ្ឋាកក៏នឹងក្រាបទូលព្រះដ៏មានព្រះភាគ ឲ្យទ្រង់ជ្រាប ។ តពីនោះ ព្រះដ៏មានព្រះភាគ ទើបស្ដេចចូលព្រះគន្ធកុដិ **បុរេភត្តកិច្ច** កិច្ចមុនសោយអាហារ មានប៉ុណ្ណេះ ។

លុះព្រះដ៏មានព្រះភាគ ទ្រង់ធ្វើកិច្ចមុនសោយអាហារយ៉ាងនេះហើយ ក៏

ប្រថាប់គន្ធត្រង់យ៉មុខព្រះគន្ធកុដិ ទ្រង់លាងព្រះបាទ ទ្រង់ឱវាទដល់ភិក្ខុសង្ឃថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរញ៉ាំងកិច្ចឲ្យដល់ព្រមដោយសេចក្តីមិនប្រមាទចុះ ការឧប្បត្តិឡើងរបស់ព្រះពុទ្ធរកបានលំបាក ការបានអត្តភាពជាមនុស្សរកបាន លំបាក ការដល់ព្រមដោយសទ្ធារកបានលំបាក ការបព្វជ្ជារកបានលំបាក ការ ស្តាប់ធម៌រកបានលំបាកក្នុងលោក ។ បណ្តាភិក្ខុទាំងនោះ ភិក្ខុរបខ្លះទូលសួរ កម្មដ្ឋានដល់ព្រះដ៏មានព្រះភាគ ។ ព្រះអង្គក៏ប្រទានកម្មដ្ឋាន ដែលសមគួរដល់ ការប្រព្រឹត្តរបស់ភិក្ខុទាំងនោះ តពីនោះ ភិក្ខុសូម្បីទាំងអស់ថ្វាយបង្គំព្រះដ៏មាន-ព្រះភាគហើយ ទៅកាន់ទីសម្រាកពេលយប់ និងពេលថ្ងៃរៀងៗ ខ្លួន ។ ពួកខ្លះ ទៅព្រៃ ពួកខ្លះទៅគល់ឈើ ពួកខ្លះទៅភ្នំជាដើមកន្លែងណាមួយ ពួកខ្លះទៅភព របស់ស្តេចចាតុម្មហារាជ ពួកខ្លះទៅភពរបស់ស្តេចវស្សវត្តី ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ស្តេចចូលទៅកាន់ព្រះគន្ធកុដិ បើទ្រង់ចង់ ក៏ទ្រង់មានសតិ សម្បជញ្ញៈ ផ្ទំផ្អៀងខាងស្តាំមួយស្របក់ លុះមានព្រះវរកាយរហ័សរហួន ស្តេច ក្រោកឡើងត្រួតមើលសត្វលោក ក្នុងភាគទី ២ ។ ក្នុងភាគទី ៣ មហាជនក្នុង គាម ឬនិគម ដែលព្រះអង្គស្តេចចូលទៅប្រថាប់នៅ ថ្វាយទានមុនអាហារ គ្រា វេលាក្រោយអាហារ ស្លៀកដណ្តប់រៀបរយហើយ កាន់យកសក្ការៈ មានរបស់ ក្រអូប និងផ្កាឈើជាដើម ប្រជុំគ្នាក្នុងព្រះវិហារ ។ លំដាប់នោះព្រះដ៏មានព្រះ-

កាគ ស្ដេចទៅដោយបាដិហារិយ៍ដែលសមគួរដល់បរិស័ទដែលប្រជុំគ្នា ប្រថាប់គង់សម្ដែងធម៌លើពុទ្ធាសនៈដ៏ប្រសើរ ដែលតាក់តែងទុកក្នុងធម្មសភា ឲ្យសមគួរដល់កាល សមគួរដល់សម័យ ។ លុះដល់វេលាដែលគួរហើយ ទើបបញ្ជូនបរិស័ទត្រឡប់ទៅ ។ ពួកមនុស្សថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ ក៏ចៀសចេញទៅ ។ **បច្ឆាភត្តកិច្ច** កិច្ចខាងក្រោយអាហារ មានដូចពោលមកនេះ ។

ព្រះដ៏មានព្រះភាគព្រះអង្គនោះ ទ្រង់ធ្វើបច្ឆាភត្តកិច្ចសម្រេចយ៉ាងនោះហើយ បើទ្រង់ព្រះបំណងនឹងទ្រង់ស្រោចស្រប់ព្រះកាយ ក៏ស្ដេចក្រោកឡើងចាកពុទ្ធាសនៈ ស្ដេចចូលបន្ទប់សម្រាប់ស្រង់ ទ្រង់ស្រោចស្រប់ព្រះកាយដោយទឹកដែលឧបដ្ឋាកចាត់ចែងថ្វាយ ។ សូម្បីព្រះឧបដ្ឋាក ក៏នាំយកពុទ្ធាសនៈមកក្រាលថ្វាយក្នុងបរិវេណព្រះគន្ធកុដិ ព្រះដ៏មានព្រះភាគ ទ្រង់ស្លៀកអន្តរវាសកៈ ២ ជាន់ ដែលជ្រលក់ល្អហើយ ទ្រង់ក្រវាត់វត្ថពន្ធចង្កេះ ទ្រង់គ្រងឧត្តរាសង្គៈហើយស្ដេចមកប្រថាប់លើពុទ្ធាសនៈនោះ ទ្រង់ពួនសម្ងំដោយខ្លួនឯងព្រះអង្គមួយស្របក់ លំដាប់នោះ ភិក្ខុទាំងឡាយមកពីទីនោះៗ ទៅកាន់ទីគាល់ព្រះសាស្ដា បណ្ដាភិក្ខុទាំងនោះ ពួកខ្លះសួរបញ្ហា ពួកខ្លះសូមកម្មដ្ឋាន ពួកខ្លះសូមស្ដាប់ធម៌ ។ ព្រះដ៏មានព្រះភាគ ទ្រង់ចាត់ឲ្យសមតាមបំណងរបស់ភិក្ខុទាំងនោះ ទ្រង់គង់នៅសូម្បីរហូតអស់យាមដើម ។ **បុរិមយាមកិច្ច** កិច្ចក្នុងយាមដើម មានដូចពោល

មកនេះ ។

វេលាស្រេចកិច្ចក្នុងយាមដើម កាលភិក្ខុទាំងឡាយថ្វាយបង្គំព្រះដ៏មាន-ព្រះភាគហើយ ចៀសចេញទៅ ទេវតាទូទៅមុឺនលោកធាតុ កាលបានឱកាសទើបចូលទៅគាល់ព្រះដ៏មានព្រះភាគ សួរបញ្ហា ទីបំផុតសូម្បីអក្សរ ៤ តួ តាមដែលតែងមក ព្រះដ៏មានព្រះភាគ កាលទ្រង់វិសជ្ជនាបញ្ហាដល់ទេវតាទាំងនោះ ទ្រង់នៅរហូតដល់អស់មជ្ឈិមយាម **មជ្ឈិមយាមកិច្ច** កិច្ចក្នុងមជ្ឈិមយាម មានដូចពោលមកនេះ ។

ព្រះដ៏មានព្រះភាគ ទ្រង់បែងចែកបច្ឆិមយាមជា ៣ ចំណែក ហើយទ្រង់ប្រថាប់នៅមួយចំណែកដោយការយាងចង្រ្កម ដើម្បីទ្រង់សម្រួលការនឿយកាយព្រះវរកាយ ដែលប្រថាប់គង់ច្រើន តាំងពីវេលាមុនសោយអាហារ , ក្នុងចំណែកទី ២ ស្តេចចូលទៅព្រះគន្ធកុដិ ទ្រង់មានព្រះសតិ និងសម្បជញ្ញៈ ផ្ទំផ្អៀងខាងស្តាំ , ក្នុងចំណែកទី ៣ ស្តេចក្រោកឡើងប្រថាប់អង្គុយ ត្រួតមើលសត្វលោកដោយពុទ្ធចក្ខុ ទ្រង់ទតព្រះនេត្រមើលបុគ្គលដែលបានធ្វើបុញ្ញាធិការទុកដោយទាន និងសីលជាដើម ក្នុងសម្នាក់របស់ព្រះពុទ្ធទាំងឡាយ ក្នុងកាលមុន ៗ **បច្ឆិមយាមកិច្ច** កិច្ចក្នុងបច្ឆិមយាម មានដូចពោលមកនេះ ។

ថ្ងៃនោះ ព្រះដ៏មានព្រះភាគ ទ្រង់តាំងនៅក្នុងកិច្ចនេះនេះឯង ទ្រង់ត្រួត

មើលសត្វលោក ក៏ទ្រង់បានឃើញហេតុនេះថា កាលបើតថាគតចារិកទៅក្នុងមហាកោសលរដ្ឋ សម្ដែងសូត្រមួយប្រៀបធៀបដោយគំនរភ្លើង ភិក្ខុ ៦០ រូបនឹងសម្រេចព្រះអរហត្ត , ភិក្ខុប្រមាណ ៦០ រូបក្អួតធ្លាក់ឈាម , ភិក្ខុប្រមាណ ៦០ រូប នឹងសឹកជាគ្រហស្ថ ។ បណ្ដាភិក្ខុទាំងនោះ ពួកភិក្ខុដែលនឹងសម្រេចព្រះអរហត្ត បានស្ដាប់ព្រះធម៌ទេសនាយ៉ាងណាមួយ នឹងបានសម្រេចតែម្ដង ។ ក៏ព្រះដ៏មានព្រះភាគ មានព្រះបំណងនឹងស្ដេចចារិកទៅ ដើម្បីសង្គ្រោះភិក្ខុក្រៅពីនេះ ទើបត្រាស់ថា អានន្ទ អ្នកចូរប្រាប់ដល់ភិក្ខុទាំងឡាយ ។

ព្រះថេរៈទៅតាមបរិវេណហើយ ពោលថា លោកដ៏មានអាយុ ព្រះសាស្ដាមានព្រះបំណងនឹងស្ដេចចារិក ដើម្បីសង្គ្រោះមហាជន លោកបំណងនឹងទៅតាមព្រះអង្គ ក៏ចូរនាំគ្នាមកចុះ ។ ភិក្ខុទាំងឡាយ មានចិត្តត្រេកអរ ដូចបានលាភធំ គិតថា យើងនឹងបានសរសើរព្រះសរីរៈដែលមានវណ្ណៈដូចមាស បានស្ដាប់ធម្មកថាដ៏ពីរោះរបស់ព្រះដ៏មានព្រះភាគ ដែលទ្រង់សម្ដែងធម៌ដល់មហាជន បុគ្គលមានសក់ឡើងវែងក៏កោរសក់ មានបាត្រត្រូវស្អិមកាន់ក៏ដុតបាត្រ មានចីវរសៅហ្មងក៏បោកគក់ចីវរ ភិក្ខុផ្សេងទៀតក៏ត្រៀមនឹងតាមស្ដេច ។ ព្រះសាស្ដាហែហមដោយភិក្ខុសង្ឃដែលកំណត់ចំនួនមិនបាន ចេញចារិកទៅកាន់កោសលរដ្ឋ ថ្ងៃមួយៗ ស្ដេចចារិកទៅ ១ គាវុត ២ គាវុត ៣ គាវុត និងមួយយោជន៍

ជាយ៉ាងក្រៃលែង តាមលំដាប់នៃគាម និងនិគម ទតព្រះនេត្រឃើញដើមឈើមានរូងមួយដើមធំត្រូវភ្លើងឆេះ ទ្រង់ត្រិះរិះថា តថាគតនឹងធ្វើដើមឈើនេះឯងឲ្យជាវត្ថុ ជាហេតុតាំងរឿង សម្តែងធម្មកថាប្រកបដោយអង្គ ៧ ទើបវៀរការស្តេចយាង ស្តេចចូលទៅកាន់គល់ឈើមួយដើមនោះ ទ្រង់សម្តែងអាការនឹងប្រថាប់អង្គុយ ។ ព្រះអានន្ទត្ថេរៈ ជ្រាបព្រះបំណងរបស់ព្រះសាស្តា គិតថាប្រាកដជានឹងមានហេតុពិតប្រាកដ ព្រះតថាគតស្តេចមិនយាងតទៅទៀត ហើយឈប់ប្រថាប់គង់ ដោយហេតុដែលមិនសមគួរមិនមានឡើយ ទើបក្រាលសង្ឃាដិ ៤ ជាន់ ។ ព្រះសាស្តា ប្រថាប់អង្គុយហើយ ត្រាស់ហៅភិក្ខុទាំងឡាយមកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមើលគំនរភ្លើងធំឯណោះ ហើយទ្រង់សម្តែងអគ្គិក្ខន្ធោបមសូត្រ ។ កាលត្រាស់វេយ្យាករណ៍នេះហើយ ភិក្ខុប្រមាណ ៦០ រូប ក្អួតឈាម ។ ភិក្ខុប្រមាណ ៦០ លាសិក្ខាជាគ្រហស្ថ ។ ភិក្ខុប្រមាណ ៦០ រូបមានចិត្តមិនប្រកាន់មាំ ក៏រួចផុតចាកអាសវៈទាំងឡាយ ។ ព្រោះបានស្តាប់វេយ្យាករណ៍នោះ នាមកាយរបស់ភិក្ខុប្រមាណ ៦០ រូប ក៏ក្តៅកាយ កាលនាមកាយក្តៅកាយ ករជកាយក៏ក្តៅឈ្លួល កាលករជកាយក្តៅឈ្លួល លោហិតដែលក្តៅ ក៏ផ្លុំគ្នាបាញ់ចេញអំពីមាត់ ។ ភិក្ខុប្រមាណ ៦០ រូបទៀត គិតថា ការប្រព្រឹត្តព្រហ្មចរិយឲ្យបរិសុទ្ធិបរិបូណ៌រហូតអស់មួយជីវិតក្នុង

ព្រះពុទ្ធសាសនា ធ្វើបានលំបាកហ្ន៎ ហើយនាំគ្នាលាសិក្ខាជាគ្រហស្ថ ។ ភិក្ខុប្រមាណ ៦០ រូប បញ្ជូនញាណឆ្ពោះកាន់ទេសនារបស់ព្រះសាស្តា ក៏សម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទា ។ បណ្តាភិក្ខុទាំងនោះ ភិក្ខុពួកណាក្អួតឈាម ភិក្ខុទាំងនោះត្រូវអាបត្តិបារាជិក ភិក្ខុពួកណាសឹកជាគ្រហស្ថ ភិក្ខុទាំងនោះ នាំគ្នាញាំញីសិក្ខាបទតូចៗ ។ ភិក្ខុពួកណាសម្រេចព្រះអរហត្ត ភិក្ខុទាំងនោះ ជាអ្នកមានសីលបរិសុទ្ធនោះឯង ។ ព្រះធម៌ទេសនារបស់ព្រះសាស្តា កើតមានផលសូម្បីដល់ភិក្ខុ ៣ ពួក ដូចពោលមកនេះ ។

សួរថា ព្រះធម៌ទេសនាកើតមានផលដល់ភិក្ខុដែលសម្រេចព្រះអរហត្តលើកទុកចុះ យ៉ាងណា ទើបកើតមានផលដល់ភិក្ខុក្រៅនេះ? ។ ឆ្លើយថា ក៏ភិក្ខុសូម្បីទាំងនោះ បើមិនបានស្តាប់ធម៌ទេសនាកណ្ឌនេះទេ ក៏ជាអ្នកប្រមាទ មិនគប្បីអាចលះឋានៈបាន តពីនោះបាបរបស់ភិក្ខុទាំងនោះកម្រើកឡើង នឹងគប្បីធ្វើលោកឲ្យលិចចុះក្នុងអបាយវិនាសបង់តែម្យ៉ាង តែស្តាប់ទេសនាកណ្ឌនេះហើយកើតសេចក្តីសង្វេគ លះបង់ឋានៈ តាំងនៅក្នុងភូមិនៃសាមណេរ បំពេញសីល ១០ ប្រកបការខ្វល់ខ្វាយក្នុងយោនិសោមនសិការ ពួកខ្លះក៏ជាព្រះសោតាបន្ន ពួកខ្លះជាព្រះសកទាគាមី ពួកខ្លះជាអនាគាមី ពួកខ្លះកើតក្នុងទេវលោក ។ ព្រះធម៌ទេសនាបានមានផល សូម្បីដល់ភិក្ខុដែលត្រូវអាបត្តិបារាជិក ដោយអាការ

យ៉ាងនេះ ។ ចំណែកភិក្ខុក្រៅពីនេះ បើមិនបានស្តាប់ព្រះធម៌ទេសនាកណ្ឌនេះទេ បើកាលកន្លងទៅៗ ក៏នឹងគប្បីត្រូវអាបត្តិសង្ឃាទិសេសខ្លះ បារាជិកខ្លះ លុះបានស្តាប់ព្រះធម៌ទេសនាកណ្ឌនេះហើយ គិតថា ព្រះពុទ្ធសាសនា ជាការជុសខាត់កិលេសពិតហ្ន៎ ពួកយើងមិនអាចនឹងបំពេញវត្តបដិបត្តិនេះ រហូតអស់ជីវិតបាន យើងនឹងលាសិក្ខា បំពេញឧបាសកធម៌ នឹងផុតចាកទុក្ខបាន ដូច្នេះហើយ ទើបនាំគ្នាសឹកទៅជាគ្រហស្ថ ។ ជនទាំងនោះ តាំងនៅក្នុងសរណៈ ៣ រក្សាសីល ៥ បំពេញឧបាសកធម៌ ពួកខ្លះជាព្រះសោតាបន្ន ពួកខ្លះជាសកទាគាមី ពួកខ្លះជាអនាគាមី ពួកខ្លះកើតក្នុងទេវលោកនោះឯង ។ ព្រះធម៌ទេសនា មានផលសម្បូរដល់ភិក្ខុទាំងនោះ ដោយអាការយ៉ាងនេះ ។ មួយទៀត ពួកទេពបានស្តាប់ព្រះធម៌ទេសនាកណ្ឌនេះហើយ បានត្រាច់ទៅប្រាប់ដល់ភិក្ខុទាំងឡាយអ្នកមិនបានស្តាប់គ្រប់រូប ។ ភិក្ខុទាំងឡាយស្តាប់ហើយគិតថា លោកដ៏ចម្រើន ការប្រព្រឹត្តព្រហ្មចរិយឲ្យបរិសុទ្ធ បរិបូររហូតអស់ជីវិតក្នុងព្រះពុទ្ធសាសនា ធ្វើបានលំបាក ។ ភិក្ខុ ១០ រូបខ្លះ ២០ រូបខ្លះ ៦០ រូបខ្លះ ១០០ រូបខ្លះ ប្រាប់លាសិក្ខាជាគ្រហស្ថភ្លាមៗ នោះឯង ។

ព្រះសាស្តា ស្តេចចារិកទៅតាមពេញព្រះហឫទ័យ ស្តេចមិនត្រឡប់ទៅព្រះជេតវ័នទេ ទើបទ្រង់ហៅភិក្ខុមក ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត

កាលត្រាច់ចារិកទៅនៅប្រឲ្យកប្រឲ្យលមកយូរ ភិក្ខុទាំងឡាយ តថាគតប្រាថ្នានឹងពួនសម្ងំកន្ទុះខែ នរណាៗ មិនត្រូវចូលទៅរកតថាគត វៀរតែភិក្ខុអ្នកនាំបិណ្ឌបាតមួយរូប ដូច្នេះ ទ្រង់សម្ងំអស់កន្ទុះខែ ស្តេចចេញចាកទីពួនសម្ងំ ព្រមដោយព្រះអានន្ទត្ថេរៈ ស្តេចចារិកត្រឡប់ទៅព្រះវិហារ ទ្រង់ឃើញភិក្ខុតិចតួចក្នុងទីដែលទ្រង់ត្រួតមើលហើយត្រួតមើលទៀត សូម្បីទ្រង់ជ្រាបហើយ ក៏ត្រាស់សួរព្រះអានន្ទត្ថេរថា អានន្ទ ក្នុងវេលាមុនៗ កាលតថាគតត្រាច់ចារិក ត្រឡប់មកកាន់ជេតវ័ន ទូទៅវិហាររុងរឿងទៅដោយសំពត់កាសាវពស្ត្រ សម្បូរណ៍ទៅដោយអ្នកស្វែងគុណ តែឥឡូវនេះ ប្រាកដជា ភិក្ខុសង្ឃមានតិចតួច និងដោយច្រើនភិក្ខុកើតរោគស្គមលឿង នេះហេតុយ៉ាងណាហ្ន៎ ។ ព្រះថេរៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុទាំងឡាយកើតសេចក្តីសង្វេគ ផ្តើមតាំងពីវេលាដែលព្រះអង្គសម្តែងព្រះធម៌ទេសនា អគ្គិក្ខន្ធោបមសូត្រ ក៏គិតថា ពួកយើងមិនអាចនឹងប្រណិបត្តិធម៌នោះ ដោយអាការទាំងពួងបាន និងការដែលភិក្ខុប្រព្រឹត្តមិនត្រឹមត្រូវ បរិភោគទេយ្យធម៌ ដែលគេឲ្យដោយសទ្ធា មិនគួរឡើយ ទើបសឹកជាគ្រហស្ថ ។

ខណៈនោះ ព្រះដ៏មានព្រះភាគទ្រង់កើតធម្មសង្វេគ ។ លំដាប់នោះ ទើបត្រាស់ចំពោះព្រះថេរៈថា កាលតថាគតសម្រាកនៅក្នុងទីពួនសម្ងំ នរណាៗ

មិនប្រាប់ឋានៈដែលគប្បីធ្វើចិត្តណាមួយ ដល់ពួកបុត្ររបស់តថាគតឡើយ ហេតុដែលគប្បីធ្វើចិត្តក្នុងសាសនានេះមានច្រើន ដូចកំពង់ជាទីចុះកាន់សាគរ ដូច្នោះហើយចុះ អានន្ទ ចូរបោសពុទ្ធាសនៈក្នុងបរិវេណគន្ធកុដិ ចូរឲ្យភិក្ខុសង្ឃប្រជុំគ្នា ។ ព្រះថេរៈបានធ្វើយ៉ាងនោះ ។ ព្រះសាស្តា ស្តេចកាន់ពុទ្ធាសនៈដ៏ប្រសើរ ត្រាស់ហៅភិក្ខុទាំងឡាយមក ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នុ៎ះជាចំណែកខាងដើមបង្អស់នៃមេត្តា មិនមែនអប្បនា មិនមែនឧបេក្ខា មានត្រឹមតែផ្សាយប្រយោជន៍ដល់សត្វទាំងឡាយប៉ុណ្ណោះ ។ ទើបទ្រង់សម្តែងអច្ឆរាសង្ឃាតសូត្រនេះ ដើម្បីជាអត្ថុប្បត្តិហេតុនេះ ។

បណ្តាបទទាំងនោះ បទថា **អច្ឆរាសង្ឃាតមត្តំ** សេចក្តីថា ត្រឹមតែការផ្ទាត់ម្រាមដៃ ។ អធិប្បាយថា ត្រឹមតែយកម្រាមដៃ ២ មកផ្ទាត់ឲ្យមានសំឡេង ។ បទថា **មេត្តចិត្តំ** បានដល់ ចិត្តដែលគិតផ្សាយប្រយោជន៍ដល់សព្វសត្វ ។

បទថា **អាសេវតិ** សួរថា រមែងសេពដូចម្តេច? ឆ្លើយថា នឹកដល់ហើយសេព ឃើញហើយសេព ពិចារណាហើយសេព ផ្គងសេចក្តីព្យាយាមហើយសេព បង្អោនចិត្តជឿហើយសេព ចូលទៅតាំងសតិហើយសេព តាំងចិត្តហើយសេព ដឹងច្បាស់ដោយបញ្ញាហើយសេព ដឹងក្រៃលែងនូវវត្ថុដែលគួរដឹងដ៏ក្រៃលែងហើយសេព កំណត់ដឹងវត្ថុដែលគួរកំណត់ដឹងហើយសេព លះវត្ថុដែល

គួរលះហើយសេព ចម្រើនវត្ថុដែលគួរចម្រើនហើយសេព ធ្វើឲ្យច្បាស់វត្ថុដែលគួរធ្វើឲ្យច្បាស់ហើយសេព ។ តែក្នុងទីនេះ គប្បីជ្រាបថា សេពដោយហេតុត្រឹមតែប្រព្រឹត្តទៅ ដោយការផ្សាយប្រយោជន៍ដ៏ធំទូលាយ ក្នុងចំណែកខាងដើមនៃមេត្តា ។

បទថា **អរិត្តជ្ឈានោ** បានដល់ អ្នកមានឈានមិនវិនាស ឬមិនលះបង់ចោលឈាន ។ បទថា **វិហរតិ** សេចក្ដីថា ប្រែប្រួល ប្រព្រឹត្តទៅ រក្សាប្រព្រឹត្តទៅឯង ឲ្យប្រព្រឹត្តទៅ ត្រាច់ទៅ នៅ ដោយហេតុនោះ លោកទើបហៅថា **វិហរតិ** ដោយបទនេះ លោកទើបពោលការនៅដោយឥរិយាបថរបស់ភិក្ខុដែលសេពមេត្តា ។

បទថា **សត្ថុសាសនករោ** បានដល់ អ្នកធ្វើតាមអនុសាសនីរបស់ព្រះសាស្តា ។ បទថា **ឱវាទបដិករោ** បានដល់ អ្នកធ្វើតាមឱវាទ ។ ក៏ក្នុងរឿងនេះការពោលតែមួយដង ឈ្មោះថា ឱវាទ ការពោលរឿយៗ ឈ្មោះថា អនុសាសនី ។ សូម្បីការពោលចំពោះមុខ ក៏ឈ្មោះថា ឱវាទ , ការបញ្ជូន (ដំណឹង) ទៅ ពោលពីតាមក្រោយ ឈ្មោះថា អនុសាសនី ។ ការពោលក្នុងកាលរឿងកើតឡើងហើយ ឈ្មោះថា ឱវាទ ។ ចំណែកការពោលក្នុងកាលរឿងកើតឡើង ឬមិនទាន់កើតឡើង ឈ្មោះថា អនុសាសនី ។ គប្បីជ្រាបសេចក្ដីប្លែកគ្នាយ៉ាងនេះ ។

តែកាលពោលអំពីបរមត្ថ ពាក្យថា ឱវាទ ឬអនុសាសនីនោះ តែមួយដូចគ្នា មានអត្ថដូចគ្នា ស្មើគ្នា ចូលគ្នាបាន កើតរួមគ្នានោះឯង ។ ក៏ក្នុងទីនេះ ពាក្យថា ភិក្ខុទាំងឡាយ បើភិក្ខុសេពមេត្តាចិត្ត សូម្បីត្រឹមតែមួយផ្ទាត់ម្រាមដៃ នេះឯង ជាពាក្យទូន្មាន និងជាឱវាទរបស់ព្រះសាស្តា គប្បីជ្រាបថា ភិក្ខុនោះ ឈ្មោះថា ជាអ្នកធ្វើតាមពាក្យទូន្មាន និងជាអ្នកទទួលឱវាទ ព្រោះបដិបត្តិពាក្យទូន្មាន និងឱវាទនោះ ។

បទថា **អមោឃំ** ប្រែថា មិនទទេ ។ បទថា **រដ្ឋបិណ្ឌំ** សេចក្តីថា បិណ្ឌបាត (អាហារ) នុ៎ះឯង លោកហៅថា រដ្ឋបិណ្ឌៈ (ដុំបាយរបស់អ្នកដែន) ព្រោះអាហារនោះ ភិក្ខុដែលលះបង់ពួកញាតិ អាស្រ័យអ្នកដែន បួសហើយ បានពីផ្ទះរបស់អ្នកដទៃ ។

បទថា **ភុញ្ជតិ** សេចក្តីថា បរិភោគ មាន ៤ យ៉ាង គឺ ថេយ្យបរិភោគ ឥណបរិភោគ ទាយជ្ជបរិភោគ សាមិបរិភោគ ។ ក្នុងបរិភោគ ៤ យ៉ាងនោះ ការបរិភោគរបស់អ្នកទ្រុស្តសីល ឈ្មោះថា ថេយ្យបរិភោគ ។ ការបរិភោគបច្ច័យដែលមិនបានពិចារណារបស់អ្នកមានសីល ឈ្មោះថា ឥណបរិភោគ ។ ការបរិភោគរបស់ព្រះសេក្ខបុគ្គល ៧ ពួក ឈ្មោះថា ទាយជ្ជបរិភោគ ។ ការបរិភោគរបស់ព្រះខីណាស្រព ឈ្មោះថា សាមិបរិភោគ ។ ក្នុង ៤ យ៉ាងនោះ

ការបរិភោគដុំបាយរបស់អ្នកព្រំដែននេះ របស់ភិក្ខុនេះ រមែងមិនទទេដោយហេតុ ២ ប្រការ ។ ភិក្ខុដែលសេពមេត្តាចិត្ត សូម្បីត្រឹមតែមួយផ្ទាត់ម្រាមដៃ ឈ្មោះថាជាម្ចាស់នៃដុំបាយរបស់អ្នកដែន បរិភោគ សូម្បីព្រោះហេតុនោះ ការបរិភោគដុំបាយរបស់អ្នកព្រំដែនរបស់ភិក្ខុនោះ ឈ្មោះថា មិនទទេ ។ ទានដែលគេឲ្យដល់ភិក្ខុដែលសេពមេត្តាសូម្បីត្រឹមតែមួយផ្ទាត់ម្រាមដៃ រមែងមានសេចក្តីសម្រេចច្រើន មានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីធំទូលាយច្រើន ព្រោះហេតុនោះ ការបរិភោគបាយរបស់អ្នកដែនរបស់ភិក្ខុនោះ មិនជាមោឃៈ មិនទទេ បទថា **កោ បន វាទោ យេ នំ ពហុលីករោន្តិ** សេចក្តីថា គួរពោលបានពិតក្នុងសេចក្តីនេះថា ភិក្ខុពួកណាសេព ចម្រើនឲ្យច្រើន ធ្វើរឿយៗនូវមេត្តាចិត្តនេះ ភិក្ខុទាំងនោះ រមែងបរិភោគដុំបាយរបស់អ្នកដែន មិនទទេ ព្រោះភិក្ខុបែបនេះ រមែងជាម្ចាស់នៃដុំបាយអ្នកដែន ជាទាយាទបរិភោគ ។

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថាសូត្រទី ៤

*ក្នុងសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៥៥] *បទថា **ភាវេតិ** បានដល់ ឲ្យកើតឡើង គឺ ឲ្យចម្រើន ។*

ចប់អដ្ឋកថា សូត្រទី ៤

# អដ្ឋកថាសូត្រទី ៥

ក្នុងសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៥៦] បទថា **មនសិករោតិ** ប្រែថា ធ្វើទុកក្នុងចិត្ត ។ ពាក្យដ៏សេសសូម្បីក្នុងសូត្រទាំងពីរនេះ គប្បីជ្រាបដោយន័យដូចពោលក្នុងសូត្រទី ៣ ។ ក៏ភិក្ខុណារមែងសេព ភិក្ខុនេះឯងឈ្មោះថា រមែងចម្រើន ភិក្ខុនេះឈ្មោះថា ធ្វើទុកក្នុងចិត្ត ។ ភិក្ខុរមែងសេពដោយចិត្តណា ឈ្មោះថា រមែងចម្រើនដោយចិត្តនោះឯង ឈ្មោះថា រមែងធ្វើទុកក្នុងចិត្តដោយចិត្តនោះ ។ ក៏ព្រះសម្មាសម្ពុទ្ធឈ្មោះថា ជាអ្នកសម្បូរណ៍ដោយលីលានៃទេសនា ព្រោះទ្រង់ត្រាស់ដឹងធម្មធាតុណា ទ្រង់អាស្រ័យលីលានៃទេសនា ១ ភាពជាធំក្នុងធម៌ ១ សេចក្ដីឆ្លាតឈ្លាសក្នុងប្រភេទនៃបដិសម្ភិទា ១ ព្រះសព្វញ្ញុតញ្ញាណដែលមិនមានអ្វីទើសទាក់ ១ របស់ព្រះអង្គ ព្រោះទ្រង់ជាអ្នកត្រាស់ដឹងធម្មធាតុនោះ ទើបទ្រង់ចែកសម្ដែងចិត្តដួងតែមួយ ដែលកើតឡើងក្នុងខណៈតែមួយប៉ុណ្ណោះ ដោយចំណែកទាំង ៣ ។

ចប់អដ្ឋកថា សូត្រទី ៥

# អដ្ឋកថាសូត្រទី ៦

ក្នុងសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៥៧] បទថា *យេ កេចិ* ជាពាក្យកំណត់មិនពិតប្រាកដ ។ បទថា *អកុសលា* ជាពាក្យកំណត់ពិតប្រាកដនៃអកុសលទាំងនោះ ។ ដោយពាក្យត្រឹមតែប៉ុណ្ណេះ អកុសលធម៌ទាំងអស់ ជាការកំណត់យកដោយមិនមានសល់ ពាក្យថា *អកុសលភាគិយា អកុសលបក្ខិកា* នេះ ជាឈ្មោះនៃអកុសលធម៌ទាំងនោះ ។ ពិតណាស់ អកុសលទាំងឡាយ ពួកខ្លះជាអកុសលចិត្ត ដោយអំណាចជាសហជាតធម៌ (កើតរួមគ្នា) ពួកខ្លះលាយគ្នាដោយអំណាចឧបនិស្សយប្បច្ច័យ និងជាបក្ខពួករបស់អកុសលធម៌ទាំងនោះ ព្រោះដូច្នោះ លោកទើបពោលថា ជាចំណែកនៃអកុសល ជាបក្ខពួកនៃអកុសល ។

បទថា *សព្វេតេ មនោបុព្វង្គមា* សេចក្តីថា ចិត្តជាប្រធាន គឺ ដល់មុននៃធម៌ទាំងនោះ ព្រោះដូច្នោះ ធម៌ទាំងនោះ ឈ្មោះថា មានចិត្តជាប្រធាន ។ ពិតហើយ ធម៌ទាំងនោះ កើតព្រមគ្នា មានវត្ថុតែមួយជាមួយគ្នា រលត់ព្រមគ្នា និងមានអារម្មណ៍តែមួយជាមួយចិត្តក៏ពិត សូម្បីដូច្នោះ ព្រោះចិត្តញុំាងធម៌ទាំងនោះ ឲ្យធ្វើ ឲ្យកើតឡើង ឲ្យតាំងឡើង ឲ្យបង្កើត ដូច្នោះ ធម៌ទាំងនោះទើបឈ្មោះថា មានចិត្តជាប្រធាន ។

បទថា **បឋមំ ឧប្បជ្ជតិ** សេចក្តីថា កាលគេពោលថា ព្រះរាជាស្តេចយាងទៅហើយ ក៏មិនមានហេតុដែលនឹងគប្បីពោលថា ទ័ពព្រះរាជាដ៏សេសចេញទៅហើយ ឬមិនទាន់ចេញទៅ គេរមែងដឹងនូវទៅថា ទ័ពព្រះរាជាចេញទៅអស់ហើយ យ៉ាងណា ចិត្តក៏ដូច្នោះដែរ រមែងមិនមានហេតុដែលនឹងគប្បីពោលថា ផ្តើមតាំងពីវេលាដែលគេពោលថា កើតឡើងហើយ ធម៌ដ៏សេសកើតរួមគ្នា លាយគ្នា ប្រកបគ្នា កើតឡើងហើយ ឬមិនទាន់កើតឡើង ធម៌ទាំងអស់នោះ រមែងប្រាកដថា កើតឡើងហើយនោះឯង អាស្រ័យអំណាចនៃប្រយោជន៍នេះ ចិត្តដែលលាយគ្នា ដែលប្រកបគ្នា ធម៌ទាំងនោះ សូម្បីនឹងកើតព្រមគ្នា និងរលត់ព្រមគ្នា លោកក៏ហៅថា កើតមុនធម៌ទាំងនោះ ។

បទថា **អន្វទេវ** ប្រែថា តាមគ្នា រួមគ្នា អធិប្បាយថា ព្រមគ្នាតែម្តង ។ តែគ្រាកាន់យកស្រមោលព្យញ្ជនៈ មិនគួរកាន់យកថា ចិត្តកើតមុន ចេតសិកកើតក្រោយ ។ ពិតណាស់ អត្ថ គឺ សេចក្តី ដែលអាស្រ័យរបស់ព្យញ្ជនៈទាំងឡាយសូម្បីក្នុងគាថាថា **មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា** ក៏ន័យនេះដូចគ្នា ។

ចប់អដ្ឋកថា សូត្រទី ៦

# អដ្ឋកថាសូត្រទី ៧

*ក្នុងសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៥៨] *កុសលធម៌សូម្បីប្រព្រឹត្តទៅក្នុងភូមិ ៤ លោកពោលថា កុសល ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យដែលពោលហើយក្នុងសូត្រទី ៦ នោះឯង ។*

ចប់អដ្ឋកថា សូត្រទី ៧

# អដ្ឋកថាសូត្រទី ៨

*ក្នុងសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៥៩] *បទថា* ***ភិក្ខវេ*** *ក្នុងពាក្យថា* ***យថយិទំ ភិក្ខវេ បមាទោ*** *នេះ ជាអាលបនៈ សេចក្តីថា* ***យថា អយំ បមាទោ*** *ដូចសេចក្តីប្រមាទនេះ ។ បទថា* ***បមាទោ*** *បានដល់ អាការ គឺ សេចក្តីប្រមាទ ។ សមពិតដូចពាក្យដែលលោកពោលទុកថា ក្នុងធម៌ទាំងនោះ សេចក្តីប្រមាទដូចម្តេច? ការបណ្តោយចិត្ត ការគាំទ្រដល់ការបណ្តោយចិត្តក្នុងកាមគុណ ៥ ដោយកាយទុច្ចរិត ដោយវចីទុច្ចរិត ឬដោយមនោទុច្ចរិត ឬការធ្វើដោយមិនគោរព ការធ្វើមិនជាប់ត ការធ្វើដែលរកប្រយោជន៍មិនបាន ការប្រព្រឹត្តធូរថយ ការលះបង់ចោលឆន្ទៈ ការលះបង់ធុរៈ ការមិនសេព ការមិនអប់រំ ការមិនធ្វើឲ្យច្រើន នូវការអប់រំកុសលធម៌ទាំងឡាយ ។ សេចក្តីប្រមាទ កិរិយាដែលប្រមាទ ភាវៈដែលប្រមាទ បែបនេះណា នេះហៅថា សេចក្តីប្រមាទ ។*

*បទថា* ***ឧប្បន្នា វា កុសលា ធម្មា បរិហាយន្តិ*** *(កុសលធម៌ដែលកើតឡើងហើយ រមែងវិនាសទៅ) នេះ លោកពោលជាប់ដោយឈាន និងវិបស្សនា ។ តែមគ្គផលដែលកើតឡើងហើយតែមួយដង មិនសាបសូន្យតទៅទៀត ។*

ចប់អដ្ឋកថា សូត្រទី ៨

# អដ្ឋកថាសូត្រទី ៩

*ក្នុងសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៦០] *សេចក្ដីមិនប្រមាទ គប្បីជ្រាបដោយពិស្ដារ ដោយផ្ទុយគ្នានឹងសេចក្ដីប្រមាទ ។*

ចប់អដ្ឋកថា សូត្រទី ៩

# អដ្ឋកថាសូត្រទី ១០

*ក្នុងសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៦១] *ភាពជាអ្នកខ្ជិលច្រអូស ឈ្មោះថា* ***កោសជ្ជៈ*** *។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។*

ចប់អដ្ឋកថា សូត្រទី ១០

## ចប់អច្ឆរាសង្ឃាតវគ្គទី ៦

រួមអដ្ឋកថាក្នុងវគ្គនេះមាន ១០ អដ្ឋកថា

# វីរិយារម្ភាទិវគ្គទី ៧

## អដ្ឋកថាសូត្រទី ១

*ក្នុងសូត្រទី ១ នៃវគ្គទី ៧ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៦២] *បទថា* ***វីរិយារម្ភោ*** *បានដល់ សេចក្ដីផ្ដើមសេចក្ដីព្យាយាម គឺសម្មប្បធាន ដែលមានកិច្ច ៤ អធិប្បាយថា ភាពជាអ្នកមានសេចក្ដីព្យាយាមដែលផ្គងទុកបរិបូណ៌ ។*

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

*ក្នុងសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៦៣] *បទថា* **មហិច្ឆតា** *បានដល់ សេចក្តីប្រាថ្នាច្រើន ដែលលោកសំដៅពោលទុកថា ក្នុងធម៌ទាំងនោះ សេចក្តីប្រាថ្នាច្រើនដូចម្តេច ? សេចក្តីប្រាថ្នាក្រៃលែងឡើងៗ ទៅ នៃភិក្ខុដែលមិនសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យដែលជាភេសជ្ជបរិក្ខារក្រៃលែងឡើងៗ ឬដោយកាមគុណ ៥ សេចក្តីប្រាថ្នា សភាពនៃសេចក្តីប្រាថ្នា សេចក្តីស្រវឹង តម្រេក តម្រេកច្រើន នៃចិត្តនេះណា នេះហៅថា* **មហិច្ឆតា** *សេចក្តីប្រាថ្នាច្រើន ។*

ចប់អដ្ឋកថា សូត្រទី ២

# អដ្ឋកថាសូត្រទី ៣

ក្នុងសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៦៤] បទថា **អប្បិច្ឆតា** បានដល់ សេចក្តីប្រាថ្នាតិច ។ បទថា **អប្បិ-ច្ឆស្ស** បានដល់ អ្នកមិនប្រាថ្នា ក៏ក្នុងទីនេះ ព្យញ្ជនៈ មើលដូចនៅមានចំណែកសល់ គឺ នៅមានសេចក្តីប្រាថ្នាខ្លះ ចំណែកអត្ថ មិនមានចំណែកនៅសល់ គឺមិនប្រាថ្នានោះឯង ។ ពិតហើយ បុគ្គលនោះ លោកហៅថា អ្នកមានសេចក្តីប្រាថ្នាតិច ព្រោះភាវៈដែលមានសេចក្តីប្រាថ្នាមានប្រមាណតិចក៏មិនមែន តែលោកហៅថា មានសេចក្តីប្រាថ្នាតិច (ប្រាថ្នាតិច) ព្រោះមិនមានសេចក្តីប្រាថ្នា គឺ ភាវៈដែលមិនមានសេចក្តីលោភ ដែលគេត្រូវសេពរឿយៗ នុ៎ះឯង ។

ម្យ៉ាងទៀត ក្នុងទីនេះ គប្បីជ្រាបសេចក្តីផ្សេងគ្នាដូច្នេះថា **អត្រិច្ឆតា** សេចក្តីប្រាថ្នាគ្មានព្រំដែន **បាបិច្ឆតា** សេចក្តីប្រាថ្នាលាមក **មហិច្ឆតា** សេចក្តីប្រាថ្នាច្រើន ។ ក្នុង ៣ យ៉ាងនោះ សេចក្តីមិនឆ្អែតក្នុងលាភរបស់ខ្លួន នៅប្រាថ្នាក្នុងលាភរបស់អ្នកដទៃ ឈ្មោះថា សេចក្តីប្រាថ្នាគ្មានព្រំដែន ។ សម្រាប់អ្នកប្រកបដោយសេចក្តីប្រាថ្នាគ្មានព្រំដែននោះ សូម្បីនំផ្អិនក្នុងភាជនៈមួយ គេដាក់ទុកក្នុងភាជនៈរបស់ខ្លួន រមែងប្រាកដដូចនំដែលឆ្អិនមិនល្អ និងដូចមានទំតិចនោះឯង គេដាក់ក្នុងភាជនៈរបស់អ្នកដទៃ ប្រាកដដូចឆ្អិនល្អ និងដូចមានច្រើន ។

សេចក្តីប្រកាសគុណដែលមិនមាន និងការមិនស្គាល់ប្រមាណក្នុងការទទួល ឈ្មោះថា សេចក្តីប្រាថ្នាលាមក ។ សេចក្តីប្រាថ្នាលាមកនោះ មកហើយក្នុងអភិធម្ម ដោយន័យមានជាដើមថា បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមិនមានសទ្ធា រមែងប្រាថ្នាថា សូមពពួកជនចូរស្គាល់យើងថា ជាអ្នកមានសទ្ធា ។ បុគ្គលដែលប្រកបដោយសេចក្តីប្រាថ្នាលាមកនោះ រមែងតាំងនៅក្នុងសេចក្តីកុហក ។ ចំណែកសេចក្តីប្រកាសគុណដែលមានហើយ និងភាពជាអ្នកមិនស្គាល់ប្រមាណក្នុងការទទួល ឈ្មោះថា ជាអ្នកមានសេចក្តីប្រាថ្នាច្រើន ។ សេចក្តីប្រាថ្នាច្រើននោះក៏មកហើយដោយន័យនេះដូចគ្នាថា បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមានសទ្ធា រមែងប្រាថ្នាថា ចូរពពួកជនស្គាល់យើងថា ជាអ្នកមានសទ្ធា ។ អ្នកខ្លះជាអ្នកមានសីល រមែងប្រាថ្នាថា សូមពពួកជនចូរស្គាល់យើងថា ជាអ្នកមានសីល ។ បុគ្គលដែលប្រកបដោយសេចក្តីប្រាថ្នាច្រើននោះ ជាអ្នកឆ្អែតបានលំបាក ។ សូម្បីមាតាអ្នកបង្កើត ក៏មិនអាចនឹងយកចិត្តគេបាន ។ ព្រោះហេតុនោះ លោកទើបពោលពាក្យនេះទុកថា ៖

អគ្គិក្ខន្ធោ សមុទ្ទោច មហិច្ឆោ ចាបិ បុគ្គលោ
សកដេន បច្ចយេ ទេន្តុ តយោបេតេ អតប្បិយា ។

គំនរភ្លើង ១ សមុទ្រ ១ អ្នកប្រាថ្នាច្រើន ១ ឲ្យបច្ច័យ

ទាំងវេទះ ទាំង ៣ ប្រភេទនោះ មិនចេះឆ្អែតឡើយ ។

ចំណែកការលាក់បាំងគុណដែលមានហើយ ភាពជាអ្នកស្គាល់ប្រមាណក្នុងការទទួល ឈ្មោះថា ភាពជាអ្នកប្រាថ្នាតិច ។ បុគ្គលដែលប្រកបដោយភាពជាអ្នកប្រាថ្នាតិចនោះ រមែងប្រាថ្នាថា សូមពពួកជនចូរស្គាល់យើងថា ជាអ្នកមានសទ្ធា ជាអ្នកមានសីល ល្អប្រសើរ ស្ងាត់ ជាពហូសូត ជាអ្នកប្រារព្ធសេចក្តីព្យាយាម ដល់ព្រមដោយសមាធិ ជាអ្នកមានបញ្ញា ជាព្រះខីណាស្រព រមែងមិនប្រាថ្នាថា សូមជនចូរដឹងយើងថា ជាព្រះខីណាស្រព ដូចព្រះមជ្ឈន្តិកត្ថេរៈ ដូច្នោះ ។

បានឮថា ព្រះថេរៈ បានជាព្រះខីណាស្រព ។ តែបាត្រ និងចីវររបស់លោក មានតម្លៃត្រឹមតែមួយបាទប៉ុណ្ណោះ ។ លោកបានជាព្រះសង្ឃត្ថេរៈ ក្នុងថ្ងៃឆ្លងវិហាររបស់ព្រះបាទធម្មាសោករាជ ។ គ្រានោះ មនុស្សទាំងឡាយឃើញថា លោកជាអ្នកក្រខ្វក់ណាស់ ទើបពោលថា លោកម្ចាស់ សូមលោកម្ចាស់ចូរនៅខាងក្រោមមួយភ្លែតចុះ ។ ព្រះថេរៈគិតថា កាលព្រះខីណាស្រពដូចយើងមិនធ្វើការសង្គ្រោះព្រះរាជា អ្នកដទៃណាហ្ន៎ នឹងធ្វើបាន ដូច្នេះ ហើយទើបមុជចុះក្នុងផែនដី ហើយផុសឡើង ទទួលដុំបាយដែលគេតម្កល់ទុកដើម្បីព្រះសង្ឃត្ថេរៈបានល្មម ។ លោកជាព្រះខីណាស្រព រមែងមិនប្រាថ្នាថា សូមអ្នកចូរស្គាល់

យើងថាជាព្រះទីណាស្រេព ដោយប្រការយ៉ាងនេះ ។

ក៏ឯភិក្ខុដែលប្រាថ្នាតិច យ៉ាងនេះ រមែងធ្វើលាភដែលមិនទាន់កើត ឲ្យកើតឡើង ឬរមែងធ្វើលាភដែលកើតឡើងហើយឲ្យកាន់តែចម្រើន រមែងធ្វើចិត្តរបស់ទាយកឲ្យត្រេកអរ ។ ភិក្ខុនោះ រមែងកាន់យកតែបន្តិច ព្រោះខ្លួនជាអ្នកប្រាថ្នាតិច ដោយប្រការណាៗ មនុស្សទាំងឡាយជ្រះថ្លាក្នុងវត្តរបស់លោកដោយប្រការនោះ រមែងថ្វាយច្រើន ។

សេចក្ដីប្រាថ្នាតិចសូម្បីដទៃទៀត មាន ៤ ប្រការ គឺ ប្រាថ្នាតិចក្នុងបច្ច័យ ១ ប្រាថ្នាតិចក្នុងធុតង្គ ១ ប្រាថ្នាតិចក្នុងបរិយត្តិ ១ ប្រាថ្នាតិចក្នុងអធិគម ១ បណ្ដាសេចក្ដីប្រាថ្នាតិច ៤ យ៉ាងនោះ សេចក្ដីប្រាថ្នាតិចក្នុងបច្ច័យ ៤ ឈ្មោះថា ប្រាថ្នាតិចក្នុងបច្ច័យ ។ ភិក្ខុនោះ រមែងដឹងកម្លាំងរបស់ទាយក រមែងដឹងកម្លាំងរបស់ទេយ្យធម៌ រមែងដឹងកម្លាំងរបស់ខ្លួន បើទេយ្យធម៌មានច្រើន ទាយកប្រាថ្នានឹងថ្វាយតិច រមែងទទួលយកតែតិច ដោយអំណាចទាយក , ទេយ្យធម៌មានតិច ទាយកប្រាថ្នានឹងថ្វាយច្រើន រមែងទទួលយកតែតិច ដោយអំណាចទេយ្យធម៌ , សូម្បីទេយ្យធម៌មានច្រើន ទាំងទាយកក៏ប្រាថ្នានឹងថ្វាយច្រើន រមែងស្គាល់កម្លាំងរបស់ខ្លួន ហើយទទួលតែល្មមប្រមាណ ។ ភិក្ខុដែលមិនបំណាងនឹងឲ្យអ្នកដទៃដឹងការសមាទានធុតង្គ គប្បីជ្រាបរឿងទាំងនេះ ជាឧទា-

ហារណ៍ ។

បានឮមកថា ព្រះមហាកុមារកស្សបត្ថេរៈ ដែលកាន់សោសានិកង្គធុតង្គ នៅក្នុងព្រៃជាទីចោលសាកសពមករហូតដល់អស់ ៦០ ឆ្នាំ ។ ភិក្ខុដទៃសូម្បីតែមួយរូបក៏មិនដឹង ដោយហេតុនោះឯង លោកទើបពោលថា

យើងនៅក្នុងព្រៃជាទីចោលសាកសពមករហូតដល់អស់ ៦០ ឆ្នាំ
ភិក្ខុដែលជាសម្លាញ់ ក៏មិនដឹងយើង ឱ យើងជាកំពូលរបស់អ្នក
សមាទានការនៅព្រៃជាទីចោលសាកសពជាវត្ត ។

ព្រះថេរៈពីររូប បងប្អូនគ្នានៅក្នុងចេតិយបព៌ត ។ ប្អូនប្រុសកាន់យកកំណាត់អំពៅដែលឧបដ្ឋាកបញ្ជូនទៅថ្វាយ ទៅកាន់សម្នាក់របស់បងប្រុស ពោលថា លោកម្ចាស់និមន្តឆាន់ចុះ ។ វេលាដែលនិយាយ ជាវេលាដែលព្រះថេរៈធ្វើភត្តកិច្ចស្រេចហើយខ្ពុរមាត់ ។ ព្រះថេរៈពោលថា កុំឡើយលោក ។ ប្អូនប្រុសពោលថា លោកម្ចាស់សមាទានឯកាសនិកង្គធុតង្គឬ ។ ព្រះថេរៈពោលថា យកមកចុះលោក កំណាត់អំពៅ សូម្បីសមាទានឯកាសនិកង្គធុតង្គអស់ ៥០ ឆ្នាំ ក៏នៅបិទបាំងធុតង្គទុក ធ្វើការឆាន់ហើយ ខ្ពុរមាត់ អធិដ្ឋានធុតង្គថ្មីតទៅ ។ ក៏ភិក្ខុណា ដូចជាព្រះសាកេតតិស្សត្ថេរៈ មិនបំណងនឹងឲ្យអ្នកដទៃដឹងថា ខ្លួនជាពហុស្សូត ភិក្ខុនោះ ឈ្មោះថា ជាអ្នកប្រាថ្នាតិចក្នុងបរិយត្តិ ។

បានឮថា ព្រះថេរៈគិតថា វេលាមិនមាន ទើបមិនធ្វើឱកាសក្នុងឧទ្ទេស (រៀន) និងបរិបុច្ឆា (សាកសួរ) ត្រូវក្រើនរំឭកថា លោកម្ចាស់ កាលណាលោកនឹងបានមរណខណៈ (វេលាស្លាប់) ទើបលះបង់ពួក ទៅកាន់កណិការវាលិកសមុទ្ទវិហារ ។ ក្នុងទីនោះ លោកមានឧបការៈដល់ព្រះថេរៈ ភិក្ខុនវកៈ និងភិក្ខុមជ្ឈិមៈ រហូតខាងក្នុងវស្សា ក្នុងបវារណា ក្នុងថ្ងៃឧបោសថ ។ ឲ្យអ្នកជនបទក្ខាក់ផ្អើលដោយធម្មិកថា ហើយក៏ទៅ ។

ចំណែកភិក្ខុណាជាព្រះអរិយៈថ្នាក់ណាមួយ មានព្រះសោតាបន្នជាដើម មិនបំណាងឲ្យអ្នកដទៃដឹងថា ខ្លួនជាព្រះសោតាបន្នជាដើម ភិក្ខុនេះ ឈ្មោះថាអ្នកមានសេចក្តីប្រាថ្នាតិចក្នុងអធិគម ដូចកុលបុត្រ ៣ នាក់ និងដូចជាងធ្នាំងឈ្មោះឃដិការៈ ។ ក៏ក្នុងអត្ថនេះ សូម្បីបុថុជ្ជនដែលសិក្សាប្រកបដោយសេចក្តីមិនលោភ មានកម្លាំងខ្លាំងក្លា បានអាសេវនៈហើយ ក៏គប្បីជ្រាបថា ជាអ្នកប្រាថ្នាតិច ។

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថាសូត្រទី ៤

*ក្នុងសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៦៥] *បទថា **អសន្តុដ្ឋិតា** បានដល់ សេចក្តីលោភ ពោលគឺ សេចក្តីមិនសន្តោស ដែលកើតដល់បុគ្គលដែលសេពគប់រក ចូលទៅអង្គុយជិតបុគ្គលដែលមិនសន្តោស ។*

ចប់អដ្ឋកថា សូត្រទី ៤

# អដ្ឋកថាសូត្រទី ៥

ក្នុងសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៦៦] បទថា **សន្តុដ្ឋិតា** បានដល់ សេចក្តីសន្តោស ពោលគឺ សេចក្តីមិនលោភ ដែលកើតដល់បុគ្គលដែលសេពគប់រក ចូលទៅអង្គុយជិតបុគ្គលដែលសន្តោស ។

បទថា **សន្តុដ្ឋស្ស** បានដល់ អ្នកប្រកបដោយសេចក្តីសន្តោសក្នុងបច្ច័យតាមមានតាមបាន សេចក្តីសន្តោសនោះ មាន ១២ យ៉ាង គឺ សេចក្តីសន្តោសក្នុងចីវរ ៣ យ៉ាង គឺ យថាលាភសន្តោស ១ យថាពលសន្តោស ១ យថាសារុប្បសន្តោស ១ ។ ក្នុងបិណ្ឌបាតជាដើមក៏ដូចគ្នា ។ សន្តោសនោះ មានការពណ៌នាតាមប្រភេទដូចតទៅនេះ ៖

ភិក្ខុក្នុងព្រះសាសនានេះ បានចីវរល្អ ឬមិនល្អក៏ដោយ លោកញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរនុ៎ះឯង មិនប្រាថ្នាចីវរដទៃ សូម្បីបានក៏មិនទទួល នេះឈ្មោះថា **យថាលាភសន្តោស** ក្នុងចីវររបស់ភិក្ខុនោះ ។

ចំណែកភិក្ខុមួយរូបទៀត ជាអ្នកមានកម្លាំងទុព្វលតាមប្រក្រតី ឬត្រូវអាពាធ និងជរាគ្របសង្កត់ ដណ្តប់ចីវរធ្ងន់ រមែងលំបាក លោកដូរចីវរនោះនឹងភិក្ខុដែលស្រឡាញ់គ្នា នឹងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរស្រាល ក៏ជា

អ្នកសន្តោស ។ នេះឈ្មោះថា **យថាពលសន្តោស** ក្នុងចីវររបស់ភិក្ខុនោះ ។

ភិក្ខុមួយរូបទៀត ជាអ្នកបានបច្ច័យដែលប្រណីត បានចីវរផ្ទាំងសំពត់ដែលនាំមកពីក្រុងសោមារជាដើម ណាមួយ ដែលមានតម្លៃ ក៏ឬថា បានចីវរជាច្រើន ឲ្យទៅដោយគិតថា ចីវរនេះ សមគួរដល់ព្រះថេរៈអ្នកបួសយូរ នេះសមគួរដល់ភិក្ខុអ្នកជាពហុស្សូត នេះសមគួរដល់ភិក្ខុដែលមានជម្ងឺ នេះសមគួរដល់ភិក្ខុអ្នកមានលាភតិច ហើយទើបជ្រើសរើសយកចីវរចាស់របស់ភិក្ខុទាំងនោះ ឬសំពត់ប្រឡាក់ពីគំនរសម្រាមជាដើម (ឬសំពត់ធ្លាក់តាមរានផ្សារ) ធ្វើជាសង្ឃាដិដោយសំពត់ទាំងនោះ ហើយស្លៀកបណ្តប់ ក៏ជាអ្នកសន្តោសនោះឯងនេះឈ្មោះថា **យថាសារុប្បសន្តោស** របស់ភិក្ខុនោះ ។

មួយទៀត ភិក្ខុក្នុងសាសនានេះ បានបិណ្ឌបាតដែលសៅហ្មង ឬប្រណីត លោករមែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយបិណ្ឌបាតនោះឯង មិនប្រាថ្នាបិណ្ឌបាតដទៃ ពេលបានក៏មិនទទួល នេះឈ្មោះថា **យថាលាភសន្តោស** របស់ភិក្ខុនោះ ។ មួយទៀត ភិក្ខុណាបានបិណ្ឌបាតដែលមិនត្រូវចិត្តជាប្រក្រតីចំពោះខ្លួន ឬមិនត្រូវចិត្តដល់ជម្ងឺ បរិភោគហើយមិនជាសុខ លោកឲ្យបិណ្ឌបាតនោះដល់ភិក្ខុដែលពេញចិត្ត ហើយឆាន់ភោជនដែលជាសប្បាយពីដៃរបស់ភិក្ខុនោះ ធ្វើសមណធម៌ ក៏ជាអ្នកសន្តោស នេះឈ្មោះថា **យថាពលសន្តោស** ក្នុងបិណ្ឌបាត

របស់ភិក្ខុនោះ ។ ភិក្ខុមួយរូបទៀត បានបិណ្ឌបាតប្រណីតដ៏ច្រើន លោកថ្វាយបិណ្ឌបាតនោះ ដល់ព្រះថេរៈអ្នកបួសយូរ អ្នកជាពហុស្សូត អ្នកមានលាភតិច និងភិក្ខុឈឺ ដូចចីវរ សូម្បីឆាន់អាហារពីសម្នាក់របស់ភិក្ខុទាំងនោះ ឬអាហារដែលលាយគ្នា ព្រោះបិណ្ឌបាតបានមក ក៏ឈ្មោះថា ជាអ្នកសន្តោសពិត ។ នេះឈ្មោះថា **យថាសារុប្បសន្តោស** ក្នុងបិណ្ឌបាតរបស់ភិក្ខុនោះ ។

មួយទៀត ភិក្ខុក្នុងព្រះសាសនានេះ បានសេនាសនៈដែលជាទីពេញចិត្ត ឬមិនពេញចិត្ត ។ លោកមិនញុំាងសេចក្តីរីករាយឲ្យកើតឡើង មិនញុំាងសេចក្តីកន្ទាល់ឲ្យកើតឡើង រមែងត្រេកអរដោយសេនាសនៈតាមដែលបានប៉ុណ្ណោះ ដោយទីបំផុតសូម្បីកម្រាលធ្វើដោយស្មៅ ។ នេះឈ្មោះថា **យថាលាភសន្តោស** ក្នុងសេនាសនៈរបស់ភិក្ខុនោះ ។ មួយទៀត ភិក្ខុបានសេនាសនៈមិនពេញចិត្តដល់ខ្លួន ឬមិនត្រូវដល់ជម្ងឺរបស់ខ្លួន ដែលលោកអាស្រ័យនៅ មិនមានសេចក្តីសុខ លោកឲ្យសេនាសនៈនោះដល់ភិក្ខុដែលពេញចិត្ត ហើយនៅក្នុងសេនាសនៈដែលសប្បាយ ក៏ជាអ្នកសន្តោសពិត នេះឈ្មោះថា **យថាពលសន្តោស** ក្នុងសេនាសនៈរបស់ភិក្ខុនោះ ។ ភិក្ខុមួយរូបទៀត មានបុណ្យច្រើន បានសេនាសនៈដែលប្រណីតជាច្រើន មានល្អាង មណ្ឌប និងផ្ទះកំពូលជាដើម លោកថ្វាយសេនាសនៈសូម្បីទាំងនោះដល់ព្រះថេរៈអ្នកបួសយូរ អ្នកពហុស្សូត អ្នកមានលាភ

តិច និងភិក្ខុឈឺ ដូចជាចីវរ ហើយនៅក្នុងទីណាមួយ ក៏ជាអ្នកសន្តោសពិត នេះឈ្មោះថា **យថាសារុប្បសន្តោស** ក្នុងសេនាសនៈរបស់ភិក្ខុនោះ ។ សូម្បីភិក្ខុណា ពិចារណាថា ធម្មតាថា សេនាសនៈដែលប្រណីត ជាទីតាំងនៃសេចក្តីប្រមាទ ថីនមិទ្ធៈ រមែងគ្របសង្កត់ដល់អ្នកអង្គុយក្នុងទីនោះ ដល់អ្នកដេកលក់ហើយភ្ញាក់ឡើង វិតក្កៈដ៏លាមករមែងប្រាកដ លោកមិនទទួលសេនាសនៈដូចនោះ សូម្បីបានមកដល់ហើយ លោកបដិសេធសេនាសនៈនោះ ហើយនៅក្នុងកណ្តាលវាល មានគល់ឈើជាដើម ក៏ជាអ្នកសន្តោសពិត នេះឈ្មោះថា **យថាសារុប្បសន្តោស** ក្នុងសេនាសនៈរបស់ភិក្ខុនោះ ។

មួយទៀត ភិក្ខុក្នុងព្រះសាសនានេះ បានភេសជ្ជៈដែលសៅហ្មង ឬប្រណីត លោករមែងត្រេកអរក្នុងភេសជ្ជៈដែលខ្លួនបាននោះឯង មិនប្រាថ្នាភេសជ្ជៈដទៃ សូម្បីបានក៏មិនទទួល នេះឈ្មោះថា **យថាលាភសន្តោស** ក្នុងគិលានប្បច្ច័យរបស់ភិក្ខុនោះ ។

មួយទៀត ភិក្ខុណាត្រូវការប្រេង ត្រឡប់ជាបានទឹកអំពៅ សូម្បីលោកថ្វាយទឹកអំពៅនោះដល់ភិក្ខុដែលពេញចិត្ត កាន់យកប្រេងពីដៃរបស់ភិក្ខុដែលពេញចិត្តនោះ ឬស្វែងរកប្រេងដទៃធ្វើភេសជ្ជៈ ក៏ជាអ្នកសន្តោសពិត នេះឈ្មោះថា **យថាពលសន្តោស** ក្នុងគិលានប្បច្ច័យរបស់ភិក្ខុនោះ ។ ភិក្ខុមួយរូបទៀត

មានបុណ្យច្រើន បានភេសជ្ជៈដែលប្រណីត មានប្រេង និងទឹកអំពៅជាដើម ដ៏ច្រើន លោកថ្វាយភេសជ្ជៈនោះដល់ព្រះថេរៈអ្នកបួសយូរ អ្នកជាពហុស្សូត អ្នកមានលាភតិច និងអ្នកឈឺ ដូចចីវរ សូម្បីនឹងញុាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយភេសជ្ជៈយ៉ាងណាមួយ ដែលគេនាំមកហើយដើម្បីភិក្ខុទាំងនោះ ក៏ជាអ្នកសន្តោសពិត ។ មួយទៀត ភិក្ខុណា កាលគេដាក់សម៉ត្រាំទឹកមូត្រក្នុងភាជនៈមួយ ដាក់វត្ថុមានរសឆ្ងាញ់ ៤ ក្នុងភាជនៈមួយ ហើយនិយាយថា លោកម្ចាស់ លោកត្រូវការវត្ថុណា ចូរកាន់យកវត្ថុនោះចុះ បើរោគរបស់លោកស្ងប់ទៅ សូម្បីដោយភេសជ្ជៈទាំងពីរប្រភេទណាមួយនោះ ដូច្នោះ ឈ្មោះថា សម៉ត្រាំទឹកមូត្រ បណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាដើមសរសើរហើយ ទើបបដិសេធរបស់មានរសឆ្ងាញ់ ៤ យ៉ាង សូម្បីធ្វើភេសជ្ជៈដោយសម៉ត្រាំទឹកមូត្រ ក៏ជាអ្នកសន្តោសយ៉ាងក្រៃលែង នេះឈ្មោះថា **យថាសារុប្បសន្តោស** ក្នុងគិលានប្បច្ច័យរបស់ភិក្ខុនោះ ។ ក៏បណ្តាសន្តោស ៣ យ៉ាង ក្នុងបច្ច័យមួយៗ នេះ **យថាសារុប្បសន្តោស** ប្រសើរជាង ។

ចប់អដ្ឋកថា សូត្រទី ៥

# អដ្ឋកថាសូត្រទី ៦-៧

*ក្នុងសូត្រទី ៦-៧ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៦៧-៦៨] *អយោនិសោមនសិការ និងយោនិសោមនសិការ មានលក្ខណៈដូចពោលហើយក្នុងកាលមុន និងពាក្យដ៏សេសក្នុងសូត្រនេះ មានសេចក្ដីងាយទាំងនោះ ដូច្នេះឯង ។*

ចប់អដ្ឋកថា សូត្រទី ៦-៧

# អដ្ឋកថាសូត្រទី ៨

*ក្នុងសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៦៩] *បទថា* ***អសម្បជញ្ញំ*** *បានដល់ សេចក្តីមិនដឹងខ្លួន ។ ពាក្យថា* ***អសម្បជញ្ញំ*** *នេះ ជាឈ្មោះរបស់មោហៈ បទថា* ***អសម្បជានស្ស*** *បានដល់ អ្នកមិនដឹងខ្លួន គឺ អ្នកវង្វេង ។*

ចប់អដ្ឋកថា សូត្រទី ៨

# អដ្ឋកថាសូត្រទី ៩

*ក្នុងសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៧០] *បទថា* **សម្បជញ្ញំ** *បានដល់ សេចក្តីដឹងខ្លួន ។ បទថា* **សម្បជញ្ញំ** *នេះ ជាឈ្មោះនៃបញ្ញា ។ បទថា* **សម្បជានស្ស** *បានដល់ អ្នកមានសេចក្តីដឹងខ្លួនហើយ ។*

ចប់អដ្ឋកថា សូត្រទី ៩

# អដ្ឋកថាសូត្រទី ១០

ក្នុងសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៧១] បទថា **បាបមិត្តតា** សេចក្តីថា មិត្តអាក្រក់ គឺ លាមក មានដល់បុគ្គលណា បុគ្គលនោះឈ្មោះថា មានមិត្តអាក្រក់ ។ ការមានមិត្តអាក្រក់ឈ្មោះថា **បាបមិត្តតា** ភាពជាអ្នកមានមិត្តអាក្រក់ ។ ពាក្យថា **បាបមិត្តតា** នេះជាឈ្មោះរបស់ខន្ធ ៤ ដែលប្រព្រឹត្តទៅដោយអាការនោះ ។ សមពិតដូចពាក្យដែលលោកពោលទុកថា ក្នុងបណ្តាធម៌ទាំងនោះ ភាពជាអ្នកមានមិត្តអាក្រក់ដូចម្តេច? បុគ្គលសេពគប់បុគ្គលណា ជាអ្នកមិនមានសទ្ធា ជាអ្នកទ្រុស្តសីល ជាអ្នកមានសុតៈតិច ជាអ្នកកំណាញ់ ជាអ្នកគ្មានបញ្ញា ការសេព ការអាស្រ័យ ការគប់ ការគប់រក ការសេពគប់ ភាពភក្តី សេចក្តីស្រឡាញ់បុគ្គលទាំងនោះ ការមានបុគ្គលទាំងនោះជាសម្លាញ់ នេះហៅថា ភាពជាអ្នកមានមិត្តអាក្រក់ ។

ចប់អដ្ឋកថា សូត្រទី ១០

## ចប់វីរិយារម្ភាទិវគ្គទី ៧

រួមអដ្ឋកថាក្នុងវគ្គនេះមាន ១០ អដ្ឋកថា

# កល្យាណមិត្តតាទិវគ្គទី ៨

## អដ្ឋកថាសូត្រទី ១

*សូត្រទី ១ នៃវគ្គទី ៨ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៧២] បទថា **កល្យាណមិត្តតា** សេចក្ដីថា ឈ្មោះថា កល្យាណមិត្ត ព្រោះមានមិត្តល្អ ភាវៈនៃភាពជាអ្នកមានកល្យាណមិត្តនោះ ឈ្មោះថា **កល្យាណមិត្តតា** ភាពជាអ្នកមានមិត្តល្អ ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យផ្ទុយគ្នានឹងពាក្យដូចពោលនេះឯង ។*

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

*ក្នុងសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៧៣] *បទថា* ***អនុយោគោ*** *បានដល់ ការប្រកប ការប្រកបទូទៅ ។ បទថា* ***អននុយោគោ*** *បានដល់ ការមិនប្រកប ការមិនប្រកបទូទៅ ។ បទថា* ***អនុយោគា*** *ប្រែថា ព្រោះការប្រកបរឿយៗ ។ បទថា* ***អននុយោគា*** *ប្រែថា ព្រោះមិនប្រកបរឿយៗ ។ បទថា* ***កុសលានំ ធម្មានំ*** *បានដល់ កុសលធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។*

ចប់អដ្ឋកថា សូត្រទី ២

# អដ្ឋកថាសូត្រទី ៣

[៧៤] *ក្នុងសូត្រនេះ មានសេចក្តីងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថាសូត្រទី ៤

ក្នុងសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៧៥] បទថា **ពោជ្ឈង្គា** បានដល់ ធម៌ ៧ ប្រការ ដែលជាអង្គគុណរបស់សត្វអ្នកត្រាស់ដឹង ។ម្យ៉ាងទៀត ឈ្មោះថា ពោជ្ឈង្គៈ ព្រោះជាអង្គនៃធម្មសាមគ្គី គ្រឿងត្រាស់ដឹងដែលជាហេតុចេញចាកវដ្តៈ ឬធ្វើឲ្យច្បាស់សច្ចៈ ៤ របស់សត្វអ្នកត្រាស់ដឹងនោះ ។ បទថា **ពោជ្ឈង្គា** សេចក្តីថា ឈ្មោះថា ពោជ្ឈង្គៈ ដោយអត្ថថាអ្វី? ដែលឈ្មោះថា ពោជ្ឈង្គៈ ព្រោះជាអង្គនៃធម្មសាមគ្គីគ្រឿងត្រាស់ដឹង ឈ្មោះថា ពោជ្ឈង្គៈ ព្រោះអង្គនៃធម្មសាមគ្គីគ្រឿងត្រាស់ដឹងតាម ។ ឈ្មោះថា ពោជ្ឈង្គៈ ព្រោះជាអង្គនៃធម៌សាមគ្គីគ្រឿងត្រាស់ដឹងចំពោះ ។ ឈ្មោះថា ពោជ្ឈង្គៈ ព្រោះជាអង្គនៃធម៌សាមគ្គីគ្រឿងត្រាស់ដឹងព្រម ។ ឈ្មោះថា ពោជ្ឈង្គៈ ព្រោះប្រព្រឹត្តទៅព្រមដោយបញ្ញាជាគ្រឿងត្រាស់ដឹង ។ ក៏បទ (ថាពោជ្ឈង្គៈនេះ) នេះ លោកចែកទុកហើយដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា សូត្រទី ៤

# អដ្ឋកថាសូត្រទី ៥

*ក្នុងសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៧៦] *ដោយបទនេះថា* ***ភាវនាបារិបូរឹ គច្ឆន្តិ*** *រមែងដល់សេចក្តីចម្រើនពេញលេញ ដូច្នេះ លោកពោលដល់ភូមិព្រមដោយកិច្ច តាមសេចក្តីពិតនៃពោជ្ឈង្គៈ ៗ ក៏ភូមិនេះ មាន ៤ យ៉ាង គឺ វិបស្សនា ១ ឈានដែលជាបាទនៃវិបស្សនា ១ មគ្គ ១ ផល ១ ក្នុង ៤ យ៉ាងនោះ ក្នុងវេលាដែលកើតក្នុងវិបស្សនា ពោជ្ឈង្គៈ ចាត់ជាកាមាវចរៈ ៗ ក្នុងវេលាដែលកើតក្នុងឈានដែលជាបាទរបស់វិបស្សនា ពោជ្ឈង្គៈ ជារូបាវចរៈ និងអរូបាវចរៈ ៗ ក្នុងវេលាដែលកើតក្នុងមគ្គ និងផល ពោជ្ឈង្គៈ ជាលោកុត្តរៈ ៗ ដូច្នោះ ក្នុងសូត្រនេះលោកទើបពោលពោជ្ឈង្គៈថា ប្រព្រឹត្តទៅក្នុងភូមិទាំង ៤ ៗ*

ចប់អដ្ឋកថា សូត្រទី ៥

# អដ្ឋកថាសូត្រទី ៦

[៧៧] ក្នុងសូត្រទី ៦ មានសេចក្ដីសង្ខេបហេតុដែលកើតរឿង ក៏ក្នុងហេតុដែលកើតរឿង លោកតាំងរឿងទុកដូចតទៅនេះ ៖

ភិក្ខុច្រើនរូប អង្គុយប្រជុំគ្នាក្នុងធម្មសភា លោកទាំងនោះកើតសន្ទនាប្រារព្ធពន្ធុលមល្លសេនាបតីឡើងក្នុងអន្តរកថា ដូច្នេះថា អាវុសោ ត្រកូលឈ្មោះឯណោះ កាលមុនមានពួកញាតិច្រើន មានបក្ខពួកច្រើន ឥឡូវនេះ មានញាតិតិច មានបក្ខពួកតិច ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបវារៈចិត្តរបស់ភិក្ខុទាំងនោះ ទ្រង់ជ្រាបថា កាលតថាគតទៅ (ទីនោះ) នឹងមានទេសនាកណ្ឌធំ ទើបស្ដេចចេញចាកព្រះគន្ធកុដិ ប្រថាប់លើពុទ្ធាសនៈដ៏ប្រសើរ ដែលគេតាក់តែងទុកក្នុងធម្មសភា ហើយត្រាស់ថា ភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វី ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ រឿងគាមនិគមជាដើមយ៉ាងដទៃរមែងមិនមាន តែត្រកូលឈ្មោះឯណោះ កាលមុនមានញាតិច្រើន មានបក្ខពួកស្មោះស្មគ្រ័ច្រើន ឥឡូវនេះ មានញាតិតិច មានបក្ខពួកស្មោះស្មគ្រ័តិច ពួកខ្ញុំព្រះអង្គ អង្គុយប្រជុំសន្ទនាគ្នា ដូច្នេះ ។ ព្រះសាស្ដាទ្រង់ប្រារព្ធសូត្រនេះថា ម្នាលភិក្ខុទាំងឡាយ សេចក្ដីវិនាសនេះ មានប្រមាណតិច ដូច្នេះ ក្នុងកាលកើតរឿងនេះ ។

បណ្ដាបទទាំងនោះ បទថា **អប្បមត្តិកា** បានដល់ តិច គឺ មានប្រមាណតិច ។ ពិតណាស់ ដោយសេចក្ដីវិនាសនេះ លោកពោលពាក្យមានជាដើមថា សេចក្ដីវិនាសចាកស្វគ៌ ឬចាកមគ្គ រមែងមិនមាន នោះត្រឹមតែសេចក្ដីវិនាសក្នុងបច្ចុប្បន្នប៉ុណ្ណោះ ។ បទថា **ឯតំ បដិកិដ្ឋំ** សេចក្ដីថា នេះជារបស់ដ៏អាក្រក់ នេះជារបស់ថោកទាប ។ បទថា **យទិទំ បញ្ញាបរិហានិ** សេចក្ដីថា សេចក្ដីវិនាសនៃកម្មស្សកតាបញ្ញា ឈានបញ្ញា វិបស្សនាបញ្ញា មគ្គបញ្ញា និងផលបញ្ញា ក្នុងសាសនារបស់តថាគត ជាសេចក្ដីវិនាសដ៏អាក្រក់ ជាសេចក្ដីវិនាសដ៏ទាបថោក ជាសេចក្ដីវិនាសដែលគួរលះបង់ចោល ។

ចប់អដ្ឋកថា សូត្រទី ៦

# អដ្ឋកថាសូត្រទី ៧

[៧៨] ក្នុងសូត្រទី ៧ លោកពោលទុកហើយ ក្នុងហេតុដែលកើតរឿងដូចគ្នា ។

បានឮថា បណ្ដាភិក្ខុសង្ឃដែលអង្គុយប្រជុំគ្នាក្នុងធម្មសភា ភិក្ខុខ្លះពោលយ៉ាងនេះថា ត្រកូលឈ្មោះឯណោះ កាលមុនមានញាតិតិច បក្ខពួកតិច ឥឡូវនេះ ត្រកូលនោះមានញាតិច្រើន មានបក្ខពួកច្រើន សំដៅយកត្រកូលនោះ ទើបពោលយ៉ាងនេះឯង ។ គឺ សំដៅដល់នាងវិសាខាឧបាសិកា និងស្ដេចលិច្ឆវីក្នុងក្រុងវេសាលី ។ ព្រះសាស្ដា ទ្រង់ជ្រាបវារៈចិត្តរបស់ភិក្ខុទាំងនោះ ទើបស្ដេចមកដោយន័យមុននុ៎ះឯង ប្រថាប់លើធម្មាសនៈ ត្រាស់សួរថា ភិក្ខុទាំងឡាយ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី? ភិក្ខុទាំងនោះក្រាបទូលឲ្យទ្រង់ជ្រាបតាមសេចក្ដីពិតហើយ ។ ព្រះសាស្ដាទ្រង់ផ្ដើមព្រះសូត្រនេះ ដើម្បីហេតុកើតនៃរឿងនេះ ។

បណ្ដាទាំងនោះ បទថា **អប្បមត្តិកា** សេចក្ដីថា ឈ្មោះថា តិច ព្រោះមិនមានអ្នកអាស្រ័យសម្បត្តិនោះហើយ ចូលដល់សួគ៌ ឬមគ្គបាន ។ បទថា **យទិទំ បញ្ញាវុឌ្ឍិ** បានដល់ សេចក្ដីចម្រើននៃកម្មស្សកតាបញ្ញាជាដើម ។ បទថា **តស្មា** សេចក្ដីថា ព្រោះឈ្មោះថា សេចក្ដីចម្រើននៃញាតិ មានត្រឹមតែបច្ចុប្បន្ន

ជារឿងបន្តិចបន្តួច មិនអាចឲ្យដល់សួគ៌ ឬមគ្គបាន ។

បទថា **បញ្ញាវុឌ្ឍិយា** បានដល់ ដោយសេចក្ដីចម្រើននៃបញ្ញា មានកម្មស្សកតាបញ្ញាជាដើម ។

ចប់អដ្ឋកថា សូត្រទី ៧

# អដ្ឋកថាសូត្រទី ៨

[៧៩] *សូត្រទី ៨ លោកពោលទុកក្នុងហេតុដែលកើតរឿងដូចគ្នា ។*

*បានឮថា ភិក្ខុច្រើនរូប អង្គុយប្រជុំគ្នាក្នុងធម្មសភា ប្រារព្ធបុត្ររបស់សេដ្ឋីអ្នកមានទ្រព្យច្រើន ពោលថា ត្រកូលឈ្មោះឯណោះ កាលមុនមានភោគៈច្រើន មានប្រាក់ និងមាសច្រើន ឥឡូវនេះត្រកូលនោះត្រឡប់ជាមានភោគៈតិច ។ ព្រះសាស្ដា ស្ដេចមកដោយន័យមុននុ៎ះឯង ទ្រង់ស្ដាប់ពាក្យរបស់ភិក្ខុទាំងនោះហើយ ទើបទ្រង់ផ្ដើមព្រះសូត្រនេះ ។*

ចប់អដ្ឋកថា សូត្រទី ៨

# អដ្ឋកថាសូត្រទី ៩

[៨០] សូម្បីក្នុងសូត្រទី ៩ លោកក៏ពោលទុក ក្នុងហេតុដែលកើតរឿងដូចគ្នា ។ បានឮថា ពួកភិក្ខុអង្គុយប្រជុំគ្នាក្នុងធម្មសភា ប្រារព្ធកាកវលិយសេដ្ឋីនិងបុណ្ណសេដ្ឋី ពោលថា ត្រកូលឈ្មោះឯណោះ កាលមុនមានភោគៈតិច ឥឡូវនេះ ត្រកូលទាំងនោះមានភោគៈច្រើន ។ ព្រះសាស្ដាស្ដេចមកដោយន័យមុននុ៎ះឯង ទ្រង់ស្ដាប់ពាក្យរបស់ភិក្ខុទាំងនោះ ទើបផ្ដើមព្រះសូត្រនេះ ។ ពាក្យដ៏សេសក្នុងសូត្រទាំង ២ នេះ គប្បីជ្រាបដោយន័យដូចពោលក្នុងខាងក្រោយនុ៎ះឯង ។

ចប់អដ្ឋកថា សូត្រទី ៩

# អដ្ឋកថាសូត្រទី ១០

[៨១] *សូម្បីសូត្រទី ១០ លោកពោលទុកហើយក្នុងហេតុដែលកើតរឿងដូចគ្នា ។ បានឮថា ភិក្ខុទាំងឡាយក្នុងធម្មសភា ប្រារព្ធព្រះបាទកោសលមហារាជ ពោលថា ត្រកូលឈ្មោះឯណោះ កាលមុនមានយសច្រើន មានបរិវារច្រើន ឥឡូវនេះមានយសតិច មានបរិវារតិច ព្រះសាស្ដាស្ដេចមកដោយន័យមុននុ៎ះឯង ទ្រង់ស្ដាប់ពាក្យរបស់ភិក្ខុទាំងនោះ ទើបផ្ដើមទេសនានេះ ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យដូចពោលហើយនុ៎ះឯង ។*

ចប់អដ្ឋកថា សូត្រទី ១០

## ចប់កល្យាណមិត្តតាទិវគ្គទី ៨

រួមអដ្ឋកថាក្នុងវគ្គនេះមាន ០៩ អដ្ឋកថា

# បមាទាទិវគ្គទី ៩

## អដ្ឋកថាសូត្រទី ១

[៨២] *វគ្គទី ៩ សូត្រទី ១ លោកពោលទុកហើយ ក្នុងហេតុកើតរឿងនុ៎ះឯង ។ បានឮថា ភិក្ខុច្រើនរូប អង្គុយប្រជុំគ្នាក្នុងធម្មសភា ប្រារព្ធដល់កុម-កឃោសក ពោលថា ត្រកូលឈ្មោះឯណោះ កាលមុនមានយសតិច មានបរិវារតិច ឥឡូវនេះមានយសច្រើន មានបរិវារច្រើន ។ ព្រះសាស្ដាស្ដេចមកដោយន័យមុននុ៎ះឯង ទ្រង់បានស្ដាប់ពាក្យរបស់ភិក្ខុទាំងនោះ ទើបផ្ដើមព្រះសូត្រនេះ សេចក្ដីនៃព្រះសូត្រនោះ គប្បីជ្រាបដោយន័យដូចពោលហើយខាងដើមនុ៎ះឯង ។*

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

ក្នុងសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៨៣] បទថា *មហតោ អនត្ថាយ* បានដល់ ដើម្បីឲ្យខូចប្រយោជន៍ដល់សេចក្ដីវិនាសយ៉ាងធំ ពាក្យដ៏សេសក្នុងសូត្រនេះ ងាយទាំងអស់ ។

ចប់អដ្ឋកថា សូត្រទី ២

## ចប់បមាទាទិវគ្គទី ៩

រួមអដ្ឋកថាក្នុងវគ្គនេះមាន ០២ អដ្ឋកថា

# អដ្ឋកថាវគ្គទី ១០

[៩៩-១៣៤] *វគ្គទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*បទថា* ***អជ្ឈត្តិកំ*** *បានដល់ វត្ថុដែលប្រព្រឹត្តទៅខាងក្នុង ដោយអំណាចកើតចំពោះខាងក្នុងខ្លួន ។ បទថា* ***អង្គំ*** *ប្រែថា ហេតុ ។ បទថា* ***ឥតិ ករិត្វា*** *ប្រែថា ធ្វើយ៉ាងនេះ ។ ព្រះដ៏មានព្រះភាគត្រាស់អធិប្បាយទុកថា ម្នាលភិក្ខុទាំងឡាយ តថាគតធ្វើវត្ថុដែលប្រព្រឹត្តទៅដល់ខ្លួន គឺ ចំពោះខ្លួន ដែលតាំងឡើងក្នុងសន្តានរបស់ខ្លួនថា ជាហេតុហើយ រមែងមិនឃើញហេតុដទៃត្រឹមតែម្យ៉ាង ដូច្នេះ ។*

*បទថា* ***ពាហិរំ*** *បានដល់ វត្ថុដែលជាចំណែកខាងក្រៅពីសន្តានខ្លួន ។ បទថា* ***ធម្មស្ស*** *បានដល់ ព្រះសទ្ធម្ម អធិប្បាយថា ព្រះសាសនា ។ បទថា* ***សម្មោសាយ*** *បានដល់ ដើម្បីសេចក្តីវិនាស ។ បទថា* ***អន្តរធានាយ*** *បានដល់ ដើម្បីសេចក្តីមិនប្រាកដ ។ បទថា* ***ឋិតិយា*** *បានដល់ ដើម្បីការតាំងនៅអស់កាលយូរ ។ បទថា* ***អសម្មោសាយ អនន្តរធានាយ*** *គប្បីជ្រាបដោយន័យផ្ទុយគ្នាពីការដែលពោលហើយនុ៎ះឯង ។ ពាក្យដ៏សេសក្នុងសូត្រនេះ មានន័យដូចពោលហើយក្នុងធម៌ដែលមាន ៤ ប្រការនុ៎ះឯង ។*

ក្នុងពាក្យថា **អធម្មំ ធម្មោតិ ទីបេន្តិ** ជាដើម ខាងមុខអំពីនេះ គប្បីជ្រាបសេចក្តីដោយបរិយាយនៃព្រះសូត្រមុន ។ កុសលកម្មបថ ១០ ឈ្មោះថា **ធម៌** ។ អកុសលកម្មបថ ១០ ឈ្មោះថា **អធម៌** ។ មួយទៀត ពោធិបក្ខិយធម៌ ៣៧ ប្រការ គឺ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ៥ ពលៈ ៥ ពោជ្ឈង្គៈ ៧ អរិយមគ្គមានអង្គ ៨ ឈ្មោះថា **ធម៌** ។ ធម៌នេះ គឺ សតិប្បដ្ឋាន ៣ សម្មប្បធាន ៣ ឥទ្ធិបាទ ៣ ឥន្ទ្រិយ ៦ ពលៈ ៦ ពោជ្ឈង្គៈ ៨ មគ្គមានអង្គ ៩ និងឧបាទាន ៤ និវរណៈ ៥ អនុស័យ ៧ មិច្ឆត្តៈ ៨ ឈ្មោះថា **អធម៌** ។ បណ្តាបទទាំងនោះ បទថា **អធម្មោ** សេចក្តីថា ភិក្ខុទាំងឡាយ កាលកាន់យកចំណែកនៃអធម៌យ៉ាងណាមួយហើយ សម្តែងថា យើងនឹងធ្វើអធម៌នេះ ឲ្យជាធម៌ កុសលចិត្តរបស់អាចារ្យពួកយើងនឹងជានិយ្យានិកធម៌ ជាគ្រឿងនាំចេញនិងពួកយើងនឹងប្រាកដក្នុងលោកដោយអាការយ៉ាងនេះ ទើបពោលអធម៌នេះថានេះជាធម៌ ឈ្មោះថា សម្តែងធម៌ ថាជាធម៌ ។ កាលកាន់យកចំណែកមួយក្នុងចំណែកនៃធម៌ ដូច្នោះដូចគ្នា ហើយសម្តែងថា នេះជាអធម៌ ឈ្មោះថា សម្តែងធម៌ ថាជាអធម៌ ។ តែកាលពោលអំពីបរិយាយនៃព្រះវិន័យ កម្មដែលចោទ ដោយរឿងដែលពិត ឲ្យរឭកបានហើយ ពិន័យអាបត្តិតាមបដិញ្ញា ឈ្មោះថា ធម៌ ។ កម្មដែលមិនបានចោទ មិនឲ្យរឭកបាន ដោយរឿងដែលមិនពិត ហើយ

ពិន័យអាបត្តិ ដោយមិនបានបេ្តជ្ញាទុក ឈ្មោះថា អធម៌ ។

បើពោលដោយបរិយាយនៃព្រះសូត្រ ធម៌នេះគឺ ការកម្ចាត់រាគៈ ការកម្ចាត់ទោសៈ ការកម្ចាត់មោហៈ សំវរៈ ការលះ ការពិចារណា ឈ្មោះថា **វិន័យ** ការមិនកម្ចាត់រាគៈជាដើម ការមិនសង្រួម ការមិនលះ និងការមិនពិចារណា ឈ្មោះថា **អវិន័យ** ។ កាលពោលដោយបរិយាយព្រះវិន័យ ធម៌នេះគឺ វត្ថុសម្បត្តិ ញត្តិសម្បត្តិ អនុសាវនាសម្បត្តិ សីមាសម្បត្តិ បរិសសម្បត្តិ ឈ្មោះថា វិន័យ ។ វត្ថុវិបត្តិ បរិសវិបត្តិ នេះឈ្មោះថា **អវិន័យ** ។

កាលពោលដោយបរិយាយនៃព្រះសូត្រ ពាក្យនេះថា សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ អរិយមគ្គមានអង្គ ៨ ព្រះតថាគតទ្រង់កាសិតទុក ត្រាស់ទុក ។ ពាក្យនេះថា សតិប្បដ្ឋាន ៣ សម្មប្បធាន ៣ ឥទ្ធិបាទ ៣ ឥន្ទ្រិយ ៦ ពលៈ ៦ សម្ពោជ្ឈង្គៈ ៨ មគ្គមានអង្គ ៩ ព្រះតថាគតទ្រង់មិនបានកាសិតទុក មិនបានត្រាស់ទុក ។ កាលពោលដោយបរិយាយព្រះវិន័យ ពាក្យនេះថា បារាជិក ៤ សង្ឃាទិសេស ១៣ អនិយតៈ ២ និស្សគ្គិយបាចិត្តិយៈ ៣០ ព្រះតថាគតទ្រង់កាសិតទុក ត្រាស់ទុក ។ ពាក្យនេះថា បារាជិក ៣ សង្ឃាទិសេស ១៤ អនិយតៈ ៣ និស្សគ្គិយបាចិត្តិយៈ ៣១ ព្រះតថាគតទ្រង់មិនបានកាសិតទុក មិនបានត្រាស់ទុក ។

កាលពោលដោយបរិយាយនៃព្រះសូត្រ កិច្ចនេះគឺ ការចូលផលសមាបត្តិ ការចូលមហាករុណាសមាបត្តិ ទ្រង់ពិចារណាមើលលោកដោយពុទ្ធចក្ខុ ទ្រង់សម្តែងព្រះសូត្រជាប់ដោយហេតុដែលកើតរឿងឡើង ការត្រាស់ជាតកករាល់ថ្ងៃៗ ដែលព្រះតថាគតធ្លាប់ប្រព្រឹត្តមក ។ កិច្ចនេះគឺ ការមិនចូលផលសមាបត្តិ ។ល។ ការមិនត្រាស់ជាតកករាល់ថ្ងៃៗ ដែលព្រះតថាគតមិនធ្លាប់ប្រព្រឹត្តមក ។ កាលពោលដោយបរិយាយនៃព្រះវិន័យ កិច្ចនេះគឺ កាលត្រូវនិមន្ត នៅចាំវស្សាហើយ ត្រូវប្រាប់លាទើបចៀសទៅកាន់ទីចារិក បវារណាហើយទើបចៀសទៅកាន់ទីចារិក ការធ្វើបដិសណ្ឋារៈមុនជាមួយភិក្ខុដែលជាអាគន្តុកៈ ព្រះតថាគតធ្លាប់ប្រព្រឹត្តមក ។ ការមិនធ្វើកិច្ច ដែលព្រះតថាគតធ្លាប់ប្រព្រឹត្តមកនោះឯង ឈ្មោះថា មិនធ្លាប់ប្រព្រឹត្តហើយ ។

កាលពោលដោយបរិយាយនៃព្រះសូត្រ សតិប្បដ្ឋាន ៤ អរិយមគ្គមានអង្គ៨ នេះឈ្មោះថា ព្រះតថាគតទ្រង់បញ្ញត្តិ ។ សតិប្បដ្ឋាន ៣ មគ្គមានអង្គ ៩ នេះឈ្មោះថា តថាគតទ្រង់មិនបញ្ញត្តិទុក ។ កាលពោលដោយបរិយាយនៃព្រះវិន័យ បារាជិក ៤ និស្សគ្គិយបាចិត្តិយ ៣០ នេះឈ្មោះថា តថាគតទ្រង់បញ្ញត្តិ ។ បារាជិក ៣ និស្សគ្គិយបាចិត្តិយ ៣១ នេះឈ្មោះថា តថាគតទ្រង់មិនបញ្ញត្តិទុក ។

ក៏ក្នុងពាក្យដែលត្រាស់ទុកក្នុងទីបំផុតនៃសូត្រទាំងពួងថា ក៏ភិក្ខុទាំងនោះ រមែងញុាំងធម៌នេះឲ្យអន្តរធានទៅ ឈ្មោះថា អន្តរធាន មាន ៥ យ៉ាង គឺ អធិគមអន្តរធាន (អន្តរធាននៃការសម្រេច) ១ បដិបត្តិអន្តរធាន (អន្តរធាននៃការបដិបត្តិ) ១ បរិយត្តិអន្តរធាន (អន្តរធាននៃបរិយត្តិ) ១ លិង្គអន្តរធាន (អន្តរធាននៃភេទ) ១ ធាតុអន្តរធាន (អន្តរធាននៃធាតុ) ១ ។ ក្នុង ៥ យ៉ាងនោះ មគ្គ ៤ ផល ៤ បដិសម្ភិទា ៤ វិជ្ជា ៣ អភិញ្ញា ៦ ឈ្មោះថា **អធិគម** ។ អធិគមនោះ កាលសាបសូន្យ រមែងសាបសូន្យទៅតាំងពីបដិសម្ភិទា ។ ពិតណាស់ រាប់តាំងពីព្រះពុទ្ធបរិនិព្វានបាន ១.០០០ ឆ្នាំប៉ុណ្ណោះ ភិក្ខុមិនអាចនឹងឲ្យបដិសម្ភិទាកើតបាន តអំពីនោះក៏អភិញ្ញា ៦ ។ បន្ទាប់មក កាលមិនអាចឲ្យអភិញ្ញាកើតបាន រមែងធ្វើវិជ្ជា ៣ ឲ្យកើត ។ លុះកាលកន្លងទៅៗ កាលមិនអាចនឹងធ្វើវិជ្ជា ៣ ឲ្យកើត ក៏ជាព្រះអរហន្តសុក្ខវិបស្សកៈ ដោយឧបាយនេះឯង ក៏ជាព្រះអនាគាមី ព្រះសកទាគាមី និងព្រះសោតាបន្ន ។ កាលលោកទាំងនោះនៅមានជីវិត អធិគម ឈ្មោះថា មិនទាន់សាបសូន្យ អធិគម ឈ្មោះថា រមែងសាបសូន្យទៅ ព្រោះការអស់ទៅនៃជីវិតរបស់ព្រះអរិយបុគ្គលដែលសោតាបន្នថ្នាក់ទាបបំផុត ដូចពោលនេះ ឈ្មោះថា **អន្តរធាននៃអធិគម** ។

ភិក្ខុមិនអាចនឹងឲ្យឈាន វិបស្សនា មគ្គ និងផលកើតបាន រក្សាត្រឹម

តែចតុប្បារិសុទ្ធិសីល ឈ្មោះថា **អន្តរធាននៃវត្តបដិបត្តិ** ។ កាលកន្លងទៅៗ ភិក្ខុទាំងឡាយគិតថា យើងនឹងរក្សាសីលឲ្យបរិបូណ៌ និងនឹងប្រកបសេចក្តីព្យាយាមរឿយៗ តែយើងក៏មិនអាចនឹងធ្វើឲ្យជាក់ច្បាស់មគ្គ ឬផលបាន ឥឡូវនេះ មិនមានការត្រាស់ដឹងអរិយធម៌ ទើបស្រងាកចិត្ត ច្រើនទៅដោយសេចក្តីខ្ជិលច្រអូស មិនជាស់តឿនគ្នានិងគ្នា មិនរង្កៀស (ក្នុងការធ្វើអាក្រក់) តាំងពីនោះក៏នាំគ្នាញាំញីសិក្ខាបទតូចៗ ។ កាលកន្លងទៅៗ ត្រូវអាបត្តិបាចិត្តិយ ថុល្លច្ច័យ តពីនោះត្រូវគរុកាបត្តិ ។ ត្រឹមតែអាបត្តិបារាជិកប៉ុណ្ណោះមុតមាំ ។ កាលភិក្ខុ ១០០ រូបខ្លះ ១.០០០ រូបខ្លះ រក្សាអាបត្តិបារាជិក ញាំងជីវិតឲ្យរស់នៅ ការបដិបត្តិ ឈ្មោះថា មិនទាន់អន្តរធាន នឹងអន្តរធានទៅ ព្រោះភិក្ខុចុងក្រោយទម្លាយសីល ឬអស់ជីវិត ដូចពោលមកនេះ ឈ្មោះថា **អន្តរាយនៃការបដិបត្តិ** ។

បទថា **បរិយត្តិ** បានដល់ បាលីព្រមទាំងអដ្ឋកថាក្នុងពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បាលីនោះតាំងនៅត្រឹមណា បរិយត្តិ ក៏ឈ្មោះថា នៅបរិបូណ៌ត្រឹមនោះ ។ កាលកន្លងទៅៗ ព្រះរាជា និងព្រះយុវរាជក្នុងកលយុគ មិនតាំងនៅក្នុងធម៌ កាលព្រះរាជា និងយុវរាជទាំងនោះ មិនតាំងនៅក្នុងធម៌ រាជអាមាត្យជាដើម ក៏មិនតាំងនៅក្នុងធម៌ តពីនោះអ្នកដែន និងអ្នកជនបទ ក៏មិនតាំងនៅ

ក្នុងធម៌ ភ្លៀងរមែងមិនធ្លាក់ត្រូវតាមរដូវកាល ព្រោះមនុស្សទាំងនោះមិនតាំងនៅក្នុងធម៌ ។ ស្រូវអង្ករមែងមិនបរិបូណ៌ កាលស្រូវអង្ករទាំងនោះមិនបរិបូណ៌ ទាយកអ្នកថ្វាយបច្ច័យ ក៏មិនអាចនឹងថ្វាយបច្ច័យដល់ភិក្ខុសង្ឃបាន ភិក្ខុសង្ឃទាំងឡាយលំបាកដោយបច្ច័យ ក៏មិនអាចសង្គ្រោះពួកអន្តេវាសិក ។ កាលវេលាកន្លងទៅៗ បរិយត្តិ រមែងសាបសូន្យ ភិក្ខុទាំងឡាយមិនអាចនឹងទ្រទ្រង់ចាំអត្ថទុកបាន ទ្រទ្រង់ចាំទុកបានតែព្រះបាលីប៉ុណ្ណោះ ។ តពីនោះ កាលកន្លងទៅ ក៏មិនអាចនឹងទ្រទ្រង់បាលីទុកបានទាំងអស់ ។ អភិធម្មបិដក រមែងសាបសូន្យមុន ។ កាលសាបសូន្យ ក៏សាបសូន្យតាំងពីចុងមក ។ ពិតណាស់ បដ្ឋានមហាបករណ៍ រមែងសាបសូន្យមុនគេឯង កាលបដ្ឋានមហាបករណ៍សាបសូន្យ យមកៈ កថាវត្ថុ បុគ្គលបញ្ញត្តិ ធាតុកថា វិភង្គ ធម្មសង្គណី ក៏សាបសូន្យ កាលអភិធម្មបិដកសាបសូន្យទៅយ៉ាងនេះ សុត្តន្តបិដក ក៏សាបសូន្យតាំងពីចុងមក អង្គុត្តរនិកាយសាបសូន្យមុន កាលអង្គុត្តរនិកាយសាបសូន្យ ឯកាទសកនិបាតសាបសូន្យមុន តពីនោះទសកនិបាត ។បេ។ តពីនោះឯកនិបាត កាលអង្គុត្តរនិកាយសាបសូន្យទៅយ៉ាងនេះ សំយុត្តនិកាយ ក៏សាបសូន្យតាំងពីចុងមក ។ ពិតណាស់ មហាវគ្គសាបសូន្យមុន តពីនោះសឡាយតនវគ្គ ខន្ធកវគ្គ និទានវគ្គ សគាថវគ្គ កាលសំយុត្តនិកាយសាបសូន្យទៅយ៉ាងនេះ

មជ្ឈិមនិកាយសាបសូន្យតាំងពីចុងមក ពិតហើយ ឧបរិបណ្ណាសកៈសាបសូន្យមុន តពីនោះ មជ្ឈិមបណ្ណាសកៈ តពីនោះ មូលបណ្ណាសកៈ ។ កាលមជ្ឈិមនិកាយសាបសូន្យយ៉ាងនេះ ទីឃនិកាយ សាបសូន្យតាំងពីចុងមក ។ ពិតហើយ បាដិកវគ្គសាបសូន្យមុន អំពីនោះមហាវគ្គ អំពីនោះសីលក្ខន្ធវគ្គ កាលទីឃនិកាយសាបសូន្យយ៉ាងនេះ ព្រះសុត្តន្តបិដក ឈ្មោះថា រមែងសាបសូន្យ ។ ទ្រង់ទុកចំពោះជាតក និងវិន័យបិដកប៉ុណ្ណោះ ។ ភិក្ខុដែលជាលជ្ជីប៉ុណ្ណោះ ទ្រទ្រង់ព្រះវិន័យបិដក ។ ចំណែកភិក្ខុដែលប្រាថ្នាក្នុងលាភ គិតថា សូម្បីកាលពោលតែព្រះសូត្រ ក៏មិនមានអ្នកនឹងកំណត់បាន ទើបទ្រទ្រង់ទុកចំពោះជាតកប៉ុណ្ណោះ ។ កាលកន្លងទៅៗ សូម្បីតែជាតកក៏មិនអាចនឹងទ្រទ្រង់ទុកបាន ។ គ្រានោះ បណ្ដាជាតកទាំងនោះ វេស្សន្តរជាតកសាបសូន្យមុន តអំពីនោះ បុណ្ណកជាតក មហានារទជាតកសាបសូន្យទៅដោយលំដាប់ ក្នុងទីបំផុតនៃបណ្ណកជាតក ក៏សាបសូន្យ ។ កាលជាតកសាបសូន្យទៅយ៉ាងនេះ ភិក្ខុទាំងឡាយរមែងទ្រង់ទុកចំពោះព្រះវិន័យបិដកប៉ុណ្ណោះ ។

កាលកន្លងទៅៗ ក៏មិនអាចនឹងទ្រទ្រង់ទុកបាន សូម្បីតែព្រះវិន័យបិដក តពីនោះក៏សាបសូន្យតាំងពីចុងមក ។ គម្ពីរបរិវារសាបសូន្យមុន តអំពីនោះ ខន្ធកៈ ភិក្ខុនីវិភង្គក៏សាបសូន្យ តអំពីនោះ ក៏ទ្រទ្រង់ទុកត្រឹមតែឧបោសថខន្ធកៈ

ប៉ុណ្ណោះតាមលំដាប់ ។ សូម្បីក្នុងកាលនោះ បរិយត្តិ ក៏ឈ្មោះថា មិនទាន់សាបសូន្យ ក៏គាថា ៤ បាទ នៅប្រព្រឹត្តក្នុងពួកមនុស្សត្រឹមណា បរិយត្តិក៏ឈ្មោះថា មិនទាន់អន្តរធានត្រឹមនោះ ។ ក្នុងកាលណា ព្រះរាជាអ្នកមានសទ្ធាជ្រះថ្លា ទ្រង់ឲ្យដាក់ថង់ទ្រព្យមួយសែនចុះក្នុងប្រអប់មាស តាំងលើ.កដំរីហើយឲ្យវាយស្គរស្រែកប្រកាសទូទៅក្នុងព្រះនគរថា ជនអ្នកដឹងគាថា ៤ បទ ដែលព្រះពុទ្ធត្រាស់ហើយ ចូរកាន់យកទ្រព្យមួយសែននេះទៅ ក៏មិនបានទូវជនដែលទទួលយកទៅ សូម្បីដោយការឲ្យដើរវាយស្គរប្រកាសតែមួយដង រមែងមានអ្នកបានខ្លះ មិនបានខ្លះ ទើបឲ្យដើរវាយស្គរប្រកាសដល់ ៣ ដង ក៏មិនបានអ្នកដែលនឹងទទួលយកទៅ ។ រាជបុរសទាំងឡាយ ទើបឲ្យនាំថង់ទ្រព្យ ១០០.០០០ នោះ ត្រឡប់កាន់រាជត្រកូលតាមដើម ។ ក្នុងកាលនោះ បរិយត្តិឈ្មោះថា រមែងសាបសូន្យទៅ ដូចពោលមកនេះ ឈ្មោះថា **ការអន្តរធាននៃព្រះបរិយត្តិ** ។

កាលកន្លងទៅៗ ការទទួលចីវរ ការទទួលបាត្រ ការបន្ទាបខ្លួន ការថែរក្សា ការក្រឡេកមើល មិនជាទីនាំមកនូវសេចក្តីជ្រះថ្លា ។ ភិក្ខុទាំងឡាយដាក់បាត្រទុកចុងដៃកាន់ត្រាច់ទៅ ដូចសមណនិគ្រន្ថកាន់បាត្រឃ្លោកត្រាច់ទៅ ។ សូម្បីដោយអាការត្រឹមតែប៉ុណ្ណោះ ភេទ ក៏ឈ្មោះថា នៅមិនទាន់អន្តរធាន ។

កាលកន្លងទៅៗ យកបាត្រចុះពីចុងដៃ យួរទៅដោយដៃ ឬដោយសន្ទែកត្រាច់ទៅ សូម្បីចីវរក៏មិនធ្វើការជ្រលក់ឲ្យត្រឹមត្រូវ ធ្វើឲ្យមានពណ៌ក្រហមប្រើ ។ កាលកន្លងទៅ ការជ្រលក់ចីវរក្តី ការកាត់ជាយសំពត់ក្តី ការចោះក្ទុមក្តី រមែងមិនមាន ធ្វើត្រឹមតែគ្រឿងសម្គាល់ហើយប្រើប្រាស់ តមកត្រឡប់លើកក្ទុម មិនធ្វើគ្រឿងសម្គាល់ តមកមិនធ្វើទាំង ២ យ៉ាង កាត់ជាយសំពត់ ត្រាច់ទៅដូចពួកបរិព្វាជក កាលកន្លងទៅៗ ក៏គិតថា ពួកយើងនឹងត្រូវការអ្វី ដោយការធ្វើដូច្នេះ ទើបចងសំពត់កាសាយៈចំរៀកតូចៗ ត្រង់ដៃ ឬត្រង់ក ឬមូរសៀតទុកត្រង់សក់ ធ្វើការចិញ្ចឹមករិយា ក្តួរស្រែព្រោះចិញ្ចឹមជីវិត ។ ក្នុងកាលនោះ បុគ្គលកាលឲ្យទក្ខិណា រមែងឲ្យដល់ជនទាំងនោះ ឧទ្ទិសសង្ឃ ព្រះដ៏មានព្រះ-ភាគ ទ្រង់សំដៅយកប្រការនេះ ទើបត្រាស់ថា ម្នាលអានន្ទ ក្នុងអនាគតកាលនឹងមានគោត្រភូសង្ឃ អ្នកមានសំពត់កាសាយៈរុំក ជាអ្នកទ្រុស្តសីល ជាអ្នកមានធម៌ដ៏លាមក ជនទាំងឡាយឲ្យទាន ក្នុងអ្នកដែលទ្រុស្តសីល អ្នកមានធម៌ដ៏លាមកទាំងនោះ ឧទ្ទិសចំពោះសង្ឃ អានន្ទ ក្នុងកាលនោះ តថាគតពោលថា ទក្ខិណាសម្រេចហើយក្នុងសង្ឃ មានផលរាប់មិនបាន ប្រមាណមិនអស់ ។ តពីនោះ កាលកន្លងទៅៗ ជនទាំងនោះគិតថា នេះឈ្មោះថា ជាធម៌គ្រឿងយឺតយូរ ពួកយើងនឹងត្រូវការអ្វី ដោយធម៌គ្រឿងយឺតយូរនេះ ទើបចោលកំណាត់

សំពត់ទៅក្នុងព្រៃ ។ ក្នុងកាលនោះ ភេទ ឈ្មោះថា វិនាសទៅ ។ បានឮថា ការជណ្តប់សំពត់សត្រាច់ទៅ ជាចារីតរបស់បុគ្គលទាំងនោះ មកពីសម័យព្រះកស្សបទសពល ដូចពោលមកនេះ ឈ្មោះថា **ការអន្តរធានទៅនៃភេទ** ។

ឈ្មោះថា **អន្តរធានទៅនៃធាតុ** គប្បីជ្រាបយ៉ាងនេះ ៖

បរិនិព្វាន មាន ៣ គឺ កិលេសបរិនិព្វាន (ការបរិនិព្វាននៃកិលេស) , ខន្ធបរិនិព្វាន (ការបរិនិព្វាននៃខន្ធ) , ធាតុបរិនិព្វាន (ការបរិនិព្វាននៃធាតុ) ។ បណ្តាបរិនិព្វាន ៣ យ៉ាងនោះ **កិលេសបរិនិព្វាន** មានត្រង់ពោធិបល្ល័ង្ក ។ **ខន្ធបរិនិព្វាន** មាននៅត្រង់ក្រុងកុសិនារា , **ធាតុបរិនិព្វាន** នឹងមានក្នុងអនាគត នឹងមានយ៉ាងណា? គឺ គ្រានោះ ធាតុទាំងឡាយ ដែលមិនបានទទួលសក្ការៈ និងការគោរពក្នុងទីនោះៗ ក៏ទៅកាន់ទីដែលមានសក្ការៈ និងការគោរព ព្រោះកម្លាំងអធិដ្ឋានរបស់ព្រះពុទ្ធទាំងឡាយ ។ កាលកន្លងទៅៗ សក្ការៈ និងការគោរព ក៏មិនមានក្នុងទីទាំងពួង ។ វេលាព្រះសាសនាថយចុះ ព្រះធាតុទាំងឡាយក្នុងតម្ពបណ្ណិទ្វីបនេះ នឹងប្រជុំគ្នា ហើយទៅកាន់មហាចេតិយ ចេញពីមហាចេតិយ ទៅកាន់នាគចេតិយ តអំពីនោះនឹងទៅកាន់ពោធិបល្ល័ង្ក ។ ព្រះធាតុទាំងឡាយ ចាកពីនាគពិភពខ្លះ ចាកពីទេវលោកខ្លះ ចាកពីព្រហ្មលោកខ្លះ នឹងទៅកាន់ពោធិបល្ល័ង្កតែមួយកន្លែង ។ ព្រះធាតុសូម្បីប្រមាណប៉ុនគ្រាប់ស្ពៃ

នឹងមិនវិនាសទៅក្នុងរវាង ។ ព្រះធាតុទាំងអស់ នឹងប្រជុំគ្នាត្រង់មហាពោធិ-មណ្ឌលស្ថានហើយ រួមជាព្រះពុទ្ធរូប សម្តែងពុទ្ធសរីរៈ ប្រថាប់គង់ព្រះភ្លែនត្រង់ពោធិមណ្ឌលស្ថាន ។ មហាបុរិសលក្ខណៈ ៣២ អនុព្យញ្ជនៈ ៨០ ព្រះរស្មីប្រមាណមួយព្យាម ទាំងអស់គ្រប់បរិបូណ៌នោះឯង ។ តពីនោះនឹងធ្វើបាដិហារ្យសម្តែងដូចក្នុងថ្ងៃសម្តែងយមកបាដិហារ្យ ។ ក្នុងកាលនោះ ឈ្មោះថា សត្វជាមនុស្ស មិនមានទៅក្នុងទីនោះ ។ ក៏ទេវតាក្នុងម៉ឺនចក្រវាឡ ប្រជុំគ្នាទាំងអស់នាំគ្នាយំរៀបរាប់ថា ថ្ងៃនេះព្រះទសពលនឹងបរិនិព្វាន ផ្តើមតាំងពីឥឡូវនេះទៅនឹងមានតែសេចក្តីងងឹត ។ លំដាប់នោះ តេជោធាតុឆេះសន្ធោសន្ធៅឡើង ចាកព្រះសរីរធាតុ ធ្វើឲ្យព្រះសរីរៈនោះ ដល់សេចក្តីរកបញ្ញត្តិមិនបាន ។ អណ្តាតភ្លើងដែលឆេះចាកពីព្រះសរីរធាតុ ផ្សាយឡើងដរាបដល់ព្រហ្មលោក កាលព្រះធាតុសូម្បីត្រឹមប៉ុនគ្រាប់ស្ពៃនៅមាន ក៏នឹងមានអណ្តាតភ្លើងនៅឆេះ កាលព្រះធាតុអស់ទៅ អណ្តាតភ្លើងក៏នឹងអស់ទៅ ។ ព្រះធាតុទាំងឡាយ សម្តែងអានុភាពធំយ៉ាងនេះហើយ ក៏អន្តរធានទៅ ។ ក្នុងកាលនោះ ពួកទេវតាធ្វើសក្ការៈដោយរបស់ក្រអូប ផ្កាឈើ និងតន្ត្រីទិព្វជាដើម ដូចក្នុងថ្ងៃដែលព្រះពុទ្ធទាំងឡាយបរិនិព្វាន ធ្វើប្រទក្សិណ ៣ ជុំ ថ្វាយបង្គំហើយ ក្រាបទូលថា បពិត្រព្រះដ៏-មានព្រះភាគ ពួកខ្ញុំព្រះអង្គ នឹងបានឃើញព្រះពុទ្ធ ដែលស្តេចឧប្បត្តិឡើងក្នុង

អនាគត ដូច្នេះ ហើយក៏ត្រឡប់ទៅទីលំនៅរៀងៗ ខ្លួន នេះឈ្មោះថា **អន្តរធាននៃព្រះធាតុ ។**

ការអន្តរធាននៃបរិយត្តិនុ៎ះឯង ជាមូលនៃអន្តរធាន ៥ យ៉ាងនេះ ពិតហើយ កាលព្រះបរិយត្តិអន្តរធានទៅ បដិបត្តិក៏រមែងអន្តរធាន កាលបរិយត្តិគង់នៅ បដិបត្តិក៏គង់នៅ ។ ព្រោះហេតុនោះឯង ក្នុងគ្រាមានភ័យធំ គ្រាដែលព្រះបាទចណ្ឌាលតិស្សៈក្នុងទ្វីបនេះ ស្តេចសក្កៈទេវរាជ និម្មិតក្បូនធំ ហើយប្រាប់ដល់ភិក្ខុទាំងឡាយថា ភ័យធំនឹងមាន ភ្លៀងនឹងមិនធ្លាក់ត្រូវតាមរដូវកាល ភិក្ខុទាំងឡាយនាំគ្នាលំបាកដោយបច្ច័យ ៤ នឹងមិនអាចទ្រទ្រង់ព្រះបរិយត្តិទុកបាន ។ គួរដល់ភិក្ខុទាំងឡាយ នឹងទៅកាន់ត្រើយឯណោះរក្សាជីវិត មេត្តាឡើងក្បូនធំនេះទៅចុះ លោកម្ចាស់ ដែលអង្គុយលើក្បូននេះ មិនគ្រប់គ្រាន់ដល់ភិក្ខុពួកណា ភិក្ខុពួកនោះ ចូរតោងកំណាត់ឈើទៅចុះ ភ័យនឹងមិនមានដល់ភិក្ខុទាំងពួង ។ ក្នុងកាលនោះ ភិក្ខុ ៦០ រូបទៅដល់ត្រើយសមុទ្រហើយធ្វើកតិកាគ្នាទុកថា មិនមានកិច្ចដែលពួកយើងនឹងទៅក្នុងទីនោះ ពួកយើងនឹងនៅក្នុងទីនេះឯង នឹងរក្សាព្រះត្រៃបិដក ដូច្នេះហើយ ទើបត្រឡប់ពីទីនោះទៅកាន់ទក្ខិណមលយៈជនបទ ចិញ្ចឹមជីវិតដោយមើមឈើ និងស្លឹកឈើ ។ កាលរាងកាយនៅប្រព្រឹត្តទៅ ក៏នាំគ្នាអង្គុយធ្វើការស្វាធ្យាយ កាលរាងកាយប្រព្រឹត្ត

ទៅមិនបាន រមែងពូនខ្សាច់ឡើងជុំវិញសីសៈ ទុកក្នុងទីមួយ ពិចារណាព្រះ-បរិយត្តិ ។ ដោយទំនងនេះ ភិក្ខុទាំងឡាយ ទ្រទ្រង់ព្រះត្រៃបិដក ព្រមទាំងអដ្ឋកថាឲ្យបរិបូណ៌ហើយ បានដល់ ១២ ឆ្នាំ ។

កាលភ័យស្ងប់ ភិក្ខុ ៧០០ រូប មិនធ្វើសូម្បីអក្ខរមួយតួ សូម្បីព្យញ្ជនៈមួយតួ ក្នុងព្រះត្រៃបិដកព្រមទាំងអដ្ឋកថា ពីស្ថានទីដែលខ្លួនទៅហើយ ឲ្យវិនាសមកដល់កោះនេះឯង ចូលទៅកាន់មណ្ឌលារាមវិហារ ក្នុងកល្លគាមជនបទ ។ ភិក្ខុ ៦០ រូប ដ៏សេសក្នុងកោះនេះ បានស្តាប់រឿងការមករបស់ព្រះថេរៈទាំងឡាយ គិតថា នឹងសួរសុខទុក្ខព្រះថេរៈទាំងឡាយ ទើបទៅផ្ទៀងផ្ទាត់ព្រះត្រៃ-បិដកជាមួយព្រះថេរៈទាំងឡាយ មិនជួបសូម្បីអក្ខរមួយតួ សូម្បីព្យញ្ជនៈមួយតួ ឈ្មោះថា មិនសមគួរ ។

ព្រះថេរៈទាំងឡាយកើតការសន្ទនាគ្នាឡើងក្នុងទីនោះថា បរិយត្តិ ជាមូលនៃព្រះសាសនា ឬបដិបត្តិ ជាមូល ។ ព្រះថេរៈអ្នកកាន់សំពត់បង្សុកូលជាវត្ត ពោលថា បដិបត្តិជាមូលនៃព្រះសាសនា ។ ចំណែកព្រះធម្មកថិកទាំងឡាយ ពោលថា ព្រះបរិយត្តិជាមូល ។ លំដាប់នោះ ព្រះថេរៈទាំងនោះពោលថា ខ្ញុំមិនជឿដោយត្រឹមតែពាក្យរបស់លោកទាំងពីរប៉ុណ្ណោះ សូមពួកលោកចូរអាងព្រះសូត្រដែលព្រះជិនៈទ្រង់ភាសិតទុក ។ ព្រះថេរៈទាំង ២ នោះ ពោល

ថា ការនាំព្រះសូត្រមកអានមិនធ្ងន់ឡើយ ព្រះថេរៈជាអ្នកទ្រទ្រង់សំពត់បង្សុកូល ទើបអានព្រះសូត្រថា ម្នាលសុភទ្ទៈ ក៏ភិក្ខុទាំងឡាយក្នុងព្រះសាសនានេះ គប្បីនៅដោយប្រពៃ លោកមិនគប្បីទំនេរចាកព្រះអរហន្តទាំងឡាយ ។ ម្នាលមហាបពិត្រ ព្រះសាសនារបស់ព្រះសាស្តា មានបដិបត្តិជាមូល មានការបដិបត្តិជាសារៈ កាលទ្រទ្រង់ហើយក្នុងការបដិបត្តិ ក៏ឈ្មោះថា តាំងនៅហើយ ។ ចំណែកពួកព្រះធម្មកថិក បានស្តាប់ព្រះសូត្រនោះហើយ ដើម្បីនឹងការពារវាទៈរបស់ខ្លួន ទើបអានព្រះសូត្រនេះថា ៖

ព្រះសូត្រតាំងនៅដរាបណា ព្រះវិន័យនៅរុងរឿងនៅដរាបណា
ភិក្ខុទាំងឡាយ រមែងឃើញពន្លឺ ដូចជាព្រះអាទិត្យឧទ័យ ដរាប
នោះ កាលព្រះសូត្រមិនមាន និងសូម្បីព្រះវិន័យក៏វិនាសទៅ
ក្នុងលោកក៏នឹងមានតែសេចក្តីងងឹត ដូចព្រះអាទិត្យអស្តង្គត
កាលភិក្ខុនៅរក្សាព្រះសូត្រហើយ រមែងជាការរក្សាបដិបត្តិ
ទុកផង អ្នកប្រាជ្ញអ្នកតាំងនៅក្នុងការបដិបត្តិ រមែងមិនឃ្លាត
ចាកពីធម៌ដែលក្សេមចាកយោគៈ ដូច្នេះ ។

កាលព្រះធម្មកថិក នាំព្រះសូត្រនេះមកអាន ព្រះថេរៈអ្នកទ្រទ្រង់សំពត់បង្សុកូលទាំងឡាយក៏នៅស្ងៀម ។ ពាក្យរបស់ព្រះថេរៈអ្នកជាធម្មកថិកនោះឯង

ជឿកាន់បាន ។ ដូចយ៉ាងថា ក្នុងចន្លោះគោឈ្មោល ១០០ ឬ ១.០០០ កាល មិនមានមេគោនឹងរក្សាពូជពង្ស ពូជពង្សក៏មិនបន្តគ្នា យ៉ាងណា កាលភិក្ខុផ្ដើម វិបស្សនា ១០០ រូប ១.០០០ រូប មានហើយ តែបរិយត្តិមិនមាន ឈ្មោះថា ការត្រាស់ដឹងអរិយមគ្គក៏មិនមាន ដូច្នោះនុ៎ះឯង ។ មួយទៀត កាលគេចារឹក អក្សរទុកលើផ្ទាំងថ្ម ដើម្បីនឹងឲ្យដឹងរណ្ដៅទ្រព្យ អក្សរមាននៅត្រឹមណា រណ្ដៅ ទ្រព្យទាំងឡាយ ឈ្មោះថា មិនទាន់វិនាសបាត់បង់ទៅត្រឹមនោះ យ៉ាងណា កាលបរិយត្តិតាំងនៅ ព្រះសាសនា ក៏ឈ្មោះថា មិនទាន់អន្តរធានទៅ ដូច្នោះ ដូចគ្នា ។

**ចប់អដ្ឋកថាវគ្គទី ១០**

# អដ្ឋកថាអធម្មវគ្គទី ១១

*គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[១៣១] *ពាក្យថា* **អធម្មំ អធម្មោ** *ជាដើម គប្បីជ្រាបដោយន័យដូចពោលហើយនុ៎ះឯង ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយទាំងអស់នោះឯង ។*

## ចប់អដ្ឋកថាអធម្មវគ្គទី ១១

# អដ្ឋកថាអនាបត្តិវគ្គទី ១២

*ក៏ក្នុងអនាបត្តិវគ្គទី ១២ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[១៣៥] ក្នុងពាក្យថា **អនាបត្តិំ អាបត្តិ** ជាដើម អនាបត្តិដែលលោកពោលទុកក្នុងទីនោះៗ មិនជាអាបត្តិដល់ភិក្ខុអ្នកមិនដឹងនៅ មិនមានថេយ្យចិត្ត មិនបំណងនឹងឲ្យស្លាប់ មិនបំណងនឹងអួត មិនបំណងនឹងបញ្ចេញ (សុក្កៈ) ដូច្នេះ ឈ្មោះថា **អនាបត្តិ** ។ អាបត្តិ ដែលលោកពោលទុកដោយន័យមានជាដើមថា ជាអាបត្តិដល់ភិក្ខុអ្នកដឹងហើយ អ្នកមានថេយ្យចិត្ត ដូច្នេះ ឈ្មោះថា **អាបត្តិ** ។ អាបត្តិ ៥ កង ឈ្មោះថា **លហុកាបត្តិ** (អាបត្តិស្រាល) , អាបត្តិ ២ កង ឈ្មោះថា **គរុកាបត្តិ** (អាបត្តិធ្ងន់) , អាបត្តិ ២ កង ឈ្មោះថា **ទុដ្ឋុល្លាបត្តិ** (អាបត្តិអាក្រក់គ្រោតគ្រាត) , អាបត្តិ ៥ កង ឈ្មោះថា **អទុដ្ឋុល្លាបត្តិ** (អាបត្តិមិនអាក្រក់គ្រោតគ្រាត) , អាបត្តិ ៦ កង ឈ្មោះថា សាវសេសាបត្តិ (អាបត្តិដែលមានចំណែកនៅសល់) , អាបត្តិបារាជិក ១ កង ឈ្មោះថា អនាវសេសាបត្តិ (អាបត្តិដែលមិនមានចំណែកនៅសល់) អាបត្តិដែលមានចំណែកសល់នុ៎ះឯង ឈ្មោះថា អាបត្តិដែលធ្វើសងបាន ។ អាបត្តិដែលមិនមានចំណែកនៅសល់នុ៎ះឯង ឈ្មោះថា អាបត្តិដែលធ្វើសងមិនបាន ។ ពាក្យដ៏សេស ក្នុងទីទាំង*

ពួន មានអត្ថាយទាំងនោះឯង ។

ចប់អដ្ឋកថា អនាបត្តិវគ្គទី ១២

## ចប់អដ្ឋកថាអនាបត្តិវគ្គទី ១២

# ឯកបុគ្គលវគ្គទី ១៣

## អដ្ឋកថាសូត្រទី ១

*ឯកបុគ្គលវគ្គ សូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[១៣៩] បទថា* ***ឯកបុគ្គលោ*** *ប្រែថា បុគ្គលឯក ។ បទថា* ***ឯកោ*** *ក្នុងពាក្យថា* ***ឯកបុគ្គលោ*** *នេះ ជាការកំណត់ចំនួន ដែលមានសេចក្តីបដិសេធនាក់ទី ២ ជាដើម ។ បទថា* ***បុគ្គលោ*** *ជាពាក្យនិយាយដោយសម្មតិ មិនមែនពាក្យនិយាយដោយបរមត្ថ ។*

*ពិតណាស់ ទេសនារបស់ព្រះមានព្រះភាគ មាន ២ យ៉ាង គឺ សម្មតិទេសនា ១ បរមត្ថទេសនា ១ ក្នុង ២ យ៉ាងនោះ ទេសនាទំនងនេះថា បុគ្គល សត្វ ស្រី ប្រុស ក្សត្រិយ៍ ព្រាហ្មណ៍ ទេវតា មារ ឈ្មោះថា* ***សម្មតិទេសនា*** *។ ទេសនាទំនងនេះថា មិនទៀង ជាទុក្ខ ជាអនត្តា ខន្ធ ធាតុ អាយតនៈ សតិប្បដ្ឋាន ឈ្មោះថា* ***បរមត្ថទេសនា*** *។ ក្នុងទេសនា ២ យ៉ាងនោះ ជនពួកណាស្តាប់ទេសនាជាប់ដោយសម្មតិ អាចយល់សេចក្តីលះមោហៈ សម្រេចគុណវិសេសបាន ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងសម្មតិទេសនាដល់ជនទាំងនោះ ។ ចំណែកជនពួកណា ស្តាប់ទេសនាជាប់ដោយបរមត្ថ ហើយអាចយល់សេចក្តី*

លះមោហៈ សម្រេចគុណវិសេសបាន ព្រះដ៏មានព្រះភាគទ្រង់សម្ដែងបរមត្ថ-ទេសនាដល់ជនពួកនោះ ។

ក្នុងសេចក្ដីនោះ គប្បីជ្រាបឧបមាដូចតទៅនេះ ៖

ដូចសេចក្ដីថា អាចារ្យដែលឈ្លាសក្នុងភាសា អ្នកបរិយាយខ្លឹមសារនៃវេទទាំង ៣ ជនពួកណា កាលនិយាយដោយភាសាទមិឡ រមែងដឹងសេចក្ដីបាន ក៏នឹងទូន្មានជនទាំងនោះ ដោយភាសាទមិឡ ។ ជនពួកណា កាលនិយាយដោយភាសាណាមួយ ក្នុងបណ្ដាភាសារបស់អ្នកស្រុកអន្ធៈជាដើម រមែងដឹងសេចក្ដីបាន ក៏នឹងទូន្មានដោយភាសានោះៗ ដល់ជនទាំងនោះ ព្រោះដូច្នោះ មាណពទាំងនោះ អាស្រ័យអាចារ្យអ្នកឈ្លាសវាងវៃ រមែងរៀនសិល្បៈបានដោយឆាប់រហ័ស ។ ក្នុងឧបមានោះ គប្បីជ្រាបថា ព្រះដ៏មានព្រះភាគ ប្រៀបដូចអាចារ្យ ។ បិដក ៣ តាំងនៅក្នុងភាវៈដែលនឹងត្រូវពោលប្រាប់ ប្រៀបដូចជាវេទ ៣ ។ ភាពជាអ្នកឈ្លាសក្នុងសម្មតិ និងបរមត្ថ ដូចភាពជាអ្នកឆ្លាតក្នុងភាសា ។ វេ-នេយ្យសត្វអ្នកអាចយល់សេចក្ដីបាន ដោយអំណាចនៃសម្មតិ និងបរមត្ថ ដូចមាណពអ្នកដឹងភាសាផ្សេងៗ គ្នា ទេសនាដោយអំណាចសម្មតិ និងបរមត្ថ របស់ព្រះដ៏មានព្រះភាគ ប្រៀបផ្ទឹមដូចការទូន្មានដោយភាសា មានភាសាទមិឡជាដើម របស់អាចារ្យ ។ សមពិតដូចដែលលោកពោលទុកក្នុងទីនេះថា ៖

ព្រះសម្ពុទ្ធ ជាកំពូលនៃអ្នកពោលទូន្មានទាំងឡាយ បាន
ត្រាស់សច្ចៈ ២ យ៉ាង គឺ សម្មតិសច្ចៈ និងបរមត្ថសច្ចៈ
មិនត្រាស់សច្ចៈទី ៣ ពាក្យដែលមនុស្សលោកបានដឹងគ្នា
ក៏ជាសច្ចៈ ព្រោះមានលោកសម្មតិជាហេតុ ពាក្យដែល
លាយដល់វត្ថុដែលជាបរមត្ថក៏ជាសច្ចៈ ព្រោះមានសេចក្ដី
ពិតរបស់ធម៌ទាំងឡាយជាហេតុ ព្រោះដូច្នោះ មុសាវាទ
ទើបមិនកើតដល់ព្រះលោកនាថជាសាស្ដា ដែលឆ្លាតក្នុង
វោហារ ទ្រង់ត្រាស់តាមសម្មតិ ។

ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគ ត្រាស់បុគ្គលកថា ពោលអំពីបុគ្គល ដោយហេតុ ៨ ប្រការ គឺ ដើម្បីទ្រង់សម្ដែងហិរិ (សេចក្ដីខ្មាស) និងឱត្តប្បៈ (សេចក្ដីខ្លាច) ១ ដើម្បីទ្រង់សម្ដែងកម្មស្សកតា (ភាពដែលសត្វមានកម្មជារបស់ខ្លួន) ១ ដើម្បីទ្រង់សម្ដែងបុគ្គលដែលធ្វើចំពោះខ្លួន ១ ដើម្បីទ្រង់សម្ដែងដល់អនន្តរិយកម្ម (កម្មមុនកម្មដទៃៗ ដែលឲ្យផល) ១ ដើម្បីទ្រង់សម្ដែងដល់ព្រហ្មវិហារធម៌ (មេត្តា ករុណា មុទិតា ឧបេក្ខា) ១ ដើម្បីទ្រង់សម្ដែងដល់បុព្វេនិវាសញ្ញាណ (រឭកជាតិមុនបាន) ១ ដើម្បីទ្រង់សម្ដែងដល់ទក្ខិណាវិសុទ្ធិ (សេចក្ដីបរិសុទ្ធិនៃទក្ខិណា) ១ និងដើម្បីទ្រង់មិនលះលោកសម្មតិ ១ ។ កាល

ព្រះអង្គត្រាស់ថា ខន្ធ ធាតុ អាយតនៈទាំងឡាយ រមែងខ្មាស រមែងខ្លាច ដូច្នេះ មហាជនរមែងមិនយល់ រមែងត្រឡប់ជាសត្រូវ (លាន់មាត់) ថា នេះជាអ្វី ខន្ធ ធាតុ អាយតនៈ រមែងខ្មាស់ រមែងខ្លាច ។ តែកាលត្រាស់ថា ស្រី ប្រុស ក្សត្រិយ៍ ព្រាហ្មណ៍ ទេវ និងមារ រមែងខ្មាស រមែងខ្លាច មហាជនរមែងយល់ រមែងមិនងឿងឆ្ងល់ មិនត្រឡប់ជាសត្រូវ (មិនលាន់មាត់) ។ ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ ទើបត្រាស់បុគ្គលកថា (កថាពោលអំពីបុគ្គល) ក៏ដើម្បីសម្តែងហិរិ និងឱត្តប្បៈ ។

សូម្បីក្នុងពាក្យដែលពោលទុកថា ខន្ធទាំងឡាយ ធាតុទាំងឡាយ អាយតនៈទាំងឡាយ មានកម្មជារបស់ខ្លួន ក៏មានន័យនេះដូចគ្នា ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ទើបត្រាស់បុគ្គលកថា ដើម្បីទ្រង់សម្តែងសភាពនៃសត្វមានកម្មជារបស់ខ្លួន ។ សូម្បីក្នុងពាក្យដែលពោលទុកថា មហាវិហារទាំងឡាយ មានវេឡុវ័នជាដើម ដែល ខន្ធ ធាតុ អាយតនៈ សាងហើយ ក៏ន័យនេះដូចគ្នា ។ ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់សម្តែងបុគ្គលកថា ដើម្បីទ្រង់សម្តែងដល់បុគ្គលដែលធ្វើចំពោះខ្លួន ។

សូម្បីក្នុងពាក្យដែលពោលទុកថា ខន្ធ ធាតុ អាយតនៈ រមែងផ្តាច់ជីវិតបិតា មាតា ព្រះអរហន្ត ធ្វើកម្ម គឺ ញុំាងព្រះលោហិតឲ្យពុរពង និងធ្វើសង្ឃភេទ

ក៏ន័យនេះដូចគ្នា ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់សម្ដែងបុគ្គលកថា ដើម្បីទ្រង់សម្ដែងដល់អនន្តរិយកម្ម ។

សូម្បីក្នុងពាក្យដែលពោលទុកថា ខន្ធ ធាតុ អាយតនៈ រមែងមានមេត្តា ក៏ន័យនេះដូចគ្នា ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់សម្ដែងបុគ្គលកថា ដើម្បីទ្រង់សម្ដែងព្រហ្មវិហារធម៌ ។

សូម្បីក្នុងពាក្យដែលពោលទុកថា ខន្ធ ធាតុ អាយតនៈ រមែងរឭកដល់បុព្វេនិវាសញ្ញាណ ក៏ន័យនេះដូចគ្នា ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់សម្ដែងបុគ្គលកថា ដើម្បីទ្រង់សម្ដែងបុព្វេនិវាសញ្ញាណ ។

សូម្បីកាលពោលថា ខន្ធ ធាតុ អាយតនៈ រមែងទទួលទាន មហាជនរមែងមិនយល់ រមែងងឿងឆ្ងល់ ត្រឡប់ជាសត្រូវថា នេះជាអ្វី ខន្ធ ធាតុ អាយតនៈ រមែងទទួលទាន ។ តែកាលពោលថា បុគ្គលដែលមានសីល មានកល្យាណធម៌ជាដើម មហាជន រមែងយល់ រមែងមិនងឿងឆ្ងល់ ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់សម្ដែងបុគ្គលកថា ដើម្បីទ្រង់សម្ដែងសេចក្ដីបរិសុទ្ធិនៃទក្ខិណា ។

ពិតហើយ ព្រះដ៏មានព្រះភាគសម្ពុទ្ធទាំងឡាយ រមែងមិនលះបង់លោកសម្មតិ តាំងនៅក្នុងឈ្មោះរបស់មនុស្សលោក ក្នុងភាសារបស់មនុស្សលោក

ក្នុងពាក្យនិយាយចចារគ្នារបស់មនុស្សលោកទាំងឯង ហើយសម្តែងធម៌ ។ ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់សម្តែងបុគ្គលកថា ដើម្បីមិនលះបង់លោក-សម្មតិ ។

ដូចនោះ ទើបឈ្មោះថា **បុគ្គលឯក** ព្រោះបុគ្គលនោះផង ជាឯកផង ។ ដែលឈ្មោះថា **បុគ្គលឯក** ព្រោះអត្ថថា អ្វី? ព្រោះអត្ថថា មិនមានអ្នកដទៃដូច ព្រោះអត្ថថា ពិសេសដោយគុណ ព្រោះអត្ថថា ស្មើដោយព្រះពុទ្ធជាម្ចាស់ មិនមានបុគ្គលស្មើ ។ ពិតហើយ ព្រះដ៏មានព្រះភាគអង្គនោះ មិនដូចគ្នានឹងមហាជនទូទៅ ដោយគុណ គឺ ពោធិសម្ភារ រាប់តាំងពីទ្រង់រំពឹងដល់បារមី ១០ តាមលំដាប់ និងដោយព្រះពុទ្ធគុណ ព្រោះដូច្នោះ ទើបឈ្មោះថា **បុគ្គលឯក** ព្រោះអត្ថថា មិនមាននរណាដូចខ្លះ ។

មួយទៀត ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់មានគុណវិសេសជាងគុណរបស់ពួកសត្វអ្នកមានគុណទូទៅ ព្រោះហេតុនោះ ទើបឈ្មោះថា **បុគ្គលឯក** ព្រោះអត្ថថា មានសេចក្តីវិសេសដោយគុណ ។ ព្រះសម្មាសម្ពុទ្ធមុនៗ មិនស្មើដោយសត្វគ្រប់ជំពូក តែព្រះដ៏មានព្រះភាគអង្គនេះ តែមួយព្រះអង្គប៉ុណ្ណោះ ជាអ្នកស្មើនឹងព្រះសម្មាសម្ពុទ្ធទាំងនោះ ដោយព្រះគុណ គឺ រូបកាយ និងព្រះគុណ គឺ នាមកាយ ព្រោះហេតុនោះ ទើបឈ្មោះថា **បុគ្គលឯក** ព្រោះអត្ថថា

ស្មើនឹងព្រះពុទ្ធជាម្ចាស់ ដែលមិនមានបុគ្គលណាស្មើ ។

បទថា លោកេ បានដល់ លោក ៣ គឺ សត្វលោក ឱកាសលោក សង្ខារលោក ។ កថាពោលដោយសេចក្ដីពិស្ដារនៃលោកទាំង ៣ នោះ លោកបានពោលទុកហើយក្នុងវិសុទ្ធិមគ្គ ។ បណ្ដាលោក ៣ នោះ សត្វលោក លោកបំណងយកក្នុងទីនេះ ។ ពិតហើយ ព្រះតថាគតនោះ សូម្បីកាលកើតក្នុងសត្វ-លោក មិនបានកើតក្នុងទេវលោក និងក្នុងព្រហ្មលោកទេ រមែងកើតចំពោះតែក្នុងមនុស្សលោកប៉ុណ្ណោះ ។ សូម្បីក្នុងមនុស្សលោក ក៏មិនបានកើតក្នុងចក្រ-វាឡដទៃ រមែងកើតចំពោះតែក្នុងចក្រវាឡនេះប៉ុណ្ណោះ សូម្បីក្នុងចក្រវាឡនោះក៏មិនកើតក្នុងទីគ្រប់កន្លែង ។

ក្នុងទិសបូព៌ា មាននិគម ឈ្មោះថា កជង្គលៈ បន្ទាប់ពីកជង្គលនិគមនោះទៅ មាននគរឈ្មោះថា មហាសាលៈ បន្ទាប់ពីមហាសាលៈនោះទៅ ជាបច្ចន្តជនបទ រួមក្នុងមជ្ឈិមជនបទ ។ ក្នុងទិសអាគ្នេយ៍ មានទន្លេឈ្មោះថា សល្លវតី បន្ទាប់ពីទន្លេសល្លវតីនោះទៅ ជាបច្ចន្តជនបទ រួមក្នុងមជ្ឈិមជនបទ ។ ក្នុងទិសទក្សិណ មាននិគម ឈ្មោះថា សេតកណ្ណិកៈ បន្ទាប់ពីសេតកណ្ណិក-និគមនោះទៅ ជាបច្ចន្តជនបទ រួមក្នុងមជ្ឈិមជនបទ ។ ក្នុងទិសបច្ចិម មានស្រុកព្រាហ្មណ៍ ឈ្មោះថា ថូនៈ បន្ទាប់ពីស្រុកព្រាហ្មណ៍នោះទៅ ជាបច្ចន្តជន-

បទ រួមក្នុងមជ្ឈិមជនបទ ។ ក្នុងទិសឧត្តរ មានភ្នំ ឈ្មោះថា ឧសីរធជៈ បន្ទាប់ពីភ្នំនោះទៅ ជាបច្ចន្តជនបទ រួមក្នុងមជ្ឈិមជនបទ ។ ព្រះតថាគត រមែងឧប្បត្តិក្នុងមជ្ឈិមប្រទេស ដែលលោកកំណត់ដូចពោលមកហើយនោះ ដោយផ្នែកបណ្តោយ វាស់បាន ៣០០ យោជន៍ ដោយផ្នែកទទឹង វាស់បាន ១៥០ យោជន៍ វាស់ដោយជុំវិញបាន ៩០០ យោជន៍ ។ មួយទៀត ព្រះតថាគតមិនបានឧប្បត្តិចំពោះតែព្រះអង្គឯងតែម្យ៉ាងទេ ព្រះបច្ចេកពុទ្ធទាំងឡាយ ព្រះអគ្គសាវក ព្រះអសីតិមហាថេរៈ សូម្បីលោកអ្នកមានបុណ្យដទៃៗ ក៏រមែងកើតឡើង ។ ព្រះពុទ្ធមាតា ព្រះពុទ្ធបិតា ស្តេចចក្រពត្តិ និងព្រាហ្មណ៍គហបតី ដែលជាបុគ្គលសំខាន់ពួកដទៃ ក៏រមែងកើតក្នុងមជ្ឈិមប្រទេសនេះដូចគ្នា ។

ក៏បទថា **ឧប្បជ្ជមានោ ឧប្បជ្ជតិ** ទាំងពីរនេះ ជាពាក្យពោលជាប់គ្នាប៉ុណ្ណោះ ។ ក៏ក្នុងពាក្យនេះ គប្បីជ្រាបសេចក្តីយ៉ាងនេះថា ព្រះតថាគត កាលឧប្បត្តិ រមែងឧប្បត្តិដើម្បីប្រយោជន៍ដល់ជនច្រើន មិនឧប្បត្តិដោយហេតុដទៃ ។ ក៏ក្នុងអធិការនេះ លក្ខណៈបែបនេះ នរណាៗ មិនអាចជំទាស់ពាក្យទាំងពីរនោះដោយលក្ខណៈស័ព្ទដទៃឡើយ ។

ម្យ៉ាងទៀត គប្បីជ្រាបសេចក្តីផ្សេងគ្នាក្នុងពាក្យនេះ ដូច្នេះថា **ឧប្បជ្ជ-មានោ** **នាម** (ឈ្មោះថា កាលនឹងឧប្បត្តិ) **ឧប្បជ្ជតិ នាម** (ឈ្មោះថា កំពុង

ឧប្បត្តិ) **ឧប្បន្នោ នាម** (ឈ្មោះថា ឧប្បត្តិហើយ ) ។ ពិតណាស់ ព្រះពុទ្ធអង្គ បានទទួលពាក្យព្យាករណ៍ ត្រង់បាទមូលនៃព្រះពុទ្ធទ្រង់ព្រះនាមថា ទីបង្ករ កាលស្វែងរកពុទ្ធការកធម៌ (ធម៌ជាគ្រឿងធ្វើសម្រេចជាព្រះពុទ្ធ) ទ្រង់ឃើញបារមី ១០ ទើបទ្រង់ដាក់ចុះព្រះទ័យថា យើងគួរបំពេញធម៌ទាំងនេះ សូម្បីកំពុងបំពេញទានបារមីហើយ ក៏ឈ្មោះថា កាលនឹងឧប្បត្តិ ។ សូម្បីកាលទ្រង់បំពេញបារមី ១០ ទាំងនេះ គឺ សីលបារមី ។លៗ ឧបេក្ខាបារមីក្ដី ទ្រង់បំពេញឧបបារមី ១០ ក្ដី ក៏ឈ្មោះថា កាលនឹងឧប្បត្តិ ។ សូម្បីកាលទ្រង់បំពេញបរមត្ថបារមី ១០ ក៏ឈ្មោះថា កាលនឹងឧប្បត្តិ ។ កាលបរិច្ចាគនូវមហាបរិច្ចាគ ៥ ប្រការ ក៏ឈ្មោះថា កាលនឹងឧប្បត្តិ ។ សូម្បីកាលទ្រង់បំពេញញាតត្ថចរិយា លោកត្ថចរិយា និងពុទ្ធត្ថចរិយា ក៏ឈ្មោះថា កាលនឹងឧប្បត្តិ ។ សូម្បីកាលទ្រង់បំពេញពុទ្ធការកធម៌ ឲ្យដល់ទីបំផុត អស់ ៤ អសង្ខេយ្យកម្រៃសែនកប្ប ក៏ឈ្មោះថា កាលនឹងឧប្បត្តិ ។ សូម្បីកាលទ្រង់លះបង់អត្តភាពព្រះវេស្សន្តរ កាន់បដិសន្ធិក្នុងតុសិតបុរី តាំងនៅរហូតដល់អស់ ៥៧ កោដិឆ្នាំ នឹង ៦០.០០០ ឆ្នាំ ក៏ឈ្មោះថា កាលនឹងឧប្បត្តិ ។ ព្រះអង្គដែលទេវតាទូលអារាធនាហើយ ទ្រង់ត្រួតមើលមហាវិលោកិតៈ៥ ប្រការ ទ្រង់កាន់បដិសន្ធិក្នុងព្រះគភ៌របស់ព្រះទេវីទ្រង់ព្រះនាមថា មហាមាយាក្ដី ទ្រង់នៅក្នុងព្រះគភ៌ ១០ ខែគត់ក្ដី ក៏ឈ្មោះថា

កាលនឹងឧប្បត្តិដូចគ្នា ។ សូម្បីទ្រង់តាំងនៅក្នុងការគ្រប់គ្រងផ្ទះ ២៩ វស្សា ក៏ឈ្មោះថា កាលនឹងឧប្បត្តិដូចគ្នា ។ សូម្បីកាលទ្រង់ឃើញទោសក្នុងកាមទាំងឡាយ ឃើញអានិសង្សក្នុងការចេញចាកកាម មាននាយឆន្នៈជាសម្លាញ់ ទ្រង់ប្រថាប់លើសេះកណ្ឋកៈដ៏ប្រសើរ ស្តេចចេញព្រះផ្នួសក្នុងថ្ងៃដែលព្រះរាហុលកុមារៈប្រសូតិ ក៏ឈ្មោះថា កាលនឹងឧប្បត្តិដូចគ្នា ។ ស្តេចកន្លងផុតរាជាណាចក្រទាំង ៣ ទ្រង់ព្រះផ្នួសត្រង់ច្រាំងទន្លេអនោមានទីក្តី ក៏ឈ្មោះថា កាលនឹងឧប្បត្តិដូចគ្នា ។ សូម្បីទ្រង់ធ្វើមហាបធាន សេចក្តីព្យាយាម ៦ វស្សា ក៏ឈ្មោះថា កាលនឹងឧប្បត្តិដូចគ្នា ។ កាលព្រះញាណចាស់ក្លាហើយ សោយគ្រឿយាហារគ្រោតគ្រាតក្តី ក៏ឈ្មោះថា កាលនឹងឧប្បត្តិដូចគ្នា ។ សូម្បីកាលឡើងកាន់មហាពោធិមណ្ឌលស្ថាន ក្នុងថ្ងៃវិសាខបុណ្ណមីក្នុងវេលាល្ងាច ទ្រង់កម្ចាត់មារ និងពលរបស់មារ ទ្រង់រឭកដល់បុព្វេនិវាសញ្ញាណក្នុងបឋមយាម ទ្រង់ជម្រះទិព្វចក្ខុក្នុងមជ្ឈិមយាម ទ្រង់ពិចារណាបដិច្ចសមុប្បាទអង្គ ១២ ដោយអនុលោមនិងបដិលោមក្នុងវេលាជាប់តគ្នានឹងបច្ឆិមយាម ហើយត្រាស់ដឹងសោតាបត្តិមគ្គក្តី ឈ្មោះថា កាលនឹងឧប្បត្តិដូចគ្នា ។ ក្នុងខណៈនៃសោតាបត្តិផលក្តី ក្នុងខណៈនៃសកទាគាមិមគ្គក្តី ក្នុងខណៈនៃសកទាគាមិផលក្តី ក្នុងខណៈនៃអនាគាមិមគ្គក្តី ក្នុងខណៈនៃអនាគាមិផលក្តី ឈ្មោះថា កាលនឹងឧប្បត្តិដូចគ្នា ។

ចំណែកក្នុងខណៈនៃអរហត្តមគ្គ ឈ្មោះថា កំពុងឧប្បត្តិ ។ ក្នុងខណៈនៃអរ-ហត្តផល ឈ្មោះថា ឧប្បត្តិហើយ ។ពិតណាស់ ឥទ្ធិវិធញ្ញាណជាដើម របស់ព្រះពុទ្ធទាំងឡាយ រមែងមិនកើតឡើងតាមលំដាប់ ដូចរបស់ព្រះសាវកទាំងឡាយ ។ ក៏គំនរនៃគុណ មានព្រះសព្វញ្ញុតញ្ញាណជាដើម សូម្បីទាំងអស់ ឈ្មោះថា រមែងមកព្រមគ្នាតែម្តងជាមួយព្រះអរហត្តមគ្គ ។ ព្រោះដូច្នោះ លោកទាំងនោះ ឈ្មោះថា ឧប្បត្តិហើយ ក្នុងខណៈនៃអរហត្តផល ព្រោះមានកិច្ចទាំងពួង ដែលសម្រេចហើយ ។ ក្នុងសូត្រនេះ គប្បីជ្រាបថា កំពុងឧប្បត្តិ សំដៅយកខណៈនៃអរហត្តផលនុ៎ះឯង ។ សេចក្តីពិត ក្នុងពាក្យថា **ឧប្បជ្ជតិ** នេះ មានសេចក្តីដូច្នេះថា **ឧប្បន្នោ ហោតិ** (រមែងជាអ្នកឧប្បត្តិ) ។

បទថា **ពហុជនហិតាយ** សេចក្តីថា ស្តេចរមែងឧប្បត្តិដើម្បីប្រយោជន៍ដ៏ធំដល់ជនច្រើន ។ បទថា **ពហុនោ ជនស្ស សុខាយ** សេចក្តីថា ស្តេចរមែងឧប្បត្តិដើម្បីប្រយោជន៍សុខដល់ជនច្រើន ។ បទថា **លោកានុកម្បាយ** សេចក្តីថា ស្តេចឧប្បត្តិព្រោះអាស្រ័យសេចក្តីអាណិតដល់សត្វលោក ។ សួរថា ដល់សត្វលោកណា? ឆ្លើយថា ដើម្បីប្រយោជន៍ដល់សត្វលោកដែលស្តាប់ព្រះធម៌-ទេសនារបស់ព្រះតថាគត បានផឹកទឹកអម្រឹតហើយត្រាស់ដឹងធម៌ ។ កាលព្រះ-ដ៏មានព្រះភាគ ប្រថាប់នៅ ៧ សប្តាហ៍ ត្រង់ពោធិមណ្ឌលស្ថាន ហើយស្តេច

ចេញចាកពីពោធិមណ្ឌលស្ថាន មកកាន់ព្រៃឥសិបតនមិគទាយវ័ន ហើយទ្រង់សម្តែងធម្មចក្កប្បវត្តនសូត្រថា ភិក្ខុទាំងឡាយ ទីបំផុត ២ យ៉ាងនេះ បព្វជិតមិនគួរសេពជាដើម ព្រហ្មរាប់បាន ១៨ កោដិ ព្រមដោយព្រះអញ្ញាកោណ្ឌញ្ញ-ត្ថេរៈ បានផឹកទឹកអម្រឹតហើយ ។ ព្រះអង្គស្តេចឧប្បត្តិដើម្បីសេចក្តីអនុគ្រោះដល់សត្វលោកនេះ ។ ថ្ងៃទី ៥ ក្នុងវេលាចប់ អនត្តលក្ខណៈសូត្រ ព្រះបញ្ច-វគ្គិយត្ថេរៈ ក៏បានតាំងនៅក្នុងព្រះអរហត្ត ។ ព្រះអង្គស្តេចឧប្បត្តិ ដើម្បីការអនុគ្រោះដល់សត្វលោកសូម្បីនេះ ។ លំដាប់នោះ ទ្រង់ឲ្យបុរស ៥៥ នាក់មានយសកុលបុត្រជាប្រធាន តាំងនៅក្នុងព្រះអរហត្ត ។ តពីនោះ ទ្រង់ឲ្យភទ្ទវគ្គីយ៍កុមារ ៣០ អ្នកនៅក្នុងដងព្រៃកប្បាស បានសម្រេចមគ្គ ៣ និងផល ៣ ។ ព្រះអង្គស្តេចឧប្បត្តិ ដើម្បីសេចក្តីអនុគ្រោះដល់សត្វលោកនេះ ។ ក្នុងវេលាចប់អាទិត្តបរិយាយសូត្រ ឲ្យជដិល ១.០០០ អ្នកតាំងនៅក្នុងព្រះអរហត្តត្រង់គយាសីសប្រទេស ។ មួយទៀត ព្រាហ្មណ៍ និងគហបតី ១១ នហុតមានព្រះបាទពិម្ពិសារជាប្រមុខ ក្នុងចំការត្នោតជំទង់ ស្តាប់ព្រះធម៌ទេសនារបស់ព្រះសាស្តាហើយ តាំងនៅក្នុងសោតាបត្តិផលទៀត , ១ នហុត តាំងនៅក្នុងសរណៈ ។ ក្នុងវេលាចប់អនុមោទនាដោយតិរោកុឌ្ឍសូត្រ សត្វ ៨៤.០០០ បានផឹកទឹកអម្រឹតហើយ ។ ក្នុងសមាគមនៃនាយសុមនមាលាការសត្វ ៨៤.០០០

ផឹកទឹកអម្រឹតហើយ ។ ក្នុងសមាគមនៃជំរីធនបាល សត្វ ១០.០០០ ផឹកទឹកអម្រឹតហើយ ។ ក្នុងសមាគមនៃខទិរង្គរជាតក សត្វ ៨៤.០០០ ផឹកទឹកអម្រឹតហើយ ។ ក្នុងសមាគមនៃជម្ពុកាជីវក សត្វ ៨៤.០០០ ផឹកទឹកអម្រឹត ។ ក្នុងសមាគមនៃអានន្ទសេដ្ឋី សត្វ ៨៤.០០០ ផឹកទឹកអម្រឹត ។ ក្នុងថ្ងៃទ្រង់សម្តែងបារាយនសូត្រនៅបាសាណកចេតិយ សត្វ ១៤ កោដិ ផឹកទឹកអម្រឹតហើយ ។ ក្នុងថ្ងៃសម្តែងយមកប្បាដិហារ្យ សត្វ ២០ កោដិ បានផឹកទឹកអម្រឹតហើយ ។ កាលព្រះសាស្តាប្រថាប់លើបណ្ឌុកម្ពលសិលាសនៈ ភពតាវត្តិង្ស ទ្រង់ធ្វើព្រះមាតាឲ្យជាកាយសក្ខី សម្តែងព្រះអភិធម្ម ៧ គម្ពីរ សត្វ ៨០ កោដិ ផឹកទឹកអម្រឹតហើយ ។ ក្នុងថ្ងៃស្តេចចុះចាកទេវលោកសត្វ ៣០ កោដិ ផឹកទឹកអម្រឹតក្នុងសក្កបញ្ហសូត្រ ទេវតា ៨០.០០០ បានផឹកទឹកអម្រឹតហើយ ។ ក្នុងឋានៈទាំង ៤ នេះ គឺ ក្នុងមហាសមយសូត្រ ក្នុងមង្គលសូត្រ ក្នុងចូឡរាហុលោវាទសូត្រ ក្នុងសមចិត្តបដិបទាសូត្រ សត្វដែលបានត្រាស់ដឹងធម៌ កំណត់មិនបាន ។ ព្រះអង្គស្តេចឧប្បត្តិ ដើម្បីសេចក្តីអនុគ្រោះដល់សត្វលោកសូម្បីនេះឯង ។ ខាងមុខពីនេះ រាប់ពីថ្ងៃនេះទៅ (និង) ក្នុងអនាគតកាល គប្បីជ្រាបសេចក្តីក្នុងអធិការនេះ ដូចពោលមកនេះ សូម្បីដោយអំណាចនៃពួកសត្វអ្នកអាស្រ័យព្រះសាសនាហើយ តាំងនៅក្នុងផ្លូវសួគ៌ និងព្រះនិព្វាន ។

បទថា **ទេវមនុស្សានំ** សេចក្តីថា ព្រះអង្គស្តេចឧប្បត្តិ ដើម្បីប្រយោជន៍ ដើម្បីអនុគ្រោះ និងដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សតែម្យ៉ាងប៉ុណ្ណោះ ក៏ទេ (តែ) ស្តេចឧប្បត្តិ ដើម្បីប្រយោជន៍ ដើម្បីអនុគ្រោះ និងដើម្បីសេចក្តីសុខ ដល់សត្វដ៏សេស មាននាគ និងគ្រុឌជាដើមផង ។ ក៏ដើម្បីនឹងសម្តែងបុគ្គលដែលបដិសន្ធិជាសហេតុកៈ ដែលសមគួរធ្វើឲ្យជាក់ច្បាស់មគ្គ និងផលទើបពោលយ៉ាងនោះ ។ ព្រោះហេតុនោះ គប្បីជ្រាបថា ព្រះអង្គស្តេចឧប្បត្តិ ដើម្បីប្រយោជន៍ ដើម្បីអនុគ្រោះ និងដើម្បីសេចក្តីសុខប៉ុណ្ណោះ សូម្បីដល់សត្វទាំងនោះ ។

បទថា **កតមោ ឯកបុគ្គលោ** មានបុច្ឆាដូចតទៅនេះ ៖

ឈ្មោះថា បុច្ឆានេះ មាន ៥ យ៉ាង គឺ អទិដ្ឋជោតនាបុច្ឆា (ពាក្យសួរដើម្បីជាក់ច្បាស់ក្នុងវត្ថុដែលខ្លួនមិនទាន់ឃើញ) ១ , ទិដ្ឋសំសន្ទនាបុច្ឆា (ពាក្យសួរដើម្បីប្រៀបធៀបនឹងវត្ថុដែលខ្លួនឃើញហើយ) ១ , វិមតិច្ឆេទនាបុច្ឆា (ពាក្យសួរដើម្បីកាត់សេចក្តីសង្ស័យ) ១ , អនុមតិបុច្ឆា (ពាក្យសួរដើម្បីទទួលអនុមតិ) ១ , កថេតុកម្យតាបុច្ឆា (ពាក្យសួរដោយបំណងនឹងពោលដោយខ្លួនឯង ១ បុច្ឆាទាំង ៥ នោះ មានសេចក្តីផ្សេងគ្នាដូចតទៅនេះ ៖

**អទិដ្ឋជោតនាបុច្ឆា** ដូចម្តេច ? លក្ខណៈតាមប្រក្រតី ជាវត្ថុនៅមិន

ទាន់ដឹង មិនទាន់ឃើញ ស្ទង់មិនទាន់បាន មិនទាន់បានរិះគិត មិនទាន់ប្រាកដច្បាស់ មិនទាន់ជាក់ច្បាស់ បុគ្គលរមែងសួរបញ្ហាដើម្បីដឹង ដើម្បីឃើញ ដើម្បីស្ទង់ ដើម្បីរិះគិត ដើម្បីត្រូវការឲ្យប្រាកដច្បាស់ ដើម្បីត្រូវការជាក់ច្បាស់ នៃលក្ខណៈនោះ នេះឈ្មោះថា **អទិដ្ឋជោតនាបុច្ឆា** ។

**ទិដ្ឋសំសន្ទនាបុច្ឆា** ដូចម្តេច? លក្ខណៈតាមប្រក្រតី ជាការដឹងហើយ ឃើញ ស្ទង់ រិះគិត ប្រាកដច្បាស់ និងជាក់ច្បាស់ហើយ បុគ្គលរមែងសួរបញ្ហា ដើម្បីប្រៀបធៀបជាមួយបណ្ឌិតពួកដទៃ នេះឈ្មោះថា **ទិដ្ឋសំសន្ទនា-បុច្ឆា** ។

**វិមតិច្ឆេទនាបុច្ឆា** ដូចម្តេច ? តាមប្រក្រតី បុគ្គលរមែងគ្រាច់ទៅកាន់សេចក្តីសង្ស័យ កើតសេចក្តីស្ទាក់ស្ទើចិត្តឡើងថា ជាយ៉ាងនេះឬហ្ន៎ មិនមែនឬហ្ន៎ ជាអ្វីហ្ន៎ ជាយ៉ាងណាហ្ន៎ គេទើបសួរបញ្ហា ដើម្បីត្រូវការកាត់សេចក្តីសង្ស័យ នេះឈ្មោះថា **វិមតិច្ឆេទនាបុច្ឆា** ។

**អនុមតិបុច្ឆា** ដូចម្តេច? ពិតហើយ ព្រះដ៏មានព្រះភាគត្រាស់សួរបញ្ហាតាមការឃើញត្រូវរបស់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកសម្គាល់សេចក្តី នោះដូចជាម្តេច? រូបទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ក៏រូបណាមិនទៀង រូបនោះ ជាទុក្ខ ឬជាសុខហ្ន៎ ។ ជាទុក្ខ ព្រះអង្គ ។ ក៏រូប

ណាមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលទៅជាធម្មតា គួរឬ ដែលនឹងតាមឃើញរូបនោះថា នោះជារបស់យើង នោះជាយើង នោះជាខ្លួនរបស់យើង ។ ក៏ប្រការនោះ មិនដូច្នោះទេ ព្រះអង្គ ។ នេះឈ្មោះថា **អនុមតិបុច្ឆា** ។

**កថេតុកម្យតាបុច្ឆា** ដូចម្ដេច? ព្រះដ៏មានព្រះភាគ ត្រាស់សួរបញ្ហាដោយព្រះអង្គ ទ្រង់មានព្រះបំណងនឹងត្រាស់ឆ្លើយដោយព្រះអង្គឯង ដល់ភិក្ខុទាំងឡាយថា ភិក្ខុទាំងឡាយ សតិប្បដ្ឋាន ៤ ទាំងនេះ សតិប្បដ្ឋាន ៤ ដូចម្ដេច? នេះឈ្មោះថា **កថេតុកម្យតាបុច្ឆា** ។

ក្នុងបុច្ឆាទាំង ៥ នោះ បុច្ឆា ៣ ខាងដើម មិនមានដល់ព្រះពុទ្ធទាំងឡាយ ។ ព្រោះហេតុអ្វី? ព្រោះថា វត្ថុណាៗ ក្នុងកាលដ៏វែង ទាំង ៣ កាល ដែលបច្ច័យតាក់តែង ឬផុតពីកាលដ៏វែង ដែលបច្ច័យតាក់តែងមិនបាន ឈ្មោះថា ទ្រង់មិនឃើញ ទ្រង់មិនជ្រាប ទ្រង់មិនស្ទង់ ទ្រង់មិនពិចារណា មិនប្រាកដច្បាស់ មិនជាក់ច្បាស់ រមែងមិនមានដល់ព្រះពុទ្ធទាំងនោះ ។ ព្រោះដូច្នោះ អទិដ្ឋជោតនាបុច្ឆា ទើបមិនមានដល់ព្រះពុទ្ធទាំងនោះ ។ ក៏វត្ថុណាដែលព្រះដ៏-មានព្រះភាគ ទ្រង់ដឹងហើយដោយព្រះញាណរបស់ព្រះអង្គ កិច្ច គឺ ការប្រៀបធៀបវត្ថុនោះជាមួយអ្នកដទៃ មិនថា ជាសមណៈ ព្រាហ្មណ៍ ទេវតា មារ ឬព្រហ្ម រមែងមិនមាន ដោយហេតុនោះ ទិដ្ឋសំសន្ទនាបុច្ឆា រមែងមិនមានដល់

ព្រះអង្គ ។ ក៏ព្រោះហេតុដែលព្រះអង្គមិនមានសេចក្តីសង្ស័យ ជាហេតុឲ្យពោលថាយ៉ាងណា ទ្រង់ជាអ្នកឆ្លងផុតសេចក្តីងឿងឆ្ងល់ចេញបាន កម្ចាត់សេចក្តីសង្ស័យក្នុងធម៌ទាំងពួងបានហើយ ដោយហេតុនោះ វិមតិច្ឆេទនាបុច្ឆា ទើបមិនមានដល់ព្រះអង្គ ។ ចំណែកបុច្ឆា ២ ប្រការ ក្រៅពីនេះ រមែងមានដល់ព្រះដ៏មានព្រះភាគ ។ ក្នុងបុច្ឆាទាំងនោះ បុច្ឆានេះ គប្បីជ្រាបថា **កថេតុកម្យតាបុច្ឆា** ។

ឥឡូវនេះ ព្រះដ៏មានព្រះភាគ កាលនឹងទ្រង់ចង្អុលដល់ **បុគ្គលឯក** ដែលគេសួរដោយពាក្យសួរនោះ ឲ្យជាក់ច្បាស់ ទើបត្រាស់ថា ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **តថាគតោ** សេចក្តីថា ព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមថា **តថាគត** ព្រោះហេតុ ៨ ប្រការ គឺ ទ្រង់ព្រះនាមថា **តថាគត** ព្រោះស្តេចមកយ៉ាងនោះ ។ ទ្រង់ព្រះនាមថា **តថាគត** ព្រោះស្តេចទៅយ៉ាងនោះ ។ ទ្រង់ព្រះនាមថា **តថាគត** ព្រោះស្តេចមកកាន់លក្ខណៈដែលពិត ។ ទ្រង់ព្រះនាមថា **តថាគត** ព្រោះត្រាស់ដឹងធម៌ដែលពិតតាមសេចក្តីពិត ។ ទ្រង់ព្រះនាមថា **តថាគត** ព្រោះទ្រង់ឃើញអារម្មណ៍ដែលពិត ។ ទ្រង់ព្រះនាមថា **តថាគត** ព្រោះមានព្រះវាចាដែលពិត ។ ទ្រង់ព្រះនាមថា **តថាគត** ព្រោះទ្រង់ធ្វើដោយព្រះអង្គឯង និងឲ្យអ្នកដទៃធ្វើ ។ ទ្រង់ព្រះនាម

ថា **តថាគត** ព្រោះអត្ថថា ទ្រង់គ្របសង្កត់បាន (គឺជាធំ) ។

ព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមថា **តថាគត** ព្រោះស្តេចមកយ៉ាងនោះដូចម្តេច?

ដូចព្រះសម្មាសម្ពុទ្ធអង្គមុនៗ ទ្រង់ខ្វល់ខ្វាយដើម្បីប្រយោជន៍ដល់លោកទាំងពួង ស្តេចមកហើយ ដូចព្រះដ៏មានព្រះភាគ ព្រះវិបស្សីស្តេចមក ដូចព្រះដ៏មានព្រះភាគព្រះសិខីស្តេចមក ដូចព្រះដ៏មានព្រះភាគព្រះវេស្សភូស្តេចមក ដូចព្រះដ៏មានព្រះភាគព្រះកកុសន្ធៈស្តេចមក ដូចព្រះដ៏មានព្រះភាគព្រះកោនាគមនៈស្តេចមក ដូចព្រះដ៏មានព្រះភាគព្រះកស្សបៈស្តេចមក ប្រការនេះ មានអធិប្បាយដូចម្តេច? មានអធិប្បាយថា ព្រះដ៏មានព្រះភាគទាំងនោះ ស្តេចមកដោយអភិនិហារណា ព្រះដ៏មានព្រះភាគរបស់យើងទាំងឡាយ ក៏ស្តេចមកដោយអភិនិហារនោះដូចគ្នា ម្យ៉ាងវិញទៀត ព្រះដ៏មានព្រះភាគព្រះវិបស្សី ។ល។ ព្រះដ៏មានព្រះភាគព្រះកស្សបៈ ទ្រង់បំពេញទានបារមី ទ្រង់បំពេញសីលបារមី នេក្ខម្មបារមី បញ្ញាបារមី វីរិយបារមី ខន្តិបារមី សច្ចបារមី អធិដ្ឋានបារមី មេត្តាបារមី និងឧបេក្ខាបារមី ទ្រង់បំពេញបារមី ៣០ ទសៈទាំងនេះ គឺ បារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ ទ្រង់បរិច្ចាគមហាបរិច្ចាគ ៥ ប្រការ គឺ បរិច្ចាគអវយវៈ បរិច្ចាគទ្រព្យ បរិច្ចាគបុត្ត បរិច្ចាគភរិយា បរិច្ចាគជីវិត ទ្រង់

បំពេញបុព្វប្រយោគ បុព្វចរិយា ការសម្តែងធម៌ និងតត្ថចរិយាជាដើម ទ្រង់ដល់ទីបំផុតនៃពុទ្ធចរិយា ស្តេចមកហើយយ៉ាងណា ព្រះដ៏មានព្រះភាគរបស់យើងទាំងឡាយ ក៏ស្តេចមកយ៉ាងនោះ ។

ន័យមួយទៀត ព្រះដ៏មានព្រះភាគ ព្រះវិបស្សី ។ល។ ព្រះដ៏មានព្រះភាគ ព្រះកស្សបៈ ទ្រង់ចម្រើនសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គៈ ៧ អរិយមគ្គមានអង្គ ៨ ស្តេចមកហើយ យ៉ាងណា ព្រះដ៏មានព្រះភាគរបស់យើងទាំងឡាយ ក៏ស្តេចមកយ៉ាងនោះ ព្រះដ៏មានព្រះ-ភាគ ទ្រង់ព្រះនាមថា **តថាគត** ព្រោះស្តេចមកយ៉ាងនោះ ដូច្នេះ ៖

ព្រះមុនីទាំងឡាយ មានព្រះវិបស្សីជាដើម ស្តេចមកកាន់
ភាពជាព្រះសព្វញ្ញូក្នុងលោកនេះ យ៉ាងណា សូម្បីព្រះ
សក្យមុនីអង្គនេះ ក៏ស្តេចមកយ៉ាងនោះ ដោយហេតុនោះ
ព្រះពុទ្ធទ្រង់មានចក្ខុ ទើបទ្រង់ព្រះនាមថា **តថាគត** ដូច្នេះ ។

ព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមថា **តថាគត** ព្រោះស្តេចមកយ៉ាងនោះ ដូច្នេះ ។

ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះស្តេចទៅយ៉ាងនោះ ដូចម្តេច?

ដូចព្រះដ៏មានព្រះភាគព្រះវិបស្សី ប្រសូតិក្នុងមួយរំពេច ក៏ស្តេចទៅ ។បេ។ ដូចព្រះដ៏មានព្រះភាគព្រះកស្សបៈ ប្រសូតិក្នុងមួយរំពេច ក៏ស្តេចទៅ ក៏ព្រះដ៏មានព្រះភាគអង្គនោះ ស្តេចទៅ យ៉ាងណា? ពិតណាស់ ព្រះដ៏មាន-ព្រះភាគអង្គនោះ ប្រសូតិក្នុងមួយរំពេចនោះឯង ប្រថាប់ឈរលើប្រថពីដោយព្រះយុគលបាទដ៏រាបស្មើ បែរព្រះភ័ក្ត្រទៅកាន់ទិសឧត្តរ ស្តេចទៅដោយឈានព្រះបាទ ៧ ជំហាន ដូចព្រះបាលីដែលត្រាស់ទុកថា ម្នាលអានន្ទ ព្រះពោធិ-សត្វប្រសូតិមួយរំពេចនោះ ក៏ប្រថាប់ឈរដោយព្រះយុគលបាទដ៏រាបស្មើ បែរព្រះភ័ក្ត្រទៅខាងទិសឧត្តរ ស្តេចទៅដោយឈានព្រះបាទ ៧ ជំហាន កាលស្តេចមហាព្រហ្មបាំងព្រះស្វេតឆត្រ ទ្រង់ក្រឡេកមើលទូទាំងទិស ទ្រង់បានបន្លឺអាសភិវាចាថា យើងជាច្បងក្នុងលោក យើងជាអ្នកចម្រើនបំផុតក្នុងលោក យើងជាអ្នកប្រសើរទីបំផុតក្នុងលោក ការកើតលើកនេះ ជាការកើតចុងក្រោយបង្អស់ ឥឡូវនេះភពថ្មីមិនមានតទៅទៀត ដូច្នេះ ។ និងការស្តេចទៅរបស់ព្រះដ៏មានព្រះភាគអង្គនោះ ក៏បានជាអាការដែលពិត មិនប្រែប្រួល ជាបុព្វ-និមិត្តនៃការសម្រេចគុណវិសេសច្រើនប្រការ គឺ ប្រការដែលព្រះអង្គប្រសូតិក្នុងមួយរំពេចនោះឯង ក៏បានប្រថាប់ឈរដោយព្រះយុគលបាទដ៏រាបស្មើ នេះជាបុព្វនិមិត្តនៃការបានឥទ្ធិបាទ ៤ របស់ព្រះអង្គ ។ មួយទៀត ការដែលព្រះអង្គ

បែរព្រះភ័ក្ត្រទៅខាងទិសឧត្តរ ជាបុព្វនិមិត្តនៃការប្រាកដលោកុត្តរធម៌ទាំងពួង ។ ការឈានព្រះបាទ ៧ ជំហាន ជាបុព្វនិមិត្តនៃការបានរតនៈ គឺ ពោជ្ឈង្គៈ ៧ ប្រការ ការបាំងព្រះស្វេតឆត្រ ជាបុព្វនិមិត្តនៃការបានស្វេតឆត្រដ៏បរិសុទ្ធិប្រសើរ គឺ ព្រះអរហត្តផលវិមុត្តិធម៌ ។ ការទតព្រះនេត្រក្រឡេកមើលទូទាំងទិស ជាបុព្វនិមិត្តនៃការបានព្រះអនាវរណញ្ញាណ គឺ ព្រះសព្វញ្ញុ ។ ការបន្លឺអាសភិវាចា ជាបុព្វនិមិត្តនៃការប្រកាសព្រះធម្មចក្កដ៏ប្រសើរ ដែលនរណាៗ ផ្លាស់ប្តូរមិនបាន ។ សូម្បីព្រះដ៏មានព្រះភាគព្រះអង្គនេះ ក៏ស្តេចទៅដូចយ៉ាងនោះ និងការស្តេចទៅរបស់ព្រះអង្គនោះ ក៏បានជាអាការដែលពិត មិនប្រែប្រួល ព្រោះជាបុព្វនិមិត្តនៃការសម្រេចគុណវិសេសទាំងនោះឯង ។

ព្រោះហេតុនោះ ព្រះបុរាណាចារ្យទាំងឡាយទើបពោលថា ៖

ព្រះគវម្បតីគោតមនោះ ប្រសូតិហើយមួយរំពេចនោះ ក៏ទ្រង់
សម្ទស្សផែនដីដោយព្រះយុគលបាទដ៏រាបស្មើ ស្តេចឈាន
ព្រះបាទទៅបាន ៧ ជំហាន និងពួកទេវតា ក៏បាំងដោយស្វេត-
ឆត្រ ព្រះគោតមនោះ គ្រាស្តេចទ្រង់ថ្លែងព្រះសូរសៀងប្រកប
ដោយអង្គ ៨ ប្រការ ប្រដូចរាជសីហ៍ ឈរលើកំពូលបពិត
ដូច្នោះ ។

ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះស្តេចទៅយ៉ាងនោះយ៉ាងនេះ ។

ន័យម្យ៉ាងទៀត ដូចព្រះដ៏មានព្រះភាគព្រះវិបស្សី ស្តេចទៅហើយ ។ល។ ព្រះដ៏មានព្រះភាគព្រះកស្សបៈស្តេចទៅហើយ យ៉ាងណា ព្រះដ៏មានព្រះភាគព្រះអង្គនេះ ក៏ដូចដូច្នោះ ទ្រង់លះបង់កាមច្ឆន្ទៈដោយនេក្ខម្មៈ ស្តេចទៅហើយ ទ្រង់លះបង់ព្យាបាទដោយសេចក្តីមិនព្យាបាទ ទ្រង់លះបង់ថីនមិទ្ធៈដោយអាលោកសញ្ញា ទ្រង់លះបង់ឧទ្ធច្ចកុក្កុច្ចៈដោយសេចក្តីមិនរាយមាយ ទ្រង់លះបង់វិចិកិច្ឆាដោយការកំណត់ធម៌ ស្តេចទៅហើយ ទ្រង់ទម្លាយអវិជ្ជាដោយព្រះប្រាជ្ញាញាណ ទ្រង់បន្ទោបង់សេចក្តីមិនត្រេកអរដោយសេចក្តីបាមោជ្ជៈ ទ្រង់បើកទ្វារ គឺ នីវរណៈដោយបឋមឈាន ទ្រង់ស្ងប់វិតក្កវិចារៈដោយទុតិយឈាន ទ្រង់នឿយណាយនឹងបីតិដោយតតិយឈាន ទ្រង់លះសុខទុក្ខដោយចតុត្ថឈាន ទ្រង់ឈានកន្លងរូបសញ្ញា បដិឃសញ្ញា និងនានត្តសញ្ញា ដោយអាកាសានញ្ចាយតនសមាបត្តិ ទ្រង់ឈានកន្លងអាកាសានញ្ចាយតនសញ្ញាដោយវិញ្ញាណញ្ចាយតនសមាបត្តិ ទ្រង់ឈានកន្លងវិញ្ញាណញ្ចាយតនសញ្ញា ដោយអាកិញ្ចញ្ញាយតនសមាបត្តិ ទ្រង់ឈានកន្លងអាកិញ្ចញ្ញាយតនសញ្ញា ដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិ ស្តេចទៅហើយ ។

ទ្រង់លះនិច្ចសញ្ញា ដោយអនិច្ចានុបស្សនា ទ្រង់លះសុខសញ្ញាដោយទុក្ខានុបស្សនា ទ្រង់លះអត្តសញ្ញាដោយអនត្តានុបស្សនា ទ្រង់លះនន្ទិ (សេចក្តីត្រេកត្រេន) ដោយនិព្វិទានុបស្សនា ទ្រង់លះរាគៈដោយវិរាគានុបស្សនា ទ្រង់លះសមុទ័យដោយនិរោធានុបស្សនា លះសេចក្តីប្រកាន់មាំដោយឧបសមានុបស្សនា ទ្រង់លះឃនសញ្ញា (សម្គាល់ថាជាដុំ) ដោយខយានុបស្សនា ទ្រង់លះអាយូហនា (ការប្រមូលមក) ដោយវយានុបស្សនា ទ្រង់លះធុវសញ្ញា (សម្គាល់ថាថិតថេរ) ដោយវិបរិណាមានុបស្សនា ទ្រង់លះនិមិត្តសញ្ញាដោយអនិមិត្តានុបស្សនា ទ្រង់លះការតាំងមាំនៃកិលេសដោយអប្បណិហិតានុបស្សនា ទ្រង់លះអភិនិវេស (ប្រកាន់មាំ) ដោយសុញ្ញតានុបស្សនា ទ្រង់លះសារាទានាភិនិវេសៈ (ប្រកាន់មាំដោយប្រកាន់ថាជាសារៈ) ដោយអធិប្បញ្ញាធម្មវិបស្សនា (ការឃើញច្បាស់ធម៌ដោយបញ្ញាដែលក្រៃលែង) ទ្រង់លះសម្មោហាភិនិវេស (ប្រកាន់មាំដោយសេចក្តីវង្វេង) ដោយយថាភូតញ្ញាណទស្សនៈ ទ្រង់លះអាលយាភិនិវេស (ប្រកាន់មាំក្នុងអាល័យ) ដោយអាទីនវានុបស្សនា លះអប្បដិសង្ខា (មិនពិចារណា) ដោយបដិសង្ខានុបស្សនា លះសំយោគាភិនិវេសៈ (ប្រកាន់មាំក្នុងការប្រកបកិលេស) ដោយវិវដ្ដានុបស្សនា ទ្រង់លះកិលេសដែលតាំងនៅក្នុងឋានៈតែមួយនឹងទិដ្ឋិ ដោយសោតាបត្តិមគ្គ ទ្រង់លះកិលេស

គ្រោតគ្រាត ដោយសកទាគាមិមគ្គ ទ្រង់ដកកិលេសយ៉ាងល្អិត ដោយអនាគាមិមគ្គ ទ្រង់កាត់កិលេសទាំងពួងបានដាច់ខាត ដោយអរហត្តមគ្គ ស្តេចទៅហើយ ។ ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះស្តេចទៅយ៉ាងនោះដូច្នេះ ។

ព្រះដ៏មានព្រះភាគទ្រង់ព្រះនាម **តថាគត** ព្រោះស្តេចមកដល់លក្ខណៈដែលពិត ដូចម្តេច? បឋវីធាតុមានលក្ខណៈរឹង ជាលក្ខណៈពិត មិនប្រែប្រួល អាបោធាតុមានលក្ខណៈហូរជ្រួតជ្រាប តេជោធាតុមានលក្ខណៈក្តៅ វាយោធាតុមានលក្ខណៈកម្រើកទៅមក អាកាសធាតុមានលក្ខណៈដែលពាល់ត្រូវមិនបាន វិញ្ញាណធាតុមានលក្ខណៈដឹងច្បាស់ រូបមានលក្ខណៈបែកធ្លាយ វេទនាមានលក្ខណៈសោយអារម្មណ៍ សញ្ញាមានលក្ខណៈចាំអារម្មណ៍ សង្ខារមានលក្ខណៈតាក់តែងអារម្មណ៍ វិញ្ញាណមានលក្ខណៈដឹងអារម្មណ៍ វិតក្កៈមានលក្ខណៈលើកចិត្តឡើងកាន់អារម្មណ៍ វិចារៈមានលក្ខណៈតាមព្រងៀលអារម្មណ៍ បីតិមានលក្ខណៈផ្សាយទៅ សុខមានលក្ខណៈសប្បាយ ឯកគ្គតាចិត្តមានលក្ខណៈមិនរវើរវាយ ផស្សៈមានលក្ខណៈពាល់ត្រូវអារម្មណ៍ សទ្ធិន្ទ្រិយមានលក្ខណៈបង្អោនចិត្តជឿ វិរិយិន្ទ្រិយ៍មានលក្ខណៈផ្គងទុក សតិន្ទ្រិយ៍មានលក្ខណៈប្រុងសមាធិន្ទ្រិយ៍មានលក្ខណៈមិនរវើរវាយ បញ្ញិន្ទ្រិយ៍មានលក្ខណៈដឹងច្បាស់ សទ្ធា-

ពលៈមានលក្ខណៈមិនញាប់ញ័រក្នុងសេចក្តីជឿ វីរិយពលៈមានលក្ខណៈមិនញាប់ញ័រក្នុងសេចក្តីខ្ជិលច្រអូស សតិពលៈមានលក្ខណៈមិនញាប់ញ័រក្នុងភាពជាអ្នកមិនមានសតិ សមាធិពលៈមានលក្ខណៈមិនញាប់ញ័រក្នុងសេចក្តីរវើរវាយ បញ្ញាពលៈមានលក្ខណៈមិនញាប់ញ័រក្នុងអវិជ្ជា សតិសម្ពោជ្ឈង្គៈមានលក្ខណៈប្រុង ធម្មវិចយសម្ពោជ្ឈង្គៈមានលក្ខណៈជ្រើសរើស វីរិយសម្ពោជ្ឈង្គៈមានលក្ខណៈផ្គង បីតិសម្ពោជ្ឈង្គៈមានលក្ខណៈផ្សាយទៅ បស្សទ្ធិសម្ពោជ្ឈង្គៈមានលក្ខណៈចូលទៅស្ងប់ សមាធិសម្ពោជ្ឈង្គៈមានលក្ខណៈមិនរវើរវាយ ឧបេក្ខាសម្ពោជ្ឈង្គៈមានលក្ខណៈពិចារណា សម្មាទិដ្ឋិមានលក្ខណៈឃើញ សម្មាសង្កប្បៈមានលក្ខណៈលើកចិត្តឡើងកាន់អារម្មណ៍ សម្មាវាចាមានលក្ខណៈកំណត់កាន់យក សម្មាកម្មន្តៈមានលក្ខណៈក្រោកឡើងព្រម សម្មាអាជីវៈមានលក្ខណៈផូរផង់ សម្មាវាយាមៈលក្ខណៈផ្គង សម្មាសតិមានលក្ខណៈប្រុង សម្មាសមាធិមានលក្ខណៈមិនរវើរវាយ អវិជ្ជាមានលក្ខណៈមិនដឹង សង្ខារមានលក្ខណៈគិតនឹក វិញ្ញាណមានលក្ខណៈដឹងអារម្មណ៍ នាមមានលក្ខណៈបង្អោនទៅ រូបមានលក្ខណៈបែកធ្លាយ សឡាយតនៈមានលក្ខណៈតគ្នា ផស្សៈមានលក្ខណៈពាល់ត្រូវអារម្មណ៍ វេទនាមានលក្ខណៈសោយអារម្មណ៍ តណ្ហាមានលក្ខណៈជាហេតុ ឧបាទានមានលក្ខណៈប្រកាន់ ភពមានលក្ខណៈប្រមូលមក ជាតិមាន

លក្ខណៈកើត ជរាមានលក្ខណៈទ្រុឌទ្រោម មរណៈមានលក្ខណៈចុតិទៅ ធាតុមានលក្ខណៈសូន្យ អាយតនៈមានលក្ខណៈតគ្នា សតិប្បដ្ឋានមានលក្ខណៈប្រុងសម្មប្បធានមានលក្ខណៈផ្ដើមតាំង ឥទ្ធិបាទមានលក្ខណៈសម្រេច ឥន្ទ្រិយមានលក្ខណៈជាធំ ពលៈមានលក្ខណៈមិនញាប់ញ័រ ពោជ្ឈង្គៈមានលក្ខណៈនាំចេញចាកទុក្ខ មគ្គមានលក្ខណៈជាតួហេតុ សច្ចៈមានលក្ខណៈជារបស់ពិត សមថៈមានលក្ខណៈមិនរវើរវាយ វិបស្សនាមានលក្ខណៈតាមឃើញ សមថៈនិងវិបស្សនាមានលក្ខណៈនៃកិច្ចតែមួយ ធម៌ដែលជាគូគ្នាមានលក្ខណៈមិនប្រែត្រឡប់ សីលវិសុទ្ធិមានលក្ខណៈសង្រួម ចិត្តវិសុទ្ធិមានលក្ខណៈមិនរវើរវាយ ទិដ្ឋិវិសុទ្ធិមានលក្ខណៈឃើញ ខយញ្ញាណ (សេចក្តីដឹងក្នុងការអស់ទៅ) មានលក្ខណៈកាត់ដាច់ អនុប្បាទញ្ញាណ (សេចក្តីដឹងក្នុងការមិនកើតឡើង) មានលក្ខណៈរម្ងាប់ ឆន្ទៈមានលក្ខណៈជាមូល មនសិការៈមានលក្ខណៈជាសមុដ្ឋានដែលកើតឡើង ផស្សៈមានលក្ខណៈជាទីរួមគ្នា វេទនាមានលក្ខណៈប្រជុំចុះ សមាធិលក្ខណៈជាប្រមុខ សតិមានលក្ខណៈជាអធិបតី បញ្ញាមានលក្ខណៈក្រៃលែងជាងនោះ វិមុត្តិមានលក្ខណៈជាសារៈ និព្វានដែលធ្លាក់ចុះកាន់អមតៈ មានលក្ខណៈជាទីបំផុត ជារបស់ពិត មិនប្រែប្រួល ឈ្មោះថា **តថាគត** ព្រោះស្ដេចមកដល់លក្ខណៈដែលពិតដោយញាណគតិ គឺ ចាក់ធ្លុះមិនឃ្លៀងឃ្លាត ដោយប្រការ

យ៉ាងនេះ ។ ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះស្ដេចមកដល់លក្ខណៈដែលពិត ដូច្នេះ ។

ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះត្រាស់ដឹងធម៌ដែលពិត តាមសេចក្ដីពិត ដូចម្ដេច? ឈ្មោះថា ធម៌ដែលពិត បានដល់ អរិយសច្ចៈ ៤ ។ ដូចដែលត្រាស់ទុកថា ភិក្ខុទាំងឡាយ អរិយសច្ចៈទាំង ៤ នេះ ជារបស់ពិត មិនខុស មិនក្លាយជាយ៉ាងដទៃ អរិយសច្ចៈ ៤ អ្វីខ្លះ? ភិក្ខុទាំងឡាយ ប្រការនេះថា នេះទុក្ខ នោះជារបស់ពិត មិនខុស មិនក្លាយជាយ៉ាងដទៃ ។ គប្បីជ្រាបសេចក្ដីពិស្ដារតទៅ ។ ក៏ព្រះដ៏មានព្រះភាគត្រាស់ដឹងដ៏ក្រៃលែងដោយព្រះអង្គឯង នូវអរិយសច្ចៈទាំង ៤ នោះ ព្រោះដូច្នោះ ទើបបានទទួលព្រះនាមថា **តថាគត** ព្រោះត្រាស់ដឹងធម៌ដែលពិត ក៏ **គត** សព្ទ ក្នុងទីនេះ មានការត្រាស់ដឹងដ៏ក្រៃលែងដោយព្រះអង្គឯង ជាអត្ថ ។

ម្យ៉ាងទៀត សភាវៈជរា និងមរណៈ ដែលកើត និងប្រជុំឡើង ព្រោះជាតិ ជាបច្ច័យ ជាសេចក្ដីពិត មិនប្រែប្រួល មិនជាយ៉ាងដទៃ ។ល។ សភាវៈសង្ខារទាំងឡាយកើត និងប្រជុំឡើង ព្រោះអវិជ្ជាជាបច្ច័យ ជាសេចក្ដីពិត មិនប្រែប្រួល មិនជាយ៉ាងដទៃ ។ សភាវៈអវិជ្ជា ជាបច្ច័យដល់សង្ខារទាំងឡាយក៏ដូចគ្នា សភាវៈដែលសង្ខារជាបច្ច័យដល់វិញ្ញាណ ។ល។ សភាវៈជាតិ ជាបច្ច័យ

ដល់ជរា និងមរណៈ , ជាសេចក្ដីពិត មិនប្រែប្រួល មិនជាយ៉ាងដទៃ ។ ព្រះដ៏មានព្រះភាគ ត្រាស់ដឹងធម៌ដែលពិតនោះទាំងអស់ ។ ព្រោះហេតុនោះ ទើបហៅថា **តថាគត** ព្រោះត្រាស់ដឹងក្រៃលែងដោយព្រះអង្គឯង នូវធម៌ដែលពិត ។ ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះត្រាស់ដឹងធម៌ដែលពិត តាមសេចក្ដីពិត ដូច្នេះ ។

ឈ្មោះថា **តថាគត** ព្រោះទ្រង់ឃើញអារម្មណ៍ដែលពិត ដូចម្ដេច ? ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដឹងរូបារម្មណ៍ ដោយអាការគ្រប់យ៉ាង ដែលមកប្រាកដផ្លូវចក្ខុទ្វារ របស់ពពួកសត្វរកប្រមាណមិនបាន ក្នុងលោកធាតុដែលរកប្រមាណមិនបាន ក្នុងលោកព្រមទាំងទេវលោក ក្នុងពពួកសត្វ ព្រមទាំងទេវតា និងមនុស្ស ។

រូបារម្មណ៍នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដឹងយ៉ាងនេះ ទ្រង់ចែកដោយអំណាចឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ជាដើមក្ដី ដោយអំណាចសណ្ឋាន , ដែលបានក្នុងការឃើញ បានឮ ជ្រាប និងដឹងច្បាស់ក្ដី ដោយឈ្មោះមិនមែនតិច ដោយវារៈ ១៣ ដោយន័យ ៥២ តាមន័យជាដើមថា រូបណា ព្រោះអាស្រ័យមហាភូតរូប ៤ មានពណ៌ និងពន្លឺ ឃើញបាន ប៉ះខ្ទប់បាន ជាពណ៌ខៀវ ពណ៌លឿង រូបនោះ គឺ រូបាយតនៈ ដូចម្ដេច ដូច្នេះ ជារបស់ពិតទាំង

នោះ មិនពិតមិនមាន ។ សូម្បីក្នុងសទ្ទារម្មណ៍ជាដើម ដែលមកប្រាកដ សូម្បីក្នុងសោតទ្វារជាដើម ក៏ន័យនេះ ។ សមពិតដូចពាក្យដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា ភិក្ខុទាំងឡាយ អារម្មណ៍ណា ដែលមនុស្សលោកព្រមដោយទេវលោក ។បេ។ ដែលពពួកសត្វព្រមដោយទេវតា និងមនុស្ស ឃើញហើយ បានស្តាប់ហើយ ជ្រាបហើយ ដឹងច្បាស់ហើយ ដល់ហើយ ស្វែងរកហើយ ពិចារណាហើយ រមែងដឹងអារម្មណ៍នោះ តថាគតដឹងដ៏ក្រៃលែងអារម្មណ៍នោះហើយដោយចិត្ត អារម្មណ៍នោះ តថាគតដឹងច្បាស់ហើយ អារម្មណ៍នោះប្រាកដដល់តថាគតហើយ ។ ឈ្មោះថា **តថាគត** ព្រោះទ្រង់ឃើញអាម្មរណ៍ដែលពិត ដោយប្រការដូច្នេះ ។ គប្បីជ្រាបការកើតនៃបទថា **តថាគត** (ទ្រង់ឃើញអារម្មណ៍ដែលពិត) ។

ឈ្មោះថា **តថាគត** ព្រោះមានព្រះវាចាដែលពិត ដូចម្តេច ?

រាត្រីណា ព្រះដ៏មានព្រះភាគ ប្រថាប់លើអបរាជិតបល្ល័ង្ក ត្រង់ពោធិមណ្ឌស្ថាន ទ្រង់ញាំញីកងទ័ពមារទាំង ៣ ត្រាស់ដឹងដ៏ក្រៃលែងនូវព្រះអនុត្តរសម្មាសម្ពោធិញ្ញាណ និងរាត្រីណា ស្តេចបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ នាចន្លោះដើមសាលៈទាំងគូ ក្នុងចន្លោះរាត្រីនោះ ក្នុងវេលាដែលព្រះអង្គមានវស្សាប្រមាណ ៤៥ ព្រះដ៏មានព្រះភាគ ត្រាស់ពុទ្ធវចនៈណា ក្នុងបឋម

ពោធិកាលខ្វះ មជ្ឈិមពោធិកាលខ្វះ បច្ឆិមពោធិកាលខ្វះ គឺ សុត្តៈ គេយ្យៈ ។ល។ វេទល្លៈ ព្រះពុទ្ធវចនៈទាំងអស់នោះ នរណាៗ តិះដៀលមិនបាន ទាំងដោយអត្ថ និងដោយព្យញ្ជនៈ មិនខ្វះមិនលើស មិនមានសេចក្តីខុសផ្គាត សូម្បីត្រឹមតែប៉ុនចុងរោមទ្រាយ ព្រះពុទ្ធវចនៈទាំងអស់នោះ ដូចប្រថាប់ទុកដោយត្រាតែមួយដូចគ្នា ដូចវាល់ដោយនាឡិតែមួយ និងដូចថ្លឹងដោយជញ្ជីងតែមួយ ទើបជារបស់ពិតប្រាកដទាំងអស់ មិនមែនមិនពិត ដោយហេតុនោះ ព្រះអង្គទើបត្រាស់ថា ម្នាលចុន្ទៈ តថាគតត្រាស់ដឹងដ៏ក្រៃលែងនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងរាត្រីណា និងបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុក្នុងរាត្រីណា ចន្លោះរាត្រីនោះ បានភាសិត បានពោល ចង្អុលបង្ហាញ ពាក្យនិយាយណា នោះជារបស់ពិតតែម្យ៉ាង មិនក្លាយជាយ៉ាងដទៃ ព្រោះដូច្នោះ ទើបហៅថា **តថាគត** ។ ពិតហើយ **គត** សព្ទ ក្នុងបទថា **តថាគតោ** នេះ មាន **គទ** ជាអត្ថ ។ ឈ្មោះថា **តថាគត** ព្រោះមានព្រះវាចាដែលពិត ដោយប្រការយ៉ាងនេះ ។ ម្យ៉ាងទៀត ការនិយាយ អធិប្បាយថា ការពោល ឈ្មោះថា **អាគទ** ។ ការត្រាស់របស់ព្រះអង្គពិត មិនវិបរិតិ ព្រោះហេតុនោះ ទើបឈ្មោះថា **តថាគត** ព្រោះផ្លាស់ ទ ជា ត ។ គប្បីជ្រាបការភ្ជាប់បទក្នុងអត្ថនោះ ដោយប្រការដូច្នេះឯង ។

ឈ្មោះថា **តថាគត** ព្រោះទ្រង់មានប្រក្រតីធ្វើដូចដែលត្រាស់ នោះដូចម្ដេច?

ព្រោះថា ព្រះកាយរបស់ព្រះដ៏មានព្រះភាគ រមែងអនុលោមដល់ព្រះវាចា សូម្បីព្រះវាចាក៏អនុលោមដល់ព្រះកាយ ព្រោះហេតុនោះ ព្រះអង្គត្រាស់យ៉ាងណា ក៏ទ្រង់ធ្វើយ៉ាងនោះ និងទ្រង់ធ្វើយ៉ាងណា ក៏ត្រាស់យ៉ាងនោះ ។ ក៏ព្រះវាចារបស់ព្រះអង្គដូច្នោះ ទ្រង់ត្រាស់យ៉ាងណា សូម្បីព្រះកាយក៏ទៅយ៉ាងនោះ អធិប្បាយថា ដំណើរទៅយ៉ាងនោះ ។ មួយទៀត ព្រះកាយទ្រង់ធ្វើយ៉ាងណា សូម្បីព្រះវាចាក៏ត្រាស់ដូច្នោះ ព្រោះហេតុនោះ ទើបឈ្មោះថា **តថាគត** ។ ព្រោះហេតុនោះឯង ព្រះដ៏មានព្រះភាគទើបត្រាស់ថា ភិក្ខុទាំងឡាយ តថាគតនិយាយយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណាក៏និយាយយ៉ាងនោះ ព្រោះដូច្នោះទើបហៅថា **តថាគត** ។ ឈ្មោះថា **តថាគត** ព្រោះទ្រង់មានប្រក្រតីធ្វើតាមដែលត្រាស់នោះ ដោយប្រការដូច្នេះ ។

ឈ្មោះថា **តថាគត** ព្រោះអត្ថគ្របសង្កត់បាន ដូចម្ដេច?

ព្រោះព្រះអង្គទ្រង់គ្របសង្កត់ សត្វទាំងពួងក្នុងលោកធាតុរកប្រមាណមិនបាន ខាងលើដល់ភវគ្គព្រហ្ម ខាងក្រោមដល់អវិចីមហានរក ខាងទទឹងកំណត់ទីបំផុតដោយជុំវិញ ដោយសីលខ្វះ សមាធិខ្វះ បញ្ញាខ្វះ វិមុត្តិខ្វះ ព្រះអង្គមិន

មានការថ្លឹង ឬការរាប់ ព្រះអង្គថ្លឹងមិនបាន រាប់មិនបាន ទ្រង់ជាកំពូល ជាព្រះរាជានៃព្រះរាជា ជាទេពនៃទេព ជាសក្កៈកំពូលនៃពួកសក្កៈ ជាព្រហ្មកំពូលនៃពួកព្រហ្ម ដោយហេតុនោះ ព្រះអង្គទើបត្រាស់ថា ភិក្ខុទាំងឡាយ តថាគតជាអ្នកគ្របសង្កត់ ពួកសត្វក្នុងលោក ព្រមទាំងទេវលោក ។បេ។ ព្រមទាំងទេវតា និងមនុស្ស ដែលនរណាៗ គ្របសង្កត់មិនបាន ជាអ្នកឃើញដោយពិតធ្វើឲ្យអ្នកដទៃនៅក្នុងអំណាច ព្រោះដូច្នោះ ទើបហៅថា **តថាគត** ។ គប្បីជ្រាបបទសន្និដ្ឋានក្នុងពាក្យថា **តថាគតោ** នោះ យ៉ាងនេះ ៖

ការត្រាស់ (គប្បីឃើញ) ដូចថ្នាំដ៏ប្រសើរ ។ ក៏ការត្រាស់នោះ គឺអ្វី? គឺ ភាពស្រស់ល្អនៃទេសនា និងការកពូនឡើងនៃបុណ្យ ។ ព្រោះហេតុនោះឯងព្រះអង្គ ទើបទ្រង់គ្របសង្កត់បុគ្គលដែលជាបរប្បវាទទាំងអស់ និងសត្វលោកព្រមទាំងទេវលោក ដូចគ្រូចាប់ពស់មានអំណាចច្រើន គ្របសង្កត់ពស់ទាំងឡាយដោយថ្នាំទិព្វ ដូច្នោះ ។ ដូចនោះ ព្រះអង្គមានការត្រាស់ គឺ សេចក្តីស្រស់ល្អនៃទេសនា និងការកពូនឡើងនៃបុណ្យ ដែលពិត មិនវិបរិត្ត ព្រោះទ្រង់គ្របសង្កត់សត្វលោកបាន ព្រោះហេតុនោះ គប្បីជ្រាបថា **តថាគត** ព្រោះផ្លាស់ ទ អក្សរជា ត អក្សរ ។ ឈ្មោះថា **តថាគត** ព្រោះអត្ថថា ទ្រង់គ្របសង្កត់ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ឈ្មោះថា **តថាគត** ព្រោះស្ដេចទៅដោយសេចក្ដីពិត ។ ព្រោះទ្រង់ដល់នូវសេចក្ដីពិត ដូច្នេះក៏មាន ។ អធិប្បាយថា ត្រាស់ដឹង ទ្រង់កន្លងហើយ ទ្រង់ចាក់ធ្លុះ ទ្រង់ដំណើរទៅ ។ ក្នុងបណ្ដាពាក្យទាំងនោះ ឈ្មោះថា **តថាគត** ព្រោះស្ដេចទៅ គឺ ត្រាស់ដឹងលោកទាំងអស់ដោយសេចក្ដីពិត គឺ តីរណបរិញ្ញា ។ ឈ្មោះថា **តថាគត** ព្រោះស្ដេចទៅ គឺ ទ្រង់កន្លងលោកសមុទ័យដោយសេចក្ដីពិត គឺ បហានបរិញ្ញា ។ ឈ្មោះថា **តថាគត** ព្រោះស្ដេចទៅ គឺ សម្រេចការរលត់ស្និទនៃលោក ដោយសេចក្ដីពិត គឺ សច្ឆិកិរិយា ។ ឈ្មោះថា **តថាគត** ព្រោះស្ដេចទៅ គឺ ដំណើរទៅកាន់សេចក្ដីពិត គឺ បដិបទាដែលញុំាងសត្វឲ្យដល់សេចក្ដីរលត់លោក ។ ដោយហេតុនោះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លោកដែលតថាគតត្រាស់ដឹងដ៏ក្រៃលែងហើយ តថាគតមិនបានប្រកបក្នុងលោក ម្នាលភិក្ខុទាំងឡាយ លោកសមុទ័យ តថាគតត្រាស់ដឹងដ៏ក្រៃលែងហើយ លោកសមុទ័យ តថាគតលះបានហើយ ម្នាលភិក្ខុទាំងឡាយ លោកនិរោធ ដែលតថាគតបានត្រាស់ដឹងដ៏ក្រៃលែងហើយ លោកនិរោធនោះតថាគតបានធ្វើឲ្យជាក់ច្បាស់ហើយ ម្នាលភិក្ខុទាំងឡាយ លោកនិរោធគាមិនី-បដិបទា ដែលតថាគតត្រាស់ដឹងដ៏ក្រៃលែងហើយ ចម្រើនហើយ ម្នាលភិក្ខុទាំងឡាយ សច្ចៈណានៃលោក ព្រមទាំងទេវលោក ។ល។ សច្ចៈទាំងអស់

តថាគតត្រាស់ដឹងដ៏ក្រៃលែងហើយ ព្រោះដូច្នោះ ទើបហៅថា **តថាគត** ។ អត្ថនៃពាក្យថា **តថាគត** នោះ បណ្ឌិតគប្បីជ្រាបសូម្បីដោយប្រការយ៉ាងនេះ ។ សូម្បីពាក្យនេះ ក៏មានត្រឹមតែជាលំនាំផ្លូវក្នុងការសម្ដែងសេចក្ដីរបស់ព្រះតថាគតដែលជាតថាគត ។ ព្រះតថាគតប៉ុណ្ណោះ ទើបនឹងពណ៌នា ភាវៈដែលតថាគតជាតថាគតបាន សព្វគ្រប់ប្រការ ។

ក៏ក្នុង ២ បទថា **អរហំ សម្មាសម្ពុទ្ធោ** ជាដំបូង គប្បីជ្រាបថា **អរហំ** ដោយហេតុទាំងនេះ គឺ ព្រោះជាអ្នកឆ្ងាយចាកសត្រូវ គឺ កិលេស ព្រោះជាអ្នកកាច់បំបាក់កាំកង់នៃសង្សារចក្រចេញបាន ព្រោះគួរដល់សក្ការៈ មានបច្ច័យជាដើម និងព្រោះមិនមានសេចក្ដីកំបាំងក្នុងការធ្វើអាក្រក់ ។ ចំណែកដែលឈ្មោះថា **សម្មាសម្ពុទ្ធៈ** ព្រោះត្រាស់ដឹងធម៌ទាំងពួងដោយប្រពៃ និងដោយព្រះអង្គឯង ។ ការសង្ខេបក្នុងសេចក្ដីនេះ មានប៉ុណ្ណេះ ។ ទាំង ២ បទនេះ ពោលទុកដោយពិស្ដារក្នុងការពណ៌នាពុទ្ធានុស្សតិ ក្នុងគម្ពីរវិសុទ្ធិមគ្គនោះឯង ។

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

ក្នុងសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖

[១៤០] បទថា **បាតុភាវោ** បានដល់ ការកើតឡើង គឺ ការសម្រេច ។ បទថា **ទុល្លភោ លោកស្មឹ** បានដល់ រកបានលំបាក គឺ រកបានដោយលំបាកក្រៃលែង ក្នុងសត្វលោកនេះ ។ ដែលឈ្មោះថា បានលំបាក ព្រោះហេតុអ្វី? ព្រោះព្រះអង្គមិនអាចបំពេញទានបារមីតែមួយ ហើយបានត្រាស់ជាព្រះពុទ្ធ ។ មួយទៀត ព្រះអង្គទ្រង់មិនមែនបំពេញទានបារមី ២ ដង ១០ ដង ២០ ដង ៥០ ដង ១០០ ដង ១.០០០ ដង កោដិដង សែនកោដិដង ទ្រង់មិនមែនបំពេញទានបារមីបាន ១ ថ្ងៃ ២ ថ្ងៃ ១០ ថ្ងៃ ២០ ថ្ងៃ ៥០ ថ្ងៃ ១០០ ថ្ងៃ ១.០០០ ថ្ងៃ ១០០.០០០ ថ្ងៃ សែនកោដិថ្ងៃ ។ល។ ១ ខែ ១ ឆ្នាំ ២ ឆ្នាំ ។ល។ សែន-កោដិឆ្នាំ ១ កប្ប ២ កប្ប ។ល។ សែនកោដិកប្ប ព្រះអង្គមិនមែនបំពេញទានបារមី ១ អសង្ខេយ្យ ២ អសង្ខេយ្យ ៣ អសង្ខេយ្យ នៃកប្ប ហើយត្រាស់ជាព្រះពុទ្ធបាន សូម្បីក្នុងសីលបារមី នេក្ខម្មបារមី ។ល។ ឧបេក្ខាបារមី ក៏ន័យនេះដូចគ្នា ។ តែគ្រាចុងក្រោយ ព្រះអង្គទ្រង់បំពេញបារមី ១០ អស់ ៤ អសង្ខេយ្យកម្រៃសែនកប្ប ហើយទើបត្រាស់ជាព្រះពុទ្ធបាន ដោយហេតុដូចពោលមកនេះ ព្រះអង្គទើបឈ្មោះថា **រកបានលំបាក** ។

ចប់អដ្ឋកថា សូត្រទី ២

# អដ្ឋកថាសូត្រទី ៣

ក្នុងសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖

[១៨១] បទថា **អច្ឆរិយមនុស្សោ** ប្រែថា មនុស្សអស្ចារ្យ ។

បទថា **អច្ឆរិយោ** សេចក្តីថា មិនមានជានិច្ច ដូចមនុស្សភ្នែកខ្វាក់ឡើងភ្នំ ។ ន័យនៃសព្ទប៉ុណ្ណេះមុន តែន័យនៃអដ្ឋកថា មានដូចតទៅនេះ ។ ឈ្មោះថា **អច្ឆរិយៈ** ព្រោះគួរដល់ការទះដៃ ។ អធិប្បាយថា គួរទះដៃហើយសម្លឹងមើល ។

មួយវិញទៀត ឈ្មោះថា **មនុស្សអស្ចារ្យ** ព្រោះប្រកបដោយធម៌ដែលមិនធ្លាប់មាន គួរអស្ចារ្យច្រើនប្រការ មានជាដើមយ៉ាងនេះថា ភិក្ខុទាំងឡាយ ធម៌ដែលមិនធ្លាប់មាន គួរអស្ចារ្យ ៤ ប្រការ រមែងមានប្រាកដ ព្រោះព្រះតថាគតអរហន្តសម្មាសម្ពុទ្ធប្រាកដ ។ ឈ្មោះថា **អច្ឆរិយមនុស្ស** ព្រោះជាមនុស្សដែលធ្លាប់សន្សំមក ក៏មាន ។

ពិតហើយ ការដែលព្រះអង្គទ្រង់ប្រជុំធម៌ ៨ ប្រការ ដែលនឹងធ្វើឲ្យអភិនីហារប្រកបព្រម ហើយទ្រង់ចងព្រះមនសៈប្រថាប់អង្គុយត្រង់មហាពោធិមណ្ឌស្ថាន ចំពោះព្រះភ័ក្ត្រនៃព្រះពុទ្ធព្រះអង្គមួយ បុគ្គលដទៃទៀតណាៗ មិនធ្លាប់បានសន្សំមកឡើយ ព្រះសព្វញ្ញុពោធិសត្វព្រះអង្គតែមួយប៉ុណ្ណោះ សន្សំ

មក ៗ មួយទៀត សូម្បីព្រះអង្គ បានទទួលព្យាករណ៍ក្នុងសម្នាក់ព្រះពុទ្ធទាំងឡាយជាអ្នកមិនវិលត្រឡប់ អធិដ្ឋានសេចក្ដីព្យាយាម និងបំពេញពុទ្ធការកធម៌ បុគ្គលដទៃណាៗ មិនបានធ្លាប់សន្សំមកឡើយ ព្រះសព្វញ្ញូពោធិសត្វប៉ុណ្ណោះធ្លាប់សន្សំមក ៗ មួយទៀត ព្រះអង្គទ្រង់បំពេញព្រះបារមីឲ្យចាស់ក្លា (ញុំាងព្រះបារមីឲ្យកាន់យកបន្ទប់) តាំងនៅក្នុងអត្តភាព ដូចសោយព្រះជាតិជាព្រះ-វេស្សន្តរ បំពេញសត្តសតកមហាទាន (៧ វត្ថុ វត្ថុមួយៗ ៧០០) មានជាដើមយ៉ាងនេះ គឺ ដំរី ៧០០ សេះ ៧០០ ប្រដាប់ដោយគ្រឿងអលង្ការគ្រប់សព្វប្រគល់ព្រះឱរស ដូចព្រះជាលីកុមារ ព្រះធីតា ដូចកណ្ហជិនា និងព្រះទេវីដូចព្រះនាងមទ្រី ទុកក្នុងមុខនៃទាន តាំងនៅរហូតអស់អាយុ ក្នុងអត្តភាពទី ២ ទ្រង់បដិសន្ធិក្នុងភពជាន់តុសិត ដែលបុគ្គលដទៃណាៗ មិនបានធ្លាប់សន្សំមកឡើយ ព្រះសព្វញ្ញូពោធិសត្វប៉ុណ្ណោះ ធ្លាប់សន្សំមក ៗ សូម្បីព្រះអង្គទ្រង់តាំងនៅក្នុងភពជាន់តុសិតរហូតដល់អស់អាយុ ទ្រង់ទទួលការអារាធនារបស់ទេវតាទាំងឡាយ ទ្រង់ត្រួតមើលមហាវិលោកិតៈ ៥ យ៉ាង ទ្រង់មានព្រះសតិនិងសម្បជញ្ញៈ ចុតិចាកពីតុសិត បដិសន្ធិក្នុងត្រកូលដែលមានភោគៈច្រើន ដែលបុគ្គលដទៃណាៗ មិនបានធ្លាប់សន្សំមកឡើយ ព្រះសព្វញ្ញូពោធិសត្វប៉ុណ្ណោះ ធ្លាប់សន្សំមក ៗ មួយទៀត មុនលោកធាតុញាប់ញ័រក្នុងថ្ងៃបដិសន្ធិក្ដី

ការដែលព្រះអង្គទ្រង់មានព្រះសតិសម្បជញ្ញៈនៅក្នុងគភ៌របស់ព្រះមាតាក្តី ការដែលម៉ឺនលោកធាតុញាប់ញ័រ សូម្បីក្នុងថ្ងៃដែលព្រះអង្គ ទ្រង់មានព្រះសតិ-សម្បជញ្ញៈ ស្តេចចេញចាកព្រះគភ៌របស់ព្រះមាតាក្តី ការដែលព្រះអង្គប្រសូតិក្នុងឥឡូវនេះ ហើយស្តេចឈានព្រះបាទបាន ៧ ជំហានក្តី ការបាំងស្វេតឆត្រដែលជាទិព្វក្តី ការបក់ដោយផ្លិតវាលវិជនីដែលជាទិព្វក្តី ការដែលព្រះអង្គទ្រង់ក្រឡេកមើលដូចជាសីហៈទៅក្នុងទិសទាំង ៤ ទ្រង់មិនឃើញសត្វណាៗ ដែលនឹងស្មើដូចព្រះអង្គ ហើយទ្រង់បន្លឺសីហនាទយ៉ាងនេះថា យើងជាអ្នកប្រសើរបំផុតរបស់លោកក្តី ការដែលម៉ឺនលោកធាតុញាប់ញ័រ ក្នុងខណៈដែលព្រះអង្គទ្រង់លះរាជសម្បត្តិ កាលព្រះញាណចាស់ក្លា ហើយស្តេចចេញសាងមហា-ភិនេសក្រមណ៍ក្តី ការដែលព្រះអង្គប្រថាប់អង្គុយក្នុងមហាពោធិមណ្ឌស្ថាន ទ្រង់ឈ្នះមារជាដើម ហើយទ្រង់ជម្រះបុព្វេនិវាសានុស្សតិញ្ញាណ និងទិព្វចក្ខុញ្ញាណ ទ្រង់ធ្វើម៉ឺនលោកធាតុឲ្យញាប់ញ័រ ខណៈទ្រង់ត្រាស់ដឹងគំនរគុណ គឺ ព្រះ-សព្វញ្ញុតញ្ញាណក្នុងវេលាជិតភ្លឺក្តី ការប្រកាសព្រះធម្មចក្រដ៏កំពូល ដែលមានបរិវដ្តៈ ៣ ដោយបឋមទេសនាក្តី សេចក្តីអស្ចារ្យទាំងអស់ ដូចពោលមកនេះជាដើម បុគ្គលដទៃណាៗ មិនបានធ្លាប់សន្សំមកឡើយ ព្រះសព្វញ្ញុពុទ្ធប៉ុណ្ណោះធ្លាប់សន្សំមក ។ ឈ្មោះ **មនុស្សអស្ចារ្យ** ព្រោះជាមនុស្សធ្លាប់សន្សំមក ដូច្នេះ

ខ្វះ ដោយប្រការយ៉ាងនេះ ។

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថាសូត្រទី ៤

ក្នុងសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖

[១៤២] បទថា **កាលកិរិយា** សេចក្តីថា ឈ្មោះថា កាលកិរិយា ព្រោះកិរិយាដែលប្រាកដក្នុងកាលមួយ ៗ ពិតណាស់ ព្រះតថាគត ទ្រង់តាំងនៅ ៤៥ វស្សា ទ្រង់ប្រកាសបិដក ៣ និកាយ ៥ សត្ថុសាសនៈមានអង្គ ៩ ព្រះធម្មក្ខន្ធ ៨៤.០០០ ព្រះធម្មក្ខន្ធ ទ្រង់ធ្វើមហាជន ឲ្យបង្អោនទៅក្នុងព្រះនិព្វាន ទោរទៅក្នុងព្រះនិព្វាន ផ្ទំចន្លោះដើមសាលៈទាំងគូ ត្រាស់ហៅភិក្ខុសង្ឃមក ទ្រង់ឱវាទដោយសេចក្តីមិនប្រមាទ ទ្រង់មានព្រះសតិសម្បជញ្ញៈ ស្តេចបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ កាលកិរិយានេះ របស់ព្រះតថាគតនោះ ប្រាកដមកដរាបដល់សព្វថ្ងៃនេះ ព្រោះហេតុនោះ ទើបឈ្មោះថា **កាលកិរិយា** ព្រោះជាកិរិយាដែលប្រាកដក្នុងវេលាមួយ ៗ បទថា **អនុតប្បា ហោតិ** ប្រែថា ធ្វើសេចក្តីក្តៅក្រហាយតាម (ក្រោយ) ៗ ក្នុងសេចក្តីនោះ កាលកិរិយារបស់ស្តេចចក្រពត្តិ ធ្វើសេចក្តីក្តៅក្រហាយតាម ដល់ទេវតា និងមនុស្សក្នុងចក្រវាឡមួយ ៗ កាលកិរិយារបស់ព្រះពុទ្ធទាំងឡាយ ធ្វើសេចក្តីក្តៅក្រហាយតាម ដល់ទេវតា និងមនុស្សទាំងឡាយក្នុងម៉ឺនចក្រវាឡ ដោយហេតុនោះ ទើបត្រាស់ថា ធ្វើសេចក្តីក្តៅក្រហាយតាម ដល់ជនច្រើន ដូច្នេះ ។

ចប់អដ្ឋកថា សូត្រទី ៤

# អដ្ឋកថាសូត្រទី ៥

*ក្នុងសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[១៨៣] *បទថា* ***អទុតិយោ*** *សេចក្តីថា ដែលឈ្មោះថា* ***អទុតិយោ*** *ព្រោះមិនមានព្រះពុទ្ធអង្គទី ២ ។ ពិតណាស់ ព្រះពុទ្ធ មាន ៤ គឺ សុតពុទ្ធៈ ចតុសច្ចពុទ្ធៈ បច្ចេកពុទ្ធៈ សព្វញ្ញុពុទ្ធៈ ។ ក្នុងពុទ្ធៈ ៤ នោះ ភិក្ខុដែលជាពហុស្សូត (មានពុទ្ធវចនៈដែលស្តាប់ច្រើនហើយ) ឈ្មោះថា* ***សុតពុទ្ធៈ*** *។ ភិក្ខុជាព្រះខីណាស្រព (មានអាសវៈអស់ហើយ) ឈ្មោះថា* ***ចតុសច្ចពុទ្ធៈ*** *។ ព្រះសម្ពុទ្ធដែលបំពេញបារមីពីរអសង្ខេយ្យ៍ កម្រៃសែនកប្ប ហើយត្រាស់ដឹងបច្ចេកពុទ្ធញាណ ឈ្មោះថា* ***បច្ចេកពុទ្ធៈ*** *។ ព្រះសម្ពុទ្ធបំពេញបារមី ៤-៨-១៦ អសង្ខេយ្យកម្រៃសែនកប្ប ហើយញាំញីកងទ័ពមារទាំង ៣ ត្រាស់ដឹងព្រះសព្វញ្ញុតញ្ញាណ ឈ្មោះថា* ***សព្វញ្ញុពុទ្ធៈ*** *។ ក្នុងពុទ្ធទាំង ៤ នេះ ព្រះសព្វញ្ញុពុទ្ធ ឈ្មោះថា មិនមានព្រះពុទ្ធអង្គទី ២ ធម្មតាថា ព្រះសព្វញ្ញុពុទ្ធអង្គដទៃនឹងស្តេចឧប្បត្តិរួមជាមួយព្រះសព្វញ្ញុពុទ្ធព្រះអង្គនោះមិនមាន ។*

*បទថា* ***អសហាយោ*** *សេចក្តីថា ឈ្មោះថា មិនមានសម្លាញ់ ព្រោះលោកមិនមានសម្លាញ់ដូចគ្នានឹងអត្តភាព ឬដោយធម៌ដែលទ្រង់ត្រាស់ដឹងហើយ ។ ក៏ព្រះសេក្ខៈ និងព្រះអសេក្ខៈ ឈ្មោះថា ជាសម្លាញ់របស់ព្រះពុទ្ធទាំងឡាយ*

ដោយបរិយាយនេះថា ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បានសេក្ខប្បដិបទា និង អសេក្ខប្បដិបទាជាសម្មាញ់នោះឯង ។

បទថា **អប្បដិមោ** (មិនមានបុគ្គលប្រៀប) សេចក្តីថា អត្តភាពហៅថា រូបប្រៀប ។ ឈ្មោះថា មិនមានបុគ្គលប្រៀប ព្រោះរូបដទៃប្រៀបដូចនឹងអត្ត-ភាពរបស់ព្រះអង្គមិនមាន ។ម្យ៉ាងទៀត មនុស្សទាំងឡាយធ្វើរូបប្រៀបណា សុទ្ធដោយមាស និងប្រាក់ជាដើម ក្នុងបណ្តារូបប្រៀបទាំងនោះ ឈ្មោះថា បុគ្គលអាចធ្វើឱកាសសូម្បីត្រឹមតែប៉ុនចុងរោមទ្រាយ ឲ្យដូចអត្តភាពរបស់ព្រះ តថាគត រមែងមិនមាន ព្រោះហេតុនោះ ទើបឈ្មោះថា មិនមានអ្នកប្រៀប សូម្បីដោយប្រការទាំងពួង ។ បទថា **អប្បដិសមោ** (មិនមានអ្នកធៀប) សេចក្តីថា ឈ្មោះថា មិនមានអ្នកធៀប ព្រោះនរណាៗ ឈ្មោះថា នឹងធៀប ជាមួយអត្តភាពរបស់ព្រះតថាគតនោះ មិនមាន ។

បទថា **អប្បដិភាគោ** (មិនមានអ្នកផ្ទឹម) សេចក្តីថា ឈ្មោះថា មិនមាន បុគ្គលផ្ទឹម ព្រោះធម៌ពួកណាដែលព្រះតថាគតទ្រង់សម្តែងទុក ដោយន័យមាន ជាដើមថា សតិប្បដ្ឋានមាន ៤ ដែលឈ្មោះថា បុគ្គលអាចដើម្បីនឹងផ្ទឹមក្នុង ធម៌ទាំងនោះ ដោយន័យមានជាដើមថា **ន ចត្តារោ សតិបដ្ឋានា តយោ វា បញ្ច វា** (សតិប្បដ្ឋានមិនមែន ៤ សតិប្បដ្ឋានមាន ៣ ឬ ៥) ។ បទថា

**អប្បដិបុគ្គលោ** (មិនមានបុគ្គលប្រណាំងប្រជែង) សេចក្តីថា ឈ្មោះថា មិនមានបុគ្គលប្រណាំងប្រជែង ព្រោះមិនមានបុគ្គលដទៃណាៗ ឈ្មោះថា អាចដើម្បីឲ្យប្តេជ្ញាយ៉ាងនេះថា យើងជាព្រះពុទ្ធ ដូច្នេះ ។

បទថា **អសមោ** (មិនមានអ្នកស្មើ) សេចក្តីថា ឈ្មោះថា បុគ្គលមិនស្មើដោយសត្វទាំងពួង ព្រោះមិនមានបុគ្គលផ្ទឹមទ្ទឹមនុ៎ះឯង ។ បទថា **អសមសមោ** (បុគ្គលស្មើនឹងបុគ្គលដែលមិនមានអ្នកណាស្មើ) សេចក្តីថា ព្រះសព្វញ្ញុពុទ្ធទាំងឡាយដែលជាអតីត និងអនាគត លោកហៅថា មិនមានអ្នកស្មើ បុគ្គលស្មើដោយព្រះសព្វញ្ញុពុទ្ធដែលមិនមាននរណាៗ ស្មើនោះ ព្រោះដូច្នោះ ទើបឈ្មោះថា អ្នកស្មើនឹងបុគ្គលដែលមិនមានបុគ្គលណាស្មើ ។

បទថា **ទ្វិបទានំ អគ្គោ**[១] សេចក្តីថា ព្រះសម្មាសម្ពុទ្ធ ជាកំពូលនៃពួកសត្វដែលមិនមានជើង មានជើង ២ មានជើង ៤ មានជើងច្រើន សត្វដែលមានរូប មិនមានរូប មានសញ្ញា មិនមានសញ្ញា មានសញ្ញាក៏មិនមែនមិនមានសញ្ញាក៏មិនមែន ។ ព្រោះហេតុណា ក្នុងទីនេះ លោកទើបពោលថា ជាកំពូលនៃពួកសត្វជើង ២ ? ព្រោះព្រះអង្គជាបុគ្គលប្រសើរជាង ។ ពិតហើយធម្មតាថា បុគ្គលដែលប្រសើរ កាលនឹងឧប្បត្តិក្នុងលោកនេះ មិនឧប្បត្តិក្នុង

---

(១) បិដក = ទិបទានំ អគ្គោ ។

សត្វមានជើង ៤ និងមានជើងច្រើនទេ រមែងឧប្បត្តិចំពោះក្នុងសត្វមានជើង ២ ប៉ុណ្ណោះ ។ ក្នុងសត្វជើង ២ ប្រភេទណា? ក្នុងមនុស្ស និងទេវតាទាំងឡាយ ។ ក៏កាលស្តេចឧប្បត្តិក្នុងពួកមនុស្ស រមែងឧប្បត្តិជាព្រះពុទ្ធ ដែលអាចដើម្បីធ្វើ ៣.០០០ លោកធាតុ និងច្រើនពាន់លោកធាតុ ឲ្យនៅក្នុងអំណាចបាន ។ កាលឧប្បត្តិក្នុងពួកទេវតា រមែងឧប្បត្តិជាស្តេចមហាព្រហ្ម ដែលធ្វើម៉ឺនលោកធាតុឲ្យនៅក្នុងអំណាចបាន ។ ស្តេចមហាព្រហ្មនោះ ព្រមទាំងកប្បិយការកៈ ឬជាអារាមិកៈរបស់ព្រះអង្គ ដូចនោះ លោកទើបហៅថា ជាកំពូលនៃសត្វជើង ២ ដោយអំណាចជាបុគ្គលប្រសើរជាងមនុស្ស និងទេវតា នោះឯង ។

ចប់អដ្ឋកថា សូត្រទី ៥

# អដ្ឋកថាសូត្រទី ៦ ជាដើម

ក្នុងសូត្រទី ៦ ជាដើម មានវិនិច្ឆ័យដូចតទៅនេះ ៖

[១៨៤] បទថា **ឯកបុគ្គលស្ស ភិក្ខវេ បាតុភាវា មហតោ ចក្ខុស្ស បាតុភាវោ ហោតិ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ចក្ខុធំរមែងប្រាកដ ព្រោះព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ជាបុគ្គលឯក ប្រាកដ ។ កាលបុគ្គលនោះប្រាកដហើយ សូម្បីចក្ខុក៏រមែងប្រាកដដូចគ្នា ព្រោះវៀរបុគ្គលប្រាកដចេញ ចក្ខុក៏ប្រាកដមិនបាន ។ បទថា **បាតុភាវោ** បានដល់ ការឧប្បត្តិ គឺ សេចក្តីសម្រេច ។ ចក្ខុប្រភេទណា? ចក្ខុ គឺ បញ្ញា ។ ប្រដូចអ្វី? ដូចវិបស្សនាបញ្ញារបស់ព្រះសារីបុត្តត្ថេរៈ ដូចសមាធិប្បញ្ញា របស់ព្រះមហាមោគ្គល្លានត្ថេរៈ ។ សូម្បីក្នុងអាលោកៈ (ការឃើញ) ជាដើម ក៏ន័យនេះដូចគ្នា ។ ពិតណាស់ក្នុងការមើលឃើញជាដើមនេះ លោកបំណងយកអាការមើលឃើញ ដូចការមើលឃើញដោយបញ្ញា និងពន្លឺ ដូចពន្លឺនៃបញ្ញារបស់ព្រះអគ្គសាវកទាំងពីរ ។ បទសូម្បីទាំង ៣ នេះ គឺ នៃកែវភ្នែកដ៏ធំ នៃការមើលឃើញដ៏ធំ នៃពន្លឺដ៏ធំ គប្បីជ្រាបថា ត្រាស់លាយគ្នាទាំងលោកិយៈ និងលោកុត្តរៈ ។

បទថា **ឆន្នំ អនុត្តរិយានំ** បានដល់ ធម៌ដែលខ្ពស់បំផុត ៦ យ៉ាង ដែលមិនមានធម៌ដទៃក្រៃលែងជាង ក្នុងពាក្យនោះមានអធិប្បាយថា អនុត្តរិយៈ

ទាំង ៦ នេះ គឺ ទស្សនានុត្តរិយៈ សវនានុត្តរិយៈ លាភានុត្តរិយៈ សិក្ខា-
នុត្តរិយៈ បារិចរិយានុត្តរិយៈ អនុស្សតានុត្តរិយៈ ។ សេចក្ដីប្រាកដកើតឡើង
នៃអនុត្តរិយៈទាំង ៦ នេះ ទើបមាន ។ ពិតណាស់ ព្រះអានន្ទត្ថេរៈ រមែងបាន
ឃើញព្រះតថាគតដោយចក្ខុវិញ្ញាណទាំងព្រឹកទាំងល្ងាច នេះឈ្មោះថា ទស្ស-
នានុត្តរិយៈ ។ សូម្បីបុគ្គលដទៃ មិនថាជា ព្រះសោតាបន្ន ព្រះសកទាគាមី
ព្រះអនាគាមី ក៏រមែងបានឃើញព្រះតថាគតដូចព្រះអានន្ទត្ថេរៈ សូម្បីនេះ ក៏
ឈ្មោះថា ទស្សនានុត្តរិយៈ ។ មួយទៀត បុគ្គលដទៃទៀតដែលជាកល្យាណ-
បុថុជ្ជន ក៏បានឃើញព្រះទសពលដូចព្រះអានន្ទត្ថេរៈ ធ្វើការឃើញនោះឲ្យច្រើន
រមែងសម្រេចសោតាបត្តិមគ្គ នេះក៏ឈ្មោះថា **ទស្សនៈ** ដូចគ្នា ចំណែកការ
ឃើញខាងដើម ឈ្មោះថា **ទស្សនានុត្តរិយៈ** ។

ពិតហើយ បុគ្គលរមែងបានស្ដាប់ព្រះតម្រាស់របស់ព្រះទសពលរឿយៗ
ដោយសោតវិញ្ញាណ ដូចព្រះអានន្ទត្ថេរៈ នេះឈ្មោះ សវនានុត្តរិយៈ ។ សូម្បី
ព្រះអរិយបុគ្គលពួកដទៃ មានព្រះសោតាបន្នជាដើម រមែងបានស្ដាប់ព្រះតម្រាស់
របស់ព្រះតថាគតដូចព្រះអានន្ទត្ថេរៈ សូម្បីនេះ ក៏ឈ្មោះថា សវនានុត្តរិយៈ ។
ចំណែកបុគ្គលដទៃទៀត ដែលជាកល្យាណបុថុជ្ជន បានស្ដាប់ព្រះតម្រាស់របស់
តថាគតដូចព្រះអានន្ទត្ថេរៈ ចម្រើនសវនៈនោះ រមែងសម្រេចសោតាបត្តិមគ្គ

នេះក៏ឈ្មោះថា សវនៈដូចគ្នា ចំណែកការស្តាប់ពីខាងដើម ឈ្មោះថា **សវនា-នុត្តរិយៈ** ។

បុគ្គល រមែងបានចំពោះនូវសទ្ធាក្នុងព្រះទសពល ដូចព្រះអានន្ទត្ថេរៈ នេះក៏ឈ្មោះថា **លាភានុត្តរិយៈ** ។ សូម្បីបុគ្គលដទៃ មានព្រះសោតាបន្នជាដើម បានលាភដោយចំពោះ គឺ សទ្ធាក្នុងព្រះទសពល ដូចព្រះអានន្ទត្ថេរៈ រមែងបានលាភដោយចំពោះ សូម្បីនេះក៏ឈ្មោះថា **លាភានុត្តរិយៈ** ។ ចំណែកបុគ្គលដទៃទៀត ជាកល្យាណបុថុជ្ជន បានលាភដោយចំពោះ គឺ សទ្ធាក្នុងព្រះទសពល ដូចព្រះអានន្ទត្ថេរៈ ចម្រើនលាភនោះ រមែងសម្រេចសោតាបត្តិមគ្គ នេះឈ្មោះថា ការបានដូចគ្នា ចំណែកការបានខាងដើម ឈ្មោះថា **លាភានុត្តរិយៈ** ។

មួយទៀត បុគ្គលសិក្សាសិក្ខា ៣ ក្នុងព្រះសាសនារបស់ព្រះទសពល ដូចព្រះអានន្ទត្ថេរៈ នេះឈ្មោះថា **សិក្ខានុត្តរិយៈ** ។ សូម្បីព្រះអរិយបុគ្គលពួកដទៃ មានព្រះសោតាបន្នជាដើម រមែងសិក្សាសិក្ខា ៣ ក្នុងព្រះសាសនារបស់ព្រះទសពល ដូចព្រះអានន្ទត្ថេរៈ នេះក៏ឈ្មោះថា **សិក្ខានុត្តរិយៈ** ។ ចំណែកបុគ្គលដទៃទៀត ដែលជាកល្យាណបុថុជ្ជន សិក្សាសិក្ខា ៣ ក្នុងព្រះសាសនារបស់ព្រះទសពល ដូចព្រះអានន្ទត្ថេរៈ ចម្រើនសិក្ខា ៣ នោះ រមែងសម្រេចសោតាបត្តិមគ្គ នេះឈ្មោះថា ការសិក្សាដូចគ្នា ចំណែកការសិក្សាអំពី

ខាងដើម ឈ្មោះថា **សិក្ខានុត្តរិយៈ** ។

មួយទៀត បុគ្គលប្រណិប័តន៍ព្រះទសពលរឿយៗ ដូចព្រះអានន្ទត្ថេរៈ នេះឈ្មោះថា **បារិចរិយានុត្តរិយៈ** ។ សូម្បីព្រះអរិយបុគ្គលពួកដទៃ មានព្រះសោតាបន្នជាដើម រមែងប្រណិប័តន៍ព្រះទសពលរឿយៗ សូម្បីនេះ ក៏ឈ្មោះថា **បារិចរិយានុត្តរិយៈ** ។ ចំណែកបុគ្គលដទៃៗ ដែលជាកល្យាណបុថុជ្ជន ប្រណិប័តន៍ព្រះទសពល ដូចព្រះអានន្ទត្ថេរៈ ចម្រើនការប្រណិប័តន៍នោះ រមែងសម្រេចសោតាបត្តិមគ្គ នេះឈ្មោះថា ការប្រណិប័តន៍ដូចគ្នា ចំណែកការប្រណិ-ប័តន៍ដែលពីខាងដើម ឈ្មោះថា **បារិចរិយានុត្តរិយៈ** ។

បុគ្គលរឭកដល់រឿយៗ ដល់គុណដែលជាលោកិយៈ និងលោកុត្តរៈ របស់ព្រះទសពល ដូចព្រះអានន្ទត្ថេរៈ នេះឈ្មោះថា **អនុស្សតានុត្តរិយៈ** ។ សូម្បីព្រះអរិយបុគ្គលពួកដទៃ មានព្រះសោតាបន្នជាដើម រឭករឿយៗ ដល់គុណដែលជាលោកិយៈ និងលោកុត្តរៈ របស់ព្រះទសពល ដូចព្រះអានន្ទត្ថេរៈ សូម្បីនេះ ក៏ឈ្មោះថា **អនុស្សតានុត្តរិយៈ** ។ ចំណែកបុគ្គលដទៃទៀត ជាកល្យាណបុថុជ្ជន រឭករឿយៗ ដល់គុណដែលជាលោកិយៈ និងលោកុត្តរៈ របស់ព្រះទសពល ដូចព្រះអានន្ទត្ថេរៈ ចម្រើនការរឭករឿយៗ នោះ រមែងសម្រេចសោតាបត្តិមគ្គ នេះឈ្មោះថា អនុស្សតិដូចគ្នា ចំណែកអនុស្សតិអំពីដើម

ឈ្មោះថា **អនុស្សតានុត្តរិយៈ** ដូចពណ៌នាមកនេះ គឺ អនុត្តរិយៈ ៦ ។ អនុ-ត្តរិយៈទាំង ៦ នេះ រមែងប្រាកដ អនុត្តរិយៈទាំង ៦ នេះ គប្បីជ្រាបថា លោកពោលលាយគ្នាទាំងលោកិយៈ និងលោកុត្តរៈ ។

បទថា **ចតុន្នំ បដិសម្ភិទានំ សច្ឆិកិរិយា ហោតិ** សេចក្តីថា ក៏បដិសម្ភិទា ៤ គឺ អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិ-ភាណប្បដិសម្ភិទា ។ ក្នុងបដិសម្ភិទា ៤ នោះ សេចក្តីដឹងក្នុងអត្ថ ឈ្មោះថា **អត្ថប្បដិសម្ភិទា** ។ សេចក្តីដឹងក្នុងធម៌ ឈ្មោះថា **ធម្មប្បដិសម្ភិទា** ។ ការដឹងក្នុងការពោលភាសាដែលជា អត្ថ និងធម៌ ឈ្មោះថា **និរុត្តិប្បដិសម្ភិទា** សេចក្តីដឹងក្នុងញាណទាំងឡាយ ឈ្មោះថា **បដិភាណប្បដិសម្ភិទា** ។ សេចក្តីសង្ខេបក្នុងទីនេះ មានត្រឹមតែប៉ុណ្ណេះ ។ ចំណែកសេចក្តីពិស្តារនៃបដិសម្ភិទាទាំងនោះ មកហើយក្នុងអភិធម្មនុ៎ះឯង ។ អធិប្បាយថា ការធ្វើឲ្យជាក់ច្បាស់បដិសម្ភិទាទាំង ៤ នេះ រមែងមានក្នុងពុទ្ធុប្បាទកាល ។ ការធ្វើឲ្យជាក់ច្បាស់បដិសម្ភិទាទាំងនោះ វៀរពុទ្ធុប្បាទកាលចេញ រមែងមិនមាន ។ បដិសម្ភិទាសូម្បីទាំងនេះ គប្បីជ្រាបថា លោកពោលថា បានទាំងលោកិយៈ និងលោកុត្តរៈ ។

បទថា **អនេកធាតុប្បដិវេធោ** សេចក្តីថា ការត្រាស់ដឹងធាតុ ១៨ មានពាក្យថា ចក្ខុធាតុ រូបធាតុ ដូច្នេះជាដើម រមែងមានក្នុងពុទ្ធុប្បាទកាលប៉ុណ្ណោះ

វៀរពុទ្ធុប្បាទកាល រមែងមិនមាន ។ ក្នុងពាក្យថា **នានាធាតុប្បដិវេធោ ហោតិ** ការត្រាស់ដឹងធាតុផ្សេងៗ ទើបមានទេះ ធាតុ ១៨ នេះឯង គប្បីជ្រាបថា **នានាធាតុ** ព្រោះមានសភាវៈផ្សេងៗ ។ ក៏ការត្រាស់ដឹងណា នូវធាតុទាំងនោះ ដោយហេតុផ្សេងៗ យ៉ាងនេះថា ធាតុទាំងនេះ មានសភាវៈផ្សេងគ្នា ក្នុងប្រការនេះ នេះឈ្មោះថា ការត្រាស់ដឹងធាតុផ្សេងៗ ។

បទថា **វិជ្ជា** ក្នុងបទថា **វិជ្ជាវិមុត្តិផលសច្ឆិកិរិយា** នេះ បានដល់ផលញាណ ។ បទថា **វិមុត្តិ** បានដល់ ធម៌ដែលសម្បយុត្តដោយសោតាបត្តិផល ក្រៅពីវិជ្ជានោះ ។ បទថា **សោតាបត្តិផលសច្ឆិកិរិយា** សេចក្តីថា បឋមមគ្គ ឈ្មោះថា **សោតៈ** ។ ឈ្មោះថា **សោតាបត្តិផល** ព្រោះជាផលដែលបុគ្គលគប្បីសម្រេចដោយសោតៈនោះ ។ សកទាគាមិផលជាដើម ប្រាកដច្បាស់ហើយនោះឯង ។

[១៨៥] បទថា **អនុត្តរំ** ប្រែថា កំពូល ។ បទថា **ធម្មចក្កំ** បានដល់ចក្កដ៏ប្រសើរ ។ ពិតហើយ **ចក្ក** ស័ព្ទនេះ មកក្នុងអត្ថថា **ឧរចក្ក** (គឺចក្រប្រហារជីវិត) ក្នុងគាថានេះថា ៖

លោកបានប្រសព្វនាងវេមានិកប្រេត ៤ នាក់ ពី ៤ នាក់
ជា ៨ នាក់ ពី ៨ នាក់ ជា ១៦ នាក់ កាលនឹងបានប្រសព្វ

នាងវេមានិកប្រេត ពី ១៦ នាក់ ជា ៣២ នាក់ ក៏នៅប្រាថ្នា
ក្រៃលែងជាងនោះ ទើបបានប្រសព្វចក្រនេះ ចក្រក្រុតរមែង
វិលលើខ្លួនរបស់បុគ្គល ដែលត្រូវសេចក្តីប្រាថ្នាគ្របសង្កត់
ហើយ ។

ចុះក្នុងអត្ថថា **ចក្រ** គឺ ឥរិយាបថ ក្នុងប្រយោគនេះថា អ្នកជនបទ ផ្លាស់ឥរិយាបថ ដើរទៅរឿយៗ ។ ចុះក្នុងអត្ថថា **ចក្រ** គឺ ឈើ ក្នុងប្រយោគនេះថា ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ជាងរថបង្វិលចក្រ គឺ ឈើយន្ត ដែលធ្វើ ៦ ខែទើបស្រេច ។ ចុះក្នុងអត្ថថា **ចក្រ** គឺ លក្ខណៈ មានក្នុងប្រយោគនេះថា ទោណព្រាហ្មណ៍ បានឃើញចក្រ គឺ លក្ខណៈដែលកើតត្រង់ព្រះបាទរបស់ព្រះដ៏មានព្រះភាគ ដែលមានកាំមួយពាន់ ។ ចុះក្នុងអត្ថថា **ចក្រ** គឺ សម្បត្តិ ក្នុងប្រយោគនេះថា សម្បត្តិ ៤ រមែងប្រព្រឹត្តទៅសូម្បីទេវតា និងមនុស្សទាំងឡាយ ដែលប្រកបដោយសម្បត្តិពួកណា សម្បត្តិទាំងនេះ មាន ៤ ប្រការ ។ ចុះក្នុងអត្ថថា **ចក្រ** គឺ រតនៈក្នុងប្រយោគនេះថា ចក្រ គឺ រតនៈ ដែលជាទិព្វ ប្រាកដហើយ ។ តែក្នុងទីនេះ ចុះក្នុងអត្ថថា **ចក្ក** គឺ **ធម៌** ។

ក្នុងបទថា **បវត្តិតំ** នេះ គប្បីជ្រាបប្រភេទដូច្នេះថា ឈ្មោះថា កំពុងប្រាថ្នាពិតនូវព្រះធម្មចក្ក ធម្មចក្ក ឈ្មោះថា ប្រាថ្នាពិតហើយ ឈ្មោះថា កំពុង

ធ្វើព្រះធម្មចក្កឲ្យកើតឡើង ធម្មចក្កឈ្មោះថា ទ្រង់ធ្វើឲ្យកើតឡើងហើយ ឈ្មោះថា កំពុងប្រកាសព្រះធម្មចក្ក ធម្មចក្រឈ្មោះថា ទ្រង់ប្រកាសហើយ ។

ឈ្មោះថា **កំពុងប្រាថ្នាដោយពិតនូវព្រះធម្មចក្ក** តាំងពីពេលណា? គ្រាដែលព្រះអង្គជាសុមេធព្រាហ្មណ៍ ឃើញទោសក្នុងកាមទាំងឡាយ និងអានិសង្សក្នុងនេក្ខម្មៈ ថ្វាយសត្តសតកៈមហាទាន ហើយបួសជាឥសី ធ្វើអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើត តាំងពីនោះមក ឈ្មោះថា កំពុងប្រាថ្នាដោយពិតនូវព្រះធម្មចក្ក ។

ឈ្មោះថា **ប្រាថ្នាដោយពិតហើយ** តាំងពីពេលណា? គ្រាព្រះអង្គប្រជុំធម៌ ៨ ប្រការ ហើយទ្រង់ចងព្រះមនសៈ ដើម្បីប្រយោជន៍ដល់ការធ្វើព្រះ-មហាពោធិញ្ញាណឲ្យផ្លូវផង់ ក្នុងបាទមូលនៃព្រះពុទ្ធ ព្រះនាមថាទីបង្ករ ទ្រង់អធិដ្ឋានព្រះវីរិយៈថា យើងមិនបានទទួលព្យាករណ៍ នឹងមិនក្រោកឡើង ហើយទើបដេកចុះ បានទទួលព្យាករណ៍ពីសម្នាក់ព្រះទសពលហើយ តាំងពីនោះមក ធម្មចក្ក ឈ្មោះថា ប្រាថ្នាដោយពិតហើយ ។

ឈ្មោះថា **កំពុងឲ្យធម្មចក្កកើតឡើង** តាំងពីពេលណា? កាលព្រះអង្គទ្រង់បំពេញទានបារមី ឈ្មោះថា កំពុងញ៉ាំងធម្មចក្កឲ្យកើតឡើង ។ កាលទ្រង់បំពេញសីលបារមីក្តី ។ល។ ទ្រង់បំពេញឧបបារមីក្តី ឈ្មោះថា កំពុង

ញ៉ាំងធម្មចក្កឲ្យកើតឡើង កាលទ្រង់បំពេញបារមី ១០ ឧបបារមី ១០ បរមត្ថ-បារមី ១០ ក្តី កាលទ្រង់បំពេញមហាបរិច្ចាគ ៥ ក្តី ទ្រង់បំពេញញាតត្ថចរិយាក្តី ឈ្មោះថា ទ្រង់ញ៉ាំងធម្មចក្កឲ្យកើតឡើង ។ ទ្រង់នៅក្នុងភាវៈជាព្រះវេស្សន្តរ ទ្រង់ថ្វាយសត្តសតកៈមហាទាន ទ្រង់ប្រគល់បុត្រ និងភរិយា ក្នុងមុខ គឺ ទាន ទ្រង់កាន់យកកំពូលព្រះបារមី ទ្រង់កើតក្នុងសួគ៌ជាន់តុសិត ទ្រង់តាំងនៅក្នុងតុសិតនោះរហូតអស់ព្រះជន្មាយុ ដែលទេវតាទូលអារាធនាហើយ ឲ្យប្តេជ្ញាសូម្បីទ្រង់ពិចារណាមើលមហាវិលោកនៈ ៥ ឈ្មោះថា កំពុងញ៉ាំងធម្មចក្កឲ្យកើតឡើងដូចគ្នា ។ កាលទ្រង់បដិសន្ធិក្នុងព្រះគភ៌របស់ព្រះមាតាក្តី កាលទ្រង់ធ្វើមុឺនចក្រវាឡឲ្យញាប់ញ័រក្នុងខណៈបដិសន្ធិក្តី កាលទ្រង់ធ្វើលោកឲ្យញាប់ញ័រដូច្នោះឯង ក្នុងថ្ងៃស្តេចចេញចាកព្រះគភ៌របស់មាតាក្តី កាលប្រសូតិក្នុងវំពេចនោះឯង ស្តេចឈានព្រះបាទទៅ ៧ ជំហាន ទ្រង់បន្លឺសីហនាទថា យើងជាអ្នកប្រសើរបំផុតក្តី កាលស្តេចនៅគ្រប់គ្រងផ្ទះ រហូតដល់អស់ ២៩ វស្សាក្តី ស្តេចចេញដើម្បីគុណដ៏ធំក្រៃលែងក្តី ទ្រង់បព្វជ្ជាត្រង់ច្រាំងទន្លេអនោនទីក្តី ទ្រង់ធ្វើមហាបធាន សេចក្តីព្យាយាម ៦ វស្សាក្តី សោយបាយមធុបាយាស ដែលនាងសុជាតាថ្វាយ ទ្រង់បណ្តែតថាសមាសក្នុងទន្លេ ហើយស្តេចទៅពោធិមណ្ឌ-ស្ថានដ៏ប្រសើរ ក្នុងវេលាល្ងាច ប្រថាប់អង្គុយត្រួតលោកធាតុទាទិសបុព្វា ទ្រង់

កម្ចាត់មារ និងពលរបស់មារ ក្នុងកាលព្រះអាទិត្យមិនទាន់លិចនុ៎ះឯង ទ្រង់រឭកដល់បុព្វេនិវាសញ្ញាណក្នុងបឋមយាមក្តី ទ្រង់ជម្រះទិព្វចក្ខុក្នុងមជ្ឈិមយាមក្តី ទ្រង់ពិចារណាបច្ចយាការក្នុងវេលាតមកក្នុងវេលាជិតភ្លឺ ហើយត្រាស់ដឹងសោតាបត្តិមគ្គក្តី ទ្រង់ធ្វើឲ្យច្បាស់សោតាបត្តិផលក្តី ទ្រង់ធ្វើឲ្យច្បាស់សកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផលក្តី កាលទ្រង់ត្រាស់ដឹងអរហត្តមគ្គក្តី ក៏ឈ្មោះថា ទ្រង់កំពុងធ្វើធម្មចក្កឲ្យកើតឡើងដូចគ្នា ។

ក៏ធម្មចក្ក ឈ្មោះថា ដែលព្រះអង្គឲ្យកើតឡើងហើយ ក្នុងខណៈនៃព្រះអរហត្តផល ។ ពិតណាស់ គុណរាសី គំនរនៃគុណទាំងអស់របស់ព្រះពុទ្ធទាំងឡាយ រមែងសម្រេចព្រមជាមួយនឹងអរហត្តផលនុ៎ះឯង ។ ព្រោះដូច្នោះធម្មចក្កនោះ ឈ្មោះថា ដែលព្រះអង្គឲ្យកើតឡើងហើយក្នុងខណៈនោះ ។

ព្រះអង្គ ទ្រង់ប្រកាសធម្មចក្កពេលណា? កាលព្រះអង្គទ្រង់សម្ងំនៅ ៧ សប្តាហ៍ក្នុងពោធិមណ្ឌស្ថាន ទ្រង់សម្តែងធម្មចក្កប្បវត្តនសូត្រ ធ្វើព្រះអញ្ញាកោណ្ឌញ្ញត្ថេរៈ ឲ្យជាកាយសក្ខី នាព្រៃឥសិបតនមិគទាយវ័ន ឈ្មោះថា ទ្រង់ប្រកាសព្រះធម្មចក្ក ។ ក៏ក្នុងកាលណាព្រះអញ្ញាកោណ្ឌញ្ញត្ថេរៈ បានការស្តាប់ដែលកើតដោយអានុភាពនៃទេសនាញាណរបស់ព្រះទសពល ហើយសម្រេចធម៌មុនគេបង្អស់ ផ្តើមតាំងពីកាលនោះមក គប្បីជ្រាបថា ធម្មចក្ក ឈ្មោះថា

ទ្រង់ប្រកាសហើយ ។

ពិតណាស់ ពាក្យថា **ធម្មចក្ក** នេះ ជាឈ្មោះនៃទេសនាញាណខ្លះ នៃបដិវេធញ្ញាណខ្លះ ។ ក្នុង ២ យ៉ាងនោះ ទេសនាញាណជាលោកិយៈ បដិវេធញ្ញាណជាលោកុត្តរៈ ។ សួរថា ទេសនាញាណ បដិវេធញ្ញាណជារបស់នរណា? ឆ្លើយថា មិនមែនរបស់នរណាដទៃ គប្បីជ្រាបថា ទេសនាញាណ និងបដិវេធញ្ញាណ ជារបស់ព្រះសម្មាសម្ពុទ្ធប៉ុណ្ណោះ ។

បទថា **សម្មទេវ** បានដល់ ដោយហេតុ គឺ ដោយន័យ ដោយការណ៍នោះឯង ។ បទថា **អនុប្បវត្តេតិ** សេចក្តីថា ព្រះថេរៈឈ្មោះថា រមែងប្រកាសតាមធម្មចក្ក ដែលព្រះសាស្តាទ្រង់ប្រកាសទុកមុនហើយ ដូចកាលព្រះសាស្តាស្តេចទៅខាងមុខ ព្រះថេរៈដើរទៅខាងក្រោយ ឈ្មោះថា ដើរតាមព្រះសាស្តានោះ ដូច្នោះ ។ សួរថា ប្រកាសតាមដូចម្តេច? ឆ្លើយថា ក៏ព្រះសាស្តា កាលទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋានទាំង ៤ នេះ សតិប្បដ្ឋាន ៤ អ្វីខ្លះ ឈ្មោះថា ទ្រង់ប្រកាសធម្មចក្ក ។ ព្រះធម្មសេនាបតីសារីបុត្តទុំ៉ះឯង កាលសម្តែងថា ម្នាលអ្នកដ៏មានអាយុ សតិប្បដ្ឋានទាំង ៤ នេះ ឈ្មោះថា រមែងប្រកាសតាមធម្មចក្ក ។ សូម្បីក្នុងសម្មប្បធានជាដើម ក៏ន័យនេះដូចគ្នា ។ មិនមែនតែក្នុងពោធិបក្ខិយធម៌តែម្យ៉ាង ។

សូម្បីក្នុងពាក្យថា ភិក្ខុទាំងឡាយ អរិយសច្ចៈទាំង ៤ នេះ អរិយវង្ស ទាំង ៤ នេះ ជាដើម ក៏គប្បីជ្រាបន័យនេះដូចគ្នា ។ ដោយប្រការដូចពោលនេះ ព្រះសម្មាសម្ពុទ្ធ ឈ្មោះថា ទ្រង់ប្រកាសធម្មចក្ក ព្រះថេរៈ ឈ្មោះថា ប្រកាសតាមព្រះធម្មចក្ក ដែលព្រះទសពលទ្រង់ប្រកាសហើយ ។

ក៏ព្រះធម៌ ដែលព្រះថេរៈប្រកាសតាមធម្មចក្កយ៉ាងនេះ សម្ដែងហើយក្ដី ប្រកាសហើយក្ដី រមែងឈ្មោះថា ជាការព្រះសាស្ដាទ្រង់សម្ដែងហើយ ប្រកាសហើយតែម្យ៉ាង ។ បុគ្គលណាម្នាក់ មិនថាជា ភិក្ខុ ភិក្ខុនីក៏ដោយ ឧបាសក ឧបាសិកាក៏ដោយ ជាទេព ឬជាស្ដេចសក្កៈក៏ដោយ ជាមារ ឬជាព្រហ្មក៏ដោយ សម្ដែងធម៌ទុក ធម៌ទាំងអស់នោះ ឈ្មោះថា ព្រះសាស្ដាទ្រង់សម្ដែងហើយ ទ្រង់ប្រកាសហើយ ។ ចំណែកជនក្រៅពីនោះ ឈ្មោះថា តាំងនៅក្នុងចំណែកនៃអ្នកដែលដើរតាមស្នាម ។ ដូចម្ដេច? ដូច ជនទាំងឡាយអានលាយល័ក្ខព្រះរាជហត្ថដែលព្រះរាជាទ្រង់ប្រទាន ហើយធ្វើការងារណាៗ ការងារនោះៗ បុគ្គលណាម្នាក់ ធ្វើខ្លួនឯងក្ដី ឲ្យអ្នកដទៃធ្វើក្ដី គេហៅថា ព្រះរាជាត្រាស់បង្គាប់ឲ្យធ្វើយ៉ាងនោះ ដូចគ្នា ។ សេចក្ដីពិត ព្រះសម្មាសម្ពុទ្ធ ដូចព្រះរាជាអ្នកធំ ។ ព្រះពុទ្ធវចនៈ គឺ បិដក ៣ ដូចលាយល័ក្ខព្រះរាជហត្ថ ការឲ្យដោយមុខ គឺន័យក្នុងព្រះត្រៃបិដក ដូចការដែលទ្រង់ប្រទានលាយល័ក្ខព្រះរាជហត្ថ ។ ការ

ឲ្យបរិស័ទ ៤ រៀនព្រះពុទ្ធវចនៈតាមកម្លាំងរបស់ខ្លួន ហើយសម្តែង ប្រកាស ដល់ជនពួកដទៃ ដូចអានលាយល័ក្ខព្រះរាជហត្ថ ហើយធ្វើការងារ ។ ក្នុងធម៌ទាំងនោះ ធម៌ដែលបុគ្គលណាម្នាក់សម្តែងក្តី ប្រកាសក្តី គប្បីជ្រាបថា ឈ្មោះថា ធម៌ដែលព្រះសាស្តាសម្តែងហើយ ប្រកាសហើយ ដូចបុគ្គលណាម្នាក់អានលាយល័ក្ខព្រះរាជហត្ថ ធ្វើការងារណាៗ ដោយខ្លួនឯងក្តី ប្រើឲ្យអ្នកដទៃធ្វើក្តី ការងារនោះៗ ឈ្មោះថា ដែលព្រះរាជាត្រាស់បង្គាប់ឲ្យធ្វើហើយដូចគ្នា ។ ពាក្យដ៏សេសក្នុងបទទាំងពួង មានអត្ថងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា សូត្រទី ៦ ជាដើម

## ចប់ឯកបុគ្គលវគ្គទី ១៣

រួមអដ្ឋកថាក្នុងវគ្គនេះមាន ០៦ អដ្ឋកថា

# ឯតទគ្គវគ្គ

## វគ្គទី ១

## អដ្ឋកថាសូត្រទី ១

*ក្នុងសូត្រទី ១ របស់វគ្គទី ១ ក្នុងឯតទគ្គបុគ្គល គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ ៖*

[១៨៦] *បទថា **ឯតទគ្គំ** កាត់បទជា **ឯតំ អគ្គំ** ។ ក៏ **អគ្គ** ស័ព្ទនេះក្នុងបទថា **ឯតទគ្គំ** នោះ ប្រាកដក្នុងអត្ថថា ខាងដើម ចុង ចំណែក និងប្រសើរបំផុត ។ **អគ្គ** ស័ព្ទ ប្រាកដក្នុងអត្ថថា **ខាងដើម** ក្នុងប្រយោគមានជាដើមថា ម្នាលនាយឆ្មាំទ្វារសម្លាញ់ តាំងពីថ្ងៃនេះជាដើមទៅ យើងបិទទ្វារ សម្រាប់ពួកនិគ្រន្ថប្រុសស្រ្តី ។ មកក្នុងអត្ថថា **ចុង** ក្នុងប្រយោគមានជាដើមថា បុគ្គលគប្បីយកចុងម្រាមដៃនោះឯង ប៉ះចុងម្រាមដៃនោះ , ចុងអំពៅ ចុងឫស្សី ។ មកក្នុងអត្ថថា **ចំណែក** ក្នុងប្រយោគមានជាដើមថា ភិក្ខុទាំងឡាយ តថាគតអនុញ្ញាតការចែកចំណែកប្រៃ ចំណែកផ្អែម ឬចំណែកល្វីង , តាមចំណែកនៃវិហារ ឬតាមចំណែកនៃបរិវេណ ។ មកក្នុងអត្ថថា **ប្រសើរបំផុត** ក្នុងប្រយោគមានជាដើមថា ភិក្ខុទាំងឡាយ សត្វទាំងឡាយ មានប្រមាណប៉ុនណា មិនមានជើង*

ក៏ដោយ ។ល។ ព្រះតថាគត ប្រាកដថា ប្រសើរបំផុតជាងសត្វទាំងនោះ ។ ក្នុងទីនេះ **អគ្គ** សព្ទនេះ រមែងប្រើបាន ទាំងក្នុងអត្ថថា ចុង ទាំងក្នុងអត្ថថា ប្រសើរបំផុត ។ ពិតណាស់ ព្រះថេរៈទាំងនោះ ឈ្មោះថា **អគ្គ** ព្រោះជាទីបំផុតខ្លះ ព្រោះប្រសើរបំផុតខ្លះ ក្នុងតំណែងដ៏ប្រសើរបំផុតរៀងៗ ខ្លួន ព្រោះដូច្នោះ អត្ថក្នុងបទថា **ឯតទគ្គំ** នេះ មានដូច្នេះថា នេះជាទីបំផុត នេះប្រសើរបំផុត ។ សូម្បីក្នុងសូត្រទាំងពួងក៏ន័យនេះដូចគ្នា ។

ក៏ធម្មតាការតែងតាំងក្នុងតំណែង **ឯតទគ្គ** នេះ រមែងបានដោយហេតុ ៤ ប្រការ គឺ ព្រោះហេតុកើតរឿង ព្រោះការមកមុន ព្រោះជាអ្នកស្ទាត់ជំនាញ ព្រោះជាអ្នកក្រៃលែងដោយគុណ ។ ក្នុងហេតុ ៤ យ៉ាងនោះ ព្រះថេរៈរូបខ្លះរមែងបានតំណែងឯតទគ្គៈ ដោយហេតុតែម្យ៉ាង អង្គខ្លះបានដោយហេតុ ២ យ៉ាង អង្គខ្លះបានដោយហេតុ ៣ យ៉ាង អង្គខ្លះបានដោយហេតុ ទាំង ៤ យ៉ាងនោះឯង ដូចព្រះសារីបុត្តត្ថេរៈ ។ ពិតហើយ ព្រះសារីបុត្តត្ថេរៈនោះ បានតំណែងឯតទគ្គៈ ព្រោះជាអ្នកមានបញ្ញាច្រើន ព្រោះហេតុកើតរឿងខ្លះ ព្រោះហេតុមកពីមុនខ្លះ ។ យ៉ាងណា? សម័យមួយ ព្រះសាស្តាប្រថាប់នៅក្នុងព្រះវិហារជេតពន ទ្រង់សម្តែងយមកប្បាដិហារ្យ បង្ក្រាបពួកតិរ្ថិយត្រង់គល់ដើមគណ្ឌាមព្រឹក្ស ដើមស្វាយក្រអូប ទ្រង់ត្រិះរិះថា ព្រះពុទ្ធក្នុងអតីតទាំងឡាយ ទ្រង់ធ្វើយមកប្បាដិហារ្យហើយ

ចូលចាំវស្សាក្នុងទីណាហ្ន៎ ទ្រង់ជ្រាបថា ក្នុងភពតាវត្តិង្ស ទ្រង់សម្តែងស្នាមព្រះបាទទុក ២ កន្លែង ស្នាមទី ៣ ប្រថាប់ទុកតាវត្តិង្ស ស្តេចសក្កទេវរាជទតព្រះនេត្រឃើញព្រះដ៏មានព្រះភាគ ក្រោកចាកបណ្ឌុកម្ពលសិលាសនៈ ស្តេចទៅទទួល ព្រមជាមួយពួកទេវតា ។ ទេវតាទាំងឡាយគិតគ្នាថា ស្តេចសក្កទេវរាជ ហែហាមទៅដោយពួកទេវ ប្រថាប់អង្គុយលើបណ្ឌុកម្ពលសិលាសនៈប្រវែង ៦០ យោជន៍ សោយមហាសម្បត្តិ ។ ផ្តើមតាំងពីព្រះពុទ្ធទាំងឡាយប្រថាប់ហើយ បុគ្គលដទៃមិនអាចនឹងដាក់ សូម្បីតែដៃចុះក្នុងព្រះទែននេះបានចំណែកព្រះសាស្តា ប្រថាប់ក្នុងទីនោះហើយ ទ្រង់ជ្រាបវារៈចិត្តរបស់ពួកទេវៈទាំងនោះហើយ ប្រថាប់លើបណ្ឌុកម្ពលសិលាសនៈទាំងអស់ ដូចភិក្ខុអ្នកទ្រទ្រង់សំពត់បង្សុកូលផ្ទាំងធំ អង្គុយគ្របលើតាំងតូច ដូច្នោះ ។

តែនរណាៗ មិនគួរកំណត់ថា ព្រះសាស្តាកាលប្រថាប់អង្គុយយ៉ាងនេះ ទ្រង់និម្មិតព្រះសរីរៈរបស់ព្រះអង្គឲ្យធំ ឬទ្រង់ធ្វើបណ្ឌុកម្ពលសិលាសនៈឲ្យតូច ។ ព្រោះថា ពុទ្ធវិស័យ ជាអចិន្តេយ្យៈ (នរណាៗ មិនគួរគិត) ក៏ព្រះអង្គប្រថាប់អង្គុយយ៉ាងនេះហើយ ធ្វើព្រះមាតាឲ្យជាកាយសក្ខី ជាសាក្សី ផ្តើមទ្រង់សម្តែងអភិធម្មបិដក មានជាដើមថា កុសលធម៌ អកុសលធម៌ ប្រោសពួកទេវតាក្នុងមុឺនចក្រវាឡ ។

សូម្បីក្នុងទីដែលទ្រង់ធ្វើយមកប្បាដិហារ្យ បរិស័ទទាំងអស់ប្រមាណ ១២ យោជន៍ ចូលទៅរកព្រះអនុរុទ្ធៈ សួរថា លោកម្ចាស់ដ៏ចម្រើន ព្រះទសពល ប្រថាប់នៅក្នុងទីណា? ព្រះអនុរុទ្ធៈឆ្លើយថា ព្រះទសពលចូលចាំវស្សាឯបណ្ឌុ-កម្ពលសិលាសនៈ ក្នុងភពតាវត្តិង្ស ផ្តើមសម្តែងអភិធម្មបិដក បរិស័ទសួរថា លោកម្ចាស់ដ៏ចម្រើន ពួកខ្ញុំមិនឃើញព្រះសាស្តា ក៏នឹងមិនត្រឡប់ទៅឡើយ អ្នកទាំងឡាយចូរដឹងវេលាដែលព្រះសាស្តាស្តេចមក ថា កាលណាព្រះសាស្តា ស្តេចនឹងមក ព្រះអនុរុទ្ធពោលថា ពួកលោកនឹងទុកនាទីដល់ព្រះមហាមោគ្គ-ល្លានត្ថេរៈចុះ លោកទៅគាល់ព្រះពុទ្ធហើយ នឹងនាំដំណឹងមក ។ បរិស័ទសួរថា ក៏កម្លាំងរបស់ព្រះថេរៈដែលនឹងទៅក្នុងទីនោះ មិនបានឬ? ព្រះអនុរុទ្ធពោលយ៉ាងនេះថា បាន ។ តែសូមបរិស័ទចូរមើលគុណវិសេសចុះ ។ មហាជនចូលទៅរកព្រះមហាមោគ្គល្លានត្ថេរៈ អង្វរសូមឲ្យលោកប្រាប់ដំណឹងរបស់ព្រះសាស្តា ស្តេចមក ។ កាលមហាជនកំពុងឃើញហើយនុ៎ះឯង ព្រះថេរៈក៏មុជចុះក្នុងមហាប្រថពីទៅខាងក្នុងភ្នំសិនេរុ ថ្វាយបង្គំព្រះសាស្តា ទូលថា បពិត្រព្រះអង្គដ៏ចម្រើន មហាជនបំណងនឹងគាល់ព្រះអង្គ ចង់ជ្រាបថ្ងៃដែលព្រះអង្គនឹងស្តេចត្រឡប់ ។ ព្រះសាស្តាត្រាស់ថា បើដូច្នោះ អ្នកចូរប្រាប់ថា លោកទាំងឡាយ នឹងឃើញត្រង់ទ្វារក្រុងសង្កស្សៈ ។

ចំណែកព្រះសាស្តាទ្រង់សម្តែងធម៌ ៧ គម្ពីរ ហើយទ្រង់សម្តែងអាការ ដើម្បីស្តេចត្រឡប់មកមនុស្សលោក ។ ស្តេចសក្កទេវរាជ ត្រាស់ហៅវិស្សុកម្មទេវបុត្រមក មានទេវឱង្ការបង្គាប់ឲ្យនិម្មិតជណ្តើរ ដើម្បីព្រះតថាគតស្តេចចុះ វិស្សុកម្មទេវបុត្រ និម្មិតជណ្តើរមាសម្ខាង ជណ្តើរប្រាក់ម្ខាង ហើយនិម្មិតជណ្តើរកែវមណីទុកត្រង់កណ្តាល ។ ព្រះសាស្តាប្រថាប់ឈរលើជណ្តើរកែវមណី ទ្រង់អធិដ្ឋានថា សូមមហាជនចូរឃើញតថាគត ទ្រង់អធិដ្ឋានដោយអានុភាពរបស់ព្រះអង្គថា សូមមហាជនចូរឃើញអវិចីមហានរក និងទ្រង់ជ្រាបថា មហាជនកើតសេចក្តីតក់ស្លុត ព្រោះឃើញនរក ទើបទ្រង់សម្តែងទេវលោក ។ លំដាប់នោះ កាលព្រះអង្គស្តេចយាងចុះ ស្តេចមហាព្រហ្មបាំងឆត្រ ស្តេចសក្កទេវរាជទ្រង់ទទួលបាត្រ ។ ស្តេចសុយាមទេវរាជបក់ផ្លិតវាលវីជនីដែលជាទិព្វថ្វាយ ។ បញ្ចសិខគន្ធព្វទេវបុត្រ ដេញពិណពណ៌លឿងដូចផ្លែព្នៅ ឲ្យរីករាយដោយមុច្ឆនាសំឡេង ៥០ គត់ ចុះនាំស្តេច ។ ក្នុងវេលាដែលព្រះពុទ្ធ ប្រថាប់ឈរលើផែនដី មហាជនអធិដ្ឋានថា ខ្ញុំនឹងថ្វាយបង្គំមុនៗ ព្រមជាមួយការជាន់មហាប្រថពីរបស់ព្រះដ៏មានព្រះភាគ ទាំងមហាជន ទាំងព្រះអសីតិមហាសាវក មិនទាន់បានថ្វាយបង្គំព្រះដ៏មានព្រះភាគមុន ។ ព្រះធម្មសេនាបតីសារីបុត្តត្ថេរប៉ុណ្ណោះ ទាន់ថ្វាយបង្គំមុន ។

តាំងពីនេះកន្លងទៅ ៣ ខែ ។ ព្រះថេរៈ នាំជំណឹងរបស់ព្រះដ៏មាន-ព្រះភាគ មកប្រាប់ដល់មហាជន ។ មហាជនតាំងជំរំនៅក្នុងទីនោះឯង ៣ ខែ ។ ព្រះចូឡអនាថបិណ្ឌិកសេដ្ឋី បានថ្វាយបាយយាគូ និងភត្ត ដល់បរិស័ទប្រមាណ ១២ យោជន៍ រហូតដល់អស់ ៣ ខែ ។

លំដាប់នោះ ព្រះសាស្ដា ទ្រង់ផ្ដើមបុថុជ្ជនបញ្ចកបញ្ហា (បញ្ហាមានបុថុជ្ជនជាទី ៥) ក្នុងរវាងបរិស័ទ ១២ យោជន៍ ដោយព្រះពុទ្ធបំណងថា មហាជនចូរដឹងអានុភាពបញ្ញារបស់ព្រះថេរៈ ។ គ្រាដំបូង ត្រាស់សួរបុថុជ្ជនដោយពុទ្ធបំណងថា លោកិយមហាជននឹងកំណត់បាន ។ ជនពួកណាៗ កំណត់បាន ជនពួកនោះៗ ក៏ឆ្លើយបាន ។ លើកទី ២ ត្រាស់សួរបញ្ហាក្នុងសោតាបត្តិ-មគ្គ កន្លងវិស័យបុថុជ្ជន ។ បុថុជ្ជនទាំងឡាយក៏ស្ងៀម ។ ព្រះសោតាបន្នប៉ុណ្ណោះឆ្លើយបាន ។ លំដាប់នោះ ទើបត្រាស់សួរបញ្ហាក្នុងសកទាគាមិមគ្គ កន្លងវិស័យព្រះសោតាបន្ន ។ ព្រះសោតាបន្នក៏ស្ងៀម ។ ព្រះសកទាគាមិ-បុគ្គលប៉ុណ្ណោះឆ្លើយបាន ។ ត្រាស់សួរបញ្ហាក្នុងអនាគាមិមគ្គ កន្លងវិស័យសូម្បីរបស់ព្រះសកទាគាមិបុគ្គលទាំងនោះ ព្រះសកទាគាមិបុគ្គលក៏ស្ងៀម ។ ព្រះអនាគាមិបុគ្គលប៉ុណ្ណោះឆ្លើយបាន ។ ត្រាស់សួរបញ្ហាក្នុងអរហត្តមគ្គ កន្លងវិស័យរបស់ព្រះអនាគាមិបុគ្គល សូម្បីទាំងនោះ ។ ព្រះអនាគាមីក៏ស្ងៀម ។

ព្រះអរហន្តប៉ុណ្ណោះឆ្លើយបាន ។ តាំងពីផ្ដើមបញ្ហាខាងក្រោមនោះ ត្រាស់សួរព្រះសាវកដែលដឹងដ៏ក្រៃលែង ។ ព្រះសាវកទាំងនោះ តាំងនៅក្នុងវិស័យនៃបដិសម្ភិទារបស់ខ្លួន រៀងៗ ខ្លួន ក៏ឆ្លើយបាន ។ លំដាប់នោះ ទើបត្រាស់សួរព្រះមហាមោគ្គល្លានត្ថេរៈ ។ ព្រះសាវកក្រៅពីនោះក៏នៅស្ងៀម ។ ព្រះថេរៈប៉ុណ្ណោះឆ្លើយបាន ។ ទ្រង់កន្លងវិស័យរបស់ព្រះថេរៈសូម្បីនោះ ត្រាស់សួរបញ្ហាក្នុងវិស័យរបស់ព្រះសារីបុត្រ ព្រះមហាមោគ្គល្លានក៏នៅស្ងៀម ។ ព្រះ-សារីបុត្តត្ថេរៈប៉ុណ្ណោះឆ្លើយបាន ។ ទ្រង់កន្លងវិស័យសូម្បីរបស់ព្រះថេរៈ ត្រាស់សួរបញ្ហាក្នុងពុទ្ធវិស័យ ព្រះធម្មសេនាបតីសូម្បីនឹកហើយ ក៏មិនអាចនឹងដឹងសម្លឹងមើលទៅកាន់ទីជុំវិញ គឺ ទិសធំ ៤ គឺ ទិសខាងកើត ទិសខាងលិច ទិសជើង ទិសត្បូង និងទិសតូចទាំង ៤ ក៏មិនអាចនឹងកំណត់ឋានៈដែលកើតបញ្ហាបាន ។

ព្រះសាស្ដាទ្រង់ជ្រាបថា ព្រះថេរៈលំបាកចិត្ត ទើបទ្រង់ព្រះតម្រិះថាសារីបុត្រលំបាកចិត្ត ចាំតថាគតនឹងសម្ដែងជាលំនាំផ្លូវដល់អ្នក ទើបត្រាស់ថាអ្នកចូរចាំសារីបុត្រ ហើយត្រាស់ប្រាប់ថា បញ្ហានោះជាវិស័យរបស់ព្រះពុទ្ធដោយព្រះតម្រាស់ថា បញ្ហានេះ មិនមែនវិស័យរបស់អ្នក ជាវិស័យរបស់ព្រះសព្វញ្ញុពុទ្ធដ៏មានយស ហើយត្រាស់ថា សារីបុត្រអ្នកចូរឃើញភូតកាយនេះ ។

ព្រះថេរៈដឹងថា ព្រះដ៏មានព្រះភាគ ត្រាស់ប្រាប់ការកំណត់កាយ ដែលប្រកប ដោយមហាភូតរូប ៤ ហើយ ទើបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គ ដឹងហើយ បពិត្រព្រះសុគត ខ្ញុំព្រះអង្គដឹងហើយ ។ កើតការសន្ទនាគ្នាឡើង ក្នុងទីនេះ ដូច្នេះថា លោកម្ចាស់ដ៏ចម្រើន ឈ្មោះថា ព្រះសារីបុត្រ មានបញ្ញា ច្រើនហ្ន៎ ឆ្លើយបញ្ហាដែលអ្នកទាំងពួងមិនដឹង និងតាំងនៅក្នុងន័យដែលព្រះពុទ្ធ ប្រទានហើយ ឆ្លើយបញ្ហាក្នុងពុទ្ធវិស័យបាន ដូច្នោះ បញ្ញានុភាពរបស់ព្រះថេរៈ ទើបខ្ចរខ្ចាយទៅគ្រប់ឋានៈទាំងពួង ស្មើនឹងកិត្តិស័ព្ទរបស់ព្រះពុទ្ធខ្ចរខ្ចាយទៅ ។ ព្រះថេរៈបានតំណែង **ឯតទគ្គ** ព្រោះមានបញ្ញាច្រើន ដោយអត្ថុប្បត្តិ (ហេតុ កើតរឿង) ដោយប្រការដូច្នេះមុន ។

បានតំណែង **ឯតទគ្គ** ដោយហេតុមកពីមុន ដូចម្តេច? ដោយន័យនៃ អត្ថុប្បត្តិនេះឯង ព្រះសាស្តាត្រាស់ថា សារីបុត្រ ជាអ្នកមានបញ្ញាតែក្នុងបច្ចុ-ប្បន្ន នេះប៉ុណ្ណោះ ក៏មិនមែន ក្នុងអតីតកាល សូម្បីលោកបួសជាឥសី ៥០០ ជាតិ ក៏បានជាអ្នកមានបញ្ញាច្រើនដូចគ្នា ។

សាវករូបណា លះកាមដែលគួរ រីករាយ ហើយបួស
ដល់ ៥០០ ជាតិ អ្នកទាំងឡាយ ចូរថ្វាយបង្គំសាវក
រូបនោះ អ្នកប្រាសចាករាគៈ អ្នកមានឥន្ទ្រិយតាំងមាំ

ល្អហើយ អ្នករលត់ស្និទ្ធហើយ គឺ សារីបុត្រ ។

លោកបរិបូរដោយការបួសយ៉ាងនេះ សម័យមួយ កើតក្នុងត្រកូលព្រាហ្មណ៍ ក្រុងពារាណសី រៀនត្រៃវេទ មិនឃើញសារៈក្នុងត្រៃវេទនោះ ទើបកើតសេចក្តីគិតឡើងថា យើងគួរនឹងបួសស្វែងរកមោក្ខធម៌តែម្យ៉ាង ។ សម័យនោះ សូម្បីព្រះពោធិសត្វ ក៏កើតក្នុងត្រកូលឧទិច្ចព្រាហ្មណ៍មហាសាល ចម្រើនវ័យហើយ រៀនសិល្បៈ ឃើញទោសក្នុងកាមទាំងឡាយ និងអានិសង្សក្នុងនេក្ខម្មៈ លះការគ្រប់គ្រងផ្ទះ ចូលព្រៃហិមពាន្ត ធ្វើបរិកម្មកសិណ ធ្វើអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើត មានផ្លែឈើ មើមឈើក្នុងព្រៃជាអាហារ ជិតហិមវន្តប្រទេស សូម្បីមាណពនោះ ក៏បួសហើយក្នុងសម្នាក់របស់ព្រះពោធិ-សត្វនោះឯង ។ លោកមានបរិវារច្រើន មានឥសីប្រមាណ ៥០០ ជាបរិវារ ។ លំដាប់នោះ ប្រមុខអន្តេវាសិករបស់លោក បាននាំបរិស័ទមួយចំណែក ទៅកាន់អាវាសមនុស្ស ដើម្បីសេពរសជូរ និងរសប្រៃ ។

សម័យនោះ ព្រះពោធិសត្វបានធ្វើកាលៈ (ស្លាប់) ក្នុងហិមវន្តប្រទេសនោះឯង ។ ក្នុងវេលានឹងធ្វើកាលៈ អន្តេវាសិកទាំងឡាយ ប្រជុំគ្នាសួរថា គុណ-វិសេសអ្វី ដែលលោកសម្រេចមានហើយឬ ។ ព្រះពោធិសត្វឆ្លើយថា អ្វីៗ មិនមាន ជាអ្នកមិនវិនាសចាកឈាន កើតក្នុងព្រហ្មលោកជាន់អាភស្សរៈ ។

លោកបានអាកិញ្ចញ្ញាយតនសមាបត្តិក៏ពិត តែធម្មតាថា ព្រះពោធិសត្វទាំងឡាយ មិនបដិសន្ធិក្នុងអរូបាវចរភូមិ ។ ព្រោះហេតុអ្វី? ព្រោះជាឋានៈដែលមិនគួរ ។ ដូច្នោះ លោកសូម្បីបានអរូបសមាបត្តិ ក៏កើតក្នុងរូបាវចរភូមិ ។ ចំណែកអន្តេវាសិករបស់លោក មិនធ្វើសក្ការៈ និងសម្មានៈអ្វីៗ ដោយគិតថា អាចារ្យពោលថា អ្វីៗ មិនមានការធ្វើកាលកិរិយារបស់លោក ជាមោឃៈសូន្យចាកគុណ ។ លំដាប់នោះ ប្រមុខអន្តេវាសិករូបនោះ កាលកន្លងវស្សាហើយ ទើបត្រឡប់មកហើយសួរថា អាចារ្យទៅណា ? អន្តេវាសិកទាំងឡាយឆ្លើយថា ធ្វើកាលៈហើយ ។ លោកសួរថា ពួកលោកសួរដល់គុណដែលលោកអាចារ្យបានខ្លះឬ? អន្តេវាសិកឆ្លើយថា ករុណា ពួកខ្ញុំសួរហើយ ។ ប្រមុខអន្តេវាសិកសួរថា លោកនិយាយថាដូចម្តេច? ពួកអន្តេវាសិក ឆ្លើយថា អាចារ្យពោលថា អ្វីៗ មិនមាន សូម្បីពួកខ្ញុំក៏គិតថា ឈ្មោះថា គុណដែលអាចារ្យបានហើយ រមែងមិនមាន ទើបមិនធ្វើសក្ការៈ និងសម្មានៈដល់លោក ។ ប្រមុខអន្តេវាសិកពោលថា ពួកអ្នកមិនដឹងសេចក្តីរបស់ភាសិតលោកអាចារ្យ គឺ លោកបានអាកិញ្ចញ្ញាយតនសមាបត្តិ ។ អន្តេវាសិកទាំងនោះ ក៏មិនជឿពាក្យរបស់ប្រមុខអន្តេវាសិក ។ ប្រមុខអន្តេវាសិកសូម្បីនិយាយរឿយៗ ក៏មិនអាចឲ្យពួកអន្តេវាសិកជឿបាន ។ លំដាប់នោះ ព្រះពោធិសត្វរំពឹងដល់ ហើយគិតថា មហាជន

អ្នកល្ងង់ខ្លៅ រមែងមិនជឿពាក្យរបស់ប្រមុខអន្តេវាសិករបស់យើង ចាំយើងនឹងធ្វើហេតុនេះឲ្យប្រាកដ ដូច្នេះ ហើយចុះចាកព្រហ្មលោក ឈរចុងអាស្រមទាំងដែលនៅក្នុងអាកាសទុះឯង ពណ៌នាអានុភាពនៃបញ្ញា របស់ប្រមុខអន្តេ-វាសិក បានពោលគាថានេះថា ៖

បរោសហស្សំបិ សមាគតានំ កន្ទេយ្យុំ តេ
វស្សសតំ អបញ្ញា ឯកោវ សេយ្យោ
បុរិសោ សបញ្ញោ យោ ភាសិតស្ស
វិជានាមិ អត្ថំ ។

បុគ្គលសូម្បីច្រើនជាង ១.០០០ នាក់ ប្រជុំគ្នា អ្នកដែលមិនមានបញ្ញា គប្បីត្អូញត្អែរហូតអស់ ១០០ ឆ្នាំ បុគ្គលដែលដឹងច្បាស់អត្ថនៃភាសិត ជាអ្នកមានបញ្ញាមួយនាក់ប៉ុណ្ណោះ ប្រសើរជាង (មនុស្សទាំង ១.០០០ នាក់) ។

ព្រះពោធិសត្វ ធ្វើឲ្យពួកឥសីយល់យ៉ាងនេះហើយ ត្រឡប់ទៅព្រហ្ម-លោក ។ សូម្បីពួកឥសីដ៏សេស មិនវិនាសឈាន ធ្វើកាលៈហើយ មានព្រហ្ម-លោកជាទីទៅក្នុងខាងមុខ ក្នុងបណ្តាបុគ្គលទាំងនោះ ព្រះពោធិសត្វសម្រេចព្រះសព្វញ្ញុតញ្ញាណ ។ ប្រមុខអន្តេវាសិក ជាព្រះសារីបុត្រ ។ ឥសីដ៏សេសជា

ពុទ្ធបរិស័ទ ។ សូម្បីក្នុងអតីតកាល ក៏គប្បីជ្រាបថា ព្រះសារីបុត្រមានបញ្ញាច្រើន អាចដឹងអត្ថរបស់ភាសិតដែលត្រាស់ទុកយ៉ាងសង្ខេប ដោយពិស្តារបាន ដោយប្រការដូច្នេះ ។

មួយទៀត ព្រះដ៏មានព្រះភាគទ្រង់ធ្វើ បុថុជ្ជនបញ្ញកបញ្ហា ឲ្យជាហេតុកើតរឿងហើយ ត្រាស់ជាតកនេះថា ៖

បើសូម្បីមនុស្សច្រើនជាង ១០០ នាក់ ប្រជុំគ្នា
បុគ្គលទាំងនោះគ្មានបញ្ញា គប្បីសម្លឹងពិនិត្យអស់
១០០ ឆ្នាំ បុគ្គលដឹងអត្ថនៃភាសិត អ្នកមានបញ្ញា
មួយនាក់ប៉ុណ្ណោះ ប្រសើរជាង ។

ខ្លឹមសាររបស់ជាតកនោះ គប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងជាតកមុនទុំះឯង ។ ទ្រង់ធ្វើបុថុជ្ជនបញ្ញកបញ្ហានេះឯង ប្រការមួយទៀត ឲ្យជាហេតុកើតរឿងហើយ ទ្រង់សម្តែងអនង្គណជាតកនេះថា ៖

ទាំងបុគ្គលមានសញ្ញា ក៏ទុគ្គតៈ ទាំងបុគ្គលមិនមានសញ្ញា
ក៏ទុគ្គតៈ សុខក្នុងសមាបត្តិនោះ មិនមានគ្រឿងសៅហ្មង
រមែងមានបានដល់ពួកជនអ្នកវៀរបុគ្គល ២ ពួកនោះ ។

ក៏ក្នុងជាតកនេះ អាចារ្យកាលទីងធ្វើកាលៈ ត្រូវអន្តេវាសិកទាំងឡាយ

សួរ ទើបពោលថា នេវសញ្ញីនាសញ្ញី (អ្នកមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន) ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យដូចពោលហើយនុ៎ះឯង ។ ទ្រង់ធ្វើបុថុជ្ជនបញ្ហាកបញ្ហាដទៃទៀត ឲ្យជាអត្ថុប្បត្តិហើយ ត្រាស់ចន្ទាភជាតក នេះថា ។

ក្នុងជាតកនេះ អាចារ្យកាលនឹងធ្វើកាលៈ ត្រូវអន្តេវាសិកសួរ ទើបពោលថា **ចន្ទាភំ សុរិយាភំ** មានសេចក្តីថា នរណាជ្ញាក់ចុះ បង្អោនទៅ ស្លុះទៅកាន់កសិណទាំង ២ នោះ គឺ ឱទាតកសិណ ឈ្មោះថា ចន្ទាភៈ បិតកសិណ ឈ្មោះថា សុរិយាភៈ សូម្បីបុគ្គលនោះក៏ចូលដល់អាភស្សរព្រហ្ម ដោយទុតិយជ្ឈាន ដែលមិនមានវិតក្កៈ យើងក៏ដូច្នោះ ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យមុននុ៎ះឯង ។ ទ្រង់ធ្វើ បុថុជ្ជនបញ្ហាកបញ្ហានេះឯង ឲ្យជាអត្ថុប្បត្តិ ទើបត្រាស់សរភជាតក ក្នុងតេរសនិបាតនេះថា ៖

ជាបុរសគប្បីសង្ឃឹមហើយ ជាបណ្ឌិតមិនគប្បីនឿយណាយ
យើងឃើញខ្លួនហើយថា ប្រាថ្នាយ៉ាងណាក៏បានជាយ៉ាងនោះ
ជាបុរសគប្បីព្យាយាម ជាបណ្ឌិតមិនគប្បីនឿយណាយ យើង
ឃើញខ្លួនហើយថា បានទទួលការជួយឲ្យឡើងពីទឹកកាន់គោក
បាន នរជនមានបញ្ញា សូម្បីប្រសព្វទុក្ខ ក៏មិនគួរកាត់សេចក្តី

សង្ឃឹមក្នុងការដែលនឹងមកកាន់សេចក្ដីសុខ ព្រោះថា ផស្សៈ ទាំងដែលមិនជាឧបការៈ និងជាឧបការៈមានច្រើន បុគ្គលដែល មិនស្រមើស្រមៃដល់ ក៏ត្រូវចូលកាន់ផ្លូវនៃសេចក្ដីស្លាប់ ។

សូម្បីវត្ថុដែលមិនបានគិតទុក ក៏មានបាន សូម្បីវត្ថុ ដែលគិតទុកក៏វិនាសទៅបាន ភោគៈទាំងឡាយរបស់ស្ត្រី ឬ បុរស សម្រេចបាន ដោយសេចក្ដីគិតនឹកមិនមានទេ កាល មុនព្រះអង្គស្ដេច ជាប់តាមសត្វឈ្លូសក្បាលណា ទៅជាប់ ត្រង់ញកភ្នំ ព្រះអង្គ ទ្រង់ព្រះជន្មតមកបាន ព្រោះអាស្រ័យ សេចក្ដីអត់ធនរបស់ឈ្លូសមួយក្បាលនោះ ដែលមានចិត្តមិន អស់សង្ឃឹម ។

សត្វឈ្លូសណា ព្យាយាមយកថ្មខ្ទប់រន្ធ ជួយព្រះអង្គ ឡើងពីអន្លង់ជ្រៅដែលឡើងបានលំបាក ដោះលែងព្រះអង្គអ្នក ចូលដល់ទុក្ខចេញចាកមាត់មច្ចុ ព្រះអង្គក៏កំពុងត្រាស់ដល់ សត្វឈ្លូសនោះដែលមានចិត្តមិនអស់សង្ឃឹម ។

ម្នាលព្រាហ្មណ៍ គ្រានោះ លោកនៅទីនោះជាមួយឬ ឬថា នរណាប្រាប់រឿងនេះដល់លោក លោកជាអ្នកបើកបង្ហាញ

ប្រការដែលសង្ស័យ ឃើញរឿងទាំងអស់ហ្ន៎ សេចក្ដីដឹងរបស់លោក ចាស់ក្លាឬហ្ន៎ ។

បពិត្រព្រះធីរាជ អ្នកជាចមជន គ្រានោះ ខ្ញុំព្រះអង្គមិនបានទៅក្នុងទីនោះទេ និងនរណាក៏មិនបានប្រាប់ដល់ខ្ញុំព្រះ-អង្គ ប៉ុន្តែថា អ្នកប្រាជ្ញទាំងឡាយ រមែងនាំសេចក្ដីនៃបទគាថាដែលព្រះអង្គទ្រង់ភាសិតទុកល្អហើយ មកពិចារណា ។

ក៏ជាតកទាំង ៥ នេះ ព្រះសាស្ដាត្រាស់ទុក ដើម្បីប្រកាសអានុភាពនៃបញ្ញារបស់ព្រះធម្មសេនាបតីសារីបុត្តត្ថេរៈប៉ុណ្ណោះថា សូម្បីក្នុងអតីត បុត្ររបស់តថាគត ក៏ដឹងអត្ថនៃធម៌ ដែលតថាគតពោលតែសង្ខេបដោយពិស្ដារបាន ព្រោះដូច្នោះ ព្រះថេរៈបានតំណែងឯតទគ្គៈ ព្រោះភាពដែលខ្លួនមានបញ្ញាច្រើន សូម្បី ដោយហេតុមកពីមុន ដោយប្រការយ៉ាងនេះ ។

ដោយភាពជាអ្នកជំនាញ ដូចម្ដេច? បានឮថា ប្រការនោះ ជាភាពជំនាញរបស់ព្រះថេរៈ ។ ព្រះថេរៈ កាលសម្ដែងធម៌កណ្ដាលបរិស័ទ ៤ រមែងសម្ដែងមិនក្រៅពីសច្ចៈ ៤ ព្រោះដូច្នោះ ព្រះថេរៈបានឯតទគ្គៈ ព្រោះជាអ្នកមានបញ្ញាច្រើន សូម្បីដោយភាពជាអ្នកជំនាញ ដោយប្រការដូច្នេះ ។

ព្រោះក្រៃលែងដោយគុណ ដូចម្ដេច? ពិតហើយ វៀរព្រះទសពលចេញ

បុគ្គលដទៃណាហ្ន៎ ស្មើជាសាវកឯក ដែលនឹងស្មើដូចព្រះធម្មសេនាបតីសារីបុត្រ រមែងមិនមាន ព្រោះលោកជាអ្នកមានបញ្ញាច្រើន ព្រោះដូច្នោះ ព្រះថេរៈបានតំណែងឯតទគ្គៈ ព្រោះមានបញ្ញាច្រើន ស្មើដោយក្រៃលែងដោយគុណដោយប្រការដូច្នេះ ។

សូម្បីព្រះមហាមោគ្គល្លាន ក៏ដូចជាព្រះសារីបុត្តត្ថេរៈ បានតំណែងជាឯតទគ្គៈ ដោយហេតុសូម្បី ៤ ប្រការនេះទាំងអស់ បានដូចម្តេច? ក៏ព្រះថេរៈមានឫទ្ធិច្រើន មានអានុភាពច្រើន ទូន្មាននាគរាជ ដូចជានន្ទោបនន្ទនាគរាជ ព្រោះដូច្នោះ ព្រះថេរៈ រមែងបានដោយអត្ថុប្បត្តិ ហេតុកើតរឿងយ៉ាងនេះ ជាដំបូង ។ ក៏ព្រះថេរៈនេះ មិនមែនជាអ្នកមានឫទ្ធិច្រើនតែក្នុងបច្ចុប្បន្នប៉ុណ្ណោះ សូម្បីក្នុងអតីត សូម្បីលោកបួសជាឥសី ក៏ជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើនដល់ ៥០០ ជាតិ ។

សាវកណា លះកាមទាំងឡាយ ដែលជាទីរីករាយចិត្ត បួស
៥០០ ជាតិ អ្នកទាំងឡាយចូរថ្វាយបង្គំព្រះសាវកនោះ អ្នក
ប្រាសចាករាគៈ អ្នកមានឥន្ទ្រិយតាំងមាំហើយ រលត់ស្និទ្ធ
ហើយ គឺ មោគ្គល្លាន នេះឯង ។

ក៏លោកបានសូម្បីដោយការមកអំពីមុនយ៉ាងនេះ ។ ក៏ប្រការនោះ ជា

សេចក្ដីជំនាញរបស់ព្រះថេរៈ ។ ព្រះថេរៈទៅនរក អធិដ្ឋានសេចក្ដីត្រជាក់ ដើម្បីឲ្យកើតសេចក្ដីធូរស្រាលចិត្ត ដល់សត្វទាំងឡាយក្នុងនរក ដោយកម្លាំងឫទ្ធិរបស់ខ្លួន ហើយនិម្មិតផ្កាបទុមប៉ុនកង់រទេះ អង្គុយក្នុងត្របកផ្កាបទុមសម្ដែងធម្មកថា ។ លោកទៅទេវលោក ធ្វើពួកទេវឲ្យដឹងគតិនៃកម្ម ហើយសម្ដែងសច្ចកថា ។ ព្រោះដូច្នោះ លោកទើបបានដោយភាពជាអ្នកជំនាញយ៉ាងនេះ ។

បានព្រោះក្រៃលែងដោយគុណ ដូចម្ដេច? វៀរព្រះសម្មាសម្ពុទ្ធហើយ ព្រះសាវកដទៃណាម្នាក់ រមែងមិនមាន ព្រោះដូច្នោះ ព្រះថេរៈបានតំណែងឯតទគ្គៈ ដោយក្រៃលែងដោយគុណយ៉ាងនេះ ។

សូម្បីព្រះមហាកស្សបត្ថេរៈ ក៏បានតំណែងឯតទគ្គៈ ដោយហេតុទាំងអស់នេះ ដូចព្រះមហាមោគ្គល្លាននេះ ។ បានដូចម្ដេច? ការពិត ព្រះសម្មាសម្ពុទ្ធទ្រង់ធ្វើការទទួលព្រះថេរៈអស់រយៈផ្លូវប្រមាណ ៣ គាវុត ទ្រង់ឲ្យឧបសម្បទដោយឱវាទ ៣ ទ្រង់ប្រទានការប្ដូរចីវរឲ្យ ។ ក្នុងសម័យនោះ មហាប្រថពីញាប់ញ័រដល់ទឹកទ្រផែនដី ។ កិត្តិគុណរបស់ព្រះថេរៈ ក៏ខ្ចរខ្ចាយទៅវាងមហាជន ។ លោកបានដោយអត្ថុប្បត្តិ

សាវកណា លះកាមទាំងឡាយ ដែលគួររីករាយចិត្ត
បួស ៥០០ ជាតិ សូមអ្នកទាំងឡាយ ចូរថ្វាយបង្គំ

*សាវកនោះ ដែលប្រាសចាកភគៈ អ្នកមានឥន្ទ្រិយ*

*តាំងមាំល្អហើយ អ្នករលត់ស្និទ្ធ គឺ កស្សបៈនេះ ។*

*លោកបានដោយការមកយ៉ាងនេះ ។ សេចក្តីពិត ប្រការនោះ ជាភាពជំនាញរបស់ព្រះថេរៈ ។ លោកនៅកណ្តាលបរិស័ទ ៤ កាលសម្តែងធម៌ រមែងសម្តែងមិនវៀរចាកកថាវត្ថុ ១០ ឡើយ ព្រោះដូច្នោះ ព្រះថេរៈបានដោយភាពជាអ្នកជំនាញយ៉ាងនេះ ។ វៀរព្រះសម្មាសម្ពុទ្ធចេញ សាវកដទៃណានឹងស្មើ ដូចព្រះមហាកស្សបៈ ដោយធុតង្គគុណ ១៣ មិនមាន ព្រោះដូច្នោះ ព្រះថេរៈបានដោយក្រៃលែងដោយគុណយ៉ាងនេះ ។*

*គួរប្រកាសគុណរបស់ព្រះថេរៈទាំងឡាយនោះៗ តាមដែលបាន ដោយទំនងនេះ ។ ពិតណាស់ កាលពោលដោយអំណាចគុណនុ៎ះឯង ស្តេចចក្រពត្តិទ្រង់សោយសិរីរាជសម្បត្តិ ក្នុងផ្ទៃចក្រវាឡ ដោយអានុភាពនៃចក្ររតន៍ ទ្រង់មិនបានខ្វល់ខ្វាយថា វត្ថុដែលគួរសម្រេច យើងក៏សម្រេចហើយ ឥឡូវនេះនឹងត្រូវការអ្វី ដោយមហាជនដែលយើងថែរក្សាហើយ ទើបសោយតែជាមួយសិរីរាជសម្បត្តិប៉ុណ្ណោះ តែទ្រង់ប្រថាប់អង្គុយក្នុងរោងសាល តាមកាលដែលសមគួរ ទ្រង់គ្របសង្កត់បុគ្គលដែលគួរគ្របសង្កត់ ទ្រង់សរសើរបុគ្គលដែលគួរសរសើរ ទ្រង់តាំងទុកក្នុងឋានន្តរៈទាំងឡាយ ចំពោះឋានន្តរៈដែលគួរតែងតាំង*

ប៉ុណ្ណោះ យ៉ាងណា ព្រះសម្មាសម្ពុទ្ធក៏ដូច្នោះ សូម្បីជាព្រះធម្មរាជា ទ្រង់សម្រេចសេចក្តីជាព្រះរាជា ព្រោះធម៌ដោយលំដាប់ ដោយអានុភាពនៃព្រះសព្វញ្ញុតញ្ញាណ ដែលព្រះអង្គទ្រង់សម្រេចក្នុងមហាពោធិមណ្ឌលស្ថាន ទ្រង់ទូលខ្វាយគិតថា ឥឡូវនេះនឹងត្រូវការអ្វី ពីមនុស្សលោក ដែលតថាគតនឹងត្រូវត្រួតមើល តថាគតនឹងសោយសុខក្នុងផលសមាបត្តិដ៏កំពូល ប្រថាប់នៅលើពុទ្ធាសនៈដ៏ប្រសើរ ដែលគេចាត់ចែងទុកកណ្តាលបរិស័ទ ៤ ទ្រង់បន្លឺព្រះសូរសៀងដូចសំឡេងព្រហ្ម ដែលប្រកបដោយអង្គ ៨ ហើយទ្រង់សម្តែងធម៌ ទ្រង់គ្របសង្កត់បុគ្គលអ្នកមានធម៌ចំណែកខ្មៅ អ្នកគួរគ្របសង្កត់ ដោយការគម្រាម ដោយភ័យក្នុងអបាយ ដូចទ្រង់បោះទៅក្នុងអន្លង់នៃរណ្តៅភ្នំសិនេរុ ទ្រង់សរសើរបុគ្គលដែលមានធម៌ដែលល្អ អ្នកគួរសរសើរ ដូចលើកឲ្យឡើងអង្គុយក្នុងភវគ្គព្រហ្ម ទ្រង់តាំងព្រះសាវក មានព្រះអញ្ញាកោណ្ឌញ្ញត្ថេរៈ ជាដើម អ្នកគួរតាំងទុកក្នុងឋានន្តរៈទាំងឡាយ ឲ្យតាំងក្នុងឋានន្តរៈទាំងឡាយ ដោយអំណាចគុណ ព្រមដោយកិច្ច គឺ នាទីតាមសេចក្តីពិតនុ៎ះឯង ទើបត្រាស់ ពាក្យមានជាដើមថា ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុសាវករបស់តថាគត ជារត្តញ្ញូ ដឹងរាត្រីយូរ អញ្ញាកោណ្ឌញ្ញៈ ប្រសើរបំផុត ដូច្នេះ ។

# រឿងព្រះអញ្ញាកោណ្ឌញ្ញត្ថេរ

[១៨៦] បទថា **ឯតទគ្គំ** ក្នុងបាលីនោះ មានអត្ថបានពោលទុកហើយទាំងនោះ ។ បទថា **រត្តញ្ញូនំ** ប្រែថា អ្នកដឹងរាត្រី ។ ពិតហើយ វៀរព្រះសម្មាសម្ពុទ្ធចេញ សាវកដទៃ ឈ្មោះថា អ្នកបួសមុនព្រះអញ្ញាកោណ្ឌញ្ញត្ថេរៈ មិនមាន ព្រោះហេតុនោះ ព្រះថេរៈរមែងដឹងរាត្រីអស់កាលយូរ ផ្ដើមតាំងពីបួស ហេតុនោះលោកទើបឈ្មោះថាជា **រត្តញ្ញូ** ។ ព្រោះលោកត្រាស់ដឹងធម៌ មុនបុគ្គលណាទាំងអស់ លោកដឹងរាត្រីដែលដឹងច្បាស់ធម៌នោះមកយូរ ព្រោះហេតុនោះ លោកទើបឈ្មោះថា **រត្តញ្ញូ** ។ មយ៉ាងទៀត ការកំណត់យប់ និងថ្ងៃរបស់លោកដែលអស់អាសវៈទាំងឡាយ ជារបស់ប្រាកដច្បាស់ ។ មួយទៀត ព្រះអញ្ញាកោណ្ឌញ្ញត្ថេរៈនេះ ជាអ្នកអស់អាសវៈមុន ព្រោះហេតុនោះ ព្រះអញ្ញាកោណ្ឌញ្ញៈនេះឯង ជាអ្នកក្រៃលែង ជាកំពូលមនុស្សដំបូង ជាអ្នកប្រសើរបំផុត នៃពួកសាវកខាងរត្តញ្ញូ សូម្បីដោយប្រការយ៉ាងនេះ ព្រោះហេតុនោះ ទើបត្រាស់ថា **រត្តញ្ញូនំ យទិទំ អញ្ញាកោណ្ឌញ្ញោ** ដូច្នេះ ។

ក៏ស័ព្ទ **យទិទំ** ក្នុងបាលីនេះ ជានិបាត (បើ) សម្ព័ន្ធយកព្រះថេរៈនោះ មានអត្ថថា **យោ ឯសោ** សម្ព័ន្ធ **អគ្គ** សព្ទ មានអត្ថថា **យំ ឯតំ** ។ បទថា

អញ្ញាកោណ្ឌញ្ញោ ប្រែថា កោណ្ឌញ្ញៈ ដឹងទូទៅហើយ កោណ្ឌញ្ញៈត្រាស់ដឹងហើយ ។ ដោយហេតុនោះឯង ព្រះដ៏មានព្រះភាគទើបត្រាស់ថា ៖

អាញ្ញាសិ វត ភោ កោណ្ឌញ្ញោ អាញ្ញាសិ
វត ភោ កោណ្ឌញ្ញោ ឥតិ ហិទំ អាយស្មតោ
កោណ្ឌញ្ញស្ស អាញ្ញាកោណ្ឌញ្ញោត្វេវ នាមំ
អហោសិ ។

កោណ្ឌញ្ញៈដឹងទូទៅហើយហ្ន៎ កោណ្ឌញ្ញៈដឹងទូទៅហើយហ្ន៎
ព្រោះហេតុនោះឯង ព្រះកោណ្ឌញ្ញៈ ទើបបានឈ្មោះថា
អញ្ញាកោណ្ឌញ្ញៈ ដូច្នេះ ។

គប្បីជ្រាបបញ្ហាកម្ម (កម្មដែលប្រាថ្នាទុកគ្រាដំបូងក្នុងអតីត) ក្នុងព្រះសាវកជាឯតទគ្គៈគ្រប់រូប ដោយន័យនេះថា ក៏ព្រះថេរៈនេះ បានធ្វើសេចក្តីប្រាថ្នាអំពីមុន ឲ្យជាសេចក្តីប្រាថ្នាដ៏ធំក្រៃលែងក្នុងសម័យព្រះពុទ្ធ ព្រះអង្គណា ? លោកបួសកាលណា ? លោកសម្រេចធម៌គ្រាដំបូងកាលណា ? បានទទួលការស្ថាបនាក្នុងតំណែងកាលណា ? បណ្តាព្រះថេរៈជាឯតទគ្គៈទាំងនោះ មុនដំបូងក្នុងបញ្ហាកម្មរបស់ព្រះថេរៈនេះ មានរឿងដែលនឹងពោលតាមលំដាប់ដូចតទៅនេះ ៖

គប្បីជ្រាបបញ្ហាកម្មក្នុងព្រះសាវកជាឯតទគ្គៈគ្រប់រូប ដោយន័យនេះថា ក៏ព្រះថេរៈនេះ បានធ្វើសេចក្ដីប្រាថ្នាកាលមុន ឲ្យជាសេចក្ដីប្រាថ្នាដ៏ធំក្រៃលែង ក្នុងសម័យព្រះពុទ្ធ ព្រះអង្គណា ? លោកបួសកាលណា ? លោកសម្រេចធម៌គ្រាដំបូងកាលណា ? បានទទួលស្ថាបនាក្នុងតំណែងកាលណា ? បណ្ដាព្រះថេរៈជាឯតទគ្គៈទាំងនោះ មុនដំបូងក្នុងបញ្ហាកម្មរបស់ព្រះថេរៈនេះ មានរឿងដែលនឹងពោលតាមលំដាប់ដូចតទៅនេះ ៖

ចុងសែនកប្បពីកទ្ទកប្បនេះ ព្រះពុទ្ធទ្រង់ព្រះនាមថា **បទុមុត្តរៈ** ឧប្បត្តិឡើងក្នុងលោក កាលព្រះអង្គត្រាស់ដឹងព្រះសព្វញ្ញុតញ្ញាណ ស្ដេចក្រោកចាកមហាពោធិបល្ល័ង្ក ពេលលើកព្រះបាទឡើងដើម្បីដាក់លើមហាប្រថពី ផ្កាបទុមដ៏ធំផុសឡើងទទួលព្រះបាទ ។ ផ្កាបទុមនោះត្របកវែង ៩០ ហត្ថ កេសរ ៣០ ហត្ថ កញ្ចុំផ្កា ១២ ហត្ថ ទីប្រតិស្ឋានព្រះបាទ ១១ ហត្ថ ។ ព្រះសរីរៈរបស់ព្រះដ៏មានព្រះភាគនោះ កម្ពស់ ៥៨ ហត្ថ កាលព្រះបាទស្ដាំរបស់ព្រះអង្គប្រតិស្ឋាននៅលើកញ្ចុំបទុម លម្អងកេសរប្រមាណ មួយនាឡិធំហុយឡើង រោយព្រះសរីរៈ ។ សូម្បីក្នុងវេលាដាក់ព្រះបាទឆ្វេង ផ្កាបទុមក៏បែបនោះឯង ផុសឡើងទទួលព្រះបាទ ។ លម្អងមានខ្នាត ដូចពោលហើយនុ៎ះឯង ហុយឡើងពីនោះរោយស្រោចព្រះសរីរៈរបស់ព្រះដ៏មានព្រះភាគនោះ ។ ក៏រស្មីព្រះសរីរៈរបស់

ព្រះដ៏មានព្រះភាគ ថ្លែងចេញគ្រប់ដណ្តប់ល្អនោះ ធ្វើទីប្រមាណ ១២ យោជន៍ ដោយជុំវិញ ឲ្យមានពន្លឺតែមួយ ដូចខ្សែទឹកមាសដែលបាញ់ចេញពីទវយន្ត ។ ក្នុងវេលាឈានព្រះបាទគ្រាទី ៣ ផ្កាបទុមដែលផុសឡើងមុន ក៏បាត់ទៅ ។ ផ្កាបទុមថ្មីដទៃ ក៏ផុសឡើងទទួលព្រះបាទ ។ ដោយទំនងនេះឯង ព្រះអង្គបំណាងនឹងស្តេចទៅក្នុងទីណាៗ ផ្កាបទុមធំក៏ផុសឡើងក្នុងទីនោះៗ គ្រប់ជំហានព្រះបាទ ។ ដោយហេតុនោះឯង ព្រះអង្គទើបមានព្រះនាមថា **បទុមុត្តរសម្មាសម្ពុទ្ធ** ។

ព្រះដ៏មានព្រះភាគនោះ ទ្រង់ឧប្បត្តិឡើងក្នុងលោកយ៉ាងនេះ មានភិក្ខុសែនរូបជាបរិវារ ស្តេចត្រាច់ភិក្ខាក្នុងគាមនិគម និងរាជធានី ដើម្បីសង្គ្រោះមហាជន ស្តេចដល់ក្រុងហង្សវតី មហារាជដែលជាព្រះពុទ្ធបិតា ទ្រង់ជ្រាបដំណឹងថា ព្រះសាស្តានោះស្តេចមក ទើបបានស្តេចចេញទៅទទួល ។ ព្រះសាស្តាបានត្រាស់ធម្មកថា ចំពោះព្រះពុទ្ធបិតា ។ ចប់ទេសនា ពួកខ្លះជាព្រះសោតាបន្ន ពួកខ្លះជាព្រះសកទាគាមី ពួកខ្លះជាព្រះអនាគាមី ពួកខ្លះសម្រេចព្រះអរហត្ត ។ ព្រះរាជាទ្រង់និមន្តព្រះទសពល ដើម្បីសោយភត្តាហារក្នុងថ្ងៃស្អែក ក្នុងថ្ងៃស្អែកទ្រង់ឲ្យប្រាប់វេលា (ភត្តាហារ) បានថ្វាយមហាទាន ក្នុងព្រះរាជនិវេសន៍របស់ព្រះអង្គ ចំពោះព្រះដ៏មានព្រះភាគ មានភិក្ខុមួយសែនរូបជាបរិវារ ។ ព្រះសាស្តាទ្រង់ធ្វើភត្តានុមោទនាហើយ ស្តេចទៅព្រះវិហារដូចដើម ។ ដោយទំនងនោះ

ឯង បានថ្វាយទានរហូតអស់កាលយូរ គឺ ថ្ងៃស្អែកអ្នកក្រុងថ្វាយ ថ្ងៃស្អែក (តទៅ) ព្រះរាជាថ្វាយ ។

គ្រានោះ ព្រះថេរៈនេះ កើតក្នុងត្រកូលគហបតីមហាសាល ក្នុងក្រុងហង្សវតី ។ ថ្ងៃមួយ ក្នុងវេលាដែលព្រះពុទ្ធទ្រង់សម្តែងធម៌ គេឃើញអ្នកក្រុងហង្សវតីផ្សេងៗ កាន់គ្រឿងក្រអូប និងផ្កាឈើជាដើម អ្នកខ្លះបង្អោនទៅ ឱនទៅទោរទៅ ក្នុងព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ហើយបានទៅកាន់ទីសម្តែងធម៌ ព្រមនឹងមហាជននោះឯង ។ សម័យនោះ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមថា បទុមុត្តរៈ ទ្រង់ស្ថាបនាភិក្ខុមួយរូប អ្នកត្រាស់ដឹងធម៌មុនគេក្នុងព្រះសាសនារបស់ព្រះអង្គ ទុកក្នុងតំណែងឯតទគ្គៈ ។ កុលបុត្រនោះ បានស្តាប់ហេតុនោះហើយ គិតថា ភិក្ខុនេះ ជាអ្នកធំហ្ន៎ បានឮថា វៀរព្រះពុទ្ធចេញ អ្នកដទៃឈ្មោះថា អ្នកត្រាស់ដឹងធម៌មុនគេក្រៅពីភិក្ខុនេះ រមែងមិនមាន សូម្បីយើងគប្បីជាអ្នកអាចត្រាស់ដឹងធម៌មុន ក្នុងសាសនារបស់ព្រះពុទ្ធមួយព្រះអង្គ ក្នុងអនាគត ក្នុងវេលាចប់ទេសនា ទើបចូលគាល់ព្រះដ៏មានព្រះភាគ និមន្តថា ស្អែកនេះសូមព្រះអង្គមេត្តាទ្រង់ទទួលភិក្ខារបស់ខ្ញុំព្រះអង្គ ។ ព្រះសាស្តា ទ្រង់ទទួលនិមន្តហើយ កុលបុត្រនោះ ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ ធ្វើប្រទក្សិណទៅកាន់ទីនៅរបស់ខ្លួន ប្រដាប់ទីប្រថាប់សម្រាប់ព្រះពុទ្ធ ដោយគ្រឿងក្រអូប និងកម្រង

ផ្កាជាដើម ឲ្យបាត់របស់គួរទំពារ និងគួរបរិភោគដ៏ប្រណីត រហូតអស់មួយយប់រហូតភ្លឺ ។ កន្លងរាត្រីនោះ បានថ្វាយស្រូវសាលីក្រអូប មានសម្ល និងបាយផ្សេងៗ រស មានបាយយាគូ និងរបស់ទំពារដ៏វិចិត្រជាបរិវារ ចំពោះព្រះដ៏-មានព្រះភាគ មានភិក្ខុ ១០០.០០០ រូបជាបរិវារ ក្នុងទីនៅរបស់ខ្លួន ក្នុងវេលាស្រេចភត្តកិច្ច បានដាក់សំពត់គួលមធ្វើចីវរបានបីផ្ទាំង ជិតព្រះបាទរបស់ព្រះ-តថាគត គិតថា យើងមិនបានសូម ដើម្បីប្រយោជន៍ដល់តំណែងតិចតួច យើងប្រាថ្នាតំណែងធំទើបសូម តែយើងមិនអាចឲ្យទានត្រឹមតែមួយថ្ងៃប៉ុណ្ណោះ ហើយប្រាថ្នាតំណែងនោះ ទើបគិត (ទៀត) ថា នឹងថ្វាយទានរហូតដល់អស់ ៧ ថ្ងៃឲ្យជាប់តគ្នា ហើយទើបនឹងប្រាថ្នា ។ ដោយទំនងនោះឯង គេទើបថ្វាយមហា-ទាន ៧ ថ្ងៃ ក្នុងវេលាស្រេចភត្តកិច្ច បានឲ្យបើកឃ្លាំងសំពត់ដាក់សំពត់សាច់ល្អិតដ៏យ៉ាងប្រណីត តម្កល់ទុកជិតព្រះបាទនៃព្រះពុទ្ធ ឲ្យភិក្ខុ ១០០.០០០ រូបគ្រងត្រៃចីវរហើយ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្រោយ ៧ ថ្ងៃ រាប់ពីថ្ងៃនេះ ខ្ញុំព្រះអង្គ គប្បីជាអ្នកអាចបួសក្នុងសាសនារបស់ព្រះពុទ្ធ ដែលនឹងឧប្បត្តិក្នុងអនាគត ហើយដឹងច្បាស់ធម៌បានមុនដូចភិក្ខុនេះ ហើយក្រាបសិរសៈចុះជិតព្រះបាទរបស់ព្រះសាស្ដា ។ ព្រះសាស្ដាទ្រង់ស្ដាប់ពាក្យនោះហើយ ទ្រង់បញ្ជូនអនាគតង្សញ្ញាណទៅ ពិចារណាមើលថា

កុលបុត្រនេះ បានធ្វើបុញ្ញាធិការទុកច្រើន សេចក្តីប្រាថ្នារបស់គេនឹងសម្រេច ទេហ្ន៎ កាលទ្រង់រំពឹង ក៏ទ្រង់ឃើញសេចក្តីសម្រេច ។ ពិតណាស់ កាលព្រះពុទ្ធទាំងឡាយ ទ្រង់រំពឹងដល់អតីត អនាគត ឬបច្ចុប្បន្ន រមែងមិនមានអ្វីជំទាស់ឡើយ ។ ហេតុដែលជាអតីត ឬហេតុដែលជាអនាគត ដែលប្រព្រឹត្តទៅក្នុងខាងក្នុងរវាងសែនកោដិកប្បដ៏ច្រើនក្តី បច្ចុប្បន្នរវាងសែនចក្រវាឡក្តី រមែងទាក់ទងដោយការនឹក ទាក់ទងដោយមនសិការទាំងនោះ ។

ព្រះដ៏មានព្រះភាគអង្គនេះ ទ្រង់បានឃើញហេតុនេះ ដោយញាណដែលមិនមាននរណាៗ ឲ្យប្រព្រឹត្តទៅបាន ថា ក្នុងអនាគត ក្នុងទីបំផុតសែនកប្បព្រះពុទ្ធទ្រង់ព្រះនាមថា **គោតម** នឹងឧប្បត្តិឡើងក្នុងលោក គ្រានោះ សេចក្តីប្រាថ្នារបស់កុលបុត្រនេះ នឹងសម្រេច ។ លំដាប់នោះ ព្រះដ៏មានព្រះភាគត្រាស់ចំពោះកុលបុត្រនោះ យ៉ាងនេះថា ម្នាលកុលបុត្រដ៏ចម្រើន ក្នុងអនាគត ក្នុងទីបំផុតសែនកប្ប ព្រះពុទ្ធទ្រង់ព្រះនាមថា **គោតម** នឹងឧប្បត្តិឡើងក្នុងលោក លោកនឹងតាំងនៅក្នុងសោតាបត្តិផល ដែលដល់ព្រមដោយពាន់ន័យ ព្រមជាមួយព្រហ្ម ១៨ កោដិ ក្នុងវេលាចប់ព្រះធម្មចក្កប្បវត្តនសូត្រ ដែលមានបរិវដ្ដៈ ៣ ដោយការសម្តែងធម៌លើកដំបូង របស់ព្រះគោតមសម្ពុទ្ធអង្គនោះ ។

ព្រះសាស្តា លុះទ្រង់ព្យាករណ៍កុលបុត្រនោះដូច្នេះហើយ ទ្រង់សម្តែង

ធម៌ ៨៤.០០០ ព្រះធម្មក្ខន្ធ ហើយបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ , ព្រះសរីរៈរបស់ព្រះអង្គ ដែលបរិនិព្វានហើយ បានជាដុំតែមួយ ដូចជាដុំមាសដូច្នោះ ។ ក៏ជនទាំងឡាយបានសាងព្រះចេតិយ បញ្ចុះព្រះសរីរៈរបស់ព្រះអង្គកម្ពស់ ៧ យោជន៍ ឥដ្ឋទាំងឡាយសុទ្ធហើយដោយមាស ជនទាំងឡាយប្រើហរតាល និងមនោសិលាជំនួសជីស្អិត ប្រើប្រេងល្ងជំនួសទឹក ក្នុងវេលាដែលព្រះពុទ្ធទាំងឡាយ ទ្រង់នៅព្រះជន្ម រស្មីនៃព្រះសរីរៈផ្សាយទៅ ១២ យោជន៍ ។ ក៏កាលព្រះពុទ្ធទាំងឡាយបរិនិព្វានហើយ រស្មីនោះ ផ្សាយចេញគ្របដណ្តប់ទីមួយរយយោជន៍ដោយជុំវិញ ។ សេដ្ឋីនោះ ឲ្យសាងរបស់គួរ តម្លៃស្មើរតនៈពាន់ដួង លោមព័ទ្ធចេតិយបញ្ចុះព្រះសរីរៈរបស់ព្រះពុទ្ធជាម្ចាស់ ។ ក្នុងថ្ងៃប្រតិស្ឋានព្រះចេតិយ ឲ្យសាងផ្ទះកែវខាងក្នុងចេតិយ ។ សេដ្ឋីនោះធ្វើកល្យាណកម្មដោយការធ្វើទានធំតែម្យ៉ាងអស់សែនឆ្នាំ ឃ្លាតចាកអត្តភាពនោះហើយ ទៅកើតក្នុងសួគ៌ ។ កាលសេដ្ឋីនោះត្រាច់អន្ទោលនៅក្នុងទេវតា និងមនុស្សទាំងឡាយនុ៎ះឯង កន្លងទៅ ៩៩.៩០៩ កប្ប កាលកាលកន្លងទៅប៉ុណ្ណោះ ក្នុងចុងកប្បទី ៩១ អំពីកប្បនេះ កុលបុត្រនេះកើតក្នុងផ្ទះនៃកុដុម្ពិកៈ ក្នុងពាមគ្រាម ជិតទ្វារក្រុងពន្ធុមតី បាននាមថា **មហាកាល** ចំណែកប្អូនប្រុសរបស់លោក នាមថា ចូឡកាល ។

សម័យនោះ ព្រះពោធិសត្វព្រះនាមថា **វិបស្សី** ចុតិចាកតុសិតបុរី កើតក្នុងព្រះគភ៌របស់ព្រះអគ្គមហេសី របស់ព្រះបាទពន្ធុមៈ ក្រុងពន្ធុមតី សម្រេចព្រះសព្វញ្ញុតញ្ញាណដោយលំដាប់ ដែលស្តេចមហាព្រហ្មបានអារាធនា ដើម្បីប្រយោជន៍ដល់ការសម្តែងធម៌ ទើបត្រិះរិះថា តថាគតនឹងសម្តែងធម៌ដល់នរណាមុនហ្ន៎ ទ្រង់ឃើញព្រះរាជកុមារ ទ្រង់ព្រះនាមថា **ខណ្ឌៈ** ដែលជាព្រះកនិដ្ឋារបស់ព្រះអង្គ និងបុត្របុរោហិត ឈ្មោះ **តិស្សៈ** ថា ជាអ្នកអាចត្រាស់ដឹងធម៌មុន ទើបទ្រង់ត្រិះរិះថា តថាគតនឹងសម្តែងធម៌ដល់ជនទាំងពីរនោះ មុននឹងសង្គ្រោះព្រះពុទ្ធបិតា ទើបស្តេចហោះមកពីពោធិមណ្ឌស្ថាន ចុះត្រង់ខេមមិគទាយវ័ន ត្រាស់បង្គាប់ឲ្យហៅអ្នកទាំង ២ នោះមក ហើយសម្តែងធម៌ ។ ក្នុងវេលាចប់ទេសនា ជនទាំងពីរតាំងនៅក្នុងព្រះអរហត្តផល ព្រមទាំងសត្វលោក ៨៤.០០០ នាក់ ។ មួយពួកទៀត ដែលបួសតាម ក្នុងវេលាព្រះអង្គជាព្រះពោធិសត្វ ស្តាប់រឿងនោះហើយ ក៏មកគាល់ព្រះសាស្តា ស្តាប់ធម៌ទេសនា តាំងនៅក្នុងព្រះអរហត្តផល ។ ក្នុងទីនោះឯង ព្រះសាស្តា ទ្រង់ស្ថាបនា **ព្រះខណ្ឌត្ថេរៈ** ទុកក្នុងតំណែងព្រះអគ្គសាវកទី ១ , ទ្រង់ស្ថាបនា **ព្រះតិស្សត្ថេរៈ** ទុកក្នុងតំណែងអគ្គសាវកទី ២ ។

ចំណែកព្រះរាជា ទ្រង់ស្តាប់រឿងនោះហើយ ទ្រង់ព្រះព្រះតម្រិះថា នឹង

សួរសុខទុក្ខបុត្រ ទើបស្ដេចទៅព្រះរាជឧទ្យាន ទ្រង់ស្ដាប់ព្រះធម៌ទេសនា តាំងនៅក្នុងរតនៈ ៣ និមន្តព្រះសាស្ដាដើម្បីសោយភត្តាហារ ថ្វាយបង្គំហើយ ធ្វើប្រទក្សិណ ហើយស្ដេចត្រឡប់ ព្រះអង្គឡើងកាន់ប្រាសាទដ៏ប្រសើរប្រថាប់អង្គុយទ្រង់ត្រិះរិះថា បុត្រច្បងរបស់យើងចេញបួស ជាព្រះពុទ្ធ បុត្រទី ២ របស់យើងក៏ជាអគ្គសាវក បុត្របុរោហិតជាសាវកទី ២ និងភិក្ខុដ៏សេសទាំងនេះ ក្នុងវេលាជាគ្រហស្ថ ត្រាច់ហែហមបុត្ររបស់យើងប៉ុណ្ណោះ ភិក្ខុទាំងនេះ ទាំងកាលមុនទាំងឥឡូវនេះ ជាភារៈរបស់យើងតែម្យ៉ាង យើងប៉ុណ្ណោះនឹងទំនុកបម្រុងភិក្ខុទាំងនោះ ដោយបច្ច័យ ៤ នឹងមិនឲ្យឱកាសដល់ពួកដទៃ ទើបឲ្យសាងបង្គោលចង្កៀងឈើសងខាង តាំងពីទ្វារព្រះវិហារ ដរាបដល់ទ្វារតំណាក់ព្រះរាជនិវេសន៍ឲ្យបាំងដោយសំពត់ ឲ្យសាងពិតានកម្រងផ្កាឈើផ្សេងៗ សូម្បីដើមត្នោតឲ្យវិចិត្រដោយផ្កាយមាសចងជារំយោល ឲ្យក្រាលផ្ទៃដីដោយកម្រាលដ៏វិចិត្រ ឲ្យតាំងថ្នាំងទឹកទុកជិតគំនរកម្រងផ្កា និងគ្រឿងក្រអូប ទាំងសងខាង ដាក់ផ្កាឈើទុកចន្លោះរបស់ក្រអូប និងដាក់របស់ក្រអូបទុកក្នុងចន្លោះផ្កាឈើ ដើម្បីឲ្យក្លិនបក់សព្វក្នុងផ្លូវ ហើយក្រាបទូលវេលាដល់ព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគ ដែលពួកភិក្ខុហែហមហើយ ស្ដេចទៅកាន់ព្រះរាជមណ្ឌប ធ្វើភត្តកិច្ចហើយ ត្រឡប់មកកាន់វិហារខាងក្នុងរាំងនទន្ទុះឯង ។ នរណាៗ ដទៃ សូម្បីនឹង

មើលក៏មិនបាន ដូចម្ដេចនឹងបានថ្វាយភិក្ខាហារ និងការបូជា ។

អ្នកព្រះនគរគិតថា កាលព្រះសាស្ដាស្ដេចឧប្បត្តិឡើងក្នុងលោក អស់វេលា ៧ ឆ្នាំ ៧ ខែ ក្នុងថ្ងៃនេះ ពួកយើងក៏មិនទាន់បានគាល់ នឹងចាំបាច់ពោលទៅថ្វី ដែលនឹងបានថ្វាយភិក្ខា ធ្វើការបូជា ឬស្ដាប់ធម៌ ព្រះរាជាប្រកាន់ថា ព្រះពុទ្ធជារបស់យើង ព្រះសង្ឃជារបស់យើង ទើបទ្រង់ទំនុកបម្រុងដោយព្រះអង្គឯង ព្រះសាស្ដា កាលស្ដេចឧប្បត្តិ ក៏ឧប្បត្តិដើម្បីប្រយោជន៍ដល់លោក ព្រមទាំងទេវលោក មិនមែនឧប្បត្តិដើម្បីប្រយោជន៍ដល់ព្រះរាជាប៉ុណ្ណោះទេ នរកជារបស់ក្ដៅសម្រាប់ព្រះរាជាព្រះអង្គតែមួយ ចំណែកជនដទៃដូចជាផ្កាឧប្បលខៀវក៏ទេ ព្រោះដូច្នោះ យើងនឹងក្រាបទូលព្រះរាជាយ៉ាងនេះថា បើព្រះរាជាប្រទានព្រះសាស្ដាដល់ពួកយើង ប្រការនោះជាការល្អ បើមិនឲ្យ ពួកយើងនឹងច្បាំងជាមួយព្រះរាជា ហើយទទួលសង្ឃទៅធ្វើបុណ្យ មានទានជាដើម ក៏អ្នកព្រះនគរទាំងនោះ មិនអាចធ្វើយ៉ាងនេះបាន ពួកយើងនឹងកាន់យកអ្នកដែលជាប្រធានម្នាក់ ដូច្នេះ ទើបចូលទៅរកសេនាបតី ប្រាប់សេចក្ដីនោះដល់លោក ហើយពោលថា នាយ លោកជាចំណែកខាងយើង ឬជាចំណែកខាងព្រះរាជា សេ-នាបតីពោលថា យើងនឹងជាចំណែកខាងលោក ប៉ុន្តែថា ពួកលោកត្រូវឲ្យយើងថ្ងៃដំបូង ។ អ្នកព្រះនគរក៏យល់ព្រម ។ សេនាបតីចូលទៅគាល់ព្រះរាជា ក្រាប

ទូលថា បពិត្រព្រះសម្មតិទេព អ្នកព្រះនគរក្រោធនឹងព្រះអង្គ ។ ព្រះរាជាសួរ ថា ក្រោធរឿងអ្វី បា! ។ សេនាបតីក្រាបទូលថា បានឮថា ព្រះអង្គប៉ុណ្ណោះ ទំនុកបម្រុងព្រះសាស្តា ពួកយើងមិនបាន ហើយទូលថា បើពួកគេបាន គេមិនក្រោធ កាលមិនបាន គេនឹងច្បាំងជាមួយព្រះអង្គ ។ ព្រះរាជាត្រាស់ថា ច្បាំងក៏ច្បាំងចុះ បា! យើងមិនឲ្យភិក្ខុសង្ឃទេ សេនាបតីទូលថា បពិត្រព្រះសម្មតិទេព ពួកទាសៈរបស់ព្រះអង្គ និយាយថា ច្បាំងជាមួយព្រះអង្គហើយ ព្រះអង្គនឹងយកនរណាច្បាំង ព្រះរាជាត្រាស់ថា លោកជាសេនាបតី មិនមែនឬ? សេនាបតីទូលថា ចំពោះអ្នកនគរបេញ ខ្ញុំព្រះអង្គមិនអាចទេព្រះអង្គ ។ លំដាប់នោះព្រះរាជាជ្រាបថា អ្នកនគរមានកម្លាំង ទាំងសេនាបតីក៏ជាចំណែករបស់អ្នកនគរទាំងនោះដូចគ្នា ទើបត្រាស់ថា សូមអ្នកនគរឲ្យភិក្ខុសង្ឃដល់យើង ៧ ឆ្នាំ ៧ ខែ ។ អ្នកនគរមិនព្រម ព្រះរាជាទ្រង់ឲ្យថយចុះយ៉ាងនេះ គឺ ៦ ឆ្នាំ ៥ ឆ្នាំ ទើបសូមទៀត ៧ ថ្ងៃ ។ អ្នកនគរយល់ព្រម ដោយឃើញថា ការដែលយើងធ្វើកម្មដ៏គ្រោតគ្រាតយូរជាមួយព្រះរាជាក្នុងឥឡូវនេះ មិនសមគួរ ។ ព្រះរាជាទ្រង់ចាត់មុខទាន (ទានដែលជាប្រធាន) ដែលរៀបចំទុកសម្រាប់ ៧ ឆ្នាំ ៧ ខែ ដើម្បី ៧ ថ្ងៃប៉ុណ្ណោះ ដែលលនរណាៗ មិនទាន់ឃើញនៅឡើយ ទ្រង់ឲ្យទានអស់ ៦ ថ្ងៃ ក្នុងថ្ងៃទី ៧ ទើបឲ្យហៅអ្នកនគរមក ត្រាស់ថា ម្នាលបា! ទាំងឡាយ

ពួកលោកនឹងអាចឲ្យទានបែបនេះឬ ។ អ្នកព្រះនគរទាំងនោះ ក្រាបទូលថា ទាននោះ កើតឡើងដល់ព្រះអង្គ ព្រោះអាស្រ័យពួកខ្ញុំព្រះអង្គប៉ុណ្ណោះ មិនមែនឬ? ព្រោះដូច្នោះ ពួកខ្ញុំព្រះអង្គនឹងអាចថ្វាយទានបាន ។ ព្រះរាជាទ្រង់យកខ្នងព្រះហស្ត ជូតទឹកព្រះនេត្រ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគិតថា នឹងធ្វើភិក្ខុ ៦.៨០០.០០០ រូប ឲ្យជាការៈ ហើយទំនុកបម្រុងដោយបច្ច័យ ៤ រហូតអស់មួយជីវិត ឥឡូវនេះ ខ្ញុំព្រះអង្គ អនុញ្ញាតឲ្យអ្នកព្រះនគរហើយ បពិត្រព្រះដ៏មានព្រះភាគ អ្នកនគរគេក្រោធថា ពួកគេមិនបានថ្វាយទាន តាំងពីស្អែកនេះទៅ មេត្តាទ្រង់អនុគ្រោះដល់អ្នកព្រះនគរទាំងនោះចុះ ។ លុះក្នុងថ្ងៃទី ២ សេនាបតីបានថ្វាយមហាទាន ។ តអំពីនោះ អ្នកព្រះនគរ ធ្វើសក្ការៈ និងការបូជា ដ៏ក្រៃលែងជាងសក្ការៈដែលព្រះរាជាទ្រង់ធ្វើហើយ បានថ្វាយទាន ។ ដោយទំនងនោះឯង កាលដល់លំដាប់របស់អ្នកព្រះនគរទូទៅ អ្នកស្រុកដែលនៅជិតទ្វារ បានត្រៀមសក្ការៈបូជាហើយ ។

កុដុម្ពិកៈមហាកាល ពោលនឹងកុដុម្ពិកៈចូឡកាលថា សក្ការៈ និងការបូជារបស់ព្រះទសពល ដល់យើងថ្ងៃស្អែកនេះ យើងនឹងធ្វើសក្ការៈ យ៉ាងណា? ចូឡកាលពោលថា បងប្រុស បងប៉ុណ្ណោះ ចូរដឹង ។ មហាកាលពោលថា បើអ្នកធ្វើតាមការពេញចិត្តរបស់យើង ស្រូវសាលីដែលកំពុងផើម ហើយមាននៅ

ក្នុងស្រែ ប្រមាណ ១៦ ករីសៈរបស់យើង យើងនឹងឲ្យហែកពោះស្រូវសាលី យកមកស្ល ឲ្យសមគួរដល់ព្រះពុទ្ធជាម្ចាស់ ចូឡកាលពោលថា កាលធ្វើយ៉ាងនេះ រមែងមិនជាឧបការៈដល់នរណាៗ ព្រោះដូច្នោះ ខ្ញុំមិនពេញចិត្តប្រការនោះ ។ មហាកាលពោលថា បើប្អូនពោលយ៉ាងនេះ ខ្ញុំក៏នឹងធ្វើតាមសេចក្តីពេញចិត្តរបស់ខ្ញុំ ហើយទើបបែងចែកស្រែ ១៦ ករីសៈ ជា ២ ចំណែកស្មើគ្នា កំណត់ទី ៨ ករីសៈ បកស្រូវសាលីយកទៅរំងាស់ជាមួយទឹកដោះ ដាក់របស់ផ្អែម ៤ ប្រភេទ ហើយថ្វាយចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ទីដែលបកពោះស្រូវសាលីនោះហើយ ក៏ត្រឡប់ជាដុះពេញវិញ ។ ក្នុងវេលាអំបុក បានថ្វាយចំណែកដ៏ប្រសើរក្នុងអំបុក ក្នុងវេលាស្រូវទុំ វេលាច្រូតកាត់ ក្នុងវេលាធ្វើគំនួចចងកណ្តាប់ ក្នុងវេលាចង ក្នុងវេលាជញ្ជូនដាក់លាន ក្នុងវេលាបោក និងក្នុងវេលាជញ្ជូនដាក់ជង្រុក បានថ្វាយចំណែកប្រសើរក្នុងវេលានោះៗ បានថ្វាយទានតាមវេលា ៩ ដង ដូចពោលមក ដូច្នេះ តែសន្ទូងសូម្បីនោះ ក៏តាំងនៅបរិបូរណ៍ ។ លោកធ្វើកម្មល្អតាមទំនងនោះឯង ដរាបដែលព្រះពុទ្ធទ្រង់ព្រះជន្មនៅ និងដរាបដែលព្រះសង្ឃនៅមាន (គ្រា) ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក ។ លោកត្រាច់រង្គាត់ទៅក្នុងទេវតា និងមនុស្ស ដោយសម្បត្តិអស់ ៩១ កប្ប ។ ក្នុងវេលាដែលព្រះសាស្តារបស់យើង ទ្រង់ឧប្បត្តិឡើងក្នុង

លោក ក៏កើតក្នុងត្រកូលព្រាហ្មណ៍មហាសាល ក្នុងស្រុកព្រាហ្មណ៍ទោណវត្ថុ មិនឆ្ងាយពីក្រុងកបិលភ័ស្តុ ។ ក្នុងថ្ងៃដាក់នាម ពួកញាតិបានដាក់នាមលោកថា **កោណ្ឌញ្ញមាណព** ។ លោកចម្រើនវ័យហើយ រៀនចប់ត្រៃវេទ លក្ខណៈមន្ត ទាំងឡាយ (តម្រាទាយលក្ខណៈ) ។

សម័យនោះ ព្រះពោធិសត្វរបស់យើងទាំងឡាយ ចុតិចាកស្ថានសួគ៌ជាន់តុសិត កើតក្នុងក្រុងកបិលភ័ស្តុ ក្នុងថ្ងៃថ្វាយព្រះនាមរបស់ព្រះអង្គ ព្រះញាតិបានអញ្ជើញព្រាហ្មណ៍ ១០៨ នាក់ ស្លៀកដណ្តប់សំពត់ថ្មី ឲ្យបរិភោគបាយមធុបាយាសមានទឹកតិច ជ្រើសរើសព្រាហ្មណ៍ ៨ នាក់ ក្នុងចំណោមព្រាហ្មណ៍ ១០៨ នោះ ឲ្យអង្គុយលើផែនដីធំ ឲ្យព្រះពោធិសត្វដែលប្រដាប់តាក់តែងហើយ ដេកលើកម្រាលសំពត់ដែលធ្វើដោយសំពត់សាច់ល្អិត នាំមកកាន់សម្នាក់របស់ព្រាហ្មណ៍ទាំងនោះ ដើម្បីត្រួតមើលព្រះលក្ខណៈ ។ ព្រាហ្មណ៍ដែលអង្គុយលើអាសនៈធំ ត្រួតមើលសម្បត្តិនៃព្រះសរីរៈ របស់ព្រះមហាបុរសហើយ លើកម្រាមដៃ ២ ឡើង ។ ៧ នាក់ លើកឡើងតាមលំដាប់យ៉ាងនេះ ។ ក៏បណ្តាព្រាហ្មណ៍ ៨ នាក់នោះ កោណ្ឌញ្ញមាណពដែលក្មេងជាងគេ ពិនិត្យមើលលក្ខណៈដ៏ប្រសើរ លើកម្រាមដៃឡើងតែមួយប៉ុណ្ណោះថា មិនមានហេតុដែលព្រះអង្គនឹងនៅគ្រប់គ្រងផ្ទះ ព្រះកុមារនេះ នឹងជាព្រះពុទ្ធមានកិលេសដូចដំបូល

ដែលបើកហើយតែម្យ៉ាង ចំណែកអ្នកទាំង ៧ នេះ ឃើញគតិជា ២ ថា បើ នៅគ្រប់គ្រងផ្ទះនឹងបានជាស្តេចចក្រពត្តិ បើបួសនឹងជាព្រះពុទ្ធ ទើបលើកម្រាមដៃ ២ ឡើង ។ ក៏ព្រះអញ្ញាកោណ្ឌញ្ញៈនេះ បានសាងបុញ្ញាធិការទុក ជាសត្វកើតក្នុងភពចុងក្រោយ ប្រសើរជាងអ្នកទាំង ៧ នេះ ដោយបញ្ញា បានឃើញគតិត្រឹមតែម្យ៉ាងថា ឈ្មោះថា បុគ្គលប្រកបដោយលក្ខណៈទាំងនេះ មិននៅគ្រប់គ្រងផ្ទះឡើយ នឹងជាព្រះពុទ្ធដោយមិនមានសង្ស័យ ព្រោះដូច្នោះ ទើបលើកតែម្រាមដៃ ១ ។ លំដាប់នោះ ព្រាហ្មណ៍ទាំងនោះទៅកាន់ផ្ទះរៀងៗ ខ្លួនប្រឹក្សានឹងបុត្រទាំងឡាយថា កូនអើយ ឱពុកចាស់ហើយ នឹងបានការសរសើរឬមិនបាន ព្រះឱរសរបស់ព្រះបាទសុទ្ធោទនមហារាជ នឹងសម្រេចព្រះសព្វ-ញ្ញុតញ្ញាណ ពួកអ្នក កាលព្រះកុមារសម្រេចព្រះសព្វញ្ញុតញ្ញាណហើយ គប្បីបួសក្នុងព្រះសាសនារបស់ព្រះអង្គ ។

ចំណែកព្រះបាទសុទ្ធោទនមហារាជ ទ្រង់ចាត់ការរក្សា ដូចជា ចាត់ចែងស្រីស្នំជាដើម ថែរក្សាដល់ព្រះពោធិសត្វ ចំណែកព្រះពោធិសត្វទ្រង់ចម្រើនវ័យហើយ សោយសម្បត្តិដូចទេព កាលព្រះញាណចាស់ក្លាហើយ ទ្រង់ឃើញទោសក្នុងកាម ឃើញអានិសង្សក្នុងការចេញចាកកាម ទើបក្នុងថ្ងៃដែលព្រះ-រាហុលកុមារប្រសូតិ មាននាយឆន្នៈជាព្រះសម្លាញ់ ទ្រង់ប្រថាប់លើសេះកណ្ឋកៈ

ស្ដេចចេញសាងមហាភិនេសក្រមណ៍ តាមទ្វារដែលទេវតាបើកឲ្យ ស្ដេចកន្លងទៅ ៣ រាជាណាខេត្ត រហូតដល់វេលាកណ្ដាលយប់នោះឯង ទ្រង់បព្វជ្ជាត្រង់ច្រាំងស្ទឹងអនោមានទី ពេលទ្រង់ទទួលទង់ជ័យនៃព្រះអរហន្ត ដែលស្ដេចឃដិការមហាព្រហ្មនាំមកថ្វាយប៉ុណ្ណោះ ដូចជាព្រះថេរៈ ១០០ វស្សា ស្ដេចយាងដល់ក្រុងរាជគ្រឹះ ដោយព្រះឥរិយាបថដែលគួរជ្រះថ្លា ស្ដេចយាងបិណ្ឌបាតក្នុងរាជគ្រឹះនោះ សោយបិណ្ឌបាតត្រង់ម្លប់ស្រមោលនៃភ្នំ ឈ្មោះថា បណ្ឌវៈ ត្រូវព្រះបាទមគធៈ ទ្រង់អារាធនាឲ្យគ្រប់គ្រងរាជសម្បត្តិ ក៏ទ្រង់បដិសេធ ស្ដេចដល់ឧរុវេលាប្រទេសដោយលំដាប់ ទ្រង់កើតព្រះតម្រិះ បែរមុខចំពោះសេចក្ដីព្យាយាមឡើងថា ភូមិភាគនេះគួររីករាយហ្ន៎ ទីនេះសមគួរនឹងធ្វើសេចក្ដីព្យាយាមរបស់កុលបុត្រដែលត្រូវការនឹងធ្វើសេចក្ដីព្យាយាមហ្ន៎ ដូច្នេះ ហើយទើបស្ដេចប្រថាប់នៅក្នុងទីនោះ ។

សម័យនោះ ព្រាហ្មណ៍ទៀត ៧ នាក់ បានទៅតាមកម្ម ។ ចំណែកកោណ្ឌញ្ញមាណព អ្នកពិនិត្យព្រះលក្ខណៈ ក្មេងជាងគេទាំងអស់ ជាអ្នកប្រាសចាកជម្ងឺ ។ លោកជ្រាបថា ព្រះមហាបុរសទ្រង់ព្រះផ្នួសហើយ ទើបចូលទៅរកពួកបុត្រព្រាហ្មណ៍ទាំងនោះ ពោលយ៉ាងនេះថា បានឮថា ព្រះសិទ្ធត្ថរាជកុមារ ទ្រង់ព្រះផ្នួសហើយ លោកនឹងជាព្រះពុទ្ធ ដោយមិនត្រូវសង្ស័យ បើបិតា

របស់ពួកលោកមិនមានជម្ងឺ ថ្ងៃនេះក៏គប្បីចេញបួស បើលោកទាំងឡាយប្រាថ្នា ដែរ មក ពួកយើងនឹងបួសតាមស្តេចព្រះមហាបុរសនោះ បុត្រព្រាហ្មណ៍ទាំង នោះ ក៏មិនមានឆន្ទៈតែមួយដូចគ្នាទេ ។ ៣ នាក់មិនបួស ។ ៤ នាក់ទៀត មាន កោណ្ឌញ្ញព្រាហ្មណ៍ជាប្រធាន បួសហើយ ។ បព្វជិតទាំង ៥ នេះ ត្រាច់ភិក្ខាក្នុង គាមនិគម និងរាជធានី បានទៅកាន់សម្នាក់ព្រះពោធិសត្វ ។ បព្វជិតទាំងនោះ កាលព្រះពោធិសត្វ ផ្តើមតាំងសេចក្តីព្យាយាមធំរហូតដល់អស់ ៦ ឆ្នាំ គិតថា ឥឡូវនេះ ព្រះពោធិសត្វនឹងជាព្រះពុទ្ធ ទើបទំនុកបម្រុងព្រះមហាសត្វ បានជា អ្នកទៅមកក្នុងសម្នាក់ព្រះពោធិសត្វនោះ ។ ក៏កាលណា ព្រះពោធិសត្វ សូម្បី ទ្រង់បញ្ឈប់ហើយដោយល្ងូ និងអង្ករមួយគ្រាប់ជាដើម ទ្រង់ដឹងថា នឹងមិនត្រាស់ ដឹងអរិយធម៌ដោយទុក្ករកិរិយា ទើបសោយព្រះក្រយាហារគ្រោតគ្រាត កាលនោះ បព្វជិតទាំងនោះ ក៏គេចទៅនៅព្រៃឥសិបតនមិគទាយវ័ន ។

គ្រានោះ ព្រះពោធិសត្វ សោយព្រះក្រយាហារគ្រោតគ្រាត ធ្វើព្រះឆវីវណ្ណ ព្រះមំសៈ និងព្រះលោហិតឲ្យបរិបូណ៌ហើយ ។ ក្នុងថ្ងៃវិសាខបុណ្ណមី ទ្រង់ សោយគោជនយ៉ាងល្អដែលនាងសុជាតាថ្វាយ ទ្រង់បណ្តែតថាសមាសទៅ ក៏ អណ្តែតបញ្ច្រាសក្រសែទន្លេទើបធ្លាក់ចុះ ព្រះទ័យថា យើងនឹងជាព្រះពុទ្ធក្នុង ថ្ងៃនេះ ។ ក្នុងវេលាល្ងាច ស្តេចកាលនាគរាជ អនុមោទនាដោយការអនុមោទនា

ប្រើនវយ ទ្រង់ឡើងកាន់មហាពោធិមណ្ឌស្ថាន បែរព្រះភក្ត្រទៅកាន់លោកធាតុទិសខាងកើត អង្គុយពែនភ្នែនក្នុងទីដែលមិនញាប់ញ័រ អធិដ្ឋានសេចក្ដីព្យាយាមប្រកបដោយអង្គ ៤ កាលព្រះអាទិត្យនៅមិនទាន់គោចរនុ៎ះឯង ទ្រង់កម្ចាត់មារនិងពលមារ បឋមយាមទ្រង់រឭកដល់បុព្វេនិវាសញ្ញាណ មជ្ឈិមយាមទ្រង់ជម្រះទិព្វចក្ខុញ្ញាណ ក្នុងវេលាជាប់តគ្នានៃបច្ចូសសម័យ ទ្រង់ញ៉ាំងព្រះញាណចុះក្នុងបដិច្ចសមុប្បាទ ពិចារណាបច្ចយាការទាំងអនុលោម និងបដិលោម ត្រាស់ដឹងចំពោះព្រះសព្វញ្ញុតញ្ញាណ ដែលជាអសាធារណញ្ញាណ[១] (ញាណដែលមិនមានទូទៅដល់សាវកដទៃ) ដែលព្រះពុទ្ធគ្រប់ព្រះអង្គទ្រង់ត្រាស់ដឹងហើយ ទ្រង់សម្រាំក្នុងពោធិមណ្ឌស្ថាននោះឯង ៧ ថ្ងៃ ដោយផលសមាបត្តិ ដែលមានព្រះនិព្វានជាអារម្មណ៍ ។

ដោយឧបាយនោះឯង ទ្រង់ប្រថាប់នៅក្នុងពោធិមណ្ឌស្ថាន ៧ សប្ដាហ៍ សោយបាយសត្តុដុំ ត្រង់គល់ដើមកេស ហើយស្ដេចត្រឡប់មកត្រង់គល់ដើម

---

១-ញាណមាន ៦ គឺ ឥន្ទ្រិយបរោបរិយត្តិញ្ញាណ ១ (ញាណកំណត់ដឹងដ៏ក្រៃលែង និងញាណកំណត់ឥន្ទ្រិយរបស់សត្វទាំងឡាយ) , អាសយានុសយញ្ញាណ ១ (ញាណកំណត់ដឹងអជ្ឈាស្រ័យ និងកិលេសដែលដេកត្រាំក្នុងសន្ដានរបស់) , យមកប្បាដិហារិញ្ញាណ ១ (ញាណក្នុងយមកប្បាដិហារ) , មហាករុណាសមាបត្តិញ្ញាណ ១ (ញាណក្នុងមហាករុណាសមាបត្តិ) , សព្វញ្ញុតញ្ញាណ ១ (ញាណជាព្រះសព្វញ្ញូ) , អនាវរណញ្ញាណ ១ (ញាណដែលមិនមានអ្វីរាំងបាន) ។

អជបាលនិគ្រោធទៀត ប្រថាប់អង្គុយក្នុងទីនោះ ទ្រង់ពិចារណាសេចក្តីនៃធម៌ដ៏ជ្រាលជ្រៅ កាលព្រះទ័យបង្អោនទៅក្នុងសេចក្តីជាអ្នកខ្វល់ខ្វាយតិច ដែលស្តេចមហាព្រហ្មទូលអារាធនាហើយ ទ្រង់ត្រួតមើលសត្វលោកដោយពុទ្ធចក្ខុ ទ្រង់ឃើញសត្វទាំងឡាយ ដោយសត្វមានឥន្ទ្រិយចាស់ក្លា និងមានឥន្ទ្រិយទន់ខ្ចីជាដើម ទើបប្រទានការបេ្តជ្ញាដល់ស្តេចមហាព្រហ្មដើម្បីសម្តែងធម៌ ទ្រង់ព្រះតម្រិះថា តថាគតនឹងសម្តែងធម៌ដល់អ្នកណាមុនហ្ន៎ ទ្រង់ជ្រាបថា អាឡារតាបស និងឧទ្ទកតាបសធ្វើកាលកិរិយាហើយ កាលទ្រង់ត្រិះរិះតទៅទៀត ក៏កើតព្រះតម្រិះឡើងថា ភិក្ខុបញ្ចវគ្គិយដែលទំនុកបម្រុងតថាគត តាំងសេចក្តីព្យាយាម រាប់ថា ជាអ្នកមានឧបការៈច្រើនដល់តថាគត តថាគតនឹងគប្បីសម្តែងធម៌ដល់ភិក្ខុបញ្ចវគ្គិយ៍មុន ។ ក៏ប្រការទាំងអស់នេះឯង មានត្រឹមតែបរិវិតក្កៈរបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយប៉ុណ្ណោះ ។ ក៏វៀរកោណ្ឌញ្ញៈចេញ បុគ្គលដទៃណាហ្ន៎ ឈ្មោះថា ជាអ្នកអាចត្រាស់ដឹងធម៌មុនមិនមាន ។ ពិតហើយ កោណ្ឌញ្ញព្រាហ្មណ៍នោះ បានធ្វើកម្មគឺ បុញ្ញាធិការទុក ១០០.០០០ កប្ប ដើម្បីប្រយោជន៍នេះឯង ទើបបានថ្វាយទានដ៏ប្រសើរក្នុងស្រូវ ៩ ដង ដល់សង្ឃមានព្រះពុទ្ធជាប្រធាន ។

លំដាប់នោះ ព្រះសាស្តា ទ្រង់កាន់បាត្រ និងចីវរ ស្តេចទៅកាន់ព្រៃឥសិបតមិគទាយវ័ន ដោយលំដាប់ ស្តេចទៅរកភិក្ខុបញ្ចវគ្គិយ ព្រះបញ្ចវគ្គិយ

ទាំងនោះ ឃើញព្រះតថាគតស្តេចមក មិនអាចតាំងនៅក្នុងកតិកាបស់ពួកខ្លួន (ដែលព្រមព្រៀងគ្នាទុក) មួយអង្គលាងព្រះបាទ មួយអង្គចាប់ផ្តិតស្លឹកត្នោតឈរបក់ថ្វាយ ។ កាលព្រះបញ្ចវគ្គិយទាំងនោះ សម្តែងវត្តយ៉ាងនេះហើយ អង្គុយក្នុងទីជិត ព្រះសាស្តាទ្រង់ធ្វើព្រះកោណ្ឌញ្ញត្ថេរៈ ឲ្យជាកាយសក្ខីហើយ ទ្រង់ផ្តើមធម្មចក្កប្បវត្តនសូត្រ មានបរិវដ្តៈ ៣ ដ៏កំពូល ។

មនុស្សបរិស័ទ ក៏គឺ ជនទាំង ៥ (បញ្ចវគ្គិយ) ប៉ុណ្ណោះ ព្រះសាស្តាទ្រង់ធ្វើព្រះកោណ្ឌញ្ញឲ្យតាំងនៅក្នុងសោតាបត្តិផល ព្រមទាំងមហាព្រហ្ម ១៨ កោដិ ។ គ្រានោះ ព្រះសាស្តាទ្រង់ព្រះតម្រិះថា កោណ្ឌញ្ញៈដឹងទូទៅនូវធម៌ ដែលតថាគតបាន បានមកដោយការធ្វើសេចក្តីព្យាយាមយ៉ាងធំ មុនអ្នកដទៃទាំងនោះ កាលទ្រង់ហៅព្រះថេរៈថា ភិក្ខុនេះឈ្មោះអញ្ញាកោណ្ឌញ្ញៈ ទើបត្រាស់ថា **អញ្ញាសិ វត ភោ កោណ្ឌញ្ញោ អញ្ញាសិ វត ភោ កោណ្ឌញ្ញោ** កោណ្ឌញ្ញៈ ត្រាស់ដឹងហើយហ្ន៎ កោណ្ឌញ្ញៈ ត្រាស់ដឹងហើយហ្ន៎ ដូច្នេះ ។ ពាក្យនោះឯង ទើបជាឈ្មោះរបស់លោក ។ ដោយហេតុនោះ លោកទើបពោលថា **ឥតិ ហិទំ អាយស្មតោ កោណ្ឌញ្ញស្ស អញ្ញាកោណ្ឌញ្ញោ ត្វេវ នាមំ អហោសិ** ដូចនោះ ពាក្យនេះថា អញ្ញាកោណ្ឌញ្ញៈ ទើបបានជាឈ្មោះរបស់ព្រះកោណ្ឌញ្ញៈ ដូចនោះ ព្រះថេរៈបានតាំងនៅក្នុងសោតាបត្តិផល ក្នុងថ្ងៃអាសាឡ្ហបុណ្ណមី ពាក់កណ្តាលខែ ៨ ថ្ងៃ ១

កេច ព្រះភទ្ទិយត្ថេរៈ , ថ្ងៃ ២ កេច ព្រះវប្បត្ថេរៈ , ថ្ងៃ ៣ កេច ព្រះមហានាមត្ថេរៈ , ថ្ងៃ ៤ កេច ព្រះអស្សជិត្ថេរៈ បានតាំងនៅក្នុងសោតាបត្តិផល ។ ដល់ថ្ងៃ ៥ កេច ចប់អនត្តលក្ខណសូត្រ ក៏តាំងនៅក្នុងព្រះអរហត្តគ្រប់រូប ។ សម័យនោះឯង ទើបមានព្រះអរហន្តក្នុងលោក ៦ អង្គ ។

តាំងពីនោះមក ព្រះសាស្ដាទ្រង់ឲ្យមហាជនធ្លាក់ចុះកាន់អរិយភូមិ យ៉ាងនេះ គឺ បុរស ៥៥ នាក់ មានយសកុលបុត្រជាប្រធាន ភទ្ទវគ្គិយកុមារ ចំនួន ៣០ នាក់ នៅឯព្រៃកប្បាស បុរាណជដិល ចំនួន ១.០០០ រូប ត្រង់ផ្ទាំងថ្មគយាសីសប្រទេស ទ្រង់ឲ្យរាជបរិវារ ១១ នហុត មានព្រះបាទពិម្ពិសារជាប្រមុខ ឲ្យតាំងនៅក្នុងសោតាបត្តិផល , ១ នហុត ឲ្យតាំងនៅក្នុងត្រៃសរណៈ ទ្រង់ធ្វើព្រះសាសនាប្រកបដោយផ្លែផ្កា លើផ្ទៃជម្ពូទ្វីប ទ្រង់ធ្វើទូទាំងមណ្ឌលជម្ពូទ្វីបឲ្យរុងរឿង ដោយកាសាវព័ស្ត្រ បរិបូរទៅដោយអ្នកស្វែងបុណ្យ សម័យមួយ ស្ដេចយាងដល់ព្រះជេតពនមហាវិហារ ស្ថិតនៅក្នុងទីនោះ ប្រថាប់លើព្រះពុទ្ធាសនៈដ៏ប្រសើរដែលគេរៀបចំទុកហើយ ទ្រង់សម្ដែងធម៌កណ្ដាលភិក្ខុសង្ឃ ទ្រង់សម្ដែងថា កោណ្ឌញ្ញៈបុត្រតថាគត ជាកំពូល រវាងពួកភិក្ខុដែលត្រាស់ដឹងធម៌ មុននរណា ទើបទ្រង់ស្ថាបនាលោកទុកក្នុងតំណែងឯតទគ្គៈ ។

សូម្បីព្រះថេរៈ ឃើញព្រះអគ្គសាវកទាំងពីរធ្វើសេចក្ដីគោរពឱនលំទោន

ចំពោះខ្លួន បំណងនឹងចៀសចេញអំពីសម្នាក់របស់ព្រះពុទ្ធជាម្ចាស់ ឃើញថា បុណ្ណមាណពបួសហើយនឹងជាកំពូលធម្មកថិកក្នុងព្រះសាសនា ទើបត្រឡប់ទៅស្រុកព្រាហ្មណ៍ឈ្មោះទោណវត្ថុ (ជាតិភូមិរបស់លោក) ឲ្យបុណ្ណមាណពក្មួយប្រុសបព្វជ្ជា ហើយគិតថា បុណ្ណមាណពនេះ នឹងនៅក្នុងសម្នាក់របស់ព្រះពុទ្ធ ទើបឲ្យបុណ្ណមាណពនោះនៅក្នុងសម្នាក់របស់ព្រះពុទ្ធទាំងឡាយ លោកខ្លួនឯងក៏ចូលទៅគាល់ព្រះទសពល សូមអនុញ្ញាតព្រះដ៏មានព្រះភាគថា បពិត្រ ព្រះ-ដ៏មានព្រះភាគ សេនាសនៈក្នុងទីជិតស្រុកមិនជាទីសប្បាយសម្រាប់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គមិនអាចនៅច្របូកច្របល់ នឹងទៅរស់នៅឯស្រះឆទ្ទន្ត ព្រះអង្គ ទើបក្រោកចាកអាសនៈ ថ្វាយបង្គំហើយ ទៅកាន់ស្រះឆទ្ទន្ត អាស្រ័យហ្វូងដំរីត្រកូលឆទ្ទន្ត នៅទីនោះអស់ ១២ ឆ្នាំ បរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ក្នុងទីនោះឯង ។

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២-៣

## ប្រវត្តិព្រះសារីបុត្រ និងព្រះមោគ្គល្លានត្ថេរ

*សូត្រទី ២-៣ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[១៨៦] *បទថា* ***មហាបញ្ញានំ*** *បានដល់ អ្នកប្រកបដោយបញ្ញាច្រើន បទថា* ***ឥទ្ធិមន្តានំ*** *បានដល់ អ្នកសម្បូរណ៍ដោយឫទ្ធិ ។ ពាក្យថា* ***សារីបុត្រ មោគ្គល្លាន*** *ជាឈ្មោះរបស់ព្រះថេរៈទាំងពីរនោះ ។ ក្នុងបញ្ហាកម្មរបស់ព្រះថេរៈទាំង ២ នេះ មានរឿងដែលនឹងពោលតាមលំដាប់ ដូច្នេះ ៖*

*ក្នុងទីបំផុតអសង្ខេយ្យកប្ប ក្រៃលែងដោយសែនកប្ប រាប់ពីកប្បនេះ ព្រះសារីបុត្រ កើតក្នុងត្រកូលព្រាហ្មណមហាសាល ឈ្មោះ សរទមាណព ។ ព្រះមោគ្គល្លាន កើតក្នុងត្រកូលគហបតីមហាសាល ឈ្មោះ សិរិវឌ្ឍកុដុម្ពិកៈ ។ ទាំង ២ នាក់ ជាសម្លាញ់លេងធូលីជាមួយគ្នា កាលបិតាធ្វើកាលកិរិយាទៅ សរទមាណព ក៏បានទ្រព្យជាច្រើនដែលជាសម្បត្តិរបស់ត្រកូល ថ្ងៃមួយ នៅក្នុងទីកំបាំង គិតថា យើងមិនដឹងអត្តភាពក្នុងលោកនេះ មិនដឹងអត្តភាពក្នុងលោកដទៃ ដែលឈ្មោះថា សេចក្តីស្លាប់ជារបស់ពិត សម្រាប់ពួកសត្វដែលកើតមកហើយ ។ យើងគប្បីនឹងបួសតែម្យ៉ាង ស្វែងរកមោក្ខធម៌ ។ សរទមាណពនោះទៅរកសម្លាញ់ ពោលថា សម្លាញ់សិរិវឌ្ឍន៍ យើងនឹងបួសស្វែងរកមោក្ខធម៌*

អ្នកនឹងបួសជាមួយយើងបានទេ ។ សិរិវឌ្ឍកុដុម្ពិកៈឆ្លើយថា មិនបានទេសម្លាញ់ អ្នកបួសម្នាក់ឯងចុះ ។ សរទមាណព គិតថា បុគ្គលកាលទៅបរលោក នឹងនាំសម្លាញ់ ឬញាតិមិត្តទៅជាមួយមិនបានទេ កម្មដែលខ្លួនធ្វើ ក៏ជារបស់ខ្លួនតែម្នាក់ឯង បន្ទាប់ពីនោះ ក៏បង្គាប់ឲ្យបើកឃ្លាំងរតនៈ ឲ្យមហាទានដល់មនុស្សកំព្រា អ្នកធ្វើដំណើរឆ្ងាយ ពាណិជ្ជករ និងយាចកទាំងឡាយ ហើយបួសជាឥសី ។ មានអ្នកបួសតាមសរទមាណពនោះ យ៉ាងនេះគឺ ១ នាក់ ២ នាក់ ៣ នាក់ ក្លាយជាជដិលចំនួនប្រមាណ ៧៤.០០០ រូប សរទឥសីនោះ ធ្វើអភិញ្ញា ៥ សមាបត្តិ ៨ ឲ្យកើតហើយ ក៏ទូន្មានកសិណបរិកម្មដល់ជដិលទាំងនោះ ។ ជដិលទាំងនោះ ក៏ធ្វើអភិញ្ញា ៥ សមាបត្តិ ៨ ឲ្យកើតគ្រប់រូប ។

សម័យនោះ ព្រះពុទ្ធព្រះនាមថា **អនោមទស្សី** ទ្រង់ឧប្បត្តិឡើងក្នុងលោក ។ ព្រះនគរឈ្មោះថា **ចន្ទវតី** ។ ព្រះពុទ្ធបិតាជាក្សត្រិយ៍ ព្រះនាមថា **យសវន្តៈ** ។ ព្រះពុទ្ធមាតាជាព្រះទេវី ព្រះនាមថា **យសោធរា** ។ ដើមឈើដែលត្រាស់ដឹង ឈ្មោះថា **អជ្ជុនព្រឹក្ស** ដើមអង្គ្រង ។ ព្រះអគ្គសាវកទាំង ២ ឈ្មោះថា **ព្រះនិសភត្ថេរៈ** និង **ព្រះអនោមត្ថេរៈ** ។ ព្រះពុទ្ធបដ្ឋាក ឈ្មោះ **ព្រះវរុណត្ថេរៈ** ព្រះអគ្គសាវិកាទាំង ២ ឈ្មោះ **សុន្ទរា** និង **សមុនា** ។ ទ្រង់មានព្រះជន្មាយុ ១០០.០០០ វស្សា ។ ព្រះវរកាយកម្ពស់ ៥៨ ហត្ថ ។

ស្មើព្រះវរកាយផ្សាយទៅ ១២ យោជន៍ ។ មានភិក្ខុជាបរិវារ ១០០.០០០ រូប ។ តមកថ្ងៃមួយ ព្រះអនោមទស្សីសម្ពុទ្ធ ស្តេចយាងចេញចាក ព្រះមហាករុណាសមាបត្តិ ទ្រង់ត្រួតមើលលោកវេលាជិតភ្លឺ ទ្រង់ឃើញសរទតាបស ទ្រង់ព្រះតម្រិះថា ថ្ងៃនេះ ព្រោះតថាគតទៅរកសរទតាបសជាបច្ច័យ នឹងមានធម្មទេសនាកណ្ឌធំ និងសរទតាបសនោះ នឹងប្រាថ្នាតំណែងអគ្គសាវក សិរិវឌ្ឍកុដុម្ពិកៈក៏សម្លាញ់របស់គេ នឹងប្រាថ្នាតំណែងអគ្គសាវកទី ២ ចប់ទេសនា ជដិល ៧៤.០០០ រូប បរិវាររបស់គេ នឹងសម្រេចព្រះអរហត្ត គួរដល់តថាគត នឹងទៅទីនោះ ។ ដូច្នេះ ហើយទ្រង់ប្រដាប់បាត្រ និងចីវររបស់ព្រះអង្គ មិនហៅអ្នកដទៃណា ស្តេចតែមួយអង្គឯងដូចរាជសីហ៍ កាលពួកអន្តេវាសិកសិស្សរបស់សរទតាបស ចេញទៅស្វែងរកផលាផល ទ្រង់អធិដ្ឋានថា សូមសរទតាបសចូរដឹងថា តថាគតជាព្រះពុទ្ធ កាលសរទតាបសកំពុងសម្លឹងមើលហើយទុំឯងស្តេចក៏ចុះចាកអាកាស ប្រថាប់ឈរលើផែនដី ។

សរទតាបស ឃើញព្រះពុទ្ធានុភាព និងព្រះសរីរសម្បត្តិរបស់ព្រះអង្គ ទើបពិចារណាលក្ខណមន្ត ក៏ដឹងថា ធម្មតាបុគ្គលប្រកបដោយលក្ខណៈទាំងនេះ កាលនៅគ្រប់គ្រងផ្ទះ ក៏នឹងជាស្តេចចក្រពត្តិ កាលបួស ក៏នឹងជាព្រះសព្វញ្ញុពុទ្ធ ដែលទ្រង់បើកកិលេសដូចដំបូលចេញហើយក្នុងលោក មហាបុរសនេះ នឹងជា

ព្រះពុទ្ធដោយមិនសង្ស័យ ទើបចេញទៅទទួល ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ក្រាលអាសនៈថ្វាយ ។ ព្រះដ៏មានព្រះភាគ ក៏ប្រថាប់លើអាសនៈដែលក្រាលហើយ ។ សូម្បីសរទតាបស ក៏កាន់យកអាសនៈដែលសមគួរដល់ខ្លួន អង្គុយក្នុងទីសមគួរម្ខាង ។ សម័យនោះជដិល ៧៤.០០០ រូប ក៏កាន់ផលាផល មានឱជៈដ៏ប្រណីតៗ មកដល់សំណាក់របស់អាចារ្យ សម្លឹងមើលអាសនៈ ដែលព្រះពុទ្ធ និងអាចារ្យអង្គុយ ហើយពោលថា លោកអាចារ្យ ពួកយើងត្រាច់ទៅដោយយល់ថា មិនមានអ្នកណាជាធំជាងលោក ក្នុងលោកនេះ តែបុរសម្នាក់នេះ ឃើញទើងធំជាងលោកឬ ។ សរទតាបសពោលថា បាអើយ និយាយអ្វី ពួកអ្នកប្រាថ្នាប្រៀបធៀបទឹងភ្នំសិនេរុ ដែលខ្ពស់ ៦.០០០.០០០ យោជន៍ ធ្វើឲ្យស្មើគ្រាប់ស្ពៃឬ ។ បាអើយ ពួកអ្នកកុំប្រៀបធៀបយើងជាមួយព្រះសព្វញ្ញុពុទ្ធឡើយ ។ គ្រានោះ ជដិលទាំងនោះគិតថា បើបុរសម្នាក់នេះ នឹងជាសត្វតូចទាបនោះ អាចារ្យរបស់យើងគង់មិននាំមកប្រៀបធៀប ដូច្នេះ ដែលពិត បុរសម្នាក់នេះ ពិតជាធំ គ្រប់រូប ទើបក្រាបទៀបខាងព្រះយុគលបាទ ថ្វាយបង្គំដោយសិរសា ។ លំដាប់នោះ អាចារ្យទើបពោលនឹងជដិលទាំងនោះថា បាអើយ ទេយ្យធម៌របស់យើងទាំងគួ គួរដល់ព្រះពុទ្ធមិនមានឡើយ ។ ក្នុងវេលាភិក្ខាចារ ព្រះសាស្តា ក៏ស្តេចមកហើយក្នុងទីនេះ ពួកយើងនឹងថ្វាយទេយ្យធម៌តាមកម្លាំង

ពួកអ្នក ចូរនាំផលាផលរបស់យើងដែលប្រណីតៗ មក ហើយឲ្យនាំមក លាង ដៃហើយ ក៏ដាក់ចុះក្នុងបាត្ររបស់ព្រះតថាគតដោយខ្លួនឯង ។ ពេលព្រះសាស្តា ទ្រង់ទទួលផលាផល ទេវតាទាំងឡាយក៏ដាក់ទិព្វឱជៈចុះ ។ តាបសក៏គ្រងទឹក ថ្វាយដោយខ្លួនឯង ។ លំដាប់នោះ កាលព្រះសាស្តាប្រថាប់សោយស្រេចហើយ តាបសក៏ហៅអន្តេវាសិកមកគ្រប់គ្នា អង្គុយនិយាយតែពាក្យដែលជាសារាណីយកថា (ពាក្យឲ្យរឮកដល់គ្នា) ក្នុងសំណាក់ព្រះសាស្តា ។

ព្រះសាស្តាទ្រង់បរិវិតក្កៈថា ព្រះអគ្គសាវកទាំងពីរ ចូរមកព្រមជាមួយ ភិក្ខុសង្ឃ ព្រះអគ្គសាវកទាំងនោះ ដឹងព្រះតម្រិះរបស់ព្រះសាស្តា មានព្រះខីណាស្រពសែនអង្គជាបរិវារ មកថ្វាយបង្គំព្រះសាស្តាហើយ ឈរក្នុងទីដ៏សមគួរ ម្ខាង ។

លំដាប់នោះ សរទតាបស ហៅពួកអន្តេវាសិកមកនិយាយថា បាទាំង ឡាយ អាសនៈដែលព្រះពុទ្ធប្រថាប់ក៏នៅទាប អាសនៈដែលព្រះសមណៈសែន អង្គ អង្គុយក៏មិនមាន ថ្ងៃនេះ គួរដល់អ្នកទាំងឡាយនឹងធ្វើពុទ្ធសក្ការៈឲ្យឱឡារ អ្នកទាំងឡាយចូរនាំផ្កាឈើដែលសម្បូរណ៌ដោយពណ៌ និងក្លិនពីជើងភ្នំមក ។ វេលាដែលពោល រមែងដូចជាយឺតយូរ តែវិស័យរបស់អ្នកមានឫទ្ធិជាអចិន្តេយ្យៈ ព្រោះហេតុនោះ តាបសទាំងនោះ ទើបនាំផ្កាឈើដែលសម្បូរណ៌ដោយពណ៌

និងកុិនមក ដោយកាលត្រឹមតែមួយភ្លែតប៉ុណ្ណោះ តាក់តែងអាសនៈផ្កាឈើ ប្រមាណមួយយោជន៍សម្រាប់ព្រះពុទ្ធ សម្រាប់ព្រះអគ្គសាវកទាំងឡាយ ៣ គាវុត សម្រាប់ភិក្ខុដ៏សេសផ្សេងទៀតកន្លះយោជន៍ ជាដើម សម្រាប់ភិក្ខុថ្មីក្នុងសង្ឃ ប្រមាណមួយឧសភៈ ។ កាលតាក់តែងអាសនៈរៀបរយស្រេចហើយ សរទ-តាបស ឈរផ្គងអញ្ជលីត្រង់ព្រះភ័ក្ត្រព្រះតថាគត ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមស្ដេចយាងកាន់អាសនៈផ្កាឈើនេះ ដើម្បីប្រយោជន៍ និងសេចក្ដីសុខដល់ខ្ញុំព្រះអង្គអស់កាលយូរចុះ ។ (គ្រាពោលហើយ ទើបបានពោលជាគាថាប្រព័ន្ធដូច្នេះថា)

នានាបុប្ផំ ច គន្ធញ្ច សម្បាទេត្វាន ឯកតោ
បុប្ផាសនំ បញ្ញាបេត្វា ឥទំ វចនមព្រវិ ។ល។

ខ្ញុំព្រះអង្គរួមគ្នារូបរួមផ្កាឈើផ្សេងៗ និងរបស់ក្រអូប
មកតាក់តែងអាសនៈផ្កាឈើ បានក្រាបទូលពាក្យនេះ
ថា បពិត្រព្រះអង្គអ្នកក្លាហាន អាសនៈនេះតាក់តែង
ទុកដើម្បីព្រះអង្គ សមគួរដល់ព្រះអង្គ សូមព្រះអង្គ
ចូរញុំាងចិត្តរបស់ខ្ញុំព្រះអង្គឲ្យថ្លាផូរផង់ ប្រថាប់លើ
អាសនៈផ្កាឈើចុះ ។ ព្រះពុទ្ធជាម្ចាស់បានប្រថាប់

លើអាសនៈផ្កាឈើ រហូតអស់ប្រាំពីរថ្ងៃ ប្រាំពីរយប់
ធ្វើចិត្តរបស់យើងឲ្យផូរផង់ ធ្វើលោកព្រមទាំងទេវតា
ឲ្យរីករាយ ។

កាលព្រះសាស្តាប្រថាប់យ៉ាងនេះហើយ ព្រះអគ្គសាវកទាំងពីរ និងពួកភិក្ខុដ៏សេស ក៏គង់លើអាសនៈដែលដល់ហើយរៀងៗ ខ្លួន សរទតាបស កាន់ឆត្រផ្កាឈើធំឈរការពារលើព្រះសិរសាព្រះតថាគត ។ ព្រះសាស្តាទ្រង់ចូលនិរោធសមាបត្តិ ដោយព្រះតម្រិះថា សក្ការៈនេះ ចូរមានផលច្រើនដល់ជដិលទាំងឡាយ ។ ព្រះអគ្គសាវកទាំងពីរក្តី ភិក្ខុដ៏សេសក្តី ដឹងថា ព្រះសាស្តាទ្រង់ចូលសមាបត្តិ ក៏នាំគ្នាចូលសមាបត្តិ ។ កាលព្រះតថាគតប្រថាប់ចូលនិរោធសមាបត្តិអស់ ៧ ថ្ងៃ ពួកអន្តេវាសិក កាលដល់វេលាភិក្ខាចារ ក៏បរិភោគមើមផលាហាររបស់ព្រៃ ក្នុងវេលាដ៏សេស ក៏ឈរផ្គងអញ្ជលីចំពោះព្រះពុទ្ធ ។ ចំណែកសរទតាបស សូម្បីភិក្ខាចារក៏មិនទៅ តាំងនៅដោយបីតិ និងសុខទាំង ៧ ថ្ងៃ ដោយទំនងដែលកាន់ឆត្រផ្កាឈើហើយនុ៎ះឯង ។

ព្រះសាស្តាទ្រង់ចេញចាកនិរោធសមាបត្តិហើយ ត្រាស់ហៅព្រះនិសភត្ថេរៈអគ្គសាវកដែលអង្គុយនៅក្នុងខាងស្តាំថា និសភៈ អ្នកចូរធ្វើបុប្ផាសនានុមោទនា ដល់តាបសទាំងឡាយដែលធ្វើសក្ការៈ ។ ព្រះថេរៈសប្បាយចិត្ត ដូច

ទាហានធំបានលាភច្រើនពីសំណាក់របស់ស្តេចចក្រពត្តិ តាំងនៅក្នុងសាវកបារមី-ញាណ ផ្តើមអនុមោទនាជាប់ទាក់ទងនឹងការថ្វាយអាសនៈផ្កាឈើ ។ ក្នុងវេលាចប់ទេសនារបស់ព្រះអគ្គសាវកនោះ ទើបត្រាស់ហៅទុតិយសាវកថា ភិក្ខុ សូម្បីអ្នកក៏ចូរសម្តែងធម៌ ។ ចំណែកព្រះអនោមត្ថេរៈ ពិចារណាព្រះត្រៃបិដក ពុទ្ធ-វចនៈមកពោលធម្មកថា ។ ដោយទេសនារបស់ព្រះអគ្គសាវកទាំងពីរ សូម្បីជដិលត្រឹមតែមួយរូបក៏មិនបានត្រាស់ដឹង ។ លំដាប់នោះ ព្រះសាស្តាទ្រង់តាំងនៅក្នុងពុទ្ធវិស័យដែលរកប្រមាណមិនបាន ទ្រង់ផ្តើមព្រះធម្មទេសនា ។ ក្នុងវេលាចប់ទេសនា វៀរសរទតាបស ជដិលសូម្បីទាំងអស់ចំនួន ៧៤.០០០ រូបសម្រេចព្រះអរហត្ត ។ ព្រះសាស្តាទ្រង់លាព្រះហស្តត្រាស់ថា ចូរជាភិក្ខុចុះ ។ ក្នុងខណៈនោះឯង សក់ និងពុកមាត់របស់ជដិលទាំងនោះក៏បាត់ទៅ បរិក្ខារ ៨ ក៏បានរួមចូលក្នុងកាយភ្លាម ។

សួរថា ព្រោះហេតុអ្វី សរទតាបស ទើបមិនសម្រេចព្រះអរហត្ត ។ ឆ្លើយថា ព្រោះមានចិត្តរវើរវាយ ។ បានឮថា ។ ផ្តើមតាំងពីស្តាប់ទេសនារបស់ព្រះអគ្គសាវកដែលគង់លើអាសនៈទីពីរនៃព្រះពុទ្ធ អ្នកតាំងនៅក្នុងសាវក-បារមីញាណសម្តែងធម៌ហើយ សរទតាបសនោះកើតសេចក្តីគិតឡើងថា ឱហ្ន៎ សូម្បីយើងក៏គួរបាននាទីដែលព្រះសាវកនេះបាន ក្នុងសាសនារបស់ព្រះពុទ្ធជា

ម្ចាស់នឹងស្តេចឧប្បត្តិឡើងក្នុងអនាគត ។ សរទតាបសនោះ មិនអាចធ្វើឲ្យច្បាស់មគ្គផល ក៏ព្រោះបរិវិតក្កៈនោះ ទើបថ្វាយបង្គំព្រះតថាគត ហើយឈរចំពោះព្រះភ័ក្ត្រ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុដែលគង់លើអាសនៈជាប់នឹងព្រះអង្គ ឈ្មោះអ្វី ក្នុងសាសនារបស់ព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ភិក្ខុនេះ ដែលប្រកាសតាមព្រះធម្មចក្កដែលតថាគតប្រកាសហើយ ដល់ទីបំផុតនៃសាវកបារមីញាណ ត្រាស់ដឹងសោឡសបញ្ហា ឈ្មោះថា និសភត្ថេរៈ អគ្គសាវកក្នុងសាសនារបស់តថាគត ។ សរទតាបស (បានស្តាប់ហើយ) ទើបបានធ្វើសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបាំងឆត្រផ្កាឈើរហូតអស់ ៧ ថ្ងៃ ធ្វើសក្ការៈនេះណា ដោយផលនៃសក្ការៈនេះ ខ្ញុំព្រះអង្គមិនបានប្រាថ្នាជាស្តេចសក្កៈ ឬជាព្រហ្មសកណាមួយ តែក្នុងអនាគត សូមឲ្យខ្ញុំព្រះអង្គបានជាព្រះអគ្គសាវករបស់ព្រះពុទ្ធមួយព្រះអង្គ ដូចព្រះនិសភត្ថេរៈនេះ ។

ព្រះសាស្តាទ្រង់បញ្ជូនអនាគតង្សញ្ញាណទៅ ពិចារណាមើលថា សេចក្តីប្រាថ្នារបស់តាបសនេះ នឹងសម្រេចឬទេហ្ន៎ ក៏ទ្រង់បានឃើញថា កន្លងទៅមួយអសង្ខេយ្យក្រៃលែងដោយសែនកប្បនឹងសម្រេច ក៏ឯគ្រាទ្រង់ឃើញហើយ ទើបត្រាស់ចំពោះសរទតាបសថា សេចក្តីប្រាថ្នាយ៉ាងនេះរបស់អ្នក នឹងមិនជារបស់ទទេ ក្នុងអនាគតកន្លងទៅមួយអសង្ខេយ្យក្រៃលែងដោយសែនកប្ប ព្រះពុទ្ធទ្រង់

ព្រះនាមថា **គោតម** នឹងឧប្បត្តិឡើងក្នុងលោក មានព្រះពុទ្ធមាតានាមថា **មហាមាយាទេវី** ព្រះពុទ្ធបិតានាមថា **សុទ្ធោទនមហារាជ** មានព្រះឱរសនាមថា **រាហុល** មានព្រះឧបដ្ឋាកនាមថា **អានន្ទ** មានព្រះទុតិយសាវកនាមថា **មោគ្គល្លាន** ចំណែកអ្នកនឹងជាព្រះអគ្គសាវករបស់ព្រះគោតមនោះ នាមថា **ព្រះធម្មសេនាបតីសារីបុត្រ** លុះទ្រង់ព្យាករណ៍តាបសនោះ យ៉ាងនេះហើយ ត្រាស់ធម្មកថា មានភិក្ខុសង្ឃជាបរិវារ ស្តេចហោះទៅផ្លូវអាកាស ។

ចំណែកសរទតាបស ទៅកាន់សំណាក់របស់ព្រះថេរៈដែលធ្លាប់ជាអន្តេវាសិក ហើយឲ្យបញ្ជូនដំណឹងដល់សិរិវឌ្ឍកុដុម្ពិកៈជាសម្លាញ់ថា លោកម្ចាស់ដ៏ចម្រើន លោកចូរប្រាប់សម្លាញ់របស់ខ្ញុំថា សរទតាបសដែលសម្លាញ់របស់លោក ប្រាថ្នាតំណែងអគ្គសាវកក្នុងសាសនារបស់ព្រះគោតមសម្ពុទ្ធ ដែលស្តេចនឹងឧប្បត្តិក្នុងអនាគត ក្នុងទីជិតបាទមូលរបស់ព្រះអនោមទស្សីសម្ពុទ្ធ ចំណែកលោកចូរប្រាថ្នាតំណែងទុតិយសាវកចុះ លុះពោលយ៉ាងនេះហើយ ក៏ទៅត្រឹមតែមួយភ្លែតមុនព្រះថេរៈទាំងឡាយ បានឈរត្រង់ទ្វារនិវេសន៍របស់សិរិវឌ្ឍកុដុម្ពិកៈ ។

សិរិវឌ្ឍកុដុម្ពិកៈប្រាស្រ័យថា យូរមកហើយ លោកម្ចាស់ទើបបានមក ហើយឲ្យអង្គុយលើអាសនៈ ចំណែកខ្លួនអង្គុយលើអាសនៈដែលទាបជាង សួរថា

ក៏អន្តេវាសិកបរិស័ទរបស់លោកមិនប្រាកដឬ លោកម្ចាស់ សរទតាបសពោល ថា ចម្រើនពរ សម្លាញ់ ព្រះអនោមទស្សីសម្ពុទ្ធស្តេចមកក្នុងអាស្រមរបស់ពួក អាត្មាភាពៗ បានធ្វើសក្ការៈចំពោះព្រះអង្គ តាមកំពុងរៀងៗ ខ្លួន ព្រះសាស្តា ទ្រង់សម្តែងធម៌ដល់តាបសទាំងអស់ ក្នុងវេលាចប់ព្រះទេសនា តាបសដ៏សេស សម្រេចព្រះអរហត្ត វៀរតែអាត្មាភាព ។ សិរីវឌ្ឍកុដុម្ពិកៈសួរថា ព្រោះហេតុអ្វី លោកទើបមិនបួស ។ សរទតាបសពោលថា អាត្មាភាពឃើញព្រះនិសភត្ថេរៈ អគ្គសាវករបស់ព្រះសាស្តាហើយ ទើបបានប្រាថ្នាតំណែងអគ្គសាវកក្នុងសាសនា របស់ព្រះពុទ្ធទ្រង់ព្រះនាមថា **គោតម** ដែលស្តេចនឹងឧប្បត្តិក្នុងអនាគត ។ សូម្បីលោក ក៏ចូរប្រាថ្នាតំណែងទុតិយសាវក ក្នុងសាសនារបស់ព្រះគោតម-សម្ពុទ្ធព្រះអង្គនោះចុះ ។ សិរីវឌ្ឍកុដុម្ពិកៈពោលថា លោកម្ចាស់ ខ្ញុំមិនមាន សេចក្តីស្និទ្ធស្នាលជាមួយព្រះពុទ្ធ ។ សរទតាបសពោលថា ការក្រាបទូលនឹង ព្រះពុទ្ធ ចូរជាភារៈរបស់អាត្មាភាព លោកចូរត្រៀមអធិការ (សក្ការៈដ៏ក្រៃ-លែង) ទុកចុះ ។ សិរីវឌ្ឍកុដុម្ពិកៈ ស្តាប់ពាក្យរបស់សរទតាបសហើយ ទើប ឲ្យចាត់ចែងស្ថានទីប្រមាណ ៨ ករីស ដោយរង្វាស់ហ្លួង ឲ្យមានផ្ទៃដីស្មើគ្នា ក្នុងស្ថានទីក្នុងនិវេសន៍របស់ខ្លួន ហើយឲ្យរោយខ្សាច់ រោយផ្កាឈើ មានលាជ ជាទី ៥ ឲ្យសាងមណ្ឌបប្រក់ដោយផ្កាឧប្បល តាក់តែងពុទ្ធាសនៈ ចាត់អាសនៈ

សម្រាប់ព្រះភិក្ខុសូម្បីដ៏សេស ត្រៀមគ្រឿងសក្ការៈបូជាធំ ហើយឲ្យសញ្ញាដល់សរទតាបសដើម្បីទូលនិមន្តព្រះពុទ្ធ ។ តាបសបានស្តាប់ពាក្យរបស់សិរីវឌ្ឍកុដុម្ពិកៈនោះហើយ ទើបនាំភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ទៅកាន់និវេសន៍របស់សិរីវឌ្ឍកុដុម្ពិកៈនោះ ។ សិរីវឌ្ឍកុដុម្ពិកៈធ្វើការទទួលស្តេច ទទួលបាត្រពីព្រះហស្តរបស់ព្រះតថាគត យាងឲ្យស្តេចចូលទៅកាន់មណ្ឌប ថ្វាយទក្ខិណោទកចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ប្រថាប់គង់លើអាសនៈដែលតាក់តែងទុកហើយ លៀងដោយភោជនដ៏ប្រណីត ក្នុងវេលាស្រេចភត្តកិច្ច អារាធនាភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន គ្រងសំពត់ដែលសមគួរមានតម្លៃច្រើន ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីផ្តើមនេះ ដើម្បីត្រូវការឋានៈដែលមានប្រមាណបន្តិចបន្តួចក៏មិនមែន សូមព្រះអង្គទ្រង់ធ្វើសេចក្តីអនុគ្រោះរហូតអស់ ៧ ថ្ងៃ ដោយទំនងនេះឯង ។ ព្រះសាស្តាទ្រង់ទទួលនិមន្តហើយ ។ សិរីវឌ្ឍកុដុម្ពិកៈនោះ ញុំាងមហាទានឲ្យប្រព្រឹត្តទៅមិនដាច់រហូតអស់ ៧ ថ្ងៃ ដោយទំនងនោះឯង ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគ ឈរផ្គងអញ្ជលី ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សរទតាបសសម្លាញ់របស់ខ្ញុំព្រះអង្គប្រាថ្នាថា សូមឲ្យជាអគ្គសាវករបស់ព្រះសាស្តាអង្គណា ខ្ញុំព្រះអង្គសូមជាទុតិយសាវកនៃព្រះសាស្តាអង្គនោះដូចគ្នា ។ ព្រះសាស្តាទ្រង់ត្រួតមើលអនាគត ទ្រង់ឃើញថា

សេចក្តីប្រាថ្នារបស់គេសម្រេច ទើបទ្រង់ព្យាករណ៍ថា កន្លងទៅមួយអសង្ខេយ្យ ក្រៃលែងដោយសែនកប្បពីកប្បនេះទៅ អ្នកនឹងជាទុតិយសាវកនៃព្រះគោតម សម្ពុទ្ធ សិរិវឌ្ឍកុដុម្ពិកៈ បានស្តាប់ពាក្យព្យាករណ៍របស់ព្រះពុទ្ធហើយ ជាអ្នក ត្រេកអររីករាយហើយ ។ ចំណែកព្រះសាស្តា ទ្រង់ធ្វើភត្តានុមោទនាហើយ ព្រមទាំងបរិវារស្តេចត្រឡប់ទៅកាន់ព្រះវិហារ ។ ចាប់តាំងពីនោះមក សិរិ-វឌ្ឍកុដុម្ពិកៈ ធ្វើកម្មល្អរហូតអស់មួយជីវិត ហើយកើតក្នុងទេវលោកជាន់កាមា-វចរ ក្នុងភពទី២ ។ សរទតាបសចម្រើនព្រហ្មវិហារ ៤ បានកើតក្នុង ព្រហ្មលោក ។ ចាប់អំពីនោះមក លោកមិននិយាយដល់កម្មក្នុងរវាងសូម្បី របស់លោកទាំងពីរនេះ ។

ក៏មុនពីការកើតឡើងនៃព្រះពុទ្ធរបស់យើងទាំងឡាយនុ៎ះឯង សរទតាបស បដិសន្ធិក្នុងគភ៌របស់សារីព្រាហ្មណី ក្នុងស្រុកឧបតិស្សគ្រាម មិនឆ្ងាយពីក្រុង រាជគ្រឹះ ។ ក៏ក្នុងថ្ងៃនោះឯង សូម្បីសម្លាញ់របស់សរទតាបសនោះ ក៏បដិ-សន្ធិក្នុងគភ៌របស់មោគ្គល្លីព្រាហ្មណី ក្នុងស្រុកកោលិតគ្រាម ដែលមិនឆ្ងាយពី ក្រុងរាជគ្រឹះដូចគ្នា ។ បានឮថា ត្រកូលទាំងពីរនោះ បានជាសម្លាញ់ស្និទ្ធស្នាល គ្នាមក ៧ ជួរត្រកូល ។ ញាតិទាំងឡាយបានឲ្យការរក្សាគភ៌ដល់អ្នកទាំងពីរ នោះ ក្នុងថ្ងៃតែមួយ បាននាំមេដោះ ៦៦ នាក់ ចូលទៅឲ្យដល់អ្នកទាំងពីរនោះ

សូម្បីដែលកើតហើយ បាន ១០ ខែ ។ ក្នុងថ្ងៃតាំងឈ្មោះ ញាតិទាំងឡាយបាន តាំងឈ្មោះបុត្ររបស់សារីព្រាហ្មណីថា ឧបតិស្សៈ ព្រោះជាបុត្ររបស់ប្រធាន ក្នុងស្រុកឧបតិស្សគាម តាំងឈ្មោះបុត្រក្រៅនេះថា កោលិតៈ ព្រោះជាបុត្រ របស់ប្រធានក្នុងស្រុកកោលិតគាម ។ អ្នកទាំងពីរនោះ ចម្រើនវ័យឡើង ក៏ សម្រេចសិល្បសាស្ត្រគ្រប់យ៉ាង ។

ក្នុងវេលាទៅកាន់ទន្លេ ឬឧទ្យានដើម្បីនឹងលេង ឧបតិស្សមាណព មាន គ្រែស្នែងមាស ៥០០ ជាគ្រឿងហែហមអមដំណើរ , កោលិតមាណព មានរថ ទឹមសេះអាជានេយ្យ ៥០០ ជាគ្រឿងហែហមអមដំណើរ ។ ជនទាំងពីរ មាន មាណពម្នាក់ៗ ៥០០ ជាបរិវារ ។ ក៏ក្នុងក្រុងរាជគ្រឹះ មានមហោស្រពលើ កំពូលភ្នំជាប្រចាំឆ្នាំ ។ ជនទាំងឡាយចងគ្រែទុកក្នុងទីជាមួយគ្នា សម្រាប់មាណព ទាំងពីរនោះ សូម្បីមាណពទាំងពីរ ក៏អង្គុយរួមគ្នាមើលមហោស្រព រីករាយ ក្នុងឋានៈដែលគួររីករាយ សង្វេគក្នុងឋានៈដែលគួរសង្វេគ ឲ្យរង្វាន់ក្នុងឋានៈ ដែលគួរឲ្យរង្វាន់ ។ ថ្ងៃមួយ កាលជនទាំងពីរនោះ មើលមហោស្រពដោយ ទំនងនេះឯង មិនបានមានសេចក្ដីរីករាយក្នុងឋានៈដែលគួររីករាយ សង្វេគក្នុង ឋានៈដែលគួរសង្វេគ ឬឲ្យរង្វាន់ក្នុងឋានៈដែលគួរឲ្យរង្វាន់ ព្រោះញាណចាស់ ក្លាហើយ ។ ក៏ជនទាំងពីរគិតយ៉ាងនេះថា មានអ្វីដែលយើងនឹងគួរមើល ក្នុង

មហោស្រពនេះ អ្នកទាំងនេះសូម្បីទាំងអស់ មិនទាន់ដល់ ១០០ ឆ្នាំ ក៏នឹងវិនាសស្លាប់អំពីគ្នាទៅ ក៏យើងទាំងឡាយគួរស្វែងរកមោក្ខធម៌តែម្យ៉ាង ដូច្នេះ ហើយអង្គុយទឹកយកជាអារម្មណ៍ លំដាប់នោះ កោលិតៈពោលនឹងឧបតិស្សៈថា សម្លាញ់ឧបតិស្សៈ លោកមិនសប្បាយរីករាយដូចថ្ងៃមុនៗ ចិត្តអណ្តែតអណ្តូង លោកគិតអ្វីឬ? ឧបតិស្សៈពោលថា សម្លាញ់កោលិតៈ យើងអង្គុយគិតដល់រឿងនេះថា ក្នុងការមើលរបស់អ្នកទាំងនេះ មិនមានខ្លឹមសារឡើយ ការមើលនេះមិនមានប្រយោជន៍ គួរស្វែងរកធម៌ជាគ្រឿងរួចផុតសម្រាប់ខ្លួន ឯលោកព្រោះហេតុអ្វី ទើបចិត្តអណ្តែតអណ្តូង សូម្បីកោលិតៈនោះ ក៏ពោលយ៉ាងនោះដូចគ្នា ។ លុះឧបតិស្សៈដឹងថា កោលិតៈនោះមានអធ្យាស្រ័យតែម្យ៉ាងនឹងខ្លួន ទើបពោលយ៉ាងនេះថា វត្ថុដែលយើងទាំងពីរនាក់គិត ជាការគិតដែលល្អ កាលនឹងស្វែងរកមោក្ខធម៌ គួរនឹងបានការបួសតែម្យ៉ាង ដូច្នោះ ពួកយើងនឹងបួសក្នុងសំណាក់អ្នកណា ។

ក៏សម័យនោះ សញ្ជ័យបរិព្វាជកអាស្រ័យនៅក្នុងក្រុងរាជគ្រឹះ ព្រមនឹងបរិព្វាជកបរិស័ទពួកធំ មាណពទាំងពីរនោះព្រមព្រៀងថា នឹងបួសក្នុងសំណាក់របស់សញ្ជ័យបរិព្វាជកនោះ ទើបបួសក្នុងសំណាក់របស់សញ្ជ័យបរិព្វាជកព្រមនឹងមាណព ៥០០ នាក់ ។ ផ្តើមតាំងពីកាលដែលមាណពទាំងពីរនោះបួសហើយ

សញ្ជ័យបរិព្វាជកបានលាភបានយសដ៏ច្រើន ។ មាណពទាំងពីរនោះ រៀនចប់លទ្ធិរបស់សញ្ជ័យបរិព្វាជកទាំងអស់ ត្រឹមតែ ២-៣ ថ្ងៃប៉ុណ្ណោះ ហើយសួរថា លោកអាចារ្យ លទ្ធិដែលជាសេចក្ដីដឹងរបស់លោកមានប៉ុណ្ណោះ ឬមានក្រៃលែងជាងនេះទៀត ។ សញ្ជ័យបរិព្វាជកពោលថា មានប៉ុណ្ណោះឯង ពួកលោកដឹងអស់ហើយ ។ មាណពទាំងនោះស្ដាប់ពាក្យរបស់សញ្ជ័យបរិព្វាជកនោះហើយគិតគ្នាថា បើដូច្នេះ ការនៅប្រព្រឹត្តព្រហ្មចរិយៈក្នុងសំណាក់របស់សញ្ជ័យបរិព្វាជកនេះ ក៏មិនមានប្រយោជន៍ ពួកយើងចេញបួស ក៏ដើម្បីស្វែងរកមោក្ខធម៌ ពួកយើងមិនអាចឲ្យកើតឡើងក្នុងសំណាក់របស់សញ្ជ័យបរិព្វាជកនេះ ក៏ជម្ពូទ្វីបដ៏ធំ ពួកយើងត្រាច់ទៅកាន់គាម និគម និងរាជធានី នឹងបានអាចារ្យត្រឹមតែម្នាក់ស្វែងរកមោក្ខធម៌បានដោយពិត ចាប់តាំងពីនោះ មាណពទាំងពីរនោះបានស្ដាប់ថា សមណព្រាហ្មណ៍ដែលជាបណ្ឌិតមាននៅក្នុងទីណាៗ ក៏ទៅក្នុងទីនោះៗធ្វើការសន្ទនាបញ្ហា ។ បញ្ហាដែលមាណពទាំងនោះសួរហើយ អ្នកដទៃៗ មិនអាចនឹងដោះស្រាយបាន ។ តែមាណពទាំងពីរនោះ ដោះស្រាយបញ្ហារបស់អ្នកទាំងនោះបាន ។ មាណពទាំងពីរនោះ ត្រាច់ទៅទូទាំងជម្ពូទ្វីប ដោយអាការយ៉ាងនេះ ហើយត្រឡប់មកកាន់ទីនៅពីដើមរបស់ខ្លួន បានធ្វើកតិកាគ្នាថា សម្លាញ់កោលិតៈ អ្នកណាសម្រេចអមតៈមុន អ្នកនោះចូរប្រាប់ដល់គ្នា ។

ក៏សម័យនោះ ព្រះសាស្តារបស់យើងទាំងឡាយសម្រេចព្រះបរមាភិ-សម្ពោធិញ្ញាណ ហើយប្រកាសព្រះធម្មចក្កដ៏បវរ ស្តេចដល់ក្រុងរាជគ្រឹះដោយលំដាប់ ៗ គ្រានោះ ព្រះអស្សជិត្ថេរៈ ក្នុងចំនួនភិក្ខុបញ្ចវគ្គិយ ក្នុងវារៈភិក្ខុទាំងឡាយដែលទ្រង់បញ្ជូនទៅប្រកាសគុណរបស់ព្រះរតនត្រ័យថា ភិក្ខុទាំងឡាយអ្នកទាំងឡាយចូរត្រាច់ទៅដើម្បីប្រយោជន៍ជួយសង្គ្រោះដល់ជនជាច្រើន ដូច្នេះក្នុងសម័យដែលពោលថា ព្រះអរហន្ត ៦១ អង្គ ឧប្បត្តិឡើងហើយក្នុងលោក ដូច្នេះ លោកវិលត្រឡប់មកកាន់ក្រុងរាជគ្រឹះក្នុងថ្ងៃស្អែក កាន់បាត្រ និងចីវរទៅបិណ្ឌបាត ចូលទៅក្រុងរាជគ្រឹះពីព្រឹកព្រលឹម ៗ សម័យនោះ ឧបតិស្សបរិព្វាជកធ្វើភត្តកិច្ចពីព្រលឹមស្រាងៗ ហើយដើរទៅកាន់អារាមបរិព្វាជក បានឃើញព្រះថេរៈ ទើបគិតថា ឈ្មោះថា បព្វជិតបែបនេះ យើងមិនធ្លាប់ឃើញឡើយ ភិក្ខុនេះគង់នឹងជាភិក្ខុរូបណាមួយក្នុងបណ្តាភិក្ខុដែលជាអរហន្ត ឬជាអ្នកសម្រេចអរហត្តមគ្គក្នុងលោក ដូច្នេះ យើងគួរចូលទៅរកភិក្ខុនេះ ហើយសួរបញ្ហាថា លោកដ៏មានអាយុ លោកបួសឧទ្ទិសចំពោះនរណា ឬនរណាជាសាស្តារបស់លោក ឬថា លោកពេញចិត្តក្នុងធម៌របស់នរណា ៗ លំដាប់នោះ គេមានការគិតថា មិនមែនកាលដែលនឹងសួរបញ្ហាចំពោះភិក្ខុនេះ ភិក្ខុនេះចូលទៅកាន់លំវែ្ងកស្រុកត្រាច់បិណ្ឌបាតហើយ យើងគប្បីជាប់តាមភិក្ខុនេះអំពីខាងក្រោយ

ព្រោះការជាប់តាមភិក្ខុនេះទៅ នុ៎ះជាផ្លូវដែលអ្នកត្រូវការចង់ដឹង ។ ឧបតិស្សបរិព្វាជក ឃើញព្រះថេរៈបានបិណ្ឌបាតហើយ ទៅកាន់ឱកាសមួយកន្លែង និងដឹងថា ព្រះថេរៈនោះត្រូវការនឹងអង្គុយ ទើបបានក្រាលតាំងបរិព្វាជករបស់ខ្លួនថ្វាយ សូមឱ្យក្នុងវេលាស្រេចភត្តកិច្ច ក៏បានថ្វាយទឹកក្នុងគណ្ឌិទឹករបស់ខ្លួនដល់ព្រះថេរៈនោះ ធ្វើអាចរិយវត្តយ៉ាងនេះហើយ ធ្វើបដិសណ្ឋារផ្អែមល្ហែមជាមួយព្រះថេរៈដែលធ្វើភត្តកិច្ចស្រេចហើយ សួរថា លោកដ៏មានអាយុ ឥន្ទ្រិយទាំងឡាយរបស់លោកថ្លាផូរផង់ណាស់ ឯឆវីវណ្ណក៏បរិសុទ្ធផូរផង់ លោកដ៏មានអាយុ លោកបួសឧទ្ទិសចំពោះនរណា ឬនរណាជាសាស្ដារបស់លោក ឬថាលោកពេញចិត្តក្នុងធម៌របស់នរណា ។ ព្រះថេរៈពោលថា អ្នកមានអាយុ ព្រះមហាសមណៈសក្យបុត្រ ចេញបួសពីសក្យត្រកូលហើយ យើងបួសឧទ្ទិសចំពោះព្រះដ៏មានព្រះភាគព្រះអង្គនោះ និងព្រះដ៏មានព្រះភាគព្រះអង្គនោះ ជាសាស្ដារបស់យើង យើងពេញចិត្តក្នុងធម៌របស់ព្រះដ៏មានព្រះភាគព្រះអង្គនោះ ។ លំដាប់នោះ ឧបតិស្សបរិព្វាជកទើបសួរព្រះថេរៈនោះថា ក៏ព្រះសាស្ដារបស់លោកដ៏មានអាយុ មានវាទៈដូចម្ដេច ពោលដូចម្ដេច ។ ព្រះថេរៈគិតថា ធម្មតាបរិព្វាជកទាំងឡាយនេះ ជាបដិបក្ខចំពោះព្រះសាសនា យើងនឹងសម្ដែងសេចក្ដីជ្រាលជ្រៅក្នុងព្រះសាសនាដល់បរិព្វាជកនេះ កាលនឹងបន្ទាបខ្លួនថា យើងជាអ្នក

បួសថ្មី ទើបពោលថា អ្នកមានអាយុ យើងជាអ្នកថ្មីបួសមិនទាន់បានយូរ ទើបតែមកកាន់ព្រះវិន័យនេះ យើងមិនអាចសម្តែងធម៌ដោយពិស្តារបានទេ ។ បរិ-ព្វាជកគិតថា យើងឈ្មោះថា ឧបតិស្សៈ លោកពោលតិច ឬច្រើនតាមដែលអាច ការត្រាស់ដឹងធម៌នោះ ដោយរយន័យពាន់ន័យ ជាភារៈរបស់យើង ទើបពោលថា ៖

អប្បំ វា ពហុំ វា ភាសស្សុ អត្ថំយេវ មេ ព្រូហិ
អត្ថេនេវ មេ អត្ថោ កឹ កាហសិ ព្យញ្ជនំ ពហុំ
លោកចូរពោលចុះ តិចក៏ដោយច្រើនក៏ដោយ ចូរពោល
ចំពោះតែខ្លឹមសារដល់ខ្ញុំ ខ្ញុំត្រូវការខ្លឹមសារប៉ុណ្ណោះ ។
លោកនឹងធ្វើព្យញ្ជនៈឲ្យច្រើនទៅធ្វើអ្វី ។

កាលពោលយ៉ាងនេះហើយ ព្រះថេរៈទើបពោលគាថាថា យេ ធម្មា ហេតុប្បភវា (ធម៌ពួកណាមានហេតុជាដែនកើត) ដូច្នេះជាដើម ។ បរិព្វាជកស្តាប់ ២ បទ ដំបូងប៉ុណ្ណោះ ក៏តាំងនៅក្នុងសោតាបត្តិមគ្គ ដែលសម្បូរណ៍ដោយន័យមួយពាន់ ។ ធ្វើ ២ បទ ក្រោយឲ្យចប់ស្រេចក្នុងវេលាជាព្រះសោតាបន្នហើយ ។ បរិព្វាជកនោះ បានជាព្រះសោតាបន្នហើយ កាលគុណវិសេសជាន់ខ្ពស់មិនទាន់កើត ទើបកំណត់ថា ហេតុក្នុងពាក្យទូន្មាននេះនឹងមាន ទើបពោលនឹងព្រះថេរៈ

ថា លោកដ៏ចម្រើន លោកកុំអធិប្បាយធម្មទេសនាឲ្យខ្ពស់ឡើងទៅ ពាក្យមាន ប្រមាណប៉ុណ្ណោះល្មមហើយ ព្រះសាស្តារបស់យើងទាំងឡាយ ប្រថាប់នៅទីណា ។ ព្រះថេរៈប្រាប់ថា ប្រថាប់នៅក្នុងព្រះវេឡុវ័ន ។ បរិព្វាជកពោលថា លោកម្ចាស់ សូមលោកចូរទៅមុនចុះ ខ្ញុំនៅមានសម្លាញ់ម្នាក់ និងបានធ្វើកតិកាគ្នាទុកថា អ្នកណាសម្រេចអមតៈមុន អ្នកនោះចូរប្រាប់ដល់គ្នា ខ្ញុំនឹងដោះបេ្ដជ្ញាប្រការនោះ ហើយនាំសម្លាញ់ទៅកាន់សំណាក់របស់ព្រះសាស្តា តាមផ្លូវដែលលោកទៅនុ៎ះ ឯង ហើយក្រាបចុះទៀបជើងព្រះថេរៈ ដោយបញ្ចង្គប្រតិស្ឋាន ធ្វើប្រទក្សិណ ៣ ដង ហើយបញ្ជូនព្រះថេរៈទៅ ចំណែកខ្លួន ក៏ដើរតម្រង់ទៅកាន់អារាមរបស់ បរិព្វាជក កោលិតបរិព្វាជក ឃើញឧបតិស្សបរិព្វាជកដើរមកពីចម្ងាយ គិតថា ថ្ងៃនេះ សម្លាញ់យើងមានសម្បុរមុខមិនដូចថ្ងៃមុនៗ គេនឹងបានសម្រេចអមតៈ ដោយពិត ទើបសួរដល់ការសម្រេចអមតៈ ។ សូម្បីឧបតិស្សបរិព្វាជកនោះ ក៏បានបេ្ដជ្ញាដល់កោលិតបរិព្វាជកនោះថា អ្នកមានអាយុ យើងសម្រេចអមតៈ ហើយ ទើបបានពោលគាថានោះឯង ។ ក្នុងវេលាចប់គាថា កោលិតៈតាំងនៅ ក្នុងសោតាបត្តិផល ហើយពោលថា សម្លាញ់ បានឮថា ព្រះសាស្តាប្រថាប់នៅ ទីណា ។ ឧបតិស្សៈពោលថា សម្លាញ់ ន័យថា ព្រះសាស្តាប្រថាប់នៅក្នុង ព្រះវេឡុវ័ន ។ ព្រះអស្សជិត្ថេរៈ អាចារ្យរបស់ពួកយើងប្រាប់យ៉ាងនេះ ដោយ

ប្រការដូច្នេះ ។ កោលិតៈពោលថា សម្លាញ់ បើយ៉ាងនោះ មក ពួកយើងនឹងគាល់ព្រះសាស្តា ។ ធម្មតាថា ព្រះសារីបុត្តត្ថេរៈនេះ ជាអ្នកបូជាអាចារ្យ សូម្បីគ្រប់កាល ព្រោះដូច្នោះ ទើបពោលនឹងកោលិតមាណពជាសម្លាញ់យ៉ាងនេះថា សម្លាញ់ យើងនឹងប្រាប់អមតៈដែលយើងសម្រេច សូម្បីដល់សញ្ជ័យបរិព្វាជកអាចារ្យរបស់យើង លោកដឹងហើយក៏នឹងត្រាស់ដឹង កាលមិនត្រាស់ដឹង ជឿពួកយើង ក៏នឹងទៅកាន់សំណាក់របស់ព្រះសាស្តា ស្តាប់ធម្មទេសនារបស់ព្រះពុទ្ធហើយ នឹងធ្វើការត្រាស់ដឹងមគ្គផល ។ បន្ទាប់ពីនោះ ជនទាំងពីរនាក់ទៅកាន់សំណាក់របស់សញ្ជ័យ ពោលថា លោកអាចារ្យ លោកនឹងធ្វើយ៉ាងណា ព្រះពុទ្ធជាម្ចាស់កើតឡើងហើយក្នុងលោក ព្រះធម៌ដែលព្រះពុទ្ធទ្រង់ត្រាស់ល្អហើយ ព្រះសង្ឃជាអ្នកបដិបត្តិល្អហើយ មក ពួកយើងនឹងគាល់ព្រះទសពល ។ សញ្ជ័យបរិព្វាជកពោលថា និយាយអ្វីបា! ហើយហាមជនទាំងពីរនោះ សម្តែងអំពីការបានលាភដ៏ប្រសើរ និងយសដ៏ប្រសើរប៉ុណ្ណោះ ដល់ជនទាំងពីរនោះ ។ ជនទាំងពីរនោះពោលថា ការនៅជាអន្តេវាសិកបែបនេះរបស់ខ្ញុំទាំងឡាយ ជាប្រចាំនោះ ចូរលើកទុកចុះ តែលោកចូរដឹងខ្លួនលោកថា នឹងទៅ ឬមិនទៅ ។ សញ្ជ័យបរិព្វាជកដឹងថា ជនទាំងនេះដឹងសេចក្តីត្រូវការមានប្រមាណប៉ុណ្ណោះហើយ នឹងមិនជឿពាក្យនិយាយរបស់យើង ទើបពោលថា ទៅចុះ បាទាំងឡាយ យើងមិន

អាចនៅជាអន្តេវាសិក (របស់អ្នកដទៃ) ក្នុងពេលជាមនុស្សចាស់ឡើយ ។ ជនទាំងពីរនោះ មិនអាចឲ្យសញ្ជ័យបរិព្វាជកនោះយល់ដោយហេតុសូម្បីជាច្រើន ទើបបាននាំជនអ្នកប្រព្រឹត្តតាមឱវាទរបស់ខ្លួនទៅកាន់ព្រះវេឡុវ័ន ។ គ្រានោះ ក្នុងបណ្តាអន្តេវាសិក ៥០០ នាក់ របស់ជនទាំងពីរនោះ ២៥០ នាក់ ត្រឡប់ ២៥០ នាក់ទៀត បានទៅជាមួយជនទាំងពីរនោះ ។

ព្រះសាស្តាទ្រង់កំពុងសម្តែងធម៌នៅកណ្តាលបរិស័ទ ៤ ទ្រង់ឃើញជនទាំងនោះពីចម្ងាយ ទើបត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ សម្លាញ់ ២ នាក់នោះ គឺ កោលិតៈ និងឧបតិស្សៈ កំពុងដើរមក គូសាវកនេះឯង នឹងជាគូសាវកដ៏ប្រសើរ ដ៏ចម្រើន ហើយទ្រង់អធិប្បាយព្រះធម្មទេសនា ជាប់ដោយចរិយានៃបរិស័ទរបស់សម្លាញ់ទាំង ២ នោះ ។ វៀរព្រះអគ្គសាវកទាំងពីរ បរិព្វាជក ២៥០ នាក់ ទាំងអស់នោះសម្រេចព្រះអរហត្ត ព្រះសាស្តាទ្រង់លាព្រះហស្ត ត្រាស់ថា ចូរជាភិក្ខុចុះ ។ សក់ និងពុកមាត់របស់បរិព្វាជកទាំងនោះបាត់ទៅ បាត្រ និងចីវរដែលកើតហើយដោយឫទ្ធិ ក៏បានមកសូម្បីដល់ព្រះអគ្គសាវកទាំងពីរផង តែកិច្ចដោយមគ្គទាំង ៣ ខាងលើ មិនទាន់សម្រេច ។ ព្រោះហេតុអ្វី? ព្រោះសាវកបារមីញាណជារបស់ធំ ។ ក្នុងថ្ងៃទី ៧ តាំងពីថ្ងៃបួស ព្រះមហាមោគ្គល្លាន ចូលទៅអាស្រ័យស្រុកកល្លវាលគ្រាម ដែនមគធៈ

ធ្វើសមណធម៌ កាលត្រូវបីនមិទ្ធៈគ្របសង្កត់ ព្រះសាស្តាទ្រង់ធ្វើឲ្យសង្វេគ បន្ទោបង់ថីនមិទ្ធៈចេញបាន កំពុងស្តាប់ធាតុកម្មដ្ឋាន ដែលព្រះតថាគតប្រទាន បានធ្វើកិច្ចនៃមគ្គ ៣ ខាងលើ ឲ្យសម្រេចដល់ទីបំផុតនៃសាវកបារមីញាណ ។ សូម្បីព្រះសារីបុត្តត្ថេរៈ កន្លងហួសវេលាទៅកន្លះខែ តាំងពីថ្ងៃបួស ចូលទៅអាស្រ័យក្រុងរាជគ្រឹះនោះឯង នៅក្នុងល្អាងសុករខាតាជាមួយព្រះសាស្តា កាលព្រះសាស្តាទ្រង់សម្តែងវេទនាបរិគ្គហសូត្រ ដល់ទីឃនខបរិព្វាជកដែលជាក្មួយរបស់ខ្លួន បានបញ្ជូនញាណទៅតាមក្រសែព្រះសូត្រ ក៏បានសម្រេចដល់ទីបំផុតនៃសាវកបារមីញាណ ដូចបរិភោគបាយដែលគេទុកដើម្បីអ្នកដទៃ ចំណែកក្មួយរបស់លោក បានតាំងនៅក្នុងសោតាបត្តិផល ក្នុងវេលាចប់ទេសនា ។ ដូច្នោះ កាលព្រះតថាគតប្រថាប់នៅក្នុងក្រុងរាជគ្រឹះនុ៎ះឯង កិច្ចនៃសាវកបារមីញាណរបស់ព្រះអគ្គសាវកសូម្បីទាំងពីរ បានដល់ទីបំផុតហើយ ។ ក៏ក្នុងវេលាតមកទៀត ព្រះសាស្តាប្រថាប់នៅក្នុងព្រះជេតវ័ន ទ្រង់បានស្ថាបនាព្រះមហាសាវកសូម្បីទាំងពីរទុកក្នុងតំណែងឯតទគ្គៈថា សារីបុត្រជាកំពូលនៃភិក្ខុសាវករបស់តថាគតអ្នកមានបញ្ញាច្រើន មហាមោគ្គល្លាន ជាកំពូលនៃភិក្ខុជាសាវករបស់តថាគតអ្នកមានឫទ្ធិច្រើន ដូច្នេះ ។

ចប់អដ្ឋកថា សូត្រទី ២-៣

# អដ្ឋកថាសូត្រទី ៤

## ប្រវត្តិព្រះមហាកស្សបត្ថេរ

*ក្នុងសូត្រទី ៤ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

*[១៤៦] ក្នុងបទថា **ធុតវាទានំ** នេះ គប្បីជ្រាបធុតបុគ្គល (បុគ្គលដែលកម្ចាត់កិលេស) ធុតវាទៈ (ការទូន្មានអំពីការកម្ចាត់កិលេស) ធុតធម៌ (ធម៌ជាគ្រឿងកម្ចាត់កិលេស) ធុតង្គៈ (អង្គរបស់អ្នកកម្ចាត់កិលេស) ។*

*បណ្ដាបទទាំងនោះ បទថា **ធុតោ** បានដល់ បុគ្គលដែលកម្ចាត់កិលេស ឬធម៌ដែលកម្ចាត់កិលេស ។*

*ក៏ក្នុងបទថា **ធុតវាទោ** នេះ (គប្បីជ្រាបថា) មានបុគ្គលដែលកម្ចាត់កិលេស មិនមានការទូន្មានក្នុងរឿងកម្ចាត់កិលេស ១ , មានបុគ្គលដែលមិនកម្ចាត់កិលេស តែមានការទូន្មានក្នុងរឿងកម្ចាត់កិលេស ១ , មានបុគ្គលដែលមិនកម្ចាត់កិលេស ទាំងមិនមានការទូន្មានក្នុងរឿងកម្ចាត់កិលេស ១ , មានបុគ្គលដែលទាំងកម្ចាត់កិលេស និងមានការទូន្មានក្នុងរឿងកម្ចាត់កិលេស ១ ។ ក្នុងបណ្ដាបុគ្គលទាំងនោះ បុគ្គលណាកម្ចាត់កិលេសរបស់ខ្លួនដោយធុតង្គៈ តែមិនឱវាទ មិនអនុសាសន៍អ្នកដទៃដោយធុតង្គៈ ដូចព្រះពកុលត្ថេរៈ បុគ្គលនេះឈ្មោះថា អ្នកកម្ចាត់កិលេស តែមិនមានការទូន្មានក្នុងរឿងកម្ចាត់កិលេស ដូច*

លោកពោលថា គឺ ព្រះពកុលៈជាអ្នកកម្ចាត់កិលេស តែមិនមានការទូន្មានក្នុងរឿងកម្ចាត់កិលេស ។ ក៏បុគ្គលណា មិនកម្ចាត់កិលេសរបស់ខ្លួនដោយធុតង្គៈ តែឱវាទ អនុសាសន៍អ្នកដទៃដោយធុតង្គៈនោះឯង ដូចព្រះឧបនន្ទត្ថេរៈ បុគ្គលនេះឈ្មោះថា ជាអ្នកមិនកម្ចាត់កិលេស តែមានការទូន្មានក្នុងរឿងកម្ចាត់កិលេស ដូចលោកពោលថា គឺ ព្រះឧបនន្ទសក្យបុត្រ មិនជាអ្នកកម្ចាត់កិលេស តែមានការទូន្មានរឿងកម្ចាត់កិលេស ។ ក៏បុគ្គលណា មិនកម្ចាត់កិលេសរបស់ខ្លួនដោយធុតង្គៈ មិនឱវាទ មិនអនុសាសន៍អ្នកដទៃដោយធុតង្គៈ ដូចព្រះលោលុទាយិត្ថេរៈ បុគ្គលនេះឈ្មោះថា ជាអ្នកមិនកម្ចាត់កិលេស (និង) មិនមានការទូន្មានរឿងកម្ចាត់កិលេស ដូចលោកពោលថា គឺ ព្រះមហាលោលុទាយី ជាអ្នកមិនកម្ចាត់កិលេស មិនមានការទូន្មានរឿងកម្ចាត់កិលេស ។ ចំណែកបុគ្គលណា សម្បូរណ៍ដោយការកម្ចាត់កិលេស និងមានការទូន្មានរឿងកម្ចាត់កិលេស ដូចព្រះមហាកស្សបត្ថេរៈ បុគ្គលនេះឈ្មោះថា ជាអ្នកកម្ចាត់កិលេស និងមានការទូន្មានរឿងកម្ចាត់កិលេស ដូចលោកពោលថា គឺ ព្រះមហាកស្សបៈ ជាអ្នកកម្ចាត់កិលេស និងមានការទូន្មានរឿងកម្ចាត់កិលេស ដូច្នេះ ។

បទថា **ធុតធម្មា វេទិតព្វា** សេចក្តីថា ធម៌ ៥ ប្រការ ដែលជាបរិវាររបស់ធុតង្គចេតនាទាំងនេះ គឺ ភាពជាអ្នកប្រាថ្នាតិច ១ ភាពជាអ្នកសន្តោស ១

ភាពជាអ្នកជុសខាត់ ១ ភាពជាអ្នកស្ងាត់ ១ ភាពជាអ្នកមានវត្ថុនេះ ១ ឈ្មោះថា ធម៌គ្រឿងកម្ចាត់កិលេស ព្រោះព្រះបាលីថា **អប្បិច្ឆំយេវ និស្សាយ** (អាស្រ័យសេចក្តីប្រាថ្នាតិចប៉ុណ្ណោះ) ដូច្នេះ ជាដើម ។ ក្នុងធម៌ ៥ ប្រការនោះ សេចក្តីប្រាថ្នាតិច និងសេចក្តីសន្តោស ជាអលោភៈ ។ ការជុសខាត់ និងសេចក្តីវិវេក ចាត់ចូលក្នុងធម៌ ២ ប្រការ គឺ អលោភៈ និងអមោហៈ ។ ភាពជាអ្នកមានវត្ថុនេះ គឺ ញាណនុ៎ះឯង ។ បណ្តាអលោភៈ និងអមោហៈទាំងនោះ កម្ចាត់សេចក្តីលោភក្នុងវត្ថុដែលត្រូវហាម ដោយអលោភៈ កម្ចាត់មោហៈដែលបិទបាំងទោសក្នុងវត្ថុដែលត្រូវហាមទាំងនោះឯង ដោយអមោហៈ ។ មួយទៀត កម្ចាត់កាមសុខល្លិកានុយោគដែលប្រព្រឹត្តទៅដោយមុខ គឺ ការសេពវត្ថុដែលទ្រង់អនុញ្ញាត ដោយអលោភៈ កម្ចាត់អត្តកិលមថានុយោគដែលប្រព្រឹត្តទៅដោយមុខ គឺ ការជុសខាត់ដ៏ក្រៃលែងក្នុងធុតង្គទាំងឡាយ ដោយអមោហៈ ព្រោះដូច្នោះ ធម៌ទាំងនេះ គប្បីជ្រាបថា ធម៌ជាគ្រឿងកម្ចាត់កិលេស ។

បទថា **ធុតង្គានិ វេទិតព្វានិ** សេចក្តីថា គប្បីជ្រាបធុតង្គៈ ១៣ គឺ បង្សុកូលិកង្គៈ (អង្គរបស់ភិក្ខុដែលសមាទានសំពត់បង្សុកូលជាវត្ត) ។ល។ នេ-សជ្ជិកង្គៈ (អង្គរបស់ភិក្ខុដែលសមាទានការអង្គុយជាវត្ត) ។

បទថា **ធុតវាទានំ យទិទំ មហាកស្សបោ** សេចក្តីថា ទ្រង់ស្ថាបនាទុក

ក្នុងតំណែងឯតទគ្គៈ ក្នុងវាងភិក្ខុដែលទ្រទ្រង់ធុតង្គៈថា មហាកស្សបត្ថេរៈនេះ ជាកំពូល ។ បទថា **មហាកស្សបោ** សេចក្ដីថា លោកពោលថា ព្រះមហាកស្សបៈអង្គនេះ ព្រោះប្រៀបនឹងព្រះថេរៈតូចៗ ទាំងនេះ គឺ ព្រះឧរុវេលកស្សបៈ ព្រះនទីកស្សបៈ ព្រះគយាកស្សបៈ ព្រះកុមារកស្សបៈ ។ ក្នុងបញ្ហាកម្ម សូម្បីរបស់ព្រះមហាកស្សបៈនេះ មានរឿងដែលពោលតាមលំដាប់ដូចតទៅ ៖

បានឮថា ក្នុងអតីតកាល ចុងសែនកប្ប ព្រះសាស្ដាព្រះនាមថា **បទុមុត្តរៈ** ឧប្បត្តិឡើងក្នុងលោក កាលព្រះអង្គស្ដេចចូលទៅអាស្រ័យក្រុងហង្សវតី ប្រថាប់នៅក្នុងខេមមិគទាយវ័ន កុដុម្ពិកៈនាមថា **វេទេហៈ** មានទ្រព្យសម្បត្តិ ៨០ កោដិ បរិភោគអាហារល្អពីព្រឹកព្រលឹម អធិដ្ឋានអង្គឧបោសថ កាន់របស់ក្រអូប និងផ្កាឈើជាដើម ទៅព្រះវិហារបូជាព្រះសាស្ដា ថ្វាយបង្គំហើយ អង្គុយក្នុងទីដ៏សមគួរមួយ ។ ខណៈនោះ ព្រះសាស្ដាទ្រង់ស្ថាបនាសាវកអង្គទី ៣ នាមថា **មហានិសភត្ថេរ** ទុកក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ និសភៈ ជាកំពូលនៃភិក្ខុសាវករបស់តថាគតអ្នកទ្រទ្រង់ធុតង្គៈ ។ ឧបាសកស្ដាប់ព្រះតម្រាស់នោះហើយ ជ្រះថ្លា វេលាចប់ធម្មកថា មហាជនក្រោកទៅហើយ ទើបថ្វាយបង្គំព្រះសាស្ដាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់ទទួលភិក្ខារបស់ខ្ញុំព្រះអង្គក្នុងថ្ងៃស្អែកនេះ ។ ព្រះសាស្ដាត្រាស់ថា ឧបាសក ភិក្ខុសង្ឃច្រើន

ណាស់ ឧបាសកទូលសួរថា បពិត្រព្រះដ៏មានព្រះភាគ ភិក្ខុសង្ឃមានប្រមាណប៉ុនណា? ព្រះសាស្ដាត្រាស់ថា មានប្រមាណ ៨ សែនអង្គ ឧបាសកក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គចូរទទួលភិក្ខា សូម្បីតែសាមណេរមួយរូបក៏កុំនៅសល់ក្នុងវិហារ ។ ព្រះសាស្ដាទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ ឧបាសកដឹងថា ព្រះសាស្ដាទ្រង់ទទួលនិមន្តហើយ ទើបទៅផ្ទះត្រៀមមហាទានក្នុងថ្ងៃស្អែក បញ្ជូនឲ្យអ្នកទៅក្រាបទូលវេលា (ភត្តាហារ) ចំពោះព្រះសាស្ដា ។ ព្រះសាស្ដាទ្រង់ប្រដាប់បាត្រ និងចីវរ មានភិក្ខុសង្ឃហែហម ទៅកាន់ផ្ទះរបស់ឧបាសក ប្រថាប់លើអាសនៈដែលគេតាក់តែងថ្វាយ ។ វេលាសម្រេចដោយទឹកទក្ខិណោទក ទ្រង់ទទួលបបរជាដើម បានទ្រង់លះបង់បាយស្រួយ ។ សូម្បីឧបាសកក៏អង្គុយនៅជិតព្រះសាស្ដា ។

វាងនោះ ព្រះមហានិសភត្ថេរ កំពុងត្រាច់បិណ្ឌបាត ដើរទៅកាន់ថ្នល់នោះឯង ។ ឧបាសកឃើញ ទើបក្រោកឡើងទៅថ្វាយបង្គំព្រះថេរៈ ហើយពោលថា លោកម្ចាស់ដ៏ចម្រើន សូមលោកចូរឲ្យបាត្រ ព្រះថេរៈបានឲ្យបាត្រ ។ ឧបាសកពោលថា លោកម្ចាស់ដ៏ចម្រើន សូមនិមន្តចូលទៅក្នុងផ្ទះនេះចុះ សូម្បីព្រះសាស្ដាក៏ប្រថាប់នៅក្នុងផ្ទះ ។ ព្រះថេរៈពោលថា មិនគួរទេដឹងឧបាសក ។ ឧបាសក ទទួលបាត្ររបស់ព្រះថេរៈដាក់បិណ្ឌបាតពេញហើយ បាននាំចេញទៅ

ថ្វាយ ។ តពីនោះ បានដើរជូនព្រះថេរៈទៅ ហើយត្រឡប់មកអង្គុយក្នុងទីជិតព្រះសាស្ដា ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមហានិសភត្ថេរ សូម្បីខ្ញុំព្រះអង្គពោលថា ព្រះសាស្ដាប្រថាប់នៅក្នុងផ្ទះ ក៏មិនប្រាថ្នានឹងចូលមក ព្រះមហានិសភត្ថេរនោះ មានគុណក្រៃលែងជាងព្រះអង្គឬហ្ន៎ ជាធម្មតាព្រះពុទ្ធទាំងឡាយ រមែងមិនមានវណ្ណមច្ឆរិយៈ (កំណាញ់គុណ គឺ សេចក្ដីល្អរបស់អ្នកដទៃ) ។ លំដាប់នោះ ព្រះសាស្ដាត្រាស់យ៉ាងនេះថា ម្នាលឧបាសក តថាគតធ្លាប់អង្គុយភិក្ខានៅក្នុងផ្ទះ តែភិក្ខុនោះមិនធ្លាប់អង្គុយភិក្ខាក្នុងផ្ទះយ៉ាងនេះ តថាគតនៅក្នុងសេនាសនៈជាយស្រុក ភិក្ខុនោះនៅក្នុងព្រៃប៉ុណ្ណោះ តថាគតនៅក្នុងទីប្រក់បាំង ភិក្ខុនោះនៅកណ្ដាលវាលប៉ុណ្ណោះ ដូច្នោះ ភិក្ខុនោះមានគុណនេះៗ ត្រាស់ដូចធ្វើមហាសមុទ្រឲ្យពេញដូច្នោះ ។ ឧបាសក សូម្បីតាមប្រក្រតីជាអ្នកជ្រះថ្លាក្រៃលែងហើយ ទើបដូចជាប្រទីបដែលឆេះឆ្លាឡើង (ព្រោះ) ត្រូវបីតដោយប្រេងដូច្នោះ គិតថា ត្រូវការអ្វីដោយសម្បត្តិដទៃសម្រាប់យើង យើងនឹងធ្វើសេចក្ដីប្រាថ្នា ដើម្បីត្រូវការភាពជាកំពូលនៃភិក្ខុទាំងឡាយដែលជាធុតវាទៈក្នុងសំណាក់របស់ព្រះពុទ្ធព្រះអង្គណាមួយក្នុងអនាគត ។

ឧបាសកនោះ ទើបនិមន្តព្រះសាស្ដាទៀត ថ្វាយមហាទានទំនងនោះឯង អស់ ៧ ថ្ងៃ ។ ថ្ងៃទី ៧ ថ្វាយត្រៃចីវរដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន

ហើយក្រាបទៀបព្រះបាទរបស់ព្រះសាស្តា ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ដោយមេត្តាកាយកម្ម មេត្តាវចីកម្ម មេត្តាមនោកម្ម របស់ខ្ញុំព្រះអង្គអ្នកថ្វាយមហាទាន ៧ ថ្ងៃ ខ្ញុំព្រះអង្គមិនប្រាថ្នាសម្បត្តិរបស់ទេវតា ឬសម្បត្តិរបស់ស្តេចសក្កៈ មារ និងព្រហ្ម ត្រឹមតែម្យ៉ាងក៏ទេ ក៏កម្មរបស់ខ្ញុំព្រះអង្គនេះចូរជាបច្ច័យដល់ភាពជាកំពូលនៃភិក្ខុដែលទ្រទ្រង់ធុតង្គៈ ១៣ ដើម្បីត្រូវការដល់តំណែងដែលព្រះមហានិសភត្ថេរដល់ហើយ ក្នុងសំណាក់របស់ព្រះពុទ្ធព្រះអង្គណាមួយក្នុងអនាគត ។ ព្រះសាស្តាទ្រង់ពិចារណាមើលថា ដែលឧបាសកនេះប្រាថ្នាតំណែងធំ នឹងសម្រេចឬទេហ្ន៎ ទ្រង់ជ្រាបថា សម្រេច ទើបត្រាស់ថាអ្នកប្រាថ្នាអគ្គឋានដ៏ធំ ព្រះពុទ្ធព្រះនាមថា **គោតម** នឹងឧប្បត្តិឡើងក្នុងទីបំផុតនៃសែនកប្បក្នុងអនាគត អ្នកនឹងជាព្រះសាវកទី ៣ របស់ព្រះគោតមសម្ពុទ្ធនោះឈ្មោះថា **មហាកស្សបត្ថេរ** ។ ឧបាសក បានស្តាប់ពុទ្ធព្យាករណ៍នោះហើយគិតថា ធម្មតាថា ព្រះពុទ្ធទាំងឡាយ រមែងមិនត្រាស់ពាក្យជា ២ ទើបបានសម្គាល់សម្បត្តិនោះ ដូចជាបានក្នុងថ្ងៃស្អែកនេះ ។ ឧបាសកនោះរស់នៅនៃជួរអាយុថ្វាយទានមានប្រការផ្សេងៗ រក្សាសីល ធ្វើកុសលកម្មនានប្បការ ស្លាប់ទៅពីអត្តភាពនោះ ហើយកើតក្នុងសួគ៌ ។ ចាប់ផ្តើមតាំងពីនោះ គេសោយសម្បត្តិទាំងក្នុងទេវតា និងមនុស្ស ក្នុងកប្បទី ៩១ ពីភទ្ទកប្បនេះ កាលព្រះវិបស្សី-

សម្មាសម្ពុទ្ធទ្រង់អាស្រ័យ ក្រុងពន្ធុមតី ប្រថាប់នៅក្នុងមិគទាយវ័នដ៏ក្សេម ក៏ចុតិចាកទេវលោក ទៅកើតក្នុងត្រកូលព្រាហ្មណ៍ចាស់មួយ ។

ក៏ក្នុងគ្រានោះ ព្រះដ៏មានព្រះភាគព្រះនាមវិបស្សី ត្រាស់ព្រះធម៌ទេសនារាល់ៗ ៧ ឆ្នាំ បានមានភាពកោលាហលធំ ។ ទេវតាទាំងឡាយទូទាំងជម្ពូទ្វីបបានប្រាប់ព្រាហ្មណ៍នោះថា ព្រះសាស្តាទ្រង់នឹងសម្តែងធម៌ ។ ព្រាហ្មណ៍បានស្តាប់ដំណឹងនោះ ។ ព្រាហ្មណ៍នោះ មានសំពត់ស្លៀកតែមួយផ្ទាំង នាងព្រាហ្មណីក៏ដូចគ្នា តែទាំងពីរនាក់មានសំពត់ដណ្តប់តែមួយផ្ទាំងប៉ុណ្ណោះ ទើបប្រាកដដោយទូទាំងព្រះនគរថា **ឯកសាដកព្រាហ្មណ៍** ។ កាលពួកព្រាហ្មណ៍ប្រជុំគ្នា ដោយកិច្ចខ្លះៗ ត្រូវឲ្យនាងព្រាហ្មណីនៅផ្ទះ ខ្លួនឯងទៅ កាល (ដល់) ពួកព្រាហ្មណីប្រជុំគ្នា ខ្លួនឯងត្រូវនៅផ្ទះ នាងព្រាហ្មណីដណ្តប់សំពត់នោះទៅ (ប្រជុំ) ក៏ក្នុងថ្ងៃនោះ ព្រាហ្មណ៍និយាយចំពោះព្រាហ្មណីថា នាងដ៏ចម្រើន នាងនឹងស្តាប់ធម៌ពេលយប់ ឬពេលថ្ងៃ ។ ព្រាហ្មណីនិយាយថា នាងខ្ញុំឈ្មោះថា ជាស្ត្រីមេផ្ទះ មិនអាចស្តាប់ពេលយប់បាន សូមស្តាប់ពេលថ្ងៃចុះ ហើយឲ្យព្រាហ្មណ៍នៅចាំផ្ទះ (ខ្លួនឯង) ដណ្តប់សំពត់នោះទៅពេលថ្ងៃព្រមជាមួយពួកឧបាសិកា ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងទីសមគួរមួយ ស្តាប់ធម៌ហើយ ត្រឡប់មកព្រមជាមួយពួកឧបាសិកា ពេលនោះ ព្រាហ្មណ៍បានឲ្យព្រាហ្មណីនៅផ្ទះ (ខ្លួនឯង)

ដណ្តប់សំពត់នោះទៅវិហារ ។ សម័យនោះ ព្រះបរមសាស្តាប្រថាប់លើធម្មាសនៈ ដែលគេតាក់តែងទុកកណ្តាលបរិស័ទ ទ្រង់ចាប់ផ្ចិតដ៏វិចិត្រ ត្រាស់ធម្មកថាហាក់ដូចជាធ្វើសត្វឲ្យចូលអាកាសគង្គា និងហាក់ដូចជាទ្រង់ធ្វើភ្នំសិនេរុ ឲ្យជាមោកវនសាគរ ដូច្នោះ ។ កាលព្រាហ្មណ៍អង្គុយស្តាប់ធម៌នៅក្រោយបរិស័ទ បីតិ ៥ ប្រការកើតឡើងពេញទូទាំងសរីរៈ ក្នុងបឋមយាមទុ៎ះឯង ព្រាហ្មណ៍នោះទាញសំពត់ដែលខ្លួនដណ្តប់ចេញមកគិតថា នឹងថ្វាយព្រះទសពល ។ គ្រានោះសេចក្តីកំណាញ់ ចន្លុលទោសដល់ពាន់ប្រការ កើតឡើងដល់ព្រាហ្មណ៍នោះថាព្រាហ្មណីនឹងយើង មានសំពត់ដណ្តប់តែមួយផ្ទាំងប៉ុណ្ណោះ សំពត់ដណ្តប់ផ្ទាំងដទៃណាៗ មិនមាន ក៏ជម្ពូតាថា មិនដណ្តប់ក៏ចេញទៅខាងក្រៅមិនបាន ទើបដាក់ចុះចិត្ត មិនត្រូវការថ្វាយដោយប្រការទាំងពួង លុះកាលបឋមយាមកន្លងទៅ បីតិដូច្នោះឯង កើតឡើងដល់ព្រាហ្មណ៍នោះ សូម្បីក្នុងមជ្ឈិមយាម ព្រាហ្មណ៍គិតដូចយ៉ាងនោះហើយ ក៏មិនបានថ្វាយដូចគ្នា ។ កាលមជ្ឈិមយាមកន្លងទៅបីតិដូច្នោះឯង កើតឡើងដល់ព្រាហ្មណ៍នោះសូម្បីក្នុងបច្ឆិមយាម ។ ព្រាហ្មណ៍នោះគិតថា ជាអ្វីហ្ន៎ នឹងដឹងគ្នាពេលក្រោយ ដូច្នេះ ហើយទាញសំពត់មកដាក់ទៀបព្រះបាទព្រះបរមសាស្តា ។ តអំពីនោះ ក៏អង្គុញដៃឆ្វេងយកដៃស្តាំទះចុះ ៣ ដង ហើយបន្លឺឡើង ៣ វារៈថា ជិតំ មេ ជិតំ មេ ជិតំ មេ (យើងឈ្នះ

ហើយៗ) ។

សម័យនោះ ព្រះបាទពន្ធុមរាជប្រថាប់អង្គុយស្តាប់ធម៌នៅខាងក្នុងវាំង-ននក្រោយធម្មាសនៈ ដែលធម្មតាព្រះរាជាទ្រង់មិនពេញព្រះទ័យនឹងសំឡេងថា ជិតំ មេ ជិតំ មេ ទើបបញ្ជូនរាជបុរសទៅ ដោយព្រះតម្រាស់ថា អ្នកចូរទៅសួរព្រាហ្មណ៍នោះថា គេនិយាយដូចម្តេច ។ ព្រាហ្មណ៍នោះត្រូវរាជបុរសសួរ ទើបពោលថា អ្នកដទៃក្រៅចាកពីខ្ញុំ ឡើងយាន គឺ ដំរីជាដើម កាន់ដាវនិងក្រោះស្បែកជាដើម ទើបបានជ័យជំនះក្នុងកងទ័ពសត្រូវ ជ័យជំនះនោះ មិនគួរអស្ចារ្យ ចំណែកយើងបានញាំញីចិត្តកំណាញ់ហើយ ថ្វាយនូវសំពត់ដែលដណ្តប់ចំពោះព្រះទសពល ដូចបុគ្គលព្រទង់វាយក្បាលគោកោង ដែលតាមមកខាងក្រោយ ធ្វើឲ្យវាគេចចេញទៅ ជ័យជំនះរបស់យើងនោះ ទើបគួរអស្ចារ្យ ។ រាជបុរសទៅក្រាបទូលរឿងរ៉ាវនោះដល់ព្រះរាជា ។ ព្រះរាជាត្រាស់បន្ទាប់ថា នែ៎នាយ ពួកយើងមិនដឹងវត្ថុដែលសមគួរដល់ព្រះទសពល ព្រាហ្មណ៍ដឹងឬ ទើបឲ្យបញ្ជូនសំពត់មួយគូ (សំពត់ស្លៀកនឹងសំពត់ដណ្តប់) ទៅព្រះរាជទាន ព្រាហ្មណ៍ឃើញសំពត់គូនោះហើយ គិតថា ព្រះរាជានេះ មិនព្រះរាជទានអ្វីជាលើកដំបូងដល់យើងដែលអង្គុយស្ងៀមៗ កាលយើងពោលគុណទាំងឡាយរបស់ព្រះបរម-សាស្តា ទើបបានព្រះរាជទាន នឹងមានប្រយោជន៍អ្វីដល់យើង ចំពោះសំពត់គូ

ដែលអាស្រ័យព្រះគុណរបស់ព្រះបរមសាស្តាកើតឡើង ទើបបានថ្វាយសំពត់គូសូម្បីនោះដល់ព្រះទសពលទៀត ។ ព្រះរាជាត្រាស់សួរថា ព្រាហ្មណ៍ធ្វើយ៉ាងណា ទ្រង់ស្តាប់ថា ព្រាហ្មណ៍ថ្វាយសំពត់គូនោះចំពោះព្រះតថាគតប៉ុណ្ណោះ ទើបត្រាស់បង្គាប់ឲ្យបញ្ជូនសំពត់គូ ២ ឈុតសូម្បីដទៃជាព្រះរាជទាន ។ ព្រាហ្មណ៍នោះបានថ្វាយសំពត់គូ ២ ឈុតសូម្បីនោះ ។ ព្រះរាជាទ្រង់បញ្ជូនសំពត់គូ ៤ ឈុតសូម្បីដទៃជាព្រះរាជទាន ទ្រង់បញ្ជូនទៅជាព្រះរាជទាន ដល់ ៣២ គូ ដោយប្រការយ៉ាងនេះ ។ លំដាប់នោះព្រាហ្មណ៍គិតថា ការធ្វើដូច្នេះ ដូចជាឲ្យបន្ថែមឡើងហើយទើបនឹងទទួលយក ទើបកាន់យកសំពត់ ២ គូ គឺ ដើម្បីប្រយោជន៍ដល់ខ្លួន ១ គូ នាងព្រាហ្មណី ១ គូ ហើយថ្វាយដល់ព្រះទសពល ៣០ គូ ។ ចាប់ផ្តើមតាំងពីនោះ ព្រាហ្មណ៍ក៏បានជាអ្នកស្និទ្ធស្នាលជាមួយព្រះបរមសាស្តា ។ ថ្ងៃមួយ ព្រះរាជាទ្រង់ស្តាប់ធម៌ក្នុងសំណាក់របស់ព្រះបរមសាស្តា ក្នុងរដូវត្រជាក់ បានព្រះរាជទានសំពត់កម្ពលក្រហមសម្រាប់ដណ្តប់ជាចំណែកព្រះអង្គ មានតម្លៃមួយពាន់ចំពោះព្រាហ្មណ៍ ហើយត្រាស់បង្គាប់ថា ចាប់ពីពេលនេះទៅ លោកចូរដណ្តប់សំពត់កម្ពលក្រហមផ្ទាំងនេះស្តាប់ធម៌ ព្រាហ្មណ៍នោះគិតថា ប្រយោជន៍អ្វីនឹងសំពត់កម្ពលក្រហមនេះចំពោះ ដែលនឹងបង្អោននាំមកចូលក្នុងកាយស្អុយនេះ ទើបបានធ្វើជាពិតានលើគ្រែរបស់ព្រះតថាគត ខាងក្នុងព្រះគន្ធកុដិ ហើយ

ក៏ទៅ ។ ក្រោយមកថ្ងៃមួយ ព្រះរាជាស្តេចទៅព្រះវិហារពីព្រឹកព្រលឹម ប្រថាប់អង្គុយក្នុងទីជិតព្រះបរមសាស្តាក្នុងព្រះគន្ធកុដិ ក៏ក្នុងខណៈនោះ ព្រះពុទ្ធរស្មីមានពណ៌ ៦ ប្រការ ប៉ះខ្លប់ដែលសំពត់កម្ពល សំពត់កម្ពលក៏ពន្លឺត្រចះត្រចង់ឡើង ព្រះរាជាទតព្រះនេត្រឃើញក៏ចាំបានទើប ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សំពត់កម្ពលផ្ទាំងនេះរបស់ខ្ញុំព្រះអង្គៗ ឲ្យឯកសាដកព្រាហ្មណ៍ ។ មហាបពិត្រ ព្រះអង្គបូជាព្រាហ្មណ៍ ព្រាហ្មណ៍បូជាតថាគត ។ ព្រះរាជាទ្រង់ជ្រះថ្លាថា ព្រាហ្មណ៍ដឹងវត្ថុដែលសមគួរ យើងមិនដឹង ទើបព្រះរាជទានវត្ថុដែលជារបស់ជួយសង្គ្រោះដល់មនុស្សគ្រប់យ៉ាងៗ មួយមុខៗ ៨ ប្រភេទ ៨ ដង ឲ្យជារបស់ប្រទាន ឈ្មោះថា សព្វដ្ឋកទាន ហើយទ្រង់តាំងឲ្យជាបុរោហិត ។ ព្រាហ្មណ៍នោះគិតថា ឈ្មោះថា របស់ ៨ ប្រភេទ ៨ ដង ក៏ជា ៦៤ ប្រភេទ ទើបតាំងស្លាកភត្ត ៦៤ កន្លែង ឲ្យទាន រក្សាសីលរហូតអស់មួយជីវិត ចុតិពីជាតិនោះទៅកើតក្នុងសួគ៌ ចុតិពីសួគ៌ត្រឡប់មកកើតក្នុងផ្ទះរបស់កុដុម្ពិកៈ ក្នុងក្រុងពារាណសី ក្នុងចន្លោះកាលរបស់ព្រះពុទ្ធ ២ ព្រះអង្គ គឺ ព្រះដ៏មានព្រះភាគកោនាគមនៈ និងព្រះកស្សបទសពលក្នុងកប្បនេះ ។ គេចម្រើនវ័យ ក៏ទទួលនាទីគ្រប់គ្រងផ្ទះ ថ្ងៃមួយ ដើរទៅលេងក្នុងព្រៃ ។

ក៏សម័យនោះ ព្រះបច្ចេកពុទ្ធធ្វើចីវរកម្ម (គឺការដេរចីវរ) នៅត្រង់ប្រាំង

ទុន្ទ សំពត់អនុវាត (ផ្ទាំងសំពត់តូចៗ ដែលផ្ចប់ទីនជាយចីវរ និងសង្ឃាដិ) មិនគ្រប់ទើបផ្ដើមនឹងមូរទុក គេឃើញទើបពោលសួរថា ព្រោះអ្វីទើបមូរទុក លោកម្ចាស់ ។ ព្រះបច្ចេកពុទ្ធពោលថា សំពត់អនុវាតមិនគ្រប់ ។ កុដុម្ពិកៈ ពោលថា មេត្តាយកសំពត់សាដកនេះធ្វើចុះ លោកម្ចាស់ ។ គេថ្វាយសំពត់សាដកហើយ តាំងសេចក្ដីប្រាថ្នាថា ក្នុងទីដែលខ្ញុំកើតហើយ សេចក្ដីសាបសូន្យណាៗ សូមកុំឲ្យមាន ។ គ្រានោះ ព្រះបច្ចេកពុទ្ធចូលទៅបិណ្ឌបាត សូម្បីក្នុងផ្ទះរបស់គេ ក្នុងកាលភរិយា និងប្អូនក្រមុំកំពុងឈ្លោះគ្នា ។ ពេលនោះ ប្អូនក្រមុំរបស់គេថ្វាយបិណ្ឌបាតដល់ព្រះបច្ចេកពុទ្ធ ហើយពោលបំណាងដល់ភរិយារបស់គេ បានតាំងសេចក្ដីប្រាថ្នាថា សូមឲ្យយើងឃ្លាតឆ្ងាយពីស្ត្រីពាលបែបនេះរយយោជន៍ ។ ភរិយារបស់គេឈរត្រង់ទីលានផ្ទះបានឮ ទើបគិតថា ភិក្ខុរូបនេះចូរកុំបានឆាន់អាហារដែលនាងម្នាក់នេះថ្វាយ ទើបចាប់បាត្រមកចាក់បិណ្ឌបាតចោល ហើយយកភក់មកដាក់ដរាបពេញ ។ នាងឃើញទើបពោលថា ស្ត្រីពាលនាងចូរជេរស្ដីយើងមុនចុះ ការចាក់កត្តាហារពីបាត្ររបស់លោកអ្នកបានបំពេញបារមីមក ២ អសង្ខេយ្យបែបនេះ ហើយដាក់ភក់ឲ្យ មិនសមគួរឡើយ ។ គ្រានោះ ភរិយារបស់គេកើតសេចក្ដីជឹងខ្លួនឡើង ទើបពោលថា មេត្តាប្រោសឈប់សិនលោកម្ចាស់ ហើយចាក់ភក់ចេញ លាងបាត្រឲ្យស្អាតដោយកម្មេចផង់

គ្រឿងក្រអូប បានដាក់របស់មានរសឆ្ងាញ់ ៤ យ៉ាង ពេញបាត្រ រួចថ្វាយបាត្រ ដ៏ផូរផង់ដោយទឹកដោះថ្លា មានពណ៌ដូចត្របកបទុមដែលស្រោចខាងលើ ក្នុងដៃ របស់ព្រះបច្ចេកពុទ្ធ តាំងសេចក្ដីប្រាថ្នាថា សរីរៈរបស់យើងចូរផូរផង់ដូចបិណ្ឌ-បាតដែលផូរផង់នេះចុះ ។ ព្រះបច្ចេកពុទ្ធអនុមោទនាហើយ ក៏ហោះឡើងកាន់ អាកាស ។

ប្ដីប្រពន្ធទាំងពីរនោះ រស់នៅរហូតអស់អាយុហើយ ទៅកើតក្នុងសួគ៌ ច្យុតិចាកសួគ៌នោះម្ដងទៀត ឧបាសកកើតជាបុត្រសេដ្ឋីមានសម្បត្តិ ៨០ កោដិ ក្នុងក្រុងពារាណសី ក្នុងគ្រាព្រះកស្សបទសពលសម្មាសម្ពុទ្ធ ចំណែកកិរិយាកើត ជាធីតារបស់សេដ្ឋីដូចគ្នា កាលគេចម្រើនវ័យ ពួកញាតិក៏នាំធីតារបស់សេដ្ឋីនោះ ឯងមក ។ ដោយអានុភាពរបស់កម្មដែលមានវិបាក ដែលមិនគួរប្រាថ្នាក្នុងជាតិ មុន ពេលនាង (ត្រូវនាំខ្លួន) ចូលទៅកាន់ត្រកូលរបស់ស្វាមី ទូទៅទាំងសរីរៈ បានកើតក្លិនស្អុយដូចបង្គន់ដែលគេបើកគម្រប (ផ្ដើមពីឈានចូលទៅ) ខាងក្នុង ទ្វារ ។ សេដ្ឋីកុមារសួរថា នេះក្លិនរបស់នរណា បានស្ដាប់ថា របស់កូនក្រមុំ សេដ្ឋី ទើបពោលថា នាំចេញទៅៗ ហើយបញ្ជូនឲ្យត្រឡប់ទៅផ្ទះត្រកូល ដោយ ទំនងដែលមក នាងត្រូវបញ្ជូនឲ្យត្រឡប់ដល់ ៧ ដង ដោយទំនងនេះឯង ។

ក៏សម័យនោះ ព្រះកស្សបទសពលស្ដេចបរិនិព្វានហើយ ពុទ្ធសាស-

និកជន ធ្វើមកសាងព្រះចេតិយកម្ពស់មួយយោជន៍ ដោយឥដ្ឋមាសពណ៌ក្រហម ទាំងក្រាស់ទាំងតាន់ មានតម្លៃមួយដុំមួយសែន ។ កាលគេកំពុងសាងព្រះចេតិយ សេដ្ឋីធីតានោះគិតថា យើងត្រូវគេបញ្ជូនឲ្យត្រឡប់ ៧ ដងហើយ នឹងប្រយោជន៍អ្វីក្នុងជីវិតរបស់យើង ទើបឲ្យដោះវត្ថុគ្រឿងប្រដាប់ខ្លួន ធ្វើឥដ្ឋមាស ប្រវែងមួយហត្ថ ទទឹងមួយចង្អាម កម្ពស់ ៤ ធ្នាប់ បន្ទាប់ពីនោះកាន់ដុំហរតាល និងមនោសិលារក្សា យកផ្កាឈូក ៨ ក្តាប់ ទៅកាន់ស្ថានទីដែលសាងព្រះចេតិយ ។ ខណៈនោះ ជួរដុំឥដ្ឋដែលក (រៀប) មក ត្រូវខ្វះឥដ្ឋមួយដុំដើម្បីភ្ជាប់ នាងទើបនិយាយជាមួយជាងថា លោកចូរដាក់ឥដ្ឋដុំនេះត្រង់នេះ ។ ជាងពោលថា នាងដ៏ចម្រើន នាងមកចំពេលហើយ ចូរនាងដាក់ខ្លួនឯងចុះ ។ នាងទើបឡើងទៅយកប្រេងផ្សំនឹងហរតាល និងមនោសិលា ដាក់ឥដ្ឋភ្ជាប់ដោយគ្រឿងលាយនោះ បូជាដោយផ្កាឧប្បល ៨ ក្តាប់ដៃ ខាងលើ (ឥដ្ឋ) ហើយថ្វាយបង្គំ តាំងសេចក្តីប្រាថ្នាថា ក្នុងទីដែលយើងកើត ក្លិនចន្ទន៍ចូរផ្សាយចេញអំពីខ្លួន ក្លិនឧប្បលចូរផ្សាយចេញអំពីមាត់ ថ្វាយបង្គំព្រះចេតិយ ហើយធ្វើប្រទក្សិណត្រឡប់ទៅ ។ ក្នុងខណៈនោះឯង សេដ្ឋីបុត្រក៏កើតសតិប្រារព្ធដល់សេដ្ឋីធីតា ដែលគេនាំមកផ្ទះគ្រាដំបូង ។ សូម្បីក្នុងព្រះនគរ ក៏មាននក្ខត្តឫក្សសំឡេងគឹកកង គេទើបនិយាយនឹងអ្នកបម្រើថា គ្រានោះ គេនាំសេដ្ឋីធីតាមកក្នុងទីនេះ នាងនៅទីណា ។

អ្នកបម្រើពោលថា នៅឯផ្ទះត្រកូល លោកម្ចាស់ សេដ្ឋីបុត្រពោលថា ពួកលោកចូរនាំមក យើងនឹងលេងនក្ខត្តឫក្សជាមួយនាង ។ ពួកអ្នកបម្រើទៅសំពះនាងហើយឈរ ត្រូវនាងសួរថា បាទាំងឡាយមកធ្វើអ្វី ទើបប្រាប់រឿងរ៉ាវដែលមកនោះ នាងពោលថា បាទាំងឡាយ យើងយកគ្រឿងអាភរណៈបូជាព្រះចេតិយអស់ហើយ យើងមិនមានគ្រឿងអាភរណៈ អ្នកបម្រើទាំងនោះ ទើបទៅប្រាប់ដល់បុត្រសេដ្ឋីៗ ពោលថា ចូរនាំមកចុះ នាងនឹងបានគ្រឿងប្រដាប់នោះ ពួកគេទើបទៅនាំនាងមក ក្លិនចន្ទន៍ និងក្លិនឧប្បលផ្សាយទៅទូទាំងផ្ទះ ព្រមជាមួយនាងចូលទៅក្នុងផ្ទះ ។ បុត្រសេដ្ឋីទើបសួរនាងថា គ្រាដំបូង ក្លិនស្អុយផ្សាយចេញខ្លួននាង តែឥឡូវនេះ ក្លិនចន្ទន៍ផ្សាយចេញពីខ្លួន ក្លិនឧប្បលផ្សាយចេញពីមាត់របស់នាង តើមានហេតុអ្វី ។ ធីតាសេដ្ឋីទើបប្រាប់កម្ម ដែលខ្លួនធ្វើតាំងពីដើម ។ បុត្រសេដ្ឋីជ្រះថ្លាថា ពាក្យទូន្មានរបស់ព្រះពុទ្ធទាំងឡាយ ជានិយ្យានិកធម៌ហ្ន៎ ទើបយកគ្រឿងគ្របដណ្តប់ធ្វើដោយសំពត់កម្ពល ដណ្តប់ព្រះចេតិយមាសមានប្រមាណមួយយោជន៍ ហើយយកផ្កាបទុមមាសទំហំប៉ុនកង់រថ ប្រដាប់ត្រង់ព្រះចេតិយមាសនោះ ។ ផ្កាបទុមមាសដែលព្យួរសំយុងមានទំហំ ១២ ហត្ថ ។ បុត្រសេដ្ឋីនោះតាំងនៅអស់អាយុក្នុងមនុស្សលោកនោះហើយ ក៏កើតក្នុងសួគ៌ ចុតិចាកសួគ៌នោះ កើតក្នុងត្រកូលអាមាត្រមួយ ក្នុងទីប្រមាណមួយយោជន៍ ពី

ក្រុងពារាណសី ចំណែកកូនក្រមុំសេដ្ឋីចុតិចាកពីទេវលោក កើតជាព្រះរាជធីតាអង្គធំ ក្នុងរាជត្រកូល ។

កាលអ្នកទាំងពីរនោះចម្រើនវ័យ គេប្រកាសដំណើងនក្ខត្តឫក្សក្នុងស្រុកដែលកុមាររស់នៅ ។ កុមារនោះពោលនឹងមាតាថា ម៉ែ ម៉ែចូរឲ្យសំពត់សាដកខ្ញុំ ខ្ញុំនឹងលេងនក្ខត្តឫក្ស មាតាបាននាំសំពត់ដែលប្រើហើយមកឲ្យ ។ គេបដិសេធថា សំពត់នេះគ្រោតគ្រាតណាស់ម៉ែ ។ នាងក៏នាំផ្ទាំងដទៃមកឲ្យ សូម្បីសំពត់ផ្ទាំងនោះ គេក៏បដិសេធ ។ ពេលនោះ មាតាទើបពោលនឹងគេថា បា យើងកើតក្នុងផ្ទះដូច្នេះ ពួកយើងមិនមានបុណ្យ នឹងបានសំពត់សាច់ល្អិតជាងនេះពីណា ។ គេពោលថា ម៉ែ បើដូច្នោះ ខ្ញុំនឹងទៅកាន់កន្លែងដែលនឹងបាន ។ មាតាពោលថា កូនអើយ ម៉ែប្រាថ្នាឲ្យឯងបានរាជសម្បត្តិក្នុងក្រុងពារាណសីថ្ងៃនេះផង ។ គេសំពះមាតាហើយពោលថា ខ្ញុំទៅហើយម៉ែ ។ មាតាថា ទៅចុះបា ។ ន័យថា មាតារបស់គេមានសេចក្តីគិតយ៉ាងនេះថា គេនឹងទៅណា គង់នឹងមកអង្គុយទីនេះទីនោះក្នុងផ្ទះនេះឯង ។ ក៏កុមារនោះ ចេញទៅតាមកំណត់របស់បុណ្យ ទៅដល់ក្រុងពារាណសី ដេកដណ្តប់សិរសៈនៅលើផែនមង្គលសិលាសនៈ ក្នុងព្រះរាជឧទ្យាន ។ ក៏ព្រះបាទពារាណសីនោះ សុគតហើយជាគម្រប់ថ្ងៃទី ៧ ។ អាមាត្រទាំងឡាយធ្វើការថ្វាយព្រះភ្លើង ហើយអង្គុយប្រឹក្សានៅត្រង់

ព្រះរាជវាំងថា ព្រះរាជាមានតែព្រះធីតា មិនមានព្រះរាជឱរស រាជសម្បត្តិមិនមានព្រះរាជា មិនសមគួរ នរណានឹងជាព្រះរាជា អ្នកដទៃៗ និយាយថា លោកឬលោកឬ ។ បុរោហិតពោលថា មិនគួរជ្រើសរើសច្រើន ណ្ហើយចុះ ពួកយើងនឹងបួងសួងទេវតាហើយផ្សងបុស្សរថ (ផ្សងរថព្រលែងទៅដើម្បីរកអ្នកដែលសមគួរនឹងគ្រងរាជ្យ កាលព្រះរាជាអង្គមុនសុគតហើយ មិនមានរជ្ជទាយាទ) ទៅ ។ អាមាត្យទាំងនោះទឹមសេះសិន្ធព ៤ ក្បាល មានពណ៌ដូចផ្កាកោមុទ ហើយតាំងគ្រឿងរាជកកុធភណ្ឌ ៥ យ៉ាង នឹងស្វេតច្ឆត្រទុកលើរថនុ៎ះឯង ព្រលែងរថនោះទៅ ឲ្យប្រគំតន្ត្រីទៅខាងក្រោយ ។ រថចេញតាមទ្វារទិសបស្ចឹម បែរមុខទៅផ្លូវព្រះរាជឧទ្យាន ។ អាមាត្យពួកខ្លះពោលថា រថបែរមុខទៅផ្លូវព្រះរាជឧទ្យានព្រោះការជ្ជាប់ ពួកលោកចូរឲ្យត្រឡប់មក បុរោហិតពោលថា កុំឲ្យត្រឡប់ ។ រថធ្វើប្រទក្សិណកុមារហើយ បានឈប់ត្រៀមព្រមនឹងឲ្យឡើង បុរោហិតលើកជាយសំពត់ដណ្តប់ ត្រួតមើលផ្ទៃជើង ពោលថា ទ្វីបនេះចូរលើកទុក បុគ្គលនេះ សមគួរគ្រងរាជ្យក្នុងទ្វីបទាំង ៤ មានទ្វីបពីរពាន់ជាបរិវារ ហើយបង្គាប់ឲ្យប្រគំតន្ត្រីឡើង ៣ ដង ថាពួកលោកចូរប្រគំតន្ត្រីឡើងទៀត ។

គ្រានោះ កុមារបើកភ្នែកសម្លឹងមើល ហើយនិយាយថា បាទាំងឡាយពួកលោកមកដោយកិច្ចកម្មអ្វី ។ ពួកអាមាត្យទូលថា បពិត្រសម្មតិទេព រាជ-

សម្បត្តិចូរមានដល់ព្រះអង្គ ។ (កុមារ) ព្រះរាជាទៅណា ។ (អាមាត្រ) ទិវង្គត ហើយ ។ (កុមារ) កន្លងទៅប៉ុន្មានថ្ងៃហើយ ។ (អាមាត្រ) ថ្ងៃនេះជាថ្ងៃទី ៧ ។ (កុមារ) ព្រះរាជឱរស ឬព្រះរាជធីតាមិនមានឬ ? (អាមាត្រ) បពិត្រសម្មតិទេព ព្រះរាជធីតាមាន ព្រះរាជឱរសមិនមាន ។ (កុមារ) យើងនឹងគ្រងរាជ្យ ។ អាមាត្រទាំងនោះសាងមណ្ឌបសម្រាប់អភិសេកក្នុងខណៈនោះឯងក្លាម ប្រដាប់ព្រះរាជធីតាដោយគ្រឿងអលង្ការគ្រប់យ៉ាង នាំមកកាន់ព្រះរាជឧទ្យាន ធ្វើការអភិសេកជាមួយកុមារ ។

គ្រានោះកាលព្រះកុមារធ្វើការអភិសេកហើយ ប្រជាជននាំសំពត់មានតម្លៃមួយសែនមកថ្វាយ ។ ព្រះកុមារពោលថា នេះអ្វីបា ។ ពួកអាមាត្រទូលថា បពិត្រសម្មតិទេព សំពត់ស្លៀកព្រះអង្គ ។ (ព្រះកុមារ) សាច់គ្រោតគ្រាតមិនមែនឬ បា ។ សំពត់ដទៃដែលសាច់ល្អិតជាងនេះ មិនមានឬ? ។ (អាមាត្រ) បពិត្រសម្មតិទេព ក្នុងបណ្តាសំពត់ដែលមនុស្សទាំងឡាយប្រើប្រាស់ សំពត់សាច់ល្អិតជាងនេះមិនមានទេ ព្រះអង្គ ។ (ព្រះកុមារ) ព្រះរាជារបស់ពួកលោកទ្រង់ស្លៀកសំពត់បែបនេះឬ ? (អាមាត្រ) ករុណាម្ចាស់ បពិត្រសម្មតិទេព ។ (ព្រះកុមារ) ព្រះរាជារបស់ពួកលោកគង់នឹងមិនមានបុណ្យ ពួកលោកចូរនាំយកឃ្លោកមាសមក យើងនឹងបានសំពត់ ។ អាមាត្រទាំងនោះនាំឃ្លោកមាសមក

ថ្វាយ ។ ព្រះកុមារនោះក្រោកឡើង លាងព្រះហស្ត ខ្ពុរព្រះឱស្ឋ យកព្រះហស្តកូរទឹកចាក់ទៅទិសខាងកើត ។ ក្នុងខណៈនោះឯង ដើមកល្បព្រឹក្សក៏ជ្រែកផែនដីដ៏ក្រាស់ផុសឡើងមក ៨ ដើម ទ្រង់កូរទឹកចាក់ទៅកាន់ទិស ៣ ទៀត យ៉ាងនេះ គឺ ទិសខាងត្បូង ទិសខាងលិច ទិសខាងជើង ។ ដើមកល្បព្រឹក្សផុសឡើងក្នុងទិសទាំង ៤ ទិសមួយៗ ៨ ដើម រួមជា ៣២ ដើម ។ ព្រះកុមារនោះទ្រង់ស្លៀកសំពត់ទិព្វមួយផ្ទាំង ទ្រង់ដណ្តប់មួយផ្ទាំង ហើយត្រាស់បង្គាប់ថា ពួកលោកចូរត្រាច់វាយស្គរប្រកាស យ៉ាងនេះថា ក្នុងព្រំដែនរបស់ព្រះបាទទន្ទរាជពួកស្ត្រីដែលមាននាទីរវៃអំបោះ កុំចាំបាច់រវៃអំបោះ ដូច្នេះ ហើយឲ្យលើកឆត្រឡើង ទ្រង់ប្រដាប់តាក់តែងព្រះអង្គ ទ្រង់ឡើងដំរីដ៏ប្រសើរចូលព្រះនគរ ឡើងកាន់ប្រាសាទសោយមហាសម្បត្តិ ។

លុះកាលវេលាកន្លងទៅដោយអាការយ៉ាងនេះ ថ្ងៃមួយ ព្រះទេវីឃើញមហាសម្បត្តិរបស់ព្រះរាជាហើយ ទ្រង់សម្តែងអាការនៃសេចក្តីករុណាថា ឱលោកអ្នកមានតបៈ ត្រូវព្រះរាជាត្រាស់សួរថា មានរឿងអ្វី ទេវី ទើបទូលថា បពិត្រសម្មតិទេព សម្បត្តិរបស់ព្រះអង្គធំក្រៃលែង ក្នុងអតីតកាល ព្រះអង្គទ្រង់បានជឿចំពោះព្រះពុទ្ធទាំងឡាយ បានធ្វើកម្មល្អទុក ឥឡូវនេះ ទ្រង់មិនធ្វើកុសលដែលជាបច្ច័យដល់អនាគត ព្រះរាជាត្រាស់ថា យើងនឹងឲ្យដល់អ្នកណា

អ្នកមានសីលមិនមាន ។ ព្រះទេវីទូលថា បពិត្រសម្មតិទេព ជម្ពូទ្វីបមិនសូន្យចាកព្រះអរហន្តទាំងឡាយទេ ព្រះអង្គទ្រង់មេត្តាត្រៀមតែទានទុកប៉ុណ្ណោះ នាងខ្ញុំនឹងសូមព្រះអរហន្តក្នុងថ្ងៃស្អែក ព្រះរាជាត្រាស់បង្គាប់ឲ្យត្រៀមទានទុកត្រង់ទ្វារទិសបស្ចឹម ។ ព្រះទេវីទ្រង់អធិដ្ឋានអង្គឧបោសថពីព្រឹកព្រលឹម បែរមុខទៅទិសខាងកើត ក្រាបចុះលើប្រាសាទជាន់លើ ហើយពោលថា បើព្រះអរហន្តមាននៅក្នុងទិសនេះ ស្អែកនេះ សូមនិមន្តមកទទួលភិក្ខាហាររបស់ខ្ញុំទាំងឡាយចុះ ។ ក្នុងទិសនោះ មិនមានព្រះអរហន្ត ក៏បានឲ្យសក្ការៈដែលត្រៀមទុកនោះដល់មនុស្សកំព្រា និងយាចក ។ ក្នុងថ្ងៃស្អែក ត្រៀមទានទុកទ្វារទិសត្បូង ហើយបានធ្វើដូចយ៉ាងនោះ ក្នុងថ្ងៃស្អែកទ្វារទិសខាងលិច ក៏បានធ្វើដូចយ៉ាងនោះ ។ ក៏ក្នុងថ្ងៃដែលទ្រង់ត្រៀមទុកទ្វារទិសខាងជើង ព្រះមហាបទុមបច្ចេកពុទ្ធ ដែលជាបងប្រុសរបស់ព្រះបច្ចេកពុទ្ធ ៥០០ អង្គ ជាឱរសរបស់ព្រះនាងបទុមវតី នៅក្នុងព្រៃហិមវន្ត ហៅព្រះបច្ចេកពុទ្ធដែលជាប្អូនប្រុស ដែលត្រូវព្រះទេវីនិមន្តយ៉ាងនោះ មកថា លោកអ្នកនិរទុក្ខទាំងឡាយ ព្រះបាទនន្ទរាជនិមន្តលោកទាំងឡាយ ចូរទទួលនិមន្តរបស់ព្រះរាជាចុះ ។ ព្រះបច្ចេកពុទ្ធទាំងនោះទទួលនិមន្តហើយ ក្នុងថ្ងៃស្អែកលុបលាងមុខនាស្រះអនោតត្តៈហើយ ហោះទៅចុះត្រង់ទ្វារទិសខាងជើង ពួកមនុស្សមកក្រាបទូលដល់ព្រះរាជាថា បពិត្រសម្មតិទេព ព្រះ

បច្ចេកពុទ្ធ ៥០០ អង្គ មកហើយព្រះអង្គ ។ ព្រះរាជាស្តេច ទៅព្រមនឹងព្រះទេវី ថ្វាយបង្គំហើយ ទទួលបាត្រ និមន្តព្រះបច្ចេកពុទ្ធទាំងឡាយឡើងកាន់ប្រាសាទ ថ្វាយទានដល់ព្រះបច្ចេកពុទ្ធទាំងនោះ លើប្រាសាទនោះ ក្នុងវេលាស្រេចភត្តកិច្ច ព្រះរាជាក្រាបត្រង់ទីជិតព្រះបាទព្រះសង្ឃត្ថេរៈ ព្រះទេវីក្រាបត្រង់ទីជិតព្រះបាទព្រះសង្ឃនវកៈ ហើយពោលថា បពិត្រលោកម្ចាស់ទាំងឡាយ លោកម្ចាស់ទាំងឡាយនឹងមិនលំបាកដោយរឿងបច្ច័យ និងខ្ញុំម្ចាស់ទាំងឡាយ ក៏នឹងមិនធ្វើបុណ្យឲ្យសាបសូន្យ សូមលោកម្ចាស់ទាំងឡាយ ចូរឲ្យបដិញ្ញាដើម្បីនៅក្នុងទីនេះ រហូតដល់អស់អាយុរបស់ខ្ញុំម្ចាស់ទាំងឡាយចុះ លុះឲ្យលោកទទួលបដិញ្ញាហើយ ទើបឲ្យតាក់តែងស្ថានទី សម្រាប់នៅអាស្រ័យដល់ព្រះបច្ចេកពុទ្ធទាំងនោះ ក្នុងព្រះឧទ្យាន ដោយអាការទាំងពួង គឺ បណ្ណសាលា ៥០០ ខ្នង ទីចង្ក្រម ៥០០ ហើយឲ្យលោកនៅក្នុងទីនោះឯង ។ កាលវេលាកន្លងទៅដោយប្រការយ៉ាងនោះ តំបន់ជាយដែនរបស់ព្រះរាជាមានការកម្រើកឡើង ។ ព្រះអង្គទ្រង់ឱវាទព្រះទេវីថា បងនឹងទៅរម្ងាប់តំបន់ជាយដែន នាងកុំលះបង់ព្រះបច្ចេកពុទ្ធទាំងឡាយឡើយ ហើយស្តេចចេញចាកពីព្រះនគរ កាលស្តេចមិនទាន់ត្រឡប់ ព្រះបច្ចេកពុទ្ធទាំងឡាយក៏អស់អាយុសង្ខារ ។

ព្រះមហាបទុមបច្ចេកពុទ្ធ ចូលឈានរហូតដល់អស់រាត្រីទាំង ៣ យាម

ក្នុងវេលាអរុណរះ បានឈរផ្អែកបន្ទះក្តារសម្រាប់កាន់បរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ សូម្បីព្រះបច្ចេកពុទ្ធដ៏សេសទាំងអស់ ក៏បរិនិព្វានហើយដោយវិធីនោះ ។ ក្នុងថ្ងៃស្អែក ព្រះទេវីឲ្យធ្វើទីអង្គុយរបស់ព្រះបច្ចេកពុទ្ធទាំងឡាយ ឲ្យលាបដោយរបស់ខៀវស្រទន់ រោយផ្កាឈើ អុជគ្រឿងក្រអូប អង្គុយរង់ចាំព្រះបច្ចេកពុទ្ធទាំងឡាយមក កាលមិនឃើញមក ទើបបញ្ជូនរាជបុរសទៅថា បា! ចូរទៅ ចូរដឹងថា លោកម្ចាស់ទាំងឡាយមិនមានសេចក្តីជាសុខយ៉ាងណា? រាជបុរសនោះទៅហើយ ក៏បើកទ្វារបណ្ណសាលារបស់ព្រះមហាបទុមបច្ចេកពុទ្ធ កាលមិនជួបក្នុងបណ្ណសាលានោះ ទើបទៅកាន់ទីចង្ក្រម ឃើញលោកឈរផ្អែកបន្ទះក្តារសម្រាប់កាន់ ទើបថ្វាយបង្គំ ហើយពោលថា បានវេលាហើយលោកម្ចាស់ ។ សរីរៈរបស់លោកដែលបរិនិព្វានហើយ នឹងនិយាយបានយ៉ាងណា ។ រាជបុរសនោះគិតថា លោកម្ចាស់សឹងលក់ ទើបដើរទៅយកដៃស្ទាបត្រង់ខ្នងជើង ដឹងថា បរិនិព្វានហើយ ព្រោះជើងទាំងពីរត្រជាក់ និងរឹងទើបទៅកាន់សំណាក់របស់ព្រះបច្ចេកពុទ្ធអង្គទី ២ កាលដឹងថា អង្គទី ២ បរិនិព្វានហើយយ៉ាងនោះ ក៏ទៅកាន់សំណាក់របស់ព្រះបច្ចេកពុទ្ធអង្គទី ៣ ដឹងថាព្រះបច្ចេកពុទ្ធគ្រប់អង្គបរិនិព្វានហើយ ដោយប្រការដូច្នេះ ទើបទៅកាន់រាជត្រកូល ព្រះទេវីត្រាស់សួរថា ព្រះបច្ចេកពុទ្ធទាំងឡាយទៅណា បា! ទើបក្រាប

ទូលថា បពិត្រព្រះទេវី ព្រះបច្ចេកពុទ្ធទាំងឡាយបរិនិព្វានហើយ ។ ព្រះទេវីទ្រង់ព្រះកន្សែងត្អូញត្អែរ ស្តេចចេញទៅកាន់បណ្ណសាលានោះព្រមទាំងអ្នកក្រុង ត្រាស់បង្គាប់ឲ្យលេងសាធុកីឡា (ការលេងដែលជាប់ទាក់ទងនឹងរឿងអនិច្ចំ ទុក្ខំ អនត្តា) ធ្វើឈាបនកិច្ចសរីរៈរបស់ព្រះបច្ចេកពុទ្ធទាំងឡាយ ហើយរក្សាធាតុសាងព្រះចេតិយទុក ។ ព្រះរាជាទ្រង់បង្ក្រាបស្រុកជាយដែនឲ្យស្ងប់ហើយ ស្តេចត្រឡប់មក ត្រាស់សួរព្រះទេវីដែលស្តេចមកទទួលថា នាងដ៏ចម្រើន នាងមិនប្រមាទ (គឺមិនលះបង់) ក្នុងព្រះបច្ចេកពុទ្ធទាំងឡាយទេឬ? លោកម្ចាស់ទាំងឡាយសុខសប្បាយទេឬ? ព្រះទេវីទូលថា បពិត្រព្រះសម្មតិទេព លោកម្ចាស់ទាំងឡាយបរិនិព្វានអស់ហើយ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា មរណៈនៅកើតដល់បណ្ឌិតទាំងឡាយបែបនេះ ពួកយើងនឹងរួចផុតទៅអំពីណា ព្រះអង្គស្តេចមិនទៅព្រះនគរ ស្តេចចូលទៅកាន់ព្រះរាជឧទ្យានតែម្តង ត្រាស់បង្គាប់ឲ្យហៅព្រះឱរសអង្គធំមក ហើយប្រគល់រាជសម្បត្តិដល់ព្រះឱរសនោះ ហើយឱវាទ ។ ចំណែកព្រះអង្គទ្រង់ព្រះផ្នួសជាសមណៈមួយប្រភេទ ។ ឯព្រះទេវី កាលព្រះរាជាទ្រង់ព្រះផ្នួសហើយ ទ្រង់ត្រិះរិះថា យើងនៅធ្វើអ្វី ទើបទ្រង់ព្រះផ្នួសនៅក្នុងព្រះរាជឧទ្យាននោះឯង ។ ព្រះរាជា និងព្រះទេវីទាំងពីរអង្គនោះ បំពេញឈាន បានចុតិចាកពីអត្តភាពនោះ ទៅកើតក្នុងព្រហ្មលោក ។

កាលអ្នកទាំងពីរនោះ នៅក្នុងព្រហ្មលោកនោះឯង ព្រះសាស្តារបស់យើងទាំងឡាយឧប្បត្តិឡើងក្នុងលោក ប្រកាសព្រះធម្មចក្កដ៏ប្រសើរ ស្តេចចូលទៅកាន់ក្រុងរាជគ្រឹះដោយលំដាប់ ។ កាលព្រះសាស្តាប្រថាប់ នៅក្នុងក្រុងរាជគ្រឹះនោះ ។ បិប្ផលិមាណពនេះ កើតក្នុងផ្ទៃភរិយារបស់កបិលព្រាហ្មណ៍ ក្នុងព្រាហ្មណគាម ឈ្មោះមហាតិត្ថៈ ក្នុងមគធរដ្ឋ ។ នាងភទ្ទា កាបិលានី កើតក្នុងផ្ទៃរបស់ភរិយាព្រាហ្មណ៍កោលិយគោត្រ ក្នុងសាគលនគរ ក្នុងមទ្ទរដ្ឋ ។ កាលជនទាំងពីរនោះធំឡើងដោយលំដាប់ នាងភទ្ទា មានអាយុដល់ឆ្នាំទី ១៦ ក្នុងឆ្នាំទី ២០ របស់បិប្ផលិមាណព បិតាមាតាសម្លឹងមើលបុត្រហើយ បានជំនះថា បា! កូន ក៏ធំហើយ ធម្មតាថា វង្សត្រកូលចាំបាច់ត្រូវតែតាំងវង្ស ។ មាណពពោលថា លោកទាំងពីរកុំពោលពាក្យបែបនេះ មិនចូលត្រចៀកកូនឡើយ កូននឹងបដិបត្តិដរាបដែលលោកទាំងពីរនៅមានជីវិត ពេលលោកទាំងពីរធ្វើមរណកាលទៅ កូននឹងបួស ។ បិតាមាតាឲ្យវេលាកន្លងទៅ ២-៣ ថ្ងៃ ក៏ពោលទៀតសូម្បីមាណពនោះ ក៏បដិសេធដូចពីដើមនុ៎ះឯង តាំងពីនោះ មាតាបានពោល (ដល់ការគ្រប់គ្រងផ្ទះ) រឿយៗ ។

មាណពគិតថា យើងនឹងញ៉ាំងមាតាឲ្យបានព្រួ ទើបយកមាសសុទ្ធ ឲ្យជាងមាសធ្វើរូបស្ត្រីម្នាក់ ក្នុងវេលាស្រេចការងារ មានការដុសខាត់ និងសំអាតជា

ដើមនូវរូបស្ត្រីនោះ ទើបឲ្យរូបស្ត្រីនោះស្លៀកសំពត់ក្រហម ប្រដាប់ដោយផ្កាឈើដែលសម្បូរណ៍ដោយពណ៌ និងគ្រឿងប្រដាប់ផ្សេងៗ ហើយឲ្យហៅមាតាមក និយាយថា អ្នកម៉ែ កាលកូនបានអារម្មណ៍បែបនេះ ទើបនឹងនៅគ្រប់គ្រងផ្ទះ បើមិនបាននឹងមិនទទួល ។ នាងព្រាហ្មណីជាអ្នកមានបញ្ញា ទើបគិតថា បុត្ររបស់យើងជាអ្នកមានបុណ្យ ឲ្យទានទុកហើយ សាងអភិនិហារទុកហើយ កាលនឹងធ្វើបុណ្យគង់នឹងមិនធ្វើតែម្នាក់ឯង ស្ត្រីអ្នកធ្វើបុណ្យរួមនឹងបុត្ររបស់យើងនេះ នឹងមានចំណែកប្រៀបផ្ទឹមដោយមាសដោយពិត ទើបហៅព្រាហ្មណ៍ ៨ នាក់មក ទំនុកបម្រុងឲ្យឆ្អែតស្កប់ស្កល់ដោយវត្ថុដែលត្រូវការគ្រប់យ៉ាង ឲ្យលើករូបមាសឡើងតាំងលើរថ ហើយបង្គាប់ថា បាទាំងឡាយ ចូរនាំគ្នាទៅ កាលឃើញទារិកាបែបនេះ (ដូចរូបមាស) ក្នុងត្រកូលដែលស្មើគ្នានឹងយើង ដោយជាតិ គោត្រ និងភោគទ្រព្យក្នុងទីណា ចូរឲ្យរូបមាសនេះឯងជាបណ្ណាការ ក្នុងទីនោះ ។

ព្រាហ្មណ៍ទាំងនោះនាំគ្នាចេញទៅដោយដឹងច្បាស់ថា នេះជាកិច្ចកម្មរបស់ពួកយើង ទើបគិតថា នឹងទៅទីណា ព្រមព្រៀងគ្នាថា ធម្មតាមទ្ទរដ្ឋ ជាអណ្តូងកើតនៃស្ត្រី ពួកយើងនឹងទៅមទ្ទរដ្ឋ ដូច្នេះហើយ ទើបបានទៅសាគលនគរ ក្នុងមទ្ទរដ្ឋ ។ គ្រានោះ ស្ត្រីបម្រើរបស់នាងភទ្ទា ឲ្យនាងភទ្ទាងូតទឹកហើយ តែងខ្លួន

ឲ្យអង្គុយក្នុងបន្ទប់ដែលរៀបចំហើយ (ខ្លួនឯង) ទើបទៅងូតទឹក ឃើញរូបនោះ ទើបកំញើញព្រោះយល់ថា ធីតានៃម៉ែម្ចាស់របស់យើងមកទីនេះ ពោលថា នាងម្ចាស់ មកទីនេះធ្វើអ្វី ហើយងាបាតដៃវាយថ្ពាល់ (ព្រមទាំង) និយាយថា ចូរប្រញាប់ទៅ ។ ដៃក៏ខ្ទាតចេញដូចវាយថ្ម ។ ស្រ្តីបម្រើនោះដឹងថា ជារបស់រឹងដោយអាការយ៉ាងនេះ ទើបចៀសចេញទៅ និយាយថា យើងឃើញរូបមាស ក៏កើតសេចក្តីយល់ថា ធីតានៃម៉ែម្ចាស់របស់យើង ក៏នាងនេះ សូម្បីនឹងជាអ្នកបានសំពត់ស្លៀកដណ្តប់របស់ធីតានៃម៉ែម្ចាស់របស់យើង ក៏នៅមិនទាន់សម ។ ពេលនោះ ពួកមនុស្សទាំងនោះនាំគ្នាចោមរោមនាង ហើយសួរថា ធីតារបស់ចៅហ្វាយនាង បែបនេះឬ? ស្ត្រីមេដោះនិយាយថា នាងនេះឬ ធីតានៃម៉ែម្ចាស់របស់យើងល្អក្រៃលែងជាងនាងនេះរយដង ពាន់ដង កាលនាងអង្គុយនៅក្នុងបន្ទប់ប្រមាណ ១២ ហត្ថ កិច្ចដោយពន្លឺប្រទីបមិនមាន នាងកម្ចាត់សេចក្តីងងឹតដោយពន្លឺចេញពីសរីរៈនោះឯង ។ ពួកមនុស្សទាំងនោះពោលថា បើយ៉ាងនោះ ចូរមក ហើយកាន់គ្រឿងបូជា លើករូបមាសដាក់លើរថ បញ្ឈប់នៅត្រង់ទ្វារផ្ទះរបស់ព្រាហ្មណ៍កោសិយគោត្រ ប្រាប់ឲ្យជ្រាបដល់ការមក ។

ព្រាហ្មណ៍ធ្វើបដិសណ្ឋារហើយសួរថា ពួកលោកមកពីណា? ជនទាំងនោះឆ្លើយថា មកពីផ្ទះរបស់កបិលព្រាហ្មណ៍ ក្នុងមហាតិត្ថគាម ក្នុងមគធរដ្ឋ ។

ព្រាហ្មណ៍សួរ មកព្រោះហេតុណា? ជនទាំងនោះឆ្លើយ ព្រោះហេតុឈ្មោះនេះ ព្រាហ្មណ៍ពោលថា ល្អហើយបាទាំងឡាយ ព្រាហ្មណ៍របស់ពួកយើង មានជាតិ គោត្រ និងទ្រព្យសម្បត្តិស្មើគ្នា យើងនឹងឲ្យទារិកា (កូនក្រមុំ) ដូច្នេះ ហើយក៏ ទទួលគ្រឿងបណ្ណាការ ។ ជនទាំងនោះ បញ្ជូនដំណឹងដល់កបិលព្រាហ្មណ៍ថា បានទារិកាហើយ លោកចូរធ្វើវត្ថុដែលនឹងត្រូវធ្វើ ។ កបិលព្រាហ្មណ៍បានស្តាប់ ដំណឹងនោះហើយ ទើបប្រាប់ដល់បិប្ផលិមាណពថា គេថា បានទារិកាហើយ ។ មាណពគិតថា យើងគិតថា នឹងមិនបាន អ្នកទាំងនេះនិយាយថា បានហើយ យើងមិនមានសេចក្តីត្រូវការ នឹងបញ្ជូនសំបុត្រទៅ (ឲ្យដឹង) ហើយទៅក្នុងទី កំបាំង សរសេរសំបុត្រថា ម្នាលនាងភទ្ទា ចូរបានគូគ្រប់គ្រងផ្ទះដែលសមគួរ ដល់ជាតិ គោត្រ និងទ្រព្យសម្បត្តិរបស់ខ្លួន យើងនឹងចេញបួស ទើបមិនក្តៅ ក្រហាយក្នុងខាងក្រោយ ។ សូម្បីនាងភទ្ទាបានស្តាប់ថា គេប្រាថ្នានឹងឲ្យយើង ដល់អ្នកឯណោះ ទើបទៅក្នុងទីកំបាំងសរសេរសំបុត្រថា សូមអយ្យបុត្ត ចូរ បានគូគ្រប់គ្រងផ្ទះដែលសមគួរដល់ជាតិ គោត្រ និងទ្រព្យសម្បត្តិរបស់ខ្លួនចុះ ខ្ញុំនឹងចេញបួស ទើបមិនក្តៅក្រហាយក្នុងខាងក្រោយ ។ សំបុត្រទាំងពីរច្បាប់ មកជួបប្រសព្វគ្នាក្នុងចន្លោះផ្លូវ ។ ជនទាំងនោះ កាលត្រូវនាងភទ្ទាសួរថា នេះ សំបុត្ររបស់នរណា ក៏ពោលថា បិប្ផលិមាណពបញ្ជូនឲ្យនាងភទ្ទា និងកាលត្រូវ

បិប្ផលិមាណពសួរថា នេះរបស់នរណា ក៏ពោលថា នាងកញ្ញាបញ្ជូនឲ្យបិប្ផលិ-មាណព ទើបនាំគ្នាអានសំបុត្រសូម្បីទាំងពីរច្បាប់ ហើយពោលថា លោកទាំងឡាយចូរមើលការធ្វើរបស់ក្មេងៗ ហើយហែកចោលនៅក្នុងព្រៃទៅ សរសេរសំបុត្រដែលមានសេចក្តីស្មើគ្នា បញ្ជូនទៅឲ្យអ្នកទាំងពីរនោះ ទាំងចំណែកនេះនិងចំណែកឯណោះ ដូច្នោះ អ្នកទាំងពីរនោះមិនប្រាថ្នាឡើយ ក៏បានមក (នៅ) រួមគ្នា ។

ក្នុងថ្ងៃនោះឯង សូម្បីមាណពក៏យកកម្រងផ្កាឈើមួយក្នុងដាក់ទុក សូម្បីនាងកញ្ញាកាបិលានី ក៏យកកម្រងផ្កាឈើមួយក្នុងដាក់ទុក ។ អ្នកទាំងពីរបរិភោគអាហារល្ងាចហើយ ដាក់កម្រងផ្កាឈើទាំងនោះទុកកណ្តាលទីដេក មកព្រមគ្នាដោយតាំងចិត្តថានឹងឡើងទីដេក មាណពឡើងទីដេកខាងស្តាំ នាងកញ្ញាឡើងទីដេកខាងឆ្វេង ហើយពោលថា ផ្កាឈើក្នុងផ្នែករបស់នរណាស្វិតស្រពោន ពួកយើងនឹងដឹងបានថា រាគៈចិត្តកើតឡើងហើយដល់អ្នកនោះ ព្រោះហេតុនោះកម្រងផ្កាឈើនេះយើងទើបមិនប៉ះពាល់ ។ ក៏អ្នកទាំងពីរនោះ ដេកមិនលក់រហូតអស់រាត្រីនៃយាមទាំង ៣ ព្រោះខ្លាចប៉ះខ្លួនគ្នានិងគ្នា ដរាបរាត្រីកន្លងទៅមួយទៀត ក្នុងវេលាថ្ងៃ ក៏មិនមានសូម្បីត្រឹមតែការញញឹមរកគ្នា ។ អ្នកទាំងពីរនោះ មិនជាប់ជំពាក់ដោយរឿងលោកាមិស មិនបានចាត់ចែងទ្រព្យសម្បត្តិដរាប

ដែលបិតាមាតានៅមានជីវិត កាលបិតាមាតាធ្វើកាលកិរិយាទៅហើយ ទើបចាត់ចែង ។ បិប្ផលិមាណពមានសម្បត្តិ (គិតជាប្រាក់) ៨៧ កោដិ ឯលម្អិតមាសដែលប្រើដុសលាបខ្លួនហើយចោលទៅ មួយថ្ងៃៗ គួរបានប្រមាណ ១២ នាឡិដោយនាឡិមគធៈ ។ មានអណ្តូងទឹកប្រមាណ ៦០ កន្លែង ប្រើដោយគ្រឿងយន្តមានរោងនង្គ័ល ដែលកសាងក្នុងផ្ទៃដីប្រមាណ ១២ យោជន៍ មានភូមិរបស់កម្មករ (១៤ ស្រុក) ទំហំប្រមាណប៉ុនក្រុងអនុរាធបុរី មានកងដំរី ១៤ កង មានកងសេះ ១៤ កង មានកងរថ ១៤ កង ។

ថ្ងៃមួយ បិប្ផលិមាណពនោះ ឡើងសេះដែលប្រដាប់តាក់តែងហើយ ហែ-ហមដោយមហាជនទៅកាន់ទីធ្វើការងារ ឈរខាងចុងស្រែ ឃើញពួកបក្សី មានក្អែកជាដើម កកាយសត្វ មានជន្លេនជាដើម ពីគន្លងនង្គ័លយកមកស៊ី ទើបសួរថា បាទាំងឡាយ សត្វទាំងនេះស៊ីអ្វី? មហាជនឆ្លើយថា លោកម្ចាស់ វាស៊ីជន្លេន ។ មាណពសួរថា បាបដែលសត្វទាំងនេះធ្វើជារបស់អ្នកណា? មហា-ជនឆ្លើយថា លោកម្ចាស់ បាបជារបស់លោក ។ មាណពគិតថា បើបាបដែលសត្វទាំងនេះធ្វើ ក៏ជារបស់យើងដែរ ទ្រព្យ ៨៧ កោដិ នឹងប្រយោជន៍អ្វីដល់យើង កិច្ចការងារ ១២ យោជន៍ អណ្តូងទឹកដែលប្រកបដោយគ្រឿងយន្ត ៦០ កន្លែង ពួកស្រុករបស់កម្មករ (១៤ កន្លែង) នឹងមានប្រយោជន៍អ្វីដល់យើង

យើងនឹងប្រគល់ទ្រព្យសម្បត្តិទាំងអស់នេះដល់កុម្ភកាបិលានី ហើយចេញបួស ។

ខណៈនោះ នាងកុម្ភកាបិលានី ឲ្យព្រោះគ្រាប់ល្ង ៣ ឆ្នាំង ចុះក្នុងចន្លោះចំការ ពួកស្ត្រីបម្រើហែហមអង្គុយ នាងបានឃើញពួកក្អែកស៊ីសត្វក្នុងគ្រាប់ល្ង ទើបសួរថា នាងទាំងឡាយ សត្វទាំងនេះស៊ីអ្វី? ពួកស្ត្រីបម្រើឆ្លើយថា ម៉ែម្ចាស់ ពួកវាស៊ីសត្វ ។ នាងសួរថា អកុសលនឹងជារបស់អ្នកណា? ពួកស្ត្រីបម្រើឆ្លើយថា ជារបស់ម៉ែម្ចាស់ ចាំ! ។ នាងគិតថា យើងបានសំពត់ ៤ ហត្ថ និងបាយប្រមាណមួយនាឡិក៏គួរ ក៏បើអកុសលនេះ ដែលជនមានប្រមាណប៉ុណ្ណេះធ្វើ នឹងជារបស់យើងសោត យើងមិនអាចងើបក្បាលឡើងពីវដ្តៈតាំង ១.០០០ កព កាលអ្នកស្វាមីមកដល់ យើងនឹងប្រគល់ទ្រព្យសម្បត្តិទាំងអស់ដល់អ្នកស្វាមីនោះ ហើយចេញបួស ។

មាណពមកហើយ ងូតទឹកឡើងកាន់ប្រាសាទ អង្គុយលើគ្រែដែលមានតម្លៃច្រើន ។ គ្រានោះ ពួកអ្នកចំអិនអាហារ ចាត់ចែងភោជនដែលសមគួរដល់ស្តេចចក្រពត្តិ ។ ជនសូម្បីទាំងពីរបរិភោគហើយ កាលបរិវារជនចេញទៅ ក៏ទៅក្នុងទីរហោឋាន អង្គុយក្នុងទីដែលមានសេចក្តីជាសុខ ។ លំដាប់នោះ មាណពពោលនឹងនាងកុម្ភថា នាងកុម្ភ នាងកាលនឹងមកផ្ទះនេះ នាំយកទ្រព្យមកប៉ុន្មាន ។ នាងកុម្ភពោលថា អ្នកជាម្ចាស់ នាំមក ៥ ម៉ឺន ៥ ពាន់រទេះ ។ មាណពពោល

ថា ទ្រព្យទាំងអស់នោះ នឹងទ្រព្យ ៨៧ កោដិ ក្នុងផ្ទះនេះ និងសម្បត្តិដ៏សេស មានអណ្តូង ៦០ អណ្តូងជាដើម ដែលប្រកបដោយគ្រឿងយន្ត ។ ទាំងអស់ យើងសូមប្រគល់ដល់នាងប៉ុណ្ណោះ ។ នាងកទ្ទាពោលថា អ្នកជាម្ចាស់ ក៏លោក នឹងទៅណា ។ (មាណព) យើងនឹងបួស នាងកទ្ទា សូម្បីនាងខ្ញុំ ក៏អង្គុយរង់ចាំ ការមករបស់អ្នកស្វាមី សូម្បីនាងខ្ញុំក៏នឹងបួស ។ កពទាំងបី ប្រាកដដល់អ្នក ទាំងពីរនោះ ដូចកុដិស្លឹកត្រូវភ្លើងឆេះ ដូច្នោះ ។ អ្នកទាំងពីរនោះ ឲ្យនាំសំពត់ កាសាយៈ និងបាត្រដីមកពីផ្សារ កោរសក់ឲ្យគ្នានិងគ្នា ពោលថា ការបួសរបស់ យើងទាំងពីរឧទ្ទិសព្រះអរហន្តក្នុងលោក ហើយស៊ើកបាត្រចូលក្នុងស្នោកបាត្រ ចុះចាកពីប្រាសាទ ។ បណ្តាទាសៈ ឬកម្មករទាំងឡាយក្នុងផ្ទះ នរណាៗ ក៏ចាំ មិនបាន ។

គ្រានោះ ជននៅឯស្រុកកម្មករ ចាំអ្នកទាំងពីរនោះ ដែលចេញពីស្រុក ព្រាហ្មណ៍ កំពុងដើរកាត់ផ្លូវទ្វារស្រុកបាន ដោយអាកប្បកិរិយា ឬកពា ជន ទាំងនោះស្រែកយំ ក្រាបចុះត្រង់ជើងពោលថា លោកម្ចាស់ លោកនឹងធ្វើឲ្យ ពួកខ្ញុំគ្មានទីពឹងឬ ។ អ្នកទាំងពីរពោលថា នែនាយ យើងទាំងឡាយឃើញថា កពទាំងបី ដូចបណ្ណសាលាត្រូវភ្លើងឆេះ ទើបបានបួស បើយើងនឹងធ្វើបណ្តា ពួកលោកម្នាក់ៗ ឲ្យជាអ្នកគ្មានបំណុលសូម្បី ១០០ ឆ្នាំ ក៏មិនសមគួរ ពួកលោក

ប៉ុណ្ណោះ ចូរលាងសិរសះរបស់ខ្លួន ហើយជាអ្នកគ្មានបំណុល ចិញ្ចឹមជីវិតចុះ កាលពួកអ្នកទាសៈកម្មករទាំងនោះ ត្អូញត្អែទ្រាំងឯង ក៏ចៀសទៅ ។ ព្រះថេរៈ ដើរទៅខាងមុខ បែរត្រឡប់មកក្រឡេកមើលបណ្តើរគិតបណ្តើរថា ភទ្ទាកាបិ-លានីនេះ ជាស្ត្រីមានតម្លៃគួរដល់ជម្ពូទ្វីបទាំងមូល ដើរមកខាងក្រោយយើង មានឋានៈដែលនរណាៗ នឹងគប្បីគិតថា ជនទាំងនេះ សូម្បីបួសហើយ ក៏មិនអាចបែកគ្នា ធ្វើមិនសមគួរដូច្នេះ កើតសេចក្តីគិតថា នរណាៗ ធ្វើចិត្តឲ្យប្រទូស-រ៉ាយក្នុងយើងទាំងឡាយ នឹងគប្បីពេញក្នុងអបាយ គួរយើងលះនាងចេញ ។

ព្រះថេរៈដើរទៅខាងមុខឃើញផ្លូវបែកជា ២ បានឈប់នៅត្រង់ក្បាលផ្លូវនោះ ។ ចំណែកនាងភទ្ទាមកហើយក៏ឈរសំពះ ។ គ្រានោះ ព្រះថេរៈពោលចំពោះនាងភទ្ទាថា នាងអើយ មហាជនឃើញស្ត្រីដូចនាងដើរតាមក្រោយយើង នឹងគិតថា ជនទាំងនេះសូម្បីបួសហើយ ក៏មិនអាចចែកគ្នា ហើយមានចិត្តប្រទូស-រ៉ាយក្នុងពួកយើង នឹងគប្បីជាអ្នកពេញនៅក្នុងអបាយ ពួកយើងឈរត្រង់ផ្លូវបែកជា ២ នេះ នាងចូរកាន់យកផ្លូវមួយ ខ្ញុំនឹងទៅផ្លូវមួយទៀត ។ នាងភទ្ទាពោលថា ពិតឬអ្នក ធម្មតាមាតុគ្រាមជាមន្ទិលរបស់បព្វជិតទាំងឡាយ ជនទាំងឡាយនឹងសម្តែងទោសរបស់ពួកយើងថា អ្នកទាំងនេះសូម្បីបួសហើយក៏មិនទាន់បែកគ្នា លោកចូរកាន់យកផ្លូវមួយ ខ្ញុំនឹងកាន់យកផ្លូវមួយ ពួកយើងនឹងបែកគ្នា

ដូច្នេះ ហើយធ្វើប្រទក្សិណ ៣ ដង ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋានក្នុងទីទាំង ៤ កន្លែង (គឺខាងមុខ ខាងក្រោយ ខាងឆ្វេង ខាងស្តាំ) ផ្គងអញ្ជលីដ៏ស្រស់ល្អ ដោយម្រាមដៃទាំង ១០ ហើយពោលថា សេចក្តីស្និទ្ធស្នាល ដែលបានធ្វើទុក រហូតអស់កាលយូរប្រមាណសែនកប្ប នឹងបែកគ្នាក្នុងថ្ងៃនេះ ហើយពោលថា លោកមានជាតិខាងស្តាំ ផ្លូវស្តាំសមគួរដល់លោក ខ្ញុំឈ្មោះថា ជាមាតុគ្រាម មានជាតិខាងឆ្វេង ផ្លូវឆ្វេងសមគួរដល់ខ្ញុំ ដូច្នេះ ថ្វាយបង្គំហើយ ក៏ធ្វើដំណើរ ទៅ ។ ក្នុងវេលាដែលលោកទាំងពីរនោះចែកផ្លូវគ្នា មហាប្រថពីនេះ បានកម្រើក ញាប់ញ័រដូចជានិយាយថា យើងអាចទ្រភ្នំចក្រវាឡ និងភ្នំសិនេរុបាន តែមិន អាចទ្រគុណរបស់ពួកលោកទាំងពីរបាន ។ ក្នុងអាកាសមានសំឡេងដូចរន្ទះ ភ្នំ ចក្រវាឡក៏ឱនចុះ ។

សូម្បីព្រះសម្មាសម្ពុទ្ធ ប្រថាប់ក្នុងព្រះគន្ធកុដិក្នុងព្រះវេឡុវ័នមហាវិហារ បានឮសំឡេងផែនដីញ័រ ទើបទ្រង់ព្រះរំពឹងថា ផែនដីញ័រដើម្បី នរណាហ្ន៎ ទ្រង់ ជ្រាបថា បិប្ផលិមាណព និងនាងភទ្ទាកាបិលានី លះបង់សម្បត្តិដែលរាប់មិន បាន ហើយបួសឧទ្ទិសតថាគត ផែនដីញ័រនេះ កើតដោយកម្លាំងនៃគុណរបស់ អ្នកទាំងពីរ ក្នុងពេលដែលអ្នកទាំងពីរនោះចែកផ្លូវគ្នា សូម្បីតថាគតក៏គួរធ្វើការ សង្គ្រោះអ្នកទាំងពីរនេះ ទើបស្តេចចេញចាកព្រះគន្ធកុដិតែព្រះអង្គឯង ទ្រង់កាន់

បាត្រ និងចីវរ មិនត្រាស់ហៅភិក្ខុណាៗ ក្នុងបណ្ដាព្រះមហាសាវក ៨០ អង្គ ស្ដេចទៅទទួលអស់ចម្ងាយផ្លូវ ៣ គាវុត ប្រថាប់គង់ពត់ក្អែនត្រង់គល់ដើមពហុ-បុត្តកនិគ្រោធ ចន្លោះក្រុងរាជគ្រឹះ និងក្រុងនាលន្ទា ។ ក៏កាលប្រថាប់គង់ មិនបានប្រថាប់គង់ដូចភិក្ខុអ្នកកាន់បង្សុកូលជាវត្ត ទ្រង់កាន់ភេទជាព្រះពុទ្ធ ប្រថាប់គង់បញ្ចេញព្រះរស្មីប្រមាណ ៨០ ហត្ថ ។ ដូច្នោះ ក្នុងខណៈនោះ ព្រះពុទ្ធរស្មីមានប្រមាណប៉ុនម្លប់ស្លឹកឈើ កង់រថ និងផ្ទះកំពូលជាដើម រត់ផ្លែលធ្លាត់ទៅជុំវិញ ធ្វើឲ្យដូចវេលាព្រះច័ន្ទ និងព្រះអាទិត្យដែលរះឡើងជាពាន់ៗ ដូង បានធ្វើជាយព្រៃនោះឲ្យមានពន្លឺតែមួយដូចគ្នា ។ ផែនដី ផ្ទៃអាកាស ដូចជាព្រោងព្រាតដោយពួកផ្កាយ រុងរឿងដោយព្រះសិរីនៃព្រះមហាបុរិសលក្ខណៈ ៣២ ប្រការ ជាយព្រៃរុងរោចន៍ដូចទឹកដែលមានផ្កាឈូករីកស្គុះស្គាយ ។ ធម្មតា ដើមនិគ្រោធមានដើមស មានស្លឹកខៀវ ផ្លែទុំក្រហម ។ តែថ្ងៃនោះ ដើមនិគ្រោធត្រឡប់ជាមានមែកស មានពណ៌ដូចមាស ។

ព្រះមហាកស្សបត្ថេរៈគិតថា បុគ្គលនេះ នឹងជាព្រះសាស្ដារបស់យើង យើងបួសឧទ្ទិសព្រះសាស្ដាអង្គនេះ ដូច្នេះ ចាប់ផ្ដើមតាំងពីទីដែលមើលឃើញ បានបង្អោនកាយដើរទៅ ថ្វាយបង្គំក្នុងទី ៣ កន្លែង ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគជាសាស្ដារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវក

បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវក ។ លំដាប់នោះ ព្រះដ៏មានព្រះភាគបានត្រាស់ចំពោះព្រះមហាកស្សបត្ថេរៈថា ម្នាលកស្សប បើអ្នកនឹងគប្បីធ្វើការគោរពនេះ ទុកក្នុងមហាប្រថពី សូម្បីមហាប្រថពីនោះ ក៏មិនអាចនឹងទទួលយកទុកបាន ការគោរពដែលអ្នកធ្វើ រមែងមិនអាចធ្វើសូម្បីរោមរបស់តថាគតឲ្យកម្រើក ព្រោះតថាគតមានគុណធំយ៉ាងនេះ អង្គុយចុះមកកស្សប តថាគតនឹងឲ្យទ្រព្យដែលជាមត៌កដល់អ្នក ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ បានប្រទានឧបសម្បទដល់ព្រះមហាកស្សបត្ថេរៈ ដោយឱវាទ ៣ ប្រការ លុះប្រទានហើយ ក៏ស្តេចចេញចាកគល់ដើមពហុបុត្តកនិគ្រោធ ស្តេចធ្វើដំណើរមានព្រះថេរៈជាបច្ឆាសមណៈ ។ ព្រះសរីរៈរបស់ព្រះសាស្តាល្អវិចិត្រដោយព្រះមហាបុរិសលក្ខណៈ ៣២ ប្រការ សរីរៈរបស់ព្រះមហាកស្សបប្រដាប់ដោយមហាបុរិសលក្ខណៈ ៧ ប្រការ ។ ព្រះមហាកស្សបនោះ ដើរតាមព្រះសាស្តា ដូចជាទូកសណ្តោងទៅតាមទូកធំពណ៌មាស ដូច្នោះ ព្រះសាស្តាស្តេចយាងទៅបន្តិចហើយចៀងចុះ (ខាងផ្លូវ) សម្តែងអាការនឹងប្រថាប់គង់ត្រង់គល់ឈើមួយកន្លែង ព្រះថេរៈដឹងថា ព្រះសាស្តាមានព្រះបំណងនឹងប្រថាប់គង់ ទើបធ្វើសង្ឃាដិដែលជាសំពត់ចាស់ ដែលខ្លួនដណ្តប់ឲ្យជា ៤ ជាន់ ក្រាលថ្វាយ ។

ព្រះសាស្ដាប្រថាប់គង់លើសំពត់សង្ឃាដិនោះ ហើយយកព្រះហស្ដស្ទាប អង្អែលសាច់សំពត់ ត្រាស់ថា កស្សប សង្ឃាដិដែលធ្វើដោយសំពត់ចាស់ផ្ទាំងនេះរបស់អ្នកទន់ល្អ ។ ព្រះថេរៈដឹងថា ព្រះសាស្ដាត្រាស់ដល់សង្ឃាដិរបស់យើងទន់ ព្រះអង្គប្រាថ្នានឹងដណ្ដប់ ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទ្រង់ដណ្ដប់សង្ឃាដិចុះ ។ ព្រះសាស្ដាត្រាស់ថា កស្សប អ្នកនឹងដណ្ដប់អ្វី? ព្រះថេរៈក្រាបទូលថា ខ្ញុំព្រះអង្គបានសំពត់ស្លៀករបស់ព្រះអង្គ ទើបនឹងដណ្ដប់ ។ ព្រះសាស្ដាត្រាស់ថា កស្សប អ្នកនឹងអាចដណ្ដប់សំពត់បង្សុកូលដែលប្រើចាស់ហើយផ្ទាំងនេះ យ៉ាងនេះបានឬ ព្រោះថា មហាប្រថពីបានញាប់ញ័ររហូតដល់ទឹកទ្រផែនដី ក្នុងថ្ងៃដែលតថាគតនាំសំពត់បង្សុកូលផ្ទាំងនេះ ។ ធម្មតាថា ចីវរដែលចាស់ ព្រោះការប្រើប្រាសរបស់ព្រះពុទ្ធទាំងឡាយនេះ សូម្បីចាស់ហើយ បុគ្គលដែលមានគុណតិចមិនអាចគ្រងបាន ចីវរចាស់ដូចពោលនេះ បុគ្គលដែលអាចក្នុងការបំពេញវត្តបដិបត្តិ អ្នកសមាទានសំពត់បង្សុកូលមកអំពីមុន ទើបនឹងគួរទទួលយក ហើយទ្រង់ប្ដូរចីវរជាមួយព្រះថេរៈ ។

ក៏ព្រះដ៏មានព្រះភាគទ្រង់ប្ដូរចីវរយ៉ាងនេះហើយ ទ្រង់ដណ្ដប់ចីវរដែលព្រះថេរៈដណ្ដប់ហើយ ព្រះថេរៈដណ្ដប់ចីវររបស់ព្រះសាស្ដា ។ ក្នុងសម័យនោះ មហាប្រថពីនេះ សូម្បីមិនមានចិត្ត ក៏ញាប់ញ័ររហូតដល់ទឹកទ្រផែនដី ដូច

ជាពោលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់ធ្វើវត្ថុដែលធ្វើបានលំបាក ចីវរដែលព្រះអង្គដណ្តប់ហើយ ឈ្មោះថា ធ្លាប់បានប្រទានដល់ព្រះសាវកមិនមាន (គឺ មិនធ្លាប់មានការប្រទានចីវរដែលទ្រង់ដណ្តប់ហើយដល់សាវក) ខ្ញុំព្រះអង្គមិនអាចទ្រទ្រង់គុណរបស់ព្រះអង្គបាន ។ សូម្បីព្រះថេរៈ ក៏មិនបានធ្វើមានះឡើងថា ឥឡូវនេះយើងបានចីវរសម្រាប់ប្រើប្រាស់របស់ព្រះពុទ្ធទាំងឡាយ វត្ថុដែលយើងនឹងគប្បីធ្វើឲ្យក្រៃលែងឡើងទៅក្នុងឥឡូវនេះ នៅមិនទាន់មាន ទើបបានសមាទានធុតង្គគុណ ១៣ ប្រការ ក្នុងសំណាក់របស់ព្រះពុទ្ធនុ៎ះឯង លោកនៅជាបុថុជ្ជនត្រឹមតែ ៧ ថ្ងៃ ក្នុងអរុណទី ៨ បានសម្រេចព្រះអរហត្តព្រមដោយសូត្រទាំងឡាយ មានជាដើមយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ កស្សបប្រៀបដូចព្រះច័ន្ទ ចូលទៅកាន់ត្រកូលទាំងឡាយ ចៀសកាយ ចៀសចិត្តចាកអកុសលធម៌ទាំងឡាយ ប្រព្រឹត្តខ្លួនជាអ្នកថ្មីជានិច្ច មិនឃ្នងក្នុងត្រកូលទាំងឡាយ ។ លុះខាងក្រោយមក ទ្រង់ធ្វើកស្សបសំយុត្តនេះឯង ឲ្យជាហេតុកើតរឿង ទើបទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងឯតទគ្គៈ ដោយព្រះតម្រាស់ថា មហាកស្សប ជាកំពូលនៃភិក្ខុទាំងឡាយអ្នកសមាទានធុតង្គ និងទូន្មានរឿងធុតង្គក្នុងសាសនារបស់តថាគត ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ៤

# អដ្ឋកថាសូត្រទី ៥

## ប្រវត្តិព្រះអនុរុទ្ធត្ថេរ

ក្នុងសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖

[១៨៦] *បទថា **ទិព្វចក្ខុកានំ យទិទំ អនុរុទ្ធោ** សេចក្ដីថា ត្រាស់ថា ព្រះអនុរុទ្ធត្ថេរៈ ជាកំពូលនៃភិក្ខុទាំងឡាយអ្នកមានចក្ខុទិព្វ គប្បីជ្រាបថា ព្រះអនុរុទ្ធត្ថេរៈនោះជាអ្នកប្រសើរបំផុត ព្រោះជាអ្នកមានសេចក្ដីជំនាញដែលសន្សំទុកហើយ ។ បានឮថា ព្រះថេរៈវៀរតែវេលាឆាន់ប៉ុណ្ណោះ វេលាដ៏សេសចម្រើនអាលោកកសិណត្រួតមើលពួកសត្វដោយទិព្វចក្ខុតែម្យ៉ាង ដូច្នោះ ព្រះថេរៈនេះ ទើបឈ្មោះថា ជាកំពូលនៃភិក្ខុទាំងឡាយអ្នកមានទិព្វចក្ខុ ព្រោះជាអ្នកមានសេចក្ដីជំនាញដែលសន្សំទុកអស់មួយថ្ងៃ និងយប់ ។ ម្យ៉ាងទៀត ជាកំពូលនៃភិក្ខុដែលមានទិព្វចក្ខុដ៏សេស ព្រោះប្រាថ្នាទុកមកអស់សែននៃកប្ប ក៏ក្នុងរឿងបុព្វកម្មរបស់លោក ក្នុងសេចក្ដីនោះ មានរឿងដែលនឹងពោលតាមលំដាប់ដូចតទៅ ៖*

*សេចក្ដីពិស្ដារថា កាលព្រះដ៏មានព្រះភាគព្រះនាមថា បទុមុត្តរទ្រង់ឯងកុលបុត្រសូម្បីនេះ បានទៅជាមួយមហាជន ទៅកាន់វិហារដើម្បីស្ដាប់ធម៌ខាងក្រោយភត្តាហារ ។ ក៏គ្រានោះ កុលបុត្រនេះ បានជាកុដុម្ពិកៈជាធំម្នាក់មិនប្រាកដ*

ឈ្មោះ ។ គេថ្វាយបង្គំព្រះទសពលហើយ ឈរខាងក្រោយបរិស័ទស្តាប់ធម្ម-កថា ។ ព្រះសាស្តាទ្រង់បន្តព្រះធម៌ទេសនាតាមអនុសន្ធិហើយ ទ្រង់ស្ថាបនាភិក្ខុដែលមានទិព្វចក្ខុមួយរូបទុកក្នុងតំណែងឯតទគ្គៈ ។ លំដាប់នោះ កុដុម្ពិកៈមានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុនេះធំហ្ន៎ ព្រះសាស្តាទ្រង់តាំងទុកក្នុងភាពជាកំពូលនៃភិក្ខុដែលមានទិព្វចក្ខុ ដោយប្រការយ៉ាងនេះ ឱហ្ន៎ សូម្បីយើងក៏គប្បីជាកំពូលនៃភិក្ខុដែលមានចក្ខុទិព្វក្នុងព្រះសាសនារបស់ព្រះពុទ្ធ ដែលនឹងឧប្បត្តិក្នុងអនាគតដូច្នេះ ហើយកើតសេចក្តីគិតដូច្នេះឡើង ដើរចូលទៅចន្លោះបរិស័ទ ទូលនិមន្តព្រះដ៏មានព្រះភាគព្រមទាំងព្រះភិក្ខុមួយសែន ដើម្បីសោយក្នុងថ្ងៃស្អែកនេះ លុះថ្ងៃស្អែក ថ្វាយមហាទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន គិតថា យើងប្រាថ្នាតំណែងធំ ទើបទូលនិមន្តក្នុងថ្ងៃនោះ ដើម្បីសោយថ្ងៃស្អែកនេះ ហើយធ្វើមហា-ទានឲ្យប្រព្រឹត្តទៅអស់ ៧ ថ្ងៃ ដោយទំនងនោះឯង ថ្វាយសំពត់យ៉ាងល្អដល់ព្រះដ៏មានព្រះភាគព្រមទាំងបរិវារ ហើយធ្វើសេចក្តីប្រាថ្នាថា បពិត្រព្រះដ៏មាន-ព្រះភាគ ខ្ញុំព្រះអង្គធ្វើសក្ការៈនេះ ដើម្បីប្រយោជន៍ដល់ទិព្វសម្បត្តិ ឬមនុស្ស-សម្បត្តិក៏មិនមែន ក៏ព្រះអង្គទ្រង់តាំងភិក្ខុណាទុកក្នុងតំណែងជាកំពូលនៃភិក្ខុ ដែលមានទិព្វចក្ខុក្នុង ៧ ថ្ងៃ កន្លងមកហើយដល់ថ្ងៃនេះ សូម្បីខ្ញុំព្រះករុណា ក៏គប្បីជាកំពូលនៃភិក្ខុដែលមានទិព្វចក្ខុដូចភិក្ខុអង្គនោះ ក្នុងព្រះសាសនារបស់ព្រះពុទ្ធ

មួយអង្គក្នុងអនាគតកាល ដូច្នេះ ហើយក្រាបចុះទៀបព្រះបាទព្រះសាស្តា ។ ព្រះសាស្តាទ្រង់ត្រួតមើលក្នុងអនាគត ទ្រង់ជ្រាបថា សេចក្តីប្រាថ្នារបស់គេនឹងបានសម្រេច ទើបត្រាស់យ៉ាងនេះថា ម្នាលបុរសអ្នកចម្រើន ក្នុងទីបំផុតសែនកប្ប ក្នុងអនាគត ព្រះពុទ្ធព្រះនាមថា **គោតម** នឹងឧប្បត្តិឡើង អ្នកនឹងមានឈ្មោះថា **អនុរុទ្ធ** ជាកំពូលនៃភិក្ខុដែលមានទិព្វចក្ខុ ក្នុងព្រះសាសនារបស់ព្រះគោតមសម្ពុទ្ធនោះ លុះត្រាស់យ៉ាងនេះហើយ ទ្រង់ធ្វើភត្តានុមោទនា ស្តេចត្រឡប់ទៅព្រះវិហារ ។

ចំណែកកុដុម្ពិកៈធ្វើកម្មល្អមិនដាច់ឡើយ ដរាបដែលព្រះពុទ្ធទ្រង់ព្រះជន្មនៅ កាលព្រះសាស្តាបរិនិព្វានហើយ បានសាងចេតិយមាសប្រមាណ ៧ យោជន៍ស្រេចហើយ ទើបចូលទៅរកភិក្ខុសង្ឃ សួរថា អ្វីជាបរិកម្មរបស់ទិព្វចក្ខុ លោកម្ចាស់ ។ ភិក្ខុសង្ឃប្រាប់ថា គួរឲ្យប្រទីប ឧបាសក ។ ឧបាសកពោលថា ល្អណាស់ ខ្ញុំករុណានឹងធ្វើ ទើបឲ្យសាងប្រទីប ១.០០០ ដើម ប៉ុនគ្នានឹងប្រទីប ១.០០០ ដើមដួងមុន បន្ទាប់ពីនោះសាងឲ្យតូចជាងនោះ បន្ទាប់ពីនោះសាងឲ្យតូចជាងនោះ រួមសេចក្តីថា បានសាងប្រទីបច្រើនពាន់ដើម ។ ចំណែកប្រទីបដ៏សេសប្រមាណមិនបាន ។ គេធ្វើកល្យាណកម្មយ៉ាងនេះ រហូតអស់មួយជីវិតអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ កន្លងទៅសែនកប្ប ក្នុងកាលនៃ

ព្រះកស្សបសម្មាសម្ពុទ្ធ កើតក្នុងផ្ទះកុដុម្ពិកៈជិតក្រុងពារាណសី កាលព្រះសាស្ដា បរិនិព្វាន បានសាងចេតិយប្រមាណ ១ យោជន៍ស្រេចហើយ ឲ្យសាងភាជនៈសំរិតដ៏ច្រើន ដាក់ទឹកដោះថ្លាជរាបពេញ ឲ្យដាក់ប្រឆេះចង្កៀង ចន្លោះពីគ្នា ១ ចន្លុលដៃៗ ត្រង់កណ្ដាល ឲ្យអុជភ្លើងឡើងព័ទ្ធជុំវិញព្រះចេតិយ ត្រង់កណ្ដាប់ព្រះចេតិយជាប់គ្នា ឲ្យសាងភាជនៈសំរិតធំជាងគេទាំងអស់សម្រាប់ខ្លួន ដាក់ទឹកដោះថ្លាពេញ ធ្វើប្រឆេះចង្កៀងមួយពាន់ដួងជុំវិញត្រង់កណ្ដាប់មាត់ភាជនៈសំរិតនោះ យកសំពត់ចាស់ធ្វើជាប្រឆេះធំទុកត្រង់កណ្ដាល ឲ្យអុជភ្លើង ហើយទូលភាជនៈសំរិតដើរប្រទក្សិណចេតិយប្រមាណ ១ យោជន៍ រហូតអស់មួយយប់ទល់ភ្លឺ ។ គេធ្វើកល្យាណកម្មរហូតអស់មួយជីវិត ដោយអត្តភាពសូម្បីនោះ ដោយអាការយ៉ាងនេះ ហើយក៏ទៅកើតក្នុងទេវលោក ។ កាលព្រះពុទ្ធមិនទាន់ឧប្បត្តិឡើង គេបដិសន្ធិក្នុងផ្ទះរបស់ត្រកូលកំសត់ ក្នុងនគរនោះឯងទៀត ជាអ្នករែកស្មៅ អាស្រ័យសុមនសេដ្ឋីចិញ្ចឹមជីវិត គេមានឈ្មោះថា **អន្នភារៈ** ។ ចំណែកសុមនសេដ្ឋីនោះ ឲ្យមហាទានត្រង់ទ្វារស្រុកដល់មនុស្សកំព្រា អ្នកធ្វើដំណើរ អ្នកសូមទាន និងយាចក រាល់ថ្ងៃៗ ។

ខាងក្រោយក្នុងថ្ងៃមួយ ព្រះបច្ចេកពុទ្ធ នាមថា **ឧបរិដ្ឋៈ** ចូលនិរោធសមាបត្តិ ឯភ្នំគន្ធមាទន៍ ចេញចាកសមាបត្តិនោះហើយ ពិចារណាថា ថ្ងៃនេះ

គួរនឹងធ្វើការអនុគ្រោះនរណា ។ ក៏ធម្មតាព្រះបច្ចេកពុទ្ធទាំងឡាយ រមែងជាអ្នកអនុគ្រោះអ្នកកំសត់ទុគ៌ត លោកគិតថា ថ្ងៃនេះយើងគួរធ្វើការអនុគ្រោះនាយអន្នភារៈ ជ្រាបថា នាយអន្នភារៈនឹងចេញពីព្រៃមកកាន់ផ្ទះខ្លួន ទើបកាន់បាត្រនិងចីវរចាកភ្នំគន្ធមាទន៍ ហោះឡើងកាន់វេហាស៍ មកប្រាកដចំពោះមុខនាយអន្នភារៈត្រង់ទ្វារផ្ទះទ្រុំឯង ។ នាយអន្នភារៈ ឃើញព្រះបច្ចេកពុទ្ធ កាន់បាត្រទទេ ទើបអភិវាទព្រះបច្ចេកពុទ្ធ ហើយសួរថា លោកម្ចាស់បានភិក្ខាខ្លះទេ ។ ព្រះបច្ចេកពុទ្ធពោលថា នឹងបាន អ្នកដ៏មានបុណ្យច្រើន ។ គេពោលថា មេត្តារង់ចាំនៅទីនេះសិនចុះលោកម្ចាស់ ហើយប្រញាប់ទៅ សួរមេផ្ទះក្នុងផ្ទះរបស់ខ្លួនថា នាងដ៏ចម្រើន ភត្តដែលជាចំណែកទុកដើម្បីយើង មានឬទេ ។ នាងឆ្លើយថា មាន នាយ ។ គេទៅពីទីនោះ ទទួលបាត្រពីដៃព្រះបច្ចេកពុទ្ធ មកពោលថា នាងដ៏ចម្រើន ព្រោះតម្ងៃដែលមិនបានធ្វើកល្យាណកម្មទុកក្នុងជាតិមុនយើងទាំង ២ ទើបយើងរស់នៅបានពីការបម្រើគេ កាលសេចក្តីប្រាថ្នានឹងឲ្យរបស់ពួកយើងមានហើយ តែទេយ្យធម៌មិនមាន កាលទេយ្យធម៌មាន ក៏មិនបានបដិគ្គាហកៈ ថ្ងៃនេះ យើងជួបព្រះឧបរិដ្ឋបច្ចេកពុទ្ធស្តេចយាងមក និងភត្តដែលជាចំណែកក៏មានហើយ នាងឯងចូរដាក់ភត្តដែលជាចំណែករបស់ខ្ញុំចុះក្នុងបាត្រនេះ ។ ស្ត្រីដែលឆ្លាតគិតថា កាលណាស្វាមីរបស់យើងឲ្យភត្តដែលជាចំណែក

នោះ កាលនោះសូម្បីយើងក៏គប្បីមានចំណែកក្នុងទាននេះ ទើបដាក់សូម្បីកត្ត ដែលជាចំណែករបស់ខ្លួនចុះក្នុងបាត្រថ្វាយដល់ឧបរិដ្ឋបច្ចេកពុទ្ធ ។ នាយអន្នភារៈ នាំបាត្រដែលដាក់កត្ត ប្រគេនដល់ព្រះបច្ចេកពុទ្ធហើយ ពោលថា សូមឲ្យពួកខ្ញុំផុតពីការរស់នៅយ៉ាងលំបាកឃើញបែបនេះចុះ លោកម្ចាស់ ។ ព្រះបច្ចេក-ពុទ្ធ អនុមោទនាថា ចូរសម្រេចយ៉ាងនោះចុះ អ្នកដ៏មានបុណ្យច្រើន ។ គេក្រាលសំពត់ដណ្តប់របស់ខ្លួនចុះក្នុងទីម្ខាង ហើយពោលថា សូមអនុគ្រោះគង់ឆាន់ត្រង់ទីនេះចុះ លោកម្ចាស់ ។ ព្រះបច្ចេកពុទ្ធគង់លើអាសនៈនោះហើយ ពិចារណាភាពជារបស់បដិកូល ៩ យ៉ាង ហើយទើបឆាន់ កាលឆាន់ស្រេចហើយ នាយអន្នភារៈ ទើបថ្វាយទឹកសម្រាប់លាងបាត្រ ព្រះបច្ចេកពុទ្ធញុំាងកត្តកិច្ចស្រេចហើយធ្វើអនុមោទនាថា ៖

វត្ថុដែលអ្នកត្រូវការហើយ ប្រាថ្នាហើយ ចូរសម្រេច
រួសរាន់ទាន់ចិត្ត សេចក្តីត្រិះរិះ ចូរពេញដូចព្រះច័ន្ទថ្ងៃ
១៥ កើត ដូច្នោះ វត្ថុដែលអ្នកត្រូវការហើយ ប្រាថ្នា
ហើយ ចូរសម្រេចទាន់ចិត្ត សេចក្តីត្រិះរិះចូរពេញ ដូច
មណីមានរស្មីរុងរឿង ដូច្នោះ ។

ហើយទ្រង់ធ្វើដំណើរទៅ ។

ទេវតាដែលស្ថិតនៅនឹងឆត្ររបស់សុមនសេដ្ឋី ពោលថា គួរអស្ចារ្យ ទានដែលតាំងទុកល្អហើយក្នុងព្រះបច្ចេកពុទ្ធនាមថា ឧបរិដ្ឋៈ ជាទានដ៏ក្រៃលែង អស់ ៣ ដង ហើយបានឲ្យសាធុការ សុមនសេដ្ឋីពោលថា លោកមិនឃើញយើងឲ្យទានរហូតកាលមានប្រមាណប៉ុណ្ណោះទេឬ ទេវតាពោលថា យើងមិនឲ្យសាធុការក្នុងទានរបស់លោក យើងជ្រះថ្លាក្នុងបិណ្ឌបាតដែលនាយអន្នភារៈ ថ្វាយចំពោះព្រះបច្ចេកពុទ្ធនាមថាឧបរិដ្ឋៈ ទើបឲ្យសាធុការ សុមនសេដ្ឋីត្រិះរិះថា រឿងនេះគួរអស្ចារ្យហ្ន៎ យើងឲ្យទានរហូតវេលាមានប្រមាណប៉ុណ្ណោះ ក៏មិនអាចធ្វើឲ្យទេវតាឲ្យសាធុការ នាយអន្នភារៈនេះ អាស្រ័យយើងហើយ ដោយការថ្វាយបិណ្ឌបាតតែមួយដងប៉ុណ្ណោះ ធ្វើឲ្យទេវតាសាធុការបាន ព្រោះបានបុគ្គលដែលជាបដិគ្គាហកៈដ៏សមគួរ យើងឲ្យវត្ថុដែលសមគួរដល់នាយអន្នភារៈនោះ ហើយធ្វើបិណ្ឌបាតនោះឲ្យជារបស់យើងទើបនឹងគួរ ដូច្នេះ ហៅនាយអន្នភារៈមក ហើយសួរថា ថ្ងៃនេះអ្នកឲ្យទានអ្វីៗ ដល់នរណាឬ លោកម្ចាស់ ខ្ញុំថ្វាយកត្តដែលជាចំណែករបស់ខ្ញុំដល់ព្រះបច្ចេកពុទ្ធនាមថា ឧបរិដ្ឋៈ សេដ្ឋីពោលថា ណ្ហើយចុះ អ្នកចូរទទួលកហាបណៈទៅ ហើយឲ្យបិណ្ឌបាតនោះដល់យើងចុះ ឲ្យមិនបានទេលោកម្ចាស់ សេដ្ឋីបន្ថែមទ្រព្យឡើងរហូតដល់ពាន់កហាបណៈ នាយអន្នភារៈក៏នៅតែពោលថា សូម្បីដល់ពាន់កហាបណៈ ក៏នៅឲ្យមិនបាន សេដ្ឋីពោលថា

ណ្ហើយចុះនាយ បើអ្នកមិនឲ្យបិណ្ឌបាត ក៏ចូរទទួលទ្រព្យមួយពាន់កហាបណៈ ទៅ ហើយឲ្យតែចំណែកបុណ្យដល់ខ្ញុំចុះ នាយអន្នភារៈពោលថា ខ្ញុំមិនដឹងថា សូម្បីចំណែកបុណ្យនោះ គួរឲ្យ ឬមិនគួរឲ្យ តែខ្ញុំនឹងសួរព្រះបច្ចេកពុទ្ធនាមថា ឧបរិដ្ឋៈមើល បើគួរឲ្យក៏នឹងឲ្យ បើមិនគួរឲ្យក៏នឹងមិនឲ្យ នាយអន្នភារៈដើរទៅ តាមទាន់ព្រះបច្ចេកពុទ្ធ សួរថា លោកម្ចាស់ សុមនសេដ្ឋីឲ្យទ្រព្យដល់ខ្ញុំមួយពាន់ សូមចំណែកបុណ្យក្នុងបិណ្ឌបាតដែលថ្វាយដល់លោកម្ចាស់ ខ្ញុំគួរឲ្យ ឬមិនគួរ ឲ្យ ព្រះបច្ចេកពុទ្ធពោលថា បណ្ឌិត យើងនឹងធ្វើឧបមាដល់អ្នក ដូចសេចក្តីថា ក្នុងតំបន់នេះ មានត្រកូលមួយរយ យើងអុជប្រទីបទុកក្នុងផ្ទះមួយខ្នងប៉ុណ្ណោះ ត្រកូលទាំងនេះយកប្រេងះចង្កៀងមកជ្រលក់ប្រេងឲ្យសើម ហើយអុជភ្លើងតគ្នា កាន់ទៅ ពន្លឺរបស់ប្រទីបដួងមុននៅមាន ឬមិនមាន នាយអន្នភារៈពោលថា លោកម្ចាស់ ពន្លឺប្រទីបក៏កាន់តែភ្លឺឡើងទៅទៀត លោកម្ចាស់ ប្រការនេះឧបមា យ៉ាងណា ម្នាលបណ្ឌិត យាគូមួយបោយ ឬបាយមួយវែកចូរលើកទុក កាល អ្នកឲ្យចំណែកបុណ្យដល់អ្នកដទៃក្នុងបិណ្ឌបាតរបស់ខ្លួន ពាន់នាក់ ឬសែននាក់ ក៏ដោយ ឲ្យដល់ប៉ុន្មាននាក់ បុណ្យក៏បន្ថែមឡើងដល់ខ្លួនមានប្រមាណប៉ុណ្ណោះ កាលលោកឲ្យក៏ឲ្យបិណ្ឌបាតតែម្យ៉ាងនុ៎ះឯង កាលឲ្យចំណែកបុណ្យដល់សុមន- សេដ្ឋីទៀត បិណ្ឌបាតក៏ចែកទៅជា ២ គឺ របស់លោកមួយចំណែក របស់សេដ្ឋី

មួយចំណែក ដូច្នេះ នាយអន្នភារៈក្រាបថ្វាយបង្គំព្រះបច្ចេកពុទ្ធហើយ ត្រឡប់ទៅកាន់សំណាក់របស់សុមនសេដ្ឋី ពោលថា សូមលោកចូរទទួលនូវចំណែកបុណ្យក្នុងបិណ្ឌបាតទានចុះ សេដ្ឋីពោលថា សូមអ្នកទទួលទ្រព្យមួយពាន់កហាបណៈចុះ នាយអន្នភារៈពោលថា ខ្ញុំមិនបានលក់បិណ្ឌបាតទាន តែខ្ញុំឲ្យចំណែកបុណ្យដល់លោកដោយសទ្ធា សេដ្ឋីពោលថា បាអន្នភារៈ បាឲ្យចំណែកបុណ្យដល់យើងដោយសទ្ធា តែយើងបូជាគុណរបស់បា ខ្ញុំឲ្យមួយពាន់កហាបណៈនេះចូរទទួលទៅចុះ បាអន្នភារៈ នាយអន្នភារៈពោលថា ចូរជាយ៉ាងនោះ ទើបកាន់យកទ្រព្យមួយពាន់កហាបណៈទៅ សេដ្ឋីពោលថា បាអន្នភារៈ តាំងពីពេលបានទ្រព្យមួយពាន់កហាបណៈហើយ មិនចាំបាច់ធ្វើកិច្ចការងារដោយដៃរបស់ខ្លួនទេ ចូរសង់ផ្ទះនៅជិតថ្នល់ចុះ បើបាត្រូវការវត្ថុណា ខ្ញុំនឹងប្រគល់វត្ថុនោះឲ្យ បាចូរមកនាំយកទៅចុះ ។

ធម្មតាបិណ្ឌបាត ដែលបុគ្គលថ្វាយចំពោះព្រះបច្ចេកពុទ្ធ អ្នកចេញចាកនិរោធសមាបត្តិ រមែងឲ្យផលក្នុងថ្ងៃនោះឯង ព្រោះដូច្នោះ សុមនសេដ្ឋីក្នុងថ្ងៃដទៃសូម្បីទៅកាន់រាជត្រកូល មិនធ្លាប់បបួលនាយអន្នភារៈទៅជាមួយ តែក្នុងថ្ងៃនោះ បានបបួលទៅជាមួយ ព្រោះអាស្រ័យបុណ្យរបស់នាយអន្នភារៈ ព្រះរាជាមិនសម្លឹងមើលសេដ្ឋីឡើយ ទ្រង់មើលតែនាយអន្នភារៈប៉ុណ្ណោះ សេដ្ឋីទើប

ទូលសួរថា បពិត្រសម្មតិទេព ហេតុដូចម្ដេច ព្រះអង្គទើបទ្រង់សម្លឹងមើលតែបុរសម្នាក់នេះម្ល៉េះព្រះអង្គ ព្រះរាជាត្រាស់ថា យើងសម្លឹងមើល ព្រោះមិនធ្លាប់គាល់ក្នុងថ្ងៃមុនៗ សេដ្ឋីទូលថា មហាបពិត្រ គេសមគួរសម្លឹងមើលយ៉ាងណា គុណដែលគួរសម្លឹងមើលរបស់គេ គឺអ្វី ព្រោះថ្ងៃនេះ គេមិនបរិភោគភត្តដែលជាចំណែករបស់ខ្លួនដោយខ្លួនឯង តែថ្វាយចំពោះព្រះបច្ចេកពុទ្ធនាមថា ឧបរិដ្ឋៈ គេបានទ្រព្យមួយពាន់កហាបណៈពីដៃរបស់ខ្ញុំព្រះអង្គ ព្រះរាជាត្រាស់សួរថា គេឈ្មោះអ្វី ឈ្មោះអន្នភារៈ ព្រះអង្គ ព្រោះបានពីដៃរបស់លោក ក៏គួរនឹងបានពីដៃរបស់យើងខ្លះ យើងក៏នឹងធ្វើការបូជាគេ ទើបព្រះរាជទានទ្រព្យមួយពាន់កហាបណៈ ហើយត្រាស់ថា នាយ ចូរពិនិត្យមើលផ្ទះដែលបុរសនេះគប្បីរស់នៅបាន រាជបុរសទូលថា ព្រះអង្គ រាជបុរសទាំងឡាយចាត់ចែងបោសសម្អាតទីផ្ទះនោះ បានឃើញរណ្ដៅទ្រព្យឈ្មោះបិង្គលៈ ក្នុងទីដែលចបប៉ះត្រូវហើយដែលតាំងនៅរៀងគ្នា ទើបមកក្រាបទូលព្រះរាជាឲ្យទ្រង់ជ្រាប ព្រះរាជាត្រាស់ថា បើដូច្នោះចូរទៅជីកឡើងមក កាលរាជបុរសទាំងនោះកំពុងជីក រណ្ដៅទ្រព្យក៏លិចចុះទៅ រាជបុរសទាំងនោះទៅក្រាបទូលព្រះរាជាទៀត ព្រះរាជាត្រាស់ថា ចូរទៅជីកតាមពាក្យរបស់អន្នភារៈ រាជបុរសក៏ទៅជីកតាមពាក្យបង្គាប់ រណ្ដៅទ្រព្យដូចផ្កាក្ដោបៗ ផុសឡើងក្នុងទីដែលចបប៉ះត្រូវហើយ រាជបុរសទាំងនោះ

ជញ្ជូនទ្រព្យដ៏ច្រើនមកគរទុកក្នុងព្រះរាជសំណាក់ ព្រះរាជាប្រជុំអាមាត្រទាំងឡាយ ហើយត្រាស់សួរថា ក្នុងក្រុងនេះ អ្នកណាមានទ្រព្យប្រមាណប៉ុណ្ណេះទេ អាមាត្រទូលថា មិនមានទេព្រះអង្គ ត្រាស់ថា បើយ៉ាងនោះ អន្នការៈនេះ ចូរឈ្មោះថា **ធនសេដ្ឋី** ក្នុងព្រះនគរនេះ គេបានឆត្រប្រចាំតំណែងសេដ្ឋីក្នុងថ្ងៃនោះឯង ។

តាំងពីថ្ងៃនោះ គេធ្វើតែកម្មដែលល្អរហូតអស់មួយជីវិត ចុតិចាកអត្តភាពនោះ ទៅកើតក្នុងទេវលោក វិលវល់នៅក្នុងទេវតា និងមនុស្សអស់វេលាយូរ គ្រាដែលព្រះសាស្តារបស់ពួកយើងទ្រង់ឧប្បត្តិ ក៏មកបដិសន្ធិក្នុងនិវេសន៍នៃសក្យ-រាជ ព្រះនាមថា **អមិតោ្តទនៈ** ក្រុងកបិលពស្តុ ក្នុងថ្ងៃដាក់ព្រះនាម មនុស្សទាំងឡាយតាំងឈ្មោះគេថា **អនុរុទ្ធកុមារ** ជាកនិដ្ឋភាតារបស់សក្យរាជ ព្រះនាមថា **មហានាម** ជាឱរសរបស់ព្រះរាជឪពុកមារបស់ព្រះសាស្តា (ត្រូវជាព្រះអនុជរបស់ព្រះសាស្តា) ជាសុខមាលជាតិ ជាអ្នកមានបុណ្យច្រើន កត្តតែងកើតឡើងក្នុងថាសមាសដល់គេតែម្យ៉ាង ក្រោយមក ព្រះមាតារបស់គេគិតថា នឹងឲ្យកូនរបស់យើងស្គាល់បទថា “មិនមាន” យកថាសមាស គ្របដោយថាសមាសមួយទៀត ហើយបញ្ជូនតែថាសទទេ ក្នុងរវាងផ្លូវ ទេវតាធ្វើឲ្យពេញដោយនំទិព្វ គេមានបុណ្យច្រើនយ៉ាងនេះ ដែលពួកស្រីស្នំបានប្រដាប់តាក់តែងហើយ ហែហមសោយសម្បត្តិលើប្រាសាទ ៣ ខ្នង សមគួរដល់រដូវទាំង ៣ ដូចទេវតា ។

ចំណែកព្រះពោធិសត្វរបស់យើង ចុតិចាកតុសិតក្នុងសម័យនោះ មកបដិសន្ធិក្នុងគភ៌របស់អគ្គមហេសីរបស់ព្រះបាទសុទ្ធោទនមហារាជ ទ្រង់ចម្រើនវ័យដោយលំដាប់ ទ្រង់នៅគ្រប់គ្រងផ្ទះ ២៩ ឆ្នាំ ហើយស្តេចទ្រង់ចេញមហាភិនេសក្រមណ៍ ទ្រង់ត្រាស់ដឹងព្រះសព្វញ្ញុតញ្ញាណដោយលំដាប់ ទ្រង់សម្ងំត្រង់ពោធិមណ្ឌស្ថាន ៧ សប្តាហ៍ ប្រកាសព្រះធម្មចក្កក្នុងព្រៃឥសិបតនមិគទាយវ័ន ទ្រង់ធ្វើការអនុគ្រោះលោក ទ្រង់ឲ្យអាមាត្រ ១០ នាក់ ព្រមទាំងបរិវារម្នាក់មួយពាន់ ដែលព្រះរាជបិតាទ្រង់ស្តាប់ដំណឹងថា បុត្ររបស់យើងមកកាន់ក្រុងរាជគ្រឹះ ហើយត្រាស់ថា ទៅចុះនាយ ពួកអ្នកឯងចូរនាំបុត្ររបស់យើងមក ដូច្នេះ ទ្រង់ឲ្យបួសដោយឯហិភិក្ខុបព្វជ្ជាហើយ ដែលព្រះកាឡុទាយិត្ថេរៈ ទូលអង្វរឲ្យស្តេចចារិក ទើបមានភិក្ខុមួយសែនរូបជាបរិវារ ស្តេចចេញចាកក្រុងរាជគ្រឹះ ទៅកាន់ក្រុងកបិលពស្តុ ទ្រង់ធ្វើព្រះធម៌ទេសនាដ៏វិចិត្រ មានបាដិហារ្យដោយឥទ្ធិបាដិហារ្យជាច្រើនក្នុងសមាគមនៃព្រះញាតិ ញុំាងមហាជនឲ្យផឹកទឹកអម្រឹតហើយ លុះថ្ងៃទី ២ ទ្រង់កាន់បាត្រ និងចីវរទៅប្រថាប់ឈរត្រង់ទ្វារព្រះនគរ ទ្រង់រំពឹងថា ព្រះសព្វញ្ញុពុទ្ធទាំងឡាយ ទ្រង់ប្រព្រឹត្តការមកកាន់នគរនៃត្រកូលដូចម្តេចហ្ន៎ ដូច្នេះ ទ្រង់ជ្រាបថា ទ្រង់ប្រព្រឹត្តការបិណ្ឌបាតតាមលំដាប់ច្រកផ្លូវ ទើបស្តេចទ្រង់បិណ្ឌបាតតាមលំដាប់ច្រកផ្លូវ ទ្រង់ត្រាស់ធម៌ថ្វាយព្រះរាជា ដែល

ទ្រង់ស្តាប់ដំណឹងថា បុត្ររបស់យើងត្រាច់បិណ្ឌបាត ស្តេចមកហើយ អ្នកមានសក្ការៈ ដែលព្រះរាជបិតាទូលអារាធនាឲ្យស្តេចមកហើយ ទូលអារាធនាឲ្យស្តេចចូលនិវេសន៍របស់ព្រះអង្គ ទ្រង់ធ្វើហើយ ទ្រង់អនុគ្រោះព្រះញាតិដែលទ្រង់គប្បីធ្វើក្នុងទីនោះ ហើយឲ្យរាហុលកុមារបព្វជ្ជា មិនយូរប៉ុន្មាន ក៏ស្តេចចេញចាកពីក្រុងកបិលពស្តុ ចារិកក្នុងមល្លរដ្ឋ ហើយស្តេចត្រឡប់មកកាន់អនុបិយអម្ពវ័ន ។

សម័យនោះ ព្រះបាទសុទ្ធោទនមហារាជ ទ្រង់ប្រជុំសក្យៈត្រកូលទាំងឡាយ ត្រាស់ថា បើបុត្ររបស់យើងនឹងគ្រប់គ្រងផ្ទះ នឹងបានជាស្តេចចក្រពត្តិប្រកបដោយរតនៈ ៧ សូម្បីរាហុលកុមារ នត្តារបស់យើង នឹងហែហមស្តេចចក្រពត្តិនោះត្រាច់ទៅជាមួយពួកក្សត្រិយ៍ មួយទៀត សូមឲ្យពួកអ្នកទាំងឡាយចូរជ្រាបសេចក្តីនេះទុកចុះថា តែឥឡូវនេះ បុត្ររបស់យើងទ្រង់ជាព្រះពុទ្ធហើយ ខត្តិយកុមារចូរជាបរិវាររបស់ព្រះអង្គចុះ ពួកអ្នកចូរឲ្យទារកម្នាក់ពីត្រកូលមួយៗ លុះព្រះបាទសុទ្ធោទនត្រាស់យ៉ាងនេះហើយ ខត្តិយកុមារដល់ពាន់អង្គ ទើបចេញបួសដោយព្រះតម្រាស់តែមួយដងប៉ុណ្ណោះ សម័យនោះ មហានាមជាម្ចាស់នៃកុដុម្ពិកៈ ទើបចូលទៅរកសក្យរាជព្រះនាមថា អនុរុទ្ធ បានពោលពាក្យនេះថា ម្នាលអនុរុទ្ធ ឥឡូវនេះ សក្យកុមារដែលមានឈ្មោះបោះសំឡេង ចេញបួសតាមព្រះដ៏មានព្រះភាគដែលទ្រង់បួសហើយ មិនមាននរណាៗ ចេញបួសពីត្រកូល

របស់យើងឡើយ បើដូច្នោះអ្នកចូរបួស ឬថា បងនឹងបួស អនុរុទ្ធកុមារបាន ស្តាប់តម្រាស់របស់ម្ចាស់បងហើយ មិនត្រេកអរក្នុងការគ្រប់គ្រងផ្ទះ បានចេញបួសជាព្រះអង្គទី ៧ លំដាប់នៃការបួសរបស់ព្រះអនុរុទ្ធនោះ មកហើយក្នុងគម្ពីរសង្ឃភេទខន្ធកៈ ព្រះអនុរុទ្ធស្តេចទៅកាន់អនុបិយអម្ពវ័ន បួសហើយដោយប្រការដូច្នេះ បណ្តាស្តេចសក្យកុមារទាំងនោះ ព្រះភទ្ទិយត្ថេរៈសម្រេចព្រះអរ-ហត្តខាងក្នុងវស្សាទុំ៖ឯង ព្រះអនុរុទ្ធត្ថេរៈធ្វើទិព្វចក្ខុឲ្យកើត ព្រះទេវទត្តធ្វើសមា-បត្តិ ៨ ឲ្យកើត ព្រះអានន្ទត្ថេរៈតាំងនៅក្នុងសោតាបត្តិផល ព្រះភគុត្ថេរៈ និងព្រះកិម្ពិលត្ថេរៈបានសម្រេចអរហត្តក្នុងខាងក្រោយ ក៏អភិនិហារនៃសេចក្តីប្រាថ្នាអំពីកាលមុនរបស់ព្រះថេរៈគ្រប់រូបនោះ នឹងមកដល់ក្នុងរឿងរបស់បុគ្គលម្នាក់ ៗ ។

ក៏ព្រះអនុរុទ្ធត្ថេរៈនេះ រៀនកម្មដ្ឋានក្នុងសំណាក់របស់ព្រះធម៌សេនាបតីហើយ ទៅបំពេញសមណធម៌ឯបាចីនវង្សទាយវ័ន ដែនចេតិយៈ ក៏ត្រិះរិះហើយដល់មហាបរិវិតក្កៈ ៧ ប្រការ លំបាកក្នុងវិតក្កៈទី ៨ ព្រះសាស្តាទ្រង់ជ្រាបថា ព្រះអនុរុទ្ធលំបាកក្នុងមហាបុរិសវិតក្កៈទី ៨ ទ្រង់ព្រះតម្រិះថា តថាគតនឹងធ្វើសេចក្តីត្រិះរិះរបស់គេឲ្យពេញ ទើបស្តេចទៅក្នុងពេលនោះ ប្រថាប់គង់លើពុទ្ធាសនៈដ៏ប្រសើរដែលគេក្រាលទុក ទ្រង់ធ្វើមហាបុរិសវិតក្កៈទី ៨ ឲ្យពេញហើយត្រាស់មហាអរិយវង្សប្រដិបទា ប្រដាប់ទៅដោយសេចក្តីសន្តោស ដោយ

បច្ច័យ ៤ និងមានការនាំជាទីត្រេកអរមកហើយ ស្ដេចហោះទៅដល់កេសក-ឡាវ័ន លុះមពេលព្រះតថាគតស្ដេចទៅហើយប៉ុណ្ណោះ ព្រះថេរៈមានវិជ្ជា ៣ ជាព្រះមហាខីណាស្រពធំ គិតថា ព្រះសាស្ដាជ្រាបចិត្តរបស់យើង ស្ដេចមកប្រទានមហាបុរិសវិតក្កៈទី ៨ ឲ្យពេញ មួយទៀត មនោរថរបស់យើងនោះ ដល់ទីបំផុតហើយ ប្រារព្ធធម៌ទេសនាដ៏ពីរោះរបស់ព្រះពុទ្ធទាំងឡាយ និងធម៌ដែលខ្លួនត្រាស់ដឹងហើយ បានភាសិតឧទានគាថាទាំងនេះថា ៖

ព្រះសាស្ដាទ្រង់ជាកំពូលក្នុងលោក ទ្រង់ជ្រាបសេចក្ដីត្រិះរិះរបស់យើងហើយ ស្ដេចមករកយើងដោយមនោមយិទ្ធិផ្លូវកាយ កាលណាសេចក្ដីត្រិះរិះមានដល់យើង កាលនោះ ព្រះពុទ្ធទ្រង់សម្ដែងធម៌ឲ្យខ្ពស់ឡើងទៅ ព្រះពុទ្ធដែលទ្រង់ត្រេកអរក្នុងធម៌ជាគ្រឿងមិនយឺតយូរ ទ្រង់បានសម្ដែងធម៌ជាគ្រឿងមិនយឺតយូរ យើងដឹងទូទៅដល់ធម៌របស់ព្រះអង្គហើយ ជាអ្នកត្រេកអរក្នុងព្រះសាសនាហើយ វិជ្ជា ៣ យើងក៏សម្រេចដោយលំដាប់ហើយ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ យើងក៏ធ្វើស្រេចហើយ ដូច្នេះ ។

តមកខាងក្រោយ ព្រះសាស្ដាប្រថាប់នៅក្នុងព្រះជេតវ័នមហាវិហារ ទ្រង់ស្ថាបនាលោកទុកក្នុងតំណែងឯតទគ្គៈថា អនុរុទ្ធ ជាកំពូលនៃពួកភិក្ខុជាសាវកដែលមានទិព្វចក្ខុក្នុងសាសនារបស់តថាគត ។

ចប់អដ្ឋកថា សូត្រទី ៥

# អដ្ឋកថាសូត្រទី ៦

## ប្រវត្តិព្រះភទ្ទិយកាឡិគោធាយបុត្រ

*គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៦ ដូចតទៅនេះ ៖*

[១៩៦] *បទថា* **ឧច្ចាកុលិកានំ** *សេចក្តីថា អ្នកកើតក្នុងត្រកូលខ្ពង់ខ្ពស់ ។ បទថា* **ភទ្ទិយោ** *បានដល់ សក្យរាជដែលជាព្រះរាជាចេញព្រះផ្នួសព្រមជាមួយព្រះអនុរុទ្ធត្ថេរៈ ។ បទថា* **កាឡិគោធាយបុត្តោ** *សេចក្តីថា ព្រះទេវីនោះជាអ្នកមានសម្បុរខ្មៅ ។ ចំណែកពាក្យថា* **គោធ** *ជានាមរបស់ព្រះទេវីនោះ ព្រោះដូច្នោះ គេទើបហៅថា* **នាងកាឡិគោធ** *អធិប្បាយថា ជាបុត្ររបស់នាងកាឡិគោធទេវី សួរថា ក៏ព្រះថេរៈនេះ លោកពោលថាជាកំពូលនៃភិក្ខុជាសាវកដែលមានត្រកូលខ្ពង់ខ្ពស់ ព្រោះហេតុអ្វី អ្នកមានត្រកូលខ្ពង់ខ្ពស់ជាងព្រះភទ្ទិយៈនោះមិនមានឬ ។ ឆ្លើយថា មិនមាន ពិតហើយ ព្រះមាតារបស់លោកជាធំបំផុតនៃសក្យត្រកូលទាំងអស់ដោយវ័យក្នុងចំណោមសាកិយានីទាំងឡាយ លោកលះបង់រាជសម្បត្តិដែលមកដល់ក្នុងសក្យត្រកូលនោះឯង ចេញបួស ព្រោះដូច្នោះ លោកទើបពោលថា ជាកំពូលនៃភិក្ខុដែលមានត្រកូលទាំងឡាយ ។ ប្រការមួយទៀត ព្រះភទ្ទិយៈនេះ ដោយអានុភាពនៃសេចក្តីប្រាថ្នាក្នុងកាលមុន កើតក្នុងរាជត្រកូលហើយគ្រងរាជសម្បត្តិដល់ ៥០០ ជាតិ ជាប់តគ្នាមកដោយលំដាប់ ដោយហេតុ*

នេះ លោកទើបពោលថា ព្រះកង្ខរេវតៈនោះ ជាកំពូលលើភិក្ខុដែលមានត្រកូលខ្ពង់ខ្ពស់ ក៏ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលនឹងពោលតាមលំដាប់តទៅនេះ ៖

សេចក្តីពិស្តារថា ក្នុងអតីតកាល សូម្បីព្រះកង្ខរេវតៈនេះ កាលព្រះពុទ្ធព្រះនាមថា **បទុមុត្តរ** លោកកើតក្នុងត្រកូលអ្នកមានភោគសម្បត្តិច្រើន ទៅស្តាប់ព្រះធម៌តាមន័យដែលពោលហើយទុំះឯង ក្នុងថ្ងៃនោះ បានឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូប ទុកក្នុងតំណែងជាកំពូលលើពួកភិក្ខុ ដែលមានត្រកូលខ្ពង់-ខ្ពស់ ទើបគិតថា សូម្បីយើងក៏គួរជាកំពូលលើពួកភិក្ខុអ្នកមានត្រកូលខ្ពង់ខ្ពស់ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយក្នុងអនាគត ដូច្នេះ ទើបអារាធនាព្រះ-តថាគត ថ្វាយមហាទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ៧ ថ្ងៃ ក្រាបទៀបបាទមូល តាំងសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានប្រាថ្នាសម្បត្តិយ៉ាងដទៃដោយផលនៃទាននេះទេ តែក្នុងអនាគតកាល សូមឲ្យខ្ញុំព្រះអង្គគប្បីជាកំពូលលើពួកភិក្ខុដែលមានត្រកូលខ្ពង់ខ្ពស់ ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយចុះ ព្រះសាស្តាទ្រង់ត្រួតមើលអនាគតសម្ដែងឃើញសេចក្តីសម្រេចទើបទ្រង់ព្យាករណ៍ថា កម្មនេះរបស់អ្នក នឹងសម្រេចក្នុងទីបំផុតនៃសែនកប្បរាប់អំពីកប្បនេះទៅ ព្រះពុទ្ធព្រះនាមថា **គោតម** ទ្រង់នឹងឧប្បត្តិឡើង អ្នកនឹងជាកំពូលលើពួកភិក្ខុដែលមានត្រកូលខ្ពង់ខ្ពស់ក្នុងសាសនារបស់ព្រះអង្គ ដូច្នេះ

ហើយទ្រង់ធ្វើអនុមោទនាកត្ត ស្តេចក៏ត្រឡប់ទៅកាន់វិហារ លុះលោកបានស្តាប់ព្យាករណ៍ហើយ ទើបទូលសួរកម្មដែលនឹងឲ្យប្រព្រឹត្តទៅសម្រាប់ភិក្ខុដែលកើតក្នុងត្រកូលខ្ពង់ខ្ពស់ បានធ្វើកម្មដែលល្អដ៏ច្រើនរហូតអស់មួយជីវិតយ៉ាងនេះ គឺសាងធម្មាសនៈ ក្រាលកម្រាលលើធម្មាសនៈនោះ ផ្ចិតសម្រាប់អ្នកសម្តែងធម៌ ប្រាក់បូជាព្រះធម៌សម្រាប់ព្រះធម្មកថិក រោងឧបោសថ ធ្វើកាលៈក្នុងអត្តភាពនោះហើយ វិលវល់នៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងចន្លោះព្រះទសពលព្រះនាមថា **កស្សប** និងព្រះដ៏មានព្រះភាគរបស់យើង មកកើតក្នុងផ្ទះរបស់កុដុម្ពិកៈក្នុងក្រុងពារាណសី ។

សម័យនោះ ព្រះបច្ចេកពុទ្ធច្រើនអង្គមកពីភ្នំគន្ធមាទន៍ គង់ឆាន់បិណ្ឌបាតក្នុងទីដែលសប្បាយ ជិតត្រើយទន្លេគង្គា ក្រុងពារាណសី កុដុម្ពិកៈនោះជ្រាបថា ព្រះបច្ចេកពុទ្ធទាំងនោះ ធ្វើការចែករំលែកភត្តគ្នាក្នុងទីនោះជាប្រចាំ ទើបក្រាលផ្ទាំងថ្មទុក ៨ ផ្ទាំង ទំនុកបម្រុងព្រះបច្ចេកពុទ្ធទាំងឡាយ រហូតអស់ជីវិត តពីនោះ លោកវិលវល់ទៅក្នុងទេវតា និងមនុស្សអស់មួយពុទ្ធន្តរ មកដល់ក្នុងពុទ្ធុប្បាទកាលនេះ ទើបមកកើតក្នុងខត្តិយត្រកូល ក្នុងក្រុងកបិលពស្តុ និងក្នុងថ្ងៃដាក់ព្រះនាម ពួកញាតិទាំងឡាយដាក់ព្រះនាមរបស់លោកថា **ភទ្ទិយ-កុមារ** ភទ្ទិយកុមារនោះ អាស្រ័យបុណ្យជាក្សត្រិយ៍មួយអង្គ ក្នុងរវាងក្សត្រិយ៍

៦ ព្រះអង្គ តាមន័យដែលពោលទុកក្នុងអនុរុទ្ធសូត្រ ក្នុងកាលខាងក្រោយ កាលព្រះសាស្តាប្រថាប់នៅក្នុងអនុបិយអម្ពវ័ន ទ្រង់បួសក្នុងសំណាក់របស់ព្រះសាស្តា ហើយបានសម្រេចព្រះអរហត្ត តមកខាងក្រោយ ព្រះសាស្តាកាលប្រថាប់នៅក្នុងជេតវ័នមហាវិហារ ទ្រង់បានស្ថាបនាទុកក្នុងតំណែងឯតទគ្គៈថា ភទ្ទិយៈ ឱរសរបស់ព្រះនាងកាឡិគោធ ជាកំពូលលើពួកភិក្ខុដែលមានត្រកូលខ្ពង់ខ្ពស់ក្នុងសាសនារបស់តថាគត ។

ចប់ អដ្ឋកថា សូត្រទី ៦

# អដ្ឋកថាសូត្រទី ៧

## ប្រវត្តិព្រះលកុណ្ឌកភទ្ទិយត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៧ ដូចតទៅនេះ ៖

[១៩៦] បទថា **មញ្ជុស្សរានំ** ប្រែថា មានសំឡេងពីរោះ ។ បទថា **លកុណ្ឌកភទ្ទិយោ** សេចក្តីថា លោកពោលដោយចំណែកដ៏ខ្ពស់ ជាអ្នកតឿព្រោះឈ្មោះ ឈ្មោះថា **ភទ្ទិយៈ** ។ ក្នុងបញ្ហាកម្មសូម្បីរបស់ព្រះភទ្ទិយៈនោះ មានរឿងដែលនឹងពោលតាមលំដាប់តទៅនេះ ៖

ពោលដោយពិស្តារ ព្រះថេរៈនេះ កើតក្នុងត្រកូលដែលមានភោគៈច្រើនក្នុងក្រុងហង្សវតី កាលសម័យព្រះពុទ្ធព្រះនាមថា **បទុមុត្តរ** ទៅព្រះវិហារស្តាប់ធម៌តាមន័យដែលពោលហើយនុ៎ះឯង សម័យនោះ លោកឃើញព្រះភិក្ខុដែលមានសំឡេងពីរោះមួយរូប ដែលព្រះសាស្តាទ្រង់ស្ថាបនាទុកក្នុងតំណែងឯតទគ្គៈ កើតចិត្តគិតថា អស្ចារ្យហ្ន៎ តទៅក្នុងអនាគត យើងគប្បីជាកំពូលលើពួកភិក្ខុដែលមានសំឡេងពីរោះក្នុងសាសនារបស់ព្រះពុទ្ធមួយអង្គ ដូចភិក្ខុនេះ ទើបនិមន្តព្រះសាស្តា ថ្វាយមហាទានចំពោះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ៧ ថ្ងៃ ហើយក្រាបចុះទៀបព្រះបាទរបស់ព្រះសាស្តា តាំងសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គដ៏ចម្រើន ដោយផលនៃទាននេះ ខ្ញុំព្រះអង្គមិនបានប្រាថ្នាសម្បត្តិដទៃ តែក្នុង

អនាគតកាល សូមឲ្យខ្ញុំព្រះអង្គគប្បីជាកំពូលលើពួកភិក្ខុដែលមានសំឡេងពីរោះ ក្នុងសាសនារបស់ព្រះពុទ្ធមួយព្រះអង្គចុះ ព្រះសាស្ដាទ្រង់ពិចារណាមើលអនាគត ក៏ទ្រង់ឃើញសេចក្ដីសម្រេច ទើបទ្រង់ព្យាករណ៍ថា កម្មរបស់អ្នកនឹងសម្រេច ក្នុងទីបំផុតនៃសែនកប្បរាប់អំពីកប្បនេះ ព្រះពុទ្ធព្រះនាមថា **គោតម** ទ្រង់នឹងឧប្បត្តិឡើង អ្នកនឹងជាកំពូលលើពួកភិក្ខុដែលមានសំឡេងពីរោះ ក្នុងសាសនារបស់ព្រះអង្គ ដូច្នេះ ហើយស្ដេចត្រឡប់ទៅកាន់ព្រះវិហារ សូម្បីលោកបានព្យាករណ៍នោះហើយ ធ្វើកម្មល្អៗ រហូតអស់មួយជីវិត ធ្វើកាលៈក្នុងអត្តភាពនោះហើយ វិលវល់នៅក្នុងទេវតា និងមនុស្សទាំងឡាយ លុះព្រះសម្មាសម្ពុទ្ធព្រះនាមថា **វិបស្សី** លោកបានកើតជាសត្វតាវៅ មានរោមស្វាយដ៏ស្អាត នៅក្នុងខេមមិគទាយវ័ន ។ ថ្ងៃមួយ ទៅកាន់ហិមវន្តប្រទេស យកមាត់ពាំផ្លែស្វាយដ៏ផ្អែមមក ឃើញព្រះសាស្ដា មានភិក្ខុសង្ឃហែហម ថ្វាយបង្គំហើយ គិតថា ក្នុងថ្ងៃដទៃៗ យើងមានខ្លួនទទេជួបព្រះតថាគត តែថ្ងៃនេះ យើងនាំផ្លែស្វាយទុំនេះមក ដើម្បីបុត្ររបស់យើង តែសម្រាប់បុត្រនោះយើងទៅយកផ្លែដទៃមកឲ្យក៏បាន តែផ្លែនេះ យើងគួរថ្វាយព្រះទសពល ដូច្នេះ ទើបទទះស្លាបហើរទៅក្នុងអាកាស ។ ព្រះសាស្ដាទ្រង់ជ្រាបចិត្តរបស់សត្វ ទើបក្រឡេកមើលព្រះឧប-ដ្ឋាកនាមថា **អសោកត្ថេរៈ** ព្រះថេរៈទើបនាំបាត្រថ្វាយព្រះសាស្ដា សត្វតាវៅបាន

យកផ្លែស្វាយទុំដាក់ទុកក្នុងបាត្ររបស់ព្រះទសពល ។ ព្រះសាស្តាប្រថាប់គង់សោយក្នុងទីនោះឯង ។ សត្វតាវៅមានចិត្តជ្រះថ្លា នឹកដល់ព្រះគុណព្រះទសពលរឿយៗ ថ្វាយបង្គំព្រះទសពលហើយ ទៅកាន់លំនៅរបស់ខ្លួន សម្ងំនៅដោយសុខបីតិ ៧ ថ្ងៃ ។ ក្នុងអត្តភាពនោះ គេធ្វើកល្យាណកម្មទុកមានប្រមាណប៉ុណ្ណោះ ដោយកម្មនេះ គេទើបមានសំឡេងពីរោះ ។

តែសម័យព្រះសម្មាសម្ពុទ្ធព្រះនាមថា **កស្សប** កាលជនទាំងឡាយផ្ដើមសាងចេតិយ អ្នកដទៃៗ និយាយគ្នាថា យើងនឹងសាងទំហំប៉ុនណា យើងសាងទំហំ ៧ យោជន៍ ក៏នឹងធំពេក បើយ៉ាងនោះក៏សាងទំហំ ៦ យោជន៍ សូម្បី ៦ យោជន៍នេះ ក៏ធំពេក យើងនឹងសាង ៥ យោជន៍ យើងនឹងសាង ៤ យោជន៍ ៣ យោជន៍ ២ យោជន៍ ដូច្នេះ ។ ព្រះភទ្ទិយៈនេះ ពេលនោះជាមេជាងធំ និយាយថា លោកដ៏ចម្រើនទាំងឡាយ ការសាង ក៏គួរនឹកដល់ការរក្សាបានងាយក្នុងអនាគតកាលខ្លះ ហើយពោលថា ពីមុខមួយទៅមុខមួយទំហំមួយគាវុត ទំហំចេតិយមួយយោជន៍ ចំណែកកម្ពស់មួយយោជន៍ ដូច្នេះ ជនទាំងនោះក៏ជឿ លោកបានធ្វើតែល្មមប្រមាណចំពោះព្រះពុទ្ធ ដែលទ្រង់ជាបុគ្គលរកប្រមាណមិនបាន ដោយកម្មនោះ ដូចពោលមកនេះ ទើបជាអ្នកមានខ្មាតទាបជាងជនពួកដទៃ ក្នុងទីដែលខ្លួនកើតហើយ ដោយប្រការដូច្នេះ ។

លុះក្នុងសម័យព្រះសាស្តារបស់យើង លោកមកកើតក្នុងត្រកូលដែលមានភោគៈសម្បត្តិច្រើន ក្នុងក្រុងសាវត្ថី ពួកញាតិបានដាក់នាមរបស់លោកថា **កង្ខារេវតៈ** លោកចម្រើនវ័យហើយ កាលព្រះសាស្តាប្រថាប់នៅក្នុងជេតវនមហាវិហារ ទើបទៅកាន់ព្រះវិហារស្តាប់ព្រះធម៌ទេសនា បានសទ្ធាហើយ ទទួលកម្មដ្ឋានក្នុងសំណាក់របស់ព្រះសាស្តា ចម្រើនវិបស្សនា ក៏សម្រេចព្រះអរហត្ត ខាងក្រោយមក ព្រះសាស្តាប្រថាប់គង់កណ្តាលព្រះអរិយសង្ឃ ទ្រង់ស្ថាបនាលោកទុកក្នុងតំណែងដ៏កំពូលលើពួកភិក្ខុ ដែលមានសំឡេងពីរោះ ។

ចប់អដ្ឋកថា សូត្រទី ៧

# អដ្ឋកថាសូត្រទី ៨

## ប្រវត្តិព្រះបិណ្ឌោលភារទ្វាជៈ

*គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៨ ដូចតទៅនេះ ៖*

[១៨៦] *បទថា* ***សីហនាទិកានំ*** *សេចក្តីថា អ្នកបន្លឺសីហនាទ គឺ ព្រះបិណ្ឌោលភារទ្វាជៈជាកំពូល បានឮមកថា ក្នុងថ្ងៃសម្រេចព្រះអរហត្ត លោកកាន់យកសំពត់ទ្រាប់អង្គុយចេញចាកវិហារនេះទៅវិហារឯណោះ ចេញចាកបរិវេណនេះទៅបរិវេណឯណោះ ត្រាច់បន្លឺសីហនាទថា លោកណា មានសេចក្តីសង្ស័យក្នុងមគ្គ ឬផល ចូរសួរយើង ដូច្នេះ លោកឈរចំពោះព្រះភក្ត្រព្រះពុទ្ធទាំងឡាយបន្លឺសីហនាទថា បពិត្រព្រះអង្គដ៏ចម្រើន កិច្ចដែលគួរធ្វើក្នុងសាសនានេះ ដល់ទីបំផុតហើយ ដូច្នោះ ឈ្មោះថា ជាកំពូលនៃពួកភិក្ខុដែលបន្លឺសីហនាទ ក៏ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលនឹងពោលតាមលំដាប់តទៅនេះ ៖*

*បានឮថា សម័យព្រះពុទ្ធព្រះនាមថា* ***បទុមុត្តរ*** *ព្រះបិណ្ឌោលភារទ្វាជៈនេះ កើតក្នុងកំណើតសីហៈ ត្រង់ជើងបព៌ត ព្រះសាស្តាទ្រង់ត្រួតមើលលោកទ្រង់ឃើញហេតុសម្បត្តិរបស់លោក (សេចក្តីដល់ព្រមនៃហេតុ) ទើបស្តេចចារិកបិណ្ឌបាត្រក្នុងក្រុងសាវត្ថី ខាងក្រោយសោយភត្តាហារហើយ ក្នុងវេលាជិតភ្លឺកាលសីហៈចេញទៅរកចំណី ទើបទ្រង់ចូលទៅកាន់ល្អាងទីនៅរបស់សីហៈនោះ*

ប្រថាប់គន់ពត់ភ្នែនក្នុងអាកាសចូលនិរោធសមាបត្តិ ស្តេចសីហៈបានចំណីហើយ ត្រឡប់មកឈប់នៅត្រង់ទ្វារល្អាង ឃើញព្រះទសពលប្រថាប់គន់ខាងក្នុងល្អាង ត្រិះរិះថា មិនមានសត្វដទៃដែលឈ្មោះថា អាចនឹងមកអង្គុយក្នុងទីនៅរបស់យើង បុរសនេះធំណាស់ហ្ន៎ មកអង្គុយពត់ភ្នែនខាងក្នុងល្អាងបាន សូម្បីរស្មីសរីរៈរបស់លោកក៏ផ្សាយទៅដោយជុំវិញ យើងមិនធ្លាប់ឃើញវត្ថុដែលគួរអស្ចារ្យយ៉ាងនេះ បុរសនេះនឹងជាកំពូលរបស់បូជនីយបុគ្គលក្នុងលោកនេះ សូម្បីយើងគួរធ្វើសក្ការៈតាមកម្លាំងថ្វាយព្រះអង្គ ទើបទៅនាំផ្កាឈើផ្សេងៗ ទាំងដែលកើតក្នុងទឹក ទាំងដែលកើតលើគោក ក្រាលជាអាសនៈផ្កាឈើ តាំងពីផ្ទៃដីដរាបដល់ទីអង្គុយ ឈរនមស្ការព្រះតថាគតក្នុងទីចំពោះព្រះភក្ត្ររហូតមួយយប់ទល់ភ្លឺ ថ្ងៃថ្មីឡើង ក៏នាំផ្កាឈើចាស់ចេញ យកផ្កាឈើថ្មីក្រាលអាសនៈដោយទំនងនេះ បានតាក់តែងបុប្ផាសនៈដល់ ៧ ថ្ងៃ កើតបីតិសោមនស្សយ៉ាងខ្លាំង ឈរគាល់នៅត្រង់ទ្វារល្អាង ក្នុងថ្ងៃទី ៧ ព្រះសាស្តាចេញចាកនិរោធ ប្រថាប់ឈរត្រង់ទ្វារល្អាង ស្តេចសីហៈរាជានៃម្រឹគ ធ្វើប្រទក្សិណព្រះតថាគត ៣ ជុំ ថ្វាយបង្គំក្នុងទីទាំង ៤ ហើយថយចេញទៅឈរ ព្រះសាស្តាទ្រង់ត្រិះរិះថា ប៉ុណ្ណេះនឹងល្មមជាឧបនិស្ស័យដល់គេ ក៏ហោះត្រឡប់ទៅព្រះវិហារដូចដើម ចំណែកស្តេចសីហៈនោះកើតទុក្ខព្រោះព្រាត់ចាកព្រះពុទ្ធអង្គ ធ្វើកាលៈហើយ បដិសន្ធិក្នុងត្រកូលមហា-

សាលក្នុងក្រុងហង្សវតី ចម្រើនវ័យហើយ ថ្ងៃមួយទៅព្រះវិហារជាមួយអ្នកក្រុង ស្តាប់ព្រះធម៌ទេសនា បំពេញមហាទាន ៧ ថ្ងៃ ដោយន័យដែលពោលហើយខាងក្រោយ ធ្វើកាលៈក្នុងភពនោះ វិលវល់នៅក្នុងទេវតា និងមនុស្សទាំងឡាយ មកកើតក្នុងត្រកូលព្រាហ្មណ៍មហាសាលក្នុងក្រុងរាជគ្រឹះ ក្នុងពុទ្ធុប្បាទកាលនេះ ដោយមានឈ្មោះថា **ភារទ្វាជៈ** លោកចម្រើនវ័យហើយ សិក្សាត្រៃវេទ ត្រាច់បង្រៀនមន្តដល់មាណព ៥០០ នាក់ លោកទទួលភិក្ខារបស់មាណពគ្រប់រូបដោយខ្លួនឯង ត្រាច់ក្នុងទីដែលគេអញ្ជើញ ព្រោះខ្លួនជាប្រធាន គេថា ភារទ្វាជៈនេះ ជាមនុស្សមានចិត្តរាយមាយ មិនទឹងទីង គឺ ដើរស្វែងរកបបរ បាយ និងរបស់ទំពារ មិនថាក្នុងទីណាៗ ជាមួយមាណពទាំងនេះ ក្នុងទីដែលលោកទៅហើយ ក៏ទទួលត្រឹមតែបបរមួយវែកប៉ុណ្ណោះ ដូច្នោះ ទើបប្រាកដឈ្មោះថា **បិណ្ឌោលភារទ្វាជៈ** ថ្ងៃមួយ កាលព្រះសាស្តាស្តេចយាងដល់ក្រុងរាជគ្រឹះ លោកបានស្តាប់ធម្មកថា បានសទ្ធាហើយ បួសបំពេញវិបស្សនា ក៏បានសម្រេចព្រះ-អរហត្ត ក្នុងវេលាដែលលោកសម្រេចព្រះអរហត្តនុ៎ះឯង លោកកាន់យកសំពត់ក្រាលអង្គុយចេញចាកវិហារនេះ ទៅវិហារឯណោះ ចេញចាកបរិវេណនេះ ទៅបរិវេណឯណោះ ត្រាច់បន្លឺសីហនាទថា លោកណាមានសេចក្តីសង្ស័យក្នុងមគ្គ ឬផល សូមលោកសួរយើងចុះ ។

ថ្ងៃមួយ សេដ្ឋីក្នុងក្រុងរាជគ្រឹះយកឫស្សីតៗ គ្នាឡើងទៅយកបាត្រឈើខ្លឹមច័ន្ទមានពណ៌ដូចផ្កាជ័យព្រឹក្សចងទុកក្នុងអាកាស លោកហោះទៅយកដោយឫទ្ធិ ជាអ្នកដែលមហាជនឲ្យសាធុការហែហមទៅព្រះវិហារ ដាក់ទុកក្នុងព្រះហស្តរបស់ព្រះតថាគត ព្រះសាស្ដាទ្រង់ជ្រាបហើយ សាកសួរថា ភារទ្វាជៈ អ្នកបានបាត្រនេះមកពីណា ទ្រង់ទើបជ្រាបហេតុការណ៍ដែលបានមកថ្វាយ ព្រះសាស្ដាត្រាស់ថា អ្នកសម្ដែងឧត្តរិមនុស្សធម៌បែបនេះដល់មហាជន អ្នកធ្វើកម្មដែលមិនគួរធ្វើហើយ ទ្រង់តិះដៀលដោយអនេកបរិយាយ ហើយទ្រង់បញ្ញត្តសិក្ខាបទថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគួរសម្ដែងឧត្តរិមនុស្សធម៌ ដែលជាឥទ្ធិបាដិហារ្យដល់ពួកគ្រហស្ថទាំងឡាយ អ្នកណាសម្ដែង ត្រូវអាបត្តិទុក្កដ" ដូច្នេះ ពេលនោះកើតការនិយាយគ្នាត្រង់កណ្ដាលភិក្ខុសង្ឃថា ព្រះថេរៈដែលបន្លឺសីហនាទ ក្នុងថ្ងៃដែលលោកសម្រេចព្រះអរហត្ត ប្រាប់ក្នុងកណ្ដាលភិក្ខុសង្ឃថា អ្នកណាមានសេចក្ដីសង្ស័យក្នុងមគ្គ ឬផល អ្នកនោះចូរសួរយើង ដូច្នេះ ក្នុងទីចំពោះព្រះភក្ត្រព្រះពុទ្ធ ក៏ទូលដល់ការសម្រេចព្រះអរហត្តរបស់ខ្លួន ព្រះសាវកពួកដទៃក៏ស្ងៀម ដោយភាពនៃខ្លួនពេញចិត្តបន្លឺសីហនាទនុ៎ះឯង សូម្បីនឹងធ្វើមហាជនឲ្យកើតសេចក្ដីជ្រះថ្លា ហោះទៅយកបាត្រឈើខ្លឹមច័ន្ទ ភិក្ខុទាំងនោះធ្វើគុណទាំង ៣ នេះតែម្យ៉ាង ក្រាបទូលដល់ព្រះសាស្ដាហើយ ក៏ធម្មតាថា ព្រះពុទ្ធទាំងឡាយ

រមែងទ្រង់តិះដៀលបុគ្គលដែលគួរតិះដៀល ទ្រង់រមែងសរសើរបុគ្គលដែលគួរសរសើរ ក្នុងឋានៈនេះ ព្រះសាស្តាទ្រង់ប្រកាសថា ភាពជាកំពូលរបស់ព្រះថេរៈដែលសមគួរសរសើរនោះឯង ហើយសរសើរព្រះថេរៈថា ម្នាលភិក្ខុទាំងឡាយ ព្រោះឥន្ទ្រិយ ៣ ទុំះឯង លោកចម្រើនហើយ ធ្វើឲ្យច្រើនហើយ ការទ្វាជភិក្ខុបានព្យាករណ៍ព្រះអរហត្តដោយខ្លួនឯងថា ជាតិអស់ហើយ ព្រហ្មចរិយៈយើងនៅចប់ហើយ កិច្ចដែលគួរធ្វើយើងធ្វើស្រេចហើយ មិនមានកិច្ចដទៃដើម្បីជាយ៉ាងនេះ ឥន្ទ្រិយ ៣ ដូចម្តេច គឺ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ម្នាលភិក្ខុទាំងឡាយ ព្រោះឥន្ទ្រិយ ៣ ទាំងនេះឯង គេចម្រើនហើយ ធ្វើឲ្យច្រើនហើយ ការទ្វាជភិក្ខុ ព្យាករណ៍ហើយនូវព្រះអរហត្តផល រមែងដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈយើងនៅចប់ហើយ កិច្ចដែលគួរធ្វើធ្វើស្រេចហើយ មិនមានកិច្ចដទៃដើម្បីភាពជាយ៉ាងនេះ ដូច្នេះ ទើបទ្រង់ស្ថាបនាទុកក្នុងតំណែងជាកំពូលនៃពួកភិក្ខុខាងបន្លឺសីហនាទនោះឯង ។

ចប់អដ្ឋកថា សូត្រទី ៨

# អដ្ឋកថាសូត្រទី ៩

## ប្រវត្តិព្រះបុណ្ណមន្តានីបុត្តត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៩ ដូចតទៅនេះ ៖

[១៤៦] ពាក្យថា បុណ្ណមន្តានីបុត្រ គឺ ព្រះថេរៈឈ្មោះថា បុណ្ណៈ ដោយឈ្មោះ តែលោកជាបុត្ររបស់នាងមន្តានីព្រាហ្មណី (ទើបឈ្មោះថា បុណ្ណ-មន្តានីបុត្រ) ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលនឹងពោលតាមលំដាប់ដូចតទៅនេះ ៖

បានឮថា មុនពេលព្រះទសពលព្រះនាមថា **បទុមុត្តរៈ** ទ្រង់ឧប្បត្តិក្នុងលោក បុណ្ណៈកើតក្នុងត្រកូលព្រាហ្មណ៍មហាសាល នាក្រុងហង្សវតី ក្នុងថ្ងៃតាំងនាមលោក ពួកញាតិតាំងនាមថា **គោតមៈ** លោកចម្រើនវ័យហើយរៀនត្រៃវេទ ជាអ្នកឆ្លាតក្នុងសិល្បសាស្ត្រទាំងពួង មានមាណព ៥០០ ជាបរិវារ ត្រាច់ទៅពិចារណាត្រៃវេទមើល ក៏មិនឃើញមោក្ខធម៌ជាគ្រឿងរួចផុត គិតថា ធម្មតាត្រៃវេទនេះ ដូចដើមចេក ខាងក្រៅរលើបរលោង តែខាងក្នុងរកសារៈមិនបាន ការកាន់យកត្រៃវេទនេះត្រាច់ទៅ ក៏ដូចបរិភោគអង្កាម យើងនឹងត្រូវការអ្វីដោយសិល្បៈនេះ ទើបចេញបួសជាឥសី ធ្វើព្រហ្មវិហារឲ្យកើត ជាអ្នកមានឈានមិនសាបសូន្យ ក៏ចូលដល់ព្រហ្មលោក ដូច្នេះ ទើបព្រមជាមួយមាណព ៥០០ នាក់

ទៅកាន់ជើងភ្នំបួសជាឥសី លោកមានជដិល ១៨.០០០ ជាបរិវារ លោកធ្វើអភិញ្ញា ៥ សមាបត្តិ ៨ ឲ្យកើត ហើយប្រាប់កសិណបរិកម្មដល់ជដិលទាំងនោះផង ជដិលទាំងនោះតាំងនៅក្នុងឱវាទរបស់លោក បំពេញជាបបានអភិញ្ញា ៥ សមាបត្តិ ៨ គ្រប់រូប ។

កាលវេលាកន្លងយូរទៅ ក្នុងវេលាដែលគោតមតាបសនោះចាស់ ព្រះបទុមុត្តរៈទសពល ក៏ទ្រង់ត្រាស់ដឹងបរមាភិសម្ពោធិញ្ញាណ ទ្រង់បានប្រកាសព្រះធម្មចក្រដ៏ប្រសើរ មានភិក្ខុមួយសែនរូបជាបរិវារ ទ្រង់អាស្រ័យនៅក្នុងក្រុងហង្សវតី ថ្ងៃមួយ ព្រះទសពលនោះទ្រង់ពិចារណាមើលសត្វលោកក្នុងវេលាជិតភ្លឺ ទ្រង់ឃើញអរហត្តូបនិស្ស័យរបស់បរិស័ទគោតមតាបស និងសេចក្តីប្រាថ្នារបស់គោតមតាបស (ដែលប្រាថ្នាថា សូមឲ្យយើងបានជាកំពូលនៃពួកភិក្ខុដែលជាធម្មកថិក ក្នុងសាសនារបស់ព្រះពុទ្ធដែលទ្រង់នឹងកើតក្នុងកាលខាងមុខចុះ) ទើបជម្រះសរីរៈពីព្រឹកព្រលឹម កាន់បាត្រ និងចីវរដោយព្រះអង្គឯង ស្តេចទៅដោយភេទដែលនរណាៗ មិនស្គាល់ ក្នុងកាលអន្តេវាសិករបស់គោតមតាបសទៅស្វែងរកផ្លែ មើមឈើក្នុងព្រៃ ទ្រង់ទៅប្រថាប់ឈរត្រង់ទ្វារបណ្ណសាលារបស់គោតម-តាបស ចំណែកគោតមតាបសក៏មិនបានជ្រាបថា ព្រះពុទ្ធទ្រង់ឧប្បត្តិឡើងហើយ កាលឃើញព្រះទសពលមកពីចម្ងាយនោះឯង ក៏ជ្រាបបានថា បុរសអ្នកនេះប្រាកដ

ជាបុគ្គលផុតលោកហើយ ដូចសេចក្តីសម្រេចនៃសរីរៈរបស់ព្រះអង្គ ដែលប្រកប ដោយចក្កលក្ខណៈ បើគ្រប់គ្រងផ្ទះ ក៏នឹងជាស្តេចចក្រពត្តិ បើចេញបួសក៏នឹង ជាព្រះសព្វញ្ញុពុទ្ធ អ្នកមានកិលេសដូចដំបូលបើកហើយ ដូច្នេះ ទើបថ្វាយបង្គំ ព្រះទសពល ដោយការជួបលើកដំបូងប៉ុណ្ណោះ ទូលថា បពិត្រព្រះដ៏មានព្រះភាគ សូមទ្រង់អនុគ្រោះប្រថាប់ត្រង់នេះ ហើយបានក្រាលអាសនៈថ្វាយ ព្រះតថាគត ប្រថាប់គង់សម្តែងធម៌ដល់គោតមតាបស ខណៈនោះពួកជដិលទាំងនោះមក ដោយ សម្គាល់ថា នឹងឲ្យផ្លែ មើមឈើក្នុងព្រៃដែលប្រណីតៗ ដល់អាចារ្យ ចំណែក ដែលនៅសល់នឹងបរិភោគខ្លួនឯង ដូច្នេះ ឃើញព្រះទសពលប្រថាប់គង់លើ អាសនៈខ្ពស់ តែអាចារ្យអង្គុយលើអាសនៈក្រោម ក៏សន្ទនាគ្នាថា ពួកយើងគិត គ្នាថា ក្នុងលោកនេះមិនមាននរណាដែលក្រៃលែងជាងអាចារ្យរបស់យើង តែ ឥឡូវនេះប្រាកដថា បុរសនេះតែម្នាក់ ឲ្យអាចារ្យរបស់យើងអង្គុយលើអាសនៈ ទាប ខ្លួនឯងអង្គុយលើអាសនៈខ្ពស់ មនុស្សនេះមាននាទីជាធំហ្ន៎ ដូច្នេះ តាបស ខ្លះទៀតកាន់កន្ត្រកនាំគ្នាមក គោតមតាបសក្រែងថា ជដិលទាំងនេះនឹងថ្វាយបង្គំ ខ្លួនក្នុងសំណាក់ព្រះទសពល ទើបពោលថា បាទាំងឡាយ អ្នកកុំថ្វាយបង្គំយើង បុគ្គលដែលប្រសើរបំផុតក្នុងលោកព្រមទាំងទេវលោក ជាបុគ្គលគួរដល់លោក គ្រប់គ្នាថ្វាយបង្គំ លោកទាំងឡាយ ចូរថ្វាយបង្គំបុរសម្នាក់នេះ តាបសទាំងឡាយ

គិតថា លោកអាចារ្យបើលោកមិនដឹងគង់នឹងមិននិយាយ ទើបថ្វាយបង្គំព្រះបាទនៃព្រះតថាគតគ្រប់គ្នា គោតមតាបសពោលថា បាទាំងឡាយ យើងមិនមានភោជនយ៉ាងដទៃដែលសមគួរថ្វាយចំពោះព្រះទសពល យើងនឹងថ្វាយ ផ្លែឈើ មើមឈើក្នុងព្រៃនេះ ទើបជ្រើសរើសផ្លែដែលប្រណីតៗ ដាក់ចូលក្នុងបាត្ររបស់ព្រះពុទ្ធថ្វាយហើយ ព្រះសាស្តាសោយផ្លែឈើ មើមឈើក្នុងព្រៃហើយ តពីនោះ សូម្បីតាបស និងអន្តេវាសិកទើបឆាន់ ព្រះសាស្តាសោយស្រេចហើយទ្រង់ព្រះតម្រិះថា ព្រះអគ្គសាវកទាំង ២ ចូរនាំភិក្ខុមួយសែនរូបមក ក្នុងខណៈនោះ ព្រះមហាវិមលត្ថេរៈអគ្គសាវករឭកថា ព្រះសាស្តាស្តេចទៅទីណាហ្ន៎ បានជ្រាបថា ព្រះសាស្តាទ្រង់បំណងឲ្យយើងទៅ ទើបនាំភិក្ខុមួយសែនរូបទៅគាល់ ថ្វាយបង្គំហើយព្រះតាបសពោលនឹងអន្តេវាសិកថា បាទាំងឡាយ ពួកយើងមិនមានសក្ការៈដទៃ(ទាំង) ភិក្ខុសង្ឃក៏ឈរលំបាក យើងនឹងក្រាលបុប្ផាសនៈថ្វាយភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន លោកទាំងឡាយចូរទៅនាំយកផ្កាឈើដែលកើតទាំងលើគោកទាំងក្នុងទឹកមកចុះ ក្នុងវេលានោះឯង តាបសទាំងនោះ ទើបនាំយកផ្កាឈើដែលសម្បូរណ៍ដោយពណ៌ និងក្លិនមកពីជើងភ្នំដោយឫទ្ធិ ក្រាលអាសនៈទាំងឡាយដោយន័យដូចពោលទុកក្នុងរឿងរបស់ព្រះសារីបុត្តត្ថេរៈនោះឯង ការចូលនិរោធ-សមាបត្តិក្តី ការបាំងឆត្រក្តី គ្រប់រឿង គប្បីជ្រាបដោយន័យដែលពោលហើយ

នោះឯង ។

ក្នុងថ្ងៃទី ៧ ព្រះសាស្ដាទ្រង់ចេញចាកនិរោធសមាបត្តិ ទ្រង់ឃើញតាបសទាំងឡាយឈរលោមព័ទ្ធហើយ ទើបត្រាស់ហៅព្រះសាវកអ្នកសម្រេចឯតទគ្គៈក្នុងភាពជាព្រះធម្មកថិក ទ្រង់ត្រាស់ថា ម្នាលភិក្ខុ ពួកឥសីនេះបានធ្វើសក្ការៈធំ អ្នកចូរធ្វើអនុមោទនាបុប្ផាសនៈដល់ពួកឥសីទាំងនេះ ភិក្ខុនោះទទួលព្រះពុទ្ធតម្រាស់ហើយ ពិចារណាព្រះត្រៃបិដកធ្វើអនុមោទនា វេលាចប់ទេសនារបស់ភិក្ខុនោះ ព្រះសាស្ដាទ្រង់ថ្លែងព្រះសូរសៀងដូចសំឡេងព្រហ្ម សម្ដែងធម៌ដោយព្រះអង្គឯងកាលចប់ទេសនា (វៀរ) គោតមតាបសចេញ ជដិល ១៨.០០០ រូប ដ៏សេសបានសម្រេចព្រះអរហត្ត ចំណែកគោតមតាបសមិនអាចធ្វើការត្រាស់ដឹងដោយអត្តភាពនោះ ទើបក្រាបទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះដ៏មានព្រះភាគ ភិក្ខុដែលសម្ដែងធម៌មុននេះ ឈ្មោះអ្វី ក្នុងសាសនារបស់ព្រះអង្គ ។ (ព្រះអង្គ) ត្រាស់ថា គោតមតាបស ភិក្ខុនេះ ជាកំពូលលើពួកភិក្ខុដែលជាធម្មកថិក ក្នុងសាសនារបស់តថាគត គោតមតាបសក្រាបទៀបបាទមូល ធ្វើសេចក្ដីប្រាថ្នាថា បពិត្រព្រះអង្គដ៏ចម្រើនដោយផលនៃបុណ្យដែលខ្ញុំព្រះអង្គធ្វើមក ៧ ថ្ងៃនេះ ខ្ញុំព្រះអង្គគប្បីជាកំពូលលើពួកភិក្ខុដែលជាធម្មកថិក ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយក្នុងអនាគត ដូចភិក្ខុរូបនេះ ព្រះសាស្ដាទ្រង់ពិចារណាមើលអនាគតកាល

ក៏ទ្រង់ជ្រាបថា សេចក្តីប្រាថ្នារបស់គោតមតាបសនោះ នឹងបានសម្រេចដោយរកអន្តរាយមិនបានហើយ ទ្រង់ព្យាករណ៍ថា ក្នុងទីបំផុតនៃសែនកប្ប ក្នុងអនាគតកាលព្រះពុទ្ធព្រះនាមថា **គោតម** នឹងទ្រង់ឧប្បត្តិឡើង អ្នកនឹងជាកំពូលលើពួកភិក្ខុដែលជាធម្មកថិកក្នុងសាសនារបស់ព្រះអង្គ ហើយត្រាស់ចំពោះតាបសដែលសម្រេចព្រះអរហត្តថា **៦៨ ភិក្ខុវេ** ចូរជាភិក្ខុមកចុះ ដូច្នេះ តាបសគ្រប់រូប មានសក់ និងពុកមាត់អន្តរធានទៅ ប្រដាប់បាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ ហាក់ដូចជាព្រះថេរៈ ១០០ វស្សា ព្រះសាស្តាទ្រង់នាំភិក្ខុសង្ឃ ស្តេចត្រឡប់ទៅកាន់ព្រះវិហារ ចំណែកគោតមតាបសក៏ទំនុកបម្រុងព្រះតថាគត ដរាបអស់ជីវិត បំពេញតែកល្យាណកម្មតាមកម្លាំង វិលវល់នៅក្នុងទេវតា និងមនុស្សទាំងឡាយក្នុងសែនកប្ប លុះសម័យព្រះដ៏មានព្រះភាគរបស់យើង ទើបមកកើតក្នុងត្រកូលព្រាហ្មណ៍មហាសាល ក្នុងស្រុកព្រាហ្មណ៍ ឈ្មោះទោណវត្ថុ មិនឆ្ងាយពីក្រុងកបិលពស្តុ ក្នុងថ្ងៃដាក់នាមរបស់លោក ពួកញាតិដាក់នាមលោកថា **បុណ្ណមាណព** ។

កាលព្រះសាស្តាទ្រង់ត្រាស់ដឹងអភិសម្ពោធិញ្ញាណ ទ្រង់ប្រកាសធម្មចក្កដ៏ប្រសើរ ស្តេចដំណើរមកដោយលំដាប់ ចូលអាស្រ័យនៅក្រុងរាជគ្រឹះ ព្រះអញ្ញាកោណ្ឌញ្ញត្ថេរៈ មកកាន់ក្រុងកបិលពស្តុ ឲ្យបុណ្ណមាណពជាក្មួយប្រុសរបស់

ខ្លួនបួស លុះព្រឹកឡើង ទើបមកគាល់ព្រះទសពល ថ្វាយបង្គំហើយ ក៏ទូលលា ទៅកាន់ជនទូន្ទស្រះដើម្បីសម្រាកពេលថ្ងៃ ចំណែកព្រះបុណ្ណមន្តានីបុត្រ មកគាល់ព្រះទសពលព្រមជាមួយព្រះអញ្ញាកោណ្ឌញ្ញត្ថេរៈដែលជាអ៊ំ គិតថា យើងនឹងធ្វើកិច្ចនៃបព្វជិតរបស់យើងឲ្យដល់ទីបំផុត ទើបនឹងទៅគាល់ព្រះទសពល ដូច្នេះ ទើបត្រូវទុកឲ្យនៅក្នុងក្រុងកបិលភស្តុទ៌ុះឯង ធ្វើយោនិសោមនសិការកម្មដ្ឋាន មិនយូរប៉ុន្មានក៏សម្រេចព្រះអរហត្ត មានកុលបុត្រចេញបួសក្នុងសំណាក់របស់លោកដល់ ៥០០ រូប ព្រះថេរៈនោះឯងបានកថាវត្ថុ ១០ ទើបទូន្មានសូម្បីដល់បព្វជិតទាំងនោះដោយកថាវត្ថុ ១០ បព្វជិតទាំងនោះតាំងនៅក្នុងឱវាទរបស់លោក ក៏បានសម្រេចព្រះអរហត្តគ្រប់ៗ រូប ភិក្ខុទាំងនោះដឹងថា កិច្ចនៃបព្វជិតរបស់ខ្លួនដល់ទីបំផុតហើយ ទើបចូលទៅរកព្រះឧបជ្ឈាយ៍ពោលថា លោកដ៏ចម្រើន កិច្ចរបស់ពួកខ្ញុំ និងអ្នកបានមហាកថាវត្ថុ ១០ ដល់ទីបំផុតហើយ ជាសម័យដែលពួកខ្ញុំនឹងគាល់ព្រះទសពល ព្រះថេរៈស្តាប់ពាក្យរបស់ភិក្ខុទាំងនោះហើយ ទើបគិតថា ព្រះសាស្តាទ្រង់ជ្រាបថា យើងបានកថាវត្ថុ ១០ កាលយើងសម្តែងធម៌ ក៏សម្តែងមិនផុតពីកថាវត្ថុ ១០ កាលយើងទៅ ភិក្ខុទាំងអស់នេះក៏នឹងហែហម ទៅ ក៏ការទៅដោយប្រចូកប្រចល់ដោយពួកគណៈយ៉ាងនេះ ចូលគាល់ព្រះទស-ពលរបស់យើងក៏មិនគួរ ភិក្ខុទាំងនេះចូរទៅគាល់មុន ដូច្នេះ ទើបពោលនឹងភិក្ខុ

ទាំងនោះថា អាវុសោ លោកទាំងឡាយចូរទៅមុន ទៅគាល់ព្រះតថាគត និង ចូរក្រាបថ្វាយបង្គំព្រះបាទរបស់ព្រះអង្គតាមពាក្យរបស់យើង សូម្បីយើងក៏នឹង ទៅតាមផ្លូវដែលលោកទៅហើយដែរ ដូច្នេះ ភិក្ខុទាំងនោះគ្រប់រូបសុទ្ធតែនៅក្នុង ប្រទេសដែលជាជាតិភូមិតែមួយជាមួយព្រះទសពល ទាំងអស់ជាព្រះខីណាស្រព បានកថាវត្ថុ ១០ គ្រប់រូប ទ្រេកអរក្រៃលែងនូវឱវាទរបស់ឧបជ្ឈាយ៍របស់ខ្លួន ថ្វាយបង្គំព្រះថេរៈហើយ ត្រាច់ចារិកទៅដោយលំដាប់ កន្លងផ្លូវអស់ ៦០ យោជន៍ ដរាបដល់ព្រះជេតវនមហាវិហារក្នុងក្រុងរាជគ្រឹះ ថ្វាយបង្គំព្រះបាទាព្រះទសពល ហើយ នាំគ្នាអង្គុយនៅក្នុងទីដែលសមគួរមួយ ។

ក៏នេះជាអាចិណ្ណវត្តរបស់ព្រះដ៏មានព្រះភាគទាំងឡាយ ដែលទ្រង់រីករាយ ទទួលអាគន្តុកៈភិក្ខុទាំងឡាយ ដូច្នោះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើបដិសណ្ឋារៈ ដោយមធុរវាចានឹងភិក្ខុទាំងនោះ ដោយន័យមានជាដើមថា **កច្ចិ ភិក្ខវេ ខមនីយំ** ល្មមអត់ទ្រាំបានឬភិក្ខុទាំងឡាយ ហើយត្រាស់សួរថា ពួកអ្នកមកពីណា កាល ភិក្ខុទាំងនោះទូលតបថា ពីជាតិភូមិ ទើបត្រាស់សួរភិក្ខុដែលបានកថាវត្ថុ ១០ ថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុដែលជាព្រហ្មចារីអ្នកនៅជាតិភូមិដូចគ្នាបានសរសើរ អ្នកណាហ្ន៎យ៉ាងនេះថា ខ្លួនឯងក៏ប្រាថ្នាតិចផង ទូន្មានភិក្ខុទាំងឡាយឿងប្រាថ្នា តិចផង ដូច្នេះ ភិក្ខុទាំងឡាយក្រាបទូលថា ព្រះអង្គ លោកឈ្មោះថា បុណ្ណមន្តានី-

បុត្រ ព្រះអង្គ ព្រះសារីបុត្របានស្តាប់ពាក្យនោះ ទើបជាអ្នកប្រាថ្នាដើម្បីនឹងជួប ព្រះថេរៈ គ្រានោះ ព្រះសាស្តាស្តេចបានចេញពីក្រុងរាជគ្រឹះ ទៅកាន់ក្រុងសាវត្ថី ព្រះបុណ្ណត្ថេរៈបានឮថា ព្រះទសពលស្តេចមកក្រុងសាវត្ថី ទើបគិតថា យើងនឹង គាល់ព្រះសាស្តា ទើបចេញដើរទៅដោយទាន់ បានគាល់ព្រះតថាគតខាងក្នុង ព្រះគន្ធកុដិនោះឯង ព្រះសាស្តាទ្រង់សម្តែងធម៌ដល់លោក ព្រះថេរៈស្តាប់ធម៌ ហើយ ថ្វាយបង្គំព្រះទសពល ហើយទៅកាន់ព្រៃអន្ធវ័នដើម្បីពួនសម្ងំ ទើប អង្គុយសម្រាកពេលថ្ងៃត្រង់គល់ឈើមួយដើម សូម្បីព្រះសារីបុត្តត្ថេរៈជ្រាបថា លោកមក សម្លឹងរកមើលទិស ហើយដើរទៅកំណត់ឱកាសចូលទៅកាន់គល់ឈើ នោះ ហើយសន្ទនាជាមួយព្រះថេរៈ សួរដល់លំដាប់នៃវិសុទ្ធិ ៧ សូម្បីព្រះថេរៈ ក៏ព្យាករណ៍ដល់លោកដែលសួរហើយសួរទៀត ព្រះថេរៈទាំងពីរនោះ បានអនុ-មោទនាសុភាសិតរបស់គ្នានិងគ្នា តមកខាងក្រោយមក ព្រះសាស្តាទ្រង់ប្រថាប់ គង់កណ្តាលភិក្ខុសង្ឃ ទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងជាកំពូលលើពួកភិក្ខុ ដែលជាធម្មកថិកនោះឯង ។

ចប់អដ្ឋកថា សូត្រទី ៩

# អដ្ឋកថាសូត្រទី ១០

## ប្រវត្តិព្រះមហាកច្ចាយនត្ថេរៈ

*គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ១០ ដូចតទៅនេះ ៖*

*[១៨៦] បទថា **សង្ខិត្តេន ភាសិតស្ស** សេចក្តីថា នៃធម៌ដែលត្រាស់ទុកដោយសង្ខេប ។ បទថា **វិត្ថារេន អត្ថំ វិភជន្តានំ** សេចក្តីថា ចែកអត្ថចេញធ្វើទេសនានោះឲ្យពិស្តារ ។ ន័យថា ភិក្ខុពួកដទៃមិនអាចធ្វើព្រះតម្រាស់ដោយសង្ខេបរបស់ព្រះតថាគតឲ្យបរិបូណ៌ ទាំងដោយអត្ថទាំងដោយព្យញ្ជនៈបាន តែព្រះថេរៈនេះ អាចធ្វើឲ្យបរិបូណ៌បានសូម្បីទាំង ២ យ៉ាង ព្រោះដូច្នោះ លោកទើបពោលថាជាកំពូល ។ ក៏សូម្បីសេចក្តីប្រាថ្នាពីកាលមុនរបស់ព្រះថេរៈនោះក៏ជាយ៉ាងនេះ ។ មួយទៀត ក្នុងបញ្ហាកម្មរបស់ព្រះថេរៈនោះ មានរឿងដែលនឹងពោលតាមលំដាប់ដូចតទៅនេះ ៖*

*បានឮថា សម័យព្រះសម្មាសម្ពុទ្ធព្រះនាមថា **បទុមុត្តរៈ** ព្រះថេរៈនោះកើតក្នុងត្រកូលគហបតីមហាសាល ចម្រើនវ័យហើយ ថ្ងៃមួយទៅវិហារ តាមន័យដែលពោលហើយនោះឯង ស្តាប់ធម៌នៅខាងក្រោយបរិស័ទ ឃើញភិក្ខុមួយរូបដែលព្រះសាស្តាទ្រង់ស្ថាបនាទុកក្នុងតំណែងជាកំពូលលើភិក្ខុ ដែលចែកអត្ថនៃព្រះតម្រាស់ដែលព្រះអង្គត្រាស់ដោយសង្ខេបឲ្យពិស្តារ ទើបគិតថា ភិក្ខុដែល*

ព្រះសាស្ដាទ្រង់សរសើរយ៉ាងនេះ ជាជំហ៊ាន សូមឲ្យក្នុងអនាគតកាល យើងក៏គួរជាភិក្ខុដូចនេះក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយ ដូច្នេះ ។ ទើបនិមន្តព្រះសាស្ដាថ្វាយមហាទាន ៧ ថ្ងៃ តាមន័យដែលពោលហើយនោះឯង ។ ក្រាបចុះទៀបបាទមូលរបស់ព្រះសាស្ដា ធ្វើសេចក្ដីប្រាថ្នាថា បពិត្រព្រះអង្គ ដោយផលនៃសក្ការៈនេះ ខ្ញុំព្រះអង្គមិនប្រាថ្នាសម្បត្តិដទៃ តែក្នុងអនាគតកាល សូមខ្ញុំព្រះអង្គគប្បីបានតំណែងនេះក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយ ដូចភិក្ខុដែលព្រះអង្គទ្រង់ស្ថាបនាទុកក្នុងតំណែងក្នុងថ្ងៃចុងក្រោយ ៧ ថ្ងៃ រាប់ពីថ្ងៃនេះ ព្រះសាស្ដាទ្រង់ត្រួតមើលអនាគតកាល ទ្រង់ឃើញថា សេចក្ដីប្រាថ្នារបស់កុលបុត្រនេះនឹងបានសម្រេច ទើបទ្រង់ព្យាករណ៍ថា កុលបុត្រដ៏ចម្រើន ក្នុងទីបំផុតនៃសែនកប្ប ក្នុងអនាគត ព្រះពុទ្ធព្រះនាមថា **គោតម** ទ្រង់នឹងឧប្បត្តិឡើង អ្នកនឹងជាកំពូលលើពួកភិក្ខុដែលចែកអត្ថនៃពាក្យដែលត្រាស់ដោយសង្ខេបឲ្យពិស្ដារ ក្នុងសាសនារបស់ព្រះអង្គ ដូច្នេះ ទ្រង់ធ្វើអនុមោទនាហើយស្ដេចត្រឡប់ទៅ ។

ចំណែកកុលបុត្រនោះ បំពេញកុសលរហូតអស់ជីវិត ហើយវិលវល់ក្នុងទេវតា និងមនុស្សទាំងឡាយអស់សែនកប្ប គ្រាព្រះកស្សបសម្ពុទ្ធ ក៏មកបដិសន្ធិក្នុងត្រកូលនាក្រុងពារាណសី កាលព្រះសាស្ដាបរិនិព្វានហើយ ក៏ទៅកាន់ស្ថានទីសាងចេតិយមាស ទើបយកឥដ្ឋមាសមានតម្លៃមួយសែនបូជា តាំង

សេចក្តីប្រាថ្នាថា បពិត្រព្រះដ៏មានព្រះភាគ សរីរៈរបស់ខ្ញុំព្រះអង្គ ចូរមានវណ្ណៈដូចជាមាសក្នុងទីដែលកើតហើយចុះ ។ តអំពីនោះ ក៏ធ្វើកុសលកម្មរហូតជីវិត វិលវល់ក្នុងទេវតា និងមនុស្សមួយពុទ្ធន្តរ គ្រាព្រះទសពលរបស់យើងឧប្បត្តិ មកកើតក្នុងផ្ទះនៃបុរោហិត ក្នុងក្រុងឧជ្ជេនី ក្នុងថ្ងៃដាក់នាមលោក មាតាបិតាប្រឹក្សាគ្នាថា បុត្ររបស់យើងមានសរីរៈមានសម្បុរដូចជាមាស គង់នឹងកាន់យកឈ្មោះរបស់ខ្លួនមកហើយ ទើបដាក់នាមលោកថា កញ្ចនមាណព ដូច្នេះ ។

ពេលលោកចម្រើនវ័យហើយក៏សិក្សាត្រៃវេទ កាលបិតាអស់ជន្មាហើយ ក៏បានតំណែងបុរោហិតជំនួស ដោយគោត្រឈ្មោះថា កច្ចាយនៈ ព្រះបាទចណ្ឌបជ្ជោតទ្រង់ប្រជុំអាមាត្រ ហើយមានព្រះរាជតម្រាស់ថា ព្រះពុទ្ធទ្រង់កើតឡើងក្នុងលោកហើយ ពួកអ្នកគប្បីជាអ្នកអាចនឹងទូលនាំព្រះអង្គមកបាន ក៏ចូរនាំព្រះអង្គមក អាមាត្រទូលថា បពិត្រសម្មតិទេព អ្នកដទៃឈ្មោះថា ជាអ្នកអាចនឹងនាំព្រះទសពលមកមិនមាន អាចារ្យកញ្ចនព្រាហ្មណ៍ប៉ុណ្ណោះ អាច សូមទ្រង់បញ្ជូនលោកទៅចុះព្រះអង្គ ព្រះរាជាត្រាស់ហៅឲ្យកច្ចាយនៈមក ត្រាស់បង្គាប់ថា បា! ចូរទៅកាន់សំណាក់របស់ព្រះទសពល (អាចារ្យ) ទូលថា បពិត្រមហារាជ កាលខ្ញុំព្រះអង្គទៅហើយ បានបួសទើបនឹងទៅ ព្រះរាជាត្រាស់ថា អ្នកនឹងធ្វើយ៉ាងណាមួយ ហើយក៏នាំព្រះតថាគតមកចុះ ។ កច្ចាយនអាមាត្រនោះ គិតថា សម្រាប់

អ្នកទៅសំណាក់របស់ព្រះពុទ្ធ មិនចាំបាច់ធ្វើដោយមនុស្សចំនួនច្រើនទេ ទើបទៅត្រឹមតែ ៨ នាក់ ។ គ្រានោះ ព្រះសាស្តាទ្រង់សម្តែងធម៌ដល់អាមាត្រនោះ ចប់ទេសនា លោកបានសម្រេចព្រះអរហត្តព្រមទាំងបដិសម្ភិទាជាមួយជនទាំង ៧ នាក់ ព្រះសាស្តាទ្រង់លាព្រះហស្តត្រាស់ថា **ឯថ ភិក្ខវោ** (អ្នកទាំងឡាយចូរជាភិក្ខុចុះ) ក្នុងខណៈនោះឯង គ្រប់ៗ គ្នាក៏មានសក់ និងពុកមាត់វិនាសទៅ ប្រដាប់បាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ ដូចជាព្រះថេរៈ ១០០ វស្សា ដូច្នោះ ។ ព្រះថេរៈកាលកិច្ចរបស់ខ្លួនដល់ទីបំផុតហើយមិនអង្គុយស្ងៀម ពោលសរសើរការស្តេចទៅក្រុងឧជ្ជេនីថ្វាយព្រះសាស្តា ដូចព្រះកាឡុទាយិត្ថេរៈ ព្រះសាស្តាស្តាប់ពាក្យរបស់លោកហើយ ទ្រង់ជ្រាបថា កច្ចាយនៈរមែងប្រាថ្នាការទៅរបស់យើងក្នុងជាតិភូមិរបស់ខ្លួន តែធម្មតាព្រះពុទ្ធទាំងឡាយទ្រង់អាស្រ័យហេតុណាមួយ ទើបស្តេចមិនទៅកាន់ទីដែលមិនសមគួរ ។ ព្រោះដូច្នោះ ទើបត្រាស់ចំពោះព្រះថេរៈថា ភិក្ខុ អ្នកនោះឯងចូរទៅ កាលអ្នកទៅហើយ ព្រះរាជាទ្រង់នឹងជ្រះថ្លា ព្រះថេរៈគិតថា ព្រះពុទ្ធទាំងឡាយមិនត្រាស់ពាក្យជាពីរ ដូច្នេះ ទើបថ្វាយបង្គំព្រះតថាគត ទៅកាន់ក្រុងឧជ្ជេនីព្រមជាមួយភិក្ខុទាំង ៧ រូប ដែលមកព្រមនឹងខ្លួនទុំះឯង ក្នុងរវាងផ្លូវភិក្ខុទាំងនោះ បានត្រាច់បិណ្ឌបាតក្នុងនិគមឈ្មោះថា នាលិនិគម ។

ក្នុងនិគមនោះ មានធីតាសេដ្ឋី ២ នាក់ ម្នាក់កើតក្នុងត្រកូលកំសត់ កាលមាតាបិតាស្លាប់ទៅហើយ ក៏អាស្រ័យស្រីបម្រើចិញ្ចឹមជីវិត ។ តែអត្តភាពរបស់នាងរឹងមាំ សក់វែងជាងអ្នកដទៃៗ ។ ក្នុងនិគមនោះនុ៎ះឯង នៅមានធីតារបស់ត្រកូលសេដ្ឋីម្នាក់ទៀត ជាអ្នកមិនមានសក់ កាលមុននោះ មកសូម្បីនាង នឹងពោលថា សូមឲ្យនាង (កាត់សក់) បញ្ជូនឲ្យទៅខ្ញុំ ខ្ញុំនឹងឲ្យទ្រព្យ ១០០ ឬ ១,០០០ ដល់នាង ក៏ឲ្យគេនាំសក់មកមិនបាន ក៏ក្នុងថ្ងៃនោះ ធីតាសេដ្ឋីនោះឃើញព្រះមហាកច្ចាយនត្ថេរៈមានភិក្ខុ ៧ រូបជាបរិវារ ដើរមកមានបាត្រទទេគិតថា ភិក្ខុដែលជាផៅពង្សព្រាហ្មណ៍មួយរូប មានសម្បុរដូចមាសដើរទៅបាត្រទទេ ទ្រព្យយ៉ាងដទៃរបស់យើងក៏មិនមាន ប៉ុន្តែថា ធីតាសេដ្ឋីស្រុកឯណោះ (ធ្លាប់) បញ្ជូន (មនុស្ស) មក ដើម្បីត្រូវការសក់នេះ ពេលនេះយើងអាចថ្វាយទេយ្យធម៌ដល់ព្រះថេរៈបានដោយទ្រព្យដែលកើតពីការបានតម្លៃសក់នេះ ដូច្នេះទើបបញ្ជូនស្រីបម្រើទៅនិមន្តព្រះថេរៈទាំងឡាយឲ្យគង់ខាងក្នុងផ្ទះ ពេលព្រះថេរៈគង់ហើយ (នាង) ក៏ចូលបន្ទប់កាត់សក់របស់ខ្លួន ពោលថា ម្នាលនាង ចូរយកសក់ទាំងនេះឲ្យដល់ធីតាសេដ្ឋីស្រុកឯណោះ ហើយយករបស់ដែលនាងឲ្យមក យើងនឹងថ្វាយបិណ្ឌបាតដល់លោកម្ចាស់ទាំងឡាយ ។ ស្រីបម្រើយកខ្នងដៃជូតទឹកភ្នែក យកដៃម្ខាងក្តោបទុកត្រង់ទ្រូង បិទបាំងទុកក្នុងសំណាក់ព្រះថេរៈទាំងឡាយ

កាន់សក់នោះទៅកាន់សំណាក់របស់ធីតាសេដ្ឋី ។ ធម្មតាដែលឈ្មោះថា របស់ដែលត្រូវលក់ សូម្បីមានសារៈ (តម្លៃ) ម្ចាស់របស់នាំទៅឲ្យខ្លួនឯង ក៏មិនធ្វើឲ្យកើតសេចក្ដីក្រែងចិត្ត ។ ដូច្នោះ ធីតាសេដ្ឋីទើបគិតថា កាលមុន យើងមិនអាចនឹងឲ្យនាំសក់ទាំងនេះមកបានដោយទ្រព្យជាច្រើន តែឥឡូវនេះ តាំងពីវេលាកាត់ចេញហើយ ក៏មិនបានតាមតម្លៃដូចដើម ទើបពោលនឹងស្រីបម្រើថា កាលមុនខ្ញុំមិនអាចឲ្យនាំសក់មកសូម្បីដោយទ្រព្យជាច្រើន តែសក់នេះនាំទៅទីណាៗក៏បាន មិនមែនសក់របស់អ្នករស់ មានតម្លៃតែ ៨ កហាបណៈ ទើបឲ្យទៅ ៨ កហាបណៈប៉ុណ្ណោះ ស្រីបម្រើបាននាំកហាបណៈទៅប្រគល់ឲ្យដល់ធីតាសេដ្ឋី ។ ធីតាសេដ្ឋីក៏ចាត់ចែងបិណ្ឌបាតមួយៗ មានតម្លៃមួយកហាបណៈ ឲ្យថ្វាយចំពោះព្រះថេរៈទាំងឡាយហើយ ។ ព្រះថេរៈរំពឹងហើយ ឃើញឧបនិស្ស័យរបស់ធីតា-សេដ្ឋី ទើបសួរថា ធីតាសេដ្ឋីទៅណា ។ ស្រីបម្រើឆ្លើយថា នៅក្នុងបន្ទប់លោកម្ចាស់ ព្រះថេរៈពោលថា ចូរទៅហៅនាងមក ។ ព្រះថេរៈនិយាយតែមួយដងនាងក៏មកដោយសេចក្ដីគោរពក្នុងព្រះថេរៈ ថ្វាយបង្គំព្រះថេរៈហើយ កើតសទ្ធាយ៉ាងខ្លាំង បិណ្ឌបាតដែលតាំងទុកក្នុងខេត្តដែលបរិសុទ្ធិ រមែងឲ្យវិបាកក្នុងបច្ចុ-ប្បន្នជាតិតែម្ដង ព្រោះដូច្នោះ ព្រមគ្នានឹងការថ្វាយបង្គំព្រះថេរៈ សក់ទាំងឡាយក៏ត្រឡប់មកតាំងនៅដូចប្រក្រតី ។

ចំណែកព្រះថេរៈទាំងឡាយ កាន់យកបិណ្ឌបាតនោះហោះឡើងទៅ ទាំងដែលធីតាសេដ្ឋីឃើញ ក៏ចុះត្រង់ព្រះរាជឧទ្យាន ឈ្មោះឧទ្យានកញ្ចនៈ អ្នករក្សាព្រះរាជឧទ្យានឃើញព្រះថេរៈនោះហើយ ទើបទៅគាល់ព្រះរាជា ក្រាបទូលថា បពិត្រសម្មតិទេព លោកម្ចាស់កច្ចាយនៈបុរោហិតរបស់យើងបួសហើយ បានត្រឡប់មកកាន់ឧទ្យានហើយព្រះអង្គ ព្រះបាទចណ្ឌបជ្ជោតស្តេចក៏ទៅកាន់ឧទ្យាន ថ្វាយបង្គំព្រះថេរៈដែលធ្វើភត្តកិច្ចហើយដោយបញ្ចង្គប្រតិស្ឋាន ហើយប្រថាប់អង្គុយក្នុងទីសមគួរមួយ ត្រាស់សួរថា លោកម្ចាស់ ព្រះដ៏មានព្រះភាគប្រថាប់នៅក្នុងទីណា ព្រះថេរៈទូលថា ព្រះអង្គស្តេចទ្រង់មិនបានយាងមកទេ ទ្រង់បញ្ជូនអាត្មាមក មហាបពិត្រ ។ ព្រះរាជាត្រាស់សួរថា លោកម្ចាស់ដ៏ចម្រើន ថ្ងៃនេះលោកម្ចាស់បានភិក្ខាក្នុងទីណា ព្រះថេរៈទូលប្រាប់រឿងដែលធ្វើបានដោយលំបាកដែលធីតាសេដ្ឋីធ្វើគ្រប់យ៉ាងឲ្យព្រះរាជាទ្រង់ជ្រាប តាមពាក្យដែលទ្រង់ត្រាស់សួរ ព្រះរាជាត្រាស់ឲ្យចាត់ចែងទីនៅដល់ព្រះថេរៈ ហើយនិមន្តព្រះថេរៈទៅកាន់និវេសន៍ ត្រាស់បង្គាប់ឲ្យទៅនាំធីតាសេដ្ឋីមកតាំងទុកក្នុងតំណែងអគ្គមហេសី ក៏ការបានយសក្នុងបច្ចុប្បន្នជាតិបានមានហើយដល់ស្ត្រីនេះ ចាប់តាំងពីនោះ ព្រះរាជាទ្រង់ធ្វើសក្ការៈធំដល់ព្រះថេរៈ មហាជនជ្រះថ្លាក្នុងធម្មកថារបស់ព្រះថេរៈ បួសក្នុងសំណាក់របស់ព្រះថេរៈ ផ្តើមតាំងពីកាលនោះ ទូទាំងព្រះនគរក៏រុងរឿងដោយសំពត់

កាសាវពស្ត្រតែម្យ៉ាង សម្បូរទៅដោយពួកឥសី ចំណែកព្រះទេវីនោះទ្រង់គភ៌ពេលកន្លងទសមាសក៏ប្រសូតិព្រះឱរស ក្នុងថ្ងៃថ្វាយព្រះនាមឱរសនោះ ព្រះញាតិទាំងឡាយថ្វាយព្រះនាមរបស់សេដ្ឋីដែលជាជីតាថា គោបាលកុមារ ។ ព្រះមាតាក៏មានព្រះនាមថា គោបាលមាតាទេវី តាមឈ្មោះរបស់ព្រះឱរស ព្រះនាងទ្រង់ជ្រះថ្លាក្នុងព្រះថេរៈយ៉ាងក្រៃលែង សូមព្រះរាជានុញ្ញាតសាងវិហារថ្វាយព្រះថេរៈក្នុងកញ្ចនរាជឧទ្យាន ។ ព្រះថេរៈញ៉ាំងអ្នកស្រុកឧជ្ជេនីឲ្យជ្រះថ្លាហើយ ទៅគាល់ព្រះសាស្តាម្តងទៀត តមកខាងក្រោយ ព្រះសាស្តាកាលប្រថាប់នៅក្នុងជេតវនមហាវិហារ ទ្រង់ធ្វើព្រះសូត្រ ៣ សូត្រ ទាំងនេះ គឺ មធុបណ្ឌិកសូត្រ , កច្ចាយនបេយ្យាលសូត្រ , បរាយនសូត្រ ឲ្យជាអត្ថុប្បត្តិហេតុ ហើយទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងជាកំពូលនៃពួកភិក្ខុអ្នកចែកអត្ថនៃព្រះតម្រាស់ ដែលទ្រង់ត្រាស់ដោយសង្ខេបឲ្យពិស្តារបាន ។

ចប់អដ្ឋកថា សូត្រទី ១០

## ចប់វគ្គទី ១

រួមអដ្ឋកថាក្នុងវគ្គនេះមាន ១០ អដ្ឋកថា

# វគ្គទី ២

## អដ្ឋកថាសូត្រទី ១-២

## ប្រវត្តិព្រះចុល្លបន្ថកត្ថេរ និងព្រះមហាបន្ថកត្ថេរ

*វគ្គទី ២ សូត្រទី ១ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[១៤៧] *បទថា* ***មនោមយំ*** *សេចក្តីថា កាយដែលកើតឡើងដោយចិត្ត ក្នុងអាគតស្ថាន ដែលត្រាស់ទុកថា "ចូលទៅរកហើយដោយមនោមយិទ្ធិផ្លូវកាយ" ឈ្មោះថា* ***កាយមនោម័យ*** *។ កាយដែលកើតឡើងដោយចិត្ត ក្នុងអាគតស្ថាន ដែលពោលទុកថា " រមែងចូលដល់កាយដែលសម្រេចដោយចិត្តណាមួយ" ក៏ឈ្មោះថា* ***កាយមនោម័យ*** *។ ក្នុងទីនេះបំណងយក កាយមនោម័យនេះ ។*

*ក្នុងកាយទាំង ២ យ៉ាងនេះ ភិក្ខុទាំងឡាយពួកដទៃ កាលធ្វើមនោមយកាយឲ្យកើតឡើង ក៏ធ្វើឲ្យកើតឡើង ៣ ខ្លះ ៤ ខ្លះ តែធ្វើមនុស្សច្រើននាក់ឲ្យមកជាមនុស្សតែម្នាក់មិនបាន ។ ឈ្មោះថា ធ្វើកម្មបានតែម្យ៉ាងប៉ុណ្ណោះ ។ ចំណែកព្រះថេរៈឈ្មោះថា ចុល្លបន្ថកៈ និម្មិតភិក្ខុ ១.០០០ រូប បានដោយអាវជ្ជនៈតែមួយ តែធ្វើ ២ នាក់ ឲ្យដូចជាមនុស្សម្នាក់មិនបាន ឈ្មោះថា ធ្វើកម្មតែម្យ៉ាងមិន*

បាន ។ ព្រោះដូច្នោះ លោកឈ្មោះថា ជាកំពូលលើពួកភិក្ខុខាងនិម្មិតមនោម-យកាយ ។ ព្រះចុល្លបន្ថកៈ រាប់ថា ជាកំពូលលើពួកភិក្ខុ គឺ ភិក្ខុដែលឆ្លាតក្នុងចេតោវិវដ្តៈ ។ ចំណែកព្រះមហាបន្ថកត្ថេរៈ លោកពោលថា ជាកំពូលលើពួកភិក្ខុដែលឆ្លាតក្នុងបញ្ញាវិវដ្តៈ ។ បណ្តាទាំងពីរអង្គនោះ ព្រះចុល្លបន្ថកត្ថេរៈ លោកពោលថា ជាអ្នកឆ្លាតក្នុងចេតោវិវដ្តៈ ។ ព្រោះបានរូបាវចរឈាន ៤ ។ ព្រះមហាបន្ថកត្ថេរៈ លោកពោលថា ជាអ្នកឆ្លាតក្នុងបញ្ញាវិវដ្តៈ ព្រោះជាអ្នកឆ្លាតក្នុងសមា-បត្តិ ។ ព្រះមហាបន្ថកៈ ឈ្មោះថា អ្នកឆ្លាតក្នុងបញ្ញាវិវដ្តៈ ព្រោះជាអ្នកឆ្លាតក្នុងវិបស្សនា ។ មួយទៀត ក្នុងភិក្ខុ ២ រូបនេះ មួយរូបឆ្លាតក្នុងលក្ខណៈសមាធិ មួយរូបឆ្លាតក្នុងលក្ខណៈនៃវិបស្សនា មួយទៀត មួយរូបឆ្លាតក្នុងការឈានចុះកាន់សមាធិ មួយរូបឆ្លាតក្នុងការឈានចុះកាន់វិបស្សនា ។ ន័យមួយទៀត ក្នុង ២ រូបនេះ មួយរូបឆ្លាតក្នុងការសង្ខេបអង្គ មួយរូបឆ្លាតក្នុងការសង្ខេបអារម្មណ៍ ន័យមួយទៀត មួយអង្គឆ្លាតក្នុងការកំណត់អង្គ មួយអង្គឆ្លាតក្នុងការកំណត់អា-រម្មណ៍ គប្បីធ្វើការប្រកបសេចក្តីក្នុងភិក្ខុ ២ រូបនេះ ដោយប្រការដូចពោលមកនេះ ។ ម្យ៉ាងទៀត ព្រះចូឡបន្ថកត្ថេរៈ ជាអ្នកបានរូបាវចរឈាន ចេញចាកអង្គឈានហើយ សម្រេចព្រះអរហត្ត ដូច្នោះ ទើបឈ្មោះថា ជាអ្នកឆ្លាតក្នុងចេ-តោវិវដ្តៈ ព្រះមហាបន្ថកជាអ្នកបានអរូបាវចរឈាន ចេញចាកអង្គឈានហើយ

សម្រេចព្រះអរហត្ត ដូច្នោះ ទើបឈ្មោះថា ជាអ្នកឆ្លាតក្នុងបញ្ញាវិវដ្ដៈ ព្រះថេរៈទាំង ២ រូប ដែលមានឈ្មោះថា **បន្ថកៈ** ព្រោះលោកកើតត្រង់ផ្លូវទាំងពីររូបនោះឯង អង្គដែលកើតមុនឈ្មោះថា មហាបន្ថកៈ មួយរូបទៀតឈ្មោះថា ចូឡបន្ថកៈ ក៏ក្នុងបញ្ហាកម្មរបស់ព្រះថេរៈទាំង ២ រូបនេះ មានរឿងដែលនឹងពោលតាមលំដាប់ដូចតទៅនេះ ៖

ក៏ក្នុងអតីតកាល គ្រាព្រះពុទ្ធព្រះនាមថា **បទុមុត្តរៈ** មានកុដុម្ពិកៈ ២ នាក់បងប្អូន ជាអ្នកក្រុងហង្សវតី ជ្រះថ្លាក្នុងព្រះសាស្ដា ទៅស្ដាប់ធម៌ក្នុងសំណាក់ព្រះសាស្ដាជានិច្ច ។ ក្នុងកុដុម្ពិកៈ ២ នាក់បងប្អូននោះ ថ្ងៃមួយប្អូនប្រុសឃើញព្រះសាស្ដាស្ថាបនាភិក្ខុមួយរូបអ្នកប្រកបដោយអង្គ ២ ទុកក្នុងតំណែងឯតទគ្គៈថា ភិក្ខុរូបនេះ ជាកំពូលនៃពួកភិក្ខុដែលនិម្មិតកាយមនោម័យ និងជាអ្នកឆ្លាតក្នុងចេតោវិវដ្ដៈក្នុងសាសនារបស់តថាគត ទើបគិតថា គួរអស្ចារ្យហ្ន៎ ភិក្ខុនេះតែមួយអង្គឯង ធ្វើ អង្គ ២ ឲ្យបរិបូណ៌ប្រព្រឹត្តទៅបាន សូម្បីយើងក៏គួរជាអ្នកបំពេញមានអង្គ ២ ឲ្យប្រព្រឹត្តទៅក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយ ក្នុងអនាគត ដូច្នេះ គេទើបនិមន្តព្រះសាស្ដាថ្វាយមហាទាន ដោយន័យមុននុ៎ះឯង ហើយទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុដែលព្រះអង្គស្ថាបនាទុកក្នុងតំណែងឯតទគ្គៈថា ជាកំពូលក្នុងសាសនារបស់ព្រះអង្គ ដោយអង្គមនោម័យ

និងដោយភាពជាអ្នកឆ្លាតក្នុងបេតោវិវដ្ដៈ ក្នុងទីបំផុតនៃថ្ងៃទី ៧ រាប់ពីថ្ងៃនេះ សូម្បីខ្ញុំព្រះអង្គក៏គប្បីជាអ្នកបំពេញអង្គ ២ បរិបូណ៌ដូចភិក្ខុនោះ ដោយផលនៃកម្មដែលជាអធិការនេះចុះ ព្រះសាស្ដាទ្រង់ពិចារណាមើលអនាគត ក៏ទ្រង់ឃើញថា សេចក្ដីប្រាថ្នារបស់គេនឹងសម្រេចដោយរកអន្តរាយមិនបាន ទើបទ្រង់ព្យាករណ៍ថា ក្នុងអនាគត ក្នុងទីបំផុតនៃសែនកប្ប ព្រះពុទ្ធព្រះនាមថា **គោតម** ទ្រង់នឹងឧប្បត្តិឡើង ព្រះអង្គនឹងស្ថាបនាអ្នកទុកក្នុងឋានៈ ២ នេះ ដូច្នេះ ទ្រង់ធ្វើអនុមោទនា ហើយស្ដេចយាងត្រឡប់ទៅ ។

សូម្បីបងប្រុសរបស់លោកក្នុងថ្ងៃមួយ ឃើញព្រះសាស្ដាទ្រង់ស្ថាបនាភិក្ខុដែលឆ្លាតក្នុងបញ្ញាវិវដ្ដៈ ទុកក្នុងតំណែងឯតទគ្គៈ ក៏ធ្វើបុណ្យកុសលដូច្នោះ ធ្វើសេចក្ដីប្រាថ្នាហើយ សូម្បីព្រះសាស្ដា ក៏ទ្រង់ព្យាករណ៍លោកហើយ ។ ទាំង ២ នាក់បងប្អូននោះ កាលព្រះសាស្ដាបរិនិព្វានហើយ បានបូជាដោយមាសត្រង់ព្រះចេតិយបញ្ចុះព្រះសរីរៈ ចុតិចាកភពនោះ ទៅកើតក្នុងទេវលោក កាល ២ នាក់បងប្អូនវិលវល់នៅក្នុងទេវតា និងមនុស្សក្រនួងទៅអស់សែនកប្ប ក្នុងជនទាំង ២ នោះ ខ្ញុំនឹងមិនបានពោលកល្យាណកម្មដែលមហាបន្ថកៈធ្វើទុកក្នុងរវាងនោះៗ ចំណែកចុល្លបន្ថកៈ ចេញបួសក្នុងសាសនារបស់ព្រះដ៏មានព្រះភាគព្រះនាមថា **កស្សប** ចម្រើនឱទាតកសិណកន្លងទៅ ២០.០០០ ឆ្នាំ ទៅកើតក្នុងសួគ៌ លុះ

ក្រោយមក ព្រះសាស្តារបស់យើងទ្រង់ត្រាស់ដឹងព្រះអភិសម្ពោធិញ្ញាណ ទ្រង់ប្រកាសព្រះធម្មចក្រដ៏ប្រសើរហើយ ទ្រង់អាស្រ័យក្រុងរាជគ្រឹះ ប្រថាប់នៅក្នុងជេតវនមហាវិហារ គួរនឹងពោលដល់ការកើតរបស់ជនទាំង ២ នោះ ។

បានឮថា កុលធីតារបស់ធនសេដ្ឋីក្នុងក្រុងរាជគ្រឹះ ធ្វើការលួចលាក់នឹងទាសៈរបស់ខ្លួនឯង ហើយគិតថា បើអ្នកដទៃណាៗ ដឹងកម្មនេះរបស់យើង យើងមិនអាចនៅក្នុងទីនេះបាន ប្រសិនបើថា មាតាបិតារបស់យើងដឹងនូវកំហុសយ៉ាងនេះ នឹងធ្វើបិព្រាំយើងឲ្យជាចំណិតតូចៗ ចាំយើងនឹងទៅនៅអាវាសផ្សេងចុះ នឹងកាន់យកតែរបស់សំខាន់ជាប់ដៃទៅបានហើយ ហើយក៏នាំគ្នាចេញតាមទ្វារធំទៅកាន់ទីដែលមិនមានអ្នកដទៃស្គាល់ចុះ អ្នកទាំង ២ ក៏នាំគ្នាចេញទៅ កាលជនទាំង ២ នោះនៅក្នុងទីមួយ អាស្រ័យការនៅរួមគ្នា នាងក៏តាំងគភ៌ឡើង ពេលគភ៌ចាស់ នាងទើបប្រឹក្សានឹងស្វាមីថា គភ៌ខ្ញុំចាស់ហើយ ធម្មតាការប្រសូតិក្នុងកន្លែងដែលមិនមានញាតិ ជាសេចក្តីលំបាកដល់យើងទាំងពីរដោយពិត យើងទៅផ្ទះត្រកូលចុះ ស្វាមីនិយាយបង្វែថា ថ្ងៃនេះនឹងទៅ ស្អែកនេះសូមទៅ ដរាបកន្លងទៅអស់ច្រើនថ្ងៃ នាងទើបគិតថា អ្នកនេះជាមនុស្សល្ងង់ មិនហ៊ានទៅ ឬមិនទៅក៏ដោយ យើងគួរទៅ កាលស្វាមីចេញពីស្រុកទៅ ក៏រៀបចំបាយទុកក្នុងផ្ទះ ប្រាប់ដល់អ្នកនៅជិតខាងគ្នាថា ខ្លួនទៅផ្ទះត្រកូលហើយ ក៏ចេញដើរផ្លូវ ពេល

នោះ បុរសជាប្តីត្រឡប់មកផ្ទះមិនឃើញនាង សួរអ្នកជិតខាងជ្រាបថា ទៅផ្ទះត្រកូល ទើបប្រញាប់ជាប់តាមទៅទាន់គ្នាក្នុងរវាងផ្លូវ នាងក៏ប្រសូតបុត្រក្នុងទីនោះឯង បុរសនោះសួរថា នេះជាអ្វីនាងដ៏ចម្រើន នាងឆ្លើយថា នាយ! កូនកើតម្នាក់ហើយ បុរសនោះសួរថា ឥឡូវនេះយើងនឹងធ្វើយ៉ាងណា នាងពោលថា យើងនឹងទៅផ្ទះត្រកូលដើម្បីប្រយោជន៍ដល់ការណា ការនោះសម្រេចហើយក្នុងរវាងផ្លូវ យើងនឹងទៅទីនោះធ្វើអ្វីបាន ត្រឡប់វិញចុះ ពីរនាក់ស្វាមីភរិយានោះទើបនាំគ្នាត្រឡប់ ក៏ពីរនាក់ស្វាមីភរិយា តាំងឈ្មោះបុត្រថា **បន្ថកៈ** ព្រោះទារកនោះកើតត្រង់ផ្លូវ ។ មិនយូរប៉ុន្មាន នាងក៏តាំងគភ៌បុត្រម្នាក់ទៀត រឿងទាំងអស់គប្បីពោលឲ្យពិស្តារដោយន័យមុននោះឯង ។ គេតាំងឈ្មោះបុត្រដែលកើតមុនថា **មហាបន្ថកៈ** បុត្រដែលកើតត្រង់ក្រោយថា **ចុល្លបន្ថកៈ** ព្រោះទារកទាំងពីរនោះកើតត្រង់ផ្លូវ ជនទាំងពីរនោះ នាំទារកទាំងពីរទៅកាន់ទីលំនៅរបស់ខ្លួនដូចដើម ។

កាលជនទាំងនោះនៅក្នុងទីនោះ មហាបន្ថកកុមារ បានឮក្មេងដទៃៗ ហៅពូ អ៊ំ តា យាយ ទើបសួរមាតាថា ម៉ែ ក្មេងដទៃៗ ហៅតា ហៅយាយ ក៏ញាតិរបស់ពួកយើងក្នុងទីនេះមិនមានខ្លះទេឬ នាងឆ្លើយថា ពិតហើយកូន ញាតិរបស់យើងក្នុងទីនេះមិនមានទេ តែក្នុងក្រុងរាជគ្រឹះ តារបស់កូន ឈ្មោះធនសេដ្ឋី ក្នុង

ក្រុងរាជគ្រឹះនោះមានញាតិរបស់អ្នកដ៏ច្រើន ព្រោះហេតុអ្វី យើងទើបមិននាំគ្នាទៅក្នុងក្រុងរាជគ្រឹះនោះម៉ែ នាងមិនបានដល់ហេតុដែលខ្លួនមកដល់បុត្រ កាលបុត្រនិយាយរឿយៗ ទើបប្រាប់ស្វាមីថា ក្មេងៗ ទាំងនេះរំអុកហួសប្រមាណ ពុកម៉ែរបស់យើងឃើញហើយនឹងស៊ីសាច់ឬ មក! យើងនឹងទៅចង្អុលត្រកូលតាយាយដល់ក្មេងៗ ស្វាមីពោលថា ខ្ញុំមិនអាចបង្ហាញមុខបានទេ ប៉ុន្តែថា នឹងនាំទៅបាន នាងពោលថា ល្អណាស់នាយ យើងគួរឲ្យក្មេងៗ ឃើញត្រកូលតាដោយឧបាយយ៉ាងណាមួយទើបគួរ ទាំងពីរនាក់ទើបនាំទារកទៅដរាបដល់ក្រុងរាជគ្រឹះដោយលំដាប់ សម្រាកនៅសាលាមួយក្នែងជិតទ្វារនគរ មាតាក្មេងបញ្ជូនដំណឹងទៅប្រាប់មាតាបិតាថា នាំក្មេង ២ នាក់មក សត្វដែលវិលវល់នៅក្នុងសង្សារវដ្ត ឈ្មោះថា នឹងមិនមានបុត្រ និងមិនមានធីតា មិនមាន មាតាបិតានោះបានស្ដាប់ដំណឹងហើយ បញ្ជូនពាក្យតបទៅថា អ្នកទាំងពីរមានកំហុសចំពោះយើងច្រើន មិនអាចនៅក្នុងខ្សែភ្នែករបស់យើងបាន ទាំង ២ នាក់ ចូរកាន់យកទ្រព្យមានប្រមាណប៉ុណ្ណេះ ទៅកាន់ស្ថានទីដែលជាសុខចុះ តែចូរបញ្ជូនក្មេងៗ មកឲ្យយើង ធីតាសេដ្ឋី ទទួលយកទ្រព្យដែលមាតាបិតាបញ្ជូនទៅឲ្យ ហើយប្រគល់ក្មេងទាំង ២ ទុកក្នុងដៃទូតដែលមកហើយនោះឯង ក្មេងទាំង ២ នោះ ធំធាត់ហើយក្នុងត្រកូលរបស់ជីតា ។

ក្នុងបងប្អូនទាំងពីរនាក់នោះ ចុល្លបន្ថកៈនៅក្មេងពេក ចំណែកមហាបន្ថកៈទៅស្តាប់ធម្មកថារបស់ព្រះទសពលជាមួយជីតា កាលគេស្តាប់ធម៌ចំពោះព្រះភ័ក្ត្រព្រះសាស្តាជាប្រចាំ ចិត្តក៏បង្អោនទៅក្នុងបព្វជ្ជា គេនិយាយនឹងជីតាថា បើតាអនុញ្ញាត ចៅនឹងចេញបួស តាពោលថា និយាយអ្វីចៅ ការបព្វជ្ជារបស់ចៅដែលបួសហើយ ជាសេចក្តីចម្រើនទាំងដល់យើង ទាំងដល់លោកទាំងមូល បើចៅអាចក៏ចូរបួសចុះ ដូច្នេះ ទទួលពាក្យហើយនាំគ្នាទៅកាន់សំណាក់ព្រះសាស្តា ព្រះសាស្តាត្រាស់ថា មហាសេដ្ឋី លោកបានទារកហើយឬ ។ ព្រះអង្គ ទារកនេះជាចៅរបស់ខ្ញុំព្រះអង្គ គេប្រាប់ថា នឹងបួសក្នុងសំណាក់របស់ព្រះអង្គ ព្រះសាស្តាទើបត្រាស់ប្រគល់ភិក្ខុដែលកាន់បិណ្ឌបាតជាវត្តមួយរូបថា អ្នកចូរឲ្យទារកនេះបួសចុះ ព្រះថេរៈប្រាប់តចបញ្ចកកម្មដ្ឋានដល់ទារកនោះហើយ ឲ្យបព្វជ្ជា លោករៀនព្រះពុទ្ធវចនៈបានច្រើន មានវស្សាគ្រប់ ហើយក៏ឧបសម្បទ លុះឧបសម្បទហើយ ក៏ធ្វើកិច្ចកម្មក្នុងការធ្វើទុកក្នុងចិត្តដោយឧបាយត្រូវទំនង រហូតបានអរូបាវចរឈាន ៤ ចេញចាកអង្គឈានហើយ បានសម្រេចព្រះអរហត្ត ដូច្នោះ លោកទើបជាកំពូលលើបណ្តាភិក្ខុអ្នកឆ្លាតក្នុងបញ្ញាវិវដ្ដៈ ។

លោកស្ថិតនៅដោយសេចក្តីសុខក្នុងឈាន សេចក្តីសុខក្នុងមគ្គ សេចក្តីសុខក្នុងនិព្វាន ទើបគិតថា យើងអាចឲ្យសេចក្តីសុខប្រភេទនេះ ដល់ចុល្លបន្ថកៈ

បានទេហ្ន៎ តពីនោះ ទើបទៅកាន់សំណាក់របស់សេដ្ឋីដែលជាតា ពោលថា លោកមហាសេដ្ឋី បើញោមអនុញ្ញាត អាត្មានឹងឲ្យចុល្លបន្ថកៈបួស សេដ្ឋីពោលថា ចូរឲ្យបួសចុះលោក ព្រះថេរៈឲ្យចុល្លបន្ថកៈបួស ហើយឲ្យតាំងនៅក្នុងសីល ១០ សាមណេរចុល្លបន្ថកៈ រៀនគាថាក្នុងសំណាក់របស់ព្រះបងប្រុសថា ដូច្នេះ ។

បទុមំ យថា កោកនុទំ សុគន្ធំ
បាតោ សិយា ផុល្លមវីតគន្ធំ
អង្គីរសំ បស្ស វិរោចមានំ
តបន្តមាទិច្ចមិវន្តលិក្ខេ ។

ចូរលោកមើលព្រះអង្គីរស ដែលរុងរឿងហើយ
ដូចព្រះអាទិត្យដ៏ស្វាងស្វែនៅក្នុងអាកាស ដូច
ផ្កាបទុមវិសេសឈ្មោះកោកនុទៈ មានក្លិនក្រអូបរីក
ហើយអំពីព្រឹក មិនប្រាសចាកក្លិន ដូច្នោះ ។

បទដែលលោករៀនទុកហើយ ក៏វិនាសទៅ កាលមករៀនបទដែលខ្ពស់ៗឡើងទៅ លោកព្យាយាមរៀនគាថានេះតែម្យ៉ាង អស់វេលាដល់ ៤ ខែ គ្រានោះព្រះមហាបន្ថកៈពោលនឹងលោកថា បន្ថកៈអ្នកជាអភ័ព្វក្នុងសាសនានេះ អ្នកចាំគាថាសូម្បីតែមួយបទក៏មិនបាន ក្នុងវេលា ៤ ខែ អ្នកនឹងធ្វើកិច្ចរបស់បព្វជិត

ឲ្យសម្រេចបានយ៉ាងណា អ្នកចូរចេញទៅពីទីនេះចុះ លោកត្រូវព្រះថេរៈបណ្តេញ ទើបទៅឈរស្រែកយំនៅខាងក្រោយព្រះវិហារ ។

សម័យនោះ ព្រះសាស្តាទ្រង់ចូលអាស្រ័យក្រុងរាជគ្រឹះ ប្រថាប់នៅក្នុងជីវកម្ពវ័នសួនស្វាយរបស់ពេទ្យជីវក ខណៈនោះពេទ្យជីវក ប្រើបុរសទៅទូលនិមន្តព្រះសាស្តានឹងភិក្ខុ ៥០០ រូប និងសម័យនោះ ព្រះមហាបន្ថកៈមាននាទីចែកអាហារ កាលបុរសនោះពោលនិមន្តថា លោកម្ចាស់សូមនិមន្តព្រះភិក្ខុ ៥០០ រូប លោកក៏ពោលថា ខ្ញុំទទួលសម្រាប់ភិក្ខុដែលនៅសល់ វៀរតែព្រះចុល្លបន្ថកៈ ព្រះចុល្លបន្ថកៈ បានស្តាប់ពាក្យនោះ ក៏ទោមនស្សហួសប្រមាណ ព្រះសាស្តាទ្រង់ឃើញព្រះចុល្លបន្ថកៈស្រែកយំ ទ្រង់ត្រិះរិះថា ចុល្លបន្ថកៈ កាលតថាគតទៅនឹងត្រាស់ដឹង ទើបស្តេចទៅសម្តែងព្រះអង្គក្នុងទីដែលមិនឆ្ងាយ ហើយត្រាស់ថា បន្ថកៈ អ្នកយំធ្វើអ្វី ។

បន្ថកៈ : បងប្រុសបណ្តេញខ្ញុំព្រះអង្គ ព្រះអង្គ ។

ព្រះសម្ពុទ្ធ : បងប្រុសរបស់អ្នកមិនមានអាសយានុសយញ្ញាណ សម្រាប់បុគ្គលដទៃ អ្នកឈ្មោះថា ពុទ្ធវេនេយ្យបុគ្គល ដូច្នេះ ទ្រង់បណ្តាលឫទ្ធិ ប្រគល់សំពត់ផ្ទាំងតូចដែលស្អាតមួយផ្ទាំង ត្រាស់ថា បន្ថកៈ អ្នកចូរយកសំពត់ផ្ទាំងនេះ ភាវនាថា "រជោហរណំ រជោហរណំ" ដូច្នេះ ។

លោកអន្ទុយយកដៃអង្អែលកំណាត់សំពត់តូច ដែលព្រះសាស្តាប្រទាន នោះ ភាវនាថា **រជោហរណំ រជោហរណំ** កាលលោកស្ទាបអង្អែលហើយ (ដូច្នោះ) សំពត់ផ្ទាំងនោះក៏សៅហ្មង កាលលោកស្ទាបអង្អែលរឿយៗ ក៏ក្លាយដូចជាសំពត់ ជូតថ្នាំងបាយ លោកអាស្រ័យសេចក្តីចាស់ក្លានៃញាណ ផ្តើមតាំងការអស់ទៅ និងការវិនាសទៅក្នុងសំពត់នោះ គិតថា កំណាត់សំពត់នេះ ដោយប្រក្រតីស្អាត បរិសុទ្ធ ព្រោះអាស្រ័យឧបាទិន្នកសរីរៈ ទើបសៅហ្មង សូម្បីចិត្តនេះ ក៏មានគតិ ដូច្នេះដូចគ្នា ហើយចម្រើនសមាធិ ធ្វើរូបាវចរឈាន ៤ ឲ្យប្រាកដ សម្រេច ព្រះអរហត្តព្រមដោយបដិសម្ភិទាហើយ លោកជាអ្នកបានឈានដោយមនោម-យិទ្ធិនុ៎ះឯង អាចធ្វើមួយនាក់ជាច្រើននាក់បាន ច្រើននាក់ក៏អាចធ្វើឲ្យមកជាម្នាក់ បាន ក៏ព្រះត្រៃបិដក និងអភិញ្ញា ៦ មកដល់លោកព្រមជាមួយព្រះអរហត្តមគ្គ នុ៎ះឯង ។

ថ្ងៃស្អែក ព្រះសាស្តាស្តេចទៅព្រមទាំងភិក្ខុ ៥០០ រូប ប្រថាប់គង់ក្នុង និវេសន៍របស់ពេទ្យជីវក ចំណែកព្រះចុល្លបន្ថកៈមិនបានទៅ ព្រោះខ្លួនមិនបាន ទទួលនិមន្តនុ៎ះឯង ជីវកផ្តើមថ្វាយបាយយាគូ ព្រះសាស្តាទ្រង់យកព្រះហស្តបិទ បាត្រ ពេទ្យជីវកទូលសួរថា ព្រោះហេតុអ្វី ព្រះអង្គទើបទ្រង់មិនទទួល ទ្រង់ ត្រាស់ថា នៅមានភិក្ខុមួយរូបទៀតក្នុងវិហារ ជីវក ពេទ្យជីវកទើបបញ្ជូនបុរស

ទៅថា នាយ ចូរទៅនិមន្តលោកម្ចាស់ដែលនៅក្នុងវិហារមក សូម្បីព្រះចុល្ល-បន្ថកត្ថេរៈ និម្មិតភិក្ខុ ១.០០០ រូប ក្នុងវេលាដែលបុរសនោះជិតមកដល់ ធ្វើមិនឲ្យដូចគ្នាសូម្បីត្រឹមតែមួយអង្គ មួយអង្គៗ ធ្វើកិច្ចរបស់សមណៈជាដើមថា ដេរចីវរមិនដូចគ្នាជាមួយអង្គដទៃៗ បុរសនោះ ឃើញភិក្ខុមានច្រើនក្នុងវិហារ ទើបត្រឡប់ទៅប្រាប់ពេទ្យជីវកថា លោកម្ចាស់ ភិក្ខុក្នុងវិហារនេះមានច្រើន ខ្ញុំមិនស្គាល់លោកម្ចាស់ដែលនឹងគប្បីនិមន្តមកពីវិហារនោះ ពេទ្យជីវកទើបទូលសួរព្រះសាស្តាថា ភិក្ខុនៅក្នុងវិហារ ឈ្មោះអ្វីព្រះអង្គ ។

ព្រះសម្ពុទ្ធ : ឈ្មោះចុល្លបន្ថកៈ ជីវក ។

ពេទ្យជីវកពោលនឹងបុរសនោះថា ទៅចុះនាយ ចូរទៅសួរថា អង្គណាឈ្មោះចុល្លបន្ថកៈ ហើយនាំមក បុរសនោះត្រឡប់មកកាន់វិហារ សួរថា អង្គណាឈ្មោះចុល្លបន្ថកៈ លោកម្ចាស់ ពោលថា យើងឈ្មោះចុល្លបន្ថកៈ យើងឈ្មោះចុល្លបន្ថកៈ ទាំង ១.០០០ រូប ។ បុរសនោះត្រឡប់ទៅប្រាប់ពេទ្យជីវកទៀតថា ភិក្ខុប្រមាណ ១.០០០ រូប គ្រប់អង្គប្រាប់ថា យើងឈ្មោះចុល្លបន្ថកៈ ខ្ញុំមិនជ្រាបថា ចុល្លបន្ថកអង្គណាដែលលោកឲ្យនិមន្ត ពេទ្យជីវកជ្រាបបានដោយន័យថា ភិក្ខុមានឫទ្ធិ ព្រោះត្រាស់ដឹងសច្ចៈហើយ ទើបពោលថា អ្នកចូរចាប់ត្រង់ជាយចីវរភិក្ខុអង្គដែលពោលមុន បុរសនោះទៅវិហារក៏ធ្វើយ៉ាងនោះឯង ក្នុង

វេលានោះ ភិក្ខុប្រមាណ ១.០០០ រូប ក៏អន្តរធានទៅ បុរសនោះនាំព្រះថេរៈមកហើយ ព្រះសាស្តាទើបទ្រង់ទទួលបាយយាគូក្នុងខណៈនោះ ។

កាលព្រះទសពលធ្វើភត្តកិច្ចស្រេចហើយ ស្តេចត្រឡប់ទៅកាន់ព្រះវិហារ កើតការសន្ទនាគ្នាឡើងក្នុងធម្មសភាថា ធម្មតា ព្រះពុទ្ធទាំងឡាយមានអានុភាពធំហ្ន៎ ទ្រង់ធ្វើភិក្ខុដែលមិនអាចចាំសូម្បីមួយគាថាបានរហូតអស់ ៤ ខែ ឲ្យជាអ្នកមានឫទ្ធិច្រើនយ៉ាងនេះបាន ព្រះសាស្តាទ្រង់ជ្រាបវារចិត្តរបស់ភិក្ខុទាំងនោះ ប្រថាប់គង់លើអាសនៈដែលគេរៀបចំទុក ហើយត្រាស់សួរថា ភិក្ខុទាំងឡាយ អ្នកនិយាយអ្វី ។

ភិក្ខុ : បពិត្រព្រះដ៏មានព្រះភាគ ពួកខ្ញុំព្រះអង្គមិនបានពោលរឿងអ្វីៗដទៃ ពោលពីគុណរបស់ព្រះអង្គប៉ុណ្ណោះថា ព្រះចុល្លបន្ថកៈបានលាភធំពីសំណាក់របស់ព្រះអង្គ ដូច្នេះ ។

ព្រះសម្ពុទ្ធ : ម្នាលភិក្ខុទាំងឡាយ ចុល្លបន្ថកនេះ ធ្វើតាមឱវាទរបស់តថាគតហើយ បានជាទាយាទនៃលោកុត្តរៈក្នុងឥឡូវនេះ មិនគួរអស្ចារ្យឡើយ សូម្បីក្នុងអតីត គេក៏ធ្វើតាមឱវាទរបស់តថាគត ដែលតាំងនៅក្នុងញាណមិនទាន់ចាស់ក្លា ក៏បានជាទាយាទចំណែកនៃលោកិយៈ ។

ភិក្ខុទាំងឡាយទើបទូលអង្វរថា កាលណាព្រះអង្គ ព្រះសាស្តាទ្រង់នាំ

អតីតនិទានមកសម្ដែងដល់ភិក្ខុទាំងនោះថា ៖

ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាល ព្រះរាជាព្រះនាមថា ព្រហ្មទត្ត គ្រងរាជសម្បត្តិក្នុងក្រុងពារាណសី , សម័យនោះ បណ្ឌិតឈ្មោះចុល្លកសេដ្ឋីជាអ្នកឆ្លាត ដឹងនិមិត្តទាំងពួង ថ្ងៃមួយកំពុងដើរទៅគាល់ព្រះរាជា ឃើញកណ្ដុរស្លាប់ (មួយក្បាល) ក្នុងវាំងផ្លូវ ទើបកំណត់នក្សត្រក្នុងខណៈនោះហើយ ពោលពាក្យនេះថា កុលបុត្រអ្នកមានភ្នែក មានបញ្ញា អាចយកកណ្ដុរនេះទៅចិញ្ចឹមភរិយានិងចាត់ចែងការងារបាន កុលបុត្រកំសត់ម្នាក់ស្ដាប់ពាក្យសេដ្ឋីនោះហើយ គិតថាបុគ្គលនេះមិនដឹងគង់មិននិយាយ ដូច្នេះ ទើបយកកណ្ដុរទៅឲ្យអ្នកលក់នៅផ្សារមួយកន្លែងដើម្បីជាចំណីឆ្មា បានទ្រព្យមួយកាកណិក ហើយទិញទឹកអំពៅដោយទ្រព្យមួយកាកណិកនោះ យកឆ្នាំងមួយដាក់ទឹកផឹកទៅ ឃើញអ្នកក្រងផ្កាឈើដើរមកពីព្រៃ ក៏ឲ្យភ្លក់ទឹកអំពៅបន្តិច ហើយយកបោយដងទឹកឲ្យផឹក អ្នកក្រងផ្កាឈើទាំងនោះ ឲ្យផ្កាឈើដល់បុរសនោះ ម្នាក់មួយក្ដាប់ សូម្បីក្នុងថ្ងៃស្អែកគេយកតម្លៃផ្កាឈើនោះ ទៅទិញទឹកអំពៅ និងឆ្នាំងទឹកផឹក ហើយទៅកាន់សួនផ្កាឈើនោះឯង ថ្ងៃនោះ អ្នកក្រងផ្កាឈើក៏ឲ្យគុម្ពផ្កាឈើដែលខ្លួនរក្សាពាក់កណ្ដាលដល់គេហើយក៏ទៅ កន្លងទៅមិនយូរប៉ុន្មាន គេបានទ្រព្យរាប់បាន ៨ កហាបណៈ ដោយឧបាយនេះ ក្នុងថ្ងៃដែលមានខ្យល់ និងភ្លៀង (ធ្លាក់ខ្លាំង) ថ្ងៃមួយ គេធ្វើ

ឈើដែលដួលរលំហើយឲ្យជាគំនរ ទើបបានទ្រព្យ ១៦ កហាបណៈទៀត ពីនាយស្ទូនឆ្នាំងហ្លួង កាលគេបានទ្រព្យកើតឡើងដល់ ២៤ កហាបណៈហើយ គិតថាឧបាយនេះមានប្រយោជន៍ដល់យើង ទើបតាំងឆ្នាំងទឹកផឹកទុកក្នុងទីមិនឆ្ងាយពីទ្វារក្រុង យកទឹកផឹកចិញ្ចឹមអ្នកកាត់ស្មៅ ៥០០ នាក់ អ្នកកាត់ស្មៅទាំងនោះនិយាយគ្នាថា សម្លាញ់ លោកមានឧបការៈច្រើនដល់ពួកយើង ពួកយើងនឹងធ្វើអ្វីដល់លោកបានខ្លះ បុរសនោះឆ្លើយថា កាលមានកិច្ចកើតឡើង ទើបធ្វើដល់ខ្ញុំចុះ ដើរទៅផ្លូវនេះផ្លូវនោះ ធ្វើការចងមិត្តជាមួយអ្នកធ្វើការងារផ្លូវគោក និងអ្នកធ្វើការងារផ្លូវទឹក អ្នកធ្វើការងារផ្លូវគោកប្រាប់ដល់គេថា ស្អែកនេះ ឈ្មួញសេះនឹងនាំសេះ ៥០០ ក្បាល មកកាន់ក្រុងនេះ គេបានស្តាប់ពាក្យនោះហើយឲ្យសញ្ញាដល់អ្នកកាត់ស្មៅឲ្យធ្វើបាច់ស្មៅតែមួយបាច់ៗ ឲ្យជា ២ ប៉ុនគ្នា ហើយនាំមក លុះវេលាសេះទាំងឡាយមកសម្រាកក្នុងក្រុងហើយ (គេ) ក៏មកអង្គុយធ្វើបាច់ស្មៅ ១.០០០ បាច់ គរទុកជិតទ្វារផ្នែកខាងក្នុង ឈ្មួញសេះរកស្មៅស្រស់ឲ្យសេះទូទៅក្រុងមិនបាន ត្រូវឲ្យទ្រព្យពាន់មួយដល់បុរសនោះ ទិញស្មៅនោះទៅតពីនោះកន្លងទៅ ២-៣ ថ្ងៃ សម្លាញ់ដែលធ្វើការងារផ្លូវសមុទ្រប្រាប់ថា នឹងមានទូកធំចូលចតត្រង់កំពង់ បុរសនោះគិតថា ឧបាយនេះមាន ទើបយកទ្រព្យ ៨ កហាបណៈ ជួលរថដែលព្រមដោយគ្រឿងប្រើគ្រប់ប្រភេទទៅកាន់កំពង់ទូក ធ្វើ

សញ្ញានឹងនាយកំពង់ ប្រថាប់ម្រាមដៃទុកត្រង់ទូកហើយ ឲ្យបាំងវាំងននទុកក្នុងទីមិនឆ្ងាយ អង្គុយនៅក្នុងខាងក្នុងវាំងននោះ បង្គាប់បុរសអ្នកបម្រើទុកថា កាលឈ្មួញពីខាងក្រោមមកដល់ ចូរមកប្រាប់ផ្លូវទ្វារផ្ទះទី ៣ កាលអ្នកបម្រើទាំងនោះជ្រាបថា ទុកមកដល់ហើយ ទើបប្រាប់ថា មានឈ្មួញប្រមាណ ១០០ នាក់ មកពីក្រុងពារាណសី មកទិញទំនិញ នាយទ្វារទី ៣ ពោលថា ពួកលោកនឹងមិនបានទំនិញ (ព្រោះ) នាយពាណិជ្ជធំក្នុងទីឯណោះ លោកធ្វើសញ្ញាទុកហើយ ឈ្មួញទាំងនោះស្តាប់ពាក្យរបស់បុរសទាំងនោះហើយ ទើបនាំគ្នាទៅកាន់សំណាក់របស់ឈ្មួញធំនោះ ចំណែកបុរសអ្នកជិតស្និទ្ធដឹងដំណឹងថា ឈ្មួញទាំងនោះមកផ្លូវទ្វារផ្ទះទី ៣ តាមសញ្ញាច្បាប់មុន ឈ្មួញទាំងមួយរយនាក់នោះ ត្រូវឲ្យទ្រព្យម្នាក់មួយពាន់ហើយ ទើបធ្វើដំណើរទៅទូកជាមួយបុរសនោះ ហើយចាយទ្រព្យម្នាក់មួយពាន់ៗ ទៀត ហើយឲ្យបោះបង់ចំណាំ ទើបនឹងធ្វើទំនិញឲ្យជារបស់រៀងៗ ខ្លួនបាន បុរសនោះកាន់យកទ្រព្យ ២ សែន ត្រឡប់មកកាន់ក្រុងពារាណសី គិតថា យើងគួរនឹងជាអ្នកកតញ្ញូ ទើបកាន់យកទ្រព្យមួយសែនទៅកាន់សំណាក់នៃចុល្លកសេដ្ឋី ។

គ្រានោះ សេដ្ឋីសួរបុរសនោះថា បាធ្វើដូចម្តេច ទើបបានទ្រព្យនេះមក បុរសនោះពោលថា ខ្ញុំតាំងនៅក្នុងឧបាយដែលលោកពោលហើយ ទើបបានទ្រព្យ

មកខាងក្នុង ៤ ខែប៉ុណ្ណោះ សេដ្ឋីបានស្តាប់ពាក្យរបស់បុរសនោះ ទើបគិតថា ឥឡូវនេះ យើងមិនគួរធ្វើក្មេងបែបនេះឲ្យជាសម្បត្តិរបស់អ្នកដទៃ ទើបលើកធីតាដែលចម្រើនវ័យឲ្យ ធ្វើឲ្យជាម្ចាស់របស់ទ្រព្យសម្បត្តិទាំងអស់ កុលបុត្រនោះកាលសេដ្ឋីកន្លងទៅហើយ ទើបទទួលតំណែងសេដ្ឋីជំនួសក្នុងព្រះនគរនោះ តាំងនៅដរាបអស់អាយុហើយ ទៅតាមយថាកម្ម ។

ព្រះសាស្តាត្រាស់រឿងទី ២ នេះហើយ ទ្រង់បន្តអនុសន្ធិទេសនា ក្នុងខណៈដែលត្រាស់ដឹងអនុត្តរសម្មោធិញ្ញាណហើយ ត្រាស់ព្រះគាថា ដូច្នេះ ៖

**អប្បកេនបិ មេធាវី  បាភដេន វិចក្ខណោ**

**សមុដ្ឋាបេតិ អត្តានំ  អណុំ អគ្គឹវ សន្ធមន្តិ ។**

បុគ្គលដែលមានបញ្ញា មានបញ្ញាឃើញប្រចក្ស រមែងតាំងខ្លួនបានដោយទ្រព្យដែលជាដើមទុនសូម្បីតិចតួច ដូចបុគ្គលបង្កាត់ភ្លើងដែលតិច ឲ្យឆេះឡើងបាន ដូច្នោះ ។

ព្រះសាស្តាទ្រង់សម្តែងហេតុនេះ ដល់បណ្តាភិក្ខុដែលអង្គុយប្រជុំគ្នាក្នុងធម្មសភាដោយប្រការដូច្នេះ នេះជារឿងរ៉ាវដែលមានមកតាមលំដាប់ ផ្តើមតាំងពីការតាំងសេចក្តីប្រាថ្នាទុកជាដំបូងរបស់ព្រះមហាសាវកទាំងពីរ ក៏តមក ព្រះសាស្តាមានពួកព្រះអរិយបែហហមហើយ ប្រថាប់គង់លើធម្មាសនៈ ទ្រង់ស្តាបនាព្រះចុល្ល-

*បន្ទកត្ថេរៈ ទុកក្នុងតំណែងឯតទគ្គៈជាកំពូលលើពួកភិក្ខុដែលឆ្លាតក្នុងចេតោវិវដ្ដៈ អ្នកនិម្មិតកាយមនោម័យបាន ទ្រង់ស្ថាបនាព្រះមហាបន្ទកត្ថេរៈ ទុកក្នុងតំណែងឯតទគ្គៈជាកំពូលលើពួកភិក្ខុដែលឆ្លាតក្នុងបញ្ញាវិវដ្ដៈ ដោយប្រការដូច្នេះ ។*

ចប់ អដ្ឋកថា សូត្រទី ១-២

# អដ្ឋកថាសូត្រទី ៣

## ប្រវត្តិព្រះសុភូតិត្ថេរ

*គប្បីជ្រាបវិនិច្ឆ័យក្នុងព្រះសូត្រទី ៣ តទៅនេះ ៖*

[១៤៧] *បទថា **អរណវិហារីនំ** បានដល់ អ្នកមានប្រក្រតីនៅដោយរកកិលេសមិនបាន ពិតណាស់ កិលេសទាំងឡាយមានរាគៈជាដើម លោកហៅថា **រណៈ** ឈ្មោះថា អ្នកមានប្រក្រតីនៅដោយរកកិលេសមិនបាន ព្រោះមិនមានកិលេសដែលឈ្មោះថា រណៈ នោះ ។ ឈ្មោះថា អ្នកមានប្រក្រតីនៅដោយរកកិលេសមិនបាន **អរណវិហារ** នោះ មាននៅដល់ភិក្ខុពួកណា ភិក្ខុពួកនោះឈ្មោះថា អ្នកមានប្រក្រតីនៅដោយរកកិលេសមិនបាន **ព្រះសុភូតិត្ថេរ** ជាកំពូលលើពួកភិក្ខុដែលមានប្រក្រតីនៅដោយរកកិលេសមិនបានទាំងនោះ ពិតណាស់ព្រះខីណាស្រពសូម្បីពួកដទៃ ក៏ឈ្មោះថា **អរវិហារី** ក៏ពិត តែព្រះថេរៈក៏បានឈ្មោះយ៉ាងនោះ ដោយព្រះធម៌ទេសនា ភិក្ខុពួកដទៃកាលសម្តែងធម៌ រមែងលើកសរសើរចំពោះគុណខ្លះ បន្ទះបន្ទាប់ខ្លះ ចំណែកព្រះថេរៈ កាលសម្តែងធម៌ ក៏សម្តែងមិនចេញពីប្រការកំណត់ដែលព្រះសាស្តាសម្តែងហើយ ព្រោះដូច្នោះទើបឈ្មោះថា ជាកំពូលលើពួកភិក្ខុ ដែលមានប្រក្រតីនៅដោយរកកិលេសមិន*

បាន ៗ

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថាសូត្រទី ៤

## ប្រវត្តិព្រះសុភូតិត្ថេរ

*គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៤ ដូចតទៅនេះ ៖*

*[១៤៧] បទថា **ទក្ខិណេយ្យានំ** ប្រែថា អ្នកគួរដល់ទក្ខិណា ព្រះខីណាស្រពទាំងឡាយពួកដទៃក៏ឈ្មោះថា ព្រះទក្ខិណេយ្យបុគ្គលដ៏ប្រសើរបំផុត ក្នុងបទថា **ទក្ខិណេយ្យានំ** នោះក៏ពិត តែព្រះថេរៈកំពុងបិណ្ឌបាត ក៏ចូលឈានមានមេត្តាជាអារម្មណ៍ ចេញចាកសមាបត្តិហើយ ទើបទទួលភិក្ខាក្នុងគ្រប់ខ្នងផ្ទះ ដោយទាយកអ្នកថ្វាយភិក្ខានឹងមានផលច្រើន ព្រោះដូច្នោះ លោកទើបហៅថា អ្នកគួរដល់ទក្ខិណា អត្តភាពរបស់លោកល្អស្អាត រុងរឿងយ៉ាងក្រៃលែង ដូចស៊ុមទ្វារដែលគេប្រដាប់ហើយ និងដូចផ្ទាំងសំពត់ដែលវិចិត្រហើយ ដូច្នោះ ទើបហៅថា **សុភូតិ** ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលនឹងពោលតាមលំដាប់ ដូចតទៅនេះ ៖*

*បានឮមកថា ព្រះសុភូតិនេះ កាលព្រះដ៏មានព្រះភាគព្រះនាមថា **បទុមុត្តរៈ** មិនទាន់ទ្រង់ឧប្បត្តិឡើង បានកើតក្នុងត្រកូលព្រាហ្មណ៍មហាសាល ក្នុងក្រុងហង្សវតី ញាតិទាំងឡាយដាក់នាមលោកថា **នន្ទមាណព** លោកចម្រើនវ័យហើយ រៀនត្រៃវេទ មិនឃើញសារៈក្នុងត្រៃវេទនោះ ព្រមដោយបរិវាររបស់ខ្លួន មាន*

មាណពប្រមាណ ៤៤.០០០ នាក់ ចេញបួសជាឥសី នៅត្រង់ជើងភ្នំ ធ្វើអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើត ហើយញុំាងអន្តេវាសិកទាំងឡាយឲ្យបានឈាន ផង ។ ក្នុងសម័យនោះ ព្រះដ៏មានព្រះភាគព្រះនាមថា បទុមុត្តរៈ ទ្រង់កើតក្នុង លោក ទ្រង់អាស្រ័យក្រុងហង្សវតីប្រថាប់នៅ ថ្ងៃមួយ ក្នុងវេលាជិតភ្លឺ ទ្រង់ត្រួត មើលសត្វលោក ទ្រង់ឃើញអរហត្តុបនិស្ស័យរបស់ពួកជដិលជាអន្តេវាសិក របស់នន្ទតាបស និងសេចក្តីប្រាថ្នាតំណែងសាវកអ្នកប្រកបដោយអង្គ ២ របស់ នន្ទតាបស ទើបទ្រង់បដិបត្តិព្រះសរីរៈអំពីព្រឹក ទ្រង់ប្រដាប់បាត្រ និងចីវរ ក្នុង វេលាព្រឹក ស្តេចទៅកាន់អាស្រមរបស់នន្ទតាបស ដោយន័យដែលបានពោល ហើយក្នុងរឿងរបស់ព្រះសារីបុត្តត្ថេរៈ ក្នុងទីនោះ គប្បីជ្រាបការថ្វាយផ្លែឈើ តូចធំក្តី ការតាក់តែងបុប្ផាសនៈក្តី ការចូលនិរោធសមាបត្តិក្តី ដូចន័យដែលពោល ហើយ ។

ក៏ព្រះសាស្តាចេញចាកនិរោធសមាបត្តិ ទ្រង់បញ្ជូនព្រះសាវកមួយអង្គ ដែលប្រកបដោយអង្គ ២ គឺ អរណវិហារអង្គ ១ ទក្ខិណេយ្យអង្គ ១ ថា អ្នក ចូរធ្វើអនុមោទនាបុប្ផាសនៈដល់គណៈឥសី ដូច្នេះ ព្រះថេរៈនោះ នៅក្នុងវិស័យ របស់ខ្លួន ពិចារណាព្រះត្រៃបិដកធ្វើអនុមោទនា កាលចប់ទេសនារបស់លោក ហើយ ព្រះសាស្តាទើបទ្រង់សម្តែង (ធម៌) ដោយព្រះអង្គឯង កាលចប់ទេសនា

តាបសទាំង ៨៤.០០០ បានសម្រេចព្រះអរហត្តគ្រប់រូប ចំណែកនទ្ទតាបស កាន់យកនិមិត្តនៃភិក្ខុដែលអនុមោទនា មិនអាចបញ្ជូនញាណទៅតាមក្រសែនៃទេសនារបស់ព្រះសាស្តាបាន ព្រះសាស្តាទ្រង់លាព្រះហស្តទៅកាន់ភិក្ខុដ៏សេសថា **ឯថ ភិក្ខវោ** (បួរជាភិក្ខុមកចុះ) ភិក្ខុទាំងអស់មានសក់ និងពុកមាត់អន្តរធានហើយ គ្រងបរិក្ខារដែលសម្រេចដោយឫទ្ធិ ប្រាកដដូចព្រះថេរៈ ១០០ វស្សា ។

នទ្ទតាបសថ្វាយបង្គំព្រះតថាគតហើយ ឈរចំពោះព្រះភក្ត្រ ក្រាបទូលថា ព្រះអង្គ ភិក្ខុដែលធ្វើអនុមោទនាបុប្ផាសនៈដល់គណៈឥសី មាននាមថាអ្វីក្នុងសាសនារបស់ព្រះអង្គ ទ្រង់ត្រាស់ថា ភិក្ខុនេះ ជាឯតទគ្គៈដោយអង្គ គឺការប្រព្រឹត្តទៅដោយមិនមានកិលេស ១ ដោយអង្គរបស់ភិក្ខុដែលគួរទក្ខិណា ១ នទ្ទតាបសបានតាំងសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គដ៏ចម្រើន ដោយកម្ម គឺកុសលដ៏ក្រៃលែងដែលខ្ញុំព្រះអង្គបានធ្វើមក ៧ ថ្ងៃនេះ ខ្ញុំព្រះអង្គមិនបានប្រាថ្នាសម្បត្តិដទៃ តែខ្ញុំព្រះអង្គគប្បីជាអ្នកប្រកបដោយអង្គ ២ ដូចជាព្រះថេរៈនេះក្នុងសាសនារបស់ព្រះទសពលអង្គណាមួយក្នុងអនាគត ។ ព្រះសាស្តា ទ្រង់ឃើញសេចក្តីមិនមានអន្តរាយ ទើបទ្រង់ព្យាករណ៍ ហើយស្តេចត្រឡប់ទៅ ។ ចំណែកនទ្ទតាបស ស្តាប់ធម៌ក្នុងសំណាក់ព្រះទសពលតាមសមគួរដល់កាល មិនសាបសូន្យចាកឈាន ក៏ទៅកើតក្នុងព្រហ្មលោក ។ មួយទៀត ព្រះអដ្ឋកថាចារ្យ

មិនបានពោលដល់កល្យាណកម្មរបស់តាបសនេះ ក្នុងរវាងនោះទុក ។ កន្លងទៅសែនកប្ប លោកមកកើតក្នុងផ្ទះនៃសុមនសេដ្ឋី ក្នុងក្រុងសាវត្ថី ពួកញាតិបានដាក់នាមលោកថា **សុភូតិ** ។

តមក ព្រះសាស្តារបស់ពួកយើងទ្រង់កើតក្នុងលោក អាស្រ័យក្រុងរាជគ្រឹះប្រថាប់នៅ គ្រានោះ អនាថបិណ្ឌិកសេដ្ឋីនាំទំនិញ ដែលផលិតក្នុងក្រុងសាវត្ថីទៅកាន់ផ្ទះរបស់រាជគ្រឹះសេដ្ឋីសម្លាញ់របស់ខ្លួន ជ្រាបថា ព្រះសាស្តាទ្រង់ឧប្បត្តិហើយ ទើបចូលទៅគាល់ព្រះសាស្តាដល់ទីប្រថាប់ក្នុងសីតវ័ន ដោយការគាល់គ្រាដំបូងនុ៎ះឯង បានតាំងនៅក្នុងសោតាបត្តិផល ហើយទូលអារាធនាព្រះសាស្តាឲ្យស្តេចមកកាន់ក្រុងសាវត្ថី ឲ្យសាងវិហារដោយការបរិច្ចាគទ្រព្យមួយសែនៗ គ្រប់ៗ យោជន៍ រហូតដល់អស់ផ្លូវ ៤៥ យោជន៍ ទិញឧទ្យានរបស់ព្រះរាជកុមារនាមថា **ជេត** ប្រមាណ ១៨ ករីស ដោយគ្រឿងរាប់របស់ហ្លួងក្នុងក្រុងសាវត្ថី ដោយចំណាយទ្រព្យមួយកោដិសាងវិហារក្នុងទីនោះ ថ្វាយចំពោះព្រះដ៏មានព្រះភាគ ក្នុងថ្ងៃឆ្លងវិហារ សុភូតិកុដុម្ពិកៈក៏បានទៅស្តាប់ធម៌ជាមួយអនាថបិណ្ឌិកសេដ្ឋី បានសទ្ធា ទើបបួសលោកឧបសម្បទហើយធ្វើមាតិកា ២ បទ ឲ្យជំនាញ ឲ្យប្រាប់កម្មដ្ឋានឲ្យ បំពេញសមណធម៌ក្នុងព្រៃ ចម្រើនវិបស្សនាធ្វើមេត្តាឈានឲ្យជាបាទ ក៏សម្រេចអរហត្ត កាលសម្តែងធម៌ ក៏សម្តែងធម៌ដោយ

ន័យដែលពោលហើយនុ៎ះឯង កាលត្រាច់បិណ្ឌបាត ចេញចាកមេត្តាឈានហើយ ទើបទទួលភិក្ខា ដោយន័យដែលពោលហើយដូចគ្នា គ្រានោះព្រះសាស្តាទ្រង់អាស្រ័យហេតុ ២ យ៉ាងនេះ ទើបស្ថាបនាលោកទុកក្នុងភិក្ខុអ្នកគួរដល់ទក្ខិណា ឯតំណែងឯតទគ្គៈ ជាកំពូលលើពួកភិក្ខុអ្នកមានប្រក្រតីនៅដោយមិនមានកិលេស ។

ចប់អដ្ឋកថា សូត្រទី ៤

# អដ្ឋកថាសូត្រទី ៥

## ប្រវត្តិព្រះរេវតត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៥ ដូចតទៅនេះ ៖

[១៨៧] បទថា **អារញ្ញកានំ** បានដល់ អ្នកមានប្រក្រតីនៅព្រៃជាវត្ត បទថា **រេវតោ ខទិរវនិយោ** បានដល់ ប្អូនប្រុសពៅរបស់ព្រះធម្មសេនាបតីត្ថេរៈ លោកមិនបាននៅដូចជាព្រះថេរៈពួកដទៃ កាលនឹងនៅក្នុងព្រៃ ក៏ត្រូវជ្រើសរើសព្រៃ ទឹក និងទីភិក្ខាចារដែលចូលចិត្ត ទើបនៅក្នុងព្រៃ តែលោកមិនប្រកាន់របស់ដែលចូលចិត្តទាំងនេះ អាស្រ័យនៅក្នុងព្រៃគគីជាទីរដិបរដុបដោយដុំគ្រួសនិងដុំថ្មលើទីទួល ដូច្នោះ លោកទើបឈ្មោះថា ជាកំពូលលើពួកភិក្ខុអ្នកនៅព្រៃជាវត្ត ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលនឹងពោលតាមលំដាប់ដូចតទៅនេះ ៖

បានឮថា ក្នុងអតីតកាល សម័យព្រះបទុមុត្តរសម្ពុទ្ធ ព្រះរេវតៈនេះកើតក្នុងហង្សវតី អាស្រ័យកិច្ចការជំនួញតាមសំពៅ ត្រង់កំពង់បយាគបតិស្ឋានក្នុងទន្លេគង្គា សម័យនោះ ព្រះសាស្ដាមានភិក្ខុមួយសែនជាបរិវារ ស្ដេចចារិកទៅដរាបដល់កំពង់បយាគបតិស្ឋាន គេឃើញព្រះទសពលហើយ គិតថា យើងមិនបានឃើញព្រះពុទ្ធគ្រប់គ្រាទេ ខណៈនេះ ជាខណៈដែលយើងនឹងបានខ្វល់ខ្វាយ

ក្នុងកល្យាណកម្មទុក ទើបឲ្យបង់ទូកតម្រៀបគ្នា បង់ពិតានសំពត់ខាងលើព្យួរកម្រងផ្កា គ្រឿងក្រអូបជាដើម ក្រាលកម្រាលដ៏វិចិត្រប្រកបដោយសំពត់សំបកឈើ និមន្តព្រះសាស្តាព្រមទាំងភិក្ខុសង្ឃប្រថាប់គង់ ។ ក្នុងសម័យនោះព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុដែលនៅព្រៃជាវត្តមួយអង្គ ទុកក្នុងតំណែងឯតទគ្គៈ នាយសំពៅនោះឃើញភិក្ខុនោះ ទើបគិតថា សូម្បីយើងក៏គួរជាកំពូលលើពួកភិក្ខុដែលនៅព្រៃជាវត្តក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយក្នុងអនាគត ដូច្នេះទើបនិមន្តព្រះសាស្តាថ្វាយមហាទាន ៧ ថ្ងៃ ក្រាបទៀបបាទមូលរបស់ព្រះសាស្តាធ្វើសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គដ៏ចម្រើន សូម្បីខ្ញុំព្រះអង្គ គប្បីជាកំពូលលើពួកភិក្ខុដែលនៅព្រៃជាវត្ត ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយក្នុងអនាគតដូចជាភិក្ខុដែលព្រះអង្គទ្រង់ស្ថាបនាទុកក្នុងតំណែងឯតទគ្គៈចុះ ព្រះសាស្តាទ្រង់ឃើញថារកអន្តរាយមិនបាន ទ្រង់ព្យាករណ៍ថា ក្នុងអនាគតអ្នកនឹងជាអ្នកកំពូលក្នុងសាសនារបស់ព្រះគោតមសម្ពុទ្ធ ហើយស្តេចត្រឡប់ទៅ ។ មិនបានពោលដល់កម្មរបស់លោកក្នុងរវាងទុក ។

លោកធ្វើកល្យាណកម្មដរាបអស់ជីវិត វិលវល់នៅក្នុងទេវលោក និងមនុស្ស ក្នុងពុទ្ធុប្បាទកាលនេះ ទើបមកបដិសន្ធិក្នុងផ្ទៃនៃនាងសារីព្រាហ្មណីក្នុងស្រុកព្រាហ្មណ៍ ឈ្មោះ នាលកៈ ខេត្តមគធៈ កើតជាប្អូនពៅរបស់បងប្រុស

៣ នាក់ បងស្រី ៣ នាក់ មាតាបិតា ដាក់ឈ្មោះថា **រេវតៈ** គ្រានោះ មាតា-បិតារបស់លោកគិតថា កាលកូនរបស់យើងចម្រើនវ័យហើយ ពួកព្រះសមណសក្យៈបុត្រក៏នឹងមកនាំយកទៅបួស យើងនឹងចងរេវតៈកូនពៅរបស់យើងទុកដោយគ្រឿងចង គឺ ផ្ទះ ដូច្នេះ ហើយនាំនាងទារិកាពីត្រកូលដែលស្មើគ្នាមកឲ្យសំពះយាយរបស់រេវតៈហើយ ពោលថា នែនាង នាងចូរជាអ្នកមានអាយុវែងជាងយាយរបស់នាង រេវតៈ ស្តាប់ពាក្យរបស់អ្នកទាំងនោះហើយ គិតថា នាងទារិកានេះនៅក្នុងបឋមវ័យ គេថា រូបយ៉ាងនេះរបស់នាងទារិកានេះ នឹងដូចជារូបយាយរបស់យើង យើងនឹងសួរសេចក្តីបំណងរបស់អ្នកទាំងនោះសិន ហើយទើបពោលថា លោកទាំងឡាយនឹងធ្វើយ៉ាងណា មាតាបិតាឆ្លើយថា "យើងប្រាប់ថា បាអើយ ស្រីនេះនឹងដល់សេចក្តីជរាដូចជាយាយរបស់ឯង" ។ រេវតៈនោះសួរថា រូបរបស់ស្រីនេះនឹងដូចជាយ៉ាងនេះឬ ។ មាតាបិតាឆ្លើយថា បាអើយកូននិយាយអ្វី អ្នកមានបុណ្យច្រើនក៏នឹងជាយ៉ាងនេះ រេវតៈនោះគិតថា បានឮថារូបនេះក៏នឹងមានស្បែកជ្រីវជ្រួញដោយទំនងនេះ នឹងមានសក់ស្កូវ ធ្មេញបាក់ដោយទំនងនេះ យើងត្រេកអរក្នុងរូបដូច្នេះនឹងមានប្រយោជន៍អ្វី យើងនឹងទៅតាមផ្លូវដែលបងប្រុសរបស់យើងទៅហើយទុំឯង ទើបធ្វើដូចជាឈរនិយាយនឹងក្មេងកម្លោះៗ ស្របាលៗ គ្នាថា មកពួកយើង យើងទៅរត់នៅខាងក្រៅវិញ

មាតាបិតាពោលថា កូនក្នុងថ្ងៃមង្គល កូនកុំទៅខាងក្រៅឡើយ ។

រេវតៈ ធ្វើដូចជាលេងជាមួយក្មេងទាំងឡាយ ពេលដល់វារៈខ្លួនរត់ ក៏ទៅបន្តិច ហើយត្រឡប់ដើរមកយឺតៗ ពេលដល់វារៈទៀត ក៏ទៅឲ្យឆ្ងាយជាងនោះ ហើយត្រឡប់មកវិញ លុះដល់វារៈទីបីក៏ដឹងថា នេះជាវេលារបស់យើងនឹងគេចចេញទៅក្នុងទីចំពោះមុខទុំះឯង ទៅរហូតដល់ព្រៃដែលជាទីនៅរបស់ភិក្ខុអ្នកកាន់បង្សុកូលជាវត្ត អភិវាទព្រះថេរៈហើយ សូមបព្វជ្ជា ព្រះថេរៈពោលថា សប្បុរស យើងមិនស្គាល់អ្នកទេ លោកជាកូនរបស់អ្នកណា និងលោកក៏មកទាំងគ្រឿងប្រដាប់ខ្លួនដូច្នេះ នរណានឹងអាចឲ្យអ្នកបួសបាន គេលើកដៃទាំង ២ ឡើង ស្រែកសំឡេងខ្លាំងៗ ថា គេប្លន់ខ្ញុំ គេប្លន់ខ្ញុំ ដូច្នេះ ពួកភិក្ខុក៏សំដៅមកទាំងខាងណោះខាងនេះ ពោលថា សប្បុរស ក្នុងទីនេះ មិនមាននរណាដែលឈ្មោះថា ប្លន់សំពត់ ឬគ្រឿងប្រដាប់របស់លោកឡើយ លោកនិយាយថាគេប្លន់ដូចម្តេច រេវតៈពោលថា លោកដ៏ចម្រើន ខ្ញុំមិនបានពោលសំដៅដល់សំពត់និងគ្រឿងប្រដាប់ តែពោលសំដៅដល់ពួកលោកប្លន់សម្បត្តិខាងក្នុង មិនបានបំបួសខ្ញុំ ដូច្នេះ សូមមេត្តាប្រាប់ឲ្យបងប្រុសរបស់ខ្ញុំបានជ្រាបចុះ ភិក្ខុសួរថា ក៏បងប្រុសរបស់អ្នកឈ្មោះអ្វី ។ (រេវតៈ) ក្នុងវេលាជាគ្រហស្ថឈ្មោះឧបតិស្សៈ តែក្នុងវេលានេះ មនុស្សទាំងឡាយហៅថា សារីបុត្រ ភិក្ខុទាំងឡាយពោលថា

អាវុសោ បើដូច្នោះ កុលបុត្រអ្នកនេះ ក៏ជាប្អូនប្រុសរបស់ពួកយើង ព្រះធម្ម-សេនាបតីបងប្រុសធំរបស់យើងប្រាប់ជាមុនហើយថា ពួកញាតិរបស់យើងសុទ្ធតែជាមិច្ឆាទិដ្ឋិ បើញាតិរបស់យើងអ្នកណាមួយមក ក៏ចូរឲ្យគេបួសដោយឧបាយណាមួយចុះ ដូច្នោះ ទើបពោលថា កុលបុត្រនេះជាប្អូនរបស់ព្រះថេរៈ លោកទាំងឡាយចូរឲ្យគេបួសចុះ ដូច្នេះ ហើយប្រាប់តចបញ្ចកកម្មដ្ឋាន ព្រះថេរៈរៀនកម្មដ្ឋានដ្ឋានហើយចូលទៅកាន់ព្រៃឈើគគី ដែលមានប្រការដូចពោលទុក ក្នុងទីមិនឆ្ងាយពីឧបជ្ឈាយអាចារ្យបំពេញសមណធម៌ កាលលោកព្យាយាម ដោយតាំងចិត្តថា យើងមិនបានសម្រេចព្រះអរហត្ត ក៏នឹងមិនទៅគាល់ព្រះទសពលឬព្រះថេរៈជាបងប្រុស កន្លងទៅ ៣ ខែ ជាសត្វដែលជាសុខមាលជាតិ បរិភោគភោជនដែលសៅហ្មង ចិត្តមិនឆ្ពោះមុខទៅក្នុងព្រះកម្មដ្ឋាន ដោយកន្លងទៅ ៣ ខែ បវារណាចេញវស្សាហើយ ទើបបំពេញសមណធម៌ក្នុងទីនោះឯង កាលលោកបំពេញសមណធម៌ ចិត្តក៏មានអារម្មណ៍តែមួយ លោកចម្រើនវិបស្សនា ក៏សម្រេចក៏បានព្រះអរហត្ត ។

គ្រានោះ ព្រះសារីបុត្រទូលព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន បានឮថា រេវតៈប្អូនពៅរបស់ខ្ញុំព្រះអង្គចេញបួស គេនឹងត្រេកអរ ឬមិនត្រេកអរ ខ្ញុំព្រះអង្គនឹងទៅសួរសុខទុក្ខគេ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា ព្រះរេវតៈផ្តើម

វិបស្សនាហើយ ទើបទ្រង់ហាម ២ ដង ក្នុងលើកទី ៣ លោកទូលអង្វរទៀត ទ្រង់ជ្រាបថា សម្រេចព្រះអរហត្តហើយ ទើបត្រាស់ថា សារីបុត្រ ស្តីវ្រីតថាគត ក៏នឹងទៅជាមួយ អ្នកចូរប្រាប់ភិក្ខុទាំងឡាយចុះ ព្រះថេរៈប្រជុំភិក្ខុសង្ឃហើយ ប្រាប់ដល់ព្រះភិក្ខុទាំងឡាយថា អាវុសោ ព្រះសាស្តាមានព្រះបំណងនឹងស្តេចចារិក លោកម្ចាស់អង្គណាប្រាថ្នានឹងទៅជាមួយ ក៏ចូរមកចុះ ក្នុងវេលាដែលព្រះទសពលស្តេចចារិក ឈ្មោះថា ភិក្ខុអ្នកឃឹតយូរមានតិច ដោយច្រើន ភិក្ខុជាច្រើនប្រាថ្នានឹងទៅ ព្រោះគិតថា នឹងបានឃើញព្រះសរីរៈរបស់ព្រះសាស្តាដែលមានវណ្ណៈដូចមាស ឬនឹងបានស្តាប់ធម្មកថាដ៏ពីរោះ ដោយប្រការដូច្នេះ ព្រះសាស្តាមានភិក្ខុពួកធំជាបរិវារ ស្តេចចេញទៅដោយបំណងនឹងសួរសុខទុក្ខ ព្រះរេវតៈ ព្រះអានន្ទត្ថេរៈ ដល់ផ្លូវបែកជា ២ ក្នុងទីមួយកន្លែង គ្រានោះទើបទូលសួរព្រះដ៏មានព្រះភាគថា ត្រង់នេះមានផ្លូវបែកជា ២ ភិក្ខុសង្ឃនឹងទៅផ្លូវណា ព្រះអង្គ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា អានន្ទ ផ្លូវណាមួយជាផ្លូវត្រង់ ព្រះថេរៈទូលថា បពិត្រព្រះអង្គដ៏ចម្រើន ផ្លូវត្រង់មានចម្ងាយ ៣០ យោជន៍ ជាផ្លូវរបស់អមនុស្ស (ដើរ) ចំណែកផ្លូវវាងមានចម្ងាយ ៦០ យោជន៍ ជាផ្លូវផុតភ័យ រកភិក្ខាបានងាយ ព្រះដ៏មានព្រះភាគត្រាស់ថា អានន្ទ ព្រះសីវលីមកជាមួយយើងឬទេ ព្រះថេរៈក្រាបទូលថា មកជាមួយព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា បើដូច្នោះ

ចូរឲ្យព្រះសង្ឃទៅផ្លូវត្រង់ តថាគតនឹងសាកល្បងបុណ្យរបស់ព្រះសីវលី ព្រះសាស្តាមានភិក្ខុសង្ឃជាបរិវារ ស្តេចពុទ្ធដំណើរផ្លូវត្រង់ ដើម្បីសាកល្បងបុណ្យរបស់ព្រះសីវលិត្ថេរៈ ផ្តើមតាំងពីព្រះសាស្តាស្តេចពុទ្ធដំណើរកាន់ផ្លូវ ពួកទេវតានិម្មិតនគរក្នុងទីគ្រប់ៗ យោជន៍ តាក់តែងវិហារដើម្បីជាទីនៅ ថ្វាយភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ពួកទេវបុត្រដូចជាពួកកម្មករ ដែលព្រះរាជាបញ្ជូនទៅកាន់បាយយាគូ និងរបស់ទំពារជាដើមទៅ សួរថា លោកម្ចាស់សីវលីនៅឯណា លោកម្ចាស់សីវលីនៅឯណា ព្រះថេរៈឲ្យបញ្ជូនគ្រឿងសក្ការៈទៅកាន់សំណាក់ព្រះសាស្តា ព្រះសាស្តាព្រមទាំងភិក្ខុសង្ឃទ្រង់សរសើរគ្រឿងសក្ការៈ ដោយទំនងនេះឯង ស្តេចដំណើរទៅអស់ចម្ងាយផ្លូវមួយថ្ងៃយោជន៍ជាយ៉ាងក្រៃលែង កន្ទងផ្លូវកន្តាររហូតអស់ ៣០ យោជន៍ ដរាបដល់ទីស្នាក់អាស្រ័យរបស់ព្រះខទិរវនិយត្ថេរៈ ។

ព្រះថេរៈជ្រាបថា ព្រះសាស្តាស្តេចមក និម្មិតវិហារជាទីនៅរបស់ខ្លួនឲ្យល្មមដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន និងព្រះគន្ធកុដិទីសម្រាកពេលយប់ ទីសម្រាកពេលថ្ងៃជាដើម ថ្វាយព្រះទសពលដោយឫទ្ធិ ហើយចេញទៅទទួលព្រះសាស្តា ព្រះសាស្តាស្តេចចូលកាន់វិហារតាមផ្លូវដែលតាក់តែងហើយ ។ គ្រានោះ កាលព្រះតថាគតស្តេចចូលព្រះគន្ធកុដិ ភិក្ខុទាំងឡាយក៏ចូលទៅកាន់សេនា-

សនៈដែលដល់ហើយសមគួរដល់វស្សា ទេវតាគិតថា វេលានេះមិនមែនជាវេលាអាហារ ទើបនាំទឹកអដ្ឋបានមកថ្វាយ ព្រះសាស្តាទ្រង់សោយទឹកអដ្ឋបាន ព្រមជាមួយភិក្ខុសង្ឃ ដោយទំនងនេះ ព្រះសាស្តាទ្រង់សរសើរសក្ការៈកន្លងទៅកន្លះខែ ។ គ្រានោះ ភិក្ខុដែលមានសេចក្តីអផ្សុកពួកខ្លះ អង្គុយនៅក្នុងទីជាមួយគ្នាសន្ទនាគ្នាថា ព្រះសាស្តាទ្រង់ជាទសពលត្រាស់ថា ប្អូនប្រុសពៅព្រះអគ្គសាវករបស់យើង ស្តេចមកសួរសុខទុក្ខចំពោះភិក្ខុជានវកម្មិកៈដែលកសាងបែបនេះឬគិតថា ជេតវនមហាវិហារ ឬវេឡុវនមហាវិហារជាដើម នឹងធ្វើអ្វីក្នុងសំណាក់នៃវិហារនេះបាន ភិក្ខុនេះជាអ្នកធ្វើនវកម្មបែបនេះ នឹងអាចធ្វើសមណធម៌អ្វីបានដូច្នេះ ។

គ្រានោះ ព្រះសាស្តាទ្រង់ព្រះតម្រិះថា បើតថាគតនៅយូរ ទីនេះក៏នឹងប្របូកប្របល់ ធម្មតាភិក្ខុដែលនៅព្រៃជាវត្ត រមែងត្រូវការក្នុងសេចក្តីស្ងាត់ រេវតៈនឹងនៅមិនជាសុខ បន្ទាប់ពីនោះ ស្តេចទ្រង់ទៅកាន់ទីសម្រាកពេលថ្ងៃរបស់ព្រះរេវតៈ ។

ព្រះថេរៈអង្គុយលើផ្ទាំងថ្មបន្អែកមួយផ្ទាំងដែលសកាពទេរចុះ ត្រង់ទីខាងចុងចង្រ្កមតែម្នាក់ឯង ឃើញព្រះសាស្តាស្តេចមកពីចម្ងាយ ទើបក្រោកឡើងថ្វាយបង្គំ , ទីនោះ ព្រះសាស្តាត្រាស់សួរលោកថា រេវតៈ ទីនេះ ជាទីប្រកបដោយ

សត្វកាច លោកបានឮសំឡេងដំរី និងសេះជាដើម ដែលកាចៗ ធ្វើយ៉ាងណា ចំពោះសំឡេងនោះ ។ ព្រះរេវតៈទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំព្រះអង្គបានឮសំឡេងរបស់សត្វទាំងនោះ រមែងកើតបីតិនៅក្នុងព្រៃ ព្រះសាស្ដាត្រាស់ព្រះតម្រាស់ឈ្មោះ **អរញ្ញបសំសកថា** ដោយគាថា ៥០០ ដល់ព្រះរេវតត្ថេរៈ ។ ថ្ងៃស្អែក ស្ដេចទៅដើម្បីបិណ្ឌបាតក្នុងទីមិនឆ្ងាយ ហើយហៅព្រះរេវតៈមក ទ្រង់ធ្វើឲ្យពួកភិក្ខុដែលពោលតិះដៀលព្រះថេរៈ ឲ្យវង្វេងភ្លេចឈើប្រត់ ស្បែកជើង បំពង់ត្រងទឹកប្រេង និងឆត្រ ភិក្ខុទាំងនោះត្រូវត្រឡប់មកដើម្បីយកបរិក្ខាររបស់ខ្លួន ដើរទៅតាមផ្លូវដែលខ្លួនមកហើយនុ៎ះឯង ក៏កំណត់ស្ថានទីដែលខ្លួនទុកមិនបាន ។ ក៏ដំបូង ភិក្ខុទាំងនោះដើរទៅតាមផ្លូវដែលគេតាក់តែងហើយ តែក្នុងថ្ងៃនោះ ត្រឡប់ជាដើរទៅតាមផ្លូវរដិបរដុប ត្រូវអង្គុយច្រហោង ត្រូវដើរទៅដោយជន្លង់ក្នុងទីនោះៗ ភិក្ខុទាំងនោះ ខ្លះទ្រានលើជង្គត់ឈើ គុម្ពោតព្រៃ និងបន្លាទៅដល់ទីដែលខ្លួនធ្លាប់នៅ ក៏ឃើញឆត្ររបស់ខ្លួននៅលើជង្គត់គគីរខ្លះ ឃើញស្បែកជើង ឈើប្រត់ បំពង់ត្រងទឹក ក្នុងទីកណ្ដាលវាល ពួកគេទើបដឹងថា ភិក្ខុនេះជាអ្នកមានឫទ្ធិ លុះកាន់យកបរិក្ខាររៀងៗ ខ្លួនហើយ និយាយថា ដែលឈ្មោះថា សក្ការៈដែលតាក់តែងថ្វាយព្រះទសពល រមែងមានត្រឹមតែប៉ុណ្ណោះ ក៏បាននាំគ្នាត្រឡប់ទៅ ។

នាងវិសាខាមហាឧបាសិកា សួរពួកភិក្ខុដែលទៅមុន ក្នុងវេលាដែលពួកលោកគង់ក្នុងផ្ទះរបស់ខ្លួនថា លោកម្ចាស់ដ៏ចម្រើន ទីនៅរបស់ព្រះរេវតត្ថេរគួរពេញចិត្តឬទេ ភិក្ខុទាំងនោះឆ្លើយថា គួរពេញចិត្តឧបាសិកា សេនាសនៈនោះប្រៀបដូចជាសួននន្ទវ័ន និងចិត្តលតាវ័នជាដើម បន្ទាប់ពីនោះ ទើបសួរពួកភិក្ខុដែលមកដល់ក្រោយគេថា លោកម្ចាស់ ទីនៅរបស់ព្រះរេវតត្ថេរៈគួរពេញចិត្តទេ ភិក្ខុទាំងនោះឆ្លើយថា កុំសួរឡើយឧបាសិកា ទីនោះ ជាទីដែលមិនសមគួរនឹងនិយាយដល់ ជាទីទួល មានដុំគ្រួសដុំថ្ម ព្រៃឈើគគីយ៉ាងនេះ តែភិក្ខុនោះនៅក្នុងទីនោះបាន មហាឧបាសិកាវិសាខា ស្តាប់ពាក្យរបស់ភិក្ខុដែលមកមុន និងមកពេលក្រោយហើយ គិតថា ពាក្យរបស់ភិក្ខុពួកណាហ្ន៎ជាពាក្យពិត ពេលក្រោយកត្ត កាន់យកគ្រឿងក្រអូប និងផ្កាឈើទៅឧបដ្ឋាកព្រះទសពល ថ្វាយបង្គំហើយអង្គុយក្នុងទីសមគួរម្ខាង ទើបទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន លោកម្ចាស់ពួកខ្លះសរសើរទីនៅរបស់ព្រះរេវតត្ថេរៈ ពួកខ្លះតិះដៀល ប្រការនេះដូចម្តេច ព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ម្នាលវិសាខាមហាឧបាសិកា ទីនៅរបស់ព្រះអរិយៈនឹងជាទីគួររីករាយ ឬមិនគួររីករាយចូរលើកទុកចុះ តែចិត្តរបស់ព្រះអរិយៈរមែងត្រេកអរ ទីនោះ ឈ្មោះថា ជាទីគួររីករាយដោយពិត ដូច្នេះហើយត្រាស់ព្រះគាថានេះថា ៖

*គាមេ វា យទិ វារញ្ញេ   និន្នេ វា យទិ វា ថលេ*
*យត្ថ អរហន្តោ វិហរន្តិ   តំ ភូមិរាមណេយ្យកន្តិ ។*

ព្រះអរហន្តទាំងឡាយ នៅក្នុងទីណា មិនថាជាស្រុក ព្រៃ ទីទួល ឬទីទំនាបក៏ដោយ ទីនោះ ជាភូមិភាគដែលគួររីករាយនោះឯង ដូច្នេះ ។

តមកក្នុងខាងក្រោយ ព្រះសាស្តាប្រថាប់គង់ត្រង់កណ្តាលពួកព្រះអរិយៈក្នុងជេតវនមហាវិហារ ទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងជាកំពូលលើពួកភិក្ខុទាំងឡាយអ្នកមានប្រក្រតីនៅក្នុងព្រៃជាវត្តនោះឯង ។

ចប់អដ្ឋកថា សូត្រទី ៩

# អដ្ឋកថាសូត្រទី ៦

## ប្រវត្តិព្រះកង្ខារេវតត្ថេរ

*គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៦ ដូចតទៅនេះ ៖*

[១៤៧] *បទថា* **ឈាយីនំ** *បានដល់ អ្នកបានឈាន គឺ អ្នកត្រេកអរក្រៃលែងក្នុងឈាន បានឮថា ព្រះថេរៈនោះឈ្មោះថា ជាកំពូលលើពួកភិក្ខុដែលបានឈាន តិចជាងព្រះទសពលទ្រង់ចូលសមាបត្តិ លោកចូលសមាបត្តិដោយចំណែកច្រើន ព្រោះដូច្នោះ លោកទើបឈ្មោះថា ជាកំពូលលើពួកភិក្ខុដែលចូលឈាន លោកហៅថា* **កង្ខារេវតៈ** *ព្រោះជាអ្នកច្រើនដោយសេចក្តីសង្ស័យ សេចក្តីរំខាន អធិប្បាយថា* **កុក្កុច្ចកា** *ជាអ្នកមានសេចក្តីរំខាន ឈ្មោះថា សង្ស័យ ។ សួរថា ក៏ភិក្ខុដទៃ មិនមានសេចក្តីសង្ស័យឬ ? ឆ្លើយថា មាន តែព្រះថេរៈនេះសូម្បីក្នុងវត្ថុដែលគួរ ក៏កើតសេចក្តីសង្ស័យ ព្រោះដូច្នោះ ព្រះថេរៈនោះទើបជាអ្នកមានសេចក្តីសង្ស័យជាប្រក្រតី ប្រាកដច្បាស់ហើយ ព្រោះហេតុនោះ ទើបរាប់ថា កង្ខារេវតៈ អ្នកច្រើនដោយសេចក្តីសង្ស័យ ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលនឹងពោលតាមលំដាប់ដូចតទៅនេះ ៖*

*បានឮថា គ្រាព្រះពុទ្ធព្រះនាមថា* **បទុមុត្តរៈ** *ព្រះថេរៈនេះទៅវិហារជាមួយ*

មហាជន ដោយន័យខាងដើមនោះឯង ឈរស្តាប់ធម៌នៅខាងក្រោយបរិស័ទបាន ឃើញព្រះសាស្តា ទ្រង់ស្ថាបនាភិក្ខុមួយរូបទុកក្នុងតំណែងឯតទគ្គៈជាកំពូលលើ ពួកភិក្ខុដែលត្រេកអរក្នុងឈាន ទើបគិតថា សូម្បីយើងក៏គប្បីដូចជាភិក្ខុនោះក្នុង អនាគត ចប់ទេសនា ទើបនិមន្តព្រះសាស្តាថ្វាយគ្រឿងសក្ការៈធំ ៧ ថ្ងៃ ដោយ ន័យមុននុ៎ះឯង ក្រាបទូលព្រះដ៏មានព្រះភាគថា ព្រះអង្គ ខ្ញុំព្រះអង្គមិនបានប្រាថ្នា សម្បត្តិដទៃដោយកម្ម គឺ ការធ្វើកុសលដ៏ក្រៃលែងនេះ ប៉ុន្តែថា ខ្ញុំព្រះអង្គគប្បី ជាកំពូលលើពួកភិក្ខុដែលបានឈាន ក្នុងសាសនារបស់ព្រះពុទ្ធមួយព្រះអង្គក្នុង អនាគត ដូចជាភិក្ខុដែលព្រះអង្គទ្រង់ស្ថាបនាទុកក្នុងតំណែងឯតទគ្គៈជាកំពូលលើ ពួកភិក្ខុដែលបានឈាន ក្នុងទីបំផុត ៧ ថ្ងៃ រាប់ពីថ្ងៃនេះទៅ លោកបានធ្វើ សេចក្តីប្រាថ្នាដូចពោលមកនេះ ព្រះសាស្តាទ្រង់ពិចារណាមើលអនាគត ទ្រង់ឃើញ សេចក្តីសម្រេច ទើបទ្រង់ព្យាករណ៍ថា ក្នុងអនាគត ក្នុងទីបំផុតនៃសែនកប្ប ព្រះពុទ្ធព្រះនាមថា **គោតម** ទ្រង់នឹងឧប្បត្តិ អ្នកនឹងជាកំពូលលើពួកភិក្ខុដែល បានឈានក្នុងសាសនារបស់ព្រះអង្គ ដូច្នេះ ហើយស្តេចក៏ត្រឡប់ ។

លោកធ្វើកម្មជាកុសលរហូតអស់ជីវិត វិលវល់នៅក្នុងទេវតា និងមនុស្ស អស់សែនកប្ប គ្រាព្រះដ៏មានព្រះភាគរបស់យើង លោកមកកើតក្នុងត្រកូលដែល មានភោគសម្បត្តិច្រើនក្នុងក្រុងសាវត្ថី ទៅវិហារជាមួយមហាជនដែលកំពុងដើរ

ទៅស្តាប់ធម៌ក្នុងវេលាក្រោយអាហារ ឈរស្តាប់ធម្មកថារបស់ព្រះទសពលខាង ក្រោយបរិស័ទ បានសទ្ធា បព្វជ្ជាឧបសម្បទាហើយ សូមឲ្យព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ប្រាប់កម្មដ្ឋាន ធ្វើបរិកម្មក្នុងឈាន ក៏ជាអ្នកបានឈាន ធ្វើឈាននោះ ឯងឲ្យជាបាទ សម្រេចព្រះអរហត្តផល លោកសម្រាកតិចជាងសមាបត្តិដែល ព្រះទសពលចូល ចូលសមាបត្តិដោយចំណែកច្រើន ទើបមានសេចក្តីជំនាញ ដែលសន្សំទុកក្នុងឈានទាំងឡាយ ទាំងពេលថ្ងៃទាំងពេលយប់ តមកខាងក្រោយ ព្រះសាស្តាទ្រង់កាន់យកគុណយ៉ាងនេះ ស្ថាបនាលោកទុកក្នុងតំណែងជាកំពូល លើពួកភិក្ខុដែលបានឈាន ក៏លោកឈ្មោះថា កង្ខារេវតៈ ព្រោះមានសេចក្តី សង្ស័យ ពោលគឺ សេចក្តីវិនាន ដែលមានសេចក្តីរង្កៀសកើតឡើងក្នុងវត្ថុទាំង ឡាយដែលជាកប្បិយទុ៊ះឯង យ៉ាងនេះថា អាវុសោ ទឹកអំពៅជាអកប្បិយៈ មូត្រ ជាអកប្បិយៈ ។

ចប់អដ្ឋកថា សូត្រទី ៦

# អដ្ឋកថាសូត្រទី ៧

## ប្រវត្តិព្រះសោណកោឡិវិសត្ថេរៈ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៧ ដូចតទៅនេះ ៖

[១៨៧] បទថា ***អារទ្ធវិរិយានំ*** សេចក្តីថា អ្នកតាំងសេចក្តីព្យាយាមហើយ អ្នកមានសេចក្តីព្យាយាមបរិបូណ៌ហើយ ។ ពាក្យថា ***សោណោ កោឡិវិសោ*** ជាឈ្មោះរបស់ព្រះថេរៈនោះ ។ ពាក្យថា ***កោឡិវិសោ*** ជាគោត្រ ។ ម្យ៉ាងទៀត សេចក្តីថា ឈ្មោះថា ***កោឡិវេសោ*** អធិប្បាយថា កុមារនៃត្រកូលវេស្សៈ ជាអ្នកដល់ទីបំផុតដោយភាពឥស្សរៈ ព្រោះហេតុ ដែលធម្មតាថា សេចក្តីព្យាយាមរបស់ភិក្ខុពួកដទៃ រមែងត្រូវការធ្វើឲ្យចម្រើន តែរបស់ព្រះថេរៈ ត្រឹមតែអប់រំប៉ុណ្ណោះ ព្រោះដូច្នោះ ព្រះថេរៈនេះ ឈ្មោះថា ជាកំពូលលើពួកភិក្ខុដែលមានសេចក្តីព្យាយាមដែលប្រារព្ធហើយ ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលនឹងគប្បីពោលតាមលំដាប់ដូចតទៅនេះ ៖

បានឮថា ក្នុងអតីតកាល សម័យព្រះពុទ្ធព្រះនាមថា ***បទុមុត្តរៈ*** ព្រះថេរៈនេះ កើតក្នុងត្រកូលសេដ្ឋី ពួកញាតិដាក់នាមរបស់លោកថា ***សិរិវឌ្ឍកុមារ*** លោកចម្រើនវ័យហើយ ទៅវិហារដោយន័យមុនទុំះឯង ឈរស្តាប់ធម៌នៅខាងក្រោយ

បរិស័ទ ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូបទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលលើពួកភិក្ខុដែលមានសេចក្តីព្យាយាមដែលប្រារព្ធហើយ ទើបគិតថា សូម្បីយើងក៏ដូចជាភិក្ខុនេះក្នុងអនាគត ចប់ទេសនា ទើបអារាធនាព្រះទសពលថ្វាយមហាទាន ៧ ថ្ងៃ បានធ្វើសេចក្តីប្រាថ្នា ដោយន័យដែលពោលហើយនុ៎ះឯង ព្រះសាស្តាទ្រង់ជ្រាបថា សេចក្តីប្រាថ្នារបស់លោកសម្រេច ទើបទ្រង់ព្យាករណ៍ដោយន័យមុននោះឯង ស្តេចក៏ត្រឡប់ទៅកាន់ព្រះវិហារ ។ ចំណែកសិរីវឌ្ឍសេដ្ឋីនោះធ្វើកុសលរហូតអស់ជីវិត វិលវល់នៅក្នុងទេវតា និងមនុស្សក្រនួងទៅសែនកប្បកាលព្រះកស្សបទសពលបរិនិព្វានហើយ ក្នុងកប្បនេះ លុះព្រះដ៏មានព្រះភាគរបស់យើងទ្រង់មិនទាន់ឧប្បត្តិ ក៏មកបដិសន្ធិក្នុងត្រកូលអ្នកក្រុងពារាណសី លោកទៅលេងទឹកឯទន្លេគង្គាជាមួយពួកសម្លាញ់របស់ខ្លួន គ្រានោះ ព្រះបច្ចេកពុទ្ធមួយអង្គមានចីវរចាស់ ចូលអាស្រ័យក្រុងពារាណសី សាងបណ្ណសាលានៅមាត់ច្រាំងទន្លេគង្គា តាំងចិត្តថា នឹងចូលចាំវស្សា ទើបទៅទាញកំណាត់ឈើ និងវល្លិ៍ដែលត្រូវទឹកបង្ហាត់មកជាប់ចេញ កុមារនេះព្រមទាំងសម្លាញ់ដើរទៅឈរអភិវាទហើយសួរថា លោកម្ចាស់ធ្វើអ្វី ព្រះបច្ចេកពុទ្ធត្រាស់ថា បាទាំងឡាយ វេលាចូលវស្សាហើយ ធម្មតាបព្វជិតគួរបានទីនៅ កុមារពោលថា លោកម្ចាស់ ថ្ងៃនេះសូមលោកម្ចាស់រង់ចាំមួយថ្ងៃសិន , ស្អែកនេះ ខ្ញុំនឹងធ្វើទីនៅថ្វាយលោកម្ចាស់

ព្រះបច្ចេកពុទ្ធទ្រង់បានផ្អាក ព្រោះទ្រង់មកដោយតាំងចិត្តថា នឹងធ្វើសេចក្តីសង្គ្រោះកុមារនេះដូចគ្នា កុមារនោះជ្រាបថា ព្រះបច្ចេកពុទ្ធទទួលនិមន្តហើយ ថ្ងៃស្អែកទើបចាត់ចែងគ្រឿងសក្ការៈទៅឈរចាំព្រះបច្ចេកពុទ្ធមក ចំណែកព្រះបច្ចេកពុទ្ធទ្រង់រំលឹកថា ថ្ងៃនេះយើងនឹងត្រាច់រកអាហារទីណាហ្ន៎ ទើបទៅកាន់ផ្ទះរបស់កុមារនោះ កុមារឃើញព្រះបច្ចេកពុទ្ធហើយ ក៏ជ្រះថ្លា ទទួលបាត្រ ថ្វាយអាហារនិមន្តថា រហូតដល់អស់ថ្ងៃខាងក្នុងវស្សានេះ សូមព្រះអង្គអនុគ្រោះមកកាន់ផ្ទះរបស់ខ្ញុំប៉ុណ្ណោះ ព្រះបច្ចេកពុទ្ធទទួលពាក្យ ឆាន់ស្រេចហើយក៏ចៀសចេញទៅ , ទើបទៅជាមួយសម្លាញ់របស់ខ្លួនជួយគ្នាសាងបណ្ណសាលាជាទីនៅ ទីចង្រ្កម និងទីសម្រាកពេលថ្ងៃ និងពេលយប់ ថ្វាយព្រះបច្ចេកពុទ្ធសម្រេចតែក្នុងមួយថ្ងៃ កុមារនោះគិតថា វេលាព្រះបច្ចេកពុទ្ធចូលបណ្ណសាលា កក់លើផ្ទៃដីដែលលាបដោយរបស់ខៀវស្រស់ សូមកុំបានជាប់ជើង ទើបក្រាលសំពត់កម្ពលក្រហមមានតម្លៃមួយពាន់ ដែលជាសំពត់ដណ្តប់របស់ខ្លួនគ្របលើផ្ទៃដី ឃើញរស្មីសរីរៈរបស់ព្រះបច្ចេកពុទ្ធដូចគ្នានឹងពណ៌របស់សំពត់កម្ពល ក៏ជ្រះថ្លាយ៉ាងក្រៃលែងពោលថា ចាប់ផ្តើមតាំងពីវេលាដែលលោកម្ចាស់ជាន់ហើយ ពន្លឺនៃសំពត់កម្ពលនេះ ចិញ្ចាចចិញ្ចែងយ៉ាងក្រៃលែងយ៉ាងណា សូមវណ្ណៈនៃដៃ និងជើងរបស់ខ្ញុំក៏ចូរមានពណ៌ដូចផ្កាសិរមាន់ ក្នុងទីដែលខ្ញុំកើតហើយកើតទៀត ដូច្នោះ សូមឲ្យ

ផស្សៈចូវដូចនឹងផស្សៈនៃផ្ទាំងសំពត់កប្បាសដែលគេថ្ពិចហើយ ៧ ជងនោះឯង កុមារនោះ ទំនុកបម្រុងព្រះបច្ចេកពុទ្ធវហូតដល់អស់ត្រៃមាស បានថ្វាយត្រៃចីវរ កាលវេលាបវារណាហើយ ព្រះបច្ចេកពុទ្ធមានបាត្រ និងចីវរបរិបូណ៌ហើយ ទើប ទៅកាន់ភ្នំគន្ធមាទន៍ដូចដើម ។

សម័យព្រះមានព្រះភាគរបស់យើង ចំណែកកុលបុត្រនោះ វិលវល់នៅ ក្នុងទេវតា និងមនុស្ស មកបដិសន្ធិក្នុងផ្ទះរបស់ឧសភសេដ្ឋី ក្នុងក្រុងកាលចម្បាក តាំងពីវេលាដែលកុលបុត្រនោះបដិសន្ធិ គ្រឿងបណ្ណាការច្រើនពាន់មកកាន់ត្រកូល សេដ្ឋី ក្នុងថ្ងៃដែលកើតទុំះឯង ទូទាំងព្រះនគរបានមាន គ្រឿងសក្ការៈតែម្យ៉ាង ដូចគ្នា តមកក្នុងថ្ងៃតាំងឈ្មោះកុមារនោះ មាតាបិតាគិតថា បុត្ររបស់យើងនាំ ឈ្មោះរបស់ខ្លួនមកហើយ រស្មីសរីរៈរបស់គេដូចស្រោបដោយមាសឆ្អិនក្រហម ព្រោះដូច្នោះ ទើបតាំងឈ្មោះរបស់កុមារនោះថា **សោណកុមារ** គ្រានោះ សេដ្ឋី ឲ្យស្រីបម្រើរក្សាបុត្រនោះឲ្យចម្រើនដោយសេចក្ដីសុខ ដូចជាទេវកុមារ ការចាត់ ចែងអាហារសម្រាប់កុមារនោះមានហើយយ៉ាងនេះ ទីស្រែដែលព្រោះស្រូវមាន ប្រមាណ ៦០ ករីស រក្សាដោយទឹក ៣ យ៉ាង យកធុងដាក់ទឹកដោះ និងទឹក ក្រអូបច្រើនពាន់ធុងស្រោចចូល ដូចទឹកដែលហូរចូលទៅក្នុងស្រែអំពីទីទួល វេលា ស្រូវសាលីដាក់ទឹកដោះ ក៏ដាំបង្គោលព័ទ្ធជុំវិញ និងក្នុងចន្លោះៗ ដើម្បីការពារ

សត្វទាំងឡាយ មានសត្វសេកជាដើម ធ្វើជាដែន និងដើម្បីឲ្យក្តួរស្រូវមានសភាព ទន់ល្វន់ ក្រាលសំពត់សាច់ល្អិតទុកលើបង្គោល យកឈើគងខាងលើ បិទដោយ កន្ទេលផែង បិតបាំងវាំងននដោយជុំវិញ ចាត់រក្សាទុកក្នុងទីជុំវិញគ្រប់ចំណែក កាលស្រូវទុំឡើងកាន់ជង្រុក ក៏ប្រោះព្រំដោយគន្ធជាតិ ៤ យ៉ាង អប់ដោយរបស់ ក្រអូបដ៏ប្រសើរទុកខាងលើ ពួកមនុស្សច្រើនសែន ចុះកាត់គួរស្រូវសាលីធ្វើ ជាកណ្តាប់ៗ ចងដោយខ្សែ ហាលឲ្យស្ងួត តពីនោះ ក្រាលរបស់ក្រអូបត្រង់ផ្ទៃ ក្រោមជង្រុក តម្រៀបគួរស្រូវទុកខាងលើ ឲ្យមានចន្លោះៗ អំពីគ្នា ដរាបពេញ ជង្រុកទើបបិទទ្វារ កាលគ្រប់ ៣ ឆ្នាំ ទើបគាស់បើកជង្រុកស្រូវ វេលាបើក ក៏មានក្លិនពិដោរផ្សាយទៅទូទាំងព្រះនគរ កាលបោកស្រូវសាលី ពួកអ្នកលេង ក៏នាំគ្នាមកទិញអង្កាមយកទៅ ចំណែកកន្ទក់ ពួកអ្នកបម្រើក៏យកទៅ វេលាបុក អង្ករ ក៏មករើសយកអង្ករទៅរក្សាទុក បុគ្គលទាំងនោះដាក់អង្ករនោះទុកក្នុងកញ្ច្រែង មាស ប្រមុជចុះក្នុងជាតិរសម្តង ទើបដាក់ក្នុងកញ្ច្រែងមាសទី ៣ ហើយដាក់ ជាតិរសទឹកច័ន្ទដែលនៅក្តៅៗ ដែលត្រង ៧ ដង យកតែម្តង ហើយក៏លើកឡើង ទឹកច័ន្ទដែលក្តៅ ដែលគេត្រង ៧ ដង ដាក់ស្រូវសាលីចុះ ហើយលើកឡើង ពីទឹក ដូចជាផ្កាម្លិះ ជនទាំងឡាយទើបដាក់ភោជននោះទុកក្នុងថាសមាស ត្រួត លើថាសប្រាក់ ដែលពេញដោយបាយមធុបាយាសមានទឹកតិច នៅក្តៅៗ កាន់ទៅ

ដាក់អំពីខាងមុខសេដ្ឋីបុត្រ សេដ្ឋីបុត្រនោះបរិភោគល្មមញុំាងអត្តភាពឲ្យប្រព្រឹត្ត ទៅសម្រាប់ខ្លួនហើយ លាងមាត់ដោយទឹកដែលអប់ដោយគ្រឿងក្រអូប ហើយ លាងដៃ និងជើង ទើបនាំគ្រឿងអប់មាត់មានប្រការផ្សេងៗ មកឲ្យដល់សេដ្ឋីបុត្រ នោះ ដែលបានលាងដៃ និងជើងហើយ ក្រាលកម្រាលដ៏វិចិត្រដោយសំពត់សំបក ឈើយ៉ាងល្អ ក្នុងទីដែលសេដ្ឋីបុត្រនោះជាន់ បាតដៃ និងបាតជើងរបស់សេដ្ឋីបុត្រ នោះ មានពណ៌ដូចពណ៌ផ្កាសិរមាន់ លោមាដែលមានវណ្ណៈដូចកែវមណី និង កែវកុណ្ឌលកើតត្រង់បាតជើង ដូចសម្ផស្សរបស់សំពត់កប្បាសដែលគេថ្ពិចហើយ ៧ ជង សេដ្ឋីបុត្រនោះក្រោធអ្នកណាៗ នឹងនិយាយថា ចូរដឹង ខ្ញុំនឹងដើរជាន់ដី ។ កាលលោកចម្រើនវ័យហើយ ឲ្យសាងប្រាសាទ ៣ ខ្នង ដែលសមគួរដល់រដូវ ទាំង ៣ ហើយឲ្យស្រីរបាំបម្រើសេដ្ឋីបុត្រនោះ សោយសម្បត្តិអាស្រ័យនៅដូច ទេវបុត្តនោះឯង ។

តមកកាលព្រះសាស្តារបស់យើងទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណ ទ្រង់ ប្រកាសព្រះធម្មចក្រដ៏ប្រសើរហើយ ទ្រង់ប្រថាប់នៅក្រុងរាជគ្រឹះ សេដ្ឋីបុត្រ នោះ ដែលព្រះបាទមគធៈត្រាស់ហៅមកដើម្បីនឹងទតរោមត្រង់ជើង ហើយបញ្ជូន ទៅគាល់ព្រះសាស្តាព្រមជាមួយអ្នកស្រុក ៨០.០០០ ស្តាប់ព្រះធម៌ទេសនា បាន សទ្ធា ទើបសូមបព្វជ្ជាចំពោះព្រះសាស្តា គ្រានោះព្រះដ៏មានព្រះភាគត្រាស់សួរ

គេថា មាតាបិតាអនុញ្ញាតហើយឬ ទ្រង់ស្តាប់ថា មិនទាន់បានអនុញ្ញាត ទើបទ្រង់ហាមថា សោណៈ តថាគតមិនឲ្យកុលបុត្រដែលមាតាបិតាមិនអនុញ្ញាតបួសទេ សេដ្ឋីបុត្រនោះ ទទួលព្រះតម្រាស់របស់ព្រះតថាគតដោយសិរសាថា ព្រះករុណាព្រះអង្គ ទើបទៅរកមាតាបិតាឲ្យលោកអនុញ្ញាត ហើយត្រឡប់មកគាល់ព្រះតថាគត បានបួសក្នុងសំណាក់របស់ភិក្ខុមួយរូប នេះជាសេចក្តីសង្ខេបក្នុងរឿងនេះ , ដោយពិស្តារ ពិធីបព្វជ្ជារបស់លោកមកហើយក្នុងព្រះបាលីនុ៎ះឯង ។

កាលលោកបានបព្វជ្ជាឧបសម្បទហើយ នៅក្នុងក្រុងរាជគ្រឹះ ពួកញាតិជាច្រើន ដើម្បីបានឃើញសម្លាញ់ ក៏នាំសក្ការៈ និងគ្រឿងបូជាមក ហើយពោលសរសើរសេចក្តីសម្រេចនៃរូប សូម្បីអ្នកដទៃក៏នាំគ្នាមកមើល ព្រះថេរៈគិតថា មនុស្សជាច្រើនមកកាន់សំណាក់របស់យើង យើងនឹងធ្វើកិច្ចក្នុងកម្មដ្ឋាន ឬក្នុងវិបស្សនាបានយ៉ាងណា ប្រសិនបើ យើងគប្បីរៀនកម្មដ្ឋានក្នុងសំណាក់របស់ព្រះសាស្តាហើយ ទៅកាន់សីតវ័នបំពេញសមណធម៌ មនុស្សជាច្រើននឹងរង្កៀសព្រៃសីតវ័ននោះ ហើយក៏មិនទៅ បើដូច្នោះ កិច្ចរបស់យើងនឹងដល់ទីបំផុតបាន ទើបទទួលកម្មដ្ឋានក្នុងសំណាក់របស់ព្រះសាស្តាហើយ ទៅកាន់សីតវ័ន ផ្តើមបំពេញសមណធម៌ លោកគិតថា សរីរៈរបស់យើងស្អាតល្អយ៉ាងក្រៃលែង តែមិនអាចនឹងឲ្យដល់សេចក្តីសុខបាន សូម្បីនឹងលំបាកកាយក៏គួរបំពេញសមណ-

ធម៌ តពីនោះ ទើបអធិដ្ឋានការឈរ និងការចង្រ្កម មានតែលោហិតតែម្យ៉ាង កាលលោកដើរមិនបាន ក៏ព្យាយាមចង្រ្កមដោយជង្គង់ខ្លះ ដោយដៃខ្លះ សូម្បីធ្វើសេចក្តីព្យាយាមដ៏ខ្លាំងក្លាយ៉ាងនេះ ក៏មិនអាចធ្វើគុណសូម្បីត្រឹមតែឱកាសឲ្យកើត ទើបគិតថា បើមានអ្នកដទៃធ្វើសេចក្តីព្យាយាមដូចជាយើងដែរ តែយើងព្យាយាមហើយយ៉ាងនេះ ក៏មិនអាចធ្វើមគ្គ ឬផលឲ្យកើតឡើងបាន យើងមិនមែនឧគ្ឃដិតញ្ញូបុគ្គល ឬមិនមែនវិបចិតញ្ញូបុគ្គល មិនមែននេយ្យបុគ្គល យើងពិតជាបទបរមបុគ្គល យើងមានប្រយោជន៍អ្វីក្នុងបព្វជ្ជា យើងនឹងសឹកចេញទៅបរិភោគភោគៈ និងធ្វើបុណ្យ សម័យនោះ ព្រះសាស្តាទ្រង់ជ្រាបបរិវិតក្កៈរបស់ព្រះថេរៈ វេលាល្ងាចទ្រង់មានពួកភិក្ខុហែហមទៅកាន់ព្រៃសីតវ័ននោះ ទតឃើញទីចង្រ្កមប្រឡាក់ឈាម ទ្រង់ឱវាទដល់ព្រះថេរៈដោយឱវាទ ប្រៀបដូចការដេញពិណ ត្រាស់ប្រាប់កម្មដ្ឋានដល់ព្រះថេរៈ ដើម្បីឲ្យប្រកបសេចក្តីព្យាយាមជាកណ្តាល ហើយស្តេចយាងទៅកាន់ភ្នំគិជ្ឈកូដ ចំណែកព្រះសោណត្ថេរៈ បានព្រះឱវាទក្នុងទីចំពោះព្រះភ័ក្រ្តរបស់ព្រះទសពល មិនយូរប៉ុន្មាន ក៏តាំងនៅក្នុងព្រះអរហត្តផល ។ តមកខាងក្រោយ ព្រះសាស្តាមានពួកភិក្ខុហែហម ទ្រង់សម្តែងធម៌ក្នុងព្រះជេតវ័នវិហារ ទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងជាកំពូលលើពួកភិក្ខុដែលប្រារព្ធសេចក្តីព្យាយាម ។

ចប់អដ្ឋកថា សូត្រទី ៧

# អដ្ឋកថាសូត្រទី ៨

## ប្រវត្តិព្រះសោណកុដិកណ្ណត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៨ ដូចតទៅនេះ ៖

[១៤៧] ពាក្យលោកហៅថា **វាក្ករណ** ក្នុងបទថា **កល្យាណវាក្ករណានំ** អធិប្បាយថា ពាក្យដែលល្អ គឺ ពាក្យដ៏ពីរោះ ពិតណាស់ ព្រះថេរៈនេះ ពោលធម្មកថាដោយសំឡេងដ៏ពីរោះចំពោះព្រះតថាគត ក្នុងព្រះគន្ធកុដិជាមួយគ្នានឹងព្រះទសពល ។ គ្រានោះ ព្រះសាស្ដាបានប្រទានសាធុការដល់លោក ព្រោះដូច្នោះ ព្រះថេរៈនោះទើបឈ្មោះថា ជាកំពូលលើពួកភិក្ខុដែលមានវាចាពីរោះ ពាក្យថា **សោណៈ** ជាឈ្មោះរបស់លោក តែលោកប្រដាប់គ្រឿងប្រដាប់ត្រចៀក (ក្រវិល) មានតម្លៃមួយកោដិ ព្រោះដូច្នោះ គេទើបហៅថា **កុដិកណ្ណៈ** សំដៅសេចក្ដីថា ព្រះសោណៈអ្នកមានក្រវិលត្រចៀកតម្លៃមួយកោដិ ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលគប្បីពោលតាមលំដាប់ដូចតទៅនេះ ៖

ព្រះថេរៈនេះ កាលព្រះពុទ្ធព្រះនាមថា **បទុមុត្តរៈ** លោកទៅវិហារជាមួយមហាជន ដោយន័យមុននោះឯង ឈរស្ដាប់ធម៌នៅខាងក្រោយបរិស័ទ ឃើញព្រះសាស្ដាទ្រង់ស្ថាបនាភិក្ខុមួយរូបទុកក្នុងតំណែងអ្នកជាកំពូលលើពួកភិក្ខុ ដែល

មានវាចាពីរោះ ទើបគិតថា សូម្បីយើងក៏គួរជាកំពូលលើពួកភិក្ខុដែលមានវាចាពីរោះក្នុងសាសនាព្រះពុទ្ធអង្គណាមួយក្នុងអនាគត ទើបនិមន្តព្រះទសពលថ្វាយទាន ៧ ថ្ងៃ បានធ្វើសេចក្តីប្រាថ្នាថា ព្រះអង្គ ព្រះអង្គទ្រង់តាំងភិក្ខុណាទុកក្នុងតំណែងនៃភិក្ខុដែលមានវាចាពីរោះ ថ្ងៃចុងក្រោយនៃថ្ងៃទី ៧ រាប់អំពីថ្ងៃនេះទៅ ខ្ញុំព្រះអង្គគប្បីដូចជាយ៉ាងភិក្ខុនោះ ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយក្នុងអនាគតដោយផលនៃកុសលកម្មនេះ ព្រះសាស្តាទ្រង់ឃើញថាមិនមានអន្តរាយសម្រាប់លោក ទើបទ្រង់ព្យាករណ៍ថា អ្នកនឹងជាកំពូលលើពួកភិក្ខុដែលមានវាចាពីរោះក្នុងសាសនារបស់ព្រះគោតមសម្ពុទ្ធក្នុងអនាគតកាល ហើយស្តេចក៏យាងត្រឡប់ទៅ ។ ចំណែកលោកក៏ធ្វើកុសលកម្មដរាបរហូតអស់ជីវិត វិលវល់ក្នុងទេវតា និងមនុស្សអស់សែនកប្ប ចុតិចាកទេវលោក មកបដិសន្ធិក្នុងផ្ទៃឧបាសិកាដែលជាអ្នកគ្រប់គ្រងផ្ទះ ឈ្មោះថា **កាឡី** មុនព្រះទសពលរបស់យើងទ្រង់ឧប្បត្តិ នាងមានគភ៌គ្រប់ហើយ មកកាន់និវេសន៍នៃត្រកូលរបស់ខ្លួនក្នុងក្រុងរាជគ្រឹះ ។

សម័យនោះ ព្រះសាស្តារបស់យើងទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណ ហើយទ្រង់ប្រកាសធម្មចក្រក្នុងព្រៃឥសិបតនៈ ទេវតាក្នុងម៉ឺនចក្រវាឡមកប្រជុំគ្នាក្នុងទីប្រជុំនោះ យក្សមួយឈ្មោះថា **សាតាគិរយក្ខ** ក្នុងចំណោមសេនាបតីយក្ខ

(មេទ័ពយក្ខ) ២៨ នាក់ ស្តាប់ធម្មកថារបស់ព្រះទសពល បានតាំងនៅក្នុងសោតាបត្តិផល ក៏ត្រិះរិះថា ធម្មកថាដ៏ពីរោះនេះ **ហេមវតយក្ខ** សម្លាញ់របស់យើងបានស្តាប់ ឬមិនបានស្តាប់ហ្ន៎ យក្ខនោះរកមើលក្នុងចំណោមពួកទេវតា ក៏មិនឃើញយក្ខនោះ ទើបគិតថា សម្លាញ់របស់យើងមិនជ្រាបថា រតនៈទាំង ៣ កើតឡើងហើយទេ ចាំយើងទៅពោលគុណនៃព្រះទសពលដល់គេ និងនឹងប្រាប់ដល់ធម៌ដែលយើងសម្រេចដល់គេផង ទើបទៅរកហេមវតយក្ខនោះ តាមផ្លូវអាកាសខាងលើក្រុងរាជគ្រឹះ ជាមួយបរិស័ទរបស់ខ្លួន ។

ចំណែកហេមវតយក្ខ ឃើញព្រៃហិមពាន្តដ៏ធំវែងដល់ ៣ ពាន់យោជន៍ មានផ្កាឈើរីកមិនត្រូវកាល គិតថា យើងនឹងលេងសប្បាយក្នុងព្រៃហិមពាន្តជាមួយសម្លាញ់របស់យើង ទើបទៅជាមួយបរិស័ទរបស់ខ្លួន តាមផ្លូវអាកាសពីខាងលើក្រុងរាជគ្រឹះដូចគ្នា សូម្បីយក្ខទាំងនោះ ក៏មកជួបគ្នាត្រង់ខាងលើនិវេសន៍របស់ឧបាសិកាក្នុងខណៈនោះឯង ហើយក៏សួរគ្នាថា ពួកលោកជាបរិស័ទរបស់នរណា ពួកយើងជាបរិស័ទរបស់សាតាគិរយក្ខ ចុះពួកលោកជាបរិស័ទរបស់នរណា ពួកយើងជាបរិស័ទរបស់ហេមវតយក្ខ ដូច្នេះ ពួកយក្ខទាំងនោះក៏នាំគ្នាត្រេកអររីករាយហើយ កាលជួបគ្នានៃយក្ខសេនាបតីទាំងនោះ សាតាគិរយក្ខពោលនឹងហេមវតយក្ខថា សម្លាញ់ លោកនឹងទៅណា ? ហេមវតយក្ខឆ្លើយថា

សម្លាញ់ យើងនឹងទៅសំណាក់លោក ។ សាតាគិរយក្ខសួរថា ព្រោះអ្វី ។ ហេមវតយក្ខឆ្លើយថា យើងឃើញព្រៃហិមពាន្តមានផ្កាឈើរីកស្រស់បំព្រង យើងនឹងទៅលេងក្នុងព្រៃហិមពាន្តនោះជាមួយលោក ។ សាតាគិរយក្ខពោលតបថា សម្លាញ់ ក៏លោកនឹងទៅអ្វី? លោកដឹងថា ព្រៃហិមពាន្តមានផ្កាឈើរីកស្គុះស្គាយ ដោយហេតុអ្វីទេ ។ ហេមវតយក្ខតបថា មិនដឹងទេសម្លាញ់ ។ សាតាគិរយក្ខពោលទៀតថា ព្រះសិទ្ធត្ថកុមារ ឱរសព្រះបាទសុទ្ធោទនមហារាជ ញ៉ាំងម៉ឺនលោក-ធាតុឲ្យញាប់ញ័រហើយ ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណ ទ្រង់ប្រកាសធម្មចក្រដ៏កំពូលត្រង់កណ្តាលទេវតាក្នុងម៉ឺនចក្រវាល លោកមិនដឹងថា ព្រះធម្មចក្កនោះព្រះអង្គទ្រង់ប្រកាសហើយទេឬ ។ ហេមវតយក្ខតបថា មិនដឹងទេសម្លាញ់ ។ សាតាគិរយក្ខពោលទៀតថា លោកសម្គាល់ថា ទីមានប្រមាណប៉ុណ្ណោះឯង មានផ្កាឈើរីកស្គុះស្គាយ តែទូទៅក្នុងម៉ឺនចក្រវាឡ ក៏មានផ្កាឈើរីកតែម្យ៉ាងដូចគ្នាក្នុងថ្ងៃនេះ ដើម្បីសក្ការៈបុរសនោះឯង សម្លាញ់ ។ ហេមវតយក្ខពោលថា ផ្កាឈើរីកហើយ ព្រះសាស្តានោះ លោកឃើញដោយភ្នែកខ្លួនឬ ។ សាតាគិរ-យក្ខឆ្លើយថា អើ សម្លាញ់ យើងឃើញព្រះសាស្តា ហើយយើងបានស្តាប់ធម៌ទាំងយើងបានផឹកអមតៈហើយ យើងនឹងធ្វើលោកឲ្យដឹងអមតធម៌នោះ ទើបយើងមកកាន់សំណាក់របស់សម្លាញ់ ។ កាលយក្ខទាំងនោះកំពុងចរចាគ្នាទុំះឯង ឧបាសិកា

ក្រោកឡើងពីទីដេកដ៏មានសិរី អង្គុយស្តាប់ការចរចានោះ កាន់យកនិមិត្តក្នុងសំឡេងកំណត់ថា សំឡេងនេះជាសំឡេងនៅខាងលើ មិនមែននៅខាងក្រោម ជាសំឡេងអមនុស្សនិយាយ មិនមែនសំឡេងមនុស្សនិយាយ ផ្ទៀងសោតផ្ចង់ចិត្តស្តាប់ ។ តពីនោះសាតាគិរយក្ខនិយាយថា

អជ្ជ បណ្ណរសោ ឧបោសថោ (ឥតិ សាតាគិរោ យក្ខោ)
ទិព្វា រត្តិ ឧបដ្ឋិតា អនោមនាមំ សត្ថារំ ហន្ទ បស្សាម
គោតមន្តិ ។

ថ្ងៃនេះ ជាថ្ងៃឧបោសថ ១៥ កើត រាត្រីដែលជាទិព្វ
ប្រាកដហើយ មកយើងទាំងពីរចូរទៅគាល់ព្រះគោតម
ទ្រង់មានព្រះនាមដែលមិនថោកថយយចុះ ។

សាតាគិរយក្ខពោលដូច្នេះហើយ ហេមវតយក្ខពោលថា ៖

កច្ចិ មនោ សុបណិហិតោ (ឥតិ ហេមវតោ យក្ខោ)
សព្វភូតេសុ តាទិនោ កច្ចិ ឥដ្ឋេ អនិដ្ឋេ ច សង្កប្បស្ស
វសីកតាតិ ។

ព្រះគោតមទ្រង់ស្ថិតនៅ ទ្រង់តាំងព្រះទ័យទុកល្អហើយ
ក្នុងសត្វទាំងពួងឬ ព្រះគោតមទ្រង់ធ្វើព្រះតម្រិះក្នុងឥដ្ឋា-

រម្មណ៍ និងអនិដ្ឋារម្មណ៍ឲ្យនៅក្នុងអំណាចព្រះអង្គឬ ។

ហេមវតយក្ខសួរដល់កាយសមាចារ អាជីវៈ និងមនោសមាចាររបស់ព្រះសាស្តាយ៉ាងនេះហើយ សាតាគិរយក្ខ វិសជ្ជនាប្រការដែលហេមវតយក្ខសួរហើយ កាលចប់ហេមវតសូត្រ តាមសេចក្តីពេញចិត្តដោយការពោលគុណនៃសរីរវណ្ណៈរបស់ព្រះសាស្តាយ៉ាងនេះហើយ ហេមវតយក្ខ បញ្ជូនញាណទៅតាមក្រសែនៃព្រះធម៌ទេសនារបស់សម្មាញ់ ក៏តាំងនៅក្នុងសោតាបត្តិផលនោះឯង ។ គ្រានោះ នាងកាឡីឧបាសិកា ដែលមិនធ្លាប់ឃើញព្រះតថាគត ក៏កើតសេចក្តីជ្រះថ្លា ព្រោះបានស្តាប់ក្នុងធម៌ដែលគេសម្តែងដល់បុគ្គលដទៃ ហើយបានតាំងនៅក្នុងសោតាបត្តិផល ដូចបរិភោគភោជនដែលគេរៀបចំសម្រាប់អ្នកដទៃដូច្នោះ ។ ឧបាសិកានោះ ជាព្រះសោតាបន្នដំបូងក្នុងចំណោមស្ត្រីទាំងអស់ និងជាប្រធាននៃស្ត្រីទាំងអស់ ។ ក្នុងយប់នោះ នាងក៏ប្រសូតបុត្រ ព្រមគ្នានឹងការសម្រេចសោតាបត្តិផល ក្នុងថ្ងៃដាក់ឈ្មោះទារកដែលបានមកហើយ ទើបតាំងឈ្មោះថា **សោណៈ** ។ ឧបាសិកនោះ នៅក្នុងផ្ទះនៃត្រកូលតាមសេចក្តីពេញចិត្តហើយ ទើបបានទៅកាន់កុលឃរនគរ ។

សម័យនោះ ព្រះមហាកច្ចាយនត្ថេរៈ អាស្រ័យក្រុងនោះ នៅត្រង់ភ្នំឧបវត្តៈ ឧបាសិកាឧបដ្ឋាកព្រះថេរៈ ព្រះថេរៈទៅកាន់និវេសន៍របស់នាងជាប្រចាំ

សូម្បីសោណកុមារ ក៏ទៅលេងក្នុងសំណាក់របស់ព្រះថេរៈជាប្រចាំ ទើបជិតស្និទ្ធ
គ្នា តមកក្មេងនោះបព្វជ្ជាក្នុងសំណាក់របស់ព្រះថេរៈ ព្រះថេរៈបំណងនឹងឲ្យលោក
ឧបសម្បទា ស្វែងរកភិក្ខុ ៣ ឆ្នាំ គ្រប់គណៈទើបឲ្យឧបសម្បទាបាន លោកឧប-
សម្បទាហើយ ឲ្យព្រះថេរៈប្រាប់កម្មដ្ឋាន ចម្រើនវិបស្សនា ក៏បានសម្រេចជា
ព្រះអរហត្ត ហើយរៀនគម្ពីរសុត្តនិបាតក្នុងសំណាក់របស់ព្រះថេរៈ ចេញវស្សា
បវារណាហើយ បំណងនឹងគាល់ព្រះសាស្ដា ទើបលាព្រះឧបជ្ឈាយ៍ ព្រះថេរៈ
ពោលថា សោណៈ កាលលោកទៅហើយ ព្រះសាស្ដានឹងឲ្យលោកនៅក្នុងព្រះ
គន្ធកុដិជាមួយព្រះអង្គ ទ្រង់នឹងឲ្យលោកពោលធម៌ ព្រះសាស្ដានឹងទ្រង់ជ្រះថ្លា
ក្នុងធម្មកថារបស់លោក នឹងប្រទានពរដល់លោក កាលលោកទទួលពរ ចូរ
ទទួលយកពរយ៉ាងនេះ ចូរថ្វាយបង្គំព្រះបាទរបស់ព្រះទសពលតាមពាក្យរបស់
យើង ព្រះសោណៈនោះ ដែលព្រះឧបជ្ឈាយ៍អនុញ្ញាតហើយ ទើបទៅប្រាប់ដល់
ញោមឧបាសិកា សូម្បីឧបាសិកានោះក៏ពោលថា ប្រពៃណាស់ លោកកូនកាល
ទៅគាល់ព្រះទសពល ចូរយកសំពត់កម្ពលផ្ទាំងនេះទៅ ចូរក្រាលធ្វើឲ្យជាសំពត់
កម្រាលក្នុងព្រះគន្ធកុដិទីប្រថាប់របស់ព្រះសាស្ដា ហើយថ្វាយសំពត់កម្ពលផ្ទាំង
ធំនេះចុះ ព្រះសោណត្ថេរៈទទួលសំពត់នោះហើយ បិទទីសេនាសនៈ ទៅកាន់ទី
ប្រថាប់របស់ព្រះសាស្ដាដោយលំដាប់ ចូលទៅគាល់ក្នុងវេលាដែលព្រះទសពល

ប្រថាប់គន់លើពុទ្ធាសនៈ ថ្វាយបង្គំហើយ បានឈរក្នុងទីសមគួរម្ខាង ។

ព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈនឹងព្រះថេរៈនោះហើយ ត្រាស់ហៅព្រះអានន្ទត្ថេរៈមក ត្រាស់ថា អានន្ទ ចូរចាត់សេនាសនៈសម្រាប់ភិក្ខុរូបនេះ ព្រះថេរៈជ្រាបព្រះពុទ្ធបំណងរបស់ព្រះសាស្តា បានក្រាលសំពត់ហើយ ដូចជាលើកកម្រាលសំពត់ទុកត្រង់កណ្តាលព្រះគន្ធកុដិ គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់សម្រាកកណ្តាលវាលរហូតអស់រាត្រីដ៏ច្រើន ទើបស្តេចចូលព្រះវិហារ សូម្បីព្រះសោណៈ ក៏សម្រាកកណ្តាលវាលរហូតអស់រាត្រីជាច្រើនដូចគ្នា ទើបចូលព្រះវិហារ ព្រះសាស្តាស្តេចសម្រេចសីហយាសន៍ក្នុងមជ្ឈិមយាម ស្តេចក្រោកឡើងប្រថាប់គង់ក្នុងសម័យជិតភ្លឺ ទ្រង់ជ្រាបថា ការលំបាកកាយរបស់ព្រះសោណៈនឹងស្ងប់រម្ងាប់ដោយហេតុត្រឹមប៉ុណ្ណេះ ទើបទ្រង់ត្រាស់ឲ្យពោលធម៌ ព្រះសោណត្ថេរៈបានពោលព្រះសូត្រដែលទាក់ទងដោយអដ្ឋកវគ្គ ព្យញ្ជនៈមួយគួៗ ក៏មិនបាត់ដោយសំឡេងដ៏ពីរោះ កាលចប់គាថា ព្រះដ៏មានព្រះភាគទ្រង់ប្រទានសាធុការប្រកាសដល់សេចក្តីជ្រះថ្លាថា ភិក្ខុ ធម៌អ្នករៀនទុកល្អហើយ ទេសនាក្នុងវេលាដែលតថាគតសម្តែងហើយក្តី ក្នុងថ្ងៃនេះក្តី ក៏តែម្យ៉ាងដូចគ្នា មិនខ្វះមិនលើសឡើយ ។ ចំណែកព្រះសោណៈកំណត់ថា នេះជាឱកាស ហើយថ្វាយបង្គំព្រះទសពលតាមពាក្យរបស់ព្រះឧបជ្ឈាយ៍ ទូលសូមពរគ្រប់យ៉ាង តាំងពីការឧប-

សម្បទាដោយគណៈ មានព្រះវិន័យធរគ្រប់ ៥ ព្រះសាស្តាទ្រង់ប្រទានហើយតមក ព្រះថេរៈថ្វាយបង្គំតាមពាក្យរបស់ឧបាសិកាមាតាថា បពិត្រព្រះអង្គដ៏ចម្រើន ឧបាសិកាបញ្ជូនសំពត់កម្ពលផ្ទាំងនេះមក ដើម្បីជាកម្រាលក្នុងផ្ទៃព្រះគន្ធកុដិ ជាទីប្រថាប់របស់ព្រះអង្គ ហើយថ្វាយសំពត់កម្ពល ក្រោកចាកអាសនៈថ្វាយបង្គំព្រះសាស្តាធ្វើប្រទក្សិណចៀសចេញទៅ ។ ក្នុងរឿងនេះ មានសេចក្ដីសង្ខេបប៉ុណ្ណេះ ។ តែដោយពិស្តារ រឿងតាំងពីការបព្វជ្ជារបស់ព្រះថេរៈជាដើមទាំងអស់មកក្នុងព្រះសូត្រហើយ ។

ដូចពោលមកនេះ ព្រះថេរៈបានពរ ៨ ប្រការ ពីសំណាក់ព្រះសាស្តា ហើយត្រឡប់ទៅកាន់សំណាក់ព្រះឧបជ្ឈាយ៍ ហើយដំណាលព្រឹត្តិហេតុទាំងពួងនោះឯង ។ ស្អែកឡើង ក៏ទៅកាន់ទ្វារនិវេសន៍របស់ញោមឧបាសិកា ឈររង់ចាំអាហារ ឧបាសិកាបានដំណឹងថា បុត្ររបស់យើងមកឈរត្រង់ទ្វារ ទើបប្រញាប់មកអភិវាទ ហើយទទួលបាត្រ និមន្តស្ដេចឲ្យប្រថាប់ក្នុងនិវេសន៍របស់ខ្លួន ថ្វាយភោជន ។ ទីនោះ កាលឆាន់ស្រេចហើយ ឧបាសិកាពោលនឹងលោកថា លោកកូនបានជួបព្រះទសពលហើយឬ ។ ជួបហើយ ឧបាសិកា ។ (ឧបាសិកា) លោកកូនបានថ្វាយបង្គំតាមពាក្យរបស់ញោមហើយឬ ។ (ព្រះសោណៈ) ថ្វាយបង្គំហើយ ឯសំពត់កម្ពលរបស់យើងនោះ បានក្រាលទុកធ្វើជាសំពត់កម្រាលត្រង់

ទីប្រថាប់របស់ព្រះតថាគតហើយ ។ (ឧបាសិកា) លោកកូន បានឮថា លោកកូនពោលធម្មកថាថ្វាយព្រះសាស្តា ហើយព្រះសាស្តាទ្រង់បានប្រទានសាធុការដល់លោកកូនឬ ។ ព្រះសោណៈសួរថា ញោមជ្រាបបានយ៉ាងណា ឧបាសិកា ។ ឧបាសិកាពោលថា ទេវតាដែលស្ថិតនៅក្នុងផ្ទះរបស់ញោមប្រាប់ថា ទេវតាក្នុងម៉ឺនចក្រវាឡ បានថ្វាយសាធុការ កាលព្រះសាស្តាប្រទានសាធុការដល់លោកកូនហើយពោលថា លោកកូន ញោមសង្ឃឹមថា លោកកូនគួរពោលធម៌ដូចដែលលោកកូនពោលហើយ ដល់ញោមខ្លះ ដោយទំនងដែលបានពោលចំពោះព្រះពុទ្ធ ព្រះថេរៈទទួលពាក្យរបស់ញោមហើយ ។ នាងជ្រាបថា ព្រះថេរៈទទួលពាក្យហើយ ទើបឲ្យធ្វើមណ្ឌបជិតទ្វារផ្ទះ និមន្តឲ្យពោលធម៌ដល់ខ្លួន ដោយទំនងដូចពោលដល់ព្រះទសពលនោះឯង ។ រឿងតាំងឡើងហើយក្នុងទីនេះ ។ តមកព្រះសាស្តាប្រថាប់ត្រង់កណ្តាលពួកព្រះអរិយៈ ទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងជាកំពូលលើពួកភិក្ខុដែលមានវាចាពីរោះ ។

ចប់អដ្ឋកថា សូត្រទី ៨

# អដ្ឋកថាសូត្រទី ៩

## ប្រវត្តិព្រះសីវលី

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៩ ដូចតទៅនេះ ៖

[១៨៧] ដោយបទថា **លាភីនំ យទិទំ សីវលី** ទ្រង់សម្ដែងថា វៀរព្រះតថាគត ព្រះសីវលីថេរៈជាកំពូលលើពួកភិក្ខុដែលមានលាភ ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលនឹងពោលដោយលំដាប់ដូចតទៅនេះ ៖

ព្រះថេរៈនេះ ក្នុងអតីត សម័យព្រះពុទ្ធព្រះនាមថា **បទុមុត្តរៈ** ទៅព្រះវិហារ ឈរស្ដាប់ធម៌នៅខាងក្រោយបរិស័ទ ដោយន័យដែលពោលហើយនោះឯង ឃើញព្រះសាស្ដាទ្រង់ស្ថាបនាភិក្ខុមួយរូបទុកក្នុងតំណែងជាកំពូលលើពួកភិក្ខុដែលមានលាភ គិតថា សូម្បីយើងក៏គួរជាបុគ្គលបែបនោះមួយរូបក្នុងអនាគត ទើបនិមន្តព្រះទសពលថ្វាយមហាទាន ៧ ថ្ងៃ ធ្វើសេចក្ដីប្រាថ្នាថា ដោយការធ្វើកុសលនេះ ខ្ញុំព្រះអង្គមិនប្រាថ្នាសម្បត្តិយ៉ាងដទៃ តែខ្ញុំព្រះអង្គគប្បីជាកំពូលលើពួកភិក្ខុដែលមានលាភដូចជាភិក្ខុ ដែលព្រះអង្គទ្រង់ស្ថាបនាទុកក្នុងតំណែងឯតទគ្គៈក្នុងសាសនារបស់ព្រះពុទ្ធមួយព្រះអង្គក្នុងអនាគតកាល ព្រះសាស្ដាទ្រង់ជ្រាបថាមិនមានអន្តរាយសម្រាប់លោក ទើបទ្រង់ព្យាករណ៍ថា សេចក្ដីប្រាថ្នារបស់លោកនេះ នឹងបានសម្រេចក្នុងសំណាក់របស់ព្រះពុទ្ធព្រះនាមថា **គោតមៈ** ក្នុងអនាគត

ទើបស្តេចត្រឡប់ទៅ ។ កុលបុត្រនោះធ្វើកុសលរហូតអស់ជីវិត ហើយវិលវល់នៅក្នុងទេវតា និងមនុស្សទាំងឡាយ ។ សម័យព្រះវិបស្សីសម្ពុទ្ធ កុលបុត្រនោះបំពេញកុសលរហូតអស់មួយជីវិត ត្រាច់អន្ទោលនៅក្នុងទេវតា និងមនុស្សទាំងឡាយ លុះព្រះវិបស្សីសម្ពុទ្ធបដិសន្ធិក្នុងស្រុកមួយ មិនឆ្ងាយពីក្រុងពន្ធុមតី សម័យនោះ អ្នកក្រុងពន្ធុមតី បានសន្ទនាជាមួយព្រះរាជា ថ្វាយទានចំពោះព្រះទសពល ។ ថ្ងៃមួយ មនុស្សទាំងនោះ រួមគ្នាតែមួយថ្វាយទាន គិតថា ក្នុងមុខគឺ ទានរបស់ពួកយើង នឹងមានអ្វីខ្វះហ្ន៎ ដូច្នេះ មិនបានឃើញទឹកឃ្មុំ និងទឹកដោះថ្លា មនុស្សទាំងនោះទើបឲ្យបុរសចាំស្ទាក់ផ្លូវចេញពីជនបទចូលទៅក្រុង ដោយតាំងចិត្តថា នឹងនាំរបស់ ២ យ៉ាងនោះ ពីខាងឯណោះខ្លះ ខាងនេះខ្លះមក ក្នុងគ្រានោះ កុលបុត្រនេះកាន់យកបំពង់ដុំទឹកដោះមកពីស្រុករបស់ខ្លួនគិតថា នឹងនាំមកតិចតួចប៉ុណ្ណោះ កាលទៅដល់ព្រះនគរក៏សម្លឹងរកមើលទីសប្បាយ ដោយតាំងចិត្តថា នឹងលាងមាត់ លាងដៃ និងជើងហើយ ទើបចូលទៅ ឃើញសំបុកឃ្មុំដែលមិនមានមេប៉ុននឹងដងនង្គ័ល គិតថា វត្ថុនេះកើតឡើងដោយបុណ្យរបស់យើង ទើបកាន់យក ហើយចូលទៅកាន់នគរ បុរសដែលអ្នកក្រុងទុកឲ្យចាំផ្លូវឃើញកុលបុត្រនោះ ទើបសួរថា សំឡាញ់ដ៏ចម្រើន លោកនាំទឹកឃ្មុំមកឲ្យនរណា គេឆ្លើយថា មិនបាននាំមកឲ្យនរណាទេ ក៏ទឹកឃ្មុំដែលលោកនាំមកនេះលក់ឲ្យដល់

យើងចុះ បើដូច្នោះ លោកចូរយកកហាបណៈនេះទៅ ហើយចូរឲ្យទឹកឃ្មុំ និងជុំទឹកដោះមកចុះ កុលបុត្រនោះគិតថា របស់នេះបើថាមានតម្លៃច្រើន និងបុរសនេះនឹងឲ្យច្រើនតែម្តងប៉ុណ្ណោះ គួរគិតមើលសិន បុរសនោះពោលថា យើងមិនឲ្យតែមួយកហាបណៈ ហើយពោលថា បើដូច្នោះ លោកចូរទទួលយក ២ កហាបណៈហើយចូរឲ្យ កុលបុត្រនោះឆ្លើយថា ២ កហាបណៈក៏មិនឲ្យ បុរសនោះទើបបន្ថែមដោយឧបាយនេះរឿយៗ រហូតដល់មួយពាន់កហាបណៈ កុលបុត្រនោះទើបគិតថា យើងមិនគួរនឹងចាញ់ឆោតគេ ណ្ហើយចុះ យើងនឹងសួរកិច្ចដែលគប្បីធ្វើរបស់បុរសនេះ ពេលនោះ គេទើបពោលនឹងបុរសនោះថា របស់នេះមិនមានតម្លៃច្រើន តែលោកឲ្យច្រើន លោកនឹងយកវត្ថុនេះទៅដោយកិច្ចកម្មអ្វី បុរសនោះពោលថា លោកដ៏ចម្រើន អ្នកក្រុងក្នុងក្រុងនេះសន្យាជាមួយព្រះរាជា ថ្វាយទានចំពោះព្រះវិបស្សីទសពល កាលមិនមានវត្ថុ ២ មុខនេះ ក្នុងបុណ្យ គឺទាន ទើបនាំគ្នាស្វែងរក បើមិនបានវត្ថុនេះ អ្នកក្រុងក៏នឹងចាញ់ ព្រោះដូច្នោះខ្ញុំឲ្យតម្លៃមួយពាន់ ចូរទទួលយកចុះ គេពោលថា របស់វត្ថុនេះគួរឲ្យដល់អ្នកក្រុងប៉ុណ្ណោះ ឬគួរឲ្យដល់ជនពួកដទៃ លោកនឹងឲ្យរបស់ដែលលោកនាំមកនេះដល់នរណាម្នាក់ឬ ។

(កុលបុត្ត) ក៏មាននរណាឲ្យទ្រព្យមួយពាន់ក្នុងថ្ងៃតែមួយ ក្នុងទានរបស់

អ្នកក្រុងមែនទេ ។

(បុរស) មិនមានទេសម្លាញ់ ។

(កុលបុត្ត) ក៏លោកដឹងថាវត្ថុ ២ មុខនេះ មានតម្លៃមួយពាន់ឬ ។

(បុរស) ខ្ញុំដឹង ។

(កុលបុត្ត) បើដូច្នោះ លោកចូរទៅប្រាប់ដល់អ្នកក្រុងចុះថា បុរសម្នាក់មិនឲ្យវត្ថុ ២ មុខនេះដោយតម្លៃ (តែ) បំណាច់ទឹងឲ្យដោយដៃរបស់ខ្លួនឯង ពួកលោកកុំខ្វល់ខ្វាយព្រោះហេតុនៃវត្ថុ ២ មុខនេះឡើយ ។

(បុរស) ក៏លោកចូរជាកាយសក្ខីជាសាក្សីនៃភាពជាប្រធាន គឺ ទានរបស់យើងចុះ ។

បុរសនោះ យកមាសកៈដែលខ្លួនរក្សាទុកដើម្បីប្រើប្រាស់ឯស្រុក ទិញគ្រឿងហឹរ ៥ យ៉ាង បុករហូតល្អិត ត្រងប្របាច់លាយដោយទឹកខ្មេះ ទឹកដោះ ហើយប្របាច់សំបុកឃ្មុំចូលទៅក្នុងនោះ ផ្សំជាមួយលម្អិតគ្រឿងហឹរ ៥ យ៉ាង ហើយដាក់ទុកក្នុងស្លឹកឈូកមួយ វេចខ្ចប់របស់ហើយ កាន់មកអង្គុយក្នុងទីមិនឆ្ងាយពីព្រះទសពល រង់ចាំមើលវារៈដែលដល់ខ្លួនក្នុងរវាងគ្រឿងសក្ការៈ ដែលមហាជននាំមក បានឱកាសហើយ ទើបទៅគាល់ព្រះសាស្តា ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ នេះជាទុគ្គតបណ្ណាការរបស់ខ្ញុំព្រះអង្គ សូមព្រះអង្គមេត្តាប្រោស

ទទួលរបស់វត្ថុនេះរបស់ខ្ញុំព្រះអង្គចុះ ព្រះសាស្តាទ្រង់អាស្រ័យសេចក្តីករុណាដល់បុរសនោះ ទ្រង់ទទួលបណ្ណាការនោះដោយបាត្រថ្ម ដែលស្តេចមហារាជទាំង ៤ ថ្វាយ ហើយទ្រង់អធិដ្ឋានទូវគ្រឿងបណ្ណាការនោះដល់ភិក្ខុ ៦៨.០០០ អង្គ ក៏មិនអស់ កុលបុត្រនោះ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ដែលសោយស្រេចហើយ ឈរក្នុងទីសមគួរម្ខាង ក្រាបទូលថា "ខ្ញុំព្រះអង្គជួបព្រះដ៏មានព្រះភាគហើយ ថ្ងៃនេះ អ្នកក្រុងពន្ធុមតីនាំសក្ការៈមកថ្វាយព្រះអង្គ សូមឲ្យខ្ញុំព្រះអង្គក៏គប្បីជាអ្នកដល់នូវភាពជា កំពូលខាងលាភ និងជាកំពូលខាងយសក្នុងភពដែលកើតហើយ ដោយផលនៃកម្មនេះ ។ ព្រះសាស្តាត្រាស់ថា សេចក្តីប្រាថ្នាចូរសម្រេចយ៉ាងនោះចុះ ហើយទ្រង់ធ្វើអនុមោទនាកត្តដល់កុលបុត្រនោះ និងដល់អ្នកក្រុង ស្តេចក៏យាងត្រឡប់ទៅ ។

ចំណែកកុលបុត្រនោះ ធ្វើកុសលដរាបរហូតអស់ជីវិត ហើយវិលវល់នៅក្នុងទេវតា និងមនុស្ស មកបដិសន្ធិក្នុងព្រះគភ៌របស់ព្រះរាជធីតាព្រះនាមថា **សុប្បវាសា** ក្នុងពុទ្ធុប្បាទកាលនេះ តាំងពីវេលាបដិសន្ធិ ព្រះនាងសុប្បវាសាទទួលគ្រឿងបណ្ណាការដល់ ៥០០ ទាំងព្រឹកទាំងល្ងាច គ្រានោះ ពួកព្រះញាតិត្រូវការនឹងសាកល្បងបុណ្យ ទើបឲ្យព្រះនាងយក ព្រះហស្តស្ទាបកញ្ជើដាក់គ្រាប់ពូជ ពន្លកក៏ដុះចេញអំពីគ្រាប់ពូជមួយប្រភេទៗ មួយរយខ្វះ មួយពាន់ខ្វះ ស្រូវកើត

ឡើងពីស្រែមួយករីស ៥០ រទេះខ្លះ ៦០ រទេះខ្លះ សូម្បីវេលានឹងធ្វើជង្រុកឲ្យពេញ ក៏ទ្រង់យកព្រះហស្តប៉ះត្រង់ទ្វារជង្រុក ត្រង់ទីដែលព្រះរាជធិតាប៉ះហើយក៏ត្រឡប់ពេញទៀតព្រោះបុណ្យ កាលមនុស្សទាំងឡាយពោលថា បុណ្យរបស់ព្រះរាជធិតា ហើយដួសបាយពីឆ្នាំងដែលមានបាយពេញឲ្យដល់បុគ្គលណាមួយមិនទាន់ដកព្រះហស្តពេលណា បាយក៏មិនអស់ទៅត្រឹមនោះ ។

កាលទារកនៅក្នុងគភ៌ទុះឯង វេលាកន្លងទៅអស់ ៧ ឆ្នាំ រាប់តាំងពីគភ៌ចាស់ នាងសោយទុក្ខធំអស់ ៧ ថ្ងៃ នាងប្រឹក្សាជាមួយស្វាមីថា មុននឹងស្លាប់ខ្ញុំនឹងថ្វាយទានទាំងដែលមានជីវិតរស់នៅនេះឯង ទើបប្រាប់ស្វាមីទៅគាល់ព្រះសាស្តា ដោយពោលថា អ្នកជាស្វាមី ចូរទៅក្រាបទូលរឿងនេះដល់ព្រះសាស្តា ហើយនិមន្តព្រះសាស្តា មួយទៀត ព្រះសាស្តាត្រាស់ពាក្យណា អ្នកជាស្វាមីចូរតាំងចិត្តកំណត់ពាក្យនោះឲ្យល្អ ហើយត្រឡប់មកប្រាប់ខ្ញុំផង ស្វាមីបានទៅក្រាបទូលដំណឹងចំពោះព្រះសាស្តា ព្រះសាស្តាត្រាស់ថា ព្រះនាងសុប្បវាសាកោ-ឡិយធិតា ចូរមានសេចក្តីសុខ ចូរមានសេចក្តីសប្បាយ មិនមានរោគ ចូរប្រសូតបុត្រដែលរករោគមិនបានចុះ ព្រះរាជាទ្រង់ទទួលព្រះតម្រាស់នោះ ទើបថ្វាយបង្គំលាព្រះសាស្តា ទ្រង់បែរមុខ ស្តេចត្រឡប់មកព្រះរាជនិវេសន៍ ព្រះកុមារក៏ប្រសូតចាកព្រះគភ៌របស់ព្រះនាងសុប្បវាសា ងាយដូចទឹកហូរចេញពីធម្មក្រក ដូច្នោះ

មនុស្សដែលអង្គុយជុំវិញក៏សើចឡើង ទាំងមានមុខប្រកបដោយទឹកក្អែក មហាជនក៏នាំគ្នាត្រេកអរ រីករាយ បានទៅក្រាបទូលដំណឹងដែលគួរត្រេកអរដល់ព្រះរាជា ព្រះរាជាទ្រង់ឃើញអាការរបស់ជនទាំងនោះ ទ្រង់ត្រិះរិះថា ព្រះតម្រាស់ដែលព្រះទសពលត្រាស់ហើយ ឃើញនឹងមានផល ព្រះអង្គស្តេចមកក្រាបទូលដំណឹងរបស់ព្រះរាជធិតាចំពោះព្រះទសពល ព្រះរាជធិតាត្រាស់ថា អាហារសម្រាប់អ្នកដែលព្រះអង្គនិមន្ត នឹងជាអាហារមង្គល សូមព្រះអង្គនិមន្តព្រះទសពល ៧ ថ្ងៃចុះ ។ ព្រះរាជាទ្រង់ធ្វើដូច្នោះ ថ្វាយទានចំពោះព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ៧ ថ្ងៃ ទារកបានរំលត់ចិត្តក្រវល់ក្រវាយរបស់ព្រះញាតិទាំងអស់ ព្រោះដូច្នោះ ព្រះញាតិទើបថ្វាយព្រះនាមដល់កុមារនោះថា *“សីវលីកុមារ”* សីវលីកុមារនោះជាអ្នកអត់ទ្រាំក្នុងកម្មគ្រប់យ៉ាងតាំងពីកើត ព្រោះនៅក្នុងព្រះគភ៌ដល់ ៧ ឆ្នាំ ព្រះធម្មសេនាបតីបុត្រ បានសន្ទនាប្រាស្រ័យនឹងសីវលីកុមារនោះ ក្នុងថ្ងៃទី ៧ សូម្បីព្រះសាស្តា ទ្រង់ភាសិតគាថាក្នុងធម្មបទថា

យោ ឥមំ បលិបថំ ទុគ្គំ   សំសារំ មោហមច្ចគា
តិណ្ណោ បារគតោ ឈាយី   អនេជោ អកថំកថី
អនុបាទាយ និព្វុតោ   តមហំ ព្រូមិ ព្រាហ្មណំ

អ្នកណាឆ្លងផ្លូវអន្តរាយ គឺ សង្សារ ដែលឆ្លងបានលំបាកនេះ

ដល់ត្រើយហើយ ជាអ្នកមានការសម្រឹងឈាន ឈានកន្លងនូវឱឃៈ មិនញាប់ញ័រ មិនមានសេចក្តីសង្ស័យ តថាគតហៅបុគ្គលនោះថា ជាព្រាហ្មណ៍ ដូច្នេះ ។

គ្រានោះ ព្រះថេរៈពោលនឹងសីវលីកុមារនោះយ៉ាងនេះថា ក៏អ្នកបានសោយគំនរទុក្ខបែបនេះ បើបួសមិនសមគួរឬ សីវលីកុមារឆ្លើយថា លោកម្ចាស់ដ៏ចម្រើន ខ្ញុំកាលបាន ក៏នឹងបួស ។ ព្រះនាងសុប្បវាសាឃើញទារកនោះ និយាយជាមួយព្រះថេរៈ គិតថា បុត្ររបស់យើងនិយាយអ្វីជាមួយព្រះធម្មសេនាបតី ទើបចូលទៅរកព្រះថេរៈ សួរថា បុត្ររបស់ខ្ញុំម្ចាស់និយាយអ្វីជាមួយលោកម្ចាស់ ព្រះថេរៈពោលថា បុត្ររបស់ព្រះនាងនិយាយដល់សេចក្តីទុក្ខដែលនៅក្នុងគភ៌ ដែលខ្លួនសោយហើយ ពោលថា បើព្រះនាងអនុញ្ញាតហើយ នឹងបួស ព្រះនាងសុប្បវាសាត្រាស់ថា ប្រពៃណាស់លោកម្ចាស់ មេត្តាឲ្យគេបព្វជ្ជាចុះ ព្រះថេរៈនាំទារកនោះទៅវិហារ ឲ្យតចបញ្ចកកម្មដ្ឋាន កាលនឹងឲ្យបព្វជ្ជា ពោលថា សីវលី យើងមិនចាំត្រូវឲ្យឱវាទទេ អ្នកចូរពិចារណាទុក្ខដែលអ្នកសោយមកអស់ ៧ ឆ្នាំនុ៎ះចុះ ព្រះសីវលីពោលថា ការបំបួសប៉ុណ្ណោះ ជានាទីរបស់លោកម្ចាស់ ចំណែកខ្ញុំករុណានឹងដឹងកិច្ចដែលខ្ញុំករុណាធ្វើ ។ ព្រះសីវលីនោះ តាំងនៅក្នុងសោតាបត្តិផល ក្នុងខណៈដែលកោរសក់មួយគាំបិតដំបូងនុ៎ះឯង ខណៈកោរសក់លើក

ទី ២ តាំងនៅក្នុងសកទាគាមិផល ក្នុងខណៈកោរសក់លើកទី ៣ តាំងនៅក្នុងអនាគាមិផល ការកោរសក់អស់ និងការសម្រេចព្រះអរហត្តក៏មានឡើងមិនមុនមិនក្រោយគ្នា ។ តាំងពីថ្ងៃទីលោកបួសហើយ បច្ច័យ ៤ កើតឡើងដល់ភិក្ខុ-សង្ឃគ្រប់គ្រាន់តាមសេចក្តីត្រូវការ ។ រឿងតាំងឡើងក្នុងទីនេះ ដោយប្រការដូច្នេះ ។

តមក ព្រះសាស្តាស្តេចបានទៅកាន់ក្រុងសាវត្ថី ព្រះថេរៈថ្វាយបង្គំព្រះសាស្តា ហើយទូលថា ព្រះអង្គ ខ្ញុំព្រះអង្គនឹងសាកល្បងបុណ្យរបស់ខ្ញុំព្រះអង្គសូមទ្រង់ប្រទានភិក្ខុ ៥០០ រូបដល់ខ្ញុំព្រះអង្គ ។ ត្រាស់ថា ទទួលយកចុះសីវលី ។ ទេវតាដែលស្ថិតនៅនឹងដើមនិគ្រោធ បានឃើញជាដំបូង បានថ្វាយទានចំពោះព្រះថេរៈនោះអស់ ៧ ថ្ងៃ ។

ដូច្នោះ លោកទើបពោលថា ៖

និគ្រោធំ បឋមំ បស្សិ ទុតិយំ បណ្ឌវបព្វតំ
តតិយំ អចិរវតិយំ ចតុត្ថំ វរសាគរំ
បញ្ចមំ ហិមវន្តំ សោ ឆដ្ឋំ ឆទ្ទន្តុបាគមិ
សត្តមំ គន្ធមាទនំ អដ្ឋមំ អថ រេវតំ

ឃើញគ្រាដំបូង ត្រង់ដើមនិគ្រោធ ឃើញលើកទីពីរត្រង់ ភ្នំបណ្ឌវៈ

លើកទីបី ត្រង់ទន្លេអចិរវតី លើកដែលបួន ត្រង់សមុទ្រ លើកទី ៥ ត្រង់ព្រៃហិមពាន្ត លើកទី ៦ ត្រង់ស្រះឆទ្ទន្ត លើកទី ៧ ភ្នំគន្ធមាទន៍ លើកទី ៨ ទៅកាន់ទីនៅរបស់ព្រះរេវតៈ ។

ក្នុងទីគ្រប់កន្លែង ទេវតាបានថ្វាយទានមួយកន្លែង ៧ ថ្ងៃៗ ត្រង់ភ្នំគន្ធមាទន៍ស្តេចទេវរាជឈ្មោះ **នាគទត្ត** ក្នុង ៧ ថ្ងៃ បានថ្វាយបិណ្ឌបាតលាយដោយទឹកដោះមួយថ្ងៃ , បានថ្វាយបិណ្ឌបាតលាយដោយទឹកដោះថ្លាមួយថ្ងៃ ភិក្ខុសង្ឃពោលថា អ្នកមានអាយុ សូម្បីទឹកដោះរបស់ទេវរាជនេះ មិនប្រាកដទីដែលគេរីតទឹកដោះ ការប្រចាប់ទឹកដោះថ្លាក៏មិនមាន បពិត្រទេវរាជ ផលនេះកើតឡើងដល់ព្រះអង្គបានមកដូចម្តេច ។ ស្តេចទេវរាជពោលថា លោកម្ចាស់ នេះជាផលនៃការថ្វាយស្លាកភត្ត លាយទឹកដោះចំពោះព្រះទសពល កាលព្រះកស្សបទសពលសម្ពុទ្ធ ក្រោយមកព្រះសាស្តាទ្រង់ធ្វើការ ដែលទេវតាធ្វើការទទួលព្រះថេរៈនោះក្នុងព្រៃគគីឲ្យជាអត្ថុប្បត្តិ ហេតុកើតរឿង ទើបទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងជាកំពូលលើពួកភិក្ខុដែលមានលាភ ក្នុងសាសនារបស់ព្រះអង្គ ។

ចប់អដ្ឋកថា សូត្រទី ៩

# អដ្ឋកថាសូត្រទី ១០

## ប្រវត្តិព្រះវក្កលិត្ថេរ

*គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ១០ ដូចតទៅនេះ ៖*

[១៤៧] *ដោយបទថា* ***សទ្ធាធិមុត្តានំ*** *ទ្រង់សម្តែងថា ព្រះវក្កលិត្ថេរៈ ជាកំពូលលើពួកភិក្ខុដែលបង្អោនចិត្តទៅដោយសទ្ធា មានសទ្ធាខ្លាំងក្លា ពិតហើយ សទ្ធារបស់បុគ្គលដទៃៗ មានតែធ្វើឲ្យចម្រើន ចំណែករបស់ព្រះថេរៈត្រូវថយចុះ ព្រោះដូច្នោះ ព្រះថេរៈនោះ ព្រះដ៏មានព្រះភាគទើបត្រាស់ថា ជាកំពូលលើពួកភិក្ខុដែលបង្អោនចិត្តទៅដោយសទ្ធា ។ ពាក្យថា* ***វក្កលិ*** *ជាឈ្មោះរបស់ព្រះថេរៈនោះ ។ ក្នុងបញ្ហាកម្មរបស់ព្រះថេរៈនោះ មានរឿងដែលនឹងពោលតាមលំដាប់ ដូចតទៅនេះ ៖*

*ពោលដោយសង្ខេប ក្នុងអតីតកាល សម័យព្រះបទុមុត្តរសម្ពុទ្ធ ព្រះថេរៈនេះ ទៅវិហារ ឈរស្តាប់ធម៌ខាងក្រោយបរិស័ទ ដោយន័យដែលពោលហើយនុ៎ះឯង ។ ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូប ទុកក្នុងតំណែងជាកំពូលលើពួកភិក្ខុដែលបង្អោនចិត្តទៅដោយសទ្ធា ទើបគិតថា សូម្បីយើងក៏គប្បីដូច្នេះក្នុងអនាគតកាល ទើបនិមន្តព្រះសាស្តា ដោយន័យដែលពោលហើយនោះ*

ឯង ថ្វាយមហាទាន ៧ ថ្ងៃ ថ្វាយបង្គំព្រះទសពលហើយធ្វើសេចក្ដីប្រាថ្នាថា ព្រះអង្គ ដោយកុសលកម្មយ៉ាងនេះ សូមខ្ញុំព្រះអង្គគប្បីជាកំពូលលើពួកភិក្ខុដែលបង្អោនចិត្តជឿដោយសទ្ធា ក្នុងសាសនារបស់ព្រះពុទ្ធមួយព្រះអង្គក្នុងអនាគតដូចភិក្ខុដែលព្រះអង្គទ្រង់ស្ថាបនា ទុកក្នុងតំណែងឯតទគ្គៈលើពួកភិក្ខុដែលបង្អោនចិត្តជឿដោយសទ្ធា ។ ព្រះសាស្ដាទ្រង់ជ្រាបថា គេមិនមានអន្តរាយ ទើបទ្រង់ព្យាករណ៍ ហើយស្ដេចយាងត្រឡប់ទៅ ។

ចំណែកលោកធ្វើកុសលរហូតអស់ជីវិត ហើយវិលវល់នៅក្នុងទេវតានិងមនុស្ស បានបដិសន្ធិក្នុងត្រកូលព្រាហ្មណ៍ក្រុងសាវត្ថី គ្រាព្រះសាស្ដារបស់យើង ញាតិទាំងឡាយបានដាក់នាមរបស់លោកថា **វក្កលិ** លោកចម្រើនវ័យហើយ រៀនត្រៃវេទ ឃើញព្រះទសពលមានភិក្ខុសង្ឃហែហម ស្ដេចចារិកក្នុងក្រុងសាវត្ថី ពិនិត្យមើលសិរីសម្បត្តិរបស់ព្រះសាស្ដាមិនឆ្អែត ដោយការឃើញសិរីសម្បត្តិ ទើបត្រាច់ទៅព្រមជាមួយព្រះទសពលនោះឯង ស្ដេចទៅវិហារ ក៏ទៅជាមួយព្រះទសពល ឈរមើលសេចក្ដីសម្រេចនៃព្រះសិរីសម្បត្តិនោះឯង ឈរស្ដាប់ធម៌ក្នុងទីចំពោះព្រះភ័ក្ត្រព្រះសាស្ដា ដែលប្រថាប់ត្រាស់សម្ដែងធម៌ក្នុងធម្មសភា លោកបានសទ្ធាហើយគិតថា យើងនៅគ្រប់គ្រងផ្ទះនឹងមិនបានឃើញព្រះទសពលជានិច្ច ទើបទូលសូមបព្វជ្ជា បួសហើយក្នុងសំណាក់របស់ព្រះសាស្ដា

តាំងពីនោះមក វៀរតែវេលាឆាន់អាហារ ក្នុងវេលាដ៏សេស ឈរក្នុងទីដែលអាចឃើញព្រះទសពល ទើបលះបង់យោនិសោមនសិការចេញ ហើយមើលព្រះទស-ពលតែម្យ៉ាង ព្រះសាស្តាទ្រង់រង់ចាំឲ្យញាណរបស់លោកចាស់ក្លាជាមុន កាលលោកត្រាច់ទៅមើលព្រះអង្គក្នុងទីនោះៗ អស់កាលដ៏យូរ ក៏ទ្រង់មិនត្រាស់អ្វី ទ្រង់ជ្រាបថា ឥឡូវនេះញាណរបស់លោកចាស់ក្លាហើយ លោកអាចត្រាស់ដឹងបាន ទើបត្រាស់យ៉ាងនេះថា វក្កលិ អ្នកនឹងមានប្រយោជន៍អ្វីដោយការមើលរូប-កាយស្អុយនេះ ដែលអ្នកឃើញ វក្កលិ នរណាឃើញធម៌ អ្នកនោះឈ្មោះថាឃើញតថាគត នរណាឃើញតថាគត អ្នកនោះឈ្មោះថា ឃើញធម៌ វក្កលិ ការឃើញធម៌ ទើបនឹងឈ្មោះថា ឃើញតថាគត ។ សូម្បីព្រះសាស្តាទ្រង់ឱវាទយ៉ាងនេះ ព្រះថេរៈក៏មិនអាចលះបង់ការមើលព្រះទសពលបាន ហើយក៏ទៅកាន់ទីដទៃ តពីនោះ ព្រះសាស្តាទ្រង់មានព្រះតម្រិះថា ភិក្ខុនេះមិនបានសេចក្តីសង្វេគ នឹងមិនអាចត្រាស់ដឹង កាលជិតចូលវស្សា ទ្រង់ប្រកាសបណ្តេញព្រះថេរៈនោះថា វក្កលិ ចូរចៀសចេញទៅ ធម្មតាព្រះពុទ្ធទាំងឡាយទ្រង់មានព្រះតម្រាស់ដែលពិត ព្រោះដូច្នោះ ព្រះថេរៈទើបមិនអាចឆ្លើយតបនឹងព្រះសាស្តាបាន មិនអាចទទឹងចំពោះព្រះភ័ក្ត្រព្រះទសពល គិតថា ឥឡូវនេះយើងនឹងធ្វើយ៉ាងណាបាន យើងត្រូវព្រះសាស្តាបណ្តេញចេញហើយ យើងក៏មិនបានទៅចំពោះព្រះភក្ត្រព្រះអង្គ ណ្ហើយ

ចុះ ប្រយោជន៍អ្វីដោយជីវិតរបស់យើង ទើបឡើងកាន់កំពូលភ្នំគិជ្ឈកូដ ព្រះសាស្ដា ទ្រង់ជ្រាបថា ព្រះថេរៈនោះមានសេចក្ដីលំបាក ទ្រង់ត្រិះរិះថា ភិក្ខុនេះកាលមិនបានការលួងលោមចិត្តពីតថាគត ក៏នឹងគប្បីទម្លាយឧបនិស្ស័យនៃមគ្គផលចេញ ទើបទ្រង់បញ្ចេញព្រះរស្មីទៅសម្ដែងព្រះអង្គ គ្រានោះ តាំងពីព្រះវក្កលិឃើញព្រះសាស្ដា ក៏លះបង់សេចក្ដីសោកដ៏ធំចេញ ដោយប្រការដូច្នេះ ។ ព្រះសាស្ដាដើម្បីនឹងឲ្យព្រះវក្កលិត្ថេរៈកើតបីតិសោមនស្សឡើង ដូចបង្ហូរទឹកចុះក្នុងស្រះដែលស្ងួត ទើបត្រាស់ព្រះគាថាក្នុងព្រះធម្មបទថា

បាមោជ្ជពហុលោ ភិក្ខុ បសន្នោ ពុទ្ធសាសនេ
អធិគច្ឆេ បទំ សន្តំ សង្ខារុបសមំ សុខន្តិ ។

ភិក្ខុដែលច្រើនដោយសេចក្ដីបាមោជ្ជ ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ទើបគប្បីសម្រេចបទដែលស្ងប់ដែលរម្ងាប់សង្ខារ ជាសេចក្ដីសុខ ដូច្នេះ ។

មួយទៀត ព្រះសាស្ដាទ្រង់លាព្រះហស្ត ប្រទានដល់ព្រះវក្កលិត្ថេរៈថា មកចុះវក្កលិ ។ ព្រះថេរៈកើតបីតិយ៉ាងខ្លាំងថា យើងឃើញព្រះទសពលហើយ បានទទួលព្រះតម្រាស់ត្រាស់ហៅថា មកចុះវក្កលិ ទាំងមិនដឹងការទៅរបស់ខ្លួនថា នឹងទៅផ្លូវណា ទើបលោតឡើងទៅក្នុងអាកាសចំពោះព្រះភ័ក្ត្រព្រះទសពល

ដោយដើងជាន់លើក្អំ នឹកដល់ព្រះតម្រាស់ដែលព្រះសាស្តាត្រាស់ហើយ គ្រប សង្កត់បីតិក្នុងអាកាសនុ៎ះឯង សម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទា ចុះមក ថ្វាយបង្គំព្រះតថាគត ។ ខាងក្រោយមក ព្រះសាស្តា ទ្រង់ប្រថាប់កណ្តាលពួក ព្រះអរិយៈ ទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងជាកំពូលលើពួកភិក្ខុដែលបង្អោន ចិត្តជឿដោយសទ្ធា ។

ចប់អដ្ឋកថា សូត្រទី ១០

## ចប់វគ្គទី ២

រួមអដ្ឋកថាក្នុងវគ្គនេះមាន ១០ អដ្ឋកថា

# វគ្គទី ៣

## អដ្ឋកថាសូត្រទី ១

## ប្រវត្តិព្រះរាហុលត្ថេរ

គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[១៤៨] បទថា *សិក្ខាកាមានំ* សេចក្តីថា អ្នកប្រាថ្នា មានន័យថា អ្នកពេញចិត្តការសិក្សាសិក្ខា ៣ ។ ព្រះសាស្តាទ្រង់សម្តែងព្រះរាហុល ដែលជាឱរសរបស់ព្រះអង្គថា "*រាហុលោ*" បានឮថា ព្រះថេរៈក្រោកឡើងពីព្រឹកព្រលឹម តាំងពីថ្ងៃដែលបានបួសហើយក្បង់ខ្សាច់ពេញដៃ ប្រាថ្នាថា អស្ចារ្យណាស់ យើងនឹងគប្បីបានឱវាទ និងព្រះអនុសាសនីមានប្រមាណប៉ុណ្ណេះពីព្រះទសពល និងពីព្រះឧបជ្ឈាយ៍ អាចារ្យទាំងឡាយក្នុងថ្ងៃនេះ ព្រោះដូច្នោះ លោកទើបឈ្មោះថាជាកំពូលលើពួកភិក្ខុដែលប្រាថ្នាដល់ការសិក្សា ។

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

## រឿងព្រះរដ្ឋបាលត្ថេរ

គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[១៤៨] បទថា **សទ្ធាបព្វជិតានំ** ប្រែថា អ្នកបួសដោយសទ្ធា ។ បទថា **រដ្ឋបាលោ** បានដល់ អ្នកដល់ការរាប់ថា រដ្ឋបាល ព្រោះអត្ថថា ជាអ្នកអាចរក្សារដ្ឋបាន ឬអ្នកកើតក្នុងត្រកូលដែលអាចរក្សារដ្ឋដែលបែកបាក់ឲ្យប្រួបប្រួមគ្នាបាន ។ ពិតណាស់ ភិក្ខុរដ្ឋបាលនោះ ស្តាប់ធម៌ទេសនារបស់ព្រះសាស្តា បានសទ្ធា បានអត់បាយអស់ ១៤ ថ្ងៃ ទើបញ៉ាំងមាតាបិតាអនុញ្ញាតឲ្យបួសបាន បានបួសហើយ ព្រោះដូច្នោះ លោកទើបជាកំពូលលើពួកភិក្ខុដែលបួសដោយសទ្ធា ។

ប្រវត្តិព្រះរាហុលត្ថេរ និងព្រះរដ្ឋបាលត្ថេរ ៖

ក៏ក្នុងបញ្ហាកម្មរបស់ព្រះថេរៈទាំងពីររូបនេះ មានរឿងដែលនឹងពោលតាមលំដាប់ដូចតទៅនេះ ៖

បានឮមកថា ក្នុងអតីតកាល សម័យព្រះបទុមុត្តរសម្ពុទ្ធ ព្រះថេរៈទាំង ២ នេះ កើតក្នុងត្រកូលគហបតីមហាសាលក្នុងក្រុងហង្សវតី ក្នុងវេលាដែលលោកនៅក្មេង មិនមាននរណានិយាយដល់ឈ្មោះ និងគោត្រ តែពេលលោកចម្រើន

វ័យហើយ តាំងនៅក្នុងឃរាវាស កាលបិតារបស់លោកធ្វើកាលកិរិយាទៅ អ្នកទាំង ២ ទើបហៅអ្នករក្សាឃ្លាំងរតនៈរបស់ខ្លួនមក ហើយឃើញទ្រព្យប្រមាណមិនបាន គិតថា ជនទាំងឡាយមានតា និងតាទួតជាដើម នាំយកគំនរទ្រព្យមានប្រមាណប៉ុណ្ណេះទៅជាមួយខ្លួនមិនបាន ឥឡូវនេះ យើងនឹងកាន់យកទ្រព្យនេះទៅដោយឧបាយយ៉ាងណាមួយ ដូច្នេះ បុគ្គលទាំង ២ នោះ ទើបផ្ដើមឲ្យមហាទានដល់មនុស្សកំព្រា និងអ្នកធ្វើដំណើរជាដើម ក្នុងស្ថានទី ៤ កន្លែង លោកម្នាក់សាកសួរអ្នកដែលមកហើយក្នុងរោងទានរបស់ខ្លួនថា អ្នកណាពេញចិត្តក្នុងវត្ថុណា បាយ បបរ និងរបស់ទំពារ ក៏ឲ្យវត្ថុនោះដល់អ្នកនោះ ព្រោះហេតុនោះឯង គេទើបមានឈ្មោះថា អ្នកពោលនឹងអ្នកដែលមកហើយ ។ លោកម្នាក់ទៀតមិនសួរឡើយ យកភាជនៈដែលគេកាន់មកហើយ ហើយដាក់ឲ្យពេញៗ ទើបឲ្យ ដោយហេតុនោះឯង គេទើបមានឈ្មោះថា មិនពោលជាមួយអ្នកដែលមកហើយ អធិប្បាយថា សួរដោយសេចក្ដីមិនប្រមាទ ថ្ងៃមួយ ជនទាំង ២ នោះ ចេញទៅក្រៅស្រុក ក៏ខ្ចាត់ពីព្រឹកព្រលឹម ។

សម័យនោះ តាបសអ្នកមានឫទ្ធិច្រើន ២ រូប ហោះមកពីព្រៃហិមពាន្តដើម្បីភិក្ខាចារ ចុះមិនឆ្ងាយពីសម្លាញ់ទាំង ២ នោះ ឈរក្នុងទីម្ខាងដោយគិតថា ជនទាំង ២ នោះ កាលតាបសទាំង ២ នោះ ចាត់ចែងបរិក្ខារមានទឹកក្នុងឃ្លោក

ជាដើម បំណាច់ដើរទៅខាងក្នុងស្រុក ទើបមកសំពះជិត គ្រានោះតាបសពោល
នឹងជនទាំង ២ នោះថា លោកអ្នកមានបុណ្យធំ លោកមកក្នុងវេលាណា ជនទាំង
២ នោះឆ្លើយថា មកអម្បាញ់មិញនេះឯងលោកម្ចាស់ ហើយទទួលភាជនៈឃ្លោក
ពីដៃរបស់តាបសទាំង ២ នោះ នាំទៅផ្ទះរបស់ខ្លួន ក្នុងវេលាសម្រេចភត្តកិច្ច
ទើបសូមឲ្យទទួល ប្រាប់ថា នឹងមកទទួលភិក្ខាជាប្រចាំ ។

តាបសទាំងពីររូបនោះ មួយរូបជាអ្នកប្រាជ្ញាក្តៅ ទើបញែកទឹកមហាសមុទ្រ
ចេញជា ២ ចំណែកដោយអានុភាពរបស់ខ្លួន ហើយទៅកាន់ភពរបស់បឋវិន្ទ្រ-
នាគរាជសម្រាកពេលថ្ងៃ ។ តាបសកាន់យករដូវល្ហមសប្បាយហើយ ទើបបាន
ត្រឡប់មក កាលនឹងធ្វើអនុមោទនាភត្តក្នុងផ្ទះនៃឧបដ្ឋាករបស់ខ្លួន ក៏ពោលថា
សូមសម្រេចដូចភពបឋវិន្ទ្រនាគរាជ ។ តមកថ្ងៃមួយ ឧបដ្ឋាកសួរតាបសនោះ
ថា លោកដ៏ចម្រើន លោកធ្វើអនុមោទនាថា ចូរសម្រេចដូចភពបឋវិន្ទ្រនាគរាជ
មេត្តាប្រាប់សេចក្តីនោះ ពួកខ្ញុំមិនជ្រាបសេចក្តីដែលលោកពោលទេ ពាក្យនេះ
លោកសំដៅសេចក្តីអ្វី , តាបសពោលថា ពិតហើយ កុដុម្ពិកៈ យើងពោលថា
សម្បត្តិរបស់លោក ចូរដូចជាសម្បត្តិរបស់ស្តេចនាគឈ្មោះថា បឋវិន្ទ្រ , តាំង
ពីនោះមក កុដុម្ពិកៈក៏តាំងចិត្តទុកក្នុងភពរបស់ស្តេចនាគឈ្មោះថា បឋវិន្ទ្រ ។

តាបសមួយរូបទៀត ទៅកាន់ភពតាវត្តិង្ស ធ្វើការសម្រាកពេលថ្ងៃ ក្នុង

សេរិសកវិមានដែលស្ងាត់ តាបសនោះ ត្រាច់ទៅត្រាច់មកឃើញសម្បត្តិរបស់ស្តេចសក្កទេវរាជ កាលនឹងធ្វើអនុមោទនាដល់ឧបដ្ឋាកខ្លួន ក៏ពោលថា សម្បត្តិរបស់លោកចូរដូចជាសក្កវិមាន ។ គ្រានោះ កុដុម្ពិកៈនោះ ក៏សួរតាបសនោះដូចជាសម្លាញ់ម្នាក់ទៀតសួរតាបសនោះ កុដុម្ពិកៈក៏ស្តាប់ពាក្យរបស់តាបសនោះទើបតាំងចិត្តទុកក្នុងភពរបស់សក្កទេវរាជ ។ ជនទាំងពីរនោះ ទើបកើតក្នុងទីដែលខ្លួនប្រាថ្នាហើយនោះឯង ។

អ្នកដែលកើតក្នុងភពរបស់បឋវិន្ទ្រនាគរាជ ក៏មានឈ្មោះថា បឋវិន្ទ្រ-នាគរាជា ។ ព្រះរាជានោះ ក្នុងខណៈដែលខ្លួនកើតហើយ ឃើញអត្តភាពរបស់ខ្លួន មានសេចក្តីក្តៅចិត្តថា តាបសដែលចូលកាន់ត្រកូល សរសើរគុណនៃឋានៈរបស់យើងដែលមិនគួរពេញចិត្តសោះ ទីនេះ ជាទីត្រូវវិនាសទៅព្រោះផ្ទៃ តាបសនោះមិនដឹងទីដទៃៗ ដោយពិត ក្នុងខណៈនោះឯង ពួកនាងនាគតែងខ្លួនហើយបានប្រគុំតន្ត្រីគ្រប់ទិសដល់ស្តេចនាគនោះ ក្នុងខណៈនោះឯង ស្តេចនាគនោះក៏លះបង់អត្តភាពនោះ ក្លាយភេទជាមាណពតូច ។ មហារាជទាំង ៤ ចូលគាល់ស្តេចសក្កៈរាល់កន្លះខែម្តង ព្រោះដូច្នោះ សូម្បីស្តេចនាគនោះក៏ត្រូវទៅគាល់ស្តេចសក្កៈព្រមជាមួយស្តេចនាគឈ្មោះ វិរូបក្ខផង ស្តេចសក្កៈ ឃើញស្តេចនាគនោះមកពីចម្ងាយក៏ចាំបាន ទីនោះ ស្តេចសក្កៈទើបសួរស្តេចនាគនោះក្នុងវេលាឈរ ក្នុង

ទីជិតថា សម្លាញ់ លោកទៅកើតទីណា ស្តេចនាគពោលថា មហារាជ កុំសួរឡើយ ខ្ញុំទៅកើតក្នុងទីដែលត្រូវវិនាសព្រោះផ្ទៃ ចំណែកលោកបានមិត្តដែលល្អហើយ សក្កទេវរាជត្រាស់ថា សម្លាញ់ លោកកុំលំបាកឡើយថា កើតក្នុងទីមិនសមគួរ ព្រះទសពលព្រះនាមថា **បទុមុត្តរៈ** ទ្រង់កើតក្នុងលោកហើយ លោកចូរធ្វើកុសលកម្មចំពោះព្រះអង្គនោះ ហើយប្រាថ្នាឋានៈនេះចុះ យើងទាំង ២ នឹងនៅរួមគ្នាជាសុខ ។ ស្តេចនាគនោះពោលថា ទេវៈ ខ្ញុំនឹងធ្វើយ៉ាងនោះ ទៅនិមន្តព្រះបទុមុត្តរទសពល ចាត់ចែងគ្រឿងសក្ការៈបូជា រហូតអស់មួយយប់ដល់ភ្លឺជាមួយនាគបរិស័ទក្នុងពិភពនាគរបស់ខ្លួន ។

ថ្ងៃស្អែក កាលអរុណៈ ព្រះសាស្តាត្រាស់ហៅព្រះសុមនត្ថេរៈ ដែលជាឧបដ្ឋាករបស់ព្រះអង្គថា សុមនៈ ថ្ងៃនេះ តថាគតនឹងទៅភិក្ខាចារក្នុងទីឆ្ងាយ ភិក្ខុបុថុជ្ជនចូរកុំមក , ចូរមកតែភិក្ខុអ្នកសម្រេចបដិសម្ភិទា អ្នកទ្រទ្រង់ព្រះត្រៃបិដក អ្នកមានអភិញ្ញា ៦ ប៉ុណ្ណោះ ព្រះថេរៈស្តាប់ព្រះតម្រាស់របស់ព្រះសាស្តាហើយប្រកាសដល់ភិក្ខុទាំងពួង ភិក្ខុប្រមាណមួយសែន ហោះទៅព្រមនឹងព្រះសាស្តា ស្តេចនាគបវត្ត្រជាមួយនាគបរិស័ទមកទទួល ព្រះទសពលក្រឡេកមើលភិក្ខុ-សង្ឃដែលហែហមព្រះសាស្តា ដែលកំពុងជាន់លើទឹករលកមានពណ៌ដូចកែវមណីឃើញព្រះសាស្តានៅខាងដើម ព្រះសង្ឃនវកៈ រហូតដល់សាមណេរឈ្មោះឧប-

រេវតៈ ដែលជាឱរសរបស់ព្រះតថាគត នៅខាងក្រោយ ទើបកើតបីតិបាមោជ្ជៈ ថា ពុទ្ធានុភាពបែបនេះ របស់ព្រះសាវកដ៏សេសមិនគួរអស្ចារ្យ តែព្រះពុទ្ធានុភាពនៃកុមារតូចនេះ គួរអស្ចារ្យហួសប្រមាណ ដូច្នេះ ។

គ្រានោះ កាលព្រះទសពលប្រថាប់អង្គុយក្នុងពិកពរបស់ស្តេចនាគនោះ ហើយ កាលភិក្ខុក្រៅពីនេះអង្គុយ ផ្តើមតាំងពីទីបំផុតជរាបមកដល់អាសនៈរបស់សាមណេរឧបរេវតៈ ក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះសាស្តា ស្តេចនាគកាលថ្វាយបាយយាគូក្តី កាលថ្វាយរបស់ទំពារក្តី ក្រឡេកមើលព្រះទសពលម្តង មើលសាមណេរឧបរេវតៈម្តង ន័យថា មហាបុរិសលក្ខណៈ ៣២ ប្រការ ក្នុងសរីរៈរបស់សាមណេរនោះ រមែងប្រាកដដូចព្រះពុទ្ធ មេ្លះហ្ន៎ ដូច្នេះ ទើបសួរភិក្ខុមួយរូបដែលអង្គុយជិតនោះថា លោកម្ចាស់ សាមណេររូបនេះ ជាអ្វីនឹងព្រះទសពល ភិក្ខុនោះឆ្លើយថា ជាឱរស មហាបពិត្រ ។ ព្រះអង្គទើបត្រិះរិះថា ភិក្ខុរូបនេះធំហ្ន៎ ទើបបានទូវភាវៈជាឱរសរបស់ព្រះតថាគតដែលស្រស់ល្អបែបនេះ សូម្បីសរីរៈរបស់លោក ក៏ប្រាកដដូចព្រះសរីរៈរបស់ព្រះពុទ្ធដោយចំណែកមួយ សូម្បីខ្លួនយើងក៏គួរជាយ៉ាងនេះក្នុងអនាគតកាល ទើបថ្វាយមហាទាន ៧ ថ្ងៃ ហើយធ្វើសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគប្បីជាឱរសរបស់ព្រះពុទ្ធអង្គណាមួយក្នុងអនាគត ដូចឧបរេវតៈសាមណេរនេះ ដោយអនុភាពនៃកុសលកម្ម

នេះ ព្រះសាស្តាទ្រង់ជ្រាបថា មិនមានអន្តរាយ ទើបទ្រង់ព្យាករណ៍ថា ក្នុងអនាគត មហាបពិត្រនឹងជាឱរសនៃព្រះពុទ្ធព្រះនាមថា **គោតម** ដូច្នេះ ហើយស្តេចក៏យាងត្រឡប់ទៅ ។

ចំណែកបបវិទ្ធនាគរាជ កាលដល់កន្លះខែម្តងក៏ទៅគាល់ស្តេចសក្កៈជាមួយស្តេចនាគឈ្មោះវិរូបក្ខៈ គ្រានោះ ស្តេចសក្កៈត្រាស់សួរ ស្តេចនាគនោះដែលមកឈរក្នុងទីជិតថា សម្លាញ់ លោកប្រាថ្នាទេវលោកនេះហើយឬ ។ (ស្តេចនាគ) ខ្ញុំមិនបានប្រាថ្នាទេសម្លាញ់ ។ (សក្កៈ) លោកឃើញទោសអ្វីឬ? ។ (ស្តេចនាគ) មិនមានទោសទេ មហារាជ , តែខ្ញុំឃើញឧបរេវតសាមណេរជាឱរសរបស់ព្រះទសពល តាំងពីខ្ញុំបានឃើញសាមណេរនោះ ក៏មិនបានបង្អោនចិត្តទៅក្នុងទីដទៃ ខ្ញុំធ្វើសេចក្តីប្រាថ្នាថា ក្នុងអនាគតកាល សូមឲ្យខ្ញុំបានជាឱរសបែបនេះរបស់ព្រះពុទ្ធអង្គណាមួយ បពិត្រមហារាជ សូម្បីព្រះអង្គក៏ចូរធ្វើសេចក្តីប្រាថ្នាណាមួយចុះ យើងទាំង ២ នឹងមិនបែកគ្នាក្នុងទីដែលកើតហើយ ស្តេចសក្កៈទទួលពាក្យរបស់ស្តេចនាគនោះហើយ ឃើញភិក្ខុដែលមានអានុភាពច្រើនមួយអង្គ ទើបនឹកថា កុលបុត្រនេះចេញបួសពីត្រកូលណាហ្ន៎ ដូច្នេះ ជ្រាបថា កុលបុត្រអ្នកនេះ ជាបុត្ររបស់ត្រកូលអ្នកអាចរួបរួមរដ្ឋដែលបែកបាក់គ្នា ហើយធ្វើការអត់អាហារដល់ ១៤ ថ្ងៃ ឲ្យមាតាបិតាអនុញ្ញាតឲ្យបព្វជ្ជា លុះជ្រាបហើយ ទើបធ្វើដូចជាមិនជ្រាប

ទូលសួរព្រះទសពល ហើយធ្វើមហាសក្ការៈ ៧ ថ្ងៃ តាំងសេចក្ដីប្រាថ្នាថា បពិត្រព្រះអង្គ ដោយផលនៃកល្យាណកម្មនោះ ខ្ញុំព្រះអង្គគប្បីជាកំពូលលើពួកភិក្ខុអ្នកបួសដោយសទ្ធាក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយក្នុងអនាគត ដូចជាកុលបុត្រនេះក្នុងសាសនារបស់ព្រះអង្គចុះ ។ ព្រះសាស្ដា ទ្រង់ជ្រាបសេចក្ដីប្រាថ្នាដែលរកអន្តរាយមិនបាន ទើបព្យាករណ៍ថា មហាបពិត្រ ព្រះអង្គនឹងជាកំពូលលើពួកភិក្ខុដែលបួសដោយសទ្ធាក្នុងសាសនារបស់ព្រះពុទ្ធព្រះនាមថា **គោតម** ក្នុងអនាគត ហើយស្ដេចក៏យាងត្រឡប់ទៅ ចំណែកស្ដេចសក្កៈ ក៏ស្ដេចត្រឡប់ទៅកាន់ទេវបុររបស់ព្រះអង្គដូចដើម ។

ជនទាំងពីរនាក់នោះ ចុតិចាកទីដែលខ្លួនកើតហើយ វិលវល់នៅក្នុងទេវតានិងមនុស្សកន្លងទៅច្រើនពាន់កប្ប ក្នុងទីបំផុតកប្បទី ៩២ រាប់ពីកប្បនេះ ព្រះពុទ្ធព្រះនាម **ផុស្សៈ** ទ្រង់ឧប្បត្តិឡើងក្នុងលោក ព្រះពុទ្ធបិតារបស់ព្រះអង្គ ជាព្រះរាជាព្រះនាមថា **មហិន្ទៈ** មានប្អូនប្រុសផ្សេងមាតាគ្នា ៣ ព្រះអង្គ ព្រះរាជាទ្រង់ប្រកាន់ថា ព្រះពុទ្ធជារបស់យើងប៉ុណ្ណោះ ព្រះធម៌ជារបស់យើង ព្រះសង្ឃជារបស់យើង រៀងរាល់ថ្ងៃ ទ្រង់ថ្វាយភោជនចំពោះព្រះទសពលដោយព្រះអង្គឯងជាប្រចាំ ។

តមកខាងក្រោយ ថ្ងៃមួយ កាលជាយដែនរបស់ព្រះអង្គកម្រើក ព្រះអង្គ

ត្រាស់ហៅឱរសមកបង្គាប់ថា កូនអើយ ជាយដែនកម្រើក ពួកអ្នក ឬយើងគួរ ទៅ បើយើងទៅ អ្នកនឹងត្រូវប្រណិប័តព្រះទសពលដោយទំនងនេះ ព្រះរាជឱរស ទាំង ៣ នោះ ទូលដោយសំឡេងតែមួយថា បពិត្រព្រះជនក ព្រះអង្គមិនចាំបាច់ ស្តេចទៅទេ ពួកខ្ញុំព្រះអង្គនឹងរួមគ្នាបង្ក្រាបចោរ ដូច្នេះ ទើបថ្វាយបង្គំព្រះជនក ហើយស្តេចទៅកាន់បច្ចន្តជនបទ បង្ក្រាបចោរមានជ័យជំនះហើយ ស្តេចត្រឡប់ ព្រះរាជកុមារទាំងនោះប្រឹក្សានឹងពួកអ្នកជំនិតក្នុងរវាងផ្លូវថា បាអើយក្នុងវេលា ដែលយើងចូលគាល់ ព្រះជនកនឹងប្រទានពរ យើងនឹងទទួលពរអ្វី ពួករាជ-អាមាត្យទូលថា ព្រះអយ្យបុត្ត កាលព្រះជនករបស់ព្រះអង្គស្តេចសោយទិវង្គត ទៅ មិនមានអ្វីដែលឈ្មោះថា បានលំបាក តែព្រះអង្គសូមទទួលពរ គឺ ការ ប្រណិប័តព្រះពុទ្ធសម្ពុទ្ធ ដែលជាព្រះជេដ្ឋភាតារបស់ព្រះអង្គចុះ ព្រះរាជកុមារ ទាំងនោះពោលថា ពួកលោកនិយាយនេះប្រពៃហើយ ទើបព្រមព្រៀងគ្នាគ្រប់ៗ ព្រះអង្គ ទៅគាល់ព្រះជនក ។ ក្នុងកាលនោះ ព្រះជនកទ្រង់ជ្រះថ្លានឹងព្រះរាជ-កុមារទាំងនោះ ហើយទ្រង់ប្រទានពរ ព្រះរាជកុមារទាំងនោះទូលសូមពរថា ពួក ខ្ញុំព្រះអង្គនឹងប្រណិប័តព្រះតថាគតរហូតអស់ត្រៃមាស ព្រះរាជាត្រាស់ថា ពរនេះ យើងឲ្យមិនបាន ចូរសូមពរយ៉ាងដទៃចុះ ព្រះរាជកុមារក្រាបទូលថា បពិត្រព្រះ ជនក ពួកខ្ញុំព្រះអង្គក៏មិនត្រូវការពរយ៉ាងដទៃ ប្រសិនបើព្រះអង្គបំណាងនឹងព្រះ

រាជទាន សូមព្រះរាជទានពរនោះ ដល់ពួកខ្ញុំព្រះអង្គចុះ ព្រះរាជាកាលព្រះរាជ-ឱរសទាំងនោះទូលសូមរឿយៗ ទ្រង់ត្រិះរិះថា យើងមិនឲ្យមិនបាន ព្រោះយើងបានប្តេជ្ញាទុកហើយ ទើបត្រាស់ថា បាអើយ យើងឲ្យពរដល់ពួកអ្នក ក៏ប៉ុន្តែថា ធម្មតាព្រះពុទ្ធជាបុគ្គលដែលនរណាៗ ចូលគាល់បានលំបាក ទ្រង់មានប្រក្រតីត្រាច់ទៅតែព្រះអង្គឯងដូចសីហៈ ពួកអ្នកចូរជាអ្នកមិនប្រមាទ ប្រណិប័តព្រះទស-ពលចុះ ។

ព្រះរាជកុមារទាំងនោះត្រិះរិះថា កាលបើពួកយើងប្រណិប័តព្រះតថាគត ក៏គួរនឹងប្រណិប័តឲ្យសមគួរ ទើបព្រមព្រៀងគ្នាសមាទានសីល ១០ ជាអ្នកមិនមានក្ទិនធ្លាប តាំងបុរសទុក ៣ នាក់ ឲ្យថែរក្សារោងទានសម្រាប់ព្រះសាស្តា បណ្តាបុរស ៣ នាក់នោះ ម្នាក់ជាអ្នកចាត់ចែងប្រាក់ និងបាយ ម្ហូបអាហារត្រីសាច់ , ម្នាក់មាននាទីដួសបាយ ម្នាក់មាននាទីចាត់ចែងទាន ។ ក្នុងបុរស ៣ នាក់នោះ អ្នកចាត់ចែងប្រាក់ និងបាយទឹក មកកើតជាព្រះបាទពិម្ពិសារមហារាជក្នុងបច្ចុប្បន្ន , អ្នកដួសបាយមកកើតជាវិសាខឧបាសក , អ្នកចាត់ចែងទានមកកើតជារដ្ឋបាលត្ថេរៈនេះឯង ។ កុលបុត្រនោះ បំពេញកុសលក្នុងភពនោះរហូតអស់ជីវិត ហើយកើតក្នុងទេវលោក , ចំណែកស្តេចនាគនេះ កើតជាព្រះជេដ្ឋឱរសរបស់ព្រះបាទកិកិ គ្រាព្រះទសពលព្រះនាមថា **កស្សប** ឈ្មោះថា រាហុលត្ថេរៈ

ព្រះញាតិទាំងឡាយតាំងនាមព្រះអង្គថា បឋវិន្ទ្រកុមារ ព្រះអង្គមានភគិនី ៧ អង្គ ព្រះភគិនីទាំងនោះ សាងបរិវេណថ្វាយព្រះទសពល ៧ កន្លែង ព្រះបឋវិន្ទ្រកុមារទ្រង់បានតំណែងជាឧបរាជ ព្រះអង្គត្រាស់ចំពោះភគិនីទាំងនោះថា ក្នុងបណ្តាបរិ-វេណដែលព្រះនាងបានសាងទុកនោះ សូមប្រទានឲ្យខ្ញុំមួយកន្លែង ព្រះភគិនីទាំងនោះទូលថា ម្ចាស់បង ព្រះអង្គតាំងនៅក្នុងឋានៈជាឧបរាជ ព្រះអង្គគប្បីប្រទានដល់ខ្ញុំវិញ សូមព្រះអង្គទ្រង់សាងបរិវេណដទៃចុះ ព្រះរាជកុមារនោះបានស្តាប់ពាក្យរបស់ព្រះភគិនីទាំងនោះហើយ ទើបឲ្យសាងវិហារ ៥០០ កន្លែង ។ អាចារ្យពួកខ្លះពោលថា បរិវេណ ៥០០ កន្លែងក៏មាន ព្រះរាជកុមារនោះ ទ្រង់បំពេញកុសលរហូតអស់ជីវិតក្នុងអត្តភាពនោះ ទៅកើតក្នុងទេវលោក ក្នុងពុទ្ធុប្បាទ-កាលនេះ បឋវិន្ទ្រកុមារបដិសន្ធិក្នុងព្រះគភ៌នៃព្រះអគ្គមហេសី នៃព្រះពោធិសត្វរបស់យើង សម្លាញ់របស់លោកកើតក្នុងផ្ទះនៃរដ្ឋបាលសេដ្ឋី ក្នុងថុល្លកោដ្ឋិត-និគម ដែនកុរុ ។

គ្រានោះ ព្រះទសពលរបស់យើង ទ្រង់សម្រេចអភិសម្ពោធិញ្ញាណហើយ ទ្រង់ប្រកាសធម្មចក្កដ៏ប្រសើរ ស្តេចមកកាន់ក្រុងកបិលភស្តុដោយលំដាប់ ទ្រង់បានឲ្យរាហុលកុមារបព្វជ្ជា ។ វិធីបព្វជ្ជារាហុលកុមារនោះ មកហើយក្នុងព្រះបាលី ។ ក៏ព្រះសាស្តាបានត្រាស់រាហុលោវាទសូត្រ ជាឱវាទរឿយៗ ដល់ព្រះ

រាហុលនោះដែលបព្វជ្ជាហើយយ៉ាងនេះ សូម្បីព្រះរាហុលក្រោកឡើងពីព្រឹកព្រលឹម យកដៃក្បង់ខ្សាច់ឡើងពោលថា ថ្ងៃនេះយើងគប្បីបានឱវាទមានប្រមាណប៉ុណ្ណេះ ពីព្រះទសពល និងឧបជ្ឈាយ៍ អាចារ្យទាំងឡាយ បានកើតការសន្ទនាគ្នាត្រង់កណ្តាលសង្ឃថា "រាហុលសាមណេរអត់ធន់ចំពោះព្រះឱវាទហ្ន៎ ជាឱរសដែលគួរស្រឡាញ់ដល់ព្រះជនក" ព្រះសាស្តា ទ្រង់ជ្រាបវារៈចិត្តរបស់ភិក្ខុទាំងឡាយ ទ្រង់ព្រះតម្រិះថា កាលតថាគតទៅហើយ ធម្មទេសនានឹងបកស្រាយ និងគុណរបស់រាហុលក៏ប្រាកដ ទើបស្តេចទៅ ប្រថាប់លើពុទ្ធាសនៈក្នុងធម្មសភា ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពួកខ្ញុំព្រះអង្គសន្ទនាគ្នាដល់រាហុលសាមណេរ ជាអ្នកអត់ធន់ចំពោះឱវាទព្រះអង្គ ព្រះសាស្តាទ្រង់តាំងនៅក្នុងឋានៈនេះ ទ្រង់បានសម្តែងដល់គុណរបស់រាហុលសាមណេរ ទើបទ្រង់នាំមិគជាតកមក ត្រាស់ថា ៖

មិគន្តិបល្លត្ថមនេកមាយំ
អដ្ឋក្ខុរំ អឌ្ឍរត្តាវបាយឹ
ឯកេន សោតេន ឆមាស្សសន្តោ
ឆហិ កលាហីតិ ភោ ភាគិនេយ្យោ តិ

ខ្ញុំញ៉ាំងម្រឹគជាក្មួយប្រុសដែលមានក្រចក ៨ ដេកដោយអាការ ៣ មានមារយាទច្រើនយ៉ាង ផឹកស៊ីក្នុងវេលាកណ្ដាលយប់ ឲ្យសិក្សាមាយារបស់ម្រឹគល្អហើយ ម្នាលប្អូនស្រី ម្រឹគជាក្មួយប្រុសត្រឡប់ដកដង្ហើមទុកបាន ដោយរន្ធត្រចៀកម្ខាង ដេកដួលនៅនឹងផែនដីនឹងធ្វើកល់លួងលោមនាយព្រានដោយឧបាយ ៦ ប្រការ ។

តមក ក្នុងវេលាដែលសាមណេរមានអាយុ ៧ វស្សា ទ្រង់សម្ដែងអម្ពលដ្ឋិយរាហុលោវាទដល់រាហុលសាមណេរនោះថា រាហុលកុំពោលសម្បជានមុសាដើម្បីលេងដោយសភាពជាក្មេងឡើយ ដូច្នេះជាដើម ។ ក្នុងវេលាដែលសាមណេរមានអាយុ ១៨ វស្សា ត្រាស់មហារាហុលោវាទសូត្រ ដោយន័យថា “រាហុល រូបណាមួយ” ដូច្នេះជាដើម ដល់រាហុល ដែលចូលទៅបិណ្ឌបាតតាមក្រោយព្រះតថាគត សម្លឹងមើលរូបសម្បត្តិរបស់ព្រះសាស្ដា និងរបស់ខ្លួន ត្រិះរិះដែលទាក់ទងដោយគេហស្សិតកូល ចំណែករាហុលោវាទក្នុងសំយុត្តក្ដី រាហុលោវាទក្នុងអង្គុត្តរនិកាយក្ដី ជាអាចារ្យនៃវិបស្សនារបស់ព្រះថេរៈនោះឯង ។

ក្រោយមក ព្រះសាស្ដាទ្រង់ជ្រាបថា ញាណរបស់លោកចាស់ក្លា ក្នុងវេលាដែលរាហុលជាភិក្ខុមិនទាន់មានវស្សា ប្រថាប់អង្គុយនៅអន្ធវ័ន ទ្រង់ត្រាស់ចូឡរាហុលោវាទសូត្រ វេលាចប់ទេសនា ព្រះរាហុលត្ថេរៈសម្រេចព្រះអរហត្ត

ព្រមទាំងទេវតាមួយសែនពាន់កោដិ ទេវតាដែលជាព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមីរាប់មិនបាន ។ តមកខាងក្រោយ ព្រះសាស្ដាទ្រង់ប្រថាប់ក្នុងកណ្ដាលព្រះអរិយសង្ឃ ទ្រង់ស្ថាបនាព្រះថេរៈក្នុងតំណែងជាកំពូលលើពួកភិក្ខុដែលប្រាថ្នាចំពោះការសិក្សាក្នុងសាសនានេះ ។

ក៏កាលព្រះសាស្ដាទ្រង់ស្ដេចចារិកទៅកាន់កុរុរដ្ឋ ទ្រង់យាងដល់ថុល្លកោ-ដ្ឋិតនិគមដោយលំដាប់ កុលបុត្រឈ្មោះរដ្ឋបាល ស្ដាប់ព្រះធម៌ទេសនារបស់ព្រះសាស្ដា បានសទ្ធា ឲ្យមាតាបិតាអនុញ្ញាតហើយ ចូលគាល់ព្រះទសពល បួសហើយក្នុងសំណាក់របស់ព្រះថេរៈមួយរូប តាមព្រះតម្រាស់របស់ព្រះសាស្ដា ចាប់តាំងពីថ្ងៃទីលោកបួសហើយ សេដ្ឋីគហបតីឃើញភិក្ខុទាំងឡាយទៅកាន់ត្រង់ទ្វារនិវេសន៍របស់ខ្លួន រមែងជេរបរិភាសថា មានការងារអ្វីរបស់លោក ក្នុងផ្ទះនេះ (យើង) មានបុត្រតូចម្នាក់ប៉ុណ្ណោះ ពួកលោកក៏មកនាំគេទៅ ឥឡូវនេះ នឹងធ្វើអ្វីទៀតមែនឬ ។ ព្រះសាស្ដាប្រថាប់នៅត្រង់ថុល្លកោដ្ឋិតគ្រាមកន្លះខែ ហើយស្ដេចមកកាន់ក្រុងសាវត្ថី ។ គ្រានោះ ព្រះរដ្ឋបាលធ្វើកិច្ចក្នុងយោនិសោមនសិការចម្រើនវិបស្សនា សម្រេចព្រះអរហត្តហើយ លោកទូលសូមអនុញ្ញាតព្រះសាស្ដាហើយទៅកាន់ថុល្លកោដ្ឋិតនិគម ដើម្បីសួរសុខទុក្ខបិតាមាតា ត្រាច់បិណ្ឌបាតទៅតាមលំដាប់ប្រកផ្លូវក្នុងនិគមនោះ បាននំកុម្មាសផ្អូមពីសំណាក់នៃនិវេសន៍របស់

បិតា កើតអសុភសញ្ញាក្នុងពួកស្ត្រីដែលតែងខ្លួនហើយ ទើបឈរឡើងសម្តែងធម៌ហោះទៅ ដូចសរភ្លើងដែលស្ទុះចេញពីខ្សែធ្នូ ទៅកាន់មិគាចិរឧទ្យានរបស់ព្រះបាទកោរព្យ ចុះគង់លើផ្ទាំងសិលាដែលជាមង្គល សម្តែងធម៌ដែលប្រដាប់ហើយដោយសេចក្តីជ្រះថ្លា ៤ ប្រការ ចំពោះព្រះរាជាអ្នកស្តេចមកសួរសុខទុក្ខ ចារិកទៅដោយលំដាប់ ត្រឡប់មកគាល់ព្រះសាស្តាវិញ ។ រឿងនេះតាំងឡើងហើយដោយអាការយ៉ាងនេះ ។ ខាងក្រោយតមក ព្រះសាស្តាប្រថាប់គ្រង់កណ្តាលព្រះអរិយសង្ឃ ទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងជាកំពូលលើពួកកុលបុត្រអ្នកបួសដោយសទ្ធាក្នុងសាសនានេះឯង ។

ចប់អដ្ឋកថា សូត្រទី ២

# អដ្ឋកថាសូត្រទី ៣

## ប្រវត្តិព្រះកុណ្ឌធានត្ថេរះ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៣ ដូចតទៅនេះ ។

[១៤៨] ដោយបទថា **បឋមំសលាកំ គណ្ហន្តានំ** ព្រះសាស្តាទ្រង់សម្តែងថា ព្រះកោណ្ឌធានត្ថេរៈ ជាកំពូលលើពួកភិក្ខុដែលចាប់ស្លាកបានមុនភិក្ខុដទៃ ។

បានឮមកថា ព្រះថេរៈនោះ កាលព្រះតថាគតស្តេចទៅឧគ្គនគរក្នុងថ្ងៃដែលនាងមហាសុភទ្ទានិមន្ត កាលភិក្ខុប្រាប់ថា ថ្ងៃនេះព្រះសាស្តាស្តេចទីងភិក្ខាចារឆ្ងាយ ភិក្ខុបុថុជ្ជនកុំចាប់ស្លាក ព្រះខីណាស្រព ៥០០ រូប ចូរចាប់ , ក៏បន្លឺសីហនាទចាប់ស្លាកបានមុនគេ កាលព្រះតថាគតស្តេចទៅក្រុងសាកេតក្នុងថ្ងៃដែលនាងចូឡសុភទ្ទានិមន្ត ក៏ចាប់ស្លាកបានមុនគេដូចគ្នា ក្នុងចំណោមភិក្ខុ ៥០០ រូប សូម្បីក្នុងគ្រាស្តេចទៅកាន់សុនាបរន្តជនបទ ក៏ដូចគ្នា ដោយហេតុទាំងនេះ ព្រះថេរៈទើបឈ្មោះថា ជាកំពូលលើពួកភិក្ខុដែលចាប់ស្លាកបានមុនគេ មួយទៀតពាក្យថា **កុណ្ឌធាន** ជាឈ្មោះរបស់លោក ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលនឹងពោលតាមលំដាប់ដូចតទៅនេះ ៖

បានឮថា សម័យព្រះបទុមុត្តរសម្ពុទ្ធ ព្រះថេរៈនេះកើតក្នុងត្រកូលគហបតី

នាក្រុងហង្សវតី ទៅវិហារស្តាប់ធម៌ ដោយន័យដូចពោលហើយនុ៎ះឯង ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូបទុកក្នុងតំណែងជាកំពូលលើពួកភិក្ខុ ដែលចាប់ស្លាកបានមុនគេ ទើបធ្វើកុសលកម្មចំពោះព្រះពុទ្ធប្រាថ្នាតំណែងនោះ ព្រះសាស្តាទ្រង់ឃើញថារកអន្តរាយមិនបាន ទើបព្យាករណ៍ លោកបានបំពេញកុសលរហូតអស់ជីវិត វិលវល់នៅក្នុងទេវតា និងមនុស្ស ។ ក្នុងសម័យព្រះកស្សបសម្ពុទ្ធក៏កើតជាភុម្មទេវតា ។

ធម្មតា ព្រះពុទ្ធទ្រង់មានព្រះជន្មាយុវែង មិនបានធ្វើឧបោសថរាល់កន្លះខែទេ ។ គឺ ព្រះវិបស្សីទសពល ក្នុងរវាង ៦ ឆ្នាំ ទើបមានឧបោសថម្តង ចំណែកព្រះកស្សបទសពល ទ្រង់ឲ្យសូត្រព្រះបាតិមោក្ខរាល់ៗ ៦ ខែ ក្នុងថ្ងៃសូត្របាតិ-មោក្ខនោះ ភិក្ខុ ២ រូប អ្នកនៅក្នុងទិស មកដោយតាំងចិត្តថា នឹងធ្វើឧបោសថ ។ ភុម្មទេវតានេះគិតថា ការមានមេត្រីរបស់ភិក្ខុ ២ រូបនេះ មុតមាំណាស់ បើមានអ្នកធ្វើឲ្យបែកគ្នា លោកនឹងបែកគ្នា ឬមិនបែកគ្នាហ្ន៎ ទើបរកឱកាសរបស់ភិក្ខុទាំងពីរនោះ ដើរក្នុងទីជិតៗ ភិក្ខុទាំងពីរនោះ ។ គ្រានោះ ព្រះថេរៈមួយរូបទុកបាត្រនិងចីវរទុកនឹងព្រះថេរៈមួយរូបទៀត ទៅកាន់ទីដែលមានសេចក្តីសុខដោយទឹកដើម្បីលាងជម្រះសរីរៈ លុះលាងដៃលាងជើងហើយ ក៏ចេញមកកាន់ម្លប់ឈើដែលត្រូវចិត្ត ។ ភុម្មទេវតា ក្លែងជាស្ត្រីមានរូបស្អាតនៅខាងក្រោយព្រះថេរៈនោះ

ទើបធ្វើឲ្យមានសក់សើងកន្រ្ទើងហើយរៀបរយសក់ជាថ្មី ធ្វើជាស្លៀកដណ្តប់សំពត់ជាថ្មី ដើរតាមព្រះថេរៈចេញចាកគុម្ពោតព្រៃមកឈរក្នុងទីដ៏សមគួរមួយ , ព្រះថេរៈជាសម្លាញ់ឃើញហេតុការណ៍នេះ ទើបកើតទោមនស្ស គិតថា សេចក្តីស្និទ្ធ-ស្នាលនឹងគ្នាមកអស់វេលាយូរហើយជាមួយភិក្ខុនេះ តែត្រូវមកវិនាសក្នុងឥឡូវនេះ ប្រសិនបើយើងដឹងយ៉ាងនេះ យើងនឹងមិនធ្វើសេចក្តីស្និទ្ធស្នាលជាមួយភិក្ខុនេះ យូរយ៉ាងនេះឡើយ ។ ពេលព្រះថេរៈនោះមកដល់ប៉ុណ្ណោះ ក៏និយាយថា នែ៎! អាវុសោ នេះបាត្រចីវររបស់លោក យើងមិនធ្វើដំណើរជាមួយនឹងសម្លាញ់ដូចជាលោកទេ ។ លុះបានស្តាប់ពាក្យនោះ ហទយៈរបស់ភិក្ខុដែលមានសេចក្តីខ្មាសបាបនោះ ដូចជាត្រូវលំពែងចាក់ហើយ ដូច្នោះ តអំពីនោះ លោកទើបពោលនឹងព្រះថេរៈនោះថា អាវុសោ លោកនិយាយអ្វីយ៉ាងនេះ ខ្ញុំមិនដឹងអាបត្តិសូម្បីត្រឹមតែទុក្កដរហូតមកអស់កាលត្រឹមនេះ លោកនិយាយថា ខ្ញុំជាមនុស្សអាក្រក់ក្នុងថ្ងៃនេះ លោកឃើញអ្វីឬ ? ព្រះថេរៈនោះពោលថា នឹងប្រយោជន៍អ្វីដោយកម្មដទៃដែលយើងឃើញហើយ លោកចេញមកពីក្នុងទីតែមួយជាមួយស្ត្រីដែលតែងខ្លួនយ៉ាងនេះៗ ព្រោះហេតុអ្វី ។ ព្រះថេរៈនោះទើបឆ្លើយថា អាវុសោ កម្មនោះរបស់ខ្ញុំមិនមាន , ខ្ញុំមិនបានឃើញអ្នកស្ត្រីបែបនេះ សូម្បីលោកពោលហើយដល់ ៣ ដង ។ ព្រះថេរៈមួយរូបទៀត ក៏មិនជឿ កាន់យកហេតុដែលខ្លួនឃើញ

ហើយប៉ុណ្ណោះជាសំខាន់ មិនធ្វើដំណើរជាមួយព្រះថេរៈនោះ ទៅគាល់ព្រះសាស្តា ដោយផ្លូវដទៃ ។ សូម្បីភិក្ខុមួយរូបទៀត ក៏ទៅគាល់ព្រះសាស្តាដោយផ្លូវដទៃដូចគ្នា ។

តពីនោះ វេលាភិក្ខុសង្ឃធ្វើឧបោសថ ភិក្ខុនោះចាំភិក្ខុនោះបានក្នុងរោងឧបោសថ ទើបពោលថា ក្នុងរោងឧបោសថនេះ មានភិក្ខុលាមកឈ្មោះនេះ យើងមិនធ្វើឧបោសថរួមជាមួយភិក្ខុនោះ ទើបចេញទៅឈរខាងក្រៅ ។ កុម្មទេវតាគិតថា យើងធ្វើកម្មធ្ងន់ណាស់ ទើបក្លែងជាឧបាសកចាស់ទៅរកភិក្ខុនោះ ពោលថា ហេតុអ្វីលោកម្ចាស់ទើបមកឈរក្នុងទីនេះ ។ ព្រះថេរៈពោលថា ឧបាសក ក៏ភិក្ខុលាមកចូលមកកាន់រោងឧបោសថនេះ អាត្មានឹងមិនធ្វើឧបោសថរួមជាមួយភិក្ខុលាមកនោះ ទើបបានចេញមកឈរខាងក្រៅ ។ ឧបាសកដល់នោះពោលថា លោកម្ចាស់ កុំយល់យ៉ាងនោះឡើយ ភិក្ខុនេះជាអ្នកមានសីលបរិសុទ្ធិ ខ្ញុំ គឺមនុស្សស្រីដែលលោកឃើញនោះ ខ្ញុំនេះឯងឃើញសេចក្តីល្អ សេចក្តីខ្មាសបាប និងសេចក្តីមិនខ្មាសបាប ធ្វើកម្មហើយដោយគិតថា មេត្រីភាពរបស់ព្រះថេរៈនេះ រឹងមាំ ឬមិនរឹងមាំ ក៏សាកល្បងលោកទាំងពីរមើល ភិក្ខុនោះសួរថា សប្បុរស ក៏លោកជាអ្នកណា ឧបាសកចាស់ឆ្លើយថា ខ្ញុំជាកុម្មទេវតា ។ ទេវបុត្រដែលឈរពោលដោយអានុភាពដែលជាទិព្វ បង្អោនចុះទៀបជើងរបស់ព្រះថេរៈ ពោលថា

សូមលោកម្ចាស់អត់ទោសនោះដល់ខ្ញុំ ព្រះថេរៈមិនដឹងរឿង មេត្តាធ្វើឧបោសថចុះ អន្ទងឲ្យព្រះថេរៈចូលទៅកាន់រោងឧបោសថ ព្រះថេរៈនោះក៏ធ្វើឧបោសថក្នុងទីជាមួយគ្នា ហើយក៏នៅក្នុងទីជាមួយគ្នានឹងព្រះថេរៈនោះ ដោយអំណាចនៃការចងមេត្រីម្តងទៀតនោះឯង ។ កម្មរបស់ព្រះថេរៈនេះ លោកមិនបានពោលទុកទេ ចំណែកកិច្ចដែលត្រូវចោទក៏ បំពេញវិបស្សនា.តៗ មក ក៏បានសម្រេចព្រះអរហត្តទៅ ។

កុម្មទេវតាមិនផុតភ័យ ក៏ធ្លាក់ទៅក្នុងអបាយរហូតអស់មួយពុទ្ធន្តរ ព្រោះផលនៃកម្មនោះ មកកើតជាមនុស្សតាមសមគួរដល់កាល ទោសដែលអ្នកដទៃទោះបីជានរណាក៏ដោយធ្វើ ក៏ធ្លាក់ដល់គេប៉ុណ្ណោះ លោកកើតក្នុងត្រកូលព្រាហ្មណ៍ក្នុងក្រុងសាវត្ថី គ្រាព្រះដ៏មានព្រះភាគរបស់យើងឧប្បត្តិ ញាតិរបស់លោកតាំងឈ្មោះលោកថា ធានមាណព , ធានមាណពនោះ ចម្រើនវ័យហើយ រៀនត្រៃវេទ ក្នុងវេលាបានស្តាប់ធម៌របស់ព្រះសាស្តា បានសទ្ធាហើយក៏បួស តាំងពីថ្ងៃដែលលោកបួសហើយ មានស្ត្រីអ្នកតែងខ្លួនម្នាក់ កាលលោកចូលស្រុក ក៏ចូលទៅជាមួយលោក កាលចេញក៏ចេញជាមួយ សូម្បីកាលចូលវិហារក៏ចូលជាមួយ សូម្បីកាលឈរក៏ឈរជាមួយ ដូច្នោះ រមែងប្រាកដថា តាមជាប់ជានិច្ចយ៉ាងនេះ ព្រះថេរៈក៏មិនឃើញ តែដោយផលនៃកម្មចាស់របស់ព្រះថេរៈនោះ ស្ត្រីនោះទើប

ប្រាកដដល់អ្នកដទៃៗ ស្ត្រីទាំងឡាយដែលថ្វាយបបរបាយ និងភិក្ខុក្នុងស្រុក ក៏បានចំអកថា លោកម្ចាស់ បបរបាយ មួយវែកនេះសម្រាប់លោកម្ចាស់ មួយវែកទៀតនេះសម្រាប់មិត្តស្រីរបស់លោកម្ចាស់ ព្រះថេរៈ ទើបមានសេចក្តីក្តៅក្រហាយទាស់ចិត្តយ៉ាងខ្លាំង សាមណេរ និងភិក្ខុកម្លោះ ដែលនៅជុំវិញលោកសូម្បីទៅកាន់វិហារ ក៏បានសើចចំអកថា ព្រះធានៈជាមនុស្សអាក្រក់ ។ (**ធានោ កោណ្ឌោ ជាតោ**) ។

ខាងក្រោយមក លោកមានឈ្មោះថា **កោណ្ឌធានត្ថេរៈ** ព្រោះហេតុនោះឯង ព្រះថេរៈព្យាយាមហើយព្យាយាមទៀត កាលមិនអាចអត់ទ្រាំនឹងការចំអកដែលពួកសាមណេរ និងភិក្ខុនោះបាន ក៏កើតសេចក្តីអន្ទះអន្ទែងឡើង ពោលថា ឧបជ្ឈាយ៍របស់លោកឯងអាក្រក់ អាចារ្យរបស់លោកឯងអាក្រក់ គ្រានោះភិក្ខុទាំងឡាយទើបក្រាបទូលរឿងនោះចំពោះព្រះសាស្តាថា ព្រះកុណ្ឌធានៈ ពោលពាក្យអាក្រក់យ៉ាងនេះៗ ជាមួយភិក្ខុកម្លោះ និងសាមណេរទាំងឡាយ ព្រះសាស្តាឲ្យហៅភិក្ខុនោះមក ត្រាស់សួរថា "ពិតឬ ភិក្ខុ" កាលទូលថា ពិតមែនព្រះអង្គព្រះដ៏មានព្រះភាគត្រាស់ថា ហេតុអ្វី អ្នកទើបពោលយ៉ាងនោះ ព្រះថេរៈទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គក៏មិនអាចអត់ទ្រាំនឹងពាក្យស៊កសៀតជាប្រចាំទើបពោលយ៉ាងនោះ ព្រះសាស្តាត្រាស់ថា ខ្លួនអ្នកមិនអាចញ៉ាំងកម្មដែលធ្វើទុក

ក្នុងកាលមុនឲ្យអស់ទៅដរាបដល់សព្វថ្ងៃនេះ តទៅនេះ អ្នកកុំពោលពាក្យអាក្រក់បែបនោះទៀត ដូច្នេះ ទើបត្រាស់ថា ៖

មាវោច ផរុសំ កញ្ចិ វុត្តា បដិវទេយ្យុ តំ
ទុក្ខា ហិ សារម្ភកថា បដិទណ្ឌា ផុសេយ្យុ តំ
សចេ ន ទេសិ អត្តានំ កំសោ ឧបហតោ យថា
ឯស បត្តោសិ និព្វានំ សារម្ភោតេ ន វិជ្ជតីតិ

អ្នកកុំពោលពាក្យអាក្រក់ចំពោះនរណាៗ បុគ្គលដែលអ្នកពោលហើយ ក៏នឹងធ្លាក់មករកអ្នក ព្រោះថា ពាក្យប្រណាំងប្រជែងគ្នានាំទុក្ខមកឲ្យដល់ដែលអ្នកធ្វើតប ក៏គប្បីប្រសព្វទុក្ខនោះ អ្នកមិនគប្បីធ្វើខ្លួនឲ្យញាប់ញ័រ ដូចឥន្ទធនូត្រូវលោស់ចេញហើយ អ្នកក៏នឹងជាបុគ្គលដល់ព្រះនិព្វាន ការប្រណាំងប្រជែង ក៏នឹងមិនមានដល់អ្នក ដូច្នេះ ។

ក៏បុគ្គលទាំងឡាយ ក្រាបទូលសេចក្តីដែលព្រះថេរៈនោះត្រាច់ទៅជាមួយមាតុគ្រាមនេះ ចំពោះព្រះបាទកោសល ព្រះរាជាបញ្ជូនអាមាត្រទៅថា អ្នកចូរទៅស៊ើបមើល សូម្បីព្រះអង្គឯងក៏ស្តេចទៅកាន់ទីនៅរបស់ព្រះថេរៈនោះ ព្រមទាំងរាជបរិវារជាច្រើន ប្រថាប់ឈរក្នុងទីសមគួរម្ខាង ខណៈនោះព្រះថេរៈកំពុងគង់

ដេរសំពត់ សូម្បីស្ត្រីនោះ ក៏ប្រាកដដូចឈរក្នុងទីជិតព្រះថេរៈនោះ ព្រះរាជា ឃើញហើយ ទ្រង់ត្រិះរិះថា មានហេតុដូច្នេះឬ ទើបស្តេចទៅកាន់ទីដែលស្ត្រីនោះ ឈរហើយ កាលព្រះរាជាទៅដល់ ស្ត្រីនោះក៏ដូចជាចូលទៅកាន់បណ្ណសាលា ដែលជាទីនៅរបស់ព្រះថេរៈ ព្រះរាជាក៏ស្តេចចូលទៅបណ្ណសាលព្រមជាមួយស្ត្រី នោះឯង រកមើលគ្រប់កន្លែងក៏មិនឃើញ ទើបធ្វើសេចក្តីយល់ព្រះទ័យថា នេះ មិនមែនមាតុគ្រាម ជាវិបាកនៃកម្មណាមួយរបស់ព្រះថេរៈ ដំបូងសូម្បីមកដល់ ជិតព្រះថេរៈ ក៏ទ្រង់មិនសំពះព្រះថេរៈ លុះទ្រង់ជ្រាបថា ហេតុនោះមិនពិត ទើប ស្តេចមកសំពះព្រះថេរៈ ប្រថាប់អង្គុយក្នុងទីសមគួរមួយ ត្រាស់សួរថា លោក ម្ចាស់ មិនលំបាកដោយបិណ្ឌបាតខ្លះទេឬ ព្រះថេរៈទូលថា ប្រព្រឹត្តទៅបាន សូម ថ្វាយព្រះពរ ព្រះរាជាត្រាស់ថា លោកម្ចាស់ដ៏ចម្រើន ញោមដឹងរឿងរ៉ាវរបស់ លោកម្ចាស់ហើយ កាលលោកម្ចាស់ត្រាច់ទៅជាមួយវត្ថុដែលធ្វើឲ្យសៅហ្មងបែប នេះ ឈ្មោះថា នរណាហ្ន៎ នឹងជ្រះថ្លា , ចាប់ពីពេលនេះទៅ លោកម្ចាស់មិន ចាំបាច់ទៅក្នុងទីណាៗ ញោមនឹងទំនុកបម្រុងដោយបច្ច័យ ៤ លោកម្ចាស់កុំប្រមាទ ក្នុងយោនិសោមនសិការឡើយ ហើយបញ្ជូនកិក្ខាទៅប្រគេនជាប្រចាំ ព្រះថេរៈ បានព្រះរាជូបត្ថម្ភ ជាអ្នកមានចិត្តមានអារម្មណ៍តែមួយ ព្រោះមានភោជនសប្បាយ ចម្រើនវិបស្សនា ក៏សម្រេចព្រះអរហត្តផលទៅ ។ តាំងពីនោះមក ស្ត្រីនោះក៏

វិនាសបាត់ទៅ ។

នាងមហាសុភទ្ទា នៅក្នុងត្រកូលមិច្ឆាទិដ្ឋិក្នុងឧគ្គនគរ គិតថា ព្រះសាស្តា ចូរទ្រង់អនុគ្រោះយើង ទើបអធិដ្ឋានឧបោសថ ជាបុគ្គលមិនមានក្លិនឆ្អាប នៅប្រាសាទជាន់លើ ធ្វើសច្ចកិរិយាថា ផ្កាទាំងនេះ ចូរកុំនៅក្នុងរវាងផ្លូវឡើយ ចូរសម្រេចជាពិតានការពារក្នុងខាងលើនៃព្រះទសពលចុះ សូមព្រះទសពលមេត្តាអនុគ្រោះទទួលភិក្ខារបស់នាងខ្ញុំព្រមទាំងភិក្ខុ ៥០០ រូប ដោយសញ្ញានេះចុះ ហើយបោះផ្កាឈើ ៨ ក្តាប់ទៅ ផ្កាឈើក៏ទៅ ជាពិតានការពារនៅខាងលើព្រះសាស្តាក្នុងវេលាសម្តែងធម៌ ព្រះសាស្តាទតឃើញពិតានផ្កាម្លិះនោះ ទ្រង់ក៏បានទទួលភិក្ខារបស់នាងសុភទ្ទាដោយចិត្តនោះឯង ។ ថ្ងៃស្អែក កាលអរុណរះ ទើបត្រាស់បង្គាប់ព្រះអានន្ទថា អានន្ទ ថ្ងៃនេះតថាគតនឹងទៅភិក្ខាចារក្នុងដែលឆ្ងាយ ចូរកុំឲ្យស្លាកដល់ភិក្ខុជាបុថុជ្ជន ចូរឲ្យដល់ព្រះអរិយៈប៉ុណ្ណោះ ព្រះថេរៈប្រាប់ដល់ភិក្ខុទាំងឡាយថា អ្នកមានអាយុ ថ្ងៃនេះព្រះសាស្តា ស្តេចភិក្ខាចារក្នុងទីឆ្ងាយ ភិក្ខុជាបុថុជ្ជនចូរកុំចាប់ស្លាក ព្រះអរិយៈប៉ុណ្ណោះចូរចាប់ ព្រះកោណ្ឌញ្ញត្ថេរៈពោលថា អ្នកមានអាយុ ចូរនាំស្លាកមក ហើយលូកដៃចេញទៅ ព្រះអានន្ទត្ថេរៈពោលថា ព្រះសាស្តាមិនឲ្យប្រទានស្លាកដល់ភិក្ខុដូចជាលោកទេ ត្រាស់ឲ្យប្រទានចំពោះភិក្ខុដែលជាអរិយៈប៉ុណ្ណោះ ហើយវិតក្កក៏កើតឡើង ទៅក្រាបទូលព្រះសាស្តា

ព្រះសាស្តាត្រាស់ថា អ្នកចូរឲ្យស្លាកដល់ភិក្ខុ ដែលប្រាប់ឲ្យនាំស្លាកមកនោះចុះ ព្រះថេរៈទើបគិតថា ប្រសិនបើមិនឲ្យស្លាកដល់ព្រះកុណ្ឌធានៈ ព្រះសាស្តាក៏នឹងហាមយើង មុខជាមានហេតុណាមួយជាប្រាកដ ទើបប្រញាប់នាំមក ដោយគិតថា នឹងឲ្យស្លាកដល់ព្រះកុណ្ឌធានៈ ព្រះកុណ្ឌធានត្ថេរ មុនពេលព្រះអានន្ទត្ថេរមក ចូលចតុត្ថជ្ឈានដែលជាបាទនៃអភិញ្ញា ឈរក្នុងអាកាសដោយឫទ្ធិ ពោលថា លោកម្ចាស់អានន្ទ ចូរនាំស្លាកមក ព្រះសាស្តាទ្រង់ជ្រាបដល់ខ្ញុំ ព្រះសាស្តាមិនត្រាស់ហាមភិក្ខុដូចខ្ញុំដែលជាអ្នកចាប់ស្លាកបានមុន ហើយលូកដៃទៅចាប់ស្លាក ។ ព្រះសាស្តាទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុ ទើបទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងដ៏កំពូលលើពួកភិក្ខុ អ្នកចាប់ស្លាកបានមុនគេ ក្នុងសាសនានេះឯង ។

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថាសូត្រទី ៤

## ប្រវត្តិព្រះវង្គីសត្ថេរៈ

*គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៤ ដូចតទៅនេះ ៖*

*[១៤៨] ដោយបទថា **បដិភាណវន្តានំ** ព្រះដ៏មានព្រះភាគទ្រង់សម្តែងថា **ព្រះវង្គីសត្ថេរ** ជាកំពូលលើពួកភិក្ខុដែលសម្បូរណ៍ដោយបដិភាណ បានឮថា ព្រះថេរៈនេះ កាលចូលទៅគាល់ព្រះទសពលតាំងពីបានឃើញ ក៏ពោលសរសើរគុណព្រះសាស្តា ឧបមាដូចជាព្រះច័ន្ទ ឧបមាដូចជាព្រះអាទិត្យ ដូចជាអាកាស មហាសមុទ្រ ស្តេចដំរី ស្តេចសីហៈ ច្រើនរយច្រើនពាន់បទ ទើបចូលគាល់ ព្រោះដូច្នោះ លោកទើបជាកំពូលលើពួកភិក្ខុដែលមានបដិភាណ ។ ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលនឹងពោលតាមលំដាប់ដូចតទៅនេះ ៖*

*បានឮថា គ្រាព្រះពុទ្ធព្រះនាមថា **បទុមុត្តរ** ព្រះថេរៈរូបនេះ បានបដិសន្ធិក្នុងត្រកូលដែលមានភោគសម្បត្តិច្រើន ក្នុងក្រុងហង្សវតី ទៅវិហារស្តាប់ធម៌ ដូចន័យមុននុ៎ះឯង ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូបទុកក្នុងតំណែងដ៏កំពូលលើពួកភិក្ខុដែលមានបដិភាណ ទើបធ្វើកុសលកម្មចំពោះព្រះសាស្តា ធ្វើសេចក្តីប្រាថ្នាថា ក្នុងអនាគតកាលសូមខ្ញុំព្រះអង្គគប្បីជាកំពូលលើពួកភិក្ខុមានបដិភាណ*

លើពួកភិក្ខុដែលមានបដិភាណ លោកត្រូវបានព្រះសាស្តាទ្រង់ព្យាករណ៍ហើយ ធ្វើកុសលរហូតអស់ជីវិត វិលវល់នៅក្នុងទេវតា និងមនុស្ស ក្នុងពុទ្ធុប្បាទកាលនេះ ក៏មកកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី ញាតិទាំងឡាយដាក់នាមថា **វង្គីសមាណព** ។ លោកចម្រើនវ័យហើយ រៀនត្រៃវេទ ធ្វើឲ្យអាចារ្យពេញចិត្ត សិក្សាមន្តឈ្មោះថា **ឆវសីសមន្ត** មន្តដឹងសិរសៈមនុស្ស យកក្រចកគោះក្បាលខ្មោចហើយក៏ដឹងថា សត្វនេះកើតក្នុងកំណើតឯណោះៗ ព្រាហ្មណ៍ទាំងឡាយជ្រាបថា មន្តនេះជាផ្លូវសម្រាប់យើងចិញ្ចឹមជីវិត ទើបឲ្យវង្គីសមាណពអង្គុយក្នុងរថដែលបិទបាំងហើយ ទៅកាន់គាមនិគម និងរាជធានីទាំងឡាយ ឈប់ត្រង់ទ្វារក្រុង ឬទ្វារនិគម ជ្រាបថា មហាជនមកប្រជុំគ្នាហើយ ក៏និយាយថា នរណាឃើញវង្គីសៈ អ្នកនោះនឹងបានទ្រព្យ ឬបានយស ឬបានទៅសួគ៌ ដូច្នេះ ជនជាច្រើនស្តាប់ពាក្យរបស់ព្រាហ្មណ៍ទាំងនោះហើយ ឲ្យថ្លៃឈ្នួលដើម្បីត្រូវការនឹងមើលព្រះរាជា និងអាមាត្យរបស់ព្រះរាជា ទៅកាន់សំណាក់របស់ព្រាហ្មណ៍ទាំងនោះសួរថា គុណវិសេស គឺ ការដឹងរបស់អាចារ្យយ៉ាងណា លោកទាំងឡាយមិនដឹងឬ ឈ្មោះថា បណ្ឌិតដទៃដែលនឹងដូចជាអាចារ្យរបស់ពួកយើងមិនមានក្នុងជម្ពូទ្វីបទាំងអស់ ឲ្យបុគ្គលនាំសិរសៈរបស់អ្នកស្លាប់ទៅហើយ ៣ ឆ្នាំ យកក្រចកគោះ ក៏ដឹងថា សត្វនេះទៅកើតក្នុងទីឯណោះ ចំណែកវង្គីសៈដើម្បីនឹងកាត់សេចក្តី

សង្ស័យរបស់មហាជន ទើបឲ្យនាំជនទាំងនោះមក ហើយឲ្យប្រាប់គតិរៀងៗ ខ្លួន អាស្រ័យហេតុនោះ បានទ្រព្យពីដៃរបស់មហាជនមួយរយខ្លះ មួយពាន់ខ្លះ ។

ពួកព្រាហ្មណ៍ នាំវង្គីសមាណពត្រាច់ទៅតាមសេចក្ដីពេញចិត្ត ហើយក៏មកដល់ក្រុងសាវត្ថីទៀត វង្គីសៈនៅក្នុងទីមិនឆ្ងាយពីជេតវនមហាវិហារ គិតថា អ្នកទាំងឡាយនិយាយគ្នាថា ព្រះសមណៈគោតមជាបណ្ឌិត ក៏ប៉ុន្តែថា យើងទេគួរនឹងត្រាច់ទៅធ្វើតាមពាក្យរបស់ព្រាហ្មណ៍ទាំងនេះតែម្យ៉ាងគ្រប់វេលា យើងគួរទៅសំណាក់របស់បណ្ឌិតទាំងឡាយខ្លះ វង្គីសមាណពនោះ ពោលនឹងព្រាហ្មណ៍ទាំងឡាយថា លោកទាំងឡាយចូរទៅចុះ យើងនឹងមិនទៅគាល់ព្រះសមណៈគោតមជាមួយមនុស្សច្រើនទេ ព្រាហ្មណ៍ទាំងនោះប្រាប់ថា វង្គីសៈលោកកុំពេញចិត្តគាល់ព្រះសមណៈគោតមឡើយ ព្រោះនរណាឃើញព្រះសមណៈនោះ ព្រះសមណៈនោះ ក៏នឹងត្រឡប់ចិត្តបុគ្គលនោះដោយកលមាយា វង្គីសៈមិនជឿតាមពាក្យរបស់ព្រាហ្មណ៍ទាំងនោះ ទៅគាល់ព្រះសាស្ដា ធ្វើបដិសណ្ឋារៈដោយពាក្យដ៏ពីរោះ អង្គុយក្នុងទីសមគួរមួយ ។

គ្រានោះព្រះសាស្ដាសួរគេថា វង្គីសៈ លោកចេះសិល្បៈអ្វី វង្គីសៈទូលតបថា ព្រះអង្គ ខ្ញុំព្រះអង្គចេះឆវសីសមន្ត ព្រះសាស្ដាត្រាស់សួរថា មន្តនោះធ្វើអ្វី វង្គីសៈទូលថា រាយមន្តនោះហើយ យកក្រចកគោះសិរសៈរបស់អ្នកស្លាប់

ទៅសូម្បី ៣ ឆ្នាំ ក៏ដឹងទីកន្លែងគេកើត ព្រះអង្គ ព្រះសាស្ដាទ្រង់យកសិរសៈ របស់អ្នកដែលកើតក្នុងនរកមួយ សីរសៈរបស់អ្នកកើតក្នុងមនុស្សមួយ សីរសៈ របស់អ្នកកើតក្នុងទេវលោកមួយ សិរសៈរបស់អ្នកបរិនិព្វានហើយមួយ ឲ្យដល់ វង្គីសៈ វង្គីសៈនោះគោះសិរសៈដំបូង ក្រាបទូលថា ព្រះគោតម សត្វនេះទៅកាន់ នរក ព្រះសាស្ដាត្រាស់ឆ្លើយថា សាធុ សាធុ អ្នកឃើញត្រូវហើយ ហើយត្រាស់ សួរថា សត្វនេះទៅណា វង្គីសៈ ទៅកាន់មនុស្សលោក ព្រះគោតម , សត្វនេះ ទៅណា វង្គីសៈទូលថា សត្វនេះទៅទេវលោក ព្រះអង្គ គេក្រាបទូលដល់ទីកន្លែង ទៅរបស់អ្នកទាំង ៣ ពួក ដោយប្រការដូច្នេះ តែកាលយកក្រចកគោះសិរសៈ របស់លោកដែលបរិនិព្វានហើយ ក៏មិនឃើញ ទាំងខាងចុងទាំងខាងដើម ។ ពេល នោះព្រះសាស្ដាទើបត្រាស់សួរវង្គីសៈនោះថា អ្នកមិនបានឃើញទេឬ វង្គីសៈ ! វង្គីសមាណពទូលថា មិនឃើញទេ ព្រះគោតម ខ្ញុំព្រះអង្គបញ្ជូនមន្តត្រឡប់ទៅ ត្រឡប់មកហើយ វង្គីសៈ! អ្នកនឹងដឹងគតិរបស់ព្រះខីណាស្រពដោយមន្តរបស់ លទ្ធិខាងក្រៅបានដូចម្ដេច កាលនោះ ញើសក៏ហូរចេញពីមុខរបស់គេ គេមាន ការអៀនខ្មាសហើយឈរស្ងៀម គ្រានោះព្រះសាស្ដាត្រាស់ចំពោះគេថា លំបាកឬ វង្គីសៈ! វង្គីសៈទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនដឹងទីទៅរបស់សត្វនេះ បើព្រះអង្គជ្រាបសូមត្រាស់ប្រាប់ចុះ ព្រះសាស្ដាត្រាស់ថា វង្គីសៈ តថាគតដឹង

សីរសៈនេះ សូម្បីក្រលែងជាងនេះក៏ដឹង ដូច្នេះ ហើយបានភាសិតព្រះគាថា ២ គាថា នេះ ក្នុងព្រះធម្មបទថា

ចុតឹ យោ វេទិ សត្តានំ ឧបបត្តឹ ច សព្វសោ
អសត្តំ សុគតំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ
យស្ស គតឹ ន ជានន្តិ ទេវា គន្ធព្វមានុសា
ខីណាសវំ អរហន្តំ តមហំ ព្រូមិ ព្រាហ្មណន្តិ ។

នរណាដឹងចុតិ និងឧបបត្តិ របស់សត្វទាំងឡាយដោយប្រការទាំងពួង តថាគតហៅអ្នកនោះ ដែលមិនមានការជាប់ជំពាក់ ទៅល្អហើយ ដឹងហើយថាជាព្រាហ្មណ៍ ។

ទេព គន្ធព្វ និងមនុស្ស មិនជ្រាបគតិរបស់បុគ្គលណា តថាគតហៅអ្នកនោះដែលមានអាសវៈអស់ហើយ ជាព្រះអរហន្ត ថាជាព្រាហ្មណ៍ដូច្នេះ ។

បន្ទាប់ពីនោះ វង្គីសៈទូលថា ព្រះគោតម អ្នកចែករំលែកវិជ្ជាជាមួយវិជ្ជា រមែងមិនមានសេចក្តីសាបសូន្យ ខ្ញុំព្រះអង្គនឹងថ្វាយមន្តដែលខ្ញុំព្រះអង្គចេះចំពោះព្រះអង្គ ព្រះអង្គមេត្តាត្រាស់ប្រាប់មន្តនោះដល់ខ្ញុំព្រះអង្គ ព្រះសាស្តាត្រាស់ថា វង្គីសៈ តថាគតមិនមែនជាអ្នកដូរមន្តដោយមន្ត តថាគតនឹងឲ្យតែប៉ុណ្ណោះ ។ វង្គីសៈទូលថា ប្រពៃណាស់ព្រះគោតម សូមមេត្តាប្រទានដល់ខ្ញុំព្រះអង្គចុះ ហើយ

សម្តែងការនមស្ការអន្តុយធ្វើដៃប្រណម្យ ព្រះសាស្តាត្រាស់ថា វង្គីសៈ កាលសម័យអ្នករៀនមន្តដែលមានតម្លៃច្រើន ឬមន្តអ្វីៗ មិនត្រូវមានការនៅអប់រំទេឬ វង្គីសៈ មិនមានទេព្រះគោតម ព្រះសាស្តាត្រាស់ថា អ្នកនឹងសម្គាល់ថា មន្តរបស់តថាគតមិនមានការអប់រំឬ ដែលឈ្មោះថា ព្រាហ្មណ៍ទាំងឡាយ រមែងជាអ្នកមិនឆ្អែតដោយមន្ត ព្រោះដូច្នោះ វង្គីសៈនោះទើបក្រាបទូលព្រះដ៏មានព្រះភាគថា ព្រះគោតម ខ្ញុំព្រះអង្គក៏នឹងធ្វើតាមការកំណត់ដែលព្រះអង្គត្រាស់ទុក ព្រះសាស្តាត្រាស់ថា វង្គីសៈ តថាគតកាលនឹងឲ្យមន្តនេះ រមែងឲ្យដល់អ្នកដែលមានភេទស្មើគ្នានឹងតថាគត វង្គីសៈពោលនឹងព្រាហ្មណ៍ទាំងឡាយថា ខ្ញុំគួរធ្វើកិច្ចយ៉ាងណាមួយ ហើយទៅរៀនមន្តនេះ វង្គីសៈពោលថា លោកទាំងឡាយ កាលខ្ញុំបួសហើយ ក៏កុំគិតឡើយ ខ្ញុំរៀនមន្តហើយនឹងជាអ្នកធំក្រៃលែងទូទៅក្នុងជម្ពូទ្វីប បើដូច្នោះ សូម្បីលោកទាំងឡាយក៏នឹងមានសេចក្តីចម្រើនដែរ ទើបបួសក្នុងសំណាក់ព្រះសាស្តាដើម្បីរៀនមន្ត ។

ព្រះសាស្តាត្រាស់ថា អ្នកចូរនៅអប់រំដើម្បីរៀនមន្តមុន ហើយត្រាស់ប្រាប់អាការ ៣២ សត្វដែលមានបញ្ញា កាលស្វាធ្យាយអាការ ៣២ ហើយ ក៏ផ្តើមតាំងការអស់ទៅ និងសាបសូន្យទៅក្នុងអាការ ៣២ នោះ ចម្រើនវិបស្សនាក៏បានសម្រេចព្រះអរហត្ត កាលលោកសម្រេចព្រះអរហត្តហើយ ពួកព្រាហ្មណ៍

ទាំងឡាយក្នុងសំណាក់របស់លោកគិតថា វង្គីសៈនឹងជាយ៉ាងណាហ្ន៎ យើងនឹងទៅសួរសុខទុក្ខលោក សួរថា វង្គីសៈ លោករៀនសិល្បៈក្នុងសំណាក់ព្រះសមណគោតមហើយឬ ។ ព្រះវង្គីសៈតបថា យើងរៀនហើយ ។ បើដូច្នោះ មកយើងនឹងទៅវិញ ។ ព្រះវង្គីសៈតបថា លោកចូរទៅចុះ កិច្ចដែលនឹងទៅជាមួយលោក យើងធ្វើស្រេចហើយ ព្រាហ្មណ៍ទាំងឡាយពោលថា ពួកយើងប្រាប់លោកទុកមុនហើយថា ព្រះសមណៈគោតម នឹងធ្វើអ្នកដែលមករកខ្លួនឲ្យត្រឡប់ចិត្តដោយកលមាយា ឥឡូវនេះ លោកនៅក្នុងអំណាចរបស់ព្រះសមណៈគោតមហើយ ពួកយើងនឹងធ្វើអ្វីក្នុងសំណាក់របស់លោក ហើយក៏នាំគ្នាចៀសចេញទៅតាមផ្លូវដែលមកនោះឯង ចំណែកព្រះវង្គីសត្ថេរៈទៅគាល់ព្រះទសពលវេលាណាៗក៏ធ្វើសេចក្តីសរសើរតែម្យ៉ាងក្នុងវេលានោះៗ ព្រោះហេតុនោះ ព្រះសាស្តាប្រថាប់ត្រង់កណ្តាលព្រះសង្ឃ ទ្រង់ស្ថាបនាលោកទុកក្នុងតំណែងជាកំពូលលើពួកភិក្ខុដែលមានបដិភាណ ។

ចប់អដ្ឋកថា សូត្រទី ៤

# អដ្ឋកថាសូត្រទី ៥

## ប្រវត្តិព្រះឧបសេនវង្គន្តបុត្តត្ថេរ

ក្នុងសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖

[១៤៨] បទថា *សមន្តប្បាសាទិកានំ* បានដល់ អ្នកនាំសេចក្តីជ្រះថ្លាមក ដល់ជនទាំងពួង ។ ពាក្យថា **ឧបសេន** ជាឈ្មោះរបស់ព្រះថេរៈនោះ ។ ក៏ព្រះថេរៈនោះ ជាបុត្រវង្គន្តព្រាហ្មណ៍ ដូច្នោះទើបហៅថា វង្គន្តបុត្រ ។ ក៏ព្រះថេរៈនេះ មិនមែនជាអ្នកនាំសេចក្តីជ្រះថ្លាមកដោយខ្លួនឯងតែម្យ៉ាងប៉ុណ្ណោះ សូម្បីបរិស័ទរបស់លោក ក៏ជាអ្នកនាំសេចក្តីជ្រះថ្លាមក ដូច្នោះ លោកទើបឈ្មោះថា ជាកំពូលលើភិក្ខុដែលនាំសេចក្តីជ្រះថ្លាមកដោយជុំវិញ ដោយអំណាចនៃឈ្មោះ ដែលបានព្រោះអាស្រ័យបរិស័ទ ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលនឹងពោលតាមលំដាប់តទៅនេះ ៖

ក៏ព្រះថេរៈនេះ កើតក្នុងត្រកូលក្នុងនគរហង្សវតី ក្នុងកាលនៃព្រះបទុមុត្តរសម្ពុទ្ធ ចម្រើនវ័យហើយទៅគាល់ព្រះសាស្តា ស្តាប់ព្រះធម៌ ដោយន័យមុនទុំះឯង ឃើញព្រះសាស្តាទ្រង់តាំងភិក្ខុមួយរូបក្នុងតំណែងកំពូលលើភិក្ខុដែលនាំសេចក្តីជ្រះថ្លាមកដោយជុំវិញ ធ្វើកុសលធម៌ក្រៃលែងឡើងៗ ចំពោះព្រះសាស្តា

ប្រាថ្នាតំណែងនោះ ធ្វើកុសលរហូតអស់ជីវិត វិលវល់នៅក្នុងទេវតា និងមនុស្ស ទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនេះ បានបដិសន្ធិក្នុងគភ៌របស់នាងសារីព្រាហ្មណី ពួកញាតិតាំងឈ្មោះឲ្យលោកថា **ឧបសេនទារក** ។ ឧបសេនទារកចម្រើនវ័យ ហើយ រៀនត្រៃវេទ ស្តាប់ព្រះធម៌ក្នុងសំណាក់របស់ព្រះទសពល បានសទ្ធាក៏ បួស ។ លោកឧបសម្បទបានតែមួយវស្សា គិតថា យើងនឹងពង្រីកអាណាចក្រ ព្រះអរិយៈ ទើបឲ្យកុលបុត្រម្នាក់បព្វជ្ជាឧបសម្បទក្នុងសំណាក់របស់ខ្លួន ។ លុះ បវារណាចេញវស្សាហើយ ក្នុងវេលាដែលសទ្ធិវិហារិកមានវស្សាមួយ ខ្លួនឯង ពីរវស្សា លោកគិតថា ព្រះទសពលទ្រង់ឃើញយើងហើយនឹងត្រេកអរ ទើប នាំសទ្ធិវិហារិកមកគាល់ព្រះទសពល ។ ព្រះសាស្តាត្រាស់សួរលោកដែលថ្វាយ បង្គំហើយអង្គុយក្នុងទីមួយកន្លែងថា "អ្នកមានវស្សាប៉ុន្មាន ភិក្ខុ" "ពីរវស្សា ព្រះអង្គ" "ភិក្ខុនេះមានវស្សាប៉ុន្មាន" "មួយវស្សា ព្រះអង្គ" "ភិក្ខុនេះជាអ្វីរបស់ លោក" "ជាសទ្ធិវិហារិករបស់ខ្ញុំព្រះអង្គ ព្រះអង្គ" ។

គ្រានោះ ព្រះសាស្តាត្រាស់ថា ចេញទៅមោឃបុរស អ្នកវិលមកដើម្បី សេចក្តីប្រាថ្នាច្រើន ហើយទ្រង់តិះដៀលលោកដោយអនេកបរិយាយ ។ ព្រះថេរៈ ត្រូវតិះដៀលពីសំណាក់ព្រះសាស្តា ថ្វាយបង្គំព្រះដ៏មានព្រះភាគ លោកមានទឹក មុខថ្លាផូរផង់ដូចព្រះចន្ទក្នុងថ្ងៃពេញបូណ៌មី គិតថា យើងនឹងឲ្យព្រះសាស្តាប្រទាន

សាធុការ ព្រោះអាស្រ័យបរិស័ទនេះឯង ដូច្នេះហើយ ទៅកាន់ទីកន្លែងមួយក្នុងថ្ងៃនោះឯង ចម្រើនវិបស្សនាកម្មដ្ឋាន មិនយូរក៏បានសម្រេចព្រះអរហត្ត ។

លំដាប់នោះ ព្រោះព្រះថេរៈចេញបួសពីត្រកូលធំ និងជាព្រះធម្មកថិកដ៏ឆ្លាតក្នុងការពោលទូន្មាន ដូច្នោះ ទើបមានទារករបស់ត្រកូលជាចំនួនច្រើនជ្រះថ្លាក្នុងធម្មកថារបស់លោក និងចេញចាកត្រកូលមិត្តអាមាត្រ និងញាតិអ្នកធំនាំគ្នាទៅបព្វជ្ជាកាន់សំណាក់របស់ព្រះថេរៈ ។ លោកពោលថា យើងជាអ្នកនៅព្រៃជាវត្ត សូម្បីពួកលោកក៏ជាអ្នកនៅព្រៃជាវត្ត បព្វជ្ជាចុះ ដូច្នេះ ហើយប្រាប់ធុតង្គ ១៣ ។ ឲ្យគេទាំងនោះអធិដ្ឋានធុតង្គនោះៗ តាមកម្លាំងរបស់ខ្លួន ។ សូម្បីព្រះថេរៈ ក្នុងវេលាដែលខ្លួនមានវស្សា ១០ សិក្សាវិន័យស្ទាត់ជំនាញហើយ ឲ្យសាមណេរទាំងអស់ឧបសម្បទ ។ ភិក្ខុប្រមាណ ៥០០ រូប ដែលឧបសម្បទហើយ បានជាបរិវាររបស់លោក ដោយប្រការដូច្នេះ ។

សម័យនោះ ព្រះសាស្ដាប្រថាប់នៅក្នុងព្រះជេតវនមហាវិហារ ត្រាស់ប្រាប់ភិក្ខុសង្ឃថា ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នានឹងសម្ងំនៅកន្លះខែ ហើយប្រថាប់នៅតែមួយព្រះអង្គ ។ សូម្បីភិក្ខុសង្ឃក៏បានធ្វើកតិកាគ្នាថា អង្គណាចូលទៅគាល់ព្រះដ៏មានព្រះភាគ ត្រូវឲ្យអង្គនោះសម្ដែងអាបត្តិបាចិត្តិយ ។ គ្រានោះព្រះឧបសេនត្ថេរគិតថា នឹងគាល់ព្រះដ៏មានព្រះភាគ ទើបព្រមជាមួយនឹងបរិស័ទ

របស់ខ្លួនទៅព្រះវិហារជេតវន ចូលគាល់ព្រះសាស្តា ថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរមួយ ។ ដើម្បីផ្តើមការសន្ទនា ព្រះសាស្តាត្រាស់ហៅសទ្ធិវិហារិករបស់ព្រះថេរៈមួយរូបថា ភិក្ខុ អ្នកពេញចិត្តបង្សុកូលចីវរឬ ។ សទ្ធិវិហារិករូបនោះក្រាបទូលថា ខ្ញុំព្រះអង្គមិនពេញចិត្តបង្សុកូលចីវរឡើយ ព្រះអង្គ ហើយក្រាបទូលចំពោះព្រះសាស្តាដល់រឿងដែលពួកខ្លួនត្រូវបង្សុកូលចីវរ ក៏ដោយសេចក្តីគោរពព្រះឧបជ្ឈាយ៍ ។ ក្នុងឋានៈនេះ ព្រះសាស្តាបានប្រទានសាធុការដល់ព្រះថេរៈថា សាធុ សាធុ ឧបសេនៈ ហើយត្រាស់កថា ពណ៌នាគុណដោយអនេកបរិយាយ ។ សេចក្តីសង្ខេបក្នុងរឿងនេះ ដូច្នេះ ។ តែសេចក្តីពិស្តារ រឿងនេះមកហើយក្នុងព្រះបាលីនុ៎ះឯង ។

ក្នុងកាលតមក ព្រះសាស្តាប្រថាប់កណ្តាលពួកព្រះអរិយៈ ទ្រង់តាំងព្រះ (ឧបសេនវង្គន្តបុត្រ) ត្ថេរៈ ទុកក្នុងតំណែងកំពូលលើពួកភិក្ខុដែលនាំសេចក្តីជ្រះថ្លាមកដោយជុំវិញ ក្នុងព្រះសាសនានេះឯង ។

ចប់អដ្ឋកថា សូត្រទី ៥

# អដ្ឋកថាសូត្រទី ៦

## ប្រវត្តិព្រះទព្វមល្លបុត្រ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៦ ដូចតទៅនេះ ៖

[១៤៨] បទថា *សេនាសនបញ្ញាបកានំ* សេចក្ដីថា ភិក្ខុដែលមាននាទីចាត់ចែងសេនាសនៈ ។ បានឮថា ក្នុងវេលាព្រះថេរៈចាត់ចែងសេនាសនៈ ក្នុងបណ្ដាមហាវិហារទាំង ១៨ កន្លែង មិនមានបរិវេណណាដែលនៅមិនបានសម្អាតឲ្យរៀបរយ សេនាសនៈដែលមិនបានបដិបត្តិរក្សាទុកដាក់ គ្រែតាំងដែលមិនទាន់បានជម្រះឲ្យស្អាត ទឹកផឹក ទឹកប្រើ ដែលមិនទាន់បានតម្កល់ទុក ព្រោះដូច្នោះលោកទើបឈ្មោះថា ជាកំពូលលើពួកភិក្ខុអ្នកមាននាទីចាត់ចែងសេនាសនៈ ពាក្យថា **ទព្វៈ** ជាឈ្មោះរបស់លោក តែព្រោះលោកកើតក្នុងត្រកូលរបស់មល្លក្សត្រទើបឈ្មោះថា **មល្លបុត្រ** ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលនឹងពោលទៅតាមលំដាប់ដូចតទៅនេះ ៖

ពោលដោយសង្ខេប សម័យព្រះបទុមុត្តរៈពុទ្ធ ព្រះថេរៈនេះ កើតក្នុងត្រកូលមួយក្នុងក្រុងហង្សវតី ចម្រើនវ័យហើយ ទៅវិហារស្ដាប់ធម៌ ដោយន័យដែលពោលហើយនុ៎ះឯង ឃើញព្រះសាស្ដាទ្រង់ស្ថាបនាភិក្ខុ ទុកក្នុងតំណែងជា

កំពូលលើពួកភិក្ខុដែលមានមុខនាទីបាត់បែងទីសេនាសនៈ ក៏ធ្វើកុសលកម្មប្រាថ្នាតំណែងនោះ ព្រះសាស្តាទ្រង់ព្យាករណ៍ហើយ លោកបានធ្វើកុសលរហូតអស់ជីវិត វិលវល់នៅក្នុងទេវតា និងមនុស្ស លុះមកក្នុងកាលសាសនារបស់ព្រះកស្សបទសពលសាបសូន្យទៅ ទើបបួស គ្រានោះបុគ្គលដទៃ ៦ នាក់ទៀត រួមជាលោកបានភិក្ខុ ៧ រូប មានចិត្តតែមួយ ឃើញបុគ្គលពួកដទៃនោះ មិនធ្វើសេចក្តីគោរពក្នុងព្រះសាស្តា ទើបប្រឹក្សាគ្នាថា ក្នុងពេលនេះ យើងត្រូវធ្វើយ៉ាងណាដើម្បីបំពេញសមណធម៌ក្នុងទីសមគួរណាមួយ ហើយធ្វើទីបំផុតទុក្ខបាន ទើបចងជណ្តើរ ឡើងកំពូលភ្នំខ្ពស់ ពោលថា យើងគប្បីដឹងនូវកម្លាំងរបស់ខ្លួន ចូររុញជណ្តើរឲ្យធ្លាក់ទៅ អ្នកដែលនៅមានសេចក្តីក្តៅក្រហាយក្នុងខាងក្រោយនៅចុះ ទើបព្រមព្រៀងគ្នា រុញជណ្តើរឲ្យធ្លាក់ទៅ ពោលទូន្មានដល់គ្នានិងគ្នាថា អាវុសោ លោកចូរជាអ្នកមិនប្រមាទចុះ អង្គុយក្នុងទីដែលពេញចិត្ត ផ្តើមបំពេញសមណធម៌ បណ្តាភិក្ខុទាំង ៧ នោះ ព្រះថេរៈមួយរូប សម្រេចព្រះអរហត្តក្នុងថ្ងៃទី ៥ គិតថា កិច្ចរបស់យើងធ្វើស្រេចហើយ យើងនឹងធ្វើអ្វីក្នុងទីនេះ ទើបទៅនាំបិណ្ឌបាតមកពីឧត្តរកុរុទ្វីបដោយឫទ្ធិ ពោលថា អាវុសោ លោកទាំងឡាយចូរឆាន់បិណ្ឌបាតនេះ នាទីភិក្ខាចារជារបស់ខ្ញុំ លោកទាំងឡាយ ចូរបំពេញសមណធម៌ចុះ ។ អាវុសោ ពួកយើងផ្លាស់រុញជណ្តើរចោល និយាយគ្នាយ៉ាងនេះ មិន

មែនឬថា អ្នកណាធ្វើឲ្យជាក់ច្បាស់នូវធម៌មុន អ្នកនោះចូរទៅនាំកិក្ខាមក ភិក្ខុក្រៅពីនេះធាន់ភិក្ខាដែលលោកនាំមក ហើយនឹងធ្វើសមណធម៌ ភិក្ខុទាំងឡាយពោលថា អាវុសោ មិនដូច្នោះទេ ព្រះថេរៈពោលថា លោកទាំងឡាយបានហើយដោយហេតុដែលមានក្នុងមុននៃខ្លួន សូម្បីខ្ញុំទាំងឡាយក៏នឹងអាចធ្វើទីបំផុតនៃវដ្តៈបាន សូមនិមន្តទៅចុះ ព្រះថេរៈកាលមិនអាចញ៉ាំងភិក្ខុទាំងនោះឲ្យព្រមបាន ក៏ធាន់បិណ្ឌបាតក្នុងទីដែលមានសេចក្តីសុខហើយក៏ទៅ ។ ក្នុងថ្ងៃទី ៧ ព្រះថេរៈមួយអង្គទៀតសម្រេចអនាគាមិផល ចុតិចាកអត្តភាពនោះ ទៅកើតក្នុងព្រហ្មលោកជាន់សុទ្ធាវាស ។

ចំណែកព្រះថេរៈក្រៅពីនេះ ចុតិចាកពីអត្តភាពនោះ ក៏វិលវល់នៅក្នុងទេវតា និងមនុស្សអស់មួយពុទ្ធន្តរ កើតក្នុងត្រកូលនោះៗ មួយអង្គកើតក្នុងព្រះរាជនិវេសន៍ក្នុងក្រុងតក្កសិលាដែនគន្ធារៈ , មួយអង្គ កើតក្នុងផ្ទៃនាងបរិព្វាជិកាក្នុងបច្ចន្តេយរដ្ឋ , អង្គមួយកើតក្នុងផ្ទះកុដុម្ពិកៈ ក្នុងពាហិយរដ្ឋ , មួយអង្គកើតក្នុងផ្ទះនៃកុដុម្ពិកៈក្រុងរាជគ្រឹះ ចំណែកព្រះទព្វមល្លៈនេះ បដិសន្ធិក្នុងនិវេសន៍របស់មល្លក្សត្រមួយព្រះអង្គ ក្នុងអនុបិយនគរ មល្លរដ្ឋ ។ ក្នុងវេលាជិតប្រសូតមាតារបស់លោក ក៏ធ្វើមរណកាល ញាតិទាំងឡាយនាំសរីរៈរបស់អ្នកស្លាប់ទៅកាន់ព្រៃស្មសាន ហើយលើកឡើងកាន់ជើងថ្ករ គរឧសហើយដុត ។ ពេលភ្លើង

ស្ងប់ ផ្ទៃរបស់នាងក៏បែកចេញជា ២ ចំណែក ក៏មានទារកធ្លាក់ទៅត្រង់សសរឈើមួយដើម ដោយកម្លាំងបុណ្យរបស់ខ្លួន អ្នកទាំងឡាយលើកពទារកនោះទៅឲ្យដល់យាយ យាយកាលនឹងតាំងឈ្មោះទារកនោះ ទើបតាំងឈ្មោះរបស់លោកថា ទព្វៈ ព្រោះលោកខ្លួតធ្លាក់ទៅត្រង់សសរឈើទើបរួចជីវិត ។

កាលលោកមានអាយុ ៧ ខួប ព្រះសាស្ដាមានភិក្ខុសង្ឃជាបរិវារ ស្ដេចចារិកទៅក្នុងមល្លរដ្ឋ លុះដល់អនុបិយនិគមទ្រង់ប្រថាប់នៅក្នុងអនុបិយអម្ពវ័នទព្វកុមារឃើញព្រះសាស្ដាក៏ជ្រះថ្លាក្នុងព្រះពុទ្ធសាសនាតែម្ដង ក៏ប្រាថ្នានឹងបួសទើបលាយាយថា "ចៅនឹងបួសក្នុងសំណាក់ព្រះទសពល" យាយពោលថា ល្អណាស់ចៅ ទើបនាំទព្វកុមារទៅគាល់ព្រះសាស្ដា ក្រាបទូលថា ព្រះអង្គដ៏ចម្រើនសូមឲ្យកុមារនេះបួសផង ព្រះសាស្ដាទ្រង់ប្រទានសញ្ញាដល់ភិក្ខុមួយរូបថា ភិក្ខុអ្នកចូរឲ្យទារកនេះបួសចុះ ព្រះថេរៈនោះទទួលព្រះពុទ្ធតម្រាស់ហើយ ក៏ឲ្យទព្វ-កុមារបព្វជ្ជា ប្រាប់តចបញ្ចកកម្មដ្ឋាន ។ សត្វដែលសម្បូណ៌ដោយបុព្វហេតុ បានបំពេញបារមីទុកហើយ ក្នុងខណៈដែលកោរសក់ដំបូង ក៏បានតាំងនៅក្នុងសោតា-បត្តិផល កាលកោរសក់លើកទី ២ តាំងនៅក្នុងសកទាគាមិផល កោរលើកទី ៣ តាំងនៅក្នុងអនាគាមិផល កាលកោរសក់អស់ និងការធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ក៏កើតឡើងមិនមុនមិនក្រោយ គឺ ព្រមគ្នា ។

ព្រះសាស្តាប្រថាប់នៅក្នុងមល្លរដ្ឋតាមព្រះពុទ្ធអធ្យាស្រ័យហើយ ស្តេចទៅកាន់ក្រុងរាជគ្រឹះ សម្រេចព្រះឥរិយាបថនៅក្នុងព្រះវេឡុវ័នវិហារ ក្នុងទីនោះ ព្រះទព្វមល្លបុត្រនៅក្នុងទីស្ងាត់ ពិចារណាមើលការសម្រេចកិច្ចរបស់ខ្លួន ប្រាថ្នានឹងប្រកបកាយក្នុងការធ្វើសេចក្តីខ្វល់ខ្វាយដល់សង្ឃ គិតថា យើងនឹងចាត់ចែងសេនាសនៈ និងចាត់អាហារថ្វាយសង្ឃ ទើបលោកចូលគាល់ព្រះសាស្តា ក្រាបទូលដល់បរិវិតក្កៈរបស់ខ្លួន ព្រះសាស្តាទ្រង់ប្រទានសាធុការដល់លោក ហើយទ្រង់ប្រទាននាទីចាត់ចែងសេនាសនៈ និងនាទីចាត់ចែងអាហារ គ្រានោះ ព្រះសាស្តាទ្រង់ព្រះតម្រិះថា ទព្វៈនេះ នៅក្មេង តែតាំងនៅក្នុងតំណែងធំ ទើបទ្រង់ឲ្យលោកឧបសម្បទាក្នុងវេលាដែលលោកមានវស្សា ៧ ប៉ុណ្ណោះ តាំងពីវេលាដែលលោកឧបសម្បទាហើយ ព្រះថេរៈចាត់ចែងសេនាសនៈ និងចាត់ចែងអាហារថ្វាយភិក្ខុគ្រប់រូបដែលអាស្រ័យនៅក្នុងក្រុងរាជគ្រឹះ សេចក្តីដែលលោកមាននាទីចាត់ចែងសេនាសនៈ បានប្រាកដទៅក្នុងទិសទាំងពួងថា បានឮថា ព្រះទព្វមល្លបុត្ររមែងឈ្លាសក្នុងការចាត់ចែងសេនាសនៈក្នុងទីមួយសម្រាប់ភិក្ខុដែលត្រូវអធ្យាស្រ័យគ្នា រមែងចាត់ចែងសេនាសនៈសូម្បីក្នុងទីឆ្ងាយ ពួកភិក្ខុដែលមិនអាចនឹងទៅបាន លោកក៏នាំទៅដោយឫទ្ធិ ។

គ្រានោះ ភិក្ខុទាំងឡាយ ប្រាប់ឲ្យលោកចាត់ចែងសេនាសនៈយ៉ាងនេះថា

អាវុសោ ចូរចាត់ចែងសេនាសនៈដល់ពួកយើងក្នុងជីវកម្ពវ័ន ចូរចាត់ចែងសេ-នាសនៈឲ្យដល់ពួកយើងក្នុងមទ្ទកុច្ឆិមិគទាយវ័ន ហើយឃើញឫទ្ធិរបស់លោកក៏ទៅ ក្នុងកាលខ្លះ ក្នុងវិកាលខ្លះ សូម្បីព្រះទព្វៈនោះ ក៏បណ្ដាលកាយមនោមយៈដោយឫទ្ធិ និម្មិតជាភិក្ខុឲ្យដូចគ្នានឹងខ្លួនលោកសម្រាប់ព្រះថេរៈអង្គមួយរូបៗ កាន់ភ្លើងទៅខាងមុខ ប្រាប់ថា នេះគ្រែ នេះតាំងជាដើម ចាត់ចែងសេនាសនៈហើយទើបត្រឡប់មកកាន់ទីនៅរបស់ខ្លួនវិញ នេះជាសេចក្ដីសង្ខេបក្នុងរឿងនេះ ។ តែដោយពិស្ដារ រឿងនេះមកក្នុងព្រះបាលីហើយដូចគ្នា ព្រះសាស្ដាទ្រង់ធ្វើហេតុនេះនុ៎ះឯងឲ្យជាអត្ថុប្បត្តិ (ហេតុកើតរឿង) ក្នុងកណ្ដាលពួកព្រះអរិយៈ ទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងជាកំពូលលើពួកភិក្ខុ ដែលមាននាទីជាអ្នកចាត់ចែងសេ-នាសនៈឯង ។

ចប់អដ្ឋកថា សូត្រទី ៦

# អដ្ឋកថាសូត្រទី ៧

## ប្រវត្តិព្រះបិលិន្ទវច្ឆត្ថេរៈ

*គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៧ ដូចតទៅនេះ ៖*

[១៤៨] *ដោយបទថា* ***ទេវានំ បិយមនាបានំ*** *ទ្រង់សំដែងថា ព្រះបិលិន្ទវច្ឆត្ថេរៈ ជាកំពូលលើពួកភិក្ខុដែលជាទីស្រឡាញ់ និងជាទីពេញចិត្តរបស់ទេវតាទាំងឡាយ បានឮថា កាលព្រះពុទ្ធទ្រង់មិនទាន់ឧប្បត្តិ ព្រះថេរៈនោះ ជាស្តេចចក្រពត្តិ ទ្រង់ឲ្យមហាជនតាំងនៅក្នុងសីល ៥ ទ្រង់បានធ្វើកុសលដែលប្រាថ្នាផលខាងមុខ គឺ សួគ៌ ដោយច្រើន ពួកទេវតាដែលកើតក្នុងឆកាមាវចរសួគ៌ ៦ ជាន់ បានឱវាទរបស់ព្រះអង្គនុ៎ះឯង ពិចារណាមើលសម្បត្តិរបស់ខ្លួនក្នុងទីដែលកើតហើយ នឹកឃើញថា យើងបានសម្បត្តិសួគ៌នេះ ព្រោះអាស្រ័យអ្នកណាហ្ន៎ ក៏ដឹងថា យើងបានសម្បត្តិព្រោះអាស្រ័យព្រះថេរៈ ទើបនមស្ការព្រះថេរៈទាំងវេលាព្រឹកវេលាល្ងាច ព្រោះដូច្នោះ លោកទើបជាកំពូលលើពួកភិក្ខុដែលជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ទេវតាទាំងឡាយ ។ ក៏ពាក្យថា* ***បិលិន្ទ*** *ជាឈ្មោះរបស់លោក , ពាក្យថា* ***វច្ឆៈ*** *ជាគោត្ររបស់លោក រួមពាក្យទាំង ២ នោះ ចូលគ្នាទើបហៅថា “****បិលិន្ទវច្ឆៈ****” ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលនឹងពោលតាមលំដាប់ដូច*

តទៅនេះ ៖

បានឮមកថា សម័យព្រះបទុមុត្តរសម្ពុទ្ធ ព្រះថេរៈនេះកើតក្នុងត្រកូលរបស់អ្នកដែលមានភោគសម្បត្តិច្រើនក្នុងក្រុងហង្សវតី ស្តាប់ធម្មទេសនារបស់ព្រះសាស្តា ដោយន័យដូចមុននុ៎ះឯង ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូបទុកក្នុងតំណែងជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ទេវតាទាំងឡាយ ក៏ប្រាថ្នាតំណែងនោះ ធ្វើកុសលជរាបអស់ជីវិត វិលវល់នៅក្នុងទេវតា និងមនុស្ស ។ ក្នុងពុទ្ធុប្បាទកាលនេះ មកកើតក្នុងត្រកូលព្រាហ្មណ៍ក្នុងក្រុងសាវត្ថី ញាតិទាំងឡាយដាក់នាមលោកថា **បិលិន្ទវច្ឆៈ** សម័យតមក លោកស្តាប់ធម្មទេសនារបស់ព្រះសាស្តា បានសទ្ធា បព្វជ្ជាឧបសម្បទាហើយ ចម្រើនវិបស្សនាក៏សម្រេចព្រះអរហត្ត លោកកាលនិយាយជាមួយគ្រហស្ថក្តី ភិក្ខុក្តី ប្រើវោហារថា ថោកទាបគ្រប់ពាក្យថា "មកមនុស្សថោកទាប , ទៅមនុស្សថោកទាប , នាំទៅមនុស្សថោកទាប , កាន់យកមកមនុស្សថោកទាប" ភិក្ខុទាំងឡាយស្តាប់រឿងនោះហើយក៏នាំទៅទូលសួរព្រះតថាគតថា បពិត្រព្រះដ៏មានព្រះភាគ ធម្មតាព្រះអរិយៈរមែងមិនពោលពាក្យគ្រោតគ្រាត ព្រះដ៏មានព្រះភាគត្រាស់ថា "ម្នាលភិក្ខុទាំងឡាយធម្មតាថា ព្រះអរិយៈទាំងឡាយមិនពោលផរុសវាចា គ្របសង្កត់អ្នកដទៃ ប៉ុន្តែថាផរុសវាចានោះ គប្បីមានបានដោយការធ្លាប់ក្នុងភពដទៃ" ភិក្ខុទាំងឡាយក្រាប

ទូលថា ព្រះអង្គ ព្រះបិលិន្ទវច្ឆត្ថេរៈព្យាយាមហើយ ព្យាយាមទៀត កាលពោល នឹងគ្រហស្ថក្តី នឹងភិក្ខុទាំងឡាយក្តី ក៏និយាយថា “មនុស្សថោកទាប មនុស្សថោកទាប” បពិត្រព្រះដ៏មានព្រះភាគ ក្នុងរឿងនេះ មានហេតុដូចម្តេច ព្រះដ៏-មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការពោលដូច្នោះនោះ នៃបុត្ររបស់តថាគត ប្រព្រឹត្តដរាបដល់ធ្លាប់ក្នុងបច្ចុប្បន្នប៉ុណ្ណោះក៏មិនមែន តែក្នុងអតីតកាល បុត្ររបស់តថាគតនេះ កើតក្នុងត្រកូលព្រាហ្មណ៍អ្នកប្រាជ្ញាពោលថា ថោកទាប អស់ ៥០០ ជាតិ ដូច្នោះ បុត្ររបស់តថាគតនេះ ទើបពោលព្រោះសេចក្តីធ្លាប់ មិនបានពោលដោយចេតនាគ្រោតគ្រាត ។ ពិតណាស់ វោហាររបស់ព្រះអរិយៈទាំងឡាយសូម្បីនឹងគ្រោតគ្រាតខ្លះ ក៏ឈ្មោះថា បរិសុទ្ធពិត ព្រោះចេតនាមិនគ្រោតគ្រាត មិនជាបាបសូម្បីមានប្រមាណតិចតួចព្រោះការពោលនេះ ។ ដូច្នេះហើយទើបត្រាស់គាថានេះ ក្នុងព្រះធម្មបទថា ៖

អកក្កសំ វិញ្ញាបនឹ គិរំ សច្ចំ ឧទីរយេ
យាយ នាភិសជេ កិញ្ចិ តមហំ ព្រូមិ ព្រាហ្មណំ

គប្បីពោលតែពាក្យដែលមិនគ្រោតគ្រាត ដែលពេញចិត្ត
ដែលគប្បីពោល ជាពាក្យពិត ដែលមិនប៉ះពាល់នរណាៗ
តថាគតហៅបុគ្គលនោះថា ព្រាហ្មណ៍ ។

តមកថ្ងៃមួយ ព្រះថេរៈចូលទៅបិណ្ឌបាតក្រុងរាជគ្រឹះ ជួបបុរសម្នាក់កាន់ដីប៉ូមកពេញថាស កំពុងចូលទៅក្នុងក្រុង ទើបសួរថា មនុស្សថោកទាបក្នុងភាជនៈមានអ្វី បុរសអ្នកនោះ គិតថា សមណៈរូបនេះ ពោលពាក្យអាក្រក់នឹងយើងពីព្រឹកតែម្តង យើងក៏គួរពោលពាក្យដែលមិនសមគួរដល់សមណៈរូបនេះដូចគ្នា ទើបឆ្លើយថា ក្នុងភាជនៈរបស់ខ្ញុំជាអាចម៍កណ្តុរលោក ។ ព្រះថេរៈនិយាយថា ណ្ហើយចុះ មនុស្សថោកទាប ជាយ៉ាងនោះចុះ ។ កាលព្រះថេរៈត្រឡប់ក្រោយទៅ ដីប៉ូក៏ក្លាយជាអាចម៍កណ្តុរអស់ទៅ គេគិតថា ដីប៉ូទាំងនេះប្រាកដដូចជាអាចម៍កណ្តុរ ជាការពិតឬហ្ន៎ ក៏យកដៃច្របាច់មើល ពេលនោះគេក៏ដឹងថាជាអាចម៍កណ្តុរពិតៗ ក៏មានសេចក្តីទាស់ចិត្តយ៉ាងក្រៃលែង ។ គេគិតថា កើតចំពោះតែដីប៉ូក្នុងថាសប៉ុណ្ណោះឬ ឬក្នុងរទេះក៏ជាយ៉ាងនេះដែរ ទើបដើរទៅពិនិត្យមើល ក៏ឃើញថា ដីប៉ូទាំងអស់ក៏ជាដូច្នោះដែរ យកដៃគក់ទ្រូង ហើយគិតថា នេះមិនមែនការធ្វើរបស់អ្នកដទៃ ពិតជាការធ្វើរបស់ភិក្ខុដែលយើងជួបពីព្រឹកនុ៎ះឯង ព្រះថេរៈនឹងដឹងកលមាយាណាមួយដោយពិត ចាំយើងនឹងតាមរកទីកន្លែងដែលភិក្ខុនោះដើរទៅ ទើបនឹងដឹងហេតុ ដូច្នេះ ហើយទើបដើរទៅតាមផ្លូវដែលព្រះថេរៈដើរទៅ លំដាប់នោះ បុរសម្នាក់ជួបបុរសនោះកំពុងដើរដោយអាការទឹង ទើបសួរថា សម្លាញ់ តើទឹងរឿងអ្វី លោកកំពុងដើរទៅធ្វើធុរៈអ្វី ។

គេទើបប្រាប់រឿងនោះដល់បុរសម្នាក់នោះ ។ បុរសម្នាក់នោះស្ដាប់រឿងរ៉ាវរបស់គេហើយ ក៏និយាយយ៉ាងនេះថា សម្លាញ់ កុំគិតឡើយ នឹងកើតមានដោយព្រះបិលិន្ទវច្ឆៈលោកម្ចាស់របស់ខ្ញុំនេះឯង សម្លាញ់ចូរកាន់ដីប៉ូនោះពេញកាជនៈទៅឈរខាងមុខព្រះថេរៈ វេលាដែលព្រះថេរៈពោលថា នោះជាអ្វី បុរសថោកទាបក៏ចូរពោលថា ដីប៉ូលោកម្ចាស់ ។ ព្រះថេរៈនឹងពោលថា នឹងជាយ៉ាងនោះចុះបុរសថោកទាប ។ វាក៏នឹងក្លាយជាដីប៉ូវិញហើយ បុរសនោះក៏បានធ្វើយ៉ាងនោះតែខាងក្រោយ ព្រះសាស្ដា ទ្រង់ធ្វើរឿងដែលព្រះថេរៈជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ពួកទេវតា ឲ្យជាហេតុ ទើបទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងឯតទគ្គៈជាកំពូលលើភិក្ខុសាវកអ្នកជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ទេវតានោះឯង ។

ចប់អដ្ឋកថា សូត្រទី ៧

# អដ្ឋកថាសូត្រទី ៨

## ប្រវត្តិព្រះពាហិយទារុចីរិយត្ថេរ

ក្នុងសូត្រទី ៨ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[១៤៨] ដោយបទថា **ខិប្បាភិញ្ញានំ** លោកសម្តែងថា ព្រះទារុចិរិយត្ថេរ ជាកំពូលលើភិក្ខុសាវកអ្នកត្រាស់ដឹងរហ័ស ពិតណាស់ ព្រះថេរៈនេះសម្រេចព្រះអរហត្តក្នុងកាលចប់ព្រះធម្មទេសនាយ៉ាងសង្ខេប មិនមានកិច្ចដែលនឹងត្រូវបរិកម្មមគ្គផលទាំងឡាយ ព្រោះហេតុនោះ លោកទើបឈ្មោះថា ជាកំពូលលើភិក្ខុសាវកអ្នកត្រាស់ដឹងរហ័ស ។ មនុស្សទាំងឡាយតាំងឈ្មោះលោកថា **ពាហិយៈ** ព្រោះលោកកើតក្នុងពាហិយរដ្ឋ ។ តមកខាងក្រោយ លោកស្លៀកសំពត់ធ្វើដោយឈើ ព្រោះហេតុនោះ ទើបឈ្មោះថា **ទារុចិរិយៈ** ក្នុងបញ្ហាកម្មរបស់លោកមានរឿងតាមលំដាប់ ដូច្នេះ ៖

ពិតណាស់ ព្រះពាហិយទារុចិរិយៈនេះ កាលសម័យព្រះពុទ្ធព្រះនាមថា **បទុមុត្តរ** បានកើតក្នុងត្រកូលក្នុងក្រុងហង្សវតី កំពុងស្តាប់ធម៌របស់ព្រះទសពល ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូបក្នុងតំណែងឯតទគ្គៈ ជាកំពូលលើពួកភិក្ខុសាវកអ្នកត្រាស់ដឹងរហ័ស ទើបធ្វើកុសលឲ្យក្រៃលែងឡើងទៅ បានប្រាថ្នា

គំណែងនោះ ធ្វើកុសលកម្មដរាបអស់ជីវិត វិលវល់នៅក្នុងពួកទេវតា និងមនុស្ស វេលាសាសនារបស់ព្រះកស្សបទសពលសាបសូន្យចុះ ក៏ធ្វើសមណធម៌រួមជាមួយពួកភិក្ខុ ដែលពោលទុកខាងក្រោយ ជាអ្នកមានសីលបរិបូណ៌ អស់ជីវិតទៅក៏កើតក្នុងទេវលោក លោកនៅក្នុងទេវលោកអស់មួយពុទ្ធន្តរ ។ ក្នុងពុទ្ធកាលនេះ ក៏កើតក្នុងត្រកូលក្នុងពាហិយរដ្ឋ ចម្រើនវ័យក៏គ្រប់គ្រងផ្ទះ ត្រិះរិះថា នឹងធ្វើជំនួញ ទើបឡើងសំពៅដែលនាំទៅសុវណ្ណភូមិ មិនទាន់ទៅដល់គោលដៅដែលប្រាថ្នា សំពៅក៏លិចកណ្តាលសមុទ្រ ។ មហាជន (អ្នកដោយសារ) ក៏ក្លាយជាចំណីរបស់អណ្តើក និងត្រី ចំណែកពាហិយៈនេះ តោងបន្ទះក្តារមួយសន្ទឹកព្យាយាមហែលអស់ ៧ ថ្ងៃ ទើបដល់កំពង់ទូកឈ្មោះ សុប្បារកៈ បានដឹងថា ជាទីដែលមនុស្សរស់នៅ គិតថា នឹងចូលទៅរកមនុស្សដោយមិនមានសំពត់ជាប់ខ្លួន មិនសមគួរ ទើបយកសារាយដែលដុះលើទឹកមួយកន្លែង ក្នុងទីមិនឆ្ងាយយកមករុំខ្លួន កាន់យកអំបែងមួយដើរទៅសូមអាហារ មនុស្សទាំងឡាយឃើញគេហើយនាំគ្នាគិតថា បើក្នុងលោកនេះនៅមានព្រះអរហន្តពិត គប្បីមានដោយវិធីយ៉ាងនេះ លោកម្ចាស់មិនទទួលសំពត់ ព្រោះកាន់យ៉ាងឧក្រិដ្ឋឬហ្ន៎ ឬទទួលសំពត់ដែលគេឲ្យ ដូច្នេះ ទើបសាកល្បងឲ្យសំពត់ទាំងឡាយ អំពីទិសផ្សេងៗ គេគិតថា បើមិនមកបែបនេះ មនុស្សទាំងនេះក៏មិនជ្រះថ្លានឹងយើង ចាំយើងនឹងនិយាយយ៉ាង

ណាមួយបញ្ឆោតមនុស្សទាំងនេះ ធ្វើជាឧបាយដើម្បីចិញ្ចឹមជីវិតក៏គួរ ទើបមិនព្រម ទទួលសំពត់ទាំងឡាយ ពួកមនុស្សក៏កាន់តែជ្រះថ្លាក្រៃលែងឡើងទៅ ។ សូម្បី គេនឹងបរិភោគអាហារ ក៏ត្រូវទៅអាស្រ័យទីដែលមិនឆ្ងាយ មហាជនក៏ដើរទៅ ជាមួយគេ ទំនុកបម្រុងទីនៅអាស្រ័យឲ្យលោក ។ គេគិតថា មនុស្សទាំងនេះ ជ្រះថ្លាត្រឹមតែការស្លៀកសាកាយរបស់យើង បានធ្វើសក្ការៈយ៉ាងនេះ យើងនឹងធ្វើ ឲ្យឧក្រិដ្ឋជាងនេះ ក៏គួរដល់មនុស្សទាំងនេះ ដូច្នេះហើយ ក៏កាន់យកសំបកឈើ ដែលស្តើងៗ ដេរភ្ជាប់ ធ្វើជាសំពត់ស្លៀកដណ្តប់ចិញ្ចឹមជីវិត ។

គ្រានោះ បណ្តាជន ៧ នាក់ ដែលធ្វើសមណធម៌គ្រាព្រះពុទ្ធព្រះនាម ថា កស្សបៈ ជនម្នាក់ជាភិក្ខុកើតក្នុងព្រហ្មលោកជាន់សុទ្ធាវាស ពិចារណាមើល សម្បត្តិព្រហ្មរបស់ខ្លួន រឭកដល់ស្ថានទីដែលជន ៧ នាក់មក ក៏ឃើញស្ថានទី ជន ៧ នាក់ ដែលគេធ្វើសមណធម៌ រឭកដល់ស្ថានទីជន ៦ នាក់ ទៅកើត ក៏ដឹងថា ម្នាក់បរិនិព្វានហើយ ៥ នាក់ទៀត ម្នាក់ទៅកើតក្នុងទេវលោកជាន់ កាមាវចរ ក៏រឭកដល់ជនទាំង ៥ នាក់ ម្តងម្នាក់ៗ កាលរឭកថា ក្នុងវេលានេះ គេនៅទីណាហ្ន៎ ក៏ឃើញទារុចិរិយៈ អាស្រ័យត្រង់កំពង់ទូកសុប្បារកៈ ចិញ្ចឹម ជីវិតដោយការកុហក គិតថា វិនាសហើយហ្ន៎ ទារុចិរិយៈនេះល្ងង់ខ្លៅណាស់តើ ធ្វើសមណធម៌មកអំពីកាលមុន មិនព្រមឆាន់បិណ្ឌបាត សូម្បីព្រះអរហន្តនាំមក

ព្រោះជាអ្នកកាន់កតិកាឧក្រិដ្ឋក្រៃលែងណាស់ មកឥឡូវនេះ មិនមែនជាព្រះអរហន្ត ក៏ប្តេជ្ញាថាជាអរហន្ត ដើរបោកបញ្ឆោតលោក ព្រោះតែផ្ទៃ ទាំងមិនដឹងថា ព្រះទសពលឧប្បត្តិហើយ ចាំយើងទៅធ្វើគេឲ្យតក់ស្លុត ហើយឲ្យគេដឹងថា ព្រះទស-ពលឧប្បត្តិហើយ ក្នុងពេលនុ៎ះឯង ក៏ចុះចាកព្រហ្មលោក ទៅប្រាកដខ្លួនចំពោះមុខទារុចិរិយៈ ក្នុងវេលាកណ្តាលយប់ត្រង់កំពង់ទូកសុប្បារកៈ ។ គេឃើញឱភាសភ្លឺក្នុងទីនៅរបស់ខ្លួន ទើបចេញមកខាងក្រៅ ឃើញមហាព្រហ្ម ផ្គងអញ្ជលី លើកដៃប្រណមសួរថា លោកជានរណា ។ មហាព្រហ្មឆ្លើយថា យើងជាសម្លាញ់ចាស់របស់លោក សម្រេចអនាគាមិផលកើតក្នុងព្រហ្មលោក ។ អ្នកដ៏ចម្រើនទីបំផុតនៃប្រធានរបស់ពួកយើង សម្រេចព្រះអរហត្តបរិនិព្វានហើយ ពួកលោក ៥ នាក់ កើតក្នុងទេវលោក ។ យើងឃើញលោកចិញ្ចឹមជីវិតដោយការបោកបញ្ឆោតគេក្នុងទីនេះ ទើបមកដើម្បីទូន្មាន ហើយទើបពោលហេតុនេះថា ពាហិយៈ លោកមិនទាន់ជាអរហន្ត មិនទាន់បដិបត្តិដល់អរហត្តមគ្គ លោកក៏មិនមានបដិ-បទាដែលនឹងឲ្យជាអរហន្ត ឬបដិបត្តិដល់អរហត្តមគ្គ ។ លំដាប់នោះ មហាព្រហ្មប្រាប់គេថា ព្រះសាស្តាឧប្បត្តិហើយ និងប្រថាប់នៅក្នុងក្រុងសាវត្ថី លោកចូរទៅកាន់សំណាក់ព្រះសាស្តា ហើយបញ្ជូនគេទៅ ខ្លួនឯងក៏ត្រឡប់ទៅកាន់ព្រហ្ម-លោក ។

សូម្បីទារុចិរិយៈ ត្រូវមហាព្រហ្មធ្វើឲ្យតក់ស្លុតហើយ ក៏គិតនឹងស្វែងរកផ្លូវរួចផុត ទើបធ្វើដំណើរ ១២០ យោជន៍ ដោយសម្រាកតែមួយយប់ បានជួបព្រះសាស្តាស្តេចចូលទៅបិណ្ឌបាតក្នុងលង្វែកស្រុក ក្រាបចុះទៀបមហាយុគលបាទព្រះសាស្តា ទូលអង្វរ ៣ ដងថា សូមព្រះដ៏មានព្រះភាគទ្រង់សម្តែងធម៌ប្រោសខ្ញុំព្រះអង្គចុះ ព្រះអង្គ សូមព្រះសុគត ទ្រង់សម្តែងធម៌ប្រោសខ្ញុំព្រះអង្គចុះព្រះអង្គ ។ ព្រះសាស្តាទ្រង់ជ្រាបថា ញាណរបស់ពាហិយៈចាស់ក្លាហើយ ដោយហេតុប៉ុណ្ណេះ ទើបទ្រង់ទូន្មានដោយព្រះឱវាទនេះថា ព្រោះហេតុនេះឯង ពាហិយៈអ្នកគប្បីសិក្សាយ៉ាងនេះថា រូបដែលឃើញហើយ ក៏ត្រឹមបានឃើញហើយ ដូច្នេះជាដើម ។ កាលចប់ទេសនា ពាហិយៈនោះ ទាំងដែលនៅចន្លោះផ្លូវ បានបញ្ជូនញាណទៅតាមក្រសែទេសនា ក៏សម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទាទាំងឡាយ ពាហិយៈនោះ ដល់ទីបំផុតនៃកិច្ចរបស់ខ្លួនហើយ ទូលសូមបព្វជ្ជាចំពោះព្រះដ៏មានព្រះភាគ ស្វែងរកបាត្រចីវរ ព្រោះមិនទាន់មានបាត្រចីវរ កំពុងទាញសំពត់ទាំងឡាយចាកពីគំនរសម្រាម លំដាប់នោះ អមនុស្សដែលមានពៀរនឹងគ្នាមកពីមុន ចូលសណ្ឋិតក្នុងមេគោកូនមួយក្បាល ធ្វើលោកឲ្យអស់ជីវិត ព្រះសាស្តាស្តេចចេញចាកក្រុងសាវត្ថី ទតឃើញពាហិយៈដួលនៅត្រង់គំនរសម្រាមវាងផ្លូវ ត្រាស់ប្រាប់ពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរជួយគ្នាលើក

រាងកាយពាហិយៈ ហើយត្រាស់ឲ្យនាំទៅធ្វើឈាបនកិច្ច ប្រោសឲ្យសាងចេតិយទុកក្នុងផ្លូវធំបែកជា ៤ បន្ទាប់ពីនោះ ក៏កើតការនិយាយគ្នាកណ្តាលសង្ឃថា ព្រះតថាគត ត្រាស់បង្គាប់ឲ្យភិក្ខុសង្ឃធ្វើឈាបនកិច្ចរាងកាយរបស់ព្រះពាហិយៈរក្សាធាតុហើយ ប្រោសឲ្យសាងចេតិយទុក ព្រះពាហិយៈនោះ ធ្វើឲ្យច្បាស់មគ្គអ្វីហ្ន៎ គេជាសាមណេរឬហ្ន៎ ភិក្ខុទាំងឡាយកើតការគិត ដូច្នេះ ។ ព្រះសាស្តាទ្រង់ប្រារព្ធពាក្យនោះឲ្យជាអត្ថុប្បត្តិ (ហេតុកើតរឿង) ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពាហិយៈជាបណ្ឌិត ទ្រង់អធិប្បាយព្រះធម្មទេសនាទុក ហើយទ្រង់ប្រកាសថា ពាហិយៈនោះបរិនិព្វានហើយ ។ រឿងដែលនិយាយគ្នានោះ កើតឡើងកណ្តាលសង្ឃទៀតថា ព្រះសាស្តាទ្រង់មិនបានសម្តែងធម៌ច្រើនឡើយ ត្រាស់ថា ពាហិយៈសម្រេចព្រះអរហត្ត នេះជារឿងអ្វីហ្ន៎ ។ ព្រះសាស្តាត្រាស់ថា ធម៌តិចឬច្រើន មិនមែនហេតុ ធម៌នោះក៏ដូចជាថ្នាំកែរោគមនុស្សដែលផឹកថ្នាំពិស ហើយត្រាស់គាថា ក្នុងព្រះធម្មបទថា

សហស្សមបិ ចេ គាថា អនត្ថបទសញ្ហិតា
ឯកំ គាថាបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ

បើគាថា សូម្បីពាន់គាថា ដែលប្រកបដោយបទដែលមិនជា
ប្រយោជន៍ រកប្រសើរជាងគាថាតែមួយបទមិនបាន ដែល

ស្តាប់ហើយស្ងប់រម្ងាប់ ។

ចប់ទេសនា សត្វប្រាំបីម៉ឺនបួនពាន់ ក៏នាំគ្នាផឹកទឹកអម្រឹត ។ ក៏ប៉ុន្តែថា រឿងរបស់ព្រះពាហិយៈនេះ មិនចាំត្រូវពោលទុកពិស្តារ ព្រោះមកក្នុងព្រះសូត្រហើយ ។ តែតមកខាងក្រោយ ព្រះសាស្តាប្រថាប់កណ្តាលសង្ឃ ទ្រង់ស្ថាបនាព្រះពាហិយត្ថេរៈទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលលើភិក្ខុសាវកអ្នកត្រាស់ដឹងរហ័សនោះឯង ។

ចប់អដ្ឋកថា សូត្រទី ៨

# អដ្ឋកថាសូត្រទី ៩
# ប្រវត្តិព្រះកុមារកស្សបត្ថេរ

ក្នុងសូត្រទី ៩ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[១៨៨] បទថា **ចិត្តកថិកានំ** បានដល់ អ្នកពោលធម៌ដ៏វិចិត្រ ។ ពិតហើយ ព្រះថេរៈកាលនឹងពោលធម៌ដល់នរណាម្នាក់ក្តី ពីរនាក់ក្តី ក៏ប្រដាប់ដោយឧបមា និងហេតុជាច្រើនឲ្យគេដឹង ទើបពោលថា ព្រោះហេតុនោះ ព្រះថេរៈទើបជាកំពូលលើភិក្ខុសាវកអ្នកពោលធម៌ដ៏វិចិត្រ បញ្ហាកម្មរបស់លោក មានរឿងដែលគប្បីពោលតាមលំដាប់ ដូច្នេះ ៖

ពិតណាស់ ព្រះកុមារកស្សបៈនេះ គ្រាព្រះពុទ្ធព្រះនាមថា **បទុមុត្តរ** បានបដិសន្ធិក្នុងត្រកូលក្នុងក្រុងហង្សវតី ចម្រើនវ័យ កំពុងស្តាប់ធម្មកថារបស់ព្រះទសពល ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុ មួយរូបទុកក្នុងតំណែងឯតទគ្គៈជាកំពូលលើពួកភិក្ខុសាវកអ្នកពោលធម៌ដ៏វិចិត្រ ទើបធ្វើកុសលកម្មឲ្យក្រៃលែងទៅប្រាថ្នាតំណែងនោះ វិលវល់នៅក្នុងទេវតា និងមនុស្ស លុះមកដល់សាសនារបស់ព្រះកស្សបសម្មាសម្ពុទ្ធសាបសូន្យចុះ ជាភិក្ខុមួយរូបក្នុងភិក្ខុ ៧ រូប ធ្វើសមណធម៌លើកំពូលភ្នំ មានសីលមិនសាបសូន្យ ចុតិចាកពីភពនោះហើយ កើតក្នុងទេវលោក

សោយសម្បត្តិអស់មួយពុទ្ធន្តរ សម័យព្រះសាស្តារបស់ពួកយើង ក៏កើតក្នុងគភ៌របស់ស្ត្រីនៃត្រកូលម្នាក់ក្នុងក្រុងរាជគ្រឹះ ក៏ស្ត្រីនៃត្រកូលនោះ អង្វរមាតាបិតាអំពីមុនតែមិនបានបព្វជ្ជា លុះទៅនៅផ្ទះនៃត្រកូល (មានស្វាមី) ក៏តាំងគភ៌ តែខ្លួនឯងមិនដឹង ទើបពោលប្រាប់ស្វាមី (សូមបព្វជ្ជា) ស្វាមីអនុញ្ញាតហើយ ក៏បព្វជ្ជាក្នុងសំណាក់ភិក្ខុនី ។ ពួកភិក្ខុនីឃើញគភ៌នាងធំឡើង ទើបនាំគ្នាទៅសួរព្រះទេវទត្ត ។ ព្រះទេវទត្តនោះក៏ពោលថា នាងមិនមែនជាសមណៈ ពួកភិក្ខុនីទើបនាំគ្នាទៅទូលសួរព្រះទសពល ។ ព្រះសាស្តាក៏ទ្រង់ ប្រគល់រឿងនោះឲ្យព្រះឧបាលិត្ថេរៈ ។ ព្រះថេរៈឲ្យអញ្ជើញត្រកូលពួកអ្នកក្រុងសាវត្ថី និងនាងវិសាខាឧបាសិកាមកជួយជម្រះ ក៏ពោលថា នាងមានគភ៌មុនពេល (បួស) បព្វជ្ជារបស់នាងទើបមិនវិនាស ។ ព្រះសាស្តា បានប្រទានសាធុការគាំទ្រដល់ព្រះថេរៈថា អធិករណ៍ដែលឧបាលីវិនិច្ឆ័យ ប្រពៃហើយ ។ ភិក្ខុនីនោះ ប្រសូតបុត្រស្រដៀងរូបមាស ព្រះបាទបសេនទិកោសលទ្រង់ទទួលក្មេងនោះ ប្រោសឲ្យចិញ្ចឹម ព្រះរាជទាននាមថា **កស្សបៈ** តមក ទ្រង់ចិញ្ចឹមធំធាត់ហើយ ក៏នាំទៅកាន់សំណាក់ព្រះសាស្តា ប្រោសឲ្យបព្វជ្ជា ។ តែព្រោះលោកបួសវេលានៅជាក្មេងតូច កាលព្រះដ៏មានព្រះភាគត្រាស់ថា ពួកអ្នកចូរហៅកស្សបៈមក ចូរឲ្យផ្លែឈើ ឬរបស់ឆាន់យ៉ាងនេះដល់កស្សបៈ ពួកភិក្ខុសង្ស័យក៏ទូលសួរថា កស្សបៈអង្គណា ព្រះអង្គ

ត្រាស់ថា កុមារកស្សបៈ កស្សបៈអង្គក្មេងតូច ។ ព្រោះបានទទួលនាមយ៉ាងនេះតាំងពីនោះមក លោកក៏ត្រូវហៅថា **កុមារកស្សប** សូម្បីក្នុងវេលាដែលលោកចាស់ហើយ ។ ន័យមួយទៀត អ្នកទាំងឡាយចាំលោកថា កុមារកស្សប ព្រោះហេតុដែលជាបុត្រចិញ្ចឹមរបស់ព្រះរាជាក៏មាន ។ តាំងពីបួសហើយ លោកធ្វើការចម្រើនវិបស្សនា និងរៀនសូត្រព្រះពុទ្ធវចនៈ ។

គ្រានោះ មហាព្រហ្ម អ្នកដែលធ្វើសមណធម៌លើកំពូលភ្នំជាមួយព្រះថេរៈនោះ សម្រេចអនាគាមិផល កើតក្នុងព្រហ្មលោកជាន់សុទ្ធាវាស រឭកដល់ក្នុងសម័យនោះ ឃើញព្រះកុមារកស្សបៈ គិតថា សម្លាញ់របស់យើងកំពុងលំបាកក្នុងការចម្រើនវិបស្សនា ចាំយើងទៅសម្ដែងផ្លូវនៃវិបស្សនាដល់លោក ដែលជាឧបាយឲ្យសម្រេចមគ្គផល ដូច្នេះ ហើយតាំងនៅក្នុងព្រហ្មលោកនុ៎ះឯង តែងបញ្ហា ១៥ ប្រការ ហើយទៅប្រាកដក្នុងទីនៅរបស់ព្រះកុមារកស្សបត្ថេរៈ បន្ទាប់ពីវេលាកណ្ដាលយប់ ព្រះថេរៈឃើញពន្លឺ ទើបសួរថា នរណានៅទីនោះ ។ មហាព្រហ្មឆ្លើយថា យើង គឺ ព្រហ្ម អ្នកធ្វើសមណធម៌ជាមួយលោកអំពីមុន បានសម្រេចអនាគាមិផល ហើយកើតក្នុងព្រហ្មលោកជាន់សុទ្ធាវាស ព្រះថេរៈសួរថា លោកមកដោយការងារអ្វី ។ មហាព្រហ្មប្រាប់បញ្ហាទាំងនោះ ដើម្បីសម្ដែងហេតុដែលខ្លួនមក ហើយពោលថា លោកចូររៀនបញ្ហាទាំងនេះ កាលអរុណរះ គប្បីចូល

ទៅគាល់ព្រះតថាគត ថ្វាយបង្គំហើយទូលសួរ ។ ព្រោះថា វៀរព្រះតថាគតចេញ បុគ្គលដទៃមិនអាចពោលដោះស្រាយបញ្ហាទាំងនេះបានទេ ហើយក៏ត្រឡប់ទៅកាន់ព្រហ្មលោកវិញ ។ ថ្ងៃស្អែក សូម្បីព្រះថេរៈក៏ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ទូលសួរបញ្ហា ដោយទំនងដែលមហាព្រហ្មពោលទុក ។ ព្រះសាស្តាទ្រង់តបបញ្ហាដល់ព្រះកុមារកស្សបៈ ហើយក៏បានសម្រេចព្រះអរហត្ត ។ ព្រះថេរៈរៀនសូត្រដោយទំនងដែលព្រះសាស្តាត្រាស់ទុក ទៅកាន់ព្រៃអន្ធវ័ន ញ៉ាំងវិបស្សនាឲ្យចាស់ក្លា ក៏សម្រេចព្រះអរហត្ត ។ តាំងពីនោះមក លោកកាលនឹងពោលធម្មកថាដល់បរិស័ទទាំង ៤ ច្រើនក្តី តិចក្តី ប្រដាប់ដោយឧបមា និងហេតុទាំងឡាយ ទើបពោលចេញយ៉ាងវិចិត្រតែម្តង ។ គ្រានោះ កាលលោកសម្តែងសូត្រប្រដាប់ដោយបញ្ហា ១៥ ប្រការ ដល់ព្រះរាជាបាយាសិ ព្រះសាស្តាទ្រង់ធ្វើព្រះសូត្រនោះឲ្យជាអត្ថុប្បត្តិ ទើបទ្រង់ស្ថាបនាលោកទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលលើពួកភិក្ខុសាវកអ្នកពោលធម៌ដ៏វិចិត្រក្នុងព្រះសាសនានេះឯង ។

ចប់អដ្ឋកថា សូត្រទី ៩

# អដ្ឋកថាសូត្រទី ១០

## ប្រវត្តិព្រះមហាកោដ្ឋិតត្ថេរ

*ក្នុងសូត្រទី ១០ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[១៤៨] *ដោយបទថា* ***បដិសម្ភិទប្បត្តានំ*** *ទ្រង់សម្តែងថា ព្រះមហាកោដ្ឋិតត្ថេរៈ ជាកំពូលលើពួកភិក្ខុសាវកអ្នកសម្រេចបដិសម្ភិទា ៤ ។ ពិតណាស់ ព្រះថេរៈរូបនេះ កាលចូលទៅរកព្រះមហាសាវក អ្នកមានឈ្មោះបោះសំឡេងសួរបញ្ហាក្តី កាលចូលទៅគាល់ព្រះទសពលទូលសួរបញ្ហាក្តី រមែងសួរបញ្ហាក្នុងរឿងបដិសម្ភិទាទាំងឡាយប៉ុណ្ណោះ ព្រោះខ្លួនជាអ្នកជំនាញក្នុងបដិសម្ភិទាទាំងឡាយដូច្នោះ លោកទើបឈ្មោះថា ជាកំពូលលើពួកភិក្ខុសាវកអ្នកសម្រេចបដិសម្ភិទាដោយអំណាចភាវៈជាអ្នកជំនាញនេះ ។ ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលនឹងពោលតាមលំដាប់ ដូច្នេះ ៖*

*ពិតណាស់ ព្រះថេរៈរូបនេះ កើតក្នុងត្រកូលដែលមានភោគសម្បត្តិច្រើនក្នុងក្រុងហង្សវតី គ្រាព្រះពុទ្ធព្រះនាមថា* ***បទុមុត្តរ*** *។ សម័យតៗ មក កំពុងស្តាប់ធម្មកថារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូប ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលលើពួកភិក្ខុសាវកអ្នកសម្រេចបដិសម្ភិទា ទើបធ្វើ*

កុសលកម្មឲ្យក្រៃលែងឡើងទៅ ប្រាថ្នាតំណែងនោះ ។ ធ្វើកុសលរហូតអស់ជីវិត វិលវល់នៅក្នុងទេវតា និងមនុស្ស កើតក្នុងត្រកូលព្រាហ្មណ៍ក្រុងសាវត្ថី ក្នុងពុទ្ធុប្បាទកាលនេះ ។ ពួកញាតិបានដាក់នាមគេថា **កោដ្ឋិតមាណព** ។ កាលគេចម្រើនវ័យ ក៏រៀនវេទទាំងបី ថ្ងៃមួយ ស្តាប់ធម្មកថារបស់ព្រះសាស្តា បានសទ្ធាហើយ ក៏បួស ។ តាំងពីបួសហើយ លោកព្យាយាមក្នុងវិបស្សនា ក៏បានសម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទាទាំងឡាយ ជាអ្នកជំនាញក្នុងបដិសម្ភិទាទាំងឡាយប៉ុណ្ណោះអស់កាលជានិច្ច កាលសួរបញ្ហា ក៏តែងតែសួរក្នុងបដិសម្ភិទាទាំងឡាយប៉ុណ្ណោះ ។ តមកខាងក្រោយ ព្រះសាស្តាទ្រង់ធ្វើមហាវេទល្លសូត្រ ឲ្យជាអត្ថុប្បត្តិ ទើបទ្រង់ស្ថាបនាលោកទុកក្នុងតំណែងឯតទគ្គៈ កំពូលលើពួកភិក្ខុសាវកអ្នកសម្រេចបដិសម្ភិទានោះឯង ។

ចប់អដ្ឋកថា សូត្រទី ១០

## ចប់វគ្គទី ៣

រួមអដ្ឋកថាក្នុងវគ្គនេះមាន ១០ អដ្ឋកថា

# វគ្គទី ៤

## អដ្ឋកថាសូត្រទី ១

## ប្រវត្តិព្រះអានន្ទត្ថេរ

*វគ្គទី ៤ សូត្រទី ១ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[១៨៩] *គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា* ***ពហុស្សុតានំ*** *ជាដើមដូច្នេះ ។ សូម្បីព្រះថេរៈរូបដទៃៗ ដែលជាពហុស្សូត ទ្រទ្រង់នូវធិតិ និងជាឧបដ្ឋាកក៏មានហើយ ចំណែកព្រះអានន្ទនេះ សិក្សាព្រះពុទ្ធវចនៈមានជំហរនៅក្នុងបរិយត្តិដូចអ្នករក្សាឃ្លាំង ក្នុងសាសនារបស់ព្រះទសពល ព្រោះហេតុនោះ លោកទើបឈ្មោះថា ជាកំពូលលើពួកភិក្ខុសាវកអ្នកជាពហុស្សូត ។ មួយទៀត សតិដែលបានសិក្សាព្រះពុទ្ធវចនៈហើយចងចាំទុករបស់ព្រះថេរៈនេះប៉ុណ្ណោះ ក៏មានកំលាំងជាងព្រះថេរៈដទៃៗ ព្រោះហេតុនោះ លោកទើបឈ្មោះថា ជាកំពូលលើពួកភិក្ខុជាសាវកអ្នកមានសតិជាគ្រឿងចាំ ។ មួយទៀត ព្រះអានន្ទនេះឯង លោកទទួលយកតែមួយបទ ក៏យល់ន័យបាន ៦ ម៉ឺនបទ ចាំបានគ្រប់បទ ដោយទំនងដែលព្រះសាស្តាត្រាស់ទុកទាំងឯង ព្រោះហេតុនោះ លោកទើបឈ្មោះថា ជាកំពូលលើពួកភិក្ខុសាវកអ្នកមានគតិ ។*

មួយទៀត សេចក្តីព្យាយាមសិក្សា សេចក្តីព្យាយាមស្វាធ្យាយ សេចក្តីព្យាយាមទ្រទ្រង់ចាំ និងសេចក្តីព្យាយាមឧបដ្ឋាកព្រះសាស្តា របស់ព្រះអានន្ទនោះប៉ុណ្ណោះ ដែលភិក្ខុដទៃៗ ប្រៀបមិនបាន ព្រោះហេតុនោះ លោកទើបឈ្មោះថា ជាកំពូលលើពួកភិក្ខុសាវកអ្នកមានធិតិ ។ មួយទៀត ព្រះអានន្ទរូបនេះ កាលឧបដ្ឋាកព្រះតថាគត ក៏មិនឧបដ្ឋាកដោយអាការឧបដ្ឋាកដូចពួកភិក្ខុឧបដ្ឋាកដទៃៗ ព្រោះថា ពួកភិក្ខុដែលឧបដ្ឋាកអង្គដទៃៗ កាលឧបដ្ឋាកព្រះតថាគត ឧបដ្ឋាកមិនបានយូរផង ទាំងឧបដ្ឋាកមិនយល់ដល់ព្រះហឫទ័យរបស់ព្រះសម្ពុទ្ធបានផង ។ ចំណែកព្រះថេរៈ ចាប់តាំងពីថ្ងៃទីបានតំណែងជាឧបដ្ឋាក ក៏ជាអ្នកប្រារព្ធសេចក្តីព្យាយាម ឧបដ្ឋាកកំណត់ព្រះហឫទ័យរបស់ព្រះតថាគតទុកបាន ព្រោះហេតុនេះ លោកទើបឈ្មោះថា ជាកំពូលលើពួកភិក្ខុសាវកអ្នកឧបដ្ឋាក ។ ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលនឹងពោលតាមលំដាប់ដូច្នេះ ៖

បានឮថា ក្នុងកប្បទីមួយសែនកប្ប រាប់ពីកប្បនេះទៅ ព្រះសាស្តាព្រះនាមថា **បទុមុត្តរៈ** ឧប្បត្តិក្នុងលោក ព្រះអង្គមានព្រះនគរឈ្មោះថា ហង្សវតី មានព្រះរាជបិតាព្រះនាមថា **នន្ទៈ** ព្រះរាជមាតាជាព្រះទេវីព្រះនាមថា **សុមេធា** មានព្រះពោធិសត្វព្រះនាមថា **ឧត្តរកុមារ** ។ ព្រះអង្គចេញអភិនេស្រ្កម៍ ទ្រង់ព្រះផ្នួសក្នុងថ្ងៃព្រះរាជឱរសប្រសូត្រ ទ្រង់ប្រកបសេចក្តីព្យាយាមរឿយៗ ហើយ

ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណតាមលំដាប់ ទ្រង់ថ្លែងព្រះពុទ្ធឧទានថា **អនេក-ជាតិសំសារំ** ជាដើម ប្រថាប់ត្រង់ពោធិបល្ល័ង្ក កន្លងវេលាទៅ ៧ ថ្ងៃ ទ្រង់បំណង ប្រថាប់ឈរដោយដាក់ព្រះបាទត្រង់ផែនដី គ្រានោះ ផ្កាបទុមមានទំហំដែលបាន ពោលទុកហើយក្នុងខាងក្រោយ ផុសអំពីផែនដីឡើងទទួល ព្រោះសំដៅដល់ផ្កា បទុមនោះ ព្រះដ៏មានព្រះភាគ ទើបប្រាកដព្រះនាមថា **បទុមុត្តរៈ** នុ៎ះឯង ។ ព្រះអង្គមានព្រះអគ្គសាវកនាមថា **ទេវិល** មួយអង្គ **ចុល្លជាត** មួយអង្គ , មាន គូព្រះអគ្គសាវិកានាមថា **អមិតា** មួយអង្គ **អសមា** មួយអង្គ , ទ្រង់មានព្រះ ឧបដ្ឋាកនាមថា **សុមនៈ** ។ ព្រះបទុមុត្តរទ្រង់មានព្រះភាគ កាលទ្រង់សង្គ្រោះ ព្រះពុទ្ធបិតា មានភិក្ខុមួយសែនរូបជាបរិវារ ប្រថាប់នៅក្នុងក្រុងហង្សវតីរាជ-ធានី ។ បំណែកព្រះកនិដ្ឋភាតារបស់ព្រះអង្គព្រះនាមថា **សុមនកុមារ** ។ ព្រះរាជា ព្រះរាជទានស្រុកសួយពីរពាន់យោជន៍ រាប់អំពីក្រុងហង្សវតី ដល់សុមនរាជ-កុមារនោះ ។ សុមនរាជកុមារនោះ ស្ដេចមកគាល់ព្រះរាជបិតា និងព្រះសាស្ដា ជាគ្រាៗ ។

តមកថ្ងៃមួយ ជនបទជាយដែនមានកើតការក្បត់ សុមនរាជកុមារ ទើប បញ្ជូនដំណឹងថ្វាយព្រះរាជា ព្រះរាជាទ្រង់ឲ្យប្រាប់ទៅថា បិតាតាំងបុត្តទុកក្នុង តំណែងនោះព្រោះហេតុអ្វី សុមនរាជកុមារបានបង្ក្រាបអំពើក្បត់នោះស្ងប់ហើយ

ទើបបញ្ជូនដំណឹងទៅក្រាបទូលព្រះរាជាថា មហាបពិត្រ ជនបទស្ងប់ហើយព្រះអង្គ ។ ព្រះរាជាទ្រង់ត្រេកអរ ត្រាស់ថា បុត្តសំឡាញ់ចូរប្រញាប់មក ។ សុមនរាជកុមារនោះ មានអាមាត្យប្រមាណមួយពាន់នាក់ ទ្រង់ប្រឹក្សានឹងអាមាត្យទាំងនោះក្នុងវាងផ្លូវថា ព្រះរាជបិតារបស់យើងទ្រង់ត្រេកអរ បើទ្រង់ព្រះរាជទានពរដល់យើង យើងនឹងទទួលអ្វី ។ លំដាប់នោះ អាមាត្យពួកខ្លះទូលព្រះរាជកុមារថា ទ្រង់ទទួលដំរី សេះ ជនបទ រតនៈ ៧ ប្រការ , ពួកខ្លះទៀត ទូលថា ព្រះអង្គជារាជឱរសរបស់ស្តេចផែនដី ឯទ្រព្យ ព្រះអង្គបានមិនលំបាក តែទ្រព្យនោះសូម្បីបានហើយ ក៏នឹងត្រូវលះបង់ទៅទាំងអស់ ចំណែកបុណ្យទើបព្រះអង្គនាំទៅបាន ព្រោះដូច្នោះ កាលសម្មតិទេពព្រះរាជទានពរ សូមព្រះអង្គទ្រង់ទទួលពរ គឺ ការឧបដ្ឋាកព្រះបទុមុត្តរព្រះមានព្រះភាគ រហូតដល់អស់ត្រៃមាសចុះព្រះអង្គ ។ ព្រះរាជកុមារនោះត្រាស់បង្គាប់ថា ពួកលោកជាកល្យាណមិត្តរបស់យើង ពួកលោកញុាំងគំនិតយ៉ាងនេះឲ្យកើតដល់យើង យើងនឹងធ្វើយ៉ាងនោះ ហើយស្តេចទៅថ្វាយបង្គំព្រះរាជបិតា ត្រូវព្រះរាជបិតាឱបរិត នឹងទ្រង់ថើប ហើយត្រាស់ថា បុត្តសំឡាញ់ បិតានឹងឲ្យពរដល់អ្នក ដូច្នេះ ទើបក្រាបទូលថា មហាបពិត្រ ខ្ញុំព្រះអង្គ បំណងនឹងឧបដ្ឋាកព្រះដ៏មានព្រះភាគដោយបច្ច័យ ៤ រហូតអស់ត្រៃមាស ដើម្បីធ្វើជីវិតឲ្យមានប្រយោជន៍ ព្រះពុទ្ធបិតាត្រាស់ថា បុត្ត បិតា

មិនអាចឲ្យពរនេះដល់កូនបានទេ បិតានឹងឲ្យពរដទៃដល់កូន ។ ព្រះរាជកុមារក្រាបទូលថា មហាបពិត្រ ធម្មតាថា ក្សត្រិយ៍មិនត្រាស់ពាក្យពីរទេ សូមព្រះអង្គមេត្តាព្រះរាជទានពរនេះដល់ខ្ញុំព្រះអង្គ ពរដទៃខ្ញុំព្រះអង្គមិនត្រូវការឡើយ ព្រះអង្គ ។ ព្រះពុទ្ធបិតាត្រាស់ថា ធម្មតាថា ព្រះហឫទ័យរបស់ព្រះពុទ្ធទាំងឡាយដឹងបានលំបាក ប្រសិនបើព្រះដ៏មានព្រះភាគទ្រង់មិនពេញព្រះទ័យ កាលបិតាឲ្យពរបុត្តហើយ តើនឹងមានប្រយោជន៍អ្វី ។ ព្រះរាជកុមារក្រាបទូលថា ប្រពៃហើយ មហាបពិត្រ ខ្ញុំព្រះអង្គនឹងគប្បីជ្រាបព្រះហឫទ័យរបស់ព្រះដ៏មានព្រះភាគដូច្នេះ ហើយស្តេចទៅកាន់ព្រះវិហារ សម័យនោះ ព្រះដ៏មានព្រះភាគសោយស្រេចហើយ ស្តេចយាងចូលព្រះគន្ធកុដិ ទើបព្រះរាជកុមារស្តេចទៅកាន់សំណាក់ភិក្ខុទាំងឡាយដែលប្រជុំគ្នាក្នុងសាលា ។ ភិក្ខុទាំងនោះ ទូលសួរព្រះរាជកុមារថាថ្វាយព្រះពរ ព្រះរាជបុត្រ ព្រះអង្គស្តេចមកព្រោះហេតុអ្វី ។ ព្រះរាជកុមារត្រាស់ថា ដើម្បីគាល់ព្រះដ៏មានព្រះភាគ មេត្តាចង្អុលប្រាប់ព្រះដ៏មានព្រះភាគដល់ខ្ញុំផងចុះ ពួកភិក្ខុទូលថា ព្រះរាជបុត្រ ពួកអាត្មាភាពចូលគាល់ព្រះសាស្តាក្នុងវេលាដែលប៉ុនប្រាថ្នាមិនបានទេ ត្រាស់សួរថា នរណាហ្ន៎នឹងគាល់បានលោកម្ចាស់ ។ ទូលតបថា ថ្វាយព្រះពរ ភិក្ខុនាមថា សុមនត្ថេរៈ ។ ព្រះរាជកុមារត្រាស់សួរដល់ទីកន្លែងរបស់ព្រះថេរៈថា ព្រះថេរៈនោះនៅទីណា លោកម្ចាស់ ។ ទើបស្តេច

យានទៅ ត្រាស់ថា លោកម្ចាស់ ខ្ញុំបំណងនឹងគាល់ព្រះដ៏មានព្រះភាគ សូមមេត្តា បង្ហាញប្រាប់ព្រះដ៏មានព្រះភាគដល់ខ្ញុំផងចុះ កាលព្រះរាជកុមារកំពុងទតឃើញហើយនុ៎ះឯង ព្រះថេរៈក៏ចូលអាបោកសិណ អធិដ្ឋានផែនដីធំឲ្យទៅជាទឹក មុជចុះក្នុងផែនដី ទៅប្រាកដត្រង់ព្រះគន្ធកុដិរបស់ព្រះសាស្ដា គ្រានោះ ព្រះដ៏មានព្រះភាគត្រាស់ចំពោះព្រះសុមនត្ថេរថា សុមនៈ ហេតុអ្វី អ្នកទើបមក លោកទូលថា ព្រះរាជបុត្រស្ដេចមកបំណងនឹងគាល់ព្រះដ៏មានព្រះភាគ ព្រះអង្គ ។ ទ្រង់ត្រាស់ថា នែភិក្ខុ បើដូច្នោះ អ្នកចូរចាត់ចែងអាសនៈចុះ កាលព្រះរាជកុមារកំពុងទតឃើញនុ៎ះឯង ព្រះថេរៈក៏កាន់យកពុទ្ធាសនៈ មុជចុះត្រង់ព្រះគន្ធកុដិ ទៅប្រាកដក្រៅបរិវេណ ចាត់ចែងអាសនៈទុកត្រង់បរិវេណ ព្រះរាជកុមារ ទ្រង់ឃើញហេតុគួរអស្ចារ្យទាំងពីរនេះហើយ ទ្រង់ត្រិះរិះថា ភិក្ខុរូបនេះធំណាស់ហ្ន៎ ។ សូម្បីព្រះដ៏មានព្រះភាគ ក៏ស្ដេចចេញចាកព្រះគន្ធកុដិហើយ ប្រថាប់លើអាសនៈដែលចាត់ចែងទុក កាលត្រាស់សួរថា ព្រះរាជបុត្រ ព្រះអង្គស្ដេចមកកាលណា ព្រះរាជកុមារទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលព្រះអង្គស្ដេចចូលព្រះគន្ធកុដិ តែភិក្ខុទាំងឡាយប្រាប់ថា លោកចូលគាល់មិនបានក្នុងខណៈដែលប៉ុនប្រាថ្នា ទើបប្រាប់ខ្ញុំព្រះអង្គទៅកាន់សំណាក់របស់ព្រះថេរៈ ចំណែកព្រះថេរៈពោលដោយពាក្យមួយៗ ព្រះថេរៈនេះជាទីស្និទ្ធស្នាលក្នុងព្រះសាសនារបស់ព្រះអង្គឬ ព្រះអង្គ ។

ទ្រង់ត្រាស់ថា ពិតហើយ ព្រះរាជកុមារ ភិក្ខុរូបនេះ ជាទីស្និទ្ធស្នាលក្នុងសាសនា របស់តថាគត ។ ទូលថា ភិក្ខុរូបនេះជាអ្វី ទើបជាទីស្និទ្ធស្នាលក្នុងព្រះសាសនា របស់ព្រះអង្គ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ជាអ្នកបានថ្វាយទាន រក្សាសីល ធ្វើឧបោសថកម្មនឹងឯង ព្រះរាជកុមារ ព្រះរាជកុមារទូលថា បពិត្រព្រះដ៏មាន-ព្រះភាគ ខ្ញុំព្រះអង្គក៏ប្រាថ្នាជាអ្នកស្និទ្ធស្នាលក្នុងព្រះពុទ្ធសាសនា ដូចព្រះថេរៈ ស្អែកនេះ សូមព្រះអង្គមេត្តាទ្រង់ទទួលភិក្ខារបស់ខ្ញុំព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ទទួលដោយតុណ្ហីភាព ព្រះរាជកុមារស្តេចទៅកាន់ទីប្រថាប់របស់ព្រះអង្គ បាន ចាត់ចែងសក្ការៈយ៉ាងធំរហូតអស់មួយយប់ទល់ភ្លឺ បានថ្វាយខន្ធវារភត្ត (ភិក្ខា ដែលថ្វាយព្រះសាស្តាក្នុងទីដែលតាំងជំរំ) ថ្ងៃទី ៧ ថ្វាយបង្គំព្រះសាស្តាទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានទទួលពរ គឺ ការឧបដ្ឋាកព្រះអង្គរហូតអស់ ត្រៃមាសខាងក្នុងវស្សា អំពីសំណាក់ព្រះរាជបិតា សូមព្រះអង្គទ្រង់មេត្តាទទួល ប្រថាប់ចាំវស្សារហូតអស់ត្រៃមាស ដើម្បីខ្ញុំព្រះអង្គផងចុះ ព្រះអង្គ ។ ព្រះដ៏-មានព្រះភាគទ្រង់ពិចារណាមើលថា ប្រយោជន៍ដោយប្រការនោះ មានឬទេហ្ន៎ ទ្រង់ក៏ឃើញថាមាន ទើបត្រាស់ថា ម្នាលរាជកុមារ ព្រះតថាគតទាំងឡាយរមែង អភិរម្យត្រេកអរក្នុងផ្ទះស្ងាត់ ព្រះរាជកុមារត្រាស់ថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គដឹងហើយ បពិត្រព្រះសុគត ខ្ញុំព្រះអង្គដឹងហើយ ហើយទូលថា បពិត្រ

ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមថ្វាយបង្គំទៅមុន នឹងឲ្យគេសាងព្រះវិហារ កាលខ្ញុំព្រះអង្គបញ្ជូនអ្នកទៅទូល សូមព្រះអង្គមេត្តាស្តេចយាងមក ព្រមដោយភិក្ខុមួយសែនរូប ព្រះរាជកុមារកាន់យកការប្តេជ្ញាហើយ ស្តេចក៏ទៅកាន់សំណាក់ព្រះរាជបិតា ក្រាបទូលថា មហាបពិត្រ ព្រះដ៏មានព្រះភាគ ប្រទានប្តេជ្ញាដល់ខ្ញុំព្រះអង្គហើយ កាលខ្ញុំព្រះអង្គបញ្ជូនអ្នកមកក្រាបទូល សូមព្រះបិតាអនុគ្រោះទូលដល់ព្រះដ៏មានព្រះភាគផង ព្រះកុមារថ្វាយបង្គំព្រះរាជបិតាហើយ ស្តេចចេញទៅ ទ្រង់សាងវិហារគ្រប់ៗ ចម្ងាយផ្លូវមួយយោជន៍ ស្តេចទៅអស់ចម្ងាយផ្លូវពីរពាន់យោជន៍ គ្រាស្តេចទៅដល់ហើយ ទ្រង់បានជ្រើសរើសទីតាំងព្រះវិហារក្នុងនគររបស់ព្រះអង្គ ទ្រង់ឃើញឧទ្យានរបស់កុដុម្ពិក: (សេដ្ឋី) ឈ្មោះ សោភ: ទ្រង់ទិញដោយទ្រព្យមួយសែន ចំណាយព្រះរាជទ្រព្យមួយសែន ទ្រង់ឲ្យសាងព្រះវិហារក្នុងឧទ្យាននោះ ទ្រង់ឲ្យសាងព្រះគន្ធកុដិសម្រាប់ព្រះដ៏មានព្រះភាគ និងកុដិទីពួនសម្ងំ និងមណ្ឌបជាទីសម្រាកពេលយប់ និងពេលថ្ងៃ សម្រាប់ពួកភិក្ខុដទៃទៀត ចាត់ចែងសាងកំពែងលោមព័ទ្ធ និងទ្វារ ហើយទ្រង់បញ្ជូនមនុស្សទៅកាន់សំណាក់ព្រះរាជបិតា ក្រាបទូលថា កិច្ចរបស់ខ្ញុំព្រះអង្គសម្រេចហើយ សូមទ្រង់បញ្ជូនព្រះសាស្តាមកចុះ ព្រះរាជបិតា ញុំាងព្រះដ៏មានព្រះភាគសោយហើយទូលថា បពិត្រព្រះដ៏មានព្រះភាគ កិច្ចរបស់សុមន:សម្រេចហើយ គេមានបំណង

ដល់ការយាងទៅរបស់ព្រះអង្គ ព្រះអង្គ ។ ព្រះដ៏មានព្រះភាគ មានភិក្ខុមួយសែនរូបហែហម ប្រថាប់នៅក្នុងវិហារទាំងឡាយ គ្រប់ៗ ចម្ងាយមួយយោជន៍ បានស្តេចទៅ ព្រះរាជកុមារទ្រង់ជ្រាបថា ព្រះសាស្តាស្តេចកំពុងយាងមក ទ្រង់ក៏ចេញទៅទទួលអស់ចម្ងាយផ្លូវមួយយោជន៍ ទ្រង់បូជាដោយគ្រឿងក្រអូប និងផ្កាឈើជាដើម យាងព្រះមានព្រះភាគចូលទៅក្នុងព្រះវិហារ ទ្រង់បង្អោនថ្វាយព្រះវិហារថា

*សតសហស្សេន មេ កីតំ សតសហស្សេន មាបិតំ*

*សោភនំ នាម ឧយ្យានំ បដិគ្គណ្ហ មហាមុនិ ។*

បពិត្រព្រះមហាមុនី សូមព្រះអង្គមេត្តាទទួលឧទ្យាន ឈ្មោះ **សោភនៈ** ដែលខ្ញុំព្រះអង្គទិញមកដោយទ្រព្យមួយសែន សាងវិហារដោយទ្រព្យមួយសែនផងចុះ ។

ព្រះរាជកុមារនោះ ក្នុងថ្ងៃចូលវស្សា ថ្វាយទានហើយ ហៅបុត្រភរិយារបស់ខ្លួន និងពួកអាមាត្យមក ហើយត្រាស់បង្គាប់ថា ព្រះសាស្តាស្តេចមកកាន់សំណាក់របស់ពួកយើងក្នុងផ្លូវដ៏ឆ្ងាយ ក៏ព្រះតថាគតរបស់យើង ទ្រង់ធ្ងន់ក្នុងធម៌ មិនឃើញដល់អាមិស ព្រោះដូច្នោះ យើងនឹងស្លៀកដណ្តប់សំពត់ពីរផ្ទាំងរហូតអស់ត្រៃមាសនេះ សមាទានសីល ១០ រស់នៅក្នុងទីនេះឯង ពួកលោកគប្បីថ្វាយទានរហូតអស់ត្រៃមាស ដោយទំនងនេះ ចំពោះព្រះខីណាស្រពមួយសែនរូប

សុមនរាជកុមារនោះ ប្រថាប់នៅ ក្នុងឋានៈដែលប្រហាក់ប្រហែលគ្នានឹងទីនៅរបស់ព្រះសុមនត្ថេរ ឃើញកិច្ចការគ្រប់យ៉ាង ដែលព្រះថេរៈធ្វើវត្តចំពោះព្រះមានព្រះភាគ ត្រិះរិះថា ព្រះថេរៈនេះ ជាទីស្និទ្ធស្នាលក្នុងព្រះតថាគត យើងគួរប្រាថ្នាតំណែងរបស់ព្រះថេរៈនោះ កាលជិតដល់ថ្ងៃបវារណាចេញវស្សា ទើបស្តេចចូលទៅកាន់ស្រុក ថ្វាយមហាទាន ៧ ថ្ងៃ , ថ្ងៃទី ៧ ទ្រង់ដាក់ត្រៃចីវរទៀបបាទាភិក្ខុមួយសែនរូប ថ្វាយបង្គំព្រះសាស្តាដោយបញ្ចង្គប្រតិស្ឋាន ទូលថាបពិត្រព្រះអង្គដ៏ចម្រើន បុណ្យនេះឯង ដែលខ្ញុំព្រះអង្គធ្វើមក តាំងពីថ្វាយខន្ធវារ-កត្តមក ៧ ថ្ងៃ បុណ្យនោះ ខ្ញុំព្រះអង្គមិនបានប្រាថ្នាសួគ៌សម្បត្តិ មិនបានប្រាថ្នាព្រហ្មសម្បត្តិ តែខ្ញុំព្រះអង្គប្រាថ្នាជាឧបដ្ឋាករបស់ព្រះពុទ្ធ ទើបធ្វើ មួយទៀតបពិត្រព្រះដ៏មានព្រះភាគ សូម្បីខ្ញុំព្រះអង្គ ក៏នឹងជាឧបដ្ឋាកដូចព្រះសុមនត្ថេរក្នុងអនាគតកាល ព្រះសាស្តាទ្រង់ជ្រាបថា មិនមានអន្តរាយដល់ព្រះរាជកុមារនោះទើបទ្រង់ព្យាករណ៍ ហើយស្តេចយាងត្រឡប់ទៅ ព្រះរាជកុមារទ្រង់ស្តាប់ហើយទ្រង់ត្រិះរិះថា ក៏ធម្មតាព្រះពុទ្ធទាំងឡាយ មិនត្រាស់ជាពាក្យពីរ ក្នុងថ្ងៃទីពីរក៏បានកាន់បាត្រ ចីវរ ហាក់ដូចជារបស់ព្រះគោតមសម្ពុទ្ធ តាមស្តេចទៅអំពីខាងក្រោយ ។

ព្រះរាជកុមារនោះ ក្នុងពុទ្ធុប្បាទកាលនោះ ថ្វាយទានហើយកើតក្នុងសួគ៌

មួយសែនឆ្នាំ គ្រាព្រះពុទ្ធព្រះនាមថា **កស្សប** បានថ្វាយសំពត់ដណ្តប់ ដើម្បីទ្រ បាត្រដល់ព្រះថេរៈដែលត្រាច់ទៅបិណ្ឌបាត បានធ្វើការបូជា កើតក្នុងសួគ៌ទៀត ចុតិពីភពនោះ បានជាព្រះរាជាក្រុងពារាណសី ស្តេចឡើងកាន់ប្រាសាទដ៏ប្រសើរ ទតឃើញព្រះបច្ចេកពុទ្ធ ៨ អង្គ ដែលមកពីភ្នំគន្ធមាទន៍ ហើយបានឲ្យគេនិមន្ត ព្រះបច្ចេកពុទ្ធទាំងនោះមកដើម្បីថ្វាយចង្ហាន់ ទ្រង់ឲ្យសាងបណ្ណសាលា ៨ ខ្នង សម្រាប់ព្រះបច្ចេកពុទ្ធទាំងនោះ ក្នុងឧទ្យានមង្គលរបស់ព្រះអង្គ ទ្រង់តាក់តែង តាំងធ្វើដោយរតនៈសុទ្ធ គ្រែ និងស្បែកជើងធ្វើដោយកែវមណី បានធ្វើការឧប- ដ្ឋាកអស់មួយម៉ឺនឆ្នាំ ។ ទាំងនេះជាឋានៈដែលប្រាកដហើយ ក៏លោកថ្វាយទាន រហូតអស់សែនកប្ប កើតក្នុងសួគ៌ជាន់តុសិត ជាមួយព្រះពោធិសត្វរបស់យើង ចុតិចាកជាន់តុសិតនោះហើយ ក៏កើតក្នុងត្រកូលរបស់ព្រះបាទអមិតោទនសក្យៈ កាលលោកកើតហើយ បានធ្វើព្រះញាតិទាំងមូលរបស់លោកឲ្យសប្បាយរីករាយ ព្រោះដូច្នោះ ព្រះញាតិទើបដាក់ព្រះនាមដល់លោកថា **អានន្ទៈ** ។ កាលព្រះដ៏- មានព្រះភាគស្តេចចេញអភិនេស្ក្រម៍តាមលំដាប់ ទ្រង់សម្រេចព្រះសម្មាសម្ពោ- ធិញ្ញាណហើយ ស្តេចមកកាន់ក្រុងកបិលពស្តុជាលើកដំបូង ពេលស្តេចចេញ ចាកក្រុងកបិលពស្តុនោះ ពួកព្រះរាជកុមារបានបព្វជ្ជាដើម្បីជាបរិវាររបស់ព្រះដ៏- មានព្រះភាគ លោកក៏ចេញបួសក្នុងសំណាក់ព្រះសាស្តា ព្រមជាមួយពួកសក្យ-

កុមារ មានព្រះភទ្ទិយៈជាដើម មិនយូរប៉ុន្មាន បានស្តាប់ធម្មកថារបស់ព្រះបុណ្ណ-មន្តានីបុត្រ ក៏តាំងនៅក្នុងសោតាបត្តិផល ។

ក៏សម័យនោះឯង ព្រះដ៏មានព្រះភាគទ្រង់មានឧបដ្ឋាកមិនប្រចាំអស់ ២០ វស្សា ក្នុងបឋមពោធិកាល ពេលខ្លះព្រះនាគសមាលៈ កាន់បាត្រចីវរតាមស្តេច ពេលខ្លះព្រះនាគិតៈ ពេលខ្លះព្រះឧបវាណៈ ពេលខ្លះព្រះសុនក្ខត្តៈ ពេលខ្លះព្រះចុន្ទសមណុទ្ទេស ពេលខ្លះព្រះសាគតៈ ពេលខ្លះព្រះរាធៈ ពេលខ្លះព្រះមេឃិយៈ បណ្តាព្រះឧបដ្ឋាកមិនប្រចាំទាំងនោះ គ្រាមួយ ព្រះដ៏មានព្រះភាគស្តេចយាងផ្លូវឆ្ងាយជាមួយព្រះនាគសមាលត្ថេរ ដល់ផ្លូវបែកជាពីរ ព្រះថេរៈចុះចាកពីផ្លូវ ទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គនឹងទៅផ្លូវនេះ លំដាប់នោះព្រះដ៏មានព្រះភាគត្រាស់នឹងលោកថា មកភិក្ខុ យើងនឹងទៅជាមួយគ្នាផ្លូវនេះ ព្រះថេរៈទូលថា បពិត្រព្រះដ៏មានព្រះភាគ សូមព្រះអង្គទ្រង់កាន់យកផ្លូវព្រះអង្គចុះ ខ្ញុំព្រះអង្គនឹងទៅផ្លូវនេះ ហើយផ្តើមនឹងដាក់បាត្រចីវរចុះត្រង់ផែនដី ព្រះមាន-ព្រះភាគត្រាស់ថា យកមកភិក្ខុ ទ្រង់ទទួលបាត្រចីវរហើយ ស្តេចទ្រង់ដំណើរទៅ កាលភិក្ខុរូបនោះធ្វើដំណើរទៅតាមខ្លួនឯង ពួកចោរក៏ប្លន់យកបាត្រចីវរ និងវាយបែកសីរសៈ លោកគិតថា ឥឡូវនេះ ក៏មានតែព្រះដ៏មានព្រះភាគជាទីពឹងរបស់យើងបាន មិនមានអ្នកដទៃឡើយ ហើយមកកាន់សំណាក់ព្រះដ៏មានព្រះភាគទាំង

ដែលលោហិតហូរ កាលព្រះដ៏មានព្រះភាគត្រាស់សួរថា មានរឿងអ្វីមែនទេភិក្ខុ ក៏ទូលរឿងរ៉ាវថ្វាយ ព្រះដ៏មានព្រះភាគត្រាស់លួងលោមថា កុំគិតឡើយ ភិក្ខុ តថាគតហាមអ្នក ក៏ព្រោះហេតុយ៉ាងនោះឯង ។ មួយទៀត សម័យមួយ ព្រះ-មានព្រះភាគស្តេចទៅកាន់ស្រុកជន្តុគ្រាម ជិតបាចិនវង្សមិគទាយវ័ន ជាមួយព្រះមេឃិយត្ថេរ សូម្បីក្នុងទីនោះ ព្រះមេឃិយៈត្រាច់បិណ្ឌបាតទៅក្នុងជន្តុគ្រាម ឃើញចម្ការស្វាយគួរជ្រះថ្លា ត្រង់ច្រាំងទន្លេ ក៏ទូលថា បពិត្រព្រះដ៏មានព្រះភាគ សូមព្រះអង្គមេត្តាទទួលបាត្រចីវររបស់ព្រះអង្គចុះ ខ្ញុំព្រះអង្គនឹងធ្វើសមណធម៌ត្រង់ព្រៃស្វាយនោះ សូម្បីត្រូវព្រះដ៏មានព្រះភាគទ្រង់ហាមបីដង ក៏នៅតែទៅ ត្រូវអកុសលវិតក្កៈគ្របសង្កត់ ក៏ត្រឡប់មកទូលរឿងរ៉ាវថ្វាយ ព្រះដ៏មានព្រះភាគត្រាស់នឹងលោកថា តថាគតកំណត់ដល់ហេតុរបស់អ្នកយ៉ាងនេះឯង ទើបហាមហើយស្តេចពុទ្ធដំណើរទៅកាន់ក្រុងសាវត្ថីតាមលំដាប់ ។

នៅឯក្រុងសាវត្ថីនោះ ព្រះដ៏មានព្រះភាគប្រថាប់គង់លើពុទ្ធាសនៈដ៏ប្រសើរ ដែលគេចាត់ចែងទុកត្រង់បរិវេណព្រះគន្ធកុដិ ដែលមានភិក្ខុសង្ឃហែហមហើយ ហៅភិក្ខុទាំងឡាយមក ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតចាស់ហើយ ភិក្ខុពួកខ្លះពោលថា ខ្ញុំព្រះអង្គនឹងទៅផ្លូវនេះហើយ ក៏ចេញទៅផ្លូវមួយទៀត ពួកខ្លះក៏ដាក់បាត្រចីវររបស់តថាគតទុកលើផែនដី ពួកអ្នកបួរជ្រើស

ពើស ភិក្ខុជាឧបដ្ឋាកប្រចាំឲ្យដល់តថាគតចុះ ។ ភិក្ខុទាំងឡាយកើតធម្មសង្វេគ ។ គ្រានោះ ព្រះសារីបុត្រក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គកាលប្រាថ្នាជួបព្រះអង្គ តែមួយព្រះអង្គ ទើបបំពេញបារមីទាំងឡាយអស់មួយអសង្ខេយ្យ និងសែនកប្ប អ្នកមានបញ្ញាច្រើន ដូចខ្ញុំព្រះអង្គ ឈ្មោះថា ជាឧបដ្ឋាក មិនគួរឬ ខ្ញុំព្រះអង្គនឹងឧបដ្ឋាក ព្រះដ៏មាន-ព្រះភាគត្រាស់ហាមលោកថា កុំឡើយ សារីបុត្រ តថាគតនៅទិសណា ទិសនោះក៏មិនស្ងាត់ឡើយ ឱវាទរបស់អ្នក ក៏ដូចឱវាទរបស់ព្រះពុទ្ធទាំងឡាយ កិច្ចដែលអ្នកគប្បីឧបដ្ឋាកតថាគត មិនមានទេ ព្រះអសីតិមហាសាវក តាំងពីព្រះមោគ្គ-ល្លាន ក៏ក្រោកឡើងដោយឧបាយនោះដូចគ្នា ព្រះដ៏មានព្រះភាគ ក៏ទ្រង់ហាមទាំងអស់ ។ ចំណែកព្រះអានន្ទត្ថេរអង្គុយនៅស្ងៀម ។ លំដាប់នោះ ភិក្ខុទាំងឡាយពោលនឹងព្រះអានន្ទថា អានន្ទ ភិក្ខុសង្ឃទូលសូមតំណែងឧបដ្ឋាកគ្រប់គ្នា លោកក៏ចូរទូលសូមដែរចុះ ។ ព្រះអានន្ទត្ថេរពោលថា លោកដ៏មានអាយុ ធម្មតាថាតំណែងដែលទូលសូមបានហើយ ប្រយោជន៍អ្វី ព្រះសាស្តាទ្រង់មិនឃើញខ្ញុំឬ បើព្រះសាស្តាទ្រង់ពេញព្រះទ័យ ក៏នឹងត្រាស់ថា អានន្ទចូរឧបដ្ឋាកតថាគត ដូច្នេះ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អានន្ទមិនត្រូវការអ្នកដទៃដឹកនាំឲ្យឧស្សាហ៍ទេ នឹងដឹងដោយខ្លួនឯង ហើយឧបដ្ឋាកតថាគត ។ តពី

នោះ ភិក្ខុទាំងឡាយពោលថា ក្រោកឡើងអានន្ទ លោកចូរទូលសូមតំណែងឧប-ដ្ឋាកចំពោះព្រះទសពល ។

ព្រះថេរៈក្រោកឡើង ហើយទូលសូមពរ ៨ ប្រការ គឺ ប្រការដែលហាម ៤ ប្រការដែលអនុញ្ញាត ៤ ។ ព្រះថេរៈទូលថា ឈ្មោះថា ប្រការដែលហាម ៤ គឺ បពិត្រព្រះអង្គដ៏ចម្រើន បើព្រះដ៏មានព្រះភាគមិនប្រទានចីវរ មិនប្រទានបិណ្ឌបាតដែលប្រណីតដែលព្រះអង្គទ្រង់បានមកហើយដល់ខ្ញុំព្រះអង្គ មិនប្រទានឲ្យខ្ញុំព្រះអង្គនៅក្នុងព្រះគន្ធកុដិជាមួយនឹងព្រះអង្គ នឹងទ្រង់មិននាំខ្ញុំព្រះអង្គទៅក្នុងទីនិមន្ត ដូច្នេះ ខ្ញុំព្រះអង្គនឹងឧបដ្ឋាកព្រះដ៏មានព្រះភាគ កាលត្រាស់សួរថា អានន្ទ អ្នកឃើញទោសអ្វីក្នុងសេចក្ដីនេះ ទើបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើខ្ញុំព្រះអង្គនឹងបានវត្ថុទាំងនេះសោត នឹងមានអ្នកពោលថា អានន្ទ បរិភោគចីវរ បរិភោគបិណ្ឌបាតដែលប្រណីត នៅក្នុងព្រះគន្ធកុដិជាមួយព្រះអង្គ ទៅកាន់ទីនិមន្តជាមួយនឹងព្រះទសពល ព្រោះអាស្រ័យបានលាភនេះ ទើបឧបដ្ឋាកព្រះតថាគត នាទីរបស់អ្នកឧបដ្ឋាកយ៉ាងនេះ នឹងមានប្រយោជន៍អ្វី ព្រោះដូច្នោះ លោកទើបទូលសូមពរប្រការដែលហាម ៤ ប្រការនេះ ព្រះថេរៈទូលថា ចំណែកពរដែលទ្រង់អនុញ្ញាត ៤ គឺ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគស្ដេចទៅកាន់ទីនិមន្តដែលខ្ញុំព្រះអង្គទទួលហើយ បើខ្ញុំព្រះអង្គនឹងនាំអ្នកដែលមកពីរដ្ឋខាង

ក្រៅ ជនបទខាងក្រៅ ចូលគាល់បានក្នុងខណៈដែលគេមកហើយ ខណៈណា ខ្ញុំព្រះអង្គកើតសេចក្តីសង្ស័យ ខណៈនោះ ខ្ញុំព្រះអង្គចូលគាល់ព្រះដ៏មានព្រះភាគបាន ព្រះដ៏មានព្រះភាគទ្រង់សម្តែងធម៌ណាដែលខ្ញុំព្រះអង្គមិនបានដឹង កាលស្តេចត្រឡប់មកវិញ ត្រាស់ធម៌នោះដល់ខ្ញុំព្រះអង្គ យ៉ាងនេះ ខ្ញុំព្រះអង្គទើបឧបដ្ឋាកព្រះដ៏មានព្រះភាគ កាលត្រាស់សួរថា អានន្ទ ក្នុងសេចក្តីនេះ តើអ្នកឃើញអានិសង្សអ្វី ទើបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកកុលបុត្រអ្នកមានសទ្ធាក្នុងលោកនេះ កាលមិនបានឱកាសរបស់ព្រះដ៏មានព្រះភាគ ទើបពោលនឹងខ្ញុំព្រះអង្គយ៉ាងនេះថា លោកម្ចាស់អានន្ទ ស្អែកនេះ សូមលោកម្ចាស់ព្រមទាំងព្រះដ៏មានព្រះភាគមេត្តាទទួលភិក្ខាក្នុងផ្ទះរបស់ខ្ញុំ បើព្រះដ៏មានព្រះភាគស្តេចមិនទៅក្នុងទីនោះ ខ្ញុំព្រះអង្គមិនបានឱកាសឲ្យអ្នកចូលគាល់ ក្នុងខណៈដែលគេប្រាថ្នានិងបន្ទោបង់សេចក្តីសង្ស័យ ពួកគេក៏នឹងពោលថា ព្រះអានន្ទ ឧបដ្ឋាកព្រះទស-ពលដូចម្តេច ព្រះដ៏មានព្រះភាគទ្រង់មិនអនុគ្រោះលោក សូម្បីយ៉ាងនេះ និងពួកគេនឹងសួរខ្ញុំព្រះអង្គពីក្រោយខ្នងព្រះដ៏មានព្រះភាគថា លោកម្ចាស់អានន្ទ គាថានេះ ព្រះសូត្រនេះ ជាតកនេះ ព្រះដ៏មានព្រះភាគទ្រង់សម្តែងក្នុងទីណា បើខ្ញុំព្រះអង្គមិនបានពរប្រការនោះ ពួកគេក៏នឹងពោលថា សូម្បីព្រះតម្រាស់ប៉ុណ្ណេះ លោកក៏មិនដឹង ប្រយោជន៍អ្វី ក្នុងការនៅរួមជាមួយព្រះមានព្រះភាគ ដោយប្រការ

នោះ ខ្ញុំព្រះអង្គត្រូវការនឹងពោលធម៌ដែលព្រះដ៏មានព្រះភាគសម្ដែងក្នុងទីដែលខ្ញុំព្រះអង្គមិនដឹងទៀត ព្រោះដូច្នោះ លោកទើបទូលសូមពរ ប្រការដែលទ្រង់អនុញ្ញាត ៤ ប្រការទាំងនេះ ព្រះដ៏មានព្រះភាគ ក៏បានប្រទានពរដល់លោក ។ លោកទទួលពរ ៨ ប្រការយ៉ាងនេះ ទើបបានជាពុទ្ធុបដ្ឋាកប្រចាំ ។

ផលនៃបារមីទាំងឡាយដែលបំពេញមកអស់មួយសែនកប្ប ក៏សម្រេចដល់លោកដែលបានប្រាថ្នាតំណែងពុទ្ធុបដ្ឋាកជាប្រចាំនោះឯង ។ តាំងពីថ្ងៃបានតំណែងជាពុទ្ធុបដ្ឋាកហើយ លោកឧបដ្ឋាកព្រះទសពល ដោយកិច្ចទាំងឡាយជាដើមយ៉ាងនេះ គឺ ដោយទឹក ២ យ៉ាង ដោយឈើស្ទន់ ៣ យ៉ាង ដោយការប្របាច់ព្រះហស្ត និងព្រះបាទ ដោយការប្របាច់ខ្នង ដោយការបោសសម្អាតបរិវេណព្រះគន្ធកុដិ គិតថា ព្រះសាស្ដាគួរបានកិច្ចនេះ ក្នុងវេលានេះ ហើយកាន់ប្រទីបធំទុក ក្នុងវេលាយប់ដើរត្រួតជុំវិញបរិវេណព្រះគន្ធកុដិ មួយរាត្រី ៩ ដង មួយទៀត លោកមានសេចក្ដីត្រិះរិះយ៉ាងនេះថា បើយើងងងុយដេកសោតយើងក៏មិនអាចឆ្លើយទទួល កាលព្រះទសពលត្រាស់ហៅ ។ ព្រោះដូច្នោះ លោកទើបមិនលះបង់ប្រទីបពីដៃរហូតមួយយប់ទល់ភ្លឺ ក្នុងសេចក្ដីនេះ មានវត្ថុនិទានដូចពោលនេះ ក្រោយមក ព្រះសាស្ដាប្រថាប់នៅក្នុងព្រះជេតវនវិហារ ទ្រង់សរសើរព្រះអានន្ទត្ថេរ អ្នករក្សាឃ្លាំងធម៌ ដោយអនេកបរិយាយ ទើបទ្រង់ស្ថាបនាព្រះថេរៈ

ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលលើពួកភិក្ខុសាវក ដែលជាពហុស្សូត មានសតិ មានគតិ មានធិតិ និងពុទ្ធុប្បដ្ឋាក ក្នុងព្រះសាសនានេះ ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

## ប្រវត្តិព្រះឧរុវេលកស្សបត្ថេរៈ

*ក្នុងសូត្រទី ២ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[១៨៩] *ដោយបទថា* ***មហាបរិសានំ*** *លោកសម្តែងថា ព្រះឧរុវេលកស្សប ជាកំពូលលើពួកភិក្ខុសាវកអ្នកមានបរិវារច្រើន ពិតហើយ ព្រះថេរៈដទៃៗ កាលខ្លះក៏មានបរិវារច្រើន កាលខ្លះក៏មានបរិវារតិច ចំណែកព្រះថេរៈអង្គនេះ និងប្អូនប្រុសទាំងពីរ មានសមណៈបរិវារប្រចាំមួយពាន់រូប បណ្តាភិក្ខុជដិលបីរូបនោះ តែមួយរូបឲ្យបព្វជ្ជាម្តង មួយរូបបព្វជ្ជាម្តង ក៏បានសមណៈពីរពាន់រូប កាលបើរួមការបព្វជ្ជាពីរលើកនោះ ក៏មានសមណៈបីពាន់រូប ព្រោះដូច្នោះ ព្រះឧរុវេល-កស្សប ទើបជាកំពូលលើពួកភិក្ខុសាវកអ្នកមានបរិវារច្រើន ។ ក៏ពាក្យថា* ***កស្សប*** *ជាគោត្ររបស់លោក ។ ប្រាកដឈ្មោះថា* ***ឧរុវេលកស្សប*** *ព្រោះលោកបួសក្នុងឧរុវេលាសេនានិគម ។ ក្នុងបញ្ហាកម្មរបស់លោក មានរឿងនឹងពោលតាមលំដាប់ ដូច្នេះ ៖*

*សម័យព្រះពុទ្ធព្រះនាមថា* ***បទុមុត្តរៈ*** *ព្រះឧរុវេលកស្សបនេះ ក៏បដិសន្ធិក្នុងត្រកូលក្នុងក្រុងហង្សវតី ចម្រើនវ័យហើយ ស្តាប់ធម្មកថារបស់ព្រះសាស្តា*

ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូបទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលលើពួកភិក្ខុសាវកអ្នកមានបរិស័ទច្រើន គិតថា សូម្បីយើងក៏នឹងគួរដូចជាភិក្ខុរូបនេះក្នុងអនាគតកាល ទើបថ្វាយមហាទានចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ៧ ថ្ងៃ ឲ្យគ្រងត្រៃចីវរ ថ្វាយបង្គំព្រះសាស្តាហើយ បានធ្វើសេចក្តីប្រាថ្នាក្នុងតំណែងឯតទគ្គៈជាកំពូលលើពួកភិក្ខុសាវកអ្នកមានបរិស័ទ ព្រះសាស្តាទ្រង់ជ្រាបថា មិនមានអន្តរាយ ទើបទ្រង់ព្យាករណ៍ថា អ្នកនឹងជាកំពូលលើពួកភិក្ខុសាវកអ្នកមានបរិស័ទច្រើន ក្នុងសាសនារបស់ព្រះគោតមសម្ពុទ្ធ ក្នុងអនាគតកាល ហើយស្តេចក៏យាងត្រឡប់ទៅ ។ កុលបុត្រនោះ ធ្វើកល្យាណកម្មរហូតអស់ជីវិត វិលវល់នៅក្នុងទេវតា និងមនុស្ស ក្នុងទីបំផុតនៃកប្បទី ៩២ ក៏កើតជាកនិដ្ឋភាតា ផ្សេងមាតារបស់ព្រះពុទ្ធ ព្រះនាមថា **បុស្សៈ** ព្រះរាជបិតាព្រះនាមថា **មហិន្ទរាជា** ។ លោកនៅមានបងប្អូនដទៃពីរអង្គទៀត ។ បងប្អូនទាំងបីអង្គនោះ បានតំណែងមួយអង្គផ្នែកយ៉ាងនេះ ទ្រង់បង្ក្រាបជនបទជាយដែនដែលកើតចលាចល ដោយន័យដូចពោលហើយក្នុងកាលមុន ទ្រង់បានពរពីសំណាក់ព្រះរាជបិតា ទ្រង់ទទួលពរថា ពួកខ្ញុំព្រះអង្គនឹងទំនុកបម្រុងព្រះទសពលរហូតអស់ត្រៃមាស គ្រានោះបងប្អូនទាំងបីព្រះអង្គ ទ្រង់ត្រិះរិះថា ពួកយើងទំនុកបម្រុងព្រះទសពលធ្វើឲ្យគួរទើបគួរ បានតែងតាំងអាមាត្យម្នាក់ទុកក្នុងតំណែងជាអ្នកចាត់ការ តែងតាំងអាមាត្យ

ម្នាក់ជាអ្នកចំណាយ តែងតាំងអាមាត្យម្នាក់ក្នុងតំណែងជាអ្នកទំនុកបម្រុងភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន សមាទានសីល ១០ សម្រាប់ព្រះអង្គ រក្សាសិក្ខាបទទាំងឡាយរហូតអស់ត្រៃមាស អាមាត្យទាំងបីនាក់នោះ កើតជាព្រះបាទពិម្ពិសារ ជាវិសាខៈ និងព្រះរដ្ឋបាល ក្នុងពុទ្ធុប្បាទកាលនេះ ដោយន័យដែលពោលមកហើយក្នុងខាងក្រោយ ចំណែកព្រះរាជកុមារទាំងនោះ កាលព្រះទសពលនៅចាំវស្សា ទ្រង់បានបូជាបច្ច័យដោយព្រះហស្តរបស់ព្រះអង្គឯង ធ្វើកល្យាណកម្មរហូតអស់ជីវិត កើតក្នុងត្រកូលព្រាហ្មណ៍ ។ មុនព្រះទសពលរបស់យើងទ្រង់ឧប្បត្តិ មាននាមថា **កស្សប** ទាំងបីនាក់ តាមគោត្ររបស់ខ្លួន អ្នកទាំងបីនោះចម្រើនវ័យហើយ រៀនត្រៃវេទ បុរសបងមានមាណពជាបរិវារ ៥០០ នាក់ បុរសកណ្តាល ៣០០ នាក់ ប្អូនពៅ ២០០ នាក់ ។ ទាំងបីបងប្អូន ពិចារណាមើលសារៈក្នុងគម្ពីរ (ត្រៃវេទ) ឃើញតែប្រយោជន៍ក្នុងបច្ចុប្បន្នប៉ុណ្ណោះ មិនឃើញប្រយោជន៍ចំណែកខាងមុខ បងប្រុសទៅកាន់តំបន់ឧរុវេលា បួសជាឥសីព្រមជាមួយបរិវាររបស់ខ្លួនឈ្មោះថា **ឧរុវេលកស្សប** ។ ប្អូនកណ្តាលទៅបួសត្រង់ទីបត់នៃមហាគង្គានទី ឈ្មោះថា **នទីកស្សប** ។ ប្អូនពៅទៅបួសត្រង់គយាសីសប្រទេស ឈ្មោះថា **គយាកស្សប** ។

កាលកស្សបបងប្អូនបួសជាឥសីនៅក្នុងទីនោះ កន្លងទៅជាច្រើនថ្ងៃ ព្រះ

ពោធិសត្វរបស់យើង ស្ដេចចេញមហាភិនេស្រ្កម ទ្រង់សម្រេចព្រះសព្វញ្ញុត-ញ្ញាណ ប្រកាសព្រះធម្មចក្កតាមលំដាប់ ទ្រង់ស្ថាបនាព្រះបញ្ចវគ្គិយត្ថេរទុកក្នុងព្រះអរហត្ត ទ្រង់ណែនាំសម្លាញ់ ៥៥ នាក់ មានយសកុលបុត្រជាប្រធាន ទ្រង់បញ្ជូនព្រះអរហន្ត ៦០ អង្គ ឲ្យចារិកទៅដើម្បីប្រយោជន៍ដល់ជនច្រើន ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរចារិកទៅ ដូច្នេះជាដើម ទ្រង់បានណែនាំពួកភទ្ទវគ្គីយ៍ ហើយទ្រង់ឃើញហេតុនៃឧរុវេលកស្សប ក៏ទ្រង់ជ្រាបថាកាលតថាគតទៅ បីនាក់បងប្អូនព្រមទាំងបរិវារ នឹងសម្រេចព្រះអរហត្ត តែមួយព្រះអង្គឯងមិនមានសម្លាញ់ ស្ដេចយាងដល់ទីនៅរបស់ឧរុវេលកស្សប ទ្រង់សូមរោងភ្លើងដើម្បីប្រថាប់នៅ ទ្រង់ណែនាំឧរុវេលកស្សបព្រមទាំងបរិវារ ផ្ដើមតាំងពីទ្រង់ទូន្មានពស់ដែលនៅក្នុងរោងភ្លើងនោះ ដោយបាដិហារិយ៍ទាំងឡាយ មានចំនួនដល់ ៣.៥០០ យ៉ាង ហើយទ្រង់ឲ្យបួស ប្អូនប្រុសពីរនាក់ទៀតដឹងថា បងប្រុសបួស ក៏មកបួសព្រមទាំងបរិវារ ពួកជដិលទាំងអស់ជាឯហិភិក្ខុ ប្រដាប់បាត្រនិងចីវរដែលសម្រេចមកពីឫទ្ធិ ។ ព្រះសាស្ដាទ្រង់នាំសមណៈ ១.០០០ រូបនោះទៅកាន់គយាសីសប្រទេស ប្រថាប់លើផ្ទាំងថ្ម ទ្រង់ពិចារណាមើលថា អ្នកទាំងនេះបួសបម្រើភ្លើង គួរសម្ដែងកពទាំងបី ឲ្យដូចជាផ្ទះដែលត្រូវភ្លើងឆេះដល់អ្នកទាំងនេះ ទើបទ្រង់សម្ដែងអាទិត្តបរិយាយសូត្រ ។ ចប់ទេសនា ក៏បានសម្រេចជា

ព្រះអរហត្តគ្រប់រូប ។ ព្រះសាស្តាមានភិក្ខុជដិលទាំងនោះហែហម ទ្រង់ជ្រាប ដល់ប្តេជ្ញាដែលថ្វាយទុកចំពោះព្រះបាទពិម្ពិសារ តាមលំដាប់ ស្តេចយាងដល់ ព្រះរាជឧទ្យានលដ្ឋិវ័ន ក្រុងរាជគ្រឹះ ព្រះរាជាទ្រង់ជ្រាបថា ព្រះទសពលស្តេច យាងមកដល់ហើយ ទ្រង់ព្រមជាមួយព្រាហ្មណ៍ និងគហបតី ១២ នហុត ស្តេច ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ប្រថាប់ក្នុងទីសមគួរម្ខាង ព្រះសាស្តា ទ្រង់ពិចារណាមើលបរិស័ទទាំងអស់ ទ្រង់ឃើញមហាជនធ្វើការនមស្ការឧរុវេល- កស្សប ទ្រង់ព្រះតម្រិះថា អ្នកទាំងនេះមិនដឹងថា តថាគត ឬកស្សបជាធំ ដែល ឈ្មោះថា ពួកជនដែលមានវិតក្កៈ មិនអាចទទួលទេសនាបាន ទើបបានប្រទាន សញ្ញាដល់ព្រះថេរៈថា កស្សប អ្នកចូរកាត់វិតក្កៈពួកឧបដ្ឋាករបស់អ្នកចេញ ។ ព្រះថេរៈទទួលព្រះតម្រាស់របស់ព្រះសាស្តាហើយ ក្រោកចាកអាសនៈ ថ្វាយ បង្គំព្រះសាស្តាដោយបញ្ចង្គប្រតិស្ឋាន ហោះឡើងកាន់អាកាសប្រមាណមួយជួរ ដើមត្នោត សម្តែងឫទ្ធិផ្សេងៗ ប្រកាសថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មាន- ព្រះភាគទ្រង់ជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវក បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគទ្រង់ជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវក ហើយចុះ មកថ្វាយបង្គំព្រះយុគលបាទព្រះទសពល ដោយឧបាយនោះ លើកទី ៧ ហោះ ឡើងកាន់អាកាស ៧ ជួរដើមត្នោត ហើយថ្វាយបង្គំព្រះយុគលបាទរបស់ព្រះ

ទសពល អង្គុយក្នុងទីសមគួរមួយ ។ វេលានោះ មហាជនអស់វិតក្កៈក្នុងព្រះសាស្តាថា បុគ្គលម្នាក់នេះ ជាមហាសមណៈក្នុងលោក ។ លំដាប់នោះ ព្រះសាស្តាទើបទ្រង់សម្តែងធម៌ប្រោស ។ ចប់ទេសនា ព្រះរាជាព្រមទាំងព្រាហ្មណ៍ និងគហបតី ១១ នហុត តាំងនៅក្នុងព្រះសោតាបត្តិផល ១ នហុត ប្រកាសខ្លួនជាឧបាសក ។ ភិក្ខុចំនួនមួយពាន់រូប បរិវាររបស់ឧរុវេលកស្សបទាំងនោះ គិតដោយសភាពធ្លាប់ស្និទ្ធស្នាលរបស់ខ្លួនថា កិច្ចបព្វជិតរបស់ពួកយើងដល់ទីបំផុតហើយ ពួកយើងនឹងទៅខាងក្រៅធ្វើអ្វី ។ ទើបដើរហែហមព្រះឧរុវេលកស្សបតែម្យ៉ាង បណ្តាភិក្ខុជដិលទាំងបីនោះ ភិក្ខុជដិលតែមួយអង្គទទួលសិស្សបានមួយអង្គ[1] រួមជាពីរពាន់ កាលទទួលបានលើកទីពីរមួយអង្គៗ ទៀត ក៏ជាបីពាន់ ។ តាំងពីនោះមកសិស្សរបស់ភិក្ខុជដិលទាំងនោះមានប៉ុន្មាន នឹងពោលដល់សិស្សប៉ុណ្ណោះ ក៏គួរ ។

ក្នុងសេចក្តីនោះ មានវត្ថុនិទាន ដូច្នេះ ។ តមក ព្រះសាស្តាប្រថាប់នៅក្នុងព្រះជេតវនវិហារ ទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលលើពួកភិក្ខុសាវកអ្នកមានបរិស័ទច្រើន ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ២

---

១- ក្នុងន័យនេះ គឺ ភិក្ខុ ១.០០០ រូប ទទួលសិស្សបានមួយនាក់ៗ ទើបជា ២.០០០ នាក់ នឹងទទួលតៗ ទៅ ជា ៣.០០០ ចំនួនក៏កើនតាមដែលទទួល ។

# អដ្ឋកថាសូត្រទី ៣

## ប្រវត្តិព្រះភាទ្ទិយត្ថេរ

*ក្នុងសូត្រទី ៣ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[១៨៩] *បទថា* ***កុលប្បសាទកានំ*** *បានដល់ អ្នកធ្វើត្រកូលឲ្យជ្រះថ្លា ។ ពិតណាស់ ព្រះថេរៈនេះ ធ្វើរាជនិវេសន៍របស់ព្រះបាទសុទ្ធោទនមហារាជ ដែលមិនទាន់ជួបព្រះពុទ្ធឲ្យជ្រះថ្លា ព្រោះហេតុនោះ លោកទើបជាកំពូលលើភិក្ខុសាវកអ្នកធ្វើត្រកូលឲ្យជ្រះថ្លា ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលគប្បីពោលតាមលំដាប់ ដូច្នេះ ។*

*គ្រាព្រះពុទ្ធព្រះនាមថា* ***បទុមុត្តរៈ*** *ព្រះថេរៈនេះកើតក្នុងត្រកូល នាក្រុងហង្សវតី កំពុងស្តាប់ធម៌ទេសនារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូបទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលលើភិក្ខុសាវកអ្នកធ្វើត្រកូលឲ្យជ្រះថ្លា ទើបធ្វើកុសលកម្មឲ្យក្រៃលែងឡើងទៅ ហើយប្រាថ្នាតំណែងនោះ លោកបំពេញកុសលរហូតអស់ជីវិត វិលវល់នៅក្នុងទេវតា និងមនុស្សទាំងឡាយ បដិសន្ធិក្នុងផ្ទះរបស់អាមាត្យក្នុងក្រុងកបិលពស្តុ ក្នុងថ្ងៃដែលព្រះពោធិសត្វរបស់យើងទ្រង់បដិសន្ធិក្នុងគភ៌របស់ព្រះមាតា ក្នុងថ្ងៃកើត ក៏កើតព្រមជាមួយព្រះពោធិសត្វ*

ក្នុងថ្ងៃនោះ ញាតិទាំងឡាយក៏ឲ្យដេកលើគ្រឿងទទួល គឺ សំពត់ ហើយនាំទៅថ្វាយខ្លួន ដើម្បីបម្រើព្រះពោធិសត្វ ។

ដើមពោធិព្រឹក្ស ព្រះមាតារបស់ព្រះរាហុល រណ្តៅទ្រព្យទាំង ៤ ដំរីមង្គល (អារោហនិយហត្ថី) សេះកណ្ឋកៈ នាយឆន្នៈ អាមាត្យកាឡុទាយី រួមជា ៧ នេះ ឈ្មោះថា **សត្តសហជាត** ព្រោះកើតក្នុងថ្ងៃតែមួយជាមួយនឹងព្រះពោធិសត្វ ។

ក្នុងថ្ងៃដាក់នាមទារកនោះ ពួកញាតិតាំងឈ្មោះថា **ឧទាយី** ព្រោះកើតក្នុងថ្ងៃដែលអ្នកនគរទូទៅមានចិត្តអណ្តែតឡើង ។ តែព្រោះលោកមានសម្បុរខ្មៅ ទើបកើតឈ្មោះថា **កាឡុទាយី** កាឡុទាយីនោះ លេងរបស់លេងសម្រាប់ក្មេងប្រុសជាមួយព្រះពោធិសត្វដរាបចម្រើនវ័យ តមកព្រះពោធិសត្វស្តេចចេញមហាភិនេស្រ្កម៍ សម្រេចព្រះសព្វញ្ញុតញ្ញាណ តាមលំដាប់ ទ្រង់បានប្រកាសធម្មចក្កដ៏ប្រសើរ ទ្រង់ធ្វើការអនុគ្រោះសត្វលោក ទ្រង់អាស្រ័យក្រុងរាជគ្រឹះ ប្រថាប់នៅ ។ សម័យនោះ ព្រះបាទសុទ្ធោទនមហារាជ ទ្រង់ជ្រាបថា សិទ្ធត្ថកុមារសម្រេចអភិសម្ពោធិញ្ញាណ អាស្រ័យក្រុងរាជគ្រឹះ ប្រថាប់នៅក្នុងព្រះវេឡុវនវិហារ ទើបទ្រង់បញ្ជូនអាមាត្រមួយនាក់ មានបុរសមួយពាន់នាក់ជាបរិវារទៅជាមួយ ត្រាស់បង្គាប់ថា អ្នកចូរនាំឱរសរបស់យើងមកក្នុងទីនេះ ។ អាមាត្រនោះដើរទៅ ៦០ យោជន៍ ក៏ចូលទៅកាន់ព្រះវិហារ ក្នុងវេលាដែលព្រះទសពលកំពុង

ប្រថាប់កណ្តាលបរិស័ទ ៤ ទ្រង់សម្តែងធម៌ អាមាត្រនោះគិតថា រាជសាសន៍ដែល ព្រះរាជាទ្រង់បញ្ជូនទៅទុកសិនចុះ ហើយឈរខាងក្រោយបរិស័ទ ស្តាប់ព្រះធម៌-ទេសនារបស់ព្រះសាស្តា ក៏បានសម្រេចព្រះអរហត្តព្រមទាំងបុរសមួយពាន់នាក់ ត្រង់ទីដែលឈរនុ៎ះឯង លុះព្រះសាស្តាទ្រង់លាព្រះហស្តដល់អាមាត្រ និងបុរស មួយពាន់នាក់នោះ ដោយព្រះតម្រាស់ថា ពួកអ្នកចូរជាភិក្ខុចុះ ភ្លាមនោះឯង គ្រប់ គ្នាក៏ប្រដាប់បាត្រ និងចីវរសម្រេចមកពីឫទ្ធិ ហាក់ដូចជាព្រះថេរៈមួយរយវស្សា ចាប់តាំងពីវេលាសម្រេចព្រះអរហត្តហើយ ធម្មតាថា ព្រះអរិយៈទាំងឡាយរមែង ជាអ្នកប្រងើយ ព្រោះដូច្នោះ ភិក្ខុ (អាមាត្រ) នោះ ទើបមិនបានទូលរាជសាសន៍ ដែលព្រះរាជាទ្រង់បញ្ជូនទៅចំពោះព្រះទសពល ព្រះរាជាទ្រង់ព្រះតម្រិះថា អាមាត្រ មិនទាន់ត្រឡប់មកពីទីនោះ ប្រហែលដំណឹងក៏មិនបានឮដល់ព្រះទសពល ទើប ទ្រង់បញ្ជូនអាមាត្រដទៃៗ ទៅ ដោយទំនងនោះឯង អាមាត្រសូម្បីនោះ ទៅហើយ ក៏សម្រេចព្រះអរហត្តព្រមជាមួយបរិស័ទ ដោយន័យមុននុ៎ះឯង ហើយក៏ស្ងាត់ ទៅ ទ្រង់បញ្ជូនបុរស ៩.០០០ នាក់ ព្រមទាំងអាមាត្រ ៩ នាក់ ដោយប្រការ ដូច្នេះ គ្រប់ៗ គ្នា សម្រេចកិច្ចរបស់ខ្លួន ហើយក៏ស្ងាត់ទៅ ។

គ្រានោះ ព្រះរាជាទ្រង់ព្រះតម្រិះថា មនុស្សមានចំនួនប៉ុណ្ណេះ មិនប្រាប់ អ្វីដល់ព្រះទសពល ដើម្បីស្តេចមកក្នុងទីនេះ ព្រោះគេមិនស្រឡាញ់យើង បុគ្គល

ដទៃៗ សូម្បីទៅ ក៏គង់នឹងមិនអាចនាំព្រះទសពលមកបាន តែឧទាយីបុត្ររបស់យើង ឆ្នាំតែមួយជាមួយព្រះទសពល ដោយលេងដីជាមួយគ្នា គេគង់ស្រឡាញ់យើងខ្លះ ទើបទ្រង់ឲ្យហៅលោកមក ហើយត្រាស់បង្គាប់ថា កូនអើយ អ្នកមានបុរសមួយពាន់នាក់ជាបរិវារ ចូរទៅនាំព្រះទសពលមក កាឡុទាយីក្រាបទូលថា មហាបពិត្រ ខ្ញុំព្រះអង្គ បានបព្វជ្ជាដូចពួកបុរសដែលទៅគ្រាដំបូង ទើបនឹងនាំមក ព្រះអង្គ ៗ ត្រាស់បង្គាប់ថា អ្នកធ្វើកិច្ចយ៉ាងណាមួយស្រេចហើយ ចូរនាំកូនរបស់យើងមក កាឡុទាយីទទួលរាជឱង្ការថា ព្រះករុណាព្រះអង្គ ហើយកាន់សាសន៍របស់ព្រះរាជា ទៅក្រុងរាជគ្រឹះ ឈរស្តាប់ធម៌ខាងក្រោយបរិស័ទ ក្នុងវេលាព្រះសាស្តាទ្រង់សម្តែងធម៌ចប់ហើយ ក៏សម្រេចព្រះអរហត្ត តាំងនៅជាឯហិភិក្ខុព្រមទាំងបរិវារ បន្ទាប់ពីនោះ ក៏ត្រិះរិះថា នៅមិនទាន់ជាកាលដែលព្រះទសពលស្តេចនឹងទៅកាន់នគរនៃត្រកូល ដល់សម័យវសន្តរដូវ (រដូវស្លឹកឈើលាស់) កាលដងព្រៃមានផ្កាឈើរីក ផែនដីដណ្តប់ដោយស្មៅស្រស់ ទើបជាកាលទើបរង់ចាំវេលា ដឹងថាកាលមកដល់ហើយ ទើបទូលពណ៌នាផ្លូវ ដើម្បីព្រះទសពលស្តេចដំណើរទៅកាន់នគរនៃត្រកូល ដោយគាថាប្រមាណ ៦០ គាថា ជាដើមថា ៖

នាតិសីតំ នាតិឧណ្ហំ នាតិទុព្ភិក្ខឆាតកំ

*សទ្ទសា ហរិតា ភូមិ ឯស កាលោ មហាមុនិ*

*បពិត្រព្រះមហាមុនី ស្ថានទីមិនត្រជាក់ពេក មិនក្តៅពេក*

*មិនមែនស្ថានទីរកអាហារលំបាក និងខ្វះខាត ផ្ទៃផែនដីខៀវខ្ចី*

*គ្របដណ្តប់ដោយស្មៅ នេះជាកាលគួរ ។*

*ព្រះសាស្តាទ្រង់ជ្រាបថា ឧទាយីពោលសរសើរការដើរទៅថា ជាកាលដែលស្តេចដំណើរទៅកាន់ក្រុងកបិលពស្តុ មានភិក្ខុពីរម៉ឺនរូបជាបរិវារ ស្តេចចារិកដោយទ្រង់យាងទៅបែបមិនប្រញាប់ ព្រះឧទាយីត្ថេរជ្រាបថា ព្រះសាស្តាស្តេចចេញទៅហើយ គិតថា គួរនឹងថ្វាយសេចក្តីពេញព្រះហឫទ័យដល់ព្រះមហារាជពុទ្ធបិតា ទើបហោះទៅប្រាកដក្នុងព្រះរាជនិវេសន៍របស់ព្រះរាជា ព្រះរាជាទតឃើញព្រះថេរៈ ក៏មានព្រះហឫទ័យត្រេកអរ និមន្តឲ្យគង់លើបល្ល័ង្ក (គ្រែ) ដែលសមគួរ ដាក់ភោជនដែលមានរសដ៏ប្រសើរផ្សេងៗ ពេញបាត្រ ហើយថ្វាយ ព្រះថេរៈក្រោកឡើងសម្តែងអាកប្បកិរិយា ថានឹងទៅ ព្រះរាជទើបត្រាស់ថា និមន្តគង់ឆាន់ចុះ លោកកូន លោកទូលថា មហាបពិត្រ អាត្មាភាពនឹងទៅឆាន់ក្នុងសំណាក់ព្រះសាស្តា ត្រាស់សួរថា ក៏ព្រះសាស្តានៅទីណា លោកកូន លោកទូលថា មហាបពិត្រ ព្រះសាស្តាមានភិក្ខុពីរម៉ឺនជាបរិវារ ស្តេចចារិកដើម្បីសួរសុខទុក្ខមហាបពិត្រហើយ ត្រាស់ថា កូនឆាន់បិណ្ឌបាតនេះហើយ មេត្តានាំយក*

បិណ្ឌបាតក្រៅពីនេះ ទៅថ្វាយ ដរាបកូនរបស់ញោមនឹងមកដល់នគរនេះ ព្រះថេរៈទទួលអាហារដែលគប្បីនាំទៅថ្វាយព្រះទសពល ហើយពោលធម្មកថា ធ្វើព្រះរាជ-និវេសន៍ទាំងអស់ឲ្យបានសទ្ធា ដោយមិនទាន់ឃើញព្រះទសពលនៅឡើយ កាលមនុស្សគ្រប់គ្នាឃើញហើយនុ៎ះឯង ក៏បោះបាត្រឡើងទៅក្នុងអាកាស សូម្បីខ្លួនឯងក៏ហោះទៅនាំបិណ្ឌបាត យកទៅដាក់ត្រង់ព្រះហស្តរបស់ព្រះសាស្តា ព្រះសាស្តាក៏សោយបិណ្ឌបាតនោះ រាល់ៗ ថ្ងៃ ព្រះថេរៈនាំអាហារពីព្រះរាជនិវេសន៍ មកថ្វាយដល់ព្រះសាស្តា ដែលស្តេចកំពុងដំណើរផ្លូវ ៦០ យោជន៍ រហូតអស់ផ្លូវមួយយោជន៍ៗ ជាយ៉ាងក្រៃលែង គប្បីជ្រាបរឿងដូចពោលមកដូច្នេះ ។

ខាងក្រោយតមក ព្រះសាស្តាទ្រង់ព្រះតម្រិះថា ឧទាយី ធ្វើព្រះរាជនិវេសន៍ទាំងអស់របស់ព្រះមហារាជបិតារបស់តថាគតឲ្យជ្រះថ្លាហើយ ទើបទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលលើពួកភិក្ខុសាវកដែលធ្វើត្រកូលឲ្យជ្រះថ្លានោះឯង ។

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថាសូត្រទី ៤

## ប្រវត្តិព្រះពាក្កុលត្ថេរ

*ក្នុងសូត្រទី ៤ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[១៤៩] *បទថា* ***អប្បាពាធានំ*** *បានដល់ អ្នកមិនមានអាពាធ ។ បទថា* ***ពាកុលោ*** *បានដល់ ព្រះថេរៈបានឈ្មោះយ៉ាងនេះ ព្រោះចម្រើនវ័យមកក្នុងត្រកូលទាំងពីរ ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលនឹងពោលតាមលំដាប់ ដូច្នេះ ។*

*បានឮមក ក្នុងអតីតកាល ព្រះថេរៈនេះ បានបដិសន្ធិក្នុងត្រកូលព្រាហ្មណ៍ មុនព្រះទសពលព្រះនាមថា* ***អនោមទស្សី*** *ក្នុងទីបំផុតមួយអសង្ខេយ្យកម្រៃសែនកប្ប រាប់ពីកប្បនេះ បានចម្រើនវ័យ ក៏រៀនត្រៃវេទ ពិចារណាមិនឃើញសារៈក្នុងគម្ពីរត្រៃវេទ គិតថា នឹងស្វែងរកប្រយោជន៍ដែលប្រព្រឹត្តទៅខាងមុខ ទើបបួសជាឥសី បានអភិញ្ញា ៥ និងសមាបត្តិ ៨ ធ្វើវេលាឲ្យកន្លងទៅ ដោយការលេងឈាន សម័យនោះ ព្រះអនោមទស្សីពោធិសត្វ សម្រេចព្រះសព្វញ្ញុតញ្ញាណ មានពួកព្រះអរិយៈហែហមហើយ ស្តេចចារិកទៅ តាបសបានឮថា ព្រះរតនៈបីកើតឡើងហើយ ទើបទៅកាន់សំណាក់ព្រះសាស្តាស្តាប់ធម៌ ចប់ទេសនា ក៏តាំងនៅក្នុងសរណៈ តែមិនអាចលះបង់ឋានៈ (ភេទ) របស់ខ្លួនបាន លោកទៅគាល់ព្រះ*

សាស្តា និងស្តាប់ធម៌ជាគ្រាៗ តមក សម័យមួយ ព្រះតថាគតកើតរោគខ្យល់ក្នុងព្រះឧទរ ។ តាបសមកដើម្បីគាល់ព្រះសាស្តា ជ្រាបថា ព្រះសាស្តាប្រឈួន ទើបសួរថា បពិត្រព្រះអង្គ ទ្រង់កើតប្រឈួនអ្វី កាលភិក្ខុទាំងឡាយពោលថា មានរោគខ្យល់ក្នុងព្រះឧទរ ទើបគិតថា នេះជាវេលាធ្វើបុណ្យរបស់យើង ទើបទៅកាន់ជើងភ្នំ រួបរួមថ្នាំប្រភេទផ្សេងៗ ហើយថ្វាយព្រះថេរៈអ្នកឧបដ្ឋាក ដោយពោលថា សូមមេត្តាថ្វាយថ្នាំនេះដល់ព្រះសាស្តា រោគខ្យល់ក្នុងព្រះឧទរក៏ស្ងប់ព្រមគ្នានឹងការប្រើថ្នាំ តាបសនោះ ទៅគាល់ក្នុងវេលាដែលព្រះសាស្តាទ្រង់នៅជាសុខ ទូលយ៉ាងនេះថា ការនៅជាសុខកើតដល់ព្រះតថាគត ព្រោះថ្នាំរបស់ខ្ញុំព្រះអង្គនេះ យ៉ាងណា ដោយផលនៃការថ្វាយថ្នាំរបស់ខ្ញុំព្រះអង្គនោះ សូមអាពាធផ្លូវកាយសូម្បីតែត្រឹមដកសក់ ក៏ចូរកុំមានក្នុងភពដែលខ្ញុំព្រះអង្គកើតហើយ ។ នេះជាកល្យាណកម្មក្នុងអត្តភាពនោះរបស់លោក លោកចុតិចាកភពនោះ កើតក្នុងព្រហ្មលោក វិលវល់នៅក្នុងទេវតា និងមនុស្ស អស់មួយអសង្ខេយ្យ លុះមកដល់សម័យព្រះពុទ្ធព្រះនាមថា **បទុមុត្តរៈ** បដិសន្ធិក្នុងត្រកូលក្នុងក្រុងហង្សវតី ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូបទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលលើពួកភិក្ខុសាវកអ្នកមានអាពាធតិច ធ្វើកុសលកម្មដ៏ក្រៃលែង ហើយប្រាថ្នាតំណែងនោះ ។

លោកធ្វើកុសលជាបអស់ជីវិត រំលងរលំនៅក្នុងទេវតា និងមនុស្ស កើតនៅក្នុងត្រកូលព្រាហ្មណ៍ក្នុងក្រុងពន្ធុមវតី មុនព្រះទសពលព្រះនាមថា **វិបស្សី** ឧប្បត្តិឡើង បួសជាឥសីដោយន័យមុននុ៎ះឯង ជាអ្នកបានឈាន អាស្រ័យនៅជើងភ្នំព្រះវិបស្សីពោធិសត្វសម្រេចព្រះសព្វញ្ញុតញ្ញាណ មានភិក្ខុ ៦ លាន ៨ សែនជាបរិវារ ទ្រង់អាស្រ័យក្រុងពន្ធុមវតី ទ្រង់ធ្វើការសង្គ្រោះព្រះមហារាជដែលពុទ្ធ-បិតា ហើយប្រថាប់នៅជាសុខក្នុងមិគទាយវ័ន គ្រានោះ តាបសនេះជ្រាបថា ព្រះទសពលកើតក្នុងលោក ទើបមកស្តាប់ធម្មកថារបស់ព្រះសាស្តា បានតាំងនៅក្នុងសរណៈ មិនអាចលះបព្វជ្ជារបស់ខ្លួន តែក៏មកឧបដ្ឋាកព្រះសាស្តាជាគ្រាៗ សម័យមួយ ភិក្ខុទាំងឡាយវៀរព្រះសាស្តា និងព្រះអគ្គសាវក កើតរោគត្រង់សិរសៈព្រោះត្រូវខ្យល់របស់ដើមឈើមានពិស ដែលចេញផ្កាក្នុងព្រៃហិមពាន្ត ។ តាបសមកកាន់ទីគាល់ព្រះសាស្តា ជួបភិក្ខុអង្គុយទទូរសើសៈ ទើបសួរថា លោកម្ចាស់ភិក្ខុសង្ឃកើតអ្វី ភិក្ខុទាំងឡាយឆ្លើយថា អ្នកមានអាយុ ពួកភិក្ខុកើតរោគព្រោះផ្កាឈើពិស តាបសគិតថា នេះជាវេលាដែលនឹងធ្វើការខ្វល់ខ្វាយផ្លូវកាយដល់ភិក្ខុសង្ឃ ឲ្យបុណ្យកើតដល់យើង ទើបជ្រើសរើសថ្នាំប្រភេទផ្សេងៗ ជាមួយអំណាចរបស់ខ្លួន ហើយយកមកផ្សំជាថ្នាំថ្វាយ រោគរបស់ភិក្ខុគ្រប់រូបក៏ស្ងប់ទៅភ្លាម តាបសនោះ តាំងនៅរហូតអស់អាយុ ក៏កើតក្នុងព្រហ្មលោក រំលងរលំនៅ

ក្នុងទេវតា និងមនុស្ស ៩១ កប្ប ។ សម័យព្រះពុទ្ធព្រះនាមថា **កស្សប** កើត ក្នុងក្រុងពារាណសី ជាអ្នកគ្រប់គ្រងផ្ទះ គិតថា ផ្ទះជាទីនៅរបស់យើងទ្រុឌទ្រោម ចាំបាច់ត្រូវទៅជាយដែននាំទព្វសម្ភារៈមកធ្វើផ្ទះ ទើបទៅជាមួយពួកជាងឈើ ជួប វិហារធំចាស់ទ្រុឌទ្រោមក្នុងវាងផ្លូវ ក៏គិតថា ការធ្វើផ្ទះរបស់យើងលើកទុកចុះ ការធ្វើផ្ទះនោះ នឹងមិនទៅជាមួយយើង តែការទៅជាមួយគ្នាជួយគ្នាធ្វើយ៉ាងណា មួយមុន គួរនៅ គេឲ្យពួកជាងឈើទាំងនោះកាន់ទព្វសម្ភារៈ ឲ្យសាងរោងឧបោ-សថក្នុងវិហារនោះ ឲ្យសាងរោងឆាន់ រោងភ្លើង (ទីបម្រុង) ផ្ទះភ្លើង កប្បិយកុដិ (រោងព្យាបាល) ទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ វច្ចកុដិ (បង្គន់) ចាត់ចែងថ្នាំប្រើ និងឆាន់សម្រាប់ភិក្ខុសង្ឃទុកគ្រប់យ៉ាង ។

គេធ្វើកុសលរហូត អស់ជីវិត វិលវល់នៅក្នុងទេវតា និងមនុស្ស មួយ ពុទ្ធន្តរ ហើយបដិសន្ធិក្នុងផ្ទះ សេដ្ឋីក្រុងកោសម្ពី មុនព្រះទសពលរបស់យើង ឧប្បត្តិ តាំងពីថ្ងៃទីគេបដិសន្ធិ ត្រកូលសេដ្ឋីនោះ ក៏ប្រសព្វលាភដ៏ប្រសើរ យស ដ៏ប្រសើរ គ្រានោះមាតារបស់គេប្រសូតបុត្រហើយ គិតថា ក្មេងនេះមានបុណ្យ ធ្វើបុណ្យទុកពីមុន ជាអ្នកមិនមានរោគ អាយុវែង តាំងនៅរហូតដល់អស់កាល ប៉ុនណា ក៏នឹងជាអ្នកឲ្យសម្បត្តិដល់យើងរហូតអស់កាលត្រឹមនោះ ក៏ក្មេងទាំង ឡាយដែលងូតទឹកក្នុងទន្លេយមុនា ក្នុងថ្ងៃកើតនុ៎ះឯង រមែងជាអ្នកមិនមានរោគ

ទើបបញ្ជូនក្មេងនោះទៅផ្លូតទឹក លោកអាចារ្យអ្នករចនាគម្ពីរមជ្ឈិមនិកាយពោលថា នាងឲ្យផ្លូតសិរសៈក្នុងថ្ងៃទី ៥ ហើយបញ្ជូនក្មេងនោះទៅលេងទឹកក្នុងទីនោះ កាលស្ត្រីមេដោះកំពុងឲ្យក្មេងលេងមុជចុះមុជឡើង ត្រីមួយក្បាលឃើញក្មេងនោះសម្គាល់ថាចំណី ក៏ហាមាត់លេបយកទៅ ស្ត្រីមេដោះ (តក់ស្លុត) ក៏ទម្លាក់ក្មេងគេចចេញទៅ ត្រីក៏លេបក្មេងនោះ សត្វមានបុណ្យ មិនប្រសព្វទុក្ខ ក៏ដូចជាចូលបន្ទប់ដេក ហើយដេក ដោយតេជៈបុណ្យរបស់ក្មេង ត្រីក៏ដូចលេបកាជនៈក្តៅក៏ក្តៅក្រហល់ក្រហាយ ក៏ហែលទៅដោយរហ័សអស់ ៣០ យោជន៍ ចូលទៅជាប់អួនរបស់ព្រានសំណាញ់ អ្នកក្រុងពារាណសី ធម្មតាត្រីជំជាប់អួន រមែងស្លាប់តែតេជៈបុណ្យរបស់ក្មេង ត្រីនេះពេលគេដោះចេញពីអួនទើបស្លាប់ ព្រានសំណាញ់ទាំងឡាយបានត្រីស្លាប់ រមែងកាត់ជាកំណាត់តូចធំទើបលក់ បានប្រើឲ្យសែងទៅទាំងមូល ដើរឆ្ពោលទៅក្នុងក្រុង ប្រាប់ថា យកទ្រព្យមកមួយពាន់ នឹងឲ្យត្រីនេះ នរណាៗ ក៏មិនទិញ ។

ក្នុងក្រុងនោះ មានត្រកូលសេដ្ឋីមានសម្បត្តិ ៨០ កោដិ ពួកព្រានសំណាញ់មកជិតដល់ទ្វារផ្ទះត្រកូលសេដ្ឋីនោះ ត្រូវសេដ្ឋីសួរថា ពួកលោកយកអ្វី ទើបនឹងឲ្យ ទើបឆ្លើយថា យកកហាបណៈ ពួកគេឲ្យកហាបណៈហើយទទួលយកត្រីទៅ ថ្ងៃដទៃៗ ភរិយាសេដ្ឋីមិនដែលរវល់នឹងការធ្វើត្រីឡើយ តែថ្ងៃនោះ ដាក់ត្រីទុកលើ

ជ្រញ់ ធ្វើដោយខ្លួនឯង ធម្មតាមនុស្សទាំងឡាយ រមែងវះត្រីអំពីខាងពោះ តែកិរិយាសេដ្ឋីនោះ វះត្រីខាងខ្នង ឃើញក្មេងមានសម្បុរដូចមាសក្នុងពោះត្រី ក៏បន្លឺសំឡេងលាន់ឡើងថា យើងបានបុត្រក្នុងពោះត្រី ទើបនាំក្មេងទៅរកស្វាមីក្នុងពេលក្លាមនោះឯង សេដ្ឋីក៏ឲ្យវាយស្គរប្រកាស ហើយនាំក្មេងទៅកាន់សំណាក់ព្រះរាជា ក្រាបទូលថា មហាបពិត្រ ខ្ញុំព្រះអង្គ បានក្មេងក្នុងពោះត្រី ខ្ញុំព្រះអង្គនឹងធ្វើដូចម្តេច ព្រះរាជាត្រាស់បង្គាប់ថា ក្មេងនេះមានបុណ្យ នៅក្នុងពោះត្រីក៏មិនមានរោគ លោកចូរចិញ្ចឹមចុះ ។ ត្រកូលមួយទៀតបានឮថា គេថា ត្រកូលសេដ្ឋីមួយក្នុងក្រុងពារាណសីបានក្មេងក្នុងពោះត្រី សេដ្ឋីស្វាមីកិរិយានោះ ក៏ទៅក្រុងពារាណសី លំដាប់នោះ មាតារបស់ក្មេងនោះ ឃើញក្មេងតែងខ្លួនកំពុងសើចលេង ក៏សួរថា ក្មេងម្នាក់នេះគួរឲ្យអាណិត ទើបប្រាប់រឿងនោះ មាតាម្នាក់ទៀតពោលថា បុត្ររបស់យើងទេ សួរថា លោកបានបុត្រពីណា ឆ្លើយថា ក្នុងពោះត្រី មាតាដើមប្រាប់ថា មិនមែនជាបុត្ររបស់លោក តែជាបុត្ររបស់យើង សួរថា លោកបានមកយ៉ាងណា ឆ្លើយថា យើងពផ្ទៃមកដល់ ១០ ខែ គ្រានោះក្មេងកំពុងលេងទឹកក្នុងទន្លេ ត្រីក៏លេបក្មេងទៅ មាតាទៀតម្នាក់ប្រាប់ថា បុត្ររបស់លោក គង់នឹងត្រីដទៃលេបយកទៅ ចំណែកក្មេងនេះ យើងបានក្នុងពោះត្រី ស្ត្រីទាំងពីរក៏នាំគ្នាទៅកាន់រាជត្រកូល ព្រះរាជាកាត់សេចក្តីថា ស្ត្រីម្នាក់នេះមិន

មែនមាតាមិនអាចនឹងធ្វើបាន ព្រោះពាំផ្ទៃមកអស់ ១០ ខែ ពួកព្រានសំណាញ់ចាប់ត្រីបាន ឈ្មោះថា ចាប់បានតែខាងក្រៅ មិនមានការបីបាច់ជាដើម សូម្បីស្ត្រីម្នាក់នេះក៏មិនមែនជាមាតា ព្រោះមិនអាចធ្វើបាន ព្រោះបានក្មេងក្នុងពោះត្រី ព្រោះដូច្នោះ ក្មេងនេះ ចូរជាទាយាទរបស់ត្រកូលទាំងពីរ ចាប់ពីនោះមក ត្រកូលទាំងពីរក៏ប្រសព្វលាភដ៏ប្រសើរ យសដ៏ប្រសើរយ៉ាងក្រៃលែង ទើបនាំគ្នាដាក់នាមលោកថា **ពាកុលកុមារ** ព្រោះត្រកូលទាំងពីរចិញ្ចឹមឲ្យធំធាត់ កាលលោកដឹងសេចក្ដីហើយ ត្រកូលទាំងពីរក៏សាងប្រាសាទ ៣ ខ្នង ទុកក្នុងនគរទាំងពីរ ចាត់ចែងនាដកៈ អ្នករបាំទុក ។ លោកនៅ ២ ខែ ក្នុងនគរមួយៗ នៅគ្រប់ ៤ ខែហើយ គេសាងមណ្ឌបទុកលើទូកធំ ឲ្យលោករួមជាមួយពួកនាដកៈនៅក្នុងមណ្ឌបនោះ លោកសោយសម្បត្តិហើយ ក៏ទៅកាន់នគរមួយទៀត ៤ ខែ ពួកនាដកៈអ្នកនគរចេញទៅ ត្រូវទទួលលោកដោយគិតថា លោកនឹងមកពាក់កណ្ដាលផ្លូវ ២ ខែ ហើយហែហមលោកនាំទៅកាន់នគររបស់ខ្លួនទៀត ២ ខែ ពួកនាដកៈមួយពួកទៀត ក៏ត្រឡប់ទៅនគររបស់ខ្លួន លោកនៅក្នុងនគរនោះ ២ ខែ ហើយក៏ទៅកាន់នគរមួយទៀត ដោយទំនងនោះឯង លោកសោយសម្បត្តិយ៉ាងនេះ ៨០ ឆ្នាំ បរិបូណ៌ ។

សម័យនោះ ព្រះពោធិសត្វរបស់យើង ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណ

ប្រកាសធម្មចក្កដ៏ប្រសើរ ស្ដេចចារិកមកដោយលំដាប់ ដល់ក្រុងកោសម្ពី ព្រះមជ្ឈិមភាណកាចារ្យពោលថា ក្រុងពារាណសី សូម្បីពាកុលសេដ្ឋីដឹងដំណឹងថា ព្រះទសពលស្ដេចមកហើយ ទើបកាន់យកគ្រឿងក្រអូប និងផ្កាកម្រងទៅកាន់សំណាក់ព្រះសាស្ដាស្ដាប់ធម៌ បានសទ្ធាក៏បួស លោកនៅជាបុថុជ្ជន ៧ ថ្ងៃ អរុណថ្ងៃទី ៧ ក៏សម្រេចព្រះអរហត្តព្រមទាំងបដិសម្ភិទា គ្រានោះ ពួកស្ដ្រីមេផ្ទះដែលលោកសាងទុកកាលនៅជាគ្រហស្ថក្នុងនគរទាំងពីរ ក៏ត្រឡប់ទៅផ្ទះត្រកូលរបស់ខ្លួន នៅក្នុងផ្ទះត្រកូលនោះៗ ឯង ធ្វើចីវរបញ្ជូនទៅថ្វាយព្រះថេរៈប្រើប្រាស់ ចីវរមួយផ្ទាំងដែលអ្នកក្រុងកោសម្ពីបញ្ជូនទៅថ្វាយ កន្លះខែ ចីវរមួយផ្ទាំងដែលអ្នកក្រុងពារាណសីបញ្ជូនទៅថ្វាយ ដោយទំនងនេះឯង អ្នកនគរក៏នាំចីវរតែប្រភេទល្អបំផុតក្នុងនគរទាំងពីរមកថ្វាយដល់ព្រះថេរៈតែមួយរូប ព្រះថេរៈគ្រប់គ្រងផ្ទះ ៨០ ឆ្នាំ អាពាធណាៗ ក៏មិនមានអស់កាល សូម្បីត្រឹមតែប្រើម្រាម ២ ធ្លាប់ចាប់ដុំគ្រឿងក្រអូបហិត ។ ក្នុងឆ្នាំទី ៨០ ក៏ចូលបព្វជ្ជាដោយសប្បាយ លោកបួសហើយ អាពាធសូម្បីបន្តិចបន្តួច ឬសេចក្ដីខ្វះខាតដោយបច្ច័យ ៤ មិនមានឡើយ សូម្បីសម័យបរិនិព្វាន ក្នុងបច្ឆិមកាល លោកក៏ពោលពាកុលសូត្រទាំងអស់ ដោយសម្ដែងសេចក្ដីសុខដែលមានផ្លូវកាយ និងផ្លូវចិត្តរបស់ខ្លួន ដល់អចេលកស្សបៈសម្លាញ់ចាស់គ្រានៅជាគ្រហស្ថ ហើយក៏បរិនិព្វាន ដោយអនុបាទិសេ-

សនិព្វានធាតុ អត្ថុប្បត្តិ (ហេតុកើតរឿង) តាំងឡើងដូចពោលមកដូច្នោះ ចំណែកព្រះសាស្តាស្ថាបនាព្រះថេរៈទាំងឡាយទុកក្នុងតំណែងផ្សេងៗ តាមលំដាប់ ក៏ទ្រង់ស្ថាបនាព្រះពាកុលត្ថេរៈទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលលើភិក្ខុសាវកអ្នកមានអាពាធតិចក្នុងព្រះសាសនានេះ គ្រាព្រះថេរៈនៅមានជីវិតនោះឯង ។

ចប់អដ្ឋកថា សូត្រទី ៤

# អដ្ឋកថាសូត្រទី ៥

## ប្រវត្តិព្រះសោភិតត្ថេរ

ក្នុងសូត្រទី ៥ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[១៨៩] ដោយបទថា *បុព្វេនិវាសំ អនុស្សរន្តានំ* លោកសម្តែងថា ព្រះសោភិតត្ថេរៈ ជាកំពូលលើភិក្ខុសាវកអ្នកអាចរឭកដល់ខន្ធសន្តាន សេចក្តីបន្តនៃខន្ធដែលអាស្រ័យនៅក្នុងជាតិមុនៗ បាន បានឮថា ព្រះថេរៈនោះ កាលរឭកដល់ខន្ធដែលអាស្រ័យក្នុងជាតិមុនៗ ទៅតាមលំដាប់ ក៏កាន់យកដោយន័យ គឺប៉ាន់ស្មានដល់អចិត្តកបដិសន្ធិក្នុងអសញ្ញីភព ៥០០ កប្ប ដូចសម្តែងស្នាមជើងក្នុងអាកាស ព្រោះហេតុនោះ លោកទើបឈ្មោះថា ជាកំពូលលើភិក្ខុសាវកអ្នករឭកដល់ខន្ធដែលអាស្រ័យនៅក្នុងជាតិមុនៗ ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលគប្បីពោលតាមលំដាប់ ដូច្នេះ ។

បានឮថា ព្រះសោភិតៈនេះ សម័យព្រះពុទ្ធព្រះនាមថា **បទុមុត្តរៈ** បានបដិសន្ធិក្នុងត្រកូលក្នុងក្រុងហង្សវតី ចម្រើនវ័យ កំពុងស្តាប់ព្រះធម៌ទេសនារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូប ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលលើភិក្ខុសាវកអ្នកបានបុព្វេនិវាសញ្ញាណ ធ្វើកុសលក្រៃលែងឡើងទៅ

ប្រាថ្នាតំណែងនោះ ។ លោកធ្វើកុសលដរាបអស់ជីវិត វិលវល់នៅក្នុងទេវតា និងមនុស្ស ក្នុងពុទ្ធុប្បាទកាលនេះ ក៏កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី បិតាមាតាទើបដាក់នាមលោកថា **សោភិតៈ** សម័យតមក លោកស្តាប់ព្រះធម៌-ទេសនារបស់ព្រះសាស្តា បានសទ្ធាក៏បួស ចម្រើនវិបស្សនា សម្រេចព្រះអរហត្ត ជាអ្នកជំនាញក្នុងបុព្វេនិវាសញ្ញាណ ។ លោករឭកដល់ស្ថានទីដែលខ្លួនកើតទៅតាមលំដាប់ បានឃើញបដិសន្ធិត្រឹមតែដល់អចិត្តកបដិសន្ធិក្នុងអសញ្ញីភព ក្នុងលំដាប់តពីនោះ ក៏មិនឃើញប្រវត្តិ ៥០០ ជាតិ ឃើញចុតិក្នុងភពចុងក្រោយ រឭកថា នេះជាអ្វី ក៏សន្និដ្ឋានបានថា អសញ្ញីភព បានដោយន័យ គឺ ប៉ាន់ស្មាន ព្រះសាស្តាទ្រង់ធ្វើហេតុនេះ ឲ្យជាអត្ថុប្បត្តិហើយ ទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងឯតទគ្គៈជាកំពូលលើភិក្ខុសាវក អ្នករឭកដល់ខន្ធដែលអាស្រ័យនៅក្នុងជាតិមុន ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ៥

# អដ្ឋកថាសូត្រទី ៦

## ប្រវត្តិព្រះឧបាលិត្ថេរៈ

ក្នុងសូត្រទី ៦ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[១៤៩] ដោយបទថា **វិនយធរានំ យទិទំ ឧបាលិ** លោកសម្ដែងថា ព្រះឧបាលីត្ថេរៈ ជាកំពូលលើភិក្ខុសាវកអ្នកទ្រទ្រង់វិន័យ បានឮថា ព្រះថេរៈទទួលកម្មដ្ឋានក្នុងសំណាក់ព្រះតថាគតតែមួយព្រះអង្គ ចម្រើនវិបស្សនាហើយសម្រេចព្រះអរហត្ត រៀនព្រះវិន័យបិដកក្នុងសំណាក់ព្រះតថាគត ពោលរឿងទាំង ៣ នេះ គឺ រឿងព្រះទារុកច្ឆកៈ រឿងព្រះអជ្ជុកៈ និងរឿងព្រះកុមារកស្សបៈ ប្រៀបដូចជាព្រះសព្វញ្ញុតញ្ញាណ ព្រោះហេតុនោះ លោកទើបឈ្មោះថា ជាកំពូលលើភិក្ខុសាវកអ្នកទ្រទ្រង់វិន័យ ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលពោលតាមលំដាប់ដូច្នេះ ៗ

បានឮថា ព្រះថេរៈនេះ គ្រាព្រះពុទ្ធព្រះនាមថា **បទុមុត្តរៈ** កើតក្នុងត្រកូលក្នុងក្រុងហង្សវតី ថ្ងៃមួយកំពុងស្ដាប់ធម្មកថារបស់ព្រះសាស្ដា ឃើញព្រះសាស្ដាទ្រង់ស្ថាបនាភិក្ខុមួយរូបទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលលើភិក្ខុសាវកអ្នកទ្រទ្រង់វិន័យ ធ្វើកុសលឲ្យក្រៃលែងឡើងទៅ ប្រាថ្នាតំណែងនោះ លោកធ្វើកុសលជរាប

អស់ជីវិត វិលវល់នៅក្នុងទេវតា និងមនុស្ស ។ ក្នុងពុទ្ធុប្បាទកាលនេះ បាន បដិសន្ធិក្នុងផ្ទះជាងកោរកាត់ បិតាមាតាតាំងឈ្មោះលោកថា **ឧបាលីកុមារ** លោក ជាអ្នកក្នាក់ងារតុបតែងព្រះរាជកុមារ ៦ ព្រះអង្គ កាលព្រះតថាគតប្រថាប់នៅ អនុបិយអម្ពវ័ន ក៏ចេញបួសព្រមជាមួយរាជកុមារ ៦ ព្រះអង្គ ដែលទ្រង់កំពុង ចេញព្រះផ្នួស វិធីបព្វជ្ជារបស់លោក មកហើយក្នុងព្រះបាលី លោកបព្វជ្ជា-ឧបសម្បទាហើយ សូមឲ្យព្រះសាស្តាត្រាស់ទូន្មានកម្មដ្ឋាន ក្រាបទូលថា បពិត្រ ព្រះអង្គដ៏ចម្រើន សូមទ្រង់អនុញ្ញាតឲ្យខ្ញុំព្រះអង្គនៅព្រៃចុះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ បើអ្នកនៅព្រៃ ក៏នឹងចម្រើនធុរៈតែម្យ៉ាង តែបើអ្នកនៅក្នុងសំណាក់ តថាគត វាសធុរៈ គឺ ការអប់រំ គន្ថធុរៈ គឺ ការសិស្សាក៏នឹងបរិបូណ៌ ព្រះថេរៈ ទទួលព្រះតម្រាស់របស់ព្រះសាស្តាហើយ ចម្រើនវិបស្សនា មិនយូរក៏សម្រេច ព្រះអរហត្ត គ្រានោះ ព្រះសាស្តាទ្រង់ឲ្យលោករៀនព្រះវិន័យបិដកទាំងអស់ ដោយ ព្រះអង្គឯង តមកលោកវិនិច្ឆ័យ ៣ រឿង ដែលពោលទុកហើយក្នុងខាងក្រោយ ព្រះសាស្តាប្រទានសាធុការ គាំទ្រក្នុងរឿងមួយៗ ដែលលោកវិនិច្ឆ័យហើយ ទ្រង់ ធ្វើរឿងទាំង ៣ ដែលលោកវិនិច្ឆ័យហើយឲ្យជាអត្ថុប្បត្តិ ទើបទ្រង់ស្ថាបនាព្រះ ថេរៈទុកក្នុងតំណែងឯតទគ្គៈជាកំពូលលើភិក្ខុសាវកអ្នកទ្រង់វិន័យនោះឯង ។

ចប់អដ្ឋកថា សូត្រទី ៦

# អដ្ឋកថាសូត្រទី ៧

## ប្រវត្តិព្រះនន្ទកត្ថេរ

*ក្នុងសូត្រទី ៧ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[១៤៩] *បទថា* ***ភិក្ខុនោវាទកានំ*** *បានដល់ ជាអ្នកឱវាទពោលទូន្មានភិក្ខុនីពិតណាស់ ព្រះថេរៈនេះ កាលពោលធម្មកថា ក៏ធ្វើភិក្ខុនី ៥០០ រូប ឲ្យសម្រេចព្រះអរហត្ត ក្នុងការប្រជុំតែមួយដង ព្រោះហេតុនោះ លោកទើបឈ្មោះថា ជាកំពូលលើភិក្ខុសាវកអ្នកទូន្មានភិក្ខុនី ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលនឹងពោលតាមលំដាប់ដូច្នេះ ។*

*ព្រះថេរៈរូបនេះ គ្រាព្រះពុទ្ធព្រះនាមថា* ***បទុមុត្តរៈ*** *កើតក្នុងត្រកូលក្នុងក្រុងហង្សវតី កំពុងស្តាប់ធម្មកថារបស់ព្រះសាស្តា ឃើញព្រះសាស្តាស្ថាបនាភិក្ខុមួយរូបទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលលើភិក្ខុសាវកអ្នកឱវាទទូន្មានភិក្ខុនី ទើបធ្វើកុសលដ៏ក្រៃលែងឡើងទៅ ប្រាថ្នាតំណែងនោះ លោកធ្វើកុសលរហូតអស់ជីវិត វិលវល់នៅក្នុងទេវតា និងមនុស្ស ។ គ្រាពុទ្ធុប្បាទកាលនេះ ក៏បានបដិសន្ធិក្នុងត្រកូលក្នុងក្រុងសាវត្ថី ចម្រើនវ័យហើយ ស្តាប់ព្រះធម៌ទេសនារបស់ព្រះសាស្តា បានសទ្ធា ក៏បួសក្នុងសំណាក់ព្រះសាស្តា ចម្រើនវិបស្សនាហើយ*

សម្រេចព្រះអរហត្ត ជាអ្នកស្ទាត់ជំនាញក្នុងបុព្វេនិវាសញ្ញាណ កាលបរិស័ទ ៤ មកដល់ហើយ លោកអាចកំណត់ចិត្តរបស់បរិស័ទបានទាំងអស់ ហើយពោលធម្មកថា ព្រោះដូច្នោះ លោកទើបឈ្មោះថា ព្រះនន្ទកៈធម្មកថិក សូម្បីព្រះតថាគត កាលសក្យបុត្ត ៥០០ អង្គ ចេញបួសពីត្រកូល ព្រោះមក្កុដរាជ កើតអផ្សុកប្រាថ្នាលាសិក្ខា ក៏ទ្រង់នាំភិក្ខុជាសាកិយបុត្តទាំងនោះ ទៅកាន់ស្រះកុណាលៈ ទ្រង់ជ្រាបថា ភិក្ខុទាំងនោះសង្វេគ ព្រោះត្រាស់រឿងកុណាលជាតក ទើបត្រាស់កថាពោលអំពីសច្ចៈ ៤ ឲ្យលោកតាំងនៅក្នុងសោតាបត្តិផល តមកត្រាស់មហាសមយសូត្រ ឲ្យលោកសម្រេចព្រះអរហត្ត ដែលជាផលដ៏ប្រសើរ ភរិយារបស់ព្រះថេរៈទាំងនោះមានចិត្តតែម្យ៉ាងដូចគ្នាថា ឥឡូវនេះ យើងនឹងធ្វើអ្វីក្នុងទីនេះ ទើបនាំគ្នាចូលទៅរកព្រះមហាបជាបតីថេរី សូមបព្វជ្ជា ភរិយាទាំង ៥០០ បានបព្វជ្ជាឧបសម្បទាក្នុងសំណាក់ព្រះថេរីហើយ តែក្នុងអតីតជាតិ ភរិយាទាំងអស់បានជាបាទបរិចា-រិការបស់ព្រះនន្ទកត្ថេរ កាលតាំងនៅក្នុងអត្តភាពជាព្រះរាជា ។ សម័យនោះ ព្រះសាស្តាត្រាស់បង្គាប់ថា ពួកភិក្ខុចូរទូន្មានពួកភិក្ខុនី ព្រះថេរៈ កាលដល់វារៈ (វេន) ក៏ដឹងថា ភិក្ខុនីទាំងនោះជាបាទបរិចារិការបស់ខ្លួនក្នុងភពមុន ទើបគិតថា ភិក្ខុដែលបានបុព្វេនិវាសញ្ញាណ ឃើញយើងកំពុងអង្គុយកណ្តាលភិក្ខុនីសង្ឃ នាំឧបមាហេតុណាមួយជាដើមមក ពោលធម៌ ពិចារណាមើលហេតុការនេះហើយ

នឹងគប្បីនិយាយចំអកថា ព្រះនន្ទកៈមិនទាន់លះបង់ពួកស្នំរហូតដល់សព្វថ្ងៃនេះ លោកនៅមានពួកស្នំស្រស់សង្ហាហែហមទៀត ព្រោះហេតុនោះ លោកទើបមិនទៅដោយខ្លួនឯង បញ្ជូនភិក្ខុរូបដទៃទៅជំនួស តែភិក្ខុនីទាំង ៥០០ រូបនោះ មានបំណងចំពោះឱវាទរបស់ព្រះថេរៈ ដោយហេតុនេះ កាលដល់វារៈរបស់លោក ព្រះមានព្រះភាគ ទើបទ្រង់មិនបញ្ជូនភិក្ខុរូបដទៃទៅជំនួស ត្រាស់ចំពោះលោកថា អ្នកចូរទៅដោយខ្លួនឯង ទូន្មានភិក្ខុនីសង្ឃ លោកមិនអាចជំទាស់ព្រះតម្រាស់របស់ព្រះសាស្តាបាន កាលដល់វារៈរបស់ខ្លួន ទើបឲ្យឱវាទភិក្ខុនីសង្ឃថ្ងៃ ១៤ រោច ឲ្យភិក្ខុនីទាំងនោះគ្រប់រូប តាំងនៅក្នុងសោតាបត្តិផល ដោយធម្មទេសនាដែលប្រដាប់ដោយសឡាយតនៈ (អាយតនៈ ៦) ភិក្ខុនីទាំងនោះ រីករាយចំពោះធម្មទេសនារបស់ព្រះថេរៈ នាំគ្នាទៅសំណាក់ព្រះសាស្តា ទូលប្រាប់គុណដែលខ្លួនបាន ព្រះសាស្តាទ្រង់នឹកថា នរណាហ្ន៎សម្តែងធម៌ ទើបភិក្ខុនីទាំងនេះគប្បីសម្រេចមគ្គផលជាន់លើៗ ទៅ ទ្រង់ឃើញថា ភិក្ខុនីទាំង ៥០០ នោះ ស្តាប់ធម្មទេសនារបស់នន្ទកៈទៀត ក៏នឹងសម្រេចព្រះអរហត្ត ថ្ងៃស្អែក ទើបទ្រង់បញ្ជូនភិក្ខុនីទាំងនោះទៅ ដើម្បីស្តាប់ធម្មទេសនាក្នុងសំណាក់ព្រះថេរៈតែម្នាក់ លុះស្អែកឡើង ភិក្ខុនីទាំងនោះស្តាប់ធម៌ហើយ ក៏សម្រេចព្រះអរហត្តទាំងអស់ ថ្ងៃនោះវេលាដែលភិក្ខុនីទាំងនោះមកគាល់ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា ធម្មទេសនា

មានផល ទើបត្រាស់ថា កាលម្សិលមិញ ធម្មទេសនារបស់នទួក: ដូចជាព្រះច័ន្ទ ១៤ កើត ថ្ងៃនេះ ដូចជាព្រះច័ន្ទ ១៥ កើត ហើយទ្រង់ធ្វើហេតុនោះឯង ឲ្យជាអត្ថុប្បត្តិហេតុកើតរឿង ទើបទ្រង់ស្ថាបនាព្រះថេរៈ ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលលើពួកភិក្ខុសាវកអ្នកឲ្យឱវាទទូន្មានភិក្ខុនី ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ៧

# អដ្ឋកថាសូត្រទី ៨

## ប្រវត្តិព្រះនន្ទត្ថេរៈ

*ក្នុងសូត្រទី ៨ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[១៨៩] *ដោយបទថា* ***ឥន្ទ្រិយេសុ គុត្តទ្វារានំ*** *លោកសម្ដែងថា ព្រះនន្ទត្ថេរៈ ជាកំពូលលើពួកភិក្ខុសាវកអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ ៦ ។ សេចក្ដីពិត ព្រះសាវកទាំងឡាយរបស់ព្រះសាស្ដា ឈ្មោះថា មិនគ្រប់គ្រងទ្វារមិនមានក៏ពិត តែព្រះនន្ទត្ថេរៈ ត្រូវការទើងសម្លឹងមើលទិសណាៗ ក្នុងទិសទាំង ១០ មិនបានសម្លឹងមើលទិសនោះៗ ដោយប្រាសចាកសតិសម្បជញ្ញៈ ព្រោះហេតុនោះ លោកទើបឈ្មោះថា ជាកំពូលលើពួកភិក្ខុសាវកអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលគប្បីពោលតាមលំដាប់ ដូច្នេះ*

*ព្រះថេរៈរូបនេះ សម័យព្រះពុទ្ធព្រះនាមថា* ***បទុមុត្តរៈ*** *បានបដិសន្ធិក្នុងត្រកូលក្រុងហង្សវតី ចម្រើនវ័យហើយ កំពុងស្ដាប់ធម៌ក្នុងសំណាក់ព្រះសាស្ដា ឃើញព្រះសាស្ដាស្ថាបនាភិក្ខុមួយរូបទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលលើពួកភិក្ខុសាវកអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ទើបធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ ។ លោកធ្វើកុសលជរាបអស់ជីវិត វិលវល់នៅក្នុងទេវតា*

និងមនុស្ស ហើយបានបដិសន្ធិក្នុងព្រះគភ៌របស់ព្រះនាងមហាបជាបតិគោតមី ក្នុងក្រុងកបិលពស្តុ ។ គ្រានោះ ក្នុងថ្ងៃទទួលព្រះនាម លោកធ្វើឲ្យពួកព្រះញាតិរីករាយត្រេកអរ ព្រោះហេតុនោះ ពួកព្រះញាតិ ទើបដាក់ព្រះនាមរបស់លោកថា **នន្ទកុមារ** ។ សូម្បីព្រះមហាសត្វ ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណហើយប្រកាសព្រះធម្មចក្កដ៏ប្រសើរ ទ្រង់អនុគ្រោះលោក ស្តេចយាងចាកក្រុងរាជគ្រឹះទៅកាន់ក្រុងកបិលពស្តុ ទ្រង់ធ្វើព្រះពុទ្ធបិតាឲ្យតាំងនៅក្នុងសោតាបត្តិផល ក្នុងកាលដែលទ្រង់គាល់ជាលើកដំបូងប៉ុណ្ណោះ ថ្ងៃស្អែក ស្តេចយាងទៅព្រះរាជនិវេសន៍របស់ព្រះពុទ្ធបិតា ប្រទានឱវាទដល់ព្រះមាតារបស់ព្រះរាហុល និងទ្រង់ត្រាស់សម្តែងធម៌ដល់ជនក្រៅពីនោះ ។ ថ្ងៃស្អែក កាលកិច្ចការអាវាហមង្គលនន្ទកុមារកំពុងដំណើរការអភិសេក ព្រះដ៏មានព្រះភាគស្តេចក៏យាងទៅនិវេសន៍របស់នន្ទកុមារនោះ ទ្រង់ឲ្យនន្ទកុមារកាន់បាត្រព្រះអង្គ ហើយស្តេចបែរព្រះភក្ត្រទៅព្រះវិហារ ដើម្បីឲ្យគេបព្វជ្ជា កិច្ចការមង្គលអភិសេក ក៏រារាំងនន្ទកុមារនោះមិនបាន ។ វេលានន្ទកុមារកាន់បាត្រតាមស្តេច ជនបទកល្យាណីក៏ឡើងកាន់ប្រាសាទជាន់លើ បើកសីហបញ្ជរ ស្រែកប្រាប់ថា ព្រះអយ្យបុត្ត សូមត្រឡប់មកវិញឲ្យរហ័សៗ នន្ទកុមារនោះ បានឮសំឡេងនាង ក៏បានត្រឹមតែក្រឡេកមើលដោយចិត្តជ្រួលច្របល់ មិនអាចធ្វើនិមិត្តឲ្យសម្គាល់បានតាមសេចក្តីពេញចិត្ត ព្រោះ

គោរពក្នុងព្រះសាស្តា ។ ដោយហេតុនោះ នន្ទកុមារនោះ ទើបមានការក្តៅចិត្ត ។ ខណៈនោះ នន្ទកុមារក៏គិតឃើញថា ព្រះសាស្តានឹងឲ្យត្រឡប់វិញត្រង់នេះ ព្រះសាស្តា នឹងឲ្យត្រឡប់វិញត្រង់នេះ ព្រះសាស្តាទ្រង់ក៏នាំទៅព្រះវិហារឲ្យបព្វជ្ជា ។ នន្ទកុមារកាលបព្វជ្ជាហើយ ក៏មិនសប្បាយ បានត្រឹមតែនៅស្ងៀម ចាប់ពីថ្ងៃបព្វជ្ជាហើយ ក៏នៅរឭកដល់ពាក្យរបស់នាងជនបទកល្យាណីទុំះឯង ដូចគ្នានឹងនាងជនបទកល្យាណីនោះ មកឈរមិនឆ្ងាយ នន្ទកុមារនោះ ត្រូវសេចក្តីអផ្សុកចង់លាសិក្ខាចូលមកបៀតបៀនធ្ងន់ឡើងៗ ក៏ដើរចេញទៅ កាលដើរដល់ម្តុំព្រៃឈើ ឬដង្គត់ឈើ ក៏ឃើញដូចជាព្រះទសពលមកប្រថាប់ឈរខាងមុខ លោកប្រៀបដូចជារោមមាន់ ដែលយកដាក់ជិតគំនរភ្លើង ទើបត្រឡប់ចូលទីនៅរបស់ខ្លួន ។

ព្រះសាស្តាទ្រង់ព្រះតម្រិះថា នន្ទនៅមានសេចក្តីប្រមាទណាស់ មិនអាចរម្ងាប់សេចក្តីអផ្សុកចង់សឹកបាន គប្បីធ្វើការរំលត់សេចក្តីទាស់ចិត្តរបស់គេចេញ បន្ទាប់ពីនោះ ក៏ត្រាស់នឹងព្រះនន្ទថា មកនន្ទ យើងនឹងទៅទេវលោកជាមួយគ្នា ព្រះនន្ទទូលសួរថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គ នឹងទៅកាន់ទីដែលពួកលោកអ្នកមានឫទ្ធិទៅ បានយ៉ាងណា ត្រាស់ឆ្លើយថា អ្នកចូរធ្វើចិត្តគិតនឹងទៅតែម្យ៉ាង ទៅហើយក៏នឹងឃើញ ។ ព្រះនន្ទនោះ តាមស្តេចចារិកទៅទេវលោក

ជាមួយព្រះតថាគត ដោយអានុភាពរបស់ព្រះទសពល ក្រឡេកមើលទៅនិវេសន៍របស់ស្តេចសក្កទេវរាជ ក៏ឃើញទេពអប្សរ ៥០០ នាក់ ព្រះសាស្តាទ្រង់ឃើញព្រះនន្ទត្ថេរ ក្រឡេកមើលដោយសុភនិមិត្ត ទើបត្រាស់សួរថា នន្ទ ទេពអប្សរទាំងនេះ ឬនាងជនបទកល្យាណី ជាទីគួរពេញចិត្ត ។ ទូលថា បពិត្រព្រះអង្គដ៏ចម្រើន នាងជនបទកល្យាណី ប្រៀបនឹងទេពអប្សរទាំងនេះហើយ នឹងប្រាកដដូចគ្មានទីឯនាងពានរដែលកំបុតត្រចៀក ច្រមុះ ដូច្នោះ ព្រះអង្គ ។ ទ្រង់ត្រាស់ថា នន្ទ ទេពអប្សរទាំងនេះ បានមិនលំបាកឡើយ សម្រាប់អ្នកធ្វើសមណធម៌ ។ ទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើព្រះដ៏មានព្រះភាគទ្រង់ទទួលធានាដល់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គក៏នឹងធ្វើសមណធម៌ ។ ព្រះដ៏មានព្រះភាគត្រាស់ថា នន្ទ អ្នកចូរទុកចិត្តចុះ អ្នកចូរធ្វើសមណធម៌ទៅ កាលបើអ្នកនឹងស្លាប់ ដូចដែលសត្វមានបដិសន្ធិ តថាគតធានាថា នឹងបាននាងទេពអប្សរទាំងនោះ ។

ព្រះសាស្តាស្តេចចារិកទៅទេវលោក តាមពុទ្ធអធ្យាស្រ័យហើយ ទើបស្តេចត្រឡប់មកព្រះជេតវនដូចដើម ។ តាំងពីនោះមក ព្រះនន្ទត្ថេរ ក៏ប្រឹងប្រែងក្នុងសមណធម៌ទាំងពេលយប់ទាំងពេលថ្ងៃ ព្រោះហេតុចង់បាននាងទេពអប្សរ ។ ព្រះសាស្តាទ្រង់បង្គាប់ភិក្ខុទាំងឡាយថា ក្នុងទីនៅរបស់នន្ទ ពួកអ្នកចូរដើរនិយាយក្នុងទីនោះៗ ថា គេថាភិក្ខុមួយរូប ឲ្យព្រះទសពលទទួលធានាហើយ ទើបធ្វើ

សមណធម៌ ព្រោះហេតុចង់បាននាងទេពអប្សរទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធតម្រាស់ហើយ ក៏ដើរនិយាយថា គេថាព្រះនន្ទ ជាកូនឈ្នួល គេថាព្រះនន្ទត្រូវទិញមក ប្រព្រឹត្តព្រហ្មចរិយៈ ព្រោះហេតុចង់បាននាងទេពអប្សរទាំងឡាយ គេថា ព្រះដ៏មានព្រះភាគទ្រង់ទទួលធានាចំពោះព្រះនន្ទនោះ ដែលនឹងបាននាងទេពអប្សរ ៥០០ នាក់ ដែលមានជើងដូចមាន់[១] ភិក្ខុទាំងនោះ ឈរក្នុងទីជិតៗព្រះនន្ទ ល្មមនឹងឃើញ ល្មមនឹងឮបាន ហើយដើរនិយាយ ព្រះនន្ទត្ថេរ បានឮរឿងនោះ គិតថា ភិក្ខុទាំងនេះ មិននិយាយដល់អ្នកដទៃ គឺ និយាយប្រារព្ធដល់យើង ការធ្វើរបស់យើងមិនត្រឹមត្រូវដោយពិត ក៏ពិចារណាឡើងវិញ ហើយចម្រើនវិបស្សនា ក៏បានសម្រេចព្រះអរហត្ត ។ ខណៈដែលលោកសម្រេចព្រះអរហត្តនុ៎ះឯង ទេវតាមួយអង្គ ក៏ទូលរឿងនោះដល់ព្រះដ៏មានព្រះភាគ ។ សូម្បីព្រះដ៏មានព្រះភាគ ទ្រង់ក៏បានជ្រាបដោយព្រះអង្គឯង ។ ថ្ងៃស្អែក ព្រះនន្ទត្ថេរចូលទៅគាល់ព្រះដ៏មានព្រះភាគ ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគទ្រង់ទទួលធានាខ្ញុំព្រះអង្គ ដើម្បីនឹងបាននាងទេពអប្សរ ៥០០ នាក់ ដែលមានជើងដូចមាន់ យ៉ាងណា ខ្ញុំព្រះអង្គសូមដោះព្រះដ៏មានព្រះភាគពីបដិស្សវៈការទទួលពាក្យនោះវិញ ព្រះអង្គ ។ រឿងកើតឡើងដូចពោលមកយ៉ាងនេះ ។ តមកខាងក្រោយ ព្រះសាស្តា ប្រថាប់នៅក្នុងព្រះជេតវនវិហារ ទ្រង់បាន

ស្ថាបនាព្រះថេរៈទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលលើពួកភិក្ខុសាវកអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយនោះឯង ។

ចប់អដ្ឋកថា សូត្រទី ៨

---

(១) បាឋៈថា កុក្កុដបាទានំ ។ ក្ខមាជា កកុដបាទីនំ ប្រែថា មានជើងដូចសត្វព្រាប ក្នុងទីដទៃប្រើថា កបោតក ប្រែថា សត្វព្រាប ដូចគ្នា ។

# អដ្ឋកថាសូត្រទី ៩

## ប្រវត្តិព្រះមហាកប្បិនត្ថេរ

ក្នុងសូត្រទី ៩ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[១៨៩] បទថា *ភិក្ខុឱវាទកានំ* លោកសំដែងថា ព្រះមហាកប្បិនត្ថេរ ជាកំពូលលើពួកភិក្ខុសាវកអ្នកឲ្យឱវាទដល់ភិក្ខុ ។ បានឮថា ព្រះថេរៈនេះ ពោលធម្មកថាក្នុងការប្រជុំតែមួយដងប៉ុណ្ណោះ ក៏ធ្វើភិក្ខុ ១.០០០ រូប ឲ្យបានសម្រេចព្រះអរហត្ត ព្រោះហេតុនោះ លោកទើបឈ្មោះថា ជាកំពូលលើពួកភិក្ខុសាវកអ្នកឲ្យឱវាទដល់ភិក្ខុ ។ ក្នុងបញ្ហាកម្មរបស់លោកមានរឿងដែលនឹងពោលតាមលំដាប់ ដូច្នេះ ៖

ពិតណាស់ ព្រះថេរៈរូបនេះ សម័យព្រះពុទ្ធព្រះនាមថា **បទុមុត្តរៈ** បានកើតក្នុងត្រកូលក្នុងក្រុងហង្សវតី តមក កំពុងស្តាប់ធម្មកថារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូបទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលលើពួកភិក្ខុសាវកអ្នកឲ្យឱវាទដល់ភិក្ខុ ក៏ធ្វើកុសលឲ្យក្រៃលែងឡើង ទើបប្រាថ្នាតំណែងនោះ ។ លោកធ្វើកុសលរហូតអស់ជីវិត វិលវល់នៅក្នុងទេវតា និងមនុស្សក្នុងសម័យព្រះសម្មាសម្ពុទ្ធព្រះនាមថា **កស្សបៈ** បានបដិសន្ធិក្នុងត្រកូល ក្នុង

ក្រុងពារាណសី ជាប្រធានលើបុរស ១.០០០ នាក់ កសាងបរិវេណធំប្រដាប់ដោយបន្ទប់ ១.០០០ ។ អ្នកទាំងអស់នោះ ធ្វើកុសលដរាបអស់ជីវិត លើកកប្បិនឧបាសកឲ្យធ្វើជាប្រធាន ព្រមទាំងបុត្រភរិយា កើតក្នុងទេវលោក វិលវល់នៅក្នុងទេវតា និងមនុស្សរហូតអស់មួយពុទ្ធន្តរ ។ គ្រានោះ មុនព្រះសាស្តារបស់យើងឧប្បត្តិ កប្បិនៈនេះ បានបដិសន្ធិក្នុងរាជនិវេសន៍ នាកុក្កុដវតីនគរ ក្នុងបច្ចន្ត-ប្រទេស ។ បរិស័ទក្រៅពីនោះ កើតក្នុងត្រកូលអាមាត្រ ក្នុងនគរនោះឯង ។ បណ្តាអ្នកទាំងនោះ កប្បិនកុមារ គ្រាព្រះរាជបិតាសោយទីវង្គតទៅ ក៏លើកស្វេតឆត្រជាព្រះរាជាព្រះនាមថា **កប្បិនៈ** ។ ស្ត្រីជាមេផ្ទះរបស់ព្រះអង្គ កាលសាងកល្យាណកម្មក្នុងជាតិមុន ក៏កើតក្នុងរាជត្រកូល ដែលមានជាតិ និងភោគ-សម្បត្តិប្រហាក់ប្រហែលគ្នា ជាព្រះអគ្គមហេសីរបស់ព្រះបាទមហាកប្បិននោះ ។ តែព្រោះព្រះនាងមានព្រះឆវីវណ្ណដូចផ្កានោនង ទើបមានព្រះនាមថា **អនោជាទេវី** ។ សូម្បីព្រះបាទមហាកប្បិន ទ្រង់ក៏ពេញព្រះហឫទ័យក្នុងសុតៈ (ការសិក្សា) ភ្ញាក់ពីផ្ទំក្នុងពេលព្រឹកព្រលឹម ទ្រង់បញ្ជូនទូតដោយរហ័សចេញតាមទ្វារទាំង ៤ ដោយព្រះតម្រាស់ថា ពួកអ្នកបើជួបពួកពហុស្សូត ទ្រទ្រង់សុតៈក្នុងទីណា ត្រឡប់មកពីទីនោះវិញ ចូរមកប្រាប់យើង ដូច្នេះ ។

សម័យនោះ ព្រះសាស្តារបស់យើងទ្រង់ឧប្បត្តិក្នុងលោកហើយ ទ្រង់បាន

ប្រជាប់នៅក្រុងសាវត្ថី ។ វេលានោះពួកឈ្មួញក្រុងសាវត្ថី ទទួលទំនិញដែលកើតឡើងក្នុងក្រុងសាវត្ថីទៅកាន់នគរនោះ ទុកដាក់ទំនិញហើយ ក៏កាន់បណ្ណាការសំដៅទីនគាល់ព្រះរាជា ទៅដល់ទ្វារព្រះរាជនិវេសន៍ ជ្រាបថា ព្រះរាជាស្តេចទៅព្រះរាជឧទ្យាន ទើបទៅទីព្រះរាជឧទ្យាន ឈរនៅទីជិតៗ ទ្វារ ប្រាប់អ្នកចាំទ្វារព្រះរាជឧទ្យាន ។ លុះគេទូលឲ្យទ្រង់ជ្រាបហើយ ព្រះរាជាត្រាស់បង្គាប់ឲ្យចូលគាល់ ពួកគេថ្វាយបណ្ណាការហើយ ឈរថ្វាយ បង្គំ ត្រាស់សួរថា បាអើយពួកលោកនាំគ្នាមកពីទីណា ។ ក្រាបទូលថា មកពីក្រុងសាវត្ថី ព្រះអង្គ ។ត្រាស់សួរថា ដែនទាំងនោះមានអាហាររកងាយឬ ព្រះរាជាទ្រទ្រង់ធម៌ទេឬ ក្រាបទូលថា យ៉ាងនោះឯង ព្រះអង្គត្រាស់សួរទៀតថា ក៏ក្នុងស្រុករបស់លោកមានដំណឹងអ្វីខ្លះ ។ ក្រាបទូលថា មានព្រះអង្គ តែមិនអាចក្រាបទូលបានដោយទាំងមាត់ដែលនៅមិនស្អាត ។ ព្រះរាជាទើបឲ្យព្រះរាជទានទឹកដោយឃ្លោកមាស ។ឈ្មួញទាំងនោះ ខ្ពុរមាត់ហើយបែរមុខទៅផ្លូវព្រះទសពល ផ្គងអញ្ជលីក្រាបទូលថា បពិត្រសម្មតិទេព ក្នុងស្រុករបស់ខ្ញុំព្រះអង្គ ព្រះពុទ្ធរតនៈកើតឡើងហើយព្រះអង្គ ។ ពេលស្តាប់ពាក្យថា **ពុទ្ធោ** ប៉ុណ្ណោះ ព្រះរាជាក៏ទ្រង់កើតបីតិជ្រួតជ្រាបទូទាំងព្រះវរកាយ ។ តពីនោះត្រាស់ថា បាអើយ ពួកលោកនិយាយថា **ពុទ្ធោ** ឬ ។ ក្រាបទូលថា ពួកខ្ញុំព្រះអង្គនិយាយថា **ពុទ្ធោ** ព្រះអង្គ ។ ទ្រង់ឲ្យ

ពួកឈ្មួញពោលយ៉ាងនោះ ៣ ដង ។ បទថា ពុទ្ធោ រកប្រមាណមិនបាន នរណាៗ មិនអាចធ្វើឲ្យមានប្រមាណបានឡើយ ។ ព្រះរាជាទ្រង់ជ្រះថ្លាក្នុងបទថា ព្រះពុទ្ធ-រតនៈកើតឡើងហើយនោះ ក៏ព្រះរាជទានទ្រព្យមួយសែន ហើយត្រាស់សួរថា មានដំណឹងដទៃទៀតទេ ក្រាបទូលថា បពិត្រសម្មតិទេព ព្រះធម្មរតនៈកើតឡើងហើយ ព្រះអង្គ ។ ទ្រង់ស្តាប់ដំណឹងនោះហើយ ទ្រង់ទទួលប្តេជ្ញាយ៉ាងនោះដូចគ្នា ព្រះរាជទានទ្រព្យមួយសែនទៀត ហើយត្រាស់សួរថា មានដំណឹងដទៃៗ ទៀតទេ ក្រាបទូលថា បពិត្រទេវៈ ព្រះសង្ឃរតនៈកើតឡើងហើយ ព្រះអង្គទ្រង់ស្តាប់ដំណឹងនោះហើយ ទ្រង់ក៏ទទួលប្តេជ្ញាយ៉ាងនោះដូចគ្នា ព្រះរាជទានទ្រព្យមួយសែនទៀត ទ្រង់សរសេរប្រការដែលព្រះរាជទានទ្រព្យក្នុងសំបុត្រ បញ្ជូនទៅដោយព្រះតម្រាស់ថា បាអើយ ពួកលោកចូរទៅសំណាក់ព្រះរាជទេវីចុះ ។ កាលពួកឈ្មួញនាំគ្នាទៅហើយ ទ្រង់បានត្រាស់សួរពួកអាមាត្រថា បាអើយ ព្រះពុទ្ធកើតឡើងក្នុងលោកហើយ ពួកលោកនឹងធ្វើយ៉ាងណា ។ ពួកអាមាត្រទូលសួរថា បពិត្រសម្មតិទេព ព្រះអង្គទ្រង់នឹងធ្វើយ៉ាងណា ។ ត្រាស់ថា យើងនឹងបួស ។ ពួកអាមាត្រក្រាបទូលថា ពួកខ្ញុំព្រះបាទក៏នឹងបួសទាំងអស់ ។ អ្នកទាំងនោះមិនមានការជាប់ជំពាក់ក្នុងផ្ទះ ឬទ្រព្យសម្បត្តិ នាំគ្នាឡើងសេះហើយក៏ចេញទៅ ។

ឯពួកឈ្មួញទៅគាល់ព្រះនាងអនោជាទេវី ថ្វាយនូវចុតហ្មាយ ។ ព្រះនាងទ្រង់អានសំបុត្រនោះហើយ ត្រាស់សួរថា បាអើយ ព្រះរាជាព្រះរាជទានកហាបណៈជាច្រើនដល់ពួកលោក ពួកលោកធ្វើអ្វី ។ ក្រាបទូលថា បពិត្រព្រះទេវី ពួកខ្ញុំព្រះអង្គនាំដំណឹងដែលគួរស្រឡាញ់ថ្វាយព្រះអង្គ ។ ត្រាស់សួរថា បាអើយ ពួកលោកអាចឲ្យយើងស្តាប់ដំណឹងនោះបានទេ ។ ក្រាបទូលថា បពិត្រព្រះទេវី បាន តែពួកខ្ញុំព្រះអង្គមិនអាចក្រាបទូល ដោយមាត់ដែលមិនស្អាតទេព្រះអង្គ ។ ព្រះនាងទើបឲ្យព្រះរាជទានទឹកដោយឃ្លោកមាស ។ ឈ្មួញទាំងនោះ ខ្ពុរមាត់ហើយ ក៏ក្រាបទូលទំនងដូចដែលក្រាបទូលព្រះរាជាមកហើយ ។ សូម្បីព្រះនាងក៏ទ្រង់កើតបាមោជ្ជៈ ឲ្យពួកឈ្មួញទទួលបេ្តជ្ញា ៣ ដង ក្នុងបទតែមួយ ដោយន័យនោះដូចគ្នា ព្រះរាជទានទ្រព្យមួយបទបីសែន ៣ បទ រួមជា ៩ សែន ។ ពួកឈ្មួញបានទ្រព្យរួមទាំងអស់ដល់មួយលានពីរសែន ។ គ្រានោះ ព្រះនាងត្រាស់សួរពួកឈ្មួញថា ព្រះរាជាស្តេចទៅណា ។ ពួកឈ្មួញក្រាបទូលថា បពិត្រព្រះទេវី ព្រះរាជាស្តេចចេញទៅបំណង់នឹងទ្រង់ព្រះផ្នួស ព្រះអង្គ ។ ព្រះនាងទ្រង់បញ្ជូនពួកឈ្មួញទៅដោយព្រះតម្រាស់ថា បាអើយ បើដូច្នោះ ពួកលោកចូរត្រឡប់ទៅចុះ ហើយត្រាស់បង្គាប់ឲ្យហៅពួកករិយារបស់ពួកអាមាត្រដែលទៅជាមួយព្រះរាជាមក ហើយត្រាស់សួរថា នាងទាំងឡាយ ពួកនាងដឹងទឹកខ្លែងដែលពួក

ស្វាមីនាងទៅទេ ។ ក្រាបទូលថា បពិត្រម៉ែម្ចាស់ មិនជ្រាបទេ ពួកស្វាមីខ្ញុំព្រះអង្គទៅលេងឧទ្យានជាមួយព្រះរាជា ។ ត្រាស់ថា អើនាង ហើយនាំគ្នាទៅកាន់ឧទ្យាននោះ ក៏បានដំណឹងថា ព្រះពុទ្ធកើតឡើងហើយ ព្រះធម៌កើតឡើងហើយ ព្រះសង្ឃកើតឡើងហើយ ក៏នាំគ្នាបំណងនឹងបួសក្នុងសំណាក់ព្រះទសពល ពួកនាងនឹងធ្វើយ៉ាងណា ។ ក្រាបទូលសួរថា បពិត្រម៉ែម្ចាស់ ក៏ព្រះនាងប្រាថ្នាយ៉ាងណា ។ ត្រាស់ឆ្លើយថា យើងនឹងបួស ក្រាបទូលថា បើដូច្នោះពួកខ្ញុំព្រះអង្គក៏នឹងបួស ។ ទាំងអស់គ្នាឲ្យទឹមរថ ហើយនាំគ្នាចេញទៅ ។

ចំណែកព្រះរាជាស្ដេចដល់មាត់ស្ទឹងគង្គា ព្រមទាំងអាមាត្យមួយពាន់នាក់ ខណៈនោះ ស្ទឹងគង្គាមានទឹកពេញប្រៀប ឃើញស្ទឹងគង្គានោះហើយ ក៏ត្រិះរិះនិងអធិដ្ឋានថា ស្ទឹងគង្គាមានទឹកពេញប្រៀប សម្បូរដោយត្រីកាច មិនមានទាសៈឬមនុស្សដែលមកជាមួយពួកយើង ដែលគប្បីឲ្យទូក ឬក្បូនដល់ពួកយើងក្នុងទីនេះ តែជម្មតាថា ព្រះគុណទាំងឡាយរបស់ព្រះសាស្ដាផ្សាយទៅខាងក្រោម ពីអវីចិមហានរកដរាបដល់ភវគ្គព្រហ្ម ក៏បើព្រះសាស្ដាទ្រង់ជាព្រះសម្មាសម្ពុទ្ធសោត សូមខ្នងក្រចកសេះទាំងនេះចូរកុំសើមដោយទឹកឡើយ ហើយក៏ជេញសេះកាត់លើផ្ទៃទឹក ។ សូម្បីក្រចកសេះតែមួយក្បាល ក៏មិនបានសើមឡើយ ។ ដល់ត្រើយម្ខាង ដូចទៅដោយរាជមគ្គា ហើយស្ដេចក៏យាងដល់មហានទីដទៃៗ ខាងមុខ ។

ត្រាស់សួរថា ទន្លេទីពីរឈ្មោះអ្វី ។ ក្រាបទូលថា ឈ្មោះថា **នីលវាហិនី** មាន ប្រមាណកន្លះយោជន៍ទាំងជ្រៅ ទាំងធំ ព្រះអង្គ ។ ក្នុងទន្លេនោះ មិនមានសច្ច-កិរិយាយ៉ាងដទៃ នាំគ្នាឆ្លងស្ទឹងដ៏ធំកន្លះយោជន៍ដោយសច្ចកិរិយាសូម្បីនោះ កាល ដល់មហាទន្លេទីបីឈ្មោះថា **ចន្ទភាគ** ក៏នាំគ្នាឆ្លងដោយសច្ចកិរិយានោះឯង ។

ក្នុងថ្ងៃនោះ ព្រះសាស្តាទ្រង់ចេញចាកមហាករុណាសមាបត្តិ ត្រួតមើល សត្វលោកក្នុងវេលាជិតភ្លឺ ក៏ទ្រង់ឃើញថា ថ្ងៃនេះព្រះរាជាមហាកប្បិន ទ្រង់ លះបង់រាជសម្បត្តិមានអាមាត្រជាបរិវារ ស្តេចមកអស់រយៈផ្លូវ ៣០០ យោជន៍ ដើម្បីទ្រង់ព្រះផ្នួសក្នុងសំណាក់តថាគត ទ្រង់ត្រិះរិះថា គួរតថាគតនឹងទៅទទួល ពួកគេ ទើបទ្រង់បដិបត្តិសរីរកិច្ចពីព្រឹកព្រលឹម មានភិក្ខុសង្ឃជាបរិវារ ស្តេច បិណ្ឌបាតក្នុងក្រុងសាវត្ថី ខាងក្រោយភត្តហើយ ស្តេចត្រឡប់ពីបិណ្ឌបាត តែ មួយព្រះអង្គឯង ស្តេចហោះទៅប្រថាប់គង់ក្រោមដើមជ្រៃធំ ដែលដុះនៅត្រង់ កំពង់ដែលអ្នកទាំងនោះនឹងឆ្លង នាច្រាំងស្ទឹងចន្ទភាគ ទ្រង់តាំងព្រះសតិចំពោះ មុខ បញ្ចេញព្រះពុទ្ធឆព្វណ្ណរង្សី ។ អ្នកទាំងនោះឆ្លងត្រង់កំពង់នោះ ឃើញព្រះ ពុទ្ធរស្មីផ្ទៃលធ្លាត់ទៅមក ឃើញព្រះភក្ត្ររបស់ព្រះទសពល មានព្រះសិរីដូចជា ព្រះច័ន្ទពេញវង់ ក៏ញាប់ញ័រក្នុងចិត្តដោយអាការឃើញប៉ុណ្ណោះថា ពួកយើងបួស ចំពោះព្រះសាស្តាព្រះអង្គណា ព្រះសាស្តាព្រះអង្គនោះ ជាព្រះអង្គនេះដោយពិត

ក៏បង្អោនកាយថ្វាយបង្គំតាំងពីទីដែលបានឃើញព្រះសាស្តា ព្រះរាជាបង្អោនចាប់ត្រង់កព្រះបាទព្រះសាស្តា ថ្វាយបង្គំហើយ ប្រថាប់អង្គុយក្នុងទីដ៏សមគួរព្រមទាំងអាមាត្យមួយពាន់នាក់ ព្រះសាស្តាត្រាស់ធម្មកថាប្រោសអ្នកទាំងនោះ ចប់ព្រះទេសនា គ្រប់គ្នាក៏តាំងនៅក្នុងព្រះអរហត្ត សូមបព្វជ្ជា ។ ព្រះសាស្តាទ្រង់ជ្រាបថា អ្នកទាំងនេះបានថ្វាយចីវរទានទុកក្នុងជាតិមុន ទើបត្រូវទទួលបាត្រចីវររបស់ខ្លួន ហើយទ្រង់លាព្រះហត្ថមានវណ្ណៈដូចមាស ត្រាស់ថា ចូរជាភិក្ខុចុះធម៌តថាគតពោលល្អហើយ ពួកអ្នកចូរប្រព្រឹត្តព្រហ្មចរិយៈដើម្បីធ្វើទីបំផុតទុក្ខដោយប្រពៃចុះ ។ ឈ្មោះថា លោកទាំងនោះបព្វជ្ជា និងឧបសម្បទាហើយ បាននាំគ្នាហែហមព្រះសាស្តា ដូចព្រះថេរៈរយវស្សា ។

ចំណែកព្រះនាងអនោជាទេវី មានរថមួយពាន់ជាបរិវារ ស្តេចដល់ច្រាំងស្ទឹងគង្គា មិនឃើញទូក ឬក្បូនដែលនាំឆ្លងទៅ តែព្រោះទ្រង់ជាអ្នកឆ្លាត ទើបទ្រង់ត្រិះរិះថា ព្រះរាជាក៏គង់នឹងទ្រង់ធ្វើសច្ចកិរិយា ហើយស្តេចទៅ ក៏ព្រះសាស្តានោះ ទ្រង់មិនមែនកើតមកដើម្បីអ្នកទាំងនោះតែម្យ៉ាង បើព្រះអង្គទ្រង់ជាព្រះសម្មាសម្ពុទ្ធ រថទាំងឡាយរបស់ពួកយើងក៏កុំលិចក្នុងទឹក ទើបទ្រង់បររថកាត់តាមខ្នងទឹកនោះ ។ សូម្បីតែដុំ និងកង់របស់រថទាំងឡាយ ក៏មិនបានទទឹក ។ សូម្បីទន្លេទីពីរ ទីបី ក៏ទ្រង់ឆ្លងទៅបានដោយសច្ចៈនោះឯង កាលទ្រង់ឆ្លងទៅនុ៎ះឯង

ទ្រង់ឃើញព្រះសាស្ដាត្រង់ដើមជ្រៃ ។ លុះឃើញព្រះសាស្ដា ក៏ទ្រង់ត្រិះរិះថា ស្ត្រីទាំងនេះឃើញស្វាមីរបស់ខ្លួននឹងកើតធុរកៈ ហើយនឹងធ្វើអន្តរាយចំពោះមគ្គ-ផល ទាំងមិនអាចស្ដាប់ធម៌បាន ទើបទ្រង់ញាំងនូវឫទ្ធានុភាពដែលធ្វើមិនឲ្យពួកគេឃើញគ្នានិងគ្នាបាន ។ ស្ត្រីទាំងអស់នោះឡើងពីកំពង់ទឹកហើយ ថ្វាយបង្គំព្រះទសពលហើយអង្គុយ ព្រះសាស្ដាត្រាស់ធម្មកថាប្រោសស្ត្រីទាំងនោះ ។ ចប់ទេសនា ស្ត្រីគ្រប់រូបក៏តាំងនៅក្នុងសោតាបត្តិផល ទើបបានឃើញគ្នានិងគ្នា ។ ព្រះសាស្ដាទ្រង់ត្រិះរិះថា ឧប្បលវណ្ណាចូរមក ព្រះថេរីក៏មក បានឲ្យស្ត្រីទាំងនោះបព្វជ្ជា ហើយនាំទៅសំណាក់ភិក្ខុនី ព្រះសាស្ដាទ្រង់នាំភិក្ខុមួយពាន់រូប ស្ដេចទៅកាន់ព្រះជេតពនតាមផ្លូវអាកាស ។ គ្រានោះ ព្រះមហាកប្បិនត្ថេរ ដឹងថា កិច្ចខ្លួនដល់ទីបំផុតហើយ ក៏ជាអ្នកខ្វល់ខ្វាយតិច ធ្វើវេលាឲ្យកន្លងទៅដោយសេចក្ដីសុខក្នុងផលសមាបត្តិ នៅព្រៃក្ដី នៅគល់ឈើក្ដី នៅផ្ទះស្ងាត់ក្ដី ក៏ឧទានរឿយៗថា ***អហោ សុខំ អហោ សុខំ*** *(ឱ សុខហ្ន៎ ឱ សុខហ្ន៎)* ។ ភិក្ខុទាំងឡាយក៏ការប្រឹក្សាគ្នាថា ព្រះកប្បិនត្ថេរ រឭកដល់សុខក្នុងរាជសម្បត្តិ ទើបឧទាន នាំគ្នាទៅក្រាបទូលព្រះតថាគត ។ ព្រះដ៏មានព្រះភាគត្រាស់ថា បុត្រតថាគតប្រារព្ធសុខក្នុងមគ្គ សុខក្នុងផល ទើបឧទាន ហើយត្រាស់ព្រះគាថាក្នុងព្រះធម្មបទ ដូច្នេះថា

ធម្មបីតិ សុខំ សេតិ វិប្បសន្នេន ចេតសា

អរិយប្បវេទិតេ ធម្មេ   សទា រមតិ បណ្ឌិតោ

បណ្ឌិតមានចិត្តថ្លាផូរផង់ហើយ មានបីតិក្នុងធម៌ រមែង
នៅជាសុខ ត្រេកអរក្នុងធម៌ដែលព្រះអរិយប្រកាសហើយ
គ្រប់កាល ។

តមកថ្ងៃមួយ ព្រះសាស្ដាទ្រង់ត្រាស់ហៅភិក្ខុមួយពាន់រូបជាអន្តេវាសិករបស់លោកមក ហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អាចារ្យរបស់លោកសម្ដែងធម៌ខ្លះទេ ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ អាចារ្យរបស់ខ្ញុំព្រះអង្គមិនបានសម្ដែងធម៌ឡើយ លោកជាអ្នកខ្វល់ខ្វាយតិច ប្រកបរឿយៗ ក្នុងសុខ-វិហារធម៌ក្នុងបច្ចុប្បន្ន មិនឲ្យស្មូត្បីឱវាទដល់នរណាៗ ។ ព្រះសាស្ដាត្រាស់ឲ្យហៅលោកមក ហើយត្រាស់សួរថា កប្បិន គេថា អ្នកមិនឲ្យសូម្បីតែឱវាទដល់អន្តេវាសិកទាំងឡាយ ពិតឬ ។ លោកក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគពិតព្រះអង្គ ។ ត្រាស់ថា ម្នាលព្រាហ្មណ៍ អ្នកកុំធ្វើយ៉ាងនេះ តាំងពីថ្ងៃនេះទៅអ្នកចូរសម្ដែងធម៌ដល់អន្តេវាសិកទាំងឡាយ ។ លោកទទួលព្រះពុទ្ធតម្រាស់ដោយសិរសាថា ព្រះករុណាព្រះអង្គ ហើយសម្ដែងធម៌ទូន្មានសមណៈមួយពាន់រូប ក្នុងការប្រជុំតែម្ដងប៉ុណ្ណោះ លោកក៏សម្រេចព្រះអរហត្តគ្រប់រូប ។ តមក ព្រះសាស្ដាប្រថាប់គង់ក្នុងកណ្ដាលសង្ឃ ទ្រង់កំពុងស្ថាបនាព្រះថេរៈទាំងឡាយក្នុង

តំណែងផ្សេងៗ តាមលំដាប់ ទ្រង់បានស្ថាបនាព្រះមហាកប្បិនត្ថេរទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលលើពួកភិក្ខុសាវកអ្នកឱវាទភិក្ខុនោះឯង ។

ចប់អដ្ឋកថា សូត្រទី ៩

# អដ្ឋកថាសូត្រទី ១០

## ប្រវត្តិព្រះសាគតត្ថេរ

ក្នុងសូត្រទី ១០ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[១៤៩] ដោយបទថា **តេជោធាតុកុសលានំ** លោកសម្តែងថា ព្រះសាគតត្ថេរ ជាកំពូលលើពួកភិក្ខុសាវកអ្នកឈ្លាសក្នុងការចូលតេជោធាតុ ពិតណាស់ ព្រះថេរៈនេះប្រើតេជៈគ្របសង្កត់តេជៈរបស់នាគឈ្មោះអម្ពតិត្ថៈ បានកាច់បំបាក់មានះ ព្រោះហេតុនោះ លោកទើបឈ្មោះថា ជាកំពូលលើពួកភិក្ខុសាវកដែលឈ្លាសក្នុងការចូលតេជោធាតុ ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលនឹងពោលតាមលំដាប់ ដូច្នេះ ៖

ព្រះថេរៈរូបនេះ សម័យព្រះពុទ្ធព្រះនាមថា **បទុមុត្តរៈ** បានបដិសន្ធិក្នុងត្រកូលអ្នកគ្រប់គ្រងផ្ទះក្នុងក្រុងហង្សវតី តមក បានស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូប ទុកក្នុងតំណែងឯតទគ្គៈជាកំពូលលើពួកភិក្ខុសាវកអ្នកឈ្លាសក្នុងតេជោធាតុ ទើបធ្វើកុសលកម្មយ៉ាងធំប្រាថ្នាតំណែងនោះ ៗ គេធ្វើកុសលរហូតអស់ជីវិត វិលវល់នៅក្នុងទេវតា និងមនុស្ស ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី ។ បិតា

មាតាទើបតាំងឈ្មោះលោកថា **សាគតមាណព** ។ តមក សាគតមាណពនោះ ស្តាប់ព្រះធម៌ទេសនារបស់ព្រះសាស្តា បានសទ្ធា ទើបបួសធ្វើសមាបត្តិ ៨ ឲ្យកើតឡើង សម្រេចភាពជាអ្នកជំនាញក្នុងសមាបត្តិនោះ ។ តមកថ្ងៃមួយ ព្រះសាស្តាស្តេចចារិកទៅ ជិតដល់ក្រុងកោសម្ពី ។ សម័យនោះ មនុស្សដែលទៅមកជាមួយគ្នា ច្រើនជាសត្រូវរបស់ម្ចាស់ទូកចាស់ត្រង់កំពង់ទឹក បានវាយម្ចាស់ទូកនោះស្លាប់ ។ ម្ចាស់ទូកនោះ តាំងសេចក្តីប្រាថ្នាទាំងដោយចិត្តមានគំនុំ កើតជានាគរាជ មានអានុភាពច្រើនត្រង់កំពង់ទូកនោះឯង ព្រោះមានគំនុំ គេទើបធ្វើឲ្យភ្លៀងធ្លាក់ក្នុងវេលាមិនមែនរដូវភ្លៀង មិនឲ្យភ្លៀងធ្លាក់ក្នុងវេលារដូវភ្លៀង ។ ស្រូវអង្ករក៏មិនសម្បូរណ៍ ។ អ្នកស្រុកក្នុងដែនទាំងអស់ បានធ្វើពលីរាល់ៗ ឆ្នាំ ដើម្បីឲ្យនាគរាជនោះស្ងប់កំហឹង សាងផ្ទះមួយខ្នងឲ្យនាគរាជនោះនៅ ។ សូម្បីព្រះសាស្តាក៏ស្តេចយាងឆ្លងកំពង់នោះ ព្រមទាំងភិក្ខុសង្ឃហែហម ស្តេចយាងទៅ ទ្រង់មានព្រះបំណងនឹងប្រថាប់នៅមួយយប់ក្នុងទីនោះ ។ គ្រានោះ ព្រះថេរៈនេះជ្រាបថា បានឮថា មាននាគរាជនៅទីនោះ ទើបគិតថា គួរនឹងទូន្មាននាគរាជនេះឲ្យអស់មានះ ហើយចាត់ចែងទីប្រថាប់សម្រាប់ព្រះសាស្តា ដូច្នេះ ហើយចូលទៅកាន់ទីនៅរបស់នាគ អង្គុយក្នុងទីនោះ ។ នាគកើតសេចក្តីក្រោធថា សមណៈត្រងោលនេះឈ្មោះអ្វី ទើបហ៊ានចូលទៅអង្គុយក្នុងទីនៅរបស់យើង ទើប

បណ្ដាលផ្សែងឡើង ។ ព្រះថេរៈក៏បណ្ដាលផ្សែងឲ្យក្រៃលែងជាង ។ ស្ដេចនាគធ្វើភ្លើងឲ្យឆេះសន្ធោសន្ធៅ ។ ព្រះថេរៈក៏ធ្វើភ្លើងឆេះសន្ធោសន្ធៅក្រៃលែងជាងគ្របសង្កត់តេជៈរបស់នាគនោះ ។ នាគគិតថា ភិក្ខុរូបនេះធំពិតហ្ន៎ ទើបក្រាបចុះទៀបជើងព្រះថេរៈ ពោលថា លោកដ៏ចម្រើន ខ្ញុំសូមដល់លោកជាសរណៈ ។ ព្រះថេរៈប្រាប់ថា កិច្ចដោយសរណៈសម្រាប់យើងមិនមានទេ អ្នកចូរដល់ព្រះទសពលជាសរណៈចុះ ។ នាគនោះទទួលថា ករុណាលោកម្ចាស់ ហើយជាអ្នកដល់សរណៈ ។ [១](នាគនោះ បានដល់ ព្រះទសពលដែលមានព្រះសិរសា គឺ សព្វញ្ញុតញ្ញាណដ៏ប្រសើរ ទ្រង់មានព្រះកេតុមាលា គឺ និព្វានារម្មណ៍ដ៏ប្រសើរ ទ្រង់មានព្រះនលាដ គឺ ចតុត្ថញ្ញាណដ៏ប្រសើរ មានរស្មីព្រះឧណ្ណាលោម គឺ សមាបត្តិញ្ញាណដូចវជិរៈដ៏ប្រសើរ មានព្រះចិញ្ចើមទាំងគូដ៏ប្រសើរក្រៃលែងនៃនីលកសិណ មានគូព្រះចក្ខុ គឺ ទិព្វចក្ខុ បញ្ញាចក្ខុ និងសមន្តចក្ខុដ៏ប្រសើរ មានគូព្រះសោត គឺ ទិព្វសោតញ្ញាណដ៏ប្រសើរ មានព្រះនាសិកខ្ពស់ គឺ គោត្រ-ភូញ្ញាណដ៏ប្រសើរ មានគូនៃថ្ពាល់ គឺ មគ្គផលញ្ញាណ និងវិមុត្តិផលញ្ញាណដ៏ប្រសើរ មានគូព្រះឱស្ឋ គឺ លោកិយញ្ញាណ និងលោកុត្តរញ្ញាណដ៏ប្រសើរ មានព្រះទន្តស្អាត គឺ សត្តតឹសពោធិបក្ខិយញ្ញាណដ៏ប្រសើរ មានព្រះចង្កូម ៤ គឺ ចតុមគ្គញ្ញាណដែលប្រសើរ មានព្រះជិវ្ហា គឺ ចតុសច្ចញ្ញាណដ៏ប្រសើរ មាន

---

១- ច្បាប់ភូមាសីហឡ: មិនមាន ។

ព្រះហនុ គឺ អប្បដិហតញ្ញាណ (ព្រះញាណដែលមិនមានអ្វីជំទាស់) ដ៏ប្រសើរ ទ្រង់មានព្រះ.ក គឺ ញាណជាគ្រឿងសម្រេចវិមោក្ខដ៏កំពូលដ៏ប្រសើរ ទ្រង់មានគូព្រះពាហា (ក.ដៃ) គឺ ចតុវេសារជ្ជញ្ញាណដ៏ប្រសើរ មានព្រះអង្គុលី (ម្រាមដៃ) មូលល្អ គឺ ទសានុស្សតិញ្ញាណដ៏ប្រសើរ មានផែនព្រះឧរៈ (ទ្រូង) ពេញ គឺ សត្តពោជ្ឈង្គៈ ទ្រង់មានគូព្រះថនៈ (ដោះ) គឺ អាសយានុសយញ្ញាណដ៏ប្រសើរ ទ្រង់មានព្រះវរកាយផ្នែកកណ្តាល គឺ ទសពលញ្ញាណដ៏ប្រសើរ មានព្រះជង្ឃៈ (ស្មង) គឺ បញ្ចិន្ទ្រិយ និងបញ្ចពលៈដ៏ប្រសើរ ទ្រង់មានគូព្រះឧរុ (ជើង) គឺ ទសកុសលកម្មបថដ៏ប្រសើរ ទ្រង់មានសង្ឃាដិ គឺ សីល សមាធិ បញ្ញាដ៏ប្រសើរ ទ្រង់មានបង្សុកូលចីវរជាគ្រឿងបិទបាំងព្រះវរកាយ គឺ ហិរិឱត្តប្បៈដ៏ប្រសើរ ទ្រង់មានព្រះអន្តរវាសកៈ (ស្បង់) គឺ អដ្ឋង្គិកមគ្គញ្ញាណដ៏ប្រសើរ ទ្រង់មានវត្ថពន្ធចង្កេះ គឺ ចតុសតិប្បដ្ឋានដ៏ប្រសើរ ជាសរណៈ ព្រះសម្ពុទ្ធ លោកឲ្យជាក់ច្បាស់ហើយដូចពោលមកនេះ ព្រះដ៏មានព្រះភាគ ទ្រង់បានសម្រេចសព្វព្រះសព្វញ្ញុ-តញ្ញាណហើយ) តាំងអំពីនោះ នាគក៏មិនបៀតបៀននរណាៗ ធ្វើភ្លៀងឲ្យធ្លាក់ត្រូវតាមរដូវកាល ស្រូវអង្ករទាំងឡាយក៏សម្បូរណ៍ទៅដោយភោគផល ។

ពួកអ្នកក្រុងកោសម្ពី បានដំណឹងថា គេថា លោកម្ចាស់សាគតៈ ទូន្មានអម្ពតិត្ថនាគបានហើយ គ្រប់គ្នាក៏តាមមកគាល់ព្រះសាស្តា ចាត់ចែងសក្ការៈដ៏ច្រើន

ថ្វាយព្រះទសពល អ្នកក្រុងទាំងនោះ លុះថ្វាយសក្ការៈយ៉ាងច្រើនចំពោះព្រះ-ទសពលហើយ ក៏តាក់តែងទឹកថ្លាពណ៌ស (ប្រភេទសុរា?) ទុកក្នុងផ្ទះគ្រប់ៗ ផ្ទះ តាមពាក្យណែនាំរបស់ពួកភិក្ខុឆព្វគ្គិយ (ភិក្ខុ ៦ រូប) លុះស្អែកឡើង កាលព្រះសាគតត្ថេរត្រាច់បិណ្ឌបាត ក៏នាំគ្នាថ្វាយទឹកនោះ មួយផ្ទះបន្តិចៗ ព្រះថេរៈត្រូវមនុស្សទាំងឡាយទទូច ព្រោះទ្រង់មិនទាន់បានបញ្ញត្តិសិក្ខាបទ ក៏ផឹកគ្រប់ៗ ផ្ទះ ដើរទៅមិនឆ្ងាយប៉ុន្មាន ក៏បាត់សតិដួលចុះត្រង់គំនរសម្រាម ព្រោះមិនមានអាហារទ្រាប់ពោះ ។ ព្រះសាស្តាសោយស្រេចហើយ ស្តេចចេញទៅ ឃើញព្រះសា-គតត្ថេរនោះ ក៏ឲ្យនាំទៅព្រះវិហារ ទ្រង់តិះដៀល ហើយទ្រង់បញ្ញត្តិសិក្ខាបទ ។ ថ្ងៃស្អែកឡើង លោកដឹងខ្លួន ឮគេពោលដល់ហេតុដែលខ្លួនធ្វើហើយ ក៏សម្តែងទោសដែលកន្លងល្មើស សូមឲ្យព្រះទសពលអត់ទោសហើយ កើតសេចក្តីសង្វេគ ចម្រើនវិបស្សនា ក៏បានសម្រេចព្រះអរហត្ត ។ រឿងប្រាកដក្នុងព្រះវិន័យ ដូចពោលមកនេះ ។ គប្បីជ្រាបរឿងពិស្តារតាមន័យដែលមកហើយក្នុងវិន័យនោះឯង ។ ក្រោយមក ព្រះសាស្តាប្រថាប់ក្នុងព្រះជេតពនមហាវិហារ ទ្រង់កំពុងស្ថាបនាព្រះថេរៈទាំងឡាយទុកក្នុងតំណែងទាំងឡាយតាមលំដាប់ ទើបទ្រង់ស្ថាបនាព្រះសាគតត្ថេរ ទុកក្នុងតំណែងឯតទគ្គៈជាកំពូលលើពួកភិក្ខុសាវក អ្នកឈ្លាសក្នុងការចូលតេជោធាតុនោះឯង ។

ចប់អដ្ឋកថា ព្រះសូត្រទី ១០

# អដ្ឋកថាសូត្រទី ១១

## ប្រវត្តិព្រះរាធត្ថេរ

ក្នុងសូត្រទី ១១ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[១៤៩] បទថា **បដិភាណេយ្យកានំ** បានដល់[១] អ្នកឲ្យបដិភាណកើតឡើងបាន ដែលរាប់ថា ជាហេតុឲ្យលោកសម្តែងដដែលៗ នូវព្រះធម៌ទេសនារបស់ព្រះសាស្តាបានភ្លាមៗ ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលនឹងពោលតាមលំដាប់ ដូច្នេះ ៖

ក៏ព្រះថេរៈរូបនេះ គ្រាព្រះពុទ្ធព្រះនាមថា **បទុមុត្តរៈ** កើតក្នុងត្រកូលក្នុងក្រុងហង្សវតី ក្រោយមក កំពុងស្តាប់ព្រះធម៌ទេសនារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូបទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលលើពួកភិក្ខុសាវកអ្នកមានបដិភាណ ទើបធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ ។ លោកប្រណិបត្តិព្រះតថាគតដរាបអស់មួយជីវិត វិលវល់នៅក្នុងទេវតា និងមនុស្ស លុះមកដល់ពុទ្ធុប្បាទកាលនេះ ក៏បដិសន្ធិក្នុងត្រកូលព្រាហ្មណ៍ នាក្រុងរាជគ្រឹះ បិតាមាតាទើបដាក់នាមថា **រាធមាណព** វេលាចាស់ គេគិតថា យើងជាអ្នកដែល

---

១-កន្លែងខ្លះជា បដិភាណភិក្ខូនំ ប្រែថា ភិក្ខុដែលមានបដិភាណ ។

បុត្រកិរិយារបស់ខ្លួនមិនត្រូវការ ទើបប្តូសឲ្យវលោកនូវទៅ បានទៅព្រះវិហារ សូមបព្វជ្ជាអំពីព្រះថេរៈទាំងឡាយ ។ ព្រះថេរៈពួកខ្លះមិនបំណងឲ្យបួស ដោយឃើញថាជាមនុស្សចាស់ ជាព្រាហ្មណ៍ចាស់ ។ តមកថ្ងៃមួយ ព្រាហ្មណ៍បានទៅកាន់សំណាក់របស់ព្រះសាស្តា ធ្វើការបដិសណ្ឋារៈហើយ អង្គុយក្នុងទីដ៏សមគួរមួយ ព្រះសាស្តាទ្រង់ឃើញឧបនិស្ស័យសម្បត្តិ ការដល់ព្រមដោយឧបនិស្ស័យទ្រង់មានព្រះបំណងនឹងលើករឿងឡើង ទើបត្រាស់សួរថា ព្រាហ្មណ៍ បុត្រកិរិយានៅប្រតិបត្តិឬទេ ក្រាបទូលថា ព្រះគោតម ប្រតិបត្តិអំពីណា ពួកបុត្រកិរិយាឲ្យខ្ញុំព្រះអង្គចេញពីផ្ទះ ដោយគេគិតថា ខ្ញុំព្រះអង្គចាស់ហើយ ត្រាស់សួរថា អ្នកបួសមិនគួរឬព្រាហ្មណ៍ ក្រាបទូលថា ព្រះគោតម នរណានឹងឲ្យខ្ញុំព្រះអង្គបួស នរណាៗ ក៏គេមិនត្រូវការខ្ញុំព្រះអង្គទេ ព្រោះជាមនុស្សចាស់ហើយ ព្រះសាស្តាបានប្រទានសញ្ញាសំដៅដល់ព្រះសារីបុត្ត ព្រះថេរៈទទួលព្រះពុទ្ធតម្រាស់ដោយសិរសា ឲ្យរាធព្រាហ្មណ៍បួស លោកគិតថា ព្រះសាស្តាទ្រង់ឲ្យព្រាហ្មណ៍ម្នាក់នេះបួសដោយសេចក្តីអើពើ មិនសមគួរមើលព្រាហ្មណ៍ម្នាក់នេះ ដោយសេចក្តីមិនអើពើឡើយ ទើបនាំព្រះរាធត្ថេរទៅកាន់ទីនៅជិតស្រុក ក្នុងទីនោះ លោកមានលាភដែលរកបានលំបាក ព្រោះជាអ្នកបួសថ្មី ព្រះថេរៈទើបឲ្យទីនៅរបស់ខ្លួនដែលជាទីប្រសើរបំផុត ឲ្យបិណ្ឌបាតដ៏ប្រណីតដែលដល់ខ្លួន ដល់ព្រះរាធត្ថេរៈ

នោះ ត្រាច់ទៅបិណ្ឌបាតខ្លួនឯង ព្រះរាធត្ថេរបានសេនាសនៈដែលសប្បាយ និង ភោជនដែលសប្បាយ ទទួលកម្មដ្ឋានក្នុងសំណាក់ព្រះសារីបុត្តត្ថេរ មិនយូរប៉ុន្មាន ក៏សម្រេចព្រះអរហត្ត គ្រានោះ ព្រះសារីបុត្តត្ថេរ ក៏នាំលោកទៅគាល់ព្រះទស-ពល ព្រះសាស្តាក៏ទ្រង់ជ្រាប ទើបត្រាស់សួរថា សារីបុត្រ សិស្សដែលតថាគត ប្រគល់ឲ្យដល់លោកដូចម្តេចហើយ មិនចង់សឹកទេឬ ព្រះសារីបុត្តត្ថេរទូលថា បពិត្រព្រះអង្គដ៏ចម្រើន ធម្មតាភិក្ខុអ្នកអភិរម្យត្រេកអរក្រៃលែងក្នុងព្រះសាសនា មិនគប្បីជាដូច្នេះទេព្រះអង្គ គ្រានោះកើត បានកើតការនិយាយគ្នាកណ្តាលសង្ឃ ថា ព្រះសារីបុត្តត្ថេរ ជាកតញ្ញូកតវេទី ព្រះសាស្តាទ្រង់ស្តាប់រឿងនោះហើយ ទ្រង់ ហៅភិក្ខុទាំងឡាយមក ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្រជាអ្នក កតញ្ញូកតវេទីក្នុងជាតិនេះ មិនទាន់អស្ចារ្យទេ ក្នុងជាតិមុន សូម្បីលោកបដិសន្ធិ ក្នុងអហេតុកសត្វ ក៏ជាអ្នកមានកតញ្ញូកតវេទីដូចគ្នា ភិក្ខុទាំងឡាយទូលសួរថា បពិត្រព្រះដ៏មានព្រះភាគ ក្នុងកាលណាព្រះអង្គ ព្រះដ៏មានព្រះភាគទើបត្រាស់ ថា ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាល ជាងឈើប្រមាណ ៥០០ នាក់ ចូលទៅ ព្រៃធំនាជើងភ្នំ កាត់ទព្វសម្ភារៈបានហើយ ចងជាក្បូនធំបណ្តែតតាមទន្លេ មាន ស្តេចដំរីមួយ ន័យថា យកប្រមោយចាប់មែកឈើក្នុងទីមិនរៀបរយមួយកន្លែង មិនអាចនឹងទាញមែកឈើឲ្យបាក់បាន ក៏យកជើងជាន់ចុះត្រង់ជន្លត់ស្រួច ជើង

ត្រូវដង្គត់មុត កើតទុក្ខវេទនា មិនអាចដើរទៅណាបាន ក៏ដេកចុះទីនោះនុ៎ះឯង កន្លងទៅ ២-៣ ថ្ងៃ ស្តេចដំរីនោះក្រឡេកឃើញពួកជាងឈើដើរមកជិតខ្លួន ក៏គិតថា យើងអាស្រ័យជាងឈើទាំងនេះគង់នឹងរួចជីវិតដោយពិត ទើបបានដើរទៅតាមស្នាមជើងជាងឈើទាំងនោះ ពួកគេបែរមើលមកឃើញដំរីក៏ភ័យខ្លាច ទើបគេចចេញទៅ ស្តេចដំរីនោះដឹងថា គេគេចចេញក៏ឈប់ ហើយដើរតាមទៅវេលាគេឈប់ មេជាងឈើគិតថា ដំរីនេះ កាលយើងឈប់ក៏ដើរតាម កាលយើងគេចចេញក៏ឈប់ គង់នឹងមានហេតុក្នុងទីនោះដោយពិត គ្រប់គ្នាទើបនាំគ្នាឡើងដើមឈើ អង្គុយចាំមើលដំរីមក ស្តេចដំរីនោះដើរមកជិតជាងឈើទាំងនោះ ក៏ដេកប្រមៀលសម្តែងជើងរបស់ខ្លួន វេលានោះ ជាងឈើក៏កើតសេចក្តីយល់ ដោយពោលថា លោកដ៏ចម្រើន ដំរីនោះមក ព្រោះឈឺចាប់ មិនមែនមកព្រោះហេតុយ៉ាងដទៃ ទើបនាំគ្នាចូលទៅជិតស្តេចដំរីនោះ ឃើញដង្គត់មុតចូលទៅក្នុងជើង ក៏ដឹងថា ព្រោះហេតុនេះឯង ដំរីទើបមក ទើបយកកាំបិតដ៏មុត ឆ្កឹះត្រង់ចុងដង្គត់ ហើយយកខ្សែចងឲ្យជាប់ នាំគ្នាទាញចេញមកបាន ច្របាច់មុខដំបៅ នាំយកខ្ទុះនិងឈាមចេញ លាងដោយទឹកអម្ចត់ ដាក់ថ្នាំដែលខ្លួនស្គាល់ មិនយូរប៉ុន្មាន ក៏ធ្វើឲ្យដំរីនោះសប្បាយ ស្តេចដំរីបាត់ឈឺហើយ គិតថា ជាងឈើទាំងនេះ មានឧបការៈដល់យើងច្រើន យើងអាស្រ័យជាងឈើទាំងនេះ ទើបរួចជីវិត យើងគួរ

នឹងកតញ្ញូកតវេទីចំពោះពួកគេ ទើបត្រឡប់ទៅទីនៅរបស់ខ្លួន ហើយនាំយកកូនដំរីត្រកូលគន្ធៈមក ពួកជាងកាលឃើញកូនដំរី ក៏រីករាយចិត្តយ៉ាងក្រៃលែងថា ដំរីរបស់យើងនាំកូនមក ស្តេចដំរីគិតថា កាលយើងឈរហើយ ហេតុដូចម្តេចទើបកូនដំរីនេះមិនមក ពួកគេគង់មិនដឹងហេតុដែលយើងមក ទើបចេញទៅឈរទីដ៏ទៃៗ កូនដំរីក៏ដើរតាមត្រសងទៅពីខាងក្រោយមេ ស្តេចដំរីដឹងថា កូនតាមមក ទើបបញ្ចេញសំឡេងសញ្ញាឲ្យត្រឡប់ទៅ កូនដំរីបានឮសំឡេងមេ ក៏ត្រឡប់ទៅរកពួកជាងឈើ ពួកជាងឈើដឹងថា ដំរីនេះមកដើម្បីឲ្យកូនដំរីនេះដល់យើង ទើបពោលថា យើងមិនមានកិច្ចដែលនឹងឲ្យអ្នកធ្វើក្នុងសំណាក់យើងទេ ចូរទៅរកមេរបស់អ្នកចុះ ហើយក៏បញ្ជូនកូនដំរីត្រឡប់ទៅ ស្តេចដំរីក៏បញ្ជូនកូនមកឲ្យជាងឈើដល់ ៣ ដង ឲ្យទៅនៅជិតពួកជាងឈើទៀត តាំងពីនោះមក ពួកជាងឈើក៏នាំគ្នាទំនុកបម្រុងចិញ្ចឹមកូនដំរីទុកក្នុងសំណាក់របស់ខ្លួន វេលាស៊ី ក៏ឲ្យដុំបាយមួយដុំៗ ម្នាក់ ល្មមដល់សេចក្តីត្រូវការរបស់កូនដំរីនោះ ។ គ្រានោះកូនដំរីនោះក៏នាំទព្វសម្ភារៈដែលពួកជាងឈើកាត់ទុកក្នុងព្រៃ មកធ្វើជាគំនរទុកត្រង់ទីលាន កូនដំរីក៏ធ្វើឧបការៈសូម្បីយ៉ាងដទៃ ដោយទំនងនេះឯង ។

ព្រះសាស្តាទ្រង់នាំហេតុនេះមកសម្តែងសូម្បីក្នុងជាតិមុន ព្រះសារីបុត្រក៏ជាអ្នកមានកតញ្ញូកតវេទី ។ កាលនោះ ព្រះសារីបុត្តត្ថេរ បានជាដំរីធំ ។ ភិក្ខុ

ដែលខ្វះសេចក្ដីព្យាយាមដែលមកក្នុងអត្ថុប្បត្តិ (ហេតុកើតរឿង) បានជាកូនដំរី តែគម្ពីរសំយុត្តនិកាយ គប្បីពោលរាជសំយុត្តទាំងអស់ និងគាថាក្នុងព្រះធម្មបទ ថា ៖

និធីនំវ បវត្តារំ យំ បស្សេ វជ្ជទស្សិនំ
និគ្គយ្ហវាទឹ មេធាវឹ តាទិសំ បណ្ឌិតំ ភជេ
តាទិសំ ភជមានស្ស សេយ្យោ ហោតិ ន បាបិយោ ។

គប្បីឃើញបណ្ឌិតអ្នកពោលទូន្មាន ចង្អុលទោស និយាយគ្រប សង្កត់ មានបញ្ញាធំទូលាយ ដូចចង្អុលប្រាប់កំណប់ទ្រព្យឲ្យ គប្បី សេពគប់បណ្ឌិតដូច្នោះ កាលសេពគប់បណ្ឌិតដូច្នោះ ក៏មានតែ សេចក្ដីចម្រើន មិនវិនាសឡើយ ដូច្នេះ ។

ឈ្មោះថា ធម្មទេសនារបស់ព្រះថេរៈ តែតមក ព្រះសាស្ដាទ្រង់កំពុងស្ថាបនាព្រះថេរៈទាំងឡាយទុកក្នុងតំណែងទាំងឡាយតាមលំដាប់ ទើបទ្រង់បានស្ថាបនាព្រះរាធត្ថេរទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលលើពួកភិក្ខុសាវកអ្នកប្រកប ដោយបដិភាណ ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ១១

# អដ្ឋកថាសូត្រទី ១២

## ប្រវត្តិព្រះមោឃរាជត្ថេរ

ក្នុងសូត្រទី ១២ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[១៨៩] ដោយបទថា **លូខចីវរធរានំ** លោកសម្តែងថា ព្រះមោឃរាជ ជាកំពូលលើពួកភិក្ខុសាវកអ្នកទ្រទ្រង់ចីវរសៅហ្មង ពិតណាស់ ព្រះថេរៈអង្គនេះ ទ្រទ្រង់សំពត់បង្សុកូលចីវរ ដែលប្រកបដោយភាពសៅហ្មង ៣ យ៉ាង គឺ សៅ-ហ្មងដោយសំពត់ សៅហ្មងដោយអំបោះ សៅហ្មងដោយគ្រឿងជ្រលក់ ព្រោះហេតុនោះ លោកទើបឈ្មោះថា ជាកំពូលលើពួកភិក្ខុសាវកអ្នកស្លៀកដណ្តប់ចីវរសៅហ្មង ។ បញ្ហាកម្មរបស់លោក មានរឿងដែលនឹងពោលតាមលំដាប់ដូច្នេះ ។

ក៏ព្រះមោឃរាជនេះ គ្រាព្រះពុទ្ធព្រះនាមថា **បទុមុត្តរៈ** បានបដិសន្ធិក្នុងត្រកូលក្នុងក្រុងហង្សវតី ក្រោយមក កំពុងស្តាប់ធម្មកថារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូប ទុកក្នុងតំណែងជាកំពូលលើពួកភិក្ខុសាវកអ្នកទ្រទ្រង់ចីវរសៅហ្មង ក៏ធ្វើកុសលឲ្យក្រៃលែងឡើងទៅ ប្រាថ្នាតំណែងនោះ ។ លោកធ្វើកុសលជាបរហូតអស់ជីវិត វិលវល់នៅក្នុងទេវតា និងមនុស្ស ហើយ

បានបដិសន្ធិក្នុងត្រកូលអាមាត្រ ក្នុងនគរកុក្កុដវាហនៈ មុនពេលព្រះទសពលព្រះនាមថា **កស្សប** ស្ដេចឧប្បត្តិឡើង តមកចម្រើនវ័យហើយ ក៏ជាអ្នកគាល់រក្សាព្រះរាជាកុក្កុដវាហនៈ ក៏បានតំណែងជាអាមាត្រ ។ សម័យនោះ ព្រះកស្សបទសពល ស្ដេចឧប្បត្តិក្នុងលោកហើយ ព្រះរាជកុក្កុដវាហនៈ ទ្រង់ស្ដាប់ថា ព្រះពុទ្ធស្ដេចឧប្បត្តិឡើងហើយក្នុងលោក បានត្រាស់ហៅអាមាត្រនោះមកត្រាស់ថា បាអើយ ព្រះពុទ្ធស្ដេចឧប្បត្តិឡើងហើយក្នុងលោក នរណាៗ មិនអាចធ្វើបច្ចន្តនគរប្រទេសនេះ ឲ្យស្ងប់ស្ងៀមពីសត្រូវនៃពួកយើងទាំងពីរព្រមៗ គ្នាបាន ជាដំបូង លោកចូរទៅកាន់មជ្ឈិមប្រទេស ដឹងថា ព្រះពុទ្ធឧប្បត្តិឡើងហើយ ចូរយាងព្រះទសពលមកកាន់នគរបច្ចន្តប្រទេសនេះ ហើយទ្រង់បញ្ជូនទៅព្រមទាំងបុរស ១.០០០ នាក់ ។ អាមាត្រនោះ ទៅកាន់សំណាក់ព្រះសាស្ដាស្ដាប់ធម្មកថា បានសទ្ធាហើយ ក៏បួសក្នុងទីនោះតាមលំដាប់ បានធ្វើសមណធម៌រហូតដល់ ២០.០០០ ឆ្នាំ ។ ចំណែកបុរសដែលទៅជាមួយអាមាត្រនោះ ត្រឡប់មកកាន់សំណាក់ព្រះរាជាវិញ ។ ព្រះថេរៈនេះមានសីលបរិបូណ៌ធ្វើមរណកាលហើយ វិលវល់នៅក្នុងទេវតា និងមនុស្ស មួយពុទ្ធន្តរ បានបដិសន្ធិក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី មុនព្រះទសពលរបស់យើងឧប្បត្តិ បិតាមាតាបានតាំងឈ្មោះថា **មោឃរាជមាណព** សូម្បីព្រះរាជកុក្កុដវាហនៈ ក៏ទ្រង់ធ្វើកុសលឲ្យក្រៃលែងឡើង តាំងអំពីព្រះដ៏មានព្រះភាគកស្សបៈ

ព្រមទាំងបរិវារវិលវល់នៅក្នុងទេវតា និងមនុស្សមួយពុទ្ធន្តរ បានបដិសន្ធិក្នុងត្រកូលបុរោហិត ក្នុងក្រុងសាវត្ថី មុនព្រះទសពលរបស់យើងស្តេចឧប្បត្តិឡើង បិតាមាតាតាំងឈ្មោះថា **ពាវរីមាណព** ។ សម័យតមក ពាវរីមាណព រៀនត្រៃវេទហើយ ទូន្មានសិល្បៈដល់ពួកមាណព ១៦.០០០ នាក់ ។ គ្រានោះ ពាវរីមាណពក៏បានទទួលតំណែងបុរោហិតជំនួស កាលបិតាធ្វើមរណកាលទៅ ក្នុងសម័យដែលព្រះបាទបសេនទិកោសលប្រសូតិ ។ សូម្បីមោយរាជមាណពនេះក៏រៀនសិល្បៈក្នុងសំណាក់ពាវរីព្រាហ្មណ៍ ។

តមកថ្ងៃមួយ ពាវរីព្រាហ្មណ៍នៅក្នុងទីកំបាំង ក៏ពិចារណាមើលប្រយោជន៍ក្នុងសិល្បៈ ក៏មិនឃើញប្រយោជន៍ដែលប្រព្រឹត្តទៅក្នុងខាងមុខ គិតថា យើងនឹងបួសដោយប្រភេទណាមួយ ស្វែងរកប្រយោជន៍ដើម្បីប្រព្រឹត្តទៅក្នុងខាងមុខ ហើយក៏ចូលគាល់ព្រះបាទកោសល (មហាកោសល) ឲ្យទ្រង់អនុញ្ញាតការបួសដល់ខ្លួន ។ ពាវរីព្រាហ្មណ៍នោះ បានទទួលរាជានុញ្ញាតហើយ មានមាណព ១៦.០០០ នាក់ ហែហម ក៏ចេញទៅដើម្បីបួស ។ សូម្បីព្រះបាទកោសល ទ្រង់ក៏បញ្ជូនព្រះរាជទ្រព្យ ១.០០០ កហាបណៈ ទៅព្រមជាមួយពាវរីព្រាហ្មណ៍នោះ ដោយព្រះតម្រាស់ថា អាចារ្យបួសនៅក្នុងទីណា ពួកអ្នកចូរទៅកាន់ទីនៅរបស់អាចារ្យ ហើយឲ្យទ្រព្យក្នុងទីនោះ ។ ពាវរីព្រាហ្មណ៍បំណងនឹងត្រួតមើលទីកន្លែង

ដែលជាសុខ ក៏ចេញចាកមជ្ឈិមប្រទេស ឲ្យសាងស្ថានទីនៅរបស់ខ្លួនត្រង់ទីបត់នៃស្ទឹងគោធាវរី ចន្លោះព្រំប្រទល់របស់ព្រះរាជាអស្សកៈ និងព្រះរាជាមលកៈ ។ គ្រានោះ បុរសម្នាក់ដើរទៅដើម្បីនឹងមើលជដិលទាំងឡាយ កាលជដិលទាំងនោះអនុញ្ញាតហើយ ក៏កសាងទីនៅរបស់ខ្លួន លើដីដែលជារបស់ជដិលទាំងនោះ ។ គេឃើញកិច្ចកម្មដែលពាវរីព្រាហ្មណ៍ធ្វើហើយ ក៏ឲ្យសាងផ្ទះ ១០០ ខ្នង សម្រាប់ ១០០ គ្រួសារទៀត ។ អ្នកទាំងអស់ប្រជុំប្រឹក្សាគ្នាថា ពួកយើងនឹងនៅក្នុង ទីដីដែលជារបស់លោកម្ចាស់ទាំងឡាយ ការនៅទទេៗ មិនមែនហេតុដែលគួរទេ ពួកយើងនឹងឲ្យពួកលោកនៅជាសុខ ។ ក្នុងម្នាក់ៗ ក៏បានដាក់កហាបណៈ ១ កហាបណៈទុកក្នុងទីនៅរបស់ពាវរីព្រាហ្មណ៍ កហាបណៈដែលពួកគេទាំងអស់នាំមកដាក់ ក៏មានប្រមាណ ១០០.០០០ កហាបណៈ ។ ពាវរីព្រាហ្មណ៍សួរថា កហាបណៈទាំងនេះ ពួកលោកនាំមកដើម្បីត្រូវការអ្វី ។ ពួកគេឆ្លើយថា ដើម្បីត្រូវការឲ្យពួកលោកម្ចាស់នៅជាសុខ ។ ពាវរីព្រាហ្មណ៍ពោលថា បើយើងត្រូវការមាសប្រាក់ ក៏មិនគប្បីលះបង់គំនរទ្រព្យដ៏ធំ ចេញបួសទេ ពួកលោកទទួលយកកហាបណៈរបស់ពួកលោកទៅវិញចុះ ។ ពួកគេប្រាប់ថា ពួកយើងមិនទទួលទ្រព្យដែលពួកយើងបរិច្ចាគហើយទេ តែពួកយើងនឹងនាំមកដោយទំនងនេះរាល់ៗ ឆ្នាំ សូមលោកម្ចាស់ចូរទទួលកហាបណៈទាំងនេះទុកឲ្យទាន ផងចុះ ។ ព្រាហ្មណ៍ក៏ព្រម

ទទួល បង្អោនទុកចំណាយក្នុងការឲ្យទានដល់មនុស្សកំព្រា អ្នកដើរផ្លូវឆ្ងាយ ស្មូម និងយាចក ភាវៈនៃពាវរីព្រាហ្មណ៍នោះជាទាយក ក៏បានឮតៗ គ្នាមក ប្រាកដទៅទូទាំងជម្ពូទ្វីប ។

គ្រានោះ ព្រាហ្មណី (ភរិយា) របស់ព្រាហ្មណ៍អ្នកកើតមកក្នុងវង្សរបស់ជូជកព្រាហ្មណ៍ ក្នុងស្រុកទុន្នវិត្ថៈ ក្នុងដែនកលិង្គៈ បានដាស់តឿនព្រាហ្មណ៍ (ស្វាមី) ថា គេថាពាវរីកំពុងឲ្យទាន លោកចូរទៅនាំមាសប្រាក់មកពីទីនោះ ។ ព្រាហ្មណ៍នោះ ត្រូវព្រាហ្មណីតឿនហើយ ក៏មិនអាចទ្រាំនៅបាន កាលនឹងទៅកាន់សំណាក់ពាវរី ក៏ទៅកាលពាវរីឲ្យទានក្នុងថ្ងៃម្សិលហើយ ចូលបណ្ណសាលាកំពុងដេកនឹកដល់ទាន និងលុះចូលទៅដល់ ក៏និយាយថា ព្រាហ្មណ៍មេត្តាឲ្យទានដល់ខ្ញុំផង ព្រាហ្មណ៍មេត្តាឲ្យទានដល់ខ្ញុំផង ។ ពាវរីព្រាហ្មណ៍ពោលថា ព្រាហ្មណ៍ លោកមកមិនត្រូវវេលា យើងបានឲ្យទានដល់ពួកយាចកដែលមកដល់អស់ហើយ ឥឡូវនេះ មិនមានកហាបណៈទេ ។ ព្រាហ្មណ៍និយាយថា ព្រាហ្មណ៍ ខ្ញុំមិនត្រូវការកហាបណៈច្រើនពេកទេ កាលលោកឲ្យទានសូម្បីប៉ុណ្ណេះ ខ្ញុំក៏មិនអាចរៀរកហាបណៈបាន ៥០០ កហាបណៈក៏មិនមាន សូម្បីវេលាឲ្យទានហើយ លោកទើបនឹងបានទៀត ។ ព្រាហ្មណ៍ស្មូមពោលថា ព្រាហ្មណ៍ ៥០០ កហាបណៈ ក៏មិនមានសូម្បីដល់វេលាហើយ ទើបនឹងបានទៀត ព្រាហ្មណ៍និយាយថា ក៏វេលា

លោកឲ្យទាន ខ្ញុំនឹងមកបានយ៉ាងណា ហើយទើបពូនខ្សាច់ជាសថូបជិតទ្វារបណ្ណ-សាលា រោយផ្កាឈើពណ៌ក្រហមជុំវិញ ធ្វើមាត់ម្ចុបៗ ដូចសេពមន្ត ហើយនិយាយថា សិរសៈចូរបែក ៧ ចំណែក ។ ពាវរីព្រាហ្មណ៍គិតថា ព្រាហ្មណ៍ស្មូមនេះមានតេជៈច្រើន កាន់ការប្រព្រឹត្តតបៈជាចរណកព្រាហ្មណ៍ និយាយថា ក្នុងថ្ងៃទី ៧ សិរសៈរបស់យើងចូរបែក ៧ ចំណែក ៥០០ កហាបណៈ ដែលយើងនឹងគប្បីឲ្យដល់ព្រាហ្មណ៍ស្មូមនេះក៏មិនមាន ព្រាហ្មណ៍ស្មូមនេះ នឹងប្តូរសម្លាប់យើងតែម្តង ។

កាលពាវរីព្រាហ្មណ៍នោះ ដេកមិនលក់ដោយសេចក្តីក្រៀមក្រំនោះ ក្នុងកណ្តាលរាត្រី មាតារបស់ពាវរីព្រាហ្មណ៍ក្នុងអត្តភាពជាប់តគ្នាមក កើតជាទេវតា ។ នាងឃើញបុត្រដេកមិនលក់ដោយសេចក្តីក្រៀមក្រំចិត្ត ទើបមកពោលថា កូនអើយ តាព្រាហ្មណ៍នោះក៏មិនដឹងថា សិរសៈនឹងបែក ឬមិនបែក អ្នកមិនដឹងទេឬថា ព្រះពុទ្ធទ្រង់ឧប្បត្តិឡើងហើយក្នុងលោក បើអ្នកនៅមានសេចក្តីសង្ស័យក៏ចូរទៅគាល់ព្រះសាស្តា ហើយទូលសួរ ព្រះសាស្តានឹងត្រាស់ប្រាប់ហេតុនោះដល់អ្នកបានមិនខានឡើយ ។ ពាវរីព្រាហ្មណ៍ តាំងពីបានឮសំឡេងទេវតាពោលក៏មានស្មារតីឡើង លុះមបានអរុណ ក៏ហៅសិស្សគ្រប់គ្នាមក ហើយពោលថា បាអើយ គេថា ព្រះពុទ្ធឧប្បត្តិឡើងហើយក្នុងលោក ពួកអ្នកចូរប្រញាប់ទៅ ដឹង

ថាជាព្រះពុទ្ធ ឬមិនមែន ហើយចូរត្រឡប់មកប្រាប់យើង យើងក៏នឹងទៅគាល់ព្រះសាស្ដា ប៉ុន្ដែថា អន្ដរាយនៃជីវិតជាការដឹងបានលំបាក ព្រោះយើងចាស់ហើយ ពួកអ្នកទៅគាល់ព្រះសាស្ដា ចូរទូលសួរបញ្ហាដោយទំនងយ៉ាងនេះ យ៉ាងនេះ ចំពោះព្រះអង្គ ទើបតែងបញ្ហាឈ្មោះក្បាលបែកឲ្យទៅ តពីនោះ ពាវរីព្រាហ្មណ៍គិតថា ពួកមាណពទាំងនេះ គ្រប់គ្នាជាបណ្ឌិត ស្ដាប់ធម្មកថារបស់ព្រះសាស្ដាហើយ កាលកិច្ចរបស់ខ្លួនដល់ទីបំផុតហើយ នឹងគប្បីត្រឡប់មករកយើងឬទេហ្ន៎ ទើបឲ្យសញ្ញាដល់អជិតមាណព ក្មួយប្រុសរបស់ខ្លួនថា អ្នកគប្បីត្រឡប់មក មកប្រាប់គុណដែលខ្លួនបានដល់យើង លំដាប់នោះ ពួកជដិល ១៦.០០០ លើកអជិតមាណពជាប្រធាន ទើបចារិកទៅព្រមនឹងអន្ដេវាសិក ប្រធាន ១៦ នាក់ដោយបំណងថា នឹងទូលសួរបញ្ហាចំពោះព្រះសាស្ដា ក្នុងទីដែលទៅ ត្រូវសួរថាលោកម្ចាស់នាំគ្នាទៅណា ក៏ឆ្លើយថា ពួកយើងនឹងទៅគាល់ព្រះទសពលសួរបញ្ហាកាលនឹងសួរតាំងពីខាងដើមមក បរិស័ទទាំងអស់ក៏ធ្វើដំណើរបានច្រើនរយយោជន៍

ព្រះសាស្ដាទ្រង់ត្រិះរិះថា ក្នុងថ្ងៃដែលមាណពទាំងនោះមក ឱកាសនឹងមិនមានដល់អ្នកដទៃ ទីនេះ ទើបជាទីមិនគួរសម្រាប់បរិស័ទនេះ ទើបស្ដេចទៅប្រថាប់លើផ្ទាំងថ្ម ត្រង់បាសាណកចេតិយ សូម្បីអជិតមាណពនោះនឹងបរិស័ទ ក៏ឡើងកាន់ផ្ទាំងថ្មនោះ ឃើញសម្បត្តិនៃព្រះសរីរៈរបស់ព្រះសាស្ដា ក៏គិតថា បុរស

ម្នាក់នេះ គង់នឹងជាព្រះពុទ្ធអ្នកមានដំបូលដែលបើកហើយក្នុងលោកនេះ ទើបសួរបញ្ហាដែលអាចារ្យប្រគល់ដល់ខ្លួន ។ ថ្ងៃនោះ បរិស័ទដែលមកដល់ទីនោះប្រមាណ ១២ យោជន៍ ក្នុងវាងសិស្ស ១៦ នាក់នោះ មោឃរាជមាណពសម្គាល់ខ្លួនថាជាបណ្ឌិតប្រសើរជាងអ្នកដទៃ គេទើបត្រិះរិះថា អជិតមាណពនេះជាប្រធានរបស់សិស្សគ្រប់គ្នា មិនគួរសួរបញ្ហាមុន គេខ្មាសចំពោះអជិតមាណពនោះ ទើបមិនសួរមុន ។ កាលអជិតមាណពនោះ សួរបញ្ហាហើយ ទើបសួរបញ្ហាចំពោះព្រះសាស្តា ជាអ្នកទីពីរ ។ ព្រះសាស្តាទ្រង់ត្រិះរិះថា មោឃរាជ-មាណពជាអ្នកប្រកាន់ខ្លួន ទាំងញាណរបស់គេក៏មិនទាន់ចាស់ក្លា ដែលគួរនឹងនាំសេចក្តីប្រកាន់ខ្លួនរបស់គេចេញ ទើបត្រាស់ថា មោឃរាជអ្នកចូរសម្រាកសិនអ្នកដទៃៗ ចូរសួរបញ្ហាមុន ។ មោឃរាជមាណពនោះ ត្រូវការហាមឃាត់ពីសំណាក់ព្រះសាស្តា គិតថា យើងធ្វើដំណើររហូតអស់កាលប៉ុណ្ណេះ ដោយយល់ថា មិនមានអ្នកដែលជាបណ្ឌិតក្រៃលើសជាងយើង ធម្មតាព្រះពុទ្ធទាំងឡាយទ្រង់មិនជ្រាបសេចក្តីក្នុងចិត្ត រមែងមិនត្រាស់ ព្រះសាស្តាទ្រង់គង់នឹងឃើញទោសក្នុងការសួររបស់យើង ទើបនៅស្ងៀម ។ មោឃរាជមាណពនោះ កាលមាណពអ្នកទី ៨ សួរបញ្ហាទៅតាមលំដាប់ ក៏អត់ទ្រាំមិនបាន ក្រោកឡើងទៀតជាអ្នកទី ៩ ។ ព្រះសាស្តាទ្រង់ក៏ហាមគេទៀត ។ មោឃរាជមាណពនោះ ក៏ត្រូវស្ងៀម

គិតថា ឥឡូវនេះយើងមិនអាចនឹងជានវកៈ អ្នកបួសក្នុងសង្ឃបានទេ ហើយទើបទូលសួរបញ្ហាជាអ្នកទី ១៥ ។ លំដាប់នោះ ព្រះសាស្ដាទ្រង់ជ្រាបថា ញាណរបស់លោកចាស់ក្លាហើយ ទើបទ្រង់តបបញ្ហា ។ ចប់ទេសនា លោកក៏សម្រេចព្រះអរហត្តព្រមទាំងជដិល ១.០០០ នាក់ ជាបរិវាររបស់ខ្លួន ។ ដោយទំនងនេះឯងជដិល ១៥.០០០ នាក់ ដ៏សេសក៏សម្រេចព្រះអរហត្ត សូម្បីទាំងអស់ក៏បានជាឯហិភិក្ខុ ប្រដាប់បាត្រចីវរសម្រេចមកពីឫទ្ធិ ។ តែជនដ៏សេស លោកមិនពោលដល់ ។ ព្រះមោឃរាជត្ថេរៈនេះ ក៏ទ្រទ្រង់ចីវរប្រកបដោយភាពសៅហ្មង ៣ យ៉ាង មកតាំងពីនោះ ។ ក៏រឿងតាំងឡើងក្នុងបារាយនវគ្គយ៉ាងនេះ ។ តែខាងក្រោយមក ព្រះសាស្ដាប្រថាប់ក្នុងព្រះជេតពន កំពុងទ្រង់ស្ថាបនាព្រះថេរៈទាំងឡាយទុកក្នុងតំណែងឯតទគ្គៈតាមលំដាប់ កាលនឹងទ្រង់ស្ថាបនាព្រះមោឃរាជ-ត្ថេរៈទុកក្នុងតំណែងឯតទគ្គៈជាកំពូលលើពួកភិក្ខុសាវក អ្នកទ្រទ្រង់ចីវរសៅហ្មង ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មោឃរាជជាកំពូលលើពួកភិក្ខុសាវករបស់តថាគត អ្នកទ្រទ្រង់ចីវរសៅហ្មង ។

ចប់អដ្ឋកថា សូត្រទី ១២

## ចប់អដ្ឋកថាវគ្គទី ៤

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

| | |
|---|---|
| លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស | $ 2.000 USA |
| -ភិក្ខុ ចៅ សៀប វត្តអូស្ត្រាលី | $ 500 AUS |
| -ភិក្ខុធម្មប្បញ្ញោ ជុំ សារឿន វត្តពន្លឺពុទ្ធចក្រ សហរដ្ឋអាមេរិក ព្រមទាំងពុទ្ធបរិស័ទ | $ 920 USA |
| -ឧបាសក សោម រតនៈ ព្រមទាំងភរិយា និងបុត្ត | $ 200 USA |
| -ឧបាសក តាំង សុជល ឧបាសិកា ឡុង កេង ព្រមទាំងបុត្ត និងចៅ | កុំព្យូទ័របត់មួយគ្រឿង |